# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



រូបថត JSRC=SVA

ឆ្នាំទី ៥៣ លេខ ១ ខែ មករា - កុម្ភៈ - មីនា

ព.ស ២៥៤២ គ.ស ១៩៩៩

ភ្នំពេញ

គ្របមុខ : សម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម អគ្គាធិការនៃពុទ្ធិកសិក្សា មានពុទ្ធដីកាណែនាំអំពីការប្រើប្រាស់គម្ពីរព្រះត្រៃបិដក នៅក្នុងសិក្ខាសាលា ស្តីពី « ការលើកកំពស់ការប្រតិបត្តិពុទ្ធសាសនា » នៅវត្តជម្ពូព្រឹក្សា ឃុំសង្ឃ័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ ( រូបថត JSRC=SVA )

ពុទ្ធសាសនបណ្ឌិត្យ
អំណោយសក់ថ្មី



# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

COMMISSION DES MŒURS & COUTUMES

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

គ.ស ១៩៩៩

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ភ្នំពេញ ។

យើងខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្ដីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាពរវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្បធម៌ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

## Acknowledgement

The *Kambujasuriya Magazine* is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC=SVA), Phnom Penh.

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ

I. អត្ថបទរដ្ឋបាល

• សេចក្ដីសំរេចស្ដីពីការបែងចែកភារកិច្ចថ្នាក់ដឹកនាំក្រសួង ............ ១

II. អក្សរសាស្ត្រពុទ្ធសាសនា

• សុខោបាយកថា ( ព្រះអាចារ្យ ទូច ឡេង ) ............ ៣

III. អក្សរសាស្ត្រទូទៅ

• តួនាទីរបស់ពុទ្ធសាសនា នៃកម្ពុជា ( ឱម ខែម ) ............ ១២
• អ្វីជា KHMEROLOGY ? ( ពៅ សាវរស ) ............ ២៧
• សិលាប្រាសាទចក និងព្រះបាទជយវម្មទី៣ ( ហាម ឆាយលី ) ............ ៤៤
• បច្ឆាមរណនាម និងនាមព្រះមហាក្សត្រខ្មែរ នៅសម័យអង្គរ
តាមសិលាចារឹក ( វង់ សុធារ៉ា ) ............ ៥៥
• រឿងព្រះមហាសុបក្សីតាបស ( ធន់ ហ៊ិន ) ............ ៦៩
• ប្រវត្តិក្រុងពាលី ( អាំ ឆន ) ............ ៩៤

IV. កំណត់ និង ប្រវត្តិការណ៍

• សេចក្ដីប្រកាសរួមរបស់សិក្ខាសាលា ស្ដីពី « ការលើកកំពស់
ការប្រតិបត្តិពុទ្ធសាសនា » នៅខេត្តស្វាយរៀង ............ ១០០
• ទស្សនកិច្ចរបស់គណៈប្រតិភូ WCRP ............ ១០៤
• ពិធីប្រគល់សៀវភៅ ... នៅខេត្តកំពង់ធំ ............ ១០៧

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងធម្មការ និងសាសនា

លេខ : ១៩ / ក.ធ.ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ, ថ្ងៃទី ២៥ មករា ឆ្នាំ ១៩៩៩

# សេចក្ដីសំរេច

ស្ដីពីការបែងចែកភារកិច្ចថ្នាក់ដឹកនាំក្រសួងធម្មការ និងកិច្ចការសាសនា

- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត/១១៩៨.៨៨ ចុះថ្ងៃទី ៦ ខែ ធ្នូ ១៩៩៨ ស្ដីពីការតែងតាំងឥស្សរជន ១៣២ រូប ជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា
- ដើម្បីធានាការដឹកនាំល្អ និងប្រសិទ្ធភាពខ្ពស់នូវរាល់ភារកិច្ចដែលរាជរដ្ឋាភិបាល និងរដ្ឋសភាប្រគល់ជូន

## សំរេច

ប្រការ ១ : - ឯកឧត្ដម ជា សាវឿន រដ្ឋមន្ត្រី ទទួលបន្ទុកគ្រប់គ្រង និងដឹកនាំរួមរាល់កិច្ចការក្នុងក្រសួង និងដោយឡែកទទួលបន្ទុកគ្រប់គ្រង និងដឹកនាំនាយកដ្ឋានរដ្ឋបាល, ហិរញ្ញវត្ថុ និងអធិការដ្ឋាន ។

- ឯកឧត្ដម ស្រី វ័ណ្ណផង់ រដ្ឋលេខាធិការ ទទួលបន្ទុកគ្រប់គ្រង និងដឹកនាំអគ្គនាយកដ្ឋានធម្មការ ។
- ឯកឧត្ដម ឈន អៀម រដ្ឋលេខាធិការ ទទួលបន្ទុកគ្រប់គ្រង និងដឹកនាំពុទ្ធសាសនបណ្ឌិត្យ, ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងអធិការដ្ឋានពុទ្ធិកសិក្សា ។

- ឯកឧត្តម អ៊ុស្មាឯល ឧស្មាន អនុរដ្ឋលេខាធិការ ទទួលបន្ទុកនាយកដ្ឋានពាហិរសាសនា ។
- ឯកឧត្តម ដោក ណារិន អនុរដ្ឋលេខាធិការ ទទួលបន្ទុកអធិការដ្ឋានពុទ្ធិកសិក្សា និងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។
- ឯកឧត្តម គ្រួច សារី អនុរដ្ឋលេខាធិការ ទទួលបន្ទុកនាយកដ្ឋានអប់រំផ្សព្វផ្សាយធម្មទេសនា និងនាយកដ្ឋានធម្មការ ។
- ឯកឧត្តម សៅ វ៉ន អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធសាសនបណ្ឌិត្យ
- ឯកឧត្តម ហ្សាការីយ៉ា អាដាម អនុរដ្ឋលេខាធិការ ទទួលបន្ទុកអធិការដ្ឋាន ។

ប្រការ ២ : ក្នុងការដោះស្រាយការងារសំខាន់ៗក្នុងក្រសួង ឯកឧត្តមរដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំង ២ រូប ត្រូវជួបប្រជុំគ្នាដើម្បីសំរេច ។

ប្រការ ៣ : ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកដ្ឋានធម្មការ នាយកខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង គ្រប់មន្ទីរធម្មការ និងសាសនាខេត្ត - ក្រុង ត្រូវអនុវត្តតាមសេចក្ដីសំរេចនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា **ជា សាវឿន**

ចម្លងថ្វាយ និងជូន :
- សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលា ខេត្ត - ក្រុង

" ដើម្បីថ្វាយ និងជូនជ្រាប "
- ដូចប្រការ ៣ " ដើម្បីអនុវត្ត "
- ឯកសារ, កាលប្បវត្តិ

# សុខោបាយកថា(*)

ព្រះអាចារ្យ **ធូច ធ្មេង**
វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណា សូមបង្អោនកាយ វាចា ចិត្ត ក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្ដីគោរព ។

លំដាប់តពីនេះទៅ អាត្មាភាពសូមសំដែងនូវព្រះសទ្ធម្មទេសនា ដើម្បីបំភ្លឺការសុខ-ទុក្ខគ្រប់ជំពូក តាមរបៀបច្បាប់ព្រះពុទ្ធសាសនា ដែលមានចារឹកទុកក្នុងព្រះត្រៃបិដក ផ្សាយចែកជូនដល់អស់លោក-អ្នកកាន់ព្រះពុទ្ធសាសនា ដោយសង្ខេបដូចតទៅនេះ :

សព្វសត្វទាំងឡាយ សុទ្ធតែស្វែងរកសេចក្ដីសុខគ្រប់ៗប្រាណ តែមិនងាយនឹងបានជួបប្រទះនូវសេចក្ដីសុខនោះសោះ ដូចយ៉ាងខេមរជនយើងនេះ ច្រើនតែជួបប្រទះនូវសេចក្ដីទុក្ខលំបាកច្រើនជាងជនជាតិនានា នោះមិនមែនមកពីយើងកាន់ព្រះពុទ្ធសាសនាទេ ប្រាកដជាមកពីយើងមិនដឹងច្បាប់ព្រះពុទ្ធសាសនាឱ្យច្បាស់លាស់ ឬក៏ដឹងដែរ តែយើងមិនប្រតិបត្តិតាមឱ្យសព្វគ្រប់ បានជាយើងឃ្លាងចាកសុខដែលគួរបានអំពីផ្លូវព្រះពុទ្ធសាសនា ។

ហេតុនេះ អាត្មាភាពសូមពណ៌នាអំពីផ្លូវសុខ ។ ពាក្យថាសុខ, សុខនេះបានដល់សេចក្ដីសប្បាយ រីករាយ ធូរទូលាយ ស្រួលកាយ ស្រណុកចិត្ត ។ ឯសុខសំរាប់

(*) ដកស្រង់ និងសម្រួលពីអត្ថបទធម្មទេសនាផ្សាយតាមវិទ្យុនៃប្រទេសកម្ពុជា ពីថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំជូត សំរឹទ្ធិស័ក ព.ស ២៤៩១ (២២-៥-៤៨) និងចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ២ គ.ស ១៩៥២ ។ ឱម ខែម

មនុស្សជាតិក្នុងសកលលោកនេះ លោកចែកចេញជា ៦ ពួកគឺ :

១. សុខរបស់អ្នកគ្រប់គ្រងផ្ទះ ;

២. សុខរបស់មនុស្សមួយរូបៗ ;

៣. សុខរបស់អ្នកមានប្តីប្រពន្ធ ;

៤. សុខរបស់អ្នកជាមាតាបិតា និងកូនប្រុស-ស្រី ;

៥. សុខរបស់អ្នកជានាយចៅហ្វាយ និងកូន-ក្មួយ ;

៦. សុខរបស់គ្រូអាចារ្យ និងកូនសិស្ស ។

សូមអធិប្បាយមួយពួកម្តងៗ ដោយសេចក្តីសង្ខេបដូចតទៅនេះ :

• **សុខរបស់អ្នកនៅគ្រប់គ្រងផ្ទះ** - ជនជាគ្រហស្ថអ្នកមានផ្ទះសំបែង ក្រុមគ្រួសារ នៅក្នុងស្រុកភូមិមួយៗនោះ លុះត្រាតែបានប្រព្រឹត្តប្រតិបត្តិនូវ « ឃរាវាសធម៌ » ទើបកើតសុខ ។ ឃរាវាសធមនោះមាន ៤ យ៉ាងគឺ :

*១. សច្ចៈ* ត្រូវប្រតិបត្តិរក្សាសេចក្តីពិតត្រង់ និងមិនកុហកបោកបញ្ឆោតគ្នា ដោយផ្លូវលក់ដូរជំនួញជួញប្រែផ្សេងៗ ជាដើម ។

*២. ទមៈ* ត្រូវប្រតិបត្តិបន្ទន់កាយ វាចា ចិត្តឱ្យទន់ភ្លន់ និងមិនរំលោភបំពានទៅរកគ្នា ដោយកំលាំងលោភៈ ទោសៈ ជាដើម ។

*៣. ខន្តី* ត្រូវមានអំណត់អត់ធន់ មិនខឹងចំពោះអ្នកនៅរួម និងអត់ធន់ចំពោះការងារដ៏លំបាកៗ ដែលខ្លួនត្រូវធ្វើ ដូចកសិកម្ម ឬពាណិជ្ជកម្ម ជាដើម ។

*៤. ចាគៈ* ត្រូវលះវត្ថុឱ្យជាប្រយោជន៍ដល់អ្នកនៅជាមួយ ដែលគួរចែកជាដើម ។

• **សុខរបស់មនុស្សមួយរូបៗ** - មនុស្សម្នាក់ៗដែលតាំងចិញ្ចឹមជីវិតខ្លួនឱ្យរស់នៅបានសុខក្នុងបច្ចុប្បន្ននោះ លុះត្រាតែប្រកបដោយសុខរបស់អ្នក

រស់នៅ ៤ យ៉ាង គឺៈ

*១. សុខកើតអំពីមានទ្រព្យសម្បត្តិដ៏បរិបូណ៌* ។ ឯទ្រព្យសម្បត្តិរបស់បុគ្គលម្នាក់ៗ ដែលពេញបរិបូណ៌បាននោះ លុះតែប្រកបដោយសម្បទា ៤ យ៉ាងទៀត គឺ ត្រូវមានការប្រឹងប្រែងខ្នះខ្នែងស្វែងរកភោគសម្ប័ទឱ្យបានច្រើន តាមផ្លូវសម្មា-អាជីវោ ១, ត្រូវចេះរក្សាថែទាំទ្រព្យសម្បត្តិ ដែលរកបានមកនោះឱ្យគង់វង្សនៅឋិតថេរល្អ ១, ត្រូវចេះសេពគប់មិត្តល្អៗ គឺលោកបណ្ឌិត និងលោកស័ក្តិធំៗ ឱ្យបានជាទីទំនុកទុកចិត្ត ១, ត្រូវចេះចាយធនធានឱ្យមានប្រយោជន៍ និងចេះលៃលកចាយឱ្យសមល្មមតាមកំលាំងដែលរកបាន គឺមិនចំណាយចាយវាយខ្ជះខ្ជាយឱ្យហួសកំលាំងដែលរកបាន ១ ។

*២. សុខកើតអំពីបានចាយទ្រព្យ* ។ ជនខ្លះមានទ្រព្យមិនចេះចាយ, អ្នកចេះចាយតែងចាយទំនុកបំរុងលោកមាតាបិតារបស់ខ្លួនឱ្យបានសុខរីករាយផង, ចាយចិញ្ចឹមគ្រួសារឱ្យបានរុងរឿងផង, ចាយក្នុងកាលដែលខ្លួនមានទោសគ្រោះថ្នាក់ផង ។

*៣. សុខកើតអំពីមិនមានជំពាក់បំណុលគេ* ។ កាលដែលមិនជំពាក់បំណុលគេនោះ លុះតែបុគ្គលនោះវៀរបង់ទោសពីរយ៉ាងគឺ ៖ ជាអ្នកមិនបង្កហេតុឱ្យកើតក្តីក្តាំដល់គ្នានឹងគ្នា ១, មិនប្រព្រឹត្តអបាយមុខដែលជាគ្រឿងវិនាស មានលេងស្រី-ស្រា-បៀ-ប៉ោ ជាដើម ១ ។

*៤. សុខកើតអំពីប្រកបការងារប្រាសចាកទោស* ។ ការដែលប្រកបការងារប្រាសចាកទោសនោះ លុះតែជាអ្នកប្រតិបត្តិឱ្យល្អត្រឹមត្រូវតាមច្បាប់រដ្ឋ មានមិនប្រព្រឹត្តចោរកម្មលួចប្លន់ ជាដើម ។

• **សុខរបស់អ្នកមានប្តី-ប្រពន្ធ**- បុរសស្ត្រីដែលបានគ្នាជាគូស្រករហើយ ត្រូវប្រតិបត្តិធម៌ប្រាំៗម្នាក់ ទើបកើតសុខដល់គ្នាបាន គឺប្តីត្រូវទំនុកបំរុងប្រពន្ធ

របស់ខ្លួន ដោយធម៌ ៥ យ៉ាងគឺ ៖

១. ត្រូវរាប់អានលើកមុខប្រពន្ធថាជាប្រពន្ធពិតប្រាកដ ;

២. ត្រូវកុំមើលងាយប្រពន្ធរបស់ខ្លួន ដូចជាទាសី ;

៣. ត្រូវកុំក្បត់ចិត្តប្រពន្ធដោយមានស្រីដទៃទៀត ;

៤. ត្រូវប្រគល់ការងារក្នុងផ្ទះឱ្យប្រពន្ធត្រួតត្រា ;

៥. ត្រូវរកគ្រឿងអលង្ការឱ្យប្រពន្ធ ។

ចំណែកប្រពន្ធ ត្រូវប្រតិបត្តិស្វាមីដូចជាទេវតាក្នុងផ្ទះ ត្រូវគោរពស្វាមី ដោយធម៌ ៥ យ៉ាងគឺ ៖

១. ត្រូវចេះតាក់តែងភោជនាហារឱ្យមានឱជារសឆ្ងាញ់ពិសាជូនស្វាមី ដូចជានាង « អមរា » កាលចាត់ចែងបំរើព្រះមហោសថជាស្វាមីរបស់នាងដូច្នោះ ;

២. ត្រូវរាប់អានញាតិមិត្ត-វង្សត្រកូលខាងស្វាមី ;

៣. ត្រូវកុំក្បត់ចិត្តប្ដីដោយមានប្រុសដទៃ ;

៤. ត្រូវចេះថៃទាំទ្រព្យសម្បត្តិដែលស្វាមីរកបានមក យកទៅទុកដាក់ឱ្យស្រួលបួលល្អ គឺមិនមែនជាស្រីខ្ជះខ្ជាយ ;

៥. ត្រូវជាស្រីឈ្លាសវៃក្នុងការគ្រប់គ្រងផ្ទះ និងជាអ្នកមិនខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង គឺជួសជុល ដេរ ប៉ះ គ្រីប ប៉ាក់ ចាក់ អន្លង ត្បាញ រវៃ, ការខាងស្រីទាំងប៉ុន្មាន ត្រូវឱ្យចេះស្ទាត់ទាំងអស់ ។

• **សុខរបស់អ្នកជាមាតាបិតា និងកូនប្រុស-ស្រី** - ជនជាមាតាបិតាអាចទទួលសុខពីកូនប្រុស-ស្រីបាននោះ លុះតែបានសង្គ្រោះកូនដោយធម៌ ៥ យ៉ាងគឺ ៖

១. ត្រូវហាមឃាត់កូនកុំឱ្យធ្វើអំពើអាក្រក់ឱ្យសោះ, ត្រូវខំបង្ហាត់ ពត់បង្វឹកកូនតាំងពីនៅតូចៗ ឱ្យមានសណ្ដាប់ធ្នាប់ល្អ ;

២. ត្រូវដឹកនាំកូនឱ្យតាំងនៅក្នុងសុចរិតទាំង ១០ មានកាយសុចរិតជាដើម ;

៣. ត្រូវដឹកនាំកូនប្រុស-ស្រី ឱ្យរៀនតម្រិះវិជ្ជាផ្លូវលោក ផ្លូវធម៌ ឱ្យបានចេះដឹង ត្រូវទំនុកបំរុងកូនឱ្យចូលសាលា សិក្សាឱ្យចេះដឹងអក្សរសាស្ត្រ ភាសា-សាស្ត្រ លេខ-ក្បាច់-នព្វន្ត-ជញ្ជីង-នាឡិ-ហាប-រង្វាស់រង្វាល់ ក្បួនច្បាប់ សំរាប់លោកិយគ្រប់ផ្លូវ ។ ត្រូវស្រឡាញ់គ្រូដែលបង្រៀនកូនរបស់ខ្លួន, ត្រូវជូនចំណីអាហារដល់គ្រូរបស់កូននោះ តាមរដូវកាលដ៏គួរ ;

៤. លុះកូនប្រុសស្រីធំចំរើនឡើងល្មមរកស្វាមីភរិយាឱ្យ គប្បីផ្សំផ្គុំឱ្យល្មមតាមវង្សត្រកូលរបស់ខ្លួន ;

៥. ត្រូវបែងចែកទ្រព្យមរតកឱ្យកូនប្រុស-ស្រី ឱ្យមានគ្រឿងសំគាល់ជាប្រាកដ ឱ្យកូនមានឋានៈល្អ តាំងពីខ្លួននៅរស់ ដើម្បីការពារសេចក្តីសុខដល់កូន ។

ចំណែកកូនប្រុស-ស្រី ត្រូវគោរពមាតាបិតា ដោយកិច្ចតបគុណូបការធម៌ ៥ យ៉ាងគឺ :

១. ត្រូវចិញ្ចឹមមាតាបិតាឱ្យបានរស់នៅជាសុខ ឱ្យដូចជាលោកចិញ្ចឹមខ្លួន ;

២. បើមាតាបិតាកំពុងប្រកបកិច្ចការណា យើងជាកូនត្រូវនាំគ្នាជួយធ្វើកិច្ចការនោះជូនលោក, បើលោកចាស់ជរា ត្រូវថែទាំរក្សាបំរើដោយទឹកក្តៅត្រជាក់គ្រប់យ៉ាង, វេលាមាតាបិតាចូលដំណេក ត្រូវគក់ច្របាច់ ដកជើងដៃ និងរឹតសសៃជូនលោក, វេលាលោកមានជំងឺ ត្រូវមើលព្យាបាលដោយថ្នាំពេទ្យប្រចាំការ ;

៣. ត្រូវរក្សាវង្សត្រកូលរបស់មាតាបិតាឱ្យតាំងនៅល្អ ;

៤. ត្រូវប្រតិបត្តិខ្លួនឯងឱ្យបានសមរម្យ ល្មមឱ្យមាតាបិតាទំនុកបំរុង ទុកចិត្តបាន ជាអ្នកគួរទទួលយកទ្រព្យកេរមរតកបាន ល្មមលោកចែកឱ្យដោយងាយ ;

៥. វេលាមាតាបិតាធ្វើកាលកិរិយាទៅ កូនប្រុស-ស្រីត្រូវនាំគ្នាធ្វើសរីរ-កិច្ចតាមធនធានគ្រប់គ្នា រួចត្រូវធ្វើបុណ្យទក្ខិណានុទិ្ទសផ្សាយផលជូនដល់លោក ។

ឯកិច្ចទាំង ៥ យ៉ាងនេះ បើកូនប្រុស-ស្រីណាបានធ្វើហើយ កូនប្រុសស្រីនោះ លោកហៅថាជាអ្នក « កតញ្ញូកតវេទី » ។

• **សុខរបស់លោកជានាយចៅហ្វាយ និងកូនក្មួយ** - ពួកជនដែលនៅជ្រកកោន ឬធ្វើការស៊ីឈ្នួល នៅក្រោមបង្គាប់របស់លោកជានាយចៅហ្វាយណា នាយចៅហ្វាយនោះត្រូវសង្គ្រោះដល់បាវព្រាវ ឬកូនក្មួយនោះ ដោយធម៌ ៥ យ៉ាងគឺ :

១- ត្រូវចេះចាត់ចែងការឱ្យស្ទាត់ជំនាញ ហើយចេះលៃលកការឱ្យសមគួរដល់កំលាំង និងតម្រិះវិជ្ជា ដែលបាវព្រាវ កូនក្មួយល្មមធ្វើបាន ;

២- ត្រូវតាំងចិត្តអាណិតបាវព្រាវ កូនក្មួយ ឱ្យស្មើៗគ្នា, ត្រូវចែករង្វាន់ប្រាក់កាសឱ្យបរិភោគ ចាយវាយល្មមគ្រប់គ្រាន់ ;

៣- ត្រូវថែទាំបាវព្រាវ កូនក្មួយ ក្នុងវេលាមានជំងឺឈឺចាប់ ត្រូវជួយព្យាបាលថ្នាំ និងរកពេទ្យឬ, ជួយការពារក្នុងវេលាមានទោសទុក្ខ គ្រោះថ្នាក់ផ្សេងៗ ;

៤- ត្រូវចែកលាភសក្ការៈ និងអាហារដែលមានឱជារសប្លែកៗ ឱ្យបាវព្រាវកូនក្មួយបរិភោគផង ;

៥- ត្រូវបើកឱ្យបាវព្រាវ កូនក្មួយ បានសប្បាយតាមរដូវ និងមានពេលឈប់សំរាក មានរដូវចូលឆ្នាំ ជាដើម ។

ចំណែកបាវព្រាវ កូនក្មួយ ត្រូវប្រតិបត្តិលោកនាយចៅហ្វាយ ដោយធម៌ ៥ យ៉ាងដែរ គឺ :

១- ត្រូវក្រោកឡើងធ្វើការមុននាយចៅហ្វាយ ជាអ្នកមិនខ្ជិលច្រអូសប្រចែប្រចាំនឹងនាយចៅហ្វាយឡើយ ;

២- ត្រូវធ្វើការងារជាខាងក្រោយនាយចៅហ្វាយ មិនហ៊ានផ្ដើមការងារមុននាយចៅហ្វាយ លុះតែការណាដែលលោកអនុញ្ញាតឱ្យ ទើបធ្វើការនោះបាន ;

៣. ត្រូវទទួលយកតែរបស់ដែលនាយចៅហ្វាយឱ្យ ;

៤. ត្រូវធ្វើការងារឱ្យត្រឹមត្រូវល្អ ជូននាយចៅហ្វាយ ;

៥. បាវព្រាវ កូនក្មួយ ត្រូវនាំយកគុណសម្បត្តិ និងសមត្ថភាពរបស់នាយចៅហ្វាយ ទៅសរសើរអួតប្រាប់ក្នុងទីប្រជុំជន និងមិត្តអាមាត្យធំៗ ជាដើម ។

• **សុខរបស់គ្រូ និងកូនសិស្ស** - គ្រូដែលគួរទទួលសុខអំពីកូនសិស្សបាននោះ លុះតែសង្គ្រោះកូនសិស្សដោយធម៌ ៥ យ៉ាងគឺ :

១. ត្រូវដឹកនាំសិស្សឱ្យរៀនដោយល្អ ត្រូវញ៉ាំងសិស្សឱ្យតាំងចិត្តប្រកបដោយសុចរិត យុត្តិធម៌ យ៉ាងចំណាន ឬថ្លៃថ្នូរ ;

២. ត្រូវដឹកនាំសិស្សឱ្យរៀនច្បាប់ផ្លូវលោក ផ្លូវធម៌ ឱ្យចេះចំណានដើម្បីរក្សាជាតិ សាសនា មហាក្សត្រ ;

៣. ត្រូវបង្ហាត់បង្ហាញសិល្បវិជ្ជាដល់សិស្សឱ្យអស់តម្រិះពីខ្លួន មិនលាក់លៀមទុក ;

៤. ត្រូវលើកតម្កើងសិស្សក្នុងទីប្រជុំមិត្តអាមាត្យ មិនបន្ទោស បង្អាប់សិស្សក្នុងទីប្រជុំជន ;

៥. ត្រូវធ្វើសេចក្តីការពារសិស្សក្នុងទិសទាំងពួងថា មិនឱ្យសិស្សលំបាកដោយអាហារជាដើម ក្នុងវេលាមានដំណើរទៅកាន់ទិសទាំងពួង ។

ចំណែកយុវជន យុវនារី ជាសិស្សទាំងឡាយ ត្រូវនាំគ្នាប្រតិបត្តិគោរពគ្រូអាចារ្យរបស់ខ្លួន ដោយធម៌ ៥ យ៉ាងគឺ :

១. សិស្សត្រូវនាំគ្នាធ្វើសេចក្តីគោរពចំពោះគ្រូអាចារ្យរបស់ខ្លួន មានការបបួលគ្នាក្រោកទទួលគ្រូ ជាដើម ;

២. សិស្សត្រូវនាំគ្នាចាំបំរើគ្រូដោយកិច្ចការផ្សេងៗក្តី មិនមានកិច្ចការអ្វីក្តី មានទឹកក្តៅត្រជាក់ជានិច្ច ជាដើម ;

៣. សិស្សត្រូវនាំគ្នាទំនុកបំរុងគ្រូ ; ពេលណាដែលគ្រូមានអាពាធ ឬជំងឺ សិស្សត្រូវរកថ្នាំ ឬពេទ្យហ្ម មកព្យាបាលគ្រូ និងជូនចំណីអាហារផ្សេងៗដល់គ្រូរបស់ខ្លួនជារឿយៗ ក្នុងរដូវម្ដងមួយកាល ឬក៏រដូវចូលឆ្នាំថ្មីជាដើម ;

៤. សិស្សត្រូវជឿឱវាទដែលគ្រូប្រៀនប្រដៅ គឺត្រូវយកចិត្តទុកដាក់ស្ដាប់ឱ្យបានការ ដើម្បីយកទៅធ្វើជាច្បាប់ទម្លាប់របស់ខ្លួន ឱ្យចេះចាំប្រាកដ ចូលចិត្តឱ្យច្បាស់លាស់ ;

៥. សិស្សត្រូវនាំគ្នារៀនសូត្រដោយគោរព, ពាក្យថារៀនសូត្រដោយគោរពនោះ គឺត្រូវខំប្រឹងប្រែងខ្នះខ្នែងរៀនសូត្រ មិនខ្ជិលច្រអូសក្នុងការសិក្សា បើសិក្សាវិជ្ជាណាៗ ត្រូវឧស្សាហ៍ទន្ទេញឱ្យចេះចាំស្ទាត់រត់មាត់, ចូលចិត្តច្បាស់លាស់ក្នុងការសិក្សាវិជ្ជានោះៗ ទើបឈ្មោះថារៀនសូត្រដោយគោរព ។

ហៃយុវជន យុវនារីទាំងឡាយ, អ្នកត្រូវការសិក្សាសិល្បសាស្ត្រ អក្សរសាស្ត្រ វិទ្យាសាស្ត្រ និងនព្វន្តសាស្ត្រ-លេខ ជាដើម ត្រូវនឹកពិចារណាដល់ច្បាប់លោកនីតិបករណ៍ថា :

កុំមើលងាយមន្តសិល្បសាស្ត្រា គិតថាតិចតួចក្រែងមិនស្រេច
វិជ្ជាមួយមែនបើមិនភ្លេច គង់នឹងសំរេចប្រយោជន៍បាន ។
ចេះមួយចេះពីរឱ្យតែស្ទាត់ ប្រកបប្រាកដអ្នកចំណាន
ជាហេតុចិញ្ចឹមជីវិតបាន សន្ដានជួលពីងពំនឹងអឺយ ។
សិល្បសាស្ត្រឯណាមិនស្ទាត់ពិត នៅក្នុងស្លឹករឹតឬសៀវភៅ
ទ្រព្យធនឯណាដែលមាននៅ ធ្លាក់ទៅក្នុងដៃអ្នកដទៃ ។
បើមានកិច្ចការណាមកដល់ សិល្បទ្រព្យនោះយកមកអាស្រ័យ
ពុំបានដូចចិត្តដ្បិតឆ្ងាយដៃ សិល្បទ្រព្យនោះនៃហៅគ្មានបោង ។

**សុភាសិតថា :**

មានទ្រព្យលើកឱ្យគេខ្ចីទៅ ពម្រិះចេះនៅតែក្នុងក្បួន
ប្រពន្ធនៅឆ្ងាយអំពីខ្លួន ដល់ជូនត្រូវការររអាចិត្ត ។

•

ធម៌ទេសនាសំដែងមកនេះ ដើម្បីឱ្យខេមរជនទាំងឡាយស្ទុះក្រោកឡើងខំប្រឹងប្រែងស្វែងរកសេចក្ដីសុខដល់ខ្លួន និងដល់ជាតិប្រទេសក្នុងបច្ចុប្បន្ននេះ សូមសន្មតថាចប់តែប៉ុណ្ណេះ ឯរ ។

ដោយអំណាចនៃធម៌ទេសនានេះ សូមឱ្យជាតិ សាសនា មហាក្សត្រ នៃខេមរជាតិយើង ចំរើនសេចក្ដីសុខគ្រប់ប្រការ អស់កាលដ៏យូរអង្វែងតទៅ !

***

**ជោគវាសនាញញឹមទទួល**
**ចំពោះតែអ្នកមានសេចក្ដីក្លាហាន**

----------

អ្នកចិត្តក្លាហានបានជួយជាតិ
ឃិតយោងឱ្យឃ្លាតទាសភាព
រមែងមានឈ្មោះខ្ពស់ដរាប
បើទុកដុនដាបគង់ទេពជួយ ។

យ.អ

# តួនាទីរបស់ ពុទ្ធសាសនានៅកម្ពុជា (*)

ដោយ **ឱម ខែម**

## I. សេចក្តីផ្តើម

តាំងពីបុរាណកាលរៀងមក ព្រះពុទ្ធសាសនាមានតួនាទីជាប្រវត្តិសាស្ត្រ ដោយបានរួមចំណែកដល់ភាពថ្កុំថ្កើង និងកិត្យានុភាពនៃមាតុភូមិអង្គរ, ដោយបានថែរក្សា លើកតម្កើងអត្តសញ្ញាណជាតិកម្ពុជា ភាសា អក្សរសាស្ត្រ វប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរដ៏ល្អបវរ ព្រមទាំងបង្ហាញផ្លូវរស់នៅដ៏សុខសាន្តដល់ខេមរជនគ្រប់រូប អោយដើរឆ្ពោះទៅកាន់សន្តិភាព វិបុលភាព និងសុភមង្គល ដោយចៀសវាងអំពើហិង្សា អកុសល បាបកម្ម ផងទាំងឡាយ ។

ក្នុងដំណើរវែងឆ្ងាយ បត់បែនក្នុងប្រវត្តិសាស្ត្រជាតិយើង, ព្រះសង្ឃ និងពុទ្ធសាសនិកជនបានស្មោះស្មគ្រ ប្តូរផ្តាច់ទ្រទ្រង់ព្រះពុទ្ធសាសនាអោយបានរីកចំរើនសមស្របនឹងតថភាពសង្គមជាតិ ហើយមានដំណើរឆ្ពោះទៅមុខ ទន្ទឹមគ្នានឹងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ ។ ទាំងនេះបានបង្កើតឡើងនូវមោទនភាព និងមានឥទ្ធិពលស៊ីជម្រៅ ជ្រួតជ្រាប ក្នុងដួងចិត្តនៃជនកម្ពុជាគ្រប់រូប គ្រប់ស្រទាប់វណ្ណៈ គ្រប់ទិសទី រហូតដល់មានការទទួលស្គាល់ជាផ្លូវការជាសាសនារបស់រដ្ឋ ។

---

(*) ឯកសារពិគ្រោះ :

- ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា សង្ខេប . សម្តេចព្រះពោធិវង្ស ហួត តាត / ១៩៧០
- បទអន្តរាគមន៍របស់ក្រុមសាសនា ក្នុងសិក្ខាសាលាអន្តរជាតិ ស្តីពីបាតុភូតនៃការប្រល័យពូជសាសន៍ និងការទប់ស្កាត់មិនអោយវិលត្រឡប់វិញ ។
- ពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ ។ • វចនានុក្រមខ្មែរ របស់ពុទ្ធសាសនបណ្ឌិត្យ

ដោយសារតែសង្គ្រាមបង្ហិនបង្ហោចជាងពីរទសវត្ស ហើយធ្ងន់ធ្ងរបំផុតក្នុងចន្លោះឆ្នាំ ១៩៧៥ - ១៩៧៩ ប្រភពធនធានវប្បធម៌ស្ទើរតែទាំងអស់ ត្រូវទទួលរងការបំផ្លិចបំផ្លាញ ។ នៅក្នុងចំណោមធនធានទាំងនោះ ពុទ្ធសាសនាដែលជាមូលដ្ឋានគ្រឹះនៃវប្បធម៌របស់ជនជាតិខ្មែរ ត្រូវរងការបំផ្លាញយ៉ាងធំធេង ។ ព្រះសង្ឃជាច្រើនម៉ឺនអង្គ ត្រូវធ្វើគត់ ។ ប្រាសាទបុរាណ និងវត្តអារាម ត្រូវបោះបង់ចោល និងកំទេចអោយបាក់បែក ខ្ទេចខ្ទាំ ។ គម្ពីរ ដីកា និងសាស្ត្រា សៀវភៅផ្សេងៗ ត្រូវបានគេរើកកាយ និងដុតអោយទៅជាផេះផង់ ។

តទៅនេះ យើងនឹងលើកយកប្រធានបទ ដែលថា « តួនាទីរបស់ពុទ្ធសាសនា នៅកម្ពុជា » ភ្ជាប់ទៅនឹងផលវិបាកនៃការលុបបំបាត់ពុទ្ធសាសនា ក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ព្រមទាំងបច្ចុប្បន្នភាពនៃពុទ្ធសាសនា ក្រោយឆ្នាំ ១៩៧៩ មកពិចារណា ។

ពុទ្ធសាសនានៅកម្ពុជា មានតួនាទីសំខាន់ណាស់ មិនគ្រាន់តែនៅក្នុងការអប់រំសីលធម៌ប៉ុណ្ណោះទេ ថែមទាំងនៅក្នុងការថែរក្សាសិល្បៈ វប្បធម៌ អក្សរសាស្ត្រជាតិ និងនៅក្នុងកិច្ចការសង្គមទាំងមូលផង ។

ប្រជាជនកម្ពុជា មានជំនឿ និងគោរពបូជាព្រះពុទ្ធសាសនា ដើម្បីកសាងកុសលផង ដើម្បីសេចក្តីសុខចំរើនរបស់ខ្លួនម្នាក់ៗផង និងដើម្បីជាប្រយោជន៍ដល់សង្គមទាំងមូលផង ។

## II. តួនាទីរបស់ពុទ្ធសាសនា នៅកម្ពុជា

តួនាទីរបស់ពុទ្ធសាសនាគឺ តួនាទីរបស់វត្តអារាម របស់ព្រះសង្ឃ និងតួនាទីនៃការអប់រំខាងសីលធម៌ ។

ដោយមានជំនឿយ៉ាងមោះមុតលើពុទ្ធសាសនា ប្រជាជនបានផ្សារភ្ជាប់ជីវិតរបស់គេទៅនឹងព្រះពុទ្ធសាសនា ។ កន្លែងណាដែលមានប្រជាជនរស់នៅកុះករ

កន្លែងនោះតែងមានវត្តអារាម និងមានភិក្ខុ-សាមណេរ បំរើកិច្ចការពុទ្ធសាសនា ។

ចំពោះប្រជាជនកម្ពុជា, វត្តអារាមមានតួនាទីសំខាន់ ដូចតទៅ :

. វត្តជាទីតាំងនៃព្រះពុទ្ធសាសនា ដែលពុទ្ធសាសនិកទុកជាទីពឹងពំនាក់ ជាបង្អែកខាងផ្លូវចិត្ត ។

. វត្តជាទីកន្លែងសំរាប់ផ្តល់នូវបុណ្យកុសលគ្រប់បែបយ៉ាង ។

. វត្តជាកន្លែងអប់រំកាយ-ចិត្តផង ជាទីសក្ការៈផង ។ ប្រជាជនកម្ពុជានិយមធ្វើពិធីបុណ្យផ្សេងៗ ដែលជាប្រពៃណីពុទ្ធសាសនាក្តី ជាទំនៀមទំម្លាប់របស់ប្រជា-ជនក្តី នៅក្នុងវត្ត ដូចជាបុណ្យកឋិន ភ្ជុំបិណ្ឌ មាឃបូជា វិសាខបូជា ចូលវស្សា-ចេញវស្សា បុណ្យចូលឆ្នាំ . ល . និង . ល . ។

. វត្តជាទីកន្លែងដុសខាត់ចិត្តអោយកើតសេចក្តីជ្រះថ្លា អោយមានអារម្មណ៍ស្ងប់រំងាប់ ។

. វត្តជាទីកន្លែងបណ្តុះសិលធម៌ គុណធម៌ និងចរិយាធម៌ បណ្តុះពូជនៃបុណ្យកុសលគ្រប់យ៉ាង ដែលជាគុណសម្បត្តិនាំអោយសំរេចបាននូវសេចក្តីសុខ ។

. វត្តជាទីពឹងពំនាក់អាស្រ័យរបស់អ្នកគ្មានទីពឹង អ្នកគ្មានភ័ព្វសំណាង ទាំងខាងសម្ភារៈ ទាំងខាងស្មារតី ។

. វត្តជាទីពំនាក់អាស្រ័យរបស់សិស្សានុសិស្ស កូនចៅប្រជាជនអ្នកក្រីក្រ

. វត្តជាទីមន្ទីរពេទ្យសំរាប់ព្យាបាលជំងឺខាងផ្លូវចិត្ត ។ រាល់ពេលមានវិបត្តិខាងផ្លូវចិត្ត ប្រជាពលរដ្ឋនៅជុំវិញវត្ត តែងចូលទៅពិគ្រោះសុំយោបល់ពីព្រះសង្ឃសុំព្រះសង្ឃអោយជួយដោះស្រាយ ។ ពេលមានទុក្ខព្រួយ ក៏ទៅជួបព្រះសង្ឃ សុំអោយព្រះសង្ឃជួយពន្យល់អំពីធម៌អាថ៌តាមផ្លូវពុទ្ធសាសនា ដើម្បីរំលត់ទុក្ខព្រួយ ។ ព្រះសង្ឃជួយព្យាបាលមនុស្សដែលភ្លួតវង្វេងដោយអបាយមុខ មានល្បែង-ស្រី-ស្រា ... ឬវង្វេងដោយអំពើពាលផ្សេងៗ តាមរយៈទូន្មាន ឬតាមរយៈការបិណ្ឌបាតអោយ

ស្មុគ្រស្មាញ ត្អូញត្អែរ ។ ពេលប្រជាជនជើងវត្ត មានទំនាស់ទាស់ទែងខ្វែងគំនិតគ្នាក្នុងគ្រួសារក្តី រវាងញាតិសន្តានព្រៀងលានក្តី ក៏ព្រះសង្ឃជួយដោះស្រាយ ដោយបិណ្ឌបាតយកសេចក្តីឆ្គងវង្វេង សេចក្តីលោភ សេចក្តីក្រោធខឹង ហិង្សា នោះចេញ ។ ជួនកាលព្រះសង្ឃ ថែមទាំងអាចជួយព្យាបាលជំងឺខាងផ្លូវកាយ ដោយប្រើឱសថបុរាណថែមទៀត ។ ប្រពៃណីនេះ មានតាំងពីសម័យបុរាណ រហូតមកដល់សព្វថ្ងៃនេះ ។

. វត្តជាទីប្រជុំរបស់ប្រជាជនគ្រប់រូប គ្រប់ស្រទាប់វណ្ណៈ គ្រប់វ័យ ឥតរើសអើងពណ៌សម្បុរ ឋានៈ នាទី សង្គម ឥតប្រកាន់មានក្រ និងជំនឿផ្សេងៗ ។

. វត្តជាទីកន្លែងប្រមូលកម្លាំងសាមគ្គីទូលំទូលាយ ជួយកសាងសង្គម ។ ប្រជាជនពុទ្ធសាសនិក មិនគ្រាន់តែមានសទ្ធាក្នុងការកសាងបដិមា កសាងព្រះវិហារ កុដិ ចេតិយ សាលា ដើម្បីបំរើក្នុងពុទ្ធសាសនាប៉ុណ្ណោះទេ ថែមទាំងបានកសាងសំណង់ជាច្រើនទៀត សំរាប់ជាប្រយោជន៍សាធារណៈ ដូចជា សាលារៀន គិលានដ្ឋាន អណ្តូងទឹក ស្រះទឹក ស្ពាន ថ្នល់ ជាដើម និងដាំដើមឈើមានតម្លៃ ឈើហូបផ្លែ ឈើសំរាប់ប្រើធ្វើជាឱសថ . ល . ។ មានវត្ត គឺមានអារាម មានសួនឧទ្យានផ្តល់ម្លប់ត្រឈឹងត្រឈៃ ទាក់ទាញអ្នកដំណើរផ្លូវឆ្ងាយ និងអ្នកដែលមានកង្វល់ខាងផ្លូវចិត្តអោយចង់ចូលទៅជ្រកលំហែកាយរំសាយចិត្ត ។ វត្តអារាមក៏ជាជម្រកយ៉ាងសុខសាន្តរបស់បក្សាបក្សីផងទាំងឡាយ ។

. វត្តអារាមជាទីឃ្លាំងចំណេះចេះដឹង ជាបណ្ណាល័យ ជាសារមន្ទីរនៃវប្បធម៌ អក្សរសាស្ត្រជាតិ នៅគ្រប់សម័យកាល ។

. វត្តអារាមជាសាលាជីវិតរបស់ប្រជាជន ជាកន្លែងសិក្សាវិជ្ជាអក្សរសាស្ត្រ លេខនព្វន្ត សិល្បសាស្ត្រផ្សេងៗចាំបាច់ សំរាប់ប្រើប្រាស់ក្នុងជីវិត និងជាទីកន្លែងរៀនសូត្រអំពីវិជ្ជាខាងសាសនា មានសីលធម៌ និងចរិយាធម៌ ជាដើម ។

. វត្តអារាមជាទីបង្កើតអ្នកស្នេហាជាតិខ្មែរ ។ អ្នកនយោបាយខ្មែរជាច្រើនរូប បានទទួលការអប់រំនៅក្នុងវត្តអារាម ។

. វត្តអារាមជាកន្លែងបំផុសស្មារតីច្នៃប្រឌិត និងលើកកំពស់អ្នកមានឧប-និស្ស័យ លើកកំពស់ស្មារតីស្នេហាសិល្បៈ វប្បធម៌ជាតិ ។ អ្នកករីនិពន្ធឆ្នើមៗ និងសិល្បករល្បីៗពីបូរាណ សុទ្ធតែបានទទួលការបណ្តុះបណ្តាលនៅក្នុងវត្តទាំងអស់ ។

ដូច្នេះឃើញថា វត្តអារាមពុទ្ធសាសនា បានជួយសម្រាលបន្ទុកសេដ្ឋកិច្ចរដ្ឋមួយកម្រិត និងជួយដោះស្រាយបញ្ហាសង្គមមួយចំណែកធំ ទៀតផង ។

តួនាទីទាំងប៉ុន្មានខាងលើនេះ របស់វត្តអារាម បង្ហាញអោយឃើញថាពុទ្ធសាសនា មានសារសំខាន់ណាស់ សំរាប់ប្រជាជនខ្មែរ ។

## III. សារសំខាន់របស់ពុទ្ធសាសនា នៅកម្ពុជា

ប្រជាជនខ្មែរមិនអាចរស់នៅដោយគ្មានពុទ្ធសាសនាបានទេ ។ គេបានផ្សារភ្ជាប់ជីវិតគេទៅនឹងពុទ្ធសាសនា តាំងពីពេលកើតរហូតដល់ពេលស្លាប់ទៅវិញ ។

• ពេលកើត : គេទៅសុំព្រះសង្ឃអោយដាក់ឈ្មោះអោយទារក សុំពរពីព្រះសង្ឃ កុំអោយមានជំងឺ អោយមានអាយុវែង អោយមានសេចក្តីសុខ ។

• ពេលរៀបអាពាហ៍ពិពាហ៍ : គេត្រូវមានព្រះសង្ឃសូត្រមន្តប្រសិទ្ធពរអោយ ។

• ពេលស្លាប់ : ចាំបាច់ត្រូវមានព្រះសង្ឃ អាចារ្យសូត្រធម៌ ។ គេបូជាសពនៅក្នុងវត្ត រួចតម្កល់អដ្ឋិធាតុទុកនៅក្នុងវត្តទៀត ។

ប្រជាជនកម្ពុជា ជាប្រជាជនប្រកបដោយកតញ្ញូកតវេទិតាធម៌ ជាអ្នកដឹងគុណ និងតបស្នងសងគុណចំពោះអ្នកដែលបានធ្វើគុណចំពោះខ្លួនគេ មានមាតាបិតា និងគ្រូបាធ្យាយ ជាដើម ។ ដូច្នេះ ក្នុងមួយជីវិតរបស់គេម្នាក់ៗ ទោះបីជាក្រខ្សត់យ៉ាងណាក៏ដោយ យ៉ាងហោចណាស់ ក៏គេធ្វើបុណ្យបានម្តងដែរ ។

. ពុទ្ធសាសនា ជាសេចក្តីត្រូវការខាងស្មារតី មិនអាចខ្វះបាន,

- ពុទ្ធសាសនា ជាតុល្យភាពខាងស្មារតី និងសម្ភារៈ ធ្វើអោយប្រជាជនមានលំនឹងក្នុងជីវិត,

- ពុទ្ធសាសនា ជាសេចក្តីសង្ឃឹមរបស់ប្រជាជន,

- ពុទ្ធសាសនា ជារបស់ប្រជាពលរដ្ឋកម្ពុជា, ជាជីវិតរបស់ប្រជាជន, ជាប្រភពមិនចេះរីងស្ងួតនៃកម្លាំងសាមគ្គីរបស់ប្រជាជនទាំងមូល និងជាចរន្តប្រជាប្រិយខាងវប្បធម៌ អក្សរសាស្ត្រជាតិ,

- ពុទ្ធសាសនា ជាផែនគ្រឹះនៃសីលធម៌សង្គម, នៃទស្សនវិជ្ជាខ្មែរ និងជាគតិបណ្ឌិតប្រជាប្រិយ,

- ពុទ្ធសាសនា ជាពណ៌សម្បុរជាតិ និងចរិតជាតិ ជាព្រលឹងជាតិ,

- ពុទ្ធសាសនា ជាស្នូលនៃកម្លាំងសន្តិភាព នៃសេចក្តីសុខរបស់ប្រជាជន និងសេចក្តីចំរើនរុងរឿងរបស់សង្គម,

- ពុទ្ធសាសនា ជាសុឆន្ទៈរបស់ប្រជាជន,

ដោយហេតុនេះ ពុទ្ធសាសនាបានក្លាយទៅជាសេចក្តីត្រូវការស្មើជីវិតរបស់ប្រជាជនកម្ពុជា ។

## IV. អំពីអត្ថិភាពនៃពុទ្ធសាសនា

តាំងពីច្រើនសតវត្សមកហើយ ដែលប្រជាជនកម្ពុជាគោរពប្រតិបត្តិ និងមានជំនឿជឿជាក់លើពុទ្ធសាសនា ដោយសារពុទ្ធសាសនាបានពន្យល់ណែនាំគេអោយគេឃើញនូវមធ្យោបាយដោះស្រាយរាល់បញ្ហា ដែលចោទឡើងក្នុងជីវិតប្រកបដោយហេតុផល ។ ពិសេសគឺ ជួយអ្នកគោរពប្រតិបត្តិអោយដណ្តើមបាននូវជ័យជំនះលើអវិជ្ជា លើភាពល្ងង់ខ្លៅ និងលើចំណុចខ្សោយរបស់ខ្លួនផ្ទាល់ ។

ពុទ្ធសាសនា បានប្រកាសសេចក្តីពិត ជាសាសនាប្រាប់ផ្លូវ ៖

- អោយលះបង់អំពើអាក្រក់ អោយធ្វើអំពើល្អ,

. អោយចៀសពីផ្លូវខុស អោយដើរតាមផ្លូវត្រូវ,

. អោយស្គាល់មធ្យោបាយដោះខ្លួនអោយផុតពីសេចក្ដីទុក្ខ ដើម្បីសំរេចអោយបានសេចក្ដីសុខក្សេមក្សាន្ត ។

អាស្រ័យមានជំនឿយ៉ាងមាំលើពុទ្ធសាសនា ទើបប្រជាជនខ្មែរខំប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយ :

. តស៊ូជំរុះចិត្តអាក្រក់ . កសាងចិត្តអោយល្អ,

. តស៊ូលះបង់អំពើអាក្រក់ . កសាងអំពើល្អ,

. តស៊ូលះបង់សេចក្ដីកំណាញ់ លោភលន់ លះបង់គំនិតគិតតែប្រយោជន៍ខ្លួន ដើម្បីបណ្ដុះព្រហ្មវិហារធម៌ សប្បុរសធម៌ និងគំនិតគិតដល់ប្រយោជន៍អ្នកដទៃ,

. តស៊ូលះបង់ការយល់ខុស សេចក្ដីក្រោធខឹង អំពើកំរោល អំពើកម្លៅដើម្បីបណ្ដុះសេចក្ដីអត់ធ្មត់ ការយល់ត្រូវ សេចក្ដីស្ងប់រំងាប់ និងបញ្ញាស្មារតី,

. តស៊ូជំរុះចិត្តច្រណែនឈ្នានីស ដើម្បីបណ្ដុះចិត្តត្រេកអរ ចិត្តសន្ដោសប្រណី ចិត្តអាណិតអាសូរ ។

សរុបមក គឺការប្រតិបត្តិក្នុងការរក្សាសីល ធ្វើទាន និងភាវនា ។

ការអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងត្រឹមត្រូវតាមពុទ្ធោវាទនេះ បានធ្វើអោយមនុស្សខ្មែរមានការរីកចំរើន និងធ្វើអោយសង្គមកម្ពុជា ថ្កុំថ្កើងរុងរឿង តាំងពីរាប់ពាន់ឆ្នាំ រហូតដល់សព្វថ្ងៃ ។

នៅសម័យអង្គរ ពេលព្រះពុទ្ធសាសនាបានទទួលការឧបត្ថម្ភទំនុកបំរុងអោយទៅជាសាសនារបស់រដ្ឋ ប្រជាជនក៏បានស្គាល់សេចក្ដីសុខ ប្រទេសជាតិ ក៏ថ្កុំ-ថ្កើងរុងរឿង ។

មកដល់សម័យក្រោយ ប្រទេសជាតិធ្លាក់ចុះដុនដាប ថមថយកម្លាំង មិនអាចរកសេចក្ដីចំរើនដូចសម័យអង្គរបាន ប៉ុន្តែ ប្រជាជននៅតែមានជំនឿយ៉ាងមោះ-

មុតទៅលើពុទ្ធសាសនាដដែល ។

នៅពេលមានកើតកោលាហលក្នុងប្រទេសម្តងៗ ប្រជាជនក្តី អ្នកប្រាជ្ញបណ្ឌិតក្តី រមែងនាំគ្នាទៅជ្រកកោនក្នុងសំណាក់ពុទ្ធសាសនា ។ គម្ពីរដីកា ក្បួនខ្នាតខាងវប្បធម៌ អក្សរសាស្ត្រ សិល្បសាស្ត្រ ត្រូវបានប្រមូលទុកក្នុងវត្តអារាម ។ ពេលរត់ភៀស, ប្រជាជនក៏យកទ្រព្យសម្បត្តិមានតម្លៃដែលយកតាមខ្លួនមិនរួច ទៅផ្ញើនឹងវត្តអារាម ។ ទោះបីមានការលំបាកតោកយ៉ាកយ៉ាងណា ក៏ប្រជាជនឱបពុទ្ធសាសនាទុកជាប់នឹងខ្លួន ថាអោយបោះបង់ចោលនោះ ដាច់ខាតមិនបោះបង់ចោលឡើយ ។ ការគោរពប្រតិបត្តិជាប្រពៃណីតាំងពីបុរាណមកយ៉ាងណា នៅតែបន្តធ្វើជារៀងរហូត ដរាបដល់ព្រះពុទ្ធសាសនាបានរីកចំរើនរុងរឿងឡើងវិញ ។

តាមស្ថិតិឆ្នាំ ១៩៦១ ចំនួនវត្តនៅក្នុងប្រទេសកម្ពុជា មាន ២.៨៥០ វត្ត និងមានបព្វជិតចំនួន ៥៣.៥០៩ អង្គ ។

មកដល់ឆ្នាំ ១៩៦៩ ចំនួនវត្តអារាម បានកើនឡើងដល់ ៣.៣៦៩ ចំណែកព្រះសង្ឃបានកើនដល់ ៦៥.០៦២ អង្គ ។

នៅមុនឆ្នាំ ១៩៧០ ពុទ្ធសាសនាមិនគ្រាន់តែរីកចំរើនខាងបរិមាណនៃវត្តអារាម និងភិក្ខុសង្ឃទេ ខាងការគ្រប់គ្រង សិក្សាអប់រំ ក៏រីកចំរើនដែរ ដូចជា ៖

- មានអង្គការគ្រប់គ្រងពុទ្ធសាសនា ( គណៈសង្ឃ ) ដែលមានភារកិច្ចដឹកនាំ គ្រប់គ្រងវត្តអារាម និងភិក្ខុសង្ឃគ្រប់ជាន់ថ្នាក់ ។

- មានអង្គការសិក្សាខាងព្រះពុទ្ធសាសនា មានភារកិច្ចអប់រំបណ្តុះបណ្តាលភិក្ខុសង្ឃ ចាប់តាំងពីបឋមសិក្សា រហូតដល់ឧត្តមសិក្សា ។

- មានពុទ្ធសាសនបណ្ឌិត្យ ដែលជាបណ្ណាល័យធំបំផុត និងតែមួយគត់របស់ជាតិ មានសៀវភៅ គម្ពីរដីកា ឯកសារខាងសាសនា និងវប្បធម៌ អក្សរសាស្ត្រជាតិ រាប់សែនក្បាល សំរាប់ភិក្ខុ . សាមណេរ និងប្រជាជនទូទាំងប្រទេស ធ្វើការ

សិក្សាស្រាវជ្រាវរៀនសូត្រ ។

ចាប់តាំងពីពេលបានមកប្រតិស្ឋាននៅប្រទេសកម្ពុជា រហូតដល់ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ពុទ្ធសាសនាឥតដែលមានពេលណាមួយត្រូវបានរលត់សាបសូន្យឡើយ គ្រាន់តែមានពេលខ្លះបានរីកចម្រើន ហើយពេលខ្លះទៀតត្រូវចុះឱនថយប៉ុណ្ណោះ ។ តែដល់មកសម័យប្រល័យពូជសាសន៍ប៉ុល ពត ពុទ្ធសាសនាត្រូវរលាយសាបសូន្យទាំងស្រុង ។

## V. ការបំផ្លាញរបស់ប៉ុល ពត ក្នុងវិស័យសាសនា និងជំនឿរបស់ប្រជាជន

ពុទ្ធសាសនា និងជំនឿផ្សេងៗ ត្រូវបានពួកប៉ុលពតបំផ្លាញដោយចំហ ចាប់តាំងពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដោយ :

១. បណ្តេញព្រះសង្ឃចេញពីវត្តអារាម ។ បន្ទាប់មក, ពួកគេចាប់បង្ខំអោយព្រះសង្ឃទាំងអស់លាចាកសិក្ខាបទ . រួចបង្ខំអោយអតីតសង្ឃកសាងគ្រួសារ និងប្រព្រឹត្តអំពើបាបផ្សេងៗ ។ ព្រះសង្ឃចំនួន ២៥.១៦៨ អង្គ ( ជិត ៤០% ) ត្រូវធ្វើគត់ ក្នុងនោះមានទាំងសង្ឃទីរាជាគណៈ និងបណ្ឌិតសង្ឃ ដូចជា :

. សម្តេចព្រះសង្ឃរាជ ហួត តាត

. ព្រះពោធិវង្ស សួរ ហាយ

. ព្រះវន្ន័រត ប៉ុណ្យ សុម្ភាជ

. ព្រះវិរិយបណ្ឌិតោ ប៉ាង ខាត់

. ព្រះសាសនមុនី កឹម តូ

. ព្រះពុទ្ធវង្ស សេខ នាង ជាដើម ។

២. បិទទ្វារវត្តអារាមទាំងអស់ មិនអោយប្រជាជនទៅគោរពបូជា ។ យកវត្តអារាមទៅធ្វើជាកន្លែងឃុំឃាំងមនុស្ស, ធ្វើជាកន្លែងមនុស្សឃាត សត្តឃាត ធ្វើជាឃ្លាំងដាក់អាវុធ ធ្វើជាកន្លែងចិញ្ចឹមសត្វ ... ពោលគឺ ធ្វើការប្រមាថបន្ទាបបន្ថោក

កន្លែងដែលជាទីសក្ការបូជារបស់ប្រជាជន ។

៣. វាយកំទេចកុដិ វិហារ ព្រះពុទ្ធបដិមា យកពុទ្ធបដិមាទៅទម្លាក់ទឹក ឬយកបំណែកបាក់បែកនោះ ទៅប្រើក្នុងសំណង់ផ្សេងៗ យកទៅក្រាលថ្នល់ បង្កើតអោយមានការឈឺចាប់ខាងផ្លូវចិត្តនៅក្នុងប្រជាជន ។ វត្តអារាមចំនួន ១៩៦៨ ស្មើនឹង ៥៨% ត្រូវបំផ្លាញខ្ទេច ។ វត្តអារាមសល់ពីនោះ សុទ្ធតែត្រូវខូចខាតយ៉ាងដំណំ ។

៤. បំផ្លាញសៀវភៅ ក្បួនខ្នាត គម្ពីរ ដីកា ដែលមាននៅតាមវត្តនានា នៅក្នុងបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ និងបិទទ្វារសាលាពុទ្ធិកសិក្សាទាំងអស់ សំដៅបំផ្លាញចំណេះចេះដឹងខាងវប្បធម៌ អក្សរសាស្ត្រជាតិ និងខាងសាសនា ។

៥. ហាមឃាត់មិនអោយធ្វើពិធីបូជា គោរពប្រតិបត្តិ ចំពោះព្រះពុទ្ធសាសនា និងហាមឃាត់មិនអោយធ្វើពិធីបុណ្យ និងពិធីផ្សេងៗ តាមទំនៀមទម្លាប់របស់សាសនា និងរបស់ប្រជាជន មានបុណ្យកឋិន ភ្ជុំបិណ្ឌ ជាដើម ។ សូម្បីមនោសញ្ចេតនា ច្បាប់ សីលធម៌ អាកប្បកិរិយា ផ្នត់គំនិត របស់បុគ្គលម្នាក់ៗ ដែលជាប់ជិតដាមដោយឥទ្ធិពលសាសនា ក៏ត្រូវពួកគេរិះគន់ វាយប្រហារ និងហាមឃាត់ដែរ បានសេចក្តីថា ពួកវាកាត់ផ្តាច់បំណងប្រាថ្នា និងសេចក្តីត្រូវការចាំបាច់ខាងស្មារតីចេញពីប្រជាជន ។

៦. បំផ្លាញសំណង់ផ្សេងៗ ដែលពុទ្ធសាសនិកសង់សំរាប់ជាប្រយោជន៍សាធារណៈ ដូចជា សាលាឆ្ទាន់ អណ្តូងទឹក គិលានដ្ឋាន សាលារៀន ។ល។

ការបំផ្លាញសាសនាដោយអស់ឫសគល់បែបនេះ មិនដែលមានសោះនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ។

## VI. ហេតុអ្វីបានជាពួកប៉ុលពតបំផ្លាញពុទ្ធសាសនា ?

ពួកប៉ុលពតបំផ្លាញពុទ្ធសាសនា ពីព្រោះ ពួកគេចង់ប្រែក្លាយសង្គមកម្ពុជាទាំងមូលអោយទៅជាសង្គមដែលគ្មានសេរីភាពខាងជំនឿសាសនា ។ ការបំបិទសិទ្ធិ

សេរីភាពខាងសាសនានេះ បានធ្វើអោយប្រជាជនកម្ពុជាទូទាំងប្រទេស មានកោលាហលខាងផ្លូវចិត្ត បាត់បង់អស់នូវតុល្យភាពខាងស្មារតី ។ ប្រជាពលរដ្ឋទាំងអស់ ត្រូវធ្លាក់ទៅក្នុងភាពអស់សង្ឃឹមឥតកោះត្រើយ ។ ពួកប៉ុលពត បានប្រែក្លាយមនុស្សអោយទៅជាសត្វ ជាមនុស្សយន្ត រង់ចាំតែធ្វើតាមបញ្ជារបស់ពួកគេតែប៉ុណ្ណោះ ។ ប៉ុល ពត មេអង្គការនៃរបបកម្ពុជាប្រជាធិបតេយ្យ មានមហិច្ឆតាចង់ធ្វើអធិរាជនៅកម្ពុជា ។

ដូច្នេះ វាត្រូវតែអនុវត្តរបបគ្រប់គ្រងផ្តាច់ការ និងបំបិទសិទ្ធិ សេរីភាពគ្រប់យ៉ាងរបស់ពលរដ្ឋ ។ សិទ្ធិ និងអំណាច ត្រូវប្រមូលផ្តុំទៅលើអង្គការទាំងអស់ ។

ពួកប៉ុល ពត មិនចូលចិត្តពុទ្ធសាសនា ពីព្រោះ ពុទ្ធសាសនានាំអោយមនុស្សចេះត្រិះរិះពិចារណារកហេតុផល ពុទ្ធសាសនានាំអោយមានកំលាំងសាមគ្គី ។

ពួកប៉ុល ពត មានបំណងរំលាយវណ្ណៈប្រជាជនទាំងអស់ អោយទៅជាទាសករដូចគ្នា ។ នៅក្នុងសង្គមទាំងមូល វាអោយមានតែអង្គការ និងទាសករ ។ ចំណេះចេះដឹងខាងវប្បធម៌ អក្សរសាស្ត្រ និងការរីកចំរើនដោយឡែកខាងទេពកោសល្យច្នៃប្រឌិត ព្រមទាំងឧបនិស្ស័យរបស់មនុស្ស នាំអោយអន្តរាយដល់អង្គការ ដូច្នេះ ត្រូវតែបំបាត់ សាលារៀន និងពុទ្ធសាសនា ព្រោះពុទ្ធសាសនា និងសាលារៀននាំអោយមានចំណេះដឹង ។

ពួកប៉ុល ពត បំបាត់ពុទ្ធសាសនា ព្រោះវាចង់បង្កើតសង្គមមួយថ្មី ដោយបដិសេធសមិទ្ធផលជាប្រវត្តិសាស្ត្ររបស់មនុស្សពីសង្គមមុនៗ ។ ពួកវាលុបបំបាត់សាសនា ដើម្បីបំផ្លាញផែនគ្រឹះនៃវប្បធម៌ អក្សរសាស្ត្រជាតិ កាត់ផ្តាច់មិនអោយមាននិរន្តរភាពខាងវប្បធម៌ អរិយធម៌ ពីព្រោះពួកគេចង់បង្កើតពណ៌សម្បុរ និងចរិតថ្មីមួយ សំរាប់សង្គមថ្មីរបស់ពួកគេ ដែលពោរពេញទៅដោយមហិច្ឆតាលោភលន់ អំនួត អួតអាង ភូតភរ កុហក បោកប្រាស និងការគំរាមកំហែង បំបាក់ស្មារតី ។

## VII. ផលវិបាកនៃការបំផ្លាញពុទ្ធសាសនា

ចំពោះប្រទេសដែលមានប្រជាជនស្ទើរតែ ១០០% កាន់ពុទ្ធសាសនា និងមានសេដ្ឋកិច្ចខ្សត់ខ្សោយបែបកម្ពុជា, ការលុបបំបាត់ពុទ្ធសាសនាទាំងស្រុងយ៉ាងនេះ គឺជាការបំផ្លាញរាល់តម្លៃខាងសម្ភារៈ និងស្មារតី របស់ពុទ្ធសាសនាយ៉ាងធ្ងន់ធ្ងរបំផុត ដែលរហូតមកដល់ពេលនេះ ឥទ្ធិពលអាក្រក់នៃការបំផ្លាញនោះ នៅមិនទាន់លុបលាងជ្រះនៅឡើយទេ ។ ផលវិបាកខ្លះ ទាមទារអោយមានការខំប្រឹងប្រែងរាប់សិបឆ្នាំទៅមុខទៀត និងត្រូវចំណាយប្រាក់កាសយ៉ាងច្រើន ទើបអាចលុបបំបាត់បាន ។ យ៉ាងណាមិញ :

ក)- ផលវិបាកខាងសម្ភារៈ

១- ការកំទេចបំផ្លាញសំណង់ទាំងឡាយនៅក្នុងវត្តអារាម និងសំណង់សាធារណៈ ដែលជាការឧបត្ថម្ភរបស់ពុទ្ធសាសនា នាំអោយ :

- ខាតបង់ថវិកាអស់រាប់ពាន់លានរៀល,
- ខ្វះសាលាសំរាប់កូនចៅប្រជាជនរៀនសូត្រ,
- ខ្វះគិលានដ្ឋាន មន្ទីរពេទ្យ,
- មានការលំបាកខាងសង្គមច្រើនទៀត ដូចជា ខ្វះស្ពាន ខ្វះជម្រកសាធារណៈ ខ្វះទឹកហូប -ល- ។ ដើម្បីស្តារការបាត់បង់សំណង់នេះឡើងវិញ គេត្រូវចំណាយប្រាក់កាសអស់រាប់ពាន់លានរៀលម្តងទៀត ។

២- ការបំផ្លាញបណ្ណាល័យ និងឯកសារខាងសាសនា នាំអោយខ្វះសៀវភៅសំរាប់សិក្សារៀនសូត្រ ខ្វះគម្ពីរ ដីកា ក្បួនខ្នាត សំរាប់តម្រង់ទិសការគោរពប្រតិបត្តិ ។

៣- ការធ្វើគត់ព្រះសង្ឃ នាំអោយបាត់បង់វត្ថុប្រផេះខាងព្រះពុទ្ធសាសនាយ៉ាងធ្ងន់ធ្ងរ បាត់បង់ចំណេះដឹងយ៉ាងសំបើម ដែលមិនងាយនឹងរកមកវិញបាន ។

ខ). ផលវិបាកខាងស្មារតី

. ការបាត់បង់ពុទ្ធសាសនា ធ្វើអោយពលរដ្ឋខ្មែរទាំងមូលអស់ទីពឹង អស់ជំនឿលើខ្លួនឯង និងអស់សង្ឃឹមគ្មានកោះត្រើយ ។

. យុវជនត្រូវបានគេពង្វក់អោយឈ្លក់វង្វេងក្នុងអំពើឃោរឃៅ ព្រៃផ្សៃ ដោយការបញ្ចូលមនោគមវិជ្ជាអសីលធម៌ទៅក្នុងខួរក្បាល ហើយបានជិតជាប់ទៅក្នុងសតិបញ្ញាស្មារតីរបស់កុមារ និងយុវជនជំនាន់នោះ មិនងាយលុបបំបាត់អោយស្អាតបានឡើយ ។ ផលវិបាកខាងស្មារតីនេះ មានទំហំធំធេង និងធ្ងន់ធ្ងរជាងផលវិបាកខាងសម្ភារៈរាប់សិបដង ។ ផលវិបាកទាំងពីរខាងលើនេះ ជាបន្ទុកយ៉ាងធ្ងន់ធ្ងររបស់សង្គមកម្ពុជា សព្វថ្ងៃ ។

## VIII. បច្ចុប្បន្នភាពនៃពុទ្ធសាសនានៅកម្ពុជា ក្រោយឆ្នាំ ១៩៧៩

ចាប់តាំងពីដើមឆ្នាំ ១៩៧៩ មក អ្វីៗដែលបាត់បង់ក្នុងសម័យសង្គ្រាម និងក្នុងរបបប្រល័យពូជសាសន៍ បានចាប់រស់ឡើងវិញ, ដោយឡែក វត្តអារាមពុទ្ធ-សាសនា ត្រូវបានស្តារឡើងវិញជាបន្ទាន់ ។ នៅពាក់កណ្តាលឆ្នាំ ១៩៧៩ ព្រះសង្ឃ ៧ អង្គដំបូង ត្រូវបានបំបួសបន្តជីវិតពុទ្ធសាសនាឡើងវិញជាផ្លូវការ នៅក្រុងភ្នំពេញក្រោមការរៀបចំ និងឧបត្ថម្ភរបស់អង្គការរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ តមក អតីតបព្វជិតជាច្រើនរូបត្រូវបានផ្តល់លទ្ធភាព និងឧបត្ថម្ភអោយបួសជាផ្លូវការក្នុងសភាពសមស្របតាមពុទ្ធានុញ្ញាត និងច្បាប់រដ្ឋ ។ សំណង់ក្នុងវត្តអារាមនានា ដែលបាក់បែក ខ្ទេចខ្ទាំ ក្នុងសង្គ្រាម និងក្នុងរបបប៉ុល ពតនោះ ក៏ត្រូវបានជួសជុល ឬកសាងជាថ្មី ព្រមទាំងមានព្រះសង្ឃគង់នៅសមល្មម ។

ជាង ២០ ឆ្នាំកន្លងទៅនេះ, ការណ៍ពិតបានបញ្ជាក់អោយឃើញថា ព្រះពុទ្ធសាសនាបានរីកចំរើនឡើងវិញក្នុងសន្ទុះថ្មី ដោយបានទទួលការឧបត្ថម្ភពីពុទ្ធ-សាសនិកជនដ៏សប្បុរស ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ។ ចំនួនព្រះសង្ឃ

បានកើនដល់ ៤៧.០០០ អង្គ, វត្តអារាមបានកើនឡើងដល់ ៣.៦០០ វត្ត ។ ការសិក្សាអប់រំខាងព្រះពុទ្ធសាសនា បានឈានពីកំរិតបឋមសិក្សា ដល់ឧត្តមសិក្សា ។ រីឯពុទ្ធសាសនបណ្ឌិត្យ ក៏បានបំពេញតួនាទីជាស្នូលមួយក្នុងការស្តារវិស័យពុទ្ធសាសនា និងសីលធម៌សង្គម ចាប់តាំងពីរដ្ឋាស្ថាននេះ ត្រូវបានរៀបចំអោយដំណើរការឡើងវិញនៅក្នុងឆ្នាំ ១៩៩២ មក ។

ជាការណ៍ពិតហើយ, ជាមួយនឹងការរីកចំរើននេះ បញ្ហាថ្មីៗបានកើតឡើងដែលទាមទារនូវការដោះស្រាយមួយដ៏សមស្រប និងមានការកែលំអរអស់ពេលដ៏យូរថែមទៀត ។ ប្រការនេះ យើងគប្បីចាប់អារម្មណ៍អំពីការពង្រឹងតួនាទីព្រះពុទ្ធសាសនាក្នុងសង្គម តាមរយៈតួនាទីរបស់វត្តអារាម, ព្រះសង្ឃ និងការអប់រំឃោសនាផ្សព្វផ្សាយអំពីព្រះធម៌ ពុទ្ធឱវាទ សីលធម៌ ចរិយាធម៌ ដើម្បីបង្កើនជំនឿទុកចិត្តរបស់ពុទ្ធសាសនិកជនទៅលើព្រះពុទ្ធសាសនា និងតម្រង់ទិសសង្គម និងយុវវ័យជំនាន់ក្រោយអោយបន្តគោរពចំពោះព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធនៃយើង ។ ដើម្បីសំរេចការងារនេះ ទាមទារនូវការពង្រឹងគុណភាពព្រះសង្ឃ ដោយជំរុញពុទ្ធិកសិក្សាអោយបានទូលំទូលាយ ទាំងពុទ្ធិកបឋមសិក្សា ទាំងពុទ្ធិកមធ្យមសិក្សា ទាំងសាលាធម្មវិន័យព្រមជាមួយនឹងការបង្កើនសមត្ថភាព និងលទ្ធភាព របស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងការស្រាវជ្រាវ ចងក្រង បោះពុម្ពផ្សព្វផ្សាយអោយបានទូលំទូលាយនូវ គម្ពីរ ដីកា ក្បួនច្បាប់ និងឯកសារផ្សេងៗទៀត ។ រីឯវត្តនីមួយៗ ត្រូវតែរៀបចំអោយប្រែក្លាយទៅជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន ដោយបង្កើតអោយមានបណ្ណាល័យសំរាប់តម្កល់គម្ពីរ ក្បួនខ្នាត និងមានសៀវភៅគ្រប់មុខវិជ្ជា ... និងជាអារាមដ៏មានឧទ្យានប្រកបដោយរុក្ខជាតិមានប្រយោជន៍ ...។

សំខាន់ជាងគេមុនអ្វីៗទាំងអស់ ត្រូវកសាងអោយបាននូវសាមគ្គីភាពក្នុងក្នុងជួរពុទ្ធសាសនិកជន ពិសេស ក្នុងជួរព្រះសង្ឃដែលត្រូវដើរតួជាគំរូដល់ប្រជា-

រាស្ត្រយើង ។ ព្រះសង្ឃត្រូវបំពេញតួនាទីអោយបានសមស្របទៅនឹងការលើកតម្កើងដ៏ខ្ពង់ខ្ពស់ជាសាសនារបស់រដ្ឋ ។ សកម្មភាពមនុស្សធម៌ និងសង្គមកិច្ច របស់ព្រះសង្ឃ ដូចជាការទំនុកបំរុងចាស់ព្រឹទ្ធាចារ្យគ្មានកូនចៅ កុមារកំព្រា និងប្រជារាស្ត្រជួបគ្រោះភ័យដោយប្រការផ្សេងៗ, កិច្ចការទាំងនេះ ទោះធំឬតូចក្តី ច្រើនឬតិចក្តី សុទ្ធតែមានឥទ្ធិពលចូលជ្រៅក្នុងជីវភាពសង្គម ដែលញ៉ាំងអោយតួនាទីនៃព្រះពុទ្ធសាសនានៅកម្ពុជា កាន់តែរីកចំរើន រឹងមាំ ទៅអនាគត ។

***

## ឱវាទរបស់
## ព្រះសុធម្មបញ្ញោភ្លោរ កែប ជួប (*)

ភិក្ខុបាតិមោក្ខ អាចរារាំងបាំងអបាយ
ភិក្ខុថ្មីទាំងឡាយ ត្រូវខ្វល់ខ្វាយរៀនប្រតិបត្តិ ។
ភិក្ខុតិរោក្ខុខ្ន ក្រោជញ្ញាំងព្រះបញ្ញត្តិ
បួសហើយបែរជាកាត់- ចោលជញ្ញាំងគឺ វិន័យ ។
ដូចសត្វបរោខោ ទំមែកពោធិស៊ីផ្លែជ្រៃ
ឬដូចកូនបក្សី ធ្លាក់ជ្រុះចាកមែករុក្ខា ។
ស្បៀកស្បង់មិនកោរសក់ ឆ្លះកញ្ចក់ធ្មេចនេត្រា
វិន័យបួសសាសនា មិននឹកនាសិក្សាសោះ ។

(*) ពិកម្ពុជសុរិយា លេខ ៤ ឆ្នាំ ១៩៥២ អ្នករៀបរៀង ភិក្ខុ **ម៉ុ សាន**

# អ្វីជា KHMEROLOGY ?

ដោយលោកស្រីបណ្ឌិត **ពៅ សាវរស**

បកប្រែពីអត្ថបទភាសាអង់គ្លេស ដោយ **ខង់ សុធារ៉ា**

(អត្ថបទនេះត្រូវបានសំដែងចំនួនពីរលើក នៅទីក្រុងភ្នំពេញ ។ លើកទី១ ឧទ្ទេសកថា ជាភាសាខ្មែរ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នាថ្ងៃ ២៧ វិច្ឆិកា ១៩៩៨; លើកទី២ ឧទ្ទេសកថាជាភាសាអង់គ្លេស នៅសាលជំនុំនៃក្រសួងធម្មការ និងសាសនា នាថ្ងៃ ០២ កុម្ភៈ ១៩៩៨ ក្រោមអធិបតីភាពរបស់លោករដ្ឋមន្ត្រី ) ។

## I. សេចក្តីផ្តើម

១. ជាសមាជិកម្នាក់នៃពុទ្ធសាសនិកជននៅក្នុងប្រទេសមួយ ដែលកាន់គោរពចំពោះលទ្ធិថេរវាទរបស់ព្រះពុទ្ធជាម្ចាស់,

ជាបឋម ខ្ញុំត្រូវធ្វើគារវកិច្ចចំពោះព្រះអង្គតាមប្រពៃណីថា " **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** " មានន័យថា " សូមក្រាបថ្វាយបង្គំចំពោះព្រះភគវាអរហន្ត ដែលព្រះអង្គបានត្រាស់ដឹងដោយបរិបូណ៌ " ។

ប៉ុន្តែ ខ្ញុំ និងជនរួមជាតិនៅទីនេះ យើងទាំងអស់គ្នា គឺជាប្រជាជាតិនៃប្រទេសចំណាស់មួយ ដែលបានស្គាល់ប្រភេទ និងទំរង់ខុសៗគ្នា នៃសាសនា និងវប្បធម៌ជាច្រើនតាំងពីយូរយារ មុនពេលលទ្ធិថេរវាទមកដល់ប្រទេសកម្ពុជា ក្នុងអំឡុងសតវត្សទី១៣ . ១៤ នៃគ.ស ទៅទៀត ។ បទពិសោធន៍ខាងស្មារតីរបស់យើងក្នុងកំឡុង ១.០០០ ឆ្នាំ អាចហៅបានយ៉ាងត្រឹមត្រូវថា " ព្រាហ្មណ៍និយម-មហា

យាននិយម-ជីវចលនិយម[១] " ។ ការពិត បុព្វបុរសយើង ដែលជាអ្នកជំនឿជីវចលនិយម បានសំដែងស្វាគមន៍ និងទទួលយកសាសនាដ៏ច្រើន ដែលនាំយកមកដោយជនអន្តោប្រវេសន៍ជាតិឥណ្ឌា ហើយបានចាក់ឫសយ៉ាងមាំនៅលើដីរបស់យើង ។

ខ្មែរបុរាណ ដែលបានទុកជាកេរអោយយើងនូវសិលាចារឹកដ៏ច្រើនអនេកប្រៀបបាននឹងប្រាសាទ លោកធ្លាប់បានចាប់ផ្តើមអត្ថបទរបស់លោក ដោយពាក្យមង្គល ឬមន្ត ឬគាថា ។ ជូនកាល លោកបន្ថែមលើសហ្នឹងទៅទៀត ហើយសំដែងគារវកិច្ចឆ្ពោះទៅព្រះ ដែលលោកគោរពយ៉ាងខ្ពង់ខ្ពស់ ជាពិសេស ព្រះសិវៈ-ឥស្វរ ដ៏មានមហិទ្ធិរិទ្ធ ដែលជាអ្នកថែរក្សាការពារព្រះមហាក្សត្រ និងរាជាណាចក្រ ។

ដូច្នេះហើយ ខ្ញុំសូមប្រកាសថា" **ឱំ នមឝ្ឝិវាយ ភ្យោគុរុភ្យះ**" មានន័យថា " ឱំ ! សូមក្រាបថ្វាយបង្គំចំពោះព្រះគ្រូទាំងអស់ ដែលមានព្រះសិរៈជាកំពូល ឬម្យ៉ាងទៀត ខ្ញុំអាចប្រកាសរបៀបដូចគ្នាយ៉ាងនេះថា " **សិទ្ធិ ស្វស្តិ ឱំ នមោ ភគវតេ វាសុទេវាយ** " មានន័យថា " សិទ្ធិ សួស្តី ឱំ ! សូមក្រាបថ្វាយបង្គំចំពោះព្រះភគវន្ត វាសុទេព ( គឺព្រះវិស្ណុ-នារាយណ៍ ) " ។

ថ្ងៃនេះ ខ្ញុំមានកិត្តិយសបំផុត ដែលត្រូវបានគេអញ្ជើញមកធ្វើបាឋកថាចំពោះមុខអ្នកចេះដឹង នៅក្នុងទីកន្លែងដ៏ប្រសើរ និងធ្វើជាភ្ញៀវនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។ ការពិត វិទ្យាស្ថាននេះ ជាបេះដូងវប្បធម៌នៃប្រទេសកម្ពុជា ជាទីកន្លែងរឹងមាំតែមួយគត់ក្នុងប្រទេសមួយ ដែលបានរងការឈឺចាប់ដោយសារកលិយុគមិនឈប់ឈរ ដោយចលាចលនយោបាយ ដោយការបំផ្លិចបំផ្លាញ ដោយការអត់បាយ និងដោយអំពើអាក្រក់បំផុត ។ ជាងនេះទៅទៀត ជាប្រទេសដែលបាត់បង់ក្តីយល់ដឹងគោលសីលធម៌ និងតម្លៃទាំងពួង ។

---

(១) ការជឿថា អ្វីៗទាំងអស់សុទ្ធតែមានវិញ្ញាណ ។

ថ្ងៃនេះ ខ្ញុំជាជនម្នាក់និយាយក្នុងនាមភាសាសាស្ត្រ និងក្នុងនាមពុទ្ធ-សាសនិកជនម្នាក់ គឺថា ខ្លួនខ្ញុំជាផលិតផលនៃរបស់ពីរយ៉ាង : មួយដោយសារការអប់រំរបស់ឪពុកម្ដាយតាំងពីតូច និងទីពីរ ដោយសារការអប់រំខាងវិជ្ជាជាន់ខ្ពស់នៅអឺរ៉ុប ដូច្នេះ ខ្ញុំត្រូវតែធ្វើការគោរពចំពោះស្នាដៃទាំងអស់របស់វិទ្យាស្ថាន ហើយមុនអ្វីៗទាំងអស់ គឺនៅក្នុងនាមនៃជនជាតិខ្មែរទាំងមូល ។ ខ្ញុំសូមថ្វាយបង្គំចំពោះ " **វចនានុក្រមខ្មែរ** " ដែលជាវត្ថុមួយមានអត្តភាពមិនអាចរលត់បានស្មើនឹងអង្គរ ។ គឺថា ជាប្រាសាទមួយនៅក្នុងបណ្ដាប្រាសាទទាំងឡាយ ជាវចនានុក្រមភាសាខ្មែរសុទ្ធ ដែលមានអាយុ ៦០ ឆ្នាំហើយ ។ ទោះជាមានខ្វោះក៏ដោយ វចនានុក្រមនេះជាសមិទ្ធិ គ្មានអ្វីប្រៀបបានរហូតមកដល់ឥឡូវ ហើយបានផ្ដល់ប្រយោជន៍បរិបូរដល់អ្នកស្រាវជ្រាវពិតៗជាច្រើន រួមទាំងខ្ញុំផង ។

២. បន្ទាប់ពីវន្ទនាការទាំងបីនេះមក ឥឡូវនេះ ខ្ញុំត្រូវបែរទៅនិយាយកិច្ចការនាពេលនេះវិញ ច្បាស់ជាងនេះទៅទៀត គឺក្ដីកង្វល់របស់យើង ។ ពីព្រោះតាមគំនិតរបស់ខ្ញុំ កម្មវត្ថុសំខាន់នៃការជជែកនេះ ទាក់ទងនឹងកម្ពុជា និងអរិយធម៌របស់ស្រុក ពោលគឺថា " ខេមរវិជ្ជា " ប្រធាននេះ មិនត្រូវអ្នកណាយកមកនិយាយលេង ឬជាងនេះទៅទៀត យកមកលេងកំសាន្តសប្បាយ ។

ដំបូង ខ្ញុំសុំអនុញ្ញាតរំលឹករឿងពីរជូនលោកអ្នក ជាបំផុត ចំពោះលោកអ្នកណា ដែលមិនសូវស្គាល់រឿងហ្នឹង ហើយពិសេសជាងនេះទៅទៀត ចំពោះអ្នកខ្លះដែលបានដឹងហើយ ក៏ប៉ុន្តែធ្វើជាមិនដឹង ។

ទី១. ខ្ញុំជាប់ស្អិតនឹងខេមរវិទ្យា អស់រយៈពេលជិត ៤០ ឆ្នាំមកហើយ ហើយខ្ញុំបានបំរើវិទ្យាសាស្ត្រពីរផ្លូវ នៅខណៈដែលខ្ញុំធ្វើជាអ្នកស្រាវជ្រាវអាជីព ខ្ញុំបានចំណាយពេលច្រើនសន្ធឹក ដើម្បីបណ្ដុះបណ្ដាលនិស្សិតនៅអឺរ៉ុប ។ ជាដំបូង ខ្ញុំចាប់បង្រៀនភាសាខ្មែរថ្មីក្នុងរវាងច្រើនឆ្នាំ ។ បន្ទាប់ពីខ្ញុំបានទទួលបន្ថែមនូវបទពិសោធន៍

ខាងវិទ្យាសាស្ត្រ ខ្ញុំក៏បានបូជាកំលាំងកាយ . ចិត្ត . ចំណេះដឹង ចំពោះអ្នកស្រាវជ្រាវក្មេងៗជាច្រើនជាតិផ្សេងៗគ្នា ដែលខ្ញុំជឿជាក់ថាពួកគេ ពិតជាដឹងខ្លួនឯងថាជានិស្សិតរបស់ខ្ញុំ ។

ទី២. ខ្ញុំបានធ្វើដំណើរមកដល់ទីនេះ បន្ទាប់ពីកម្ពុជាបើកសារជាថ្មី នៅឆ្នាំ ១៩៩៣ និង ១៩៩៤ ក្នុងឋានៈជាភ្ញៀវទាំងខាងជនជាតិខ្មែរ និងពួកបារាំង ដើម្បីជួយប្រទេសអោយស្តារជាថ្មី ដោយសារការប្រើប្រាស់បទពិសោធន៍ស្រាវជ្រាវជាន់ខ្ពស់អស់រយៈពេលជាច្រើនឆ្នាំរបស់ខ្ញុំ ។ ទោះជាជួបគ្នាក្នុងរយៈពេលខ្លីយ៉ាងណាក៏ដោយ ក៏សហសេវិករបស់ខ្ញុំ និងខ្ញុំ ទាំងអស់គ្នាបានសំរេចស្នាដៃយ៉ាងច្រើន ដែលខ្ញុំសូមរាយរ៉ាប់ដោយសង្ខេប (១) :

ក. នៅសាកលវិទ្យាល័យភ្នំពេញ ខ្ញុំបានបង្រៀនជាប់ជានិច្ច ប្រយោជន៍នឹងត្រួសត្រាយផ្លូវ សំរាប់ការស្រាវជ្រាវភាសាវិទ្យាខ្មែរ ។

ខ. នៅមហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យវិចិត្រសិល្បៈ ខ្ញុំបានបង្រៀនអំពីភាសា និងអរិយធម៌ខ្មែរបុរាណ ដោយសំអាងលើសិលាចារឹកជាសំខាន់ ។ ខ្ញុំសង្កត់ធ្ងន់ទៅលើចំនួនដ៏ច្រើននៃឯកសារ ដែលនៅតែកប់នៅក្នុងអត្ថបទបុរាណ ដែលត្រូវបានគេទុកចោលមួយអន្លើ បើអ្នកស្រាវជ្រាវប្រៀបធៀបកំណាព្យសំស្ក្រឹត ជាមួយស្ថាបត្យកម្ម និងបដិមាសាស្ត្រ ហើយខ្ញុំសូមអង្វរករជាបន្ទាន់ចំពោះអ្នកទាំងឡាយ អោយខិតខំពិនិត្យទៅលើឯកសារខ្មែរបុរាណទាំងអស់នោះ ហើយជីកយកកំណប់នៅក្នុងនោះដើម្បីនឹងស្គាល់អោយប្រាកដ និងល្អជាងមុន

---

(១) តាមសេចក្តីស្នើរបស់សហសេវិកជាតិអាល្លឺម៉ង់ ខ្ញុំបានសរសេររបាយការណ៍មួយ ស្តីអំពីសកម្មភាពទាំងនេះ ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុង Kambodschanische Kultur 5, 1997 : 115-7 ក្រោមចំណងជើងថា " ទស្សនកិច្ចនៃការសិក្សាជាន់ខ្ពស់នៅភ្នំពេញ ខែកុម្ភៈ . មីនា ១៩៩៤ " ។

អំពីវប្បធម៌ខ្មែរ ។

គ. ចុងបង្អើយ នៅពេលគេអញ្ជើញខ្ញុំមកជួបជុំជាមួយគណៈទីប្រឹក្សាជាន់ខ្ពស់ ដែលកាន់កាប់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នៅពេលនោះ ខ្ញុំបានសង្កត់ទៅលើការសិក្សាមួយជាពិសេស ដោយជំរុញលោកទាំងនោះ អោយគិតអោយដិតដល់ អំពីការបង្រៀនភាសាសំស្ក្រឹត ពីព្រោះ ដូចដែលខ្ញុំបានជំរាបរួចមកហើយថា " ភាសាសំស្ក្រឹត គឺជាសសរកន្លោងនៃអរិយធម៌ខ្មែរបុរាណ ជាកំណាល់ដ៏ខ្ពង់ខ្ពស់ រហូតដល់ពេលគេឈប់ប្រើ គឺដរាបទាល់តែលទ្ធិពុទ្ធសាសនាថេរវាទមកដល់ ( នាសតវត្សទី ១៤ នៃគ.ស. ) " ។

ឃ. ពេលខ្ញុំសម្លឹងទៅអនាគតជិតៗ ខ្ញុំស្នើអោយជួបជុំគ្នាជាទូទៅនៅឯសាកលវិទ្យាល័យវិចិត្រសិល្បៈ មានទាំងរដ្ឋមន្ត្រីក្រសួងវប្បធម៌ផង ហើយខ្ញុំបានជំរុញអោយអ្នកទាំងនោះរកអាហារូបករណ៍សំរាប់និស្សិត និងបញ្ជូនពួកគេទៅបរទេស សំរាប់ការបណ្ដុះបណ្ដាលទូលំទូលាយមួយ ។ ចំណែកឯខ្លួនខ្ញុំ ស្ម័គ្រចិត្តនឹងជួយមើលខុសត្រូវ សំរាប់និស្សិតណាដែលមានសមត្ថភាពទៅរៀននៅអឺរ៉ុប ជាពិសេស នៅទីក្រុងប៉ារីស ហើយខ្ញុំនឹងបង្រៀនអំពីភាសាវិទ្យាខ្មែរ សិលាចារឹកភាសាសំស្ក្រឹត ឬខ្មែរ ។

ការស្នើទាំងប៉ុន្មាននោះ ដូចគ្នាត្រង់ចំណុចមួយ បណ្ដាលពីខ្ញុំយកបទពិសោធន៍ដ៏យូរយាររបស់ខ្ញុំ ដែលមិនគ្រាន់តែជាអ្នកប្រាជ្ញ ប៉ុន្តែ ថែមទាំងជាប្រជា-ពលរដ្ឋម្នាក់នៃពិភពលោក ។ ដូច្នេះ ខ្ញុំសំដែងនូវជំនឿយ៉ាងមុតមាំថា គ្មាននរណាម្នាក់អាចស្តារអ្វីៗពីគំនរផេះផង់ ដោយឥតមានការចាក់គ្រឹះយ៉ាងមាំនោះទេ ។

នៅក្នុងការជួបជុំជាមួយនិស្សិតយ៉ាងច្រើន ( ដោយពិត សន្ធឹកណាស់ ) និងសហសេវិក ខ្ញុំបានបញ្ជាក់យ៉ាងច្បាស់ថា យើងទាំងអស់គ្នាកំពុងជួបប្រទះឱកាសមួយ ដើម្បីចាប់ផ្ដើមកសាងសាជាថ្មីក្នុងគ្រប់វិស័យ រួមទាំងការសិក្សា និង

ស្រាវជ្រាវ ។ ខ្ញុំបានទទួចថា នៅចាំជួយខាងមុខវិជ្ជាភាសា និងអក្សរសាស្ត្រ នៅភ្នំពេញនេះ ឬនៅប៉ារីស ដែលជាកន្លែងដែលខ្ញុំនៅជាប់ ដើម្បីជួយស្រោចស្រង់វិជ្ជាសិលាចារឹកខ្មែរ [(១)] ។

តាមពិត ការជួបគ្នានេះ ជាឱកាសដ៏ចែងចាំងពោរពេញដោយក្ដីសង្ឃឹម ។ ខ្ញុំគិតដល់ទៅប្រាថ្នាត្រឡប់មកស្រុកកំណើតវិញជារៀងរហូត នៅខណៈដែលខ្មែរនៅបរទេសឯទៀត ដែលគេហៅថាបញ្ញវន្ត ! រៀបចំខ្លួន និងដឹកនាំកិច្ចការខាងចំណោះជាន់ខ្ពស់ ( អ្នកទាំងនោះឯង ) បានមកដល់កម្ពុជា និងបានទទួលនូវតួនាទីយ៉ាងខ្ពស់ ជាមួយការទទួលខុសត្រូវរបស់ខ្លួន ។ ប៉ុន្តែ គ្មានអ្វីបានកកើតឡើង ដូចដែលបានគ្រោងទុកនោះសោះ ។

បន្ទាប់មក ខ្ញុំបានដឹណឹងថា គេមិនត្រូវការអោយខ្ញុំមក ថែមទាំងមិនចង់អោយខ្ញុំមកទៀតផង ហើយពតិមាន និងការទូន្មានរបស់ខ្ញុំទាំងប៉ុន្មាន ពួកគេបោះចោលទៅក្នុងធុងសំរាម ។ ជាឧទាហរណ៍ គេបានរៀបចំមហោស្រពរឿង " រាមាយណៈ " មួយ មានទស្សនីយភាពយ៉ាងគគ្រឹកគគ្រេង ដោយគ្មានបង្ហាញអោយឃើញនូវការសិក្សាខាងរាមកេរ្តិ៍ ជាពិសេស រឿងរាមកេរ្តិ៍បុរាណ ដែលជាបេះដូងរស់នៃប្រទេសកម្ពុជា វានៅតែជាការកំសាន្ត ជាវត្ថុប្លែកភ្នែកសំរាប់ជនបរទេសគ្រប់ជាតិ ។

មានរបស់មួយទៀត ដែលធ្វើអោយខ្វល់ខ្វាយជាងនោះទៅទៀត គឺពាក្យ

---

(១) ដែលធ្វើអោយមានអាសន្ននោះ គឺនៅពេលដែលខ្ញុំបានចូលនិវត្តន៍នៅឆ្នាំ ១៩៩៤ ដោយការប្រថុយធ្វើជាមេគំនិតជាមួយអ្នកស្រាវជ្រាវគ្មានសមត្ថភាពទាំងឡាយ ។ ហេតុដូច្នេះហើយ ខ្ញុំបានស្ម័គ្រចិត្តបន្តការបង្រៀនវិជ្ជាសិលាចារឹក ព្រមជាមួយនឹងការសរសេរឯកសារស្រាវជ្រាវបន្តពី " វិជ្ជាសិលាចារឹកនៃប្រទេសកម្ពុជាបុរាណ ... " ។ ចំណែកឯវិជ្ជាសិលាចារឹកផ្នែកភាសាសំស្ក្រឹត ដោយពិតទៅ គឺហួសពីសមត្ថកិច្ចរបស់ខ្ញុំ ។

" KHMEROLOGY " ដែលគេនិយមប្រើក្នុងចំណោមជនបារាំង ។ នៅប៉ុន្មានឆ្នាំមុននេះ គេបានលើកវាំលេចវានៅក្នុង" សន្និសីទស្តីពីខេមរវិទ្យា" នៅឆ្នាំ ១៩៩៦ ដោយគ្មាននរណាម្នាក់បង្ហាញពីនិយមន័យ ទ្រឹស្តី និងវិធីរបស់វា ។ នៅពេលជាមួយគ្នានេះ មានអ្នកខ្លះខ្មីឃ្មាតខាងវិជ្ជាសិលាចារឹក ដោយខ្លួនឯងគ្មានបានរៀនតាមក្បួនខ្នាត ហើយមានទាំងផ្អែកលើនិស្សិតបញ្ចប់បរិញ្ញាប័ត្រ និងនិស្សិតក្មេងៗ នៅមហា-វិទ្យាល័យ ដែលគ្មានសមត្ថភាពអ្វីទាំងអស់ ។

ស្ថានភាពដូចបានរាយខាងលើ ធ្វើអោយអ្នកមានវិចារណញ្ញាណ ឬចេះទទួលខុសត្រូវ ជ្រួលច្របល់ និងព្រួយបារម្ភ ។ សព្វថ្ងៃនេះ ពិភពលោកបានក្លាយជាទីកន្លែងដ៏តូចមួយ ដោយសារការទំនាក់ទំនងកាន់តែរហ័ស និងកាន់តែថ្មេខ្លាំងហើយសក្តិសិទ្ធ ឯបច្ចេកវិទ្យាកាន់តែដើរលឿនគួរអោយភ័យផងដែរ ។ គេអាចនិយាយបានថា" ពិភពលោក គឺជាភូគោលតែមួយ " ( globalization ) ក្នុងគ្រប់វិស័យនៃសកម្មភាពរបស់មនុស្ស គឺមិនអាចនៅបង្អង់លេងក្បាច់ក្បួរ ឬនៅធ្វើជាល្បែងកំសាន្តបានទេ ។ ផ្ទុយទៅវិញ ម្នាក់ៗត្រូវឈរអោយមាំ រួចមក ត្រូវទទួលច្បាប់និងវិន័យនៃសាកលលោក ។ ជាពិសេស សំរាប់ប្រទេសកម្ពុជា ប្រសិនបើម្នាក់ៗប្រាថ្នាបង្កើតអ្វីៗ និងប្រាថ្នាប្រោះអោយរស់ឡើងវិញ ហើយនិងប្រាថ្នាស្តារឡើងវិញនូវមូលដ្ឋានគ្រឹះរបស់ប្រទេស ។

យ៉ាងណាក៏ដោយ ដោយសារខ្ញុំធ្លាប់ផ្អែកទៅលើធម៌" **ឧបេក្ខា**" ខ្ញុំនៅតែសង្ឃឹមថា អ្នកគ្រប់គ្នាដែលបានចាប់អារម្មណ៍លើខេមរវិទ្យា អាចស្តាប់ឮពាក្យបណ្តាំសាកលលោក ។ បន្ទាប់មក នៅខែ កក្កដា ឆ្នាំ ១៩៩៧ ស្រាប់តែឮដំណឹងអំពីការប្រឆាំងគ្នាគួរអោយរន្ធត់មួយ ដូចដែលអស់លោកអ្នកបានជ្រាបស្រាប់ ។ អ្នកផងអោយយោបល់ថា ជាចលាចលនយោបាយមួយ នៅក្នុងចំណោមចលាចលនយោ-បាយដ៏ច្រើនដែលធ្លាប់កើតមានឡើងនៅកម្ពុជា រាប់សតវត្សមកហើយ ប៉ុន្តែ ចំពោះ

យោបល់ខ្ញុំ នេះគ្រាន់តែជាសម្មតិកម្មដ៏តូចចង្អៀតមួយ ។ ពីព្រោះ បើនិយាយតាមផ្លូវសង្គមវិទ្យា វាគ្មានន័យទេ នៅក្នុងសេចក្ដីសន្និដ្ឋានអំពីការកសាងស្រុកទេសសាជាថ្មីឡើងវិញ នៅពេលដែលឥតមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំ និងការមិនទទួលយកនូវគំរូពីលោកទាំងមូល ដូចដែលបាននិយាយខាងលើ ។ ជាការពិតណាស់ ការខ្វះមូលដ្ឋានគ្រឹះនេះ ជាធម្មតាជះឥទ្ធិពលទៅលើគ្រប់វិស័យ រួមទាំងខេមរវិទ្យាផងដែរ ។ បើនិយាយម្យ៉ាងទៀត KHMEROLOGY របៀបប្លែកភ្នែក គ្រាន់តែសប្បាយ ដែលមនុស្សភាគច្រើនយកមកនិយាយឡូឡា នាពេលថ្មីៗនេះ មើលទៅដូចជាទារកស្លាប់ក្នុងពោះម្ដាយយ៉ាងពិត ។

ទោះជាយ៉ាងណា តាមធម៌បរិវត្តន៍ គេមិនអស់សង្ឃឹមទេ ចំពោះការស្ដាបនាឡើងវិញ ក៏ប៉ុន្តែ ទាល់តែមនុស្សទាំងអស់រវល់ខ្មីឃ្មាតខំស្វែងយល់អត្ថន័យពិតប្រាកដនៃពាក្យ " KHMEROLOGY " ។

## II. ខេមរវិទ្យា និង KHMEROLOGY

ខ្ញុំនឹងឆ្លៀតឱកាសនេះ ចាប់និយាយអំពីការស្វែងចំណេះជាវគ្គមួយ ព្រមទាំងការសិក្សា និងស្រាវជ្រាវ ដែលនឹងលាតត្រដាងអោយយល់នូវពាក្យ ដូច KHMEROLOGY ជាដើម ដោយទាក់ទងនឹងសារជាតិនៃវិជ្ជាជាន់ខ្ពស់ ។ នៅពេលសតវត្សទី ២០ ជិតដាច់ គ្មាននរណាម្នាក់ដែលនៅក្នុងស្ថាប័នឧត្តមសិក្សា ហ៊ានអះអាងធ្វើការ និងបង្កើតអ្វីៗ ដូចអ្នកដែលចេះឯង ដឹងឯងនោះទេ ។ ពីព្រោះតែពិភពលោក ជាភូគោលតែមួយ ។ នេះទាក់ទងមិនគ្រាន់តែចំពោះនយោបាយសេដ្ឋកិច្ចទេ ប៉ុន្តែ ថែមទាំងក្នុងមែកធាងទាំងឡាយនៃការរៀនសូត្រ ដោយរួមទាំងវិស័យនៃវិជ្ជារបស់យើងផងដែរ ។

ក្នុងវិស័យនោះទៀត អ្នកស្រាវជ្រាវណាធ្វើមិនដឹងអំពីអ្វី ដែលកំពុងមាន

ព្រមទាំងស្នាដៃអ្នកប្រាជ្ញមុនៗមកនោះ គេអត់ឱនអោយមិនបានទេ ។

ក្រឹត្យក្រមសត្យានុម័តនេះ (this axiom) គ្មាននរណាជជែកបានទេ វាដឹកនាំការពិចារណាជាមូលដ្ឋានមួយចំនួន អំពីសកម្មភាពរបស់យើង ដែលនឹងវិវត្តពីមួយទៅមួយ ។

បញ្ហាទី១ នៅចំពោះមុខ គឺជាឯកសារដែលផ្ទុកនូវវិទ្យាគ្រប់ប្រភេទ ។ បន្ទាប់មក ការប្រើប្រាស់ឯកសារទាំងនេះ គឺជាការសំរេចបានយ៉ាងលំបាកបំផុត ហើយដែលអ្នកសិក្សាទាំងអស់ (១) ត្រូវការរយៈពេលយូរ និងមានភាពជាអ្នករៀននូវមុខវិជ្ជាឯកទេស គឺថា :

ក. ការបណ្តុះបណ្តាលវិជ្ជាជាន់ខ្ពស់មួយ ទាំងមុខវិជ្ជាទូទៅ និងទាំងមុខវិជ្ជាឯកទេសមួយ ដោយមានការតំរង់ទិសជាក់លាក់ ។

ខ. ក្នុងពេលជាមួយគ្នានោះ ត្រូវរកអោយបានច្រើនបំផុត នូវប្រដាប់ប្រដាស្រាវជ្រាវដែលទាក់ទង ។

គ. ការអនុវត្តន៍នូវមុខវិជ្ជាទាំងឡាយ ដែលខ្លួនបានទទួល ( វិទ្យាសាស្ត្រ និងវប្បធម៌ ) ដើម្បីវែកញែកអោយល្អិតល្អន់គ្រប់ទិន្នន័យដែលបានទទួល ។

ឃ. ប្រមូលទិន្នន័យទាំងនេះបញ្ចូលគ្នា ដើម្បីបង្កើតជាប្រព័ន្ធមួយ ។

ការពិត គ្មាននរណាម្នាក់ ត្រូវបានគេបង្ខំអោយធ្វើជាអ្នកពូកែខាងភាសាជាច្រើនមុខនោះទេ ឬត្រូវជាអ្នកចេះស្ទាត់ជំនាញជាច្រើនមុខវិជ្ជា ដែលខ្លួនបានល្បងសិក្សានោះដែរ ។ ក៏ប៉ុន្តែ គាត់ត្រូវតែជាអ្នកដឹងយ៉ាងច្បាស់ នូវរាល់តម្រូវការទាំងអស់ ដូចដែលខ្ញុំលាតត្រដាង ។

១. ដំបូង ខ្ញុំនឹងធ្វើសេចក្តីរាយការណ៍អំពីឯកសារទាំងឡាយ ដែលគេ

---

(១) ពាក្យនេះ ចង់និយាយជាទូទៅ គឺថា « អ្នកសិក្សាទាំងនោះ » មានទាំងវ័យក្មេង និងទាំងវ័យចាស់

ស្គាល់ច្រើន នៅក្នុងវិស័យខេមរវិទ្យា ប៉ុន្តែ ដោយត្រួសៗប៉ុណ្ណោះ ដោយសង្កត់ធ្ងន់តែទៅលើឯកសារដែលចាំបាច់បំផុត ពិព្រោះ ពេលវេលានៃការរៀបចំឯកសារទាំងនេះ ដូចដែលលោកអ្នកដឹងស្រាប់ រួមមាន ៖

ក. អត្ថបទសរសេរដៃ ដែលបានពីសម័យកាលខុសៗគ្នា និងប្រភពខុសៗគ្នា ។

ខ. បុរាណវត្ថុទូទៅ ( ប្រាសាទ រូបចម្លាក់ ... ។ ល ។

គ. ទិន្នន័យដែលប្រមូលបានថ្មីៗ ពីកន្លែងចុះស្រាវជ្រាវ ។

ចំណែកឯ ឯកសារបរទេស ខ្ញុំគ្រាន់តែរំឭកអំពីចំនួនដ៏ច្រើនខុសៗគ្នារបស់វា ដូចជា ឯកសារចិននៅសម័យកាលខុសៗគ្នា បន្ទាប់មក អារ៉ាប់ និងពែរ្សបន្ទាប់មកទៀត អឺរ៉ុប ( មាន អេស្ប៉ាញ ប៉រទុយហ្គេ ហូឡង់ ហើយតិចជាងគេបង្អស់គឺ អង់គ្លេស ) ហើយចុងក្រោយបង្អស់ អាល្លឺម៉ង់ និងបារាំង ហើយឯកសាររបស់ពួកនេះយ៉ាងច្រើនបំផុត ចាប់ពីសតវត្សទី១៩ មកដល់សព្វថ្ងៃ ។ អ្នកនិពន្ធទាំងនោះ មិនមែនជាអ្នកប្រាជ្ញទេ លើកលែងតែនរវិទូជាតិអាល្លឺម៉ង់ Adolf Bastian ប៉ុន្តែ ពួកគេជាអ្នកដំណើរ ជាពាណិជ្ជករ ក្រោយមក ជាអ្នករុករកភូមិ ប្រទេស ។ ឯកសារទាំងនេះ មួយផ្នែកនៅតែរង់ចាំការសិក្សា ចំណែកឯកសារដទៃខ្លះទៀតដែលបានសិក្សាពីពេលមុន ក៏ត្រូវការអោយយកមកសិក្សាឡើងវិញដែរ ។

ឯកសារជាភាសាខ្មែរ គឺមានបរិមាណយ៉ាងច្រើនលើសខាងលើ ហើយសំខាន់ជាង ផ្ទុយទៅវិញ មិនទាន់មានអ្នកស្គាល់វាច្បាស់នៅឡើយ ។ វត្ថុបុរាណ និងវត្ថុសិល្បៈ ត្រូវបានអ្នកប្រាជ្ញ ព្រមទាំងសាធារណជនទូទៅស្គាល់ច្រើន យ៉ាងហោចណាស់ គេស្គាល់រូបរាង ដោយសារតែការទាក់ទាញចិត្តភ្ញៀវទេសចរណ៍របស់វា ។ ចំណែកឯកសារសរសេរជាភាសាខ្មែរ មានលំដាប់តាំងពីសតវត្សទី៦ នៃគ.ស. រហូតមកដល់បច្ចុប្បន្ន ។ យើងអាចចែកពួកវាជាពីរក្រុមធំៗ ៖

ទី១. បណ្តាភស្តុតាងពីបុរាណដ៏ច្រើនលើសលប់នៃវប្បធម៌ខ្មែរ គឺអត្ថបទ

សរសេរលើថ្ម ដែលគេហៅថា " សិលាចារឹក " នៃប្រទេសកម្ពុជា [១] បានតាក់តែង ឡើងជាភាសាសំស្ក្រឹត និងជាភាសាខ្មែរ រីឯជាភាសាបាលី មានចំនួនតិចតួច [២] ។

ទី២. មានអត្ថបទដ៏ច្រើនអនេក សរសេរនៅលើស្លឹកត្នោត ( ឬ olas ) និងនៅលើក្រដាស ដែលខ្មែរហៅថា សត្រា ច្បាប់ ក្បួន តម្រា ... ។ ល ។ ដោយ តម្រូវតាមទំនង ។ តាមខ្ញុំដឹង អត្ថបទទាំងនោះជាឯកសារសរសេរដៃ ឬកត់ចម្លងពី អត្ថបទដើម ដែលត្រូវបានបាត់បង់កន្លងទៅអស់ជាច្រើនឆ្នាំ ។ ក៏ប៉ុន្តែ អត្ថបទទាំង នោះអាចទុកចិត្តបាន ចំពោះអ្នកប្រាជ្ញណា ដែលបានរៀនចេះខាងអក្សរនេះ និងខាង ភាសាវិទ្យា ។

ឯកសារទាំងអស់នេះ បានទាក់ទាញចិត្តអ្នកសិក្សាជាតិផ្សេងៗយ៉ាងច្រើន អស់ជិតមួយសតវត្សមកហើយ មកដល់ឥឡូវនេះ ។ នៅពេលដំបូង វាបានទាក់ ទាញអ្នកសិក្សាទាំងនេះភាគច្រើនអោយចង់ធ្វើ មិនគ្រាន់តែចង់ចេះដឹងខាងវិទ្យា-សាស្ត្រ ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងចង់បង្ហាញឫក និងចង់ឃើញរបស់ប្លែកភ្នែកផង ដែរ ។ យ៉ាងណាក៏ដោយ ក្នុងរយៈពេលដ៏យូរយារ ទម្រាំតែ " ការចាប់អារម្មណ៍នៃ វិទ្យាសាស្ត្រពិតបានលេចចេញមក " ពីការចង់ចេះដឹងត្រឹមតែជារឿងកំសាន្ត សប្បាយ ។

ដូច្នេះ ការកត់សំគាល់ពីការចាប់ផ្ដើមពិតប្រាកដនៃខេមរវិទ្យា ខ្ញុំនឹងអធិ-ប្បាយអំពីប្រវត្តិនៃវិជ្ជានេះ ក្នុងពេលឥឡូវនេះ ។

---

(១) បច្ចេកពាក្យនៅក្នុងភាសាខ្មែរចាស់ " ប្រសស្តកម្វុជា " ។ • (២) សូមមើល S. Pou, " Nouvelles Inscriptions du Cambodge " I , 1998 ; និងអត្ថបទស្រាវជ្រាវថ្មីៗ ជាច្រើនទៀត របស់ខ្ញុំ " L'épigraphie khmère " (1997), " Khmer Epigraphy " (1997) អត្ថបទមួយទៀតស្រដៀងគ្នានេះដែរ ដែលកំពុងបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដី Orientalia Lovaniensia Periodica មានចំណងជើងថា " Praçasta Kamvuja ".

២. វិជ្ជានេះបានចាប់ផ្តើមប្រហែលមួយសតវត្សមកហើយ នៅពេលដែលអ្នកប្រាជ្ញបានចាប់អារម្មណ៍ពិតប្រាកដអំពីប្រទេសកម្ពុជា ជាពិសេស អំពីប្រាសាទទាំងឡាយដែលបានបាក់បែក ក៏ប៉ុន្តែ គួរអោយកោតសរសើរ ។ តាមពិតការចាប់អារម្មណ៍នេះមានពីរយ៉ាងគឺ ស្ថាបត្យកម្ម និងសិលាចារឹក ដែលត្រូវតែនិយាយទាំងពីរ ។ នៅខណៈនោះឯង ស្ថាបត្យករខ្វល់ខ្វាយខ្លាំងអំពីស្ថានីយ៍បុរាណទាំងឡាយ ដោយក្តីប្រាថ្នាយ៉ាងមាំ ចង់ស្គាល់បណ្តាប្រាសាទ និងរូបភាពមនុស្ស ពីអតីតកាល ដែលនៅពីក្រោយប្រាសាទទាំងនោះ ។

ដោយចៃដន្យ មានរូបថតនៃផ្ទាំងសិលាចារឹកពីរបួច បានធ្លាក់ដល់ក្រសែភ្នែករបស់អ្នកប្រាជ្ញខាងភាសាសំស្ក្រឹតជាតិហូឡង់ម្នាក់ គាត់ឈ្មោះ ហេនឌ្រិក ខេន (Hendrik Kern) ។ លោកបានបោះពុម្ពផ្សាយស្នាដៃរបស់ខ្លួន ស្តីពីការសិក្សាសិលាចារឹកភាសាសំស្ក្រឹតនៃប្រទេសកម្ពុជា ជាលើកដំបូងនៅក្នុងឆ្នាំ ១៨៧៩ [១] ហើយ ការបោះពុម្ពផ្សាយស្នាដៃនេះ ចេះតែធ្វើជាបន្តបន្ទាប់មកទៀត ។

ពន្លឺភ្លើងនោះ យើងដែលប្រកាសខ្លួនធ្វើជា " អ្នកខេមរវិទ្យា " មិនបានទទួលស្គាល់ និងសរសើរអោយបានពេញលេញឡើយ ។ ការពិត ភ្លើងនេះត្រូវបានអុជបន្ត រហូតដល់មានការចាប់អារម្មណ៍របស់អ្នកស្រាវជ្រាវខាងវិជ្ជាដូចគ្នាដទៃទៀត ( Barth, Bergaigne ) នៅក្នុងប្រទេសបារាំង ដែលក្រោយមក លោកបានចំណាយពេលរបស់ខ្លួនចំពោះការសិក្សាសិលាចារឹកសំស្ក្រឹត ដែលបានរកឃើញនៅក្នុងប្រទេសកម្ពុជា ។

អ្នកប្រាជ្ញថ្មីៗទាំងនេះ នៅខណៈដែលកំពុងបោះពុម្ពយ៉ាងរហ័ស នូវការសិក្សាសិលាចារឹករបស់ខ្លួន [២] លោកក៏បានធ្វើផងដែរនូវកិច្ចការប្រវត្តិសាស្ត្រ ដោយការលាតត្រដាង និង បង្ហាញអោយស្គាល់នូវបុគ្គលធំៗខ្លះ ដែលគ្រប់គ្រងប្រទេស

(១) សូមមើល, ឯកសារពិគ្រោះ (Bibliography) . (២) សូមមើល, ឯកសារពិគ្រោះ ។

កម្ពុជាបុរាណ និងបានស្ថាបនាប្រាសាទដ៏មានកិត្តិស័ព្ទ មិនអន់ជាងខ្លួនជាអ្នកសាង និងដែលត្រូវបានគេស្គាល់ដោយសារសហសេវិកជាស្ថាបត្យករទាំងឡាយ របស់លោក ។ អស់លោកនោះ ថែមទាំងបានពិពណ៌នាដោយសង្ខេប អំពីទិដ្ឋភាពសាសនានៃប្រទេសកម្ពុជាផងដែរ យ៉ាងហោចណាស់អំពីវរជននៃសង្គម ។

បុគ្គលមួយរូបទៀត ដែលបានលេចឡើង និងបានចូលរួមក្នុងការងារពួកគាត់ ថែរក្សាសិលាចារឹកខាងភាសាខ្មែរ គឺលោក អេត្យេន អេម៉ូនីញេ (Etienne Aymonier) ។ គាត់មិនបានទទួលការបណ្តុះបណ្តាលវិជ្ជាជាន់ខ្ពស់ទេ ក៏ប៉ុន្តែ កិច្ចការត្រួសត្រាយផ្លូវដំបូងរបស់គាត់ ពោរពេញដោយការប្តេជ្ញាចិត្ត ការតស៊ូ ដោយស្មោះ និងសុចរិតធម៌ បានធ្វើអោយគាត់ក្លាយទៅជាអ្នកប្រាជ្ញពិតប្រាកដម្នាក់ នៅដំណាច់សតវត្សទី១៩ ។ អត្ថបទដំបូងពីររបស់គាត់ ( បានបោះពុម្ព ឆ្នាំ១៨៨៣ ឆ្នាំ ១៨៨៥ ) យើងអាចចាត់ទុកបានយ៉ាងត្រឹមត្រូវ ថាជាចំណុចចាប់ផ្តើមនៃ " ខេមរៈវិទ្យា " ។

ដូច្នេះ កិច្ចការស្រាវជ្រាវបានធ្វើទៅមុខយ៉ាងឆាប់រហ័ស និងថែមទាំងបានសំរេចទាំងពីរមុខទៀតផងដែរ ៖ បុរាណវត្ថុវិទ្យា និងសិលាចារឹក ដែលទាំងពីរមុខនេះ ទាក់ទងដល់គោលបំណងរួមគ្នាតែមួយ គឺ ប្រវត្តិវិទ្យា ។ ក៏ប៉ុន្តែ តាមខ្នាតសម័យថ្មី យើងមិនអាចនិយាយបានថាជា KHMEROLOGY ទេ ពីព្រោះតែការខ្វះស្វ័យភាពយ៉ាងច្បាស់ក្រឡែត ។ តាមពិត កាលនោះ ខេមរវិទ្យា (Khmer studies) ជាផ្នែកមួយក្នុងការសិក្សាអំពីឥណ្ឌា ជាពិសេស នៅក្នុងវិស័យសាសនា និងប្រវត្តិសិល្បៈ ហើយគ្រប់ទិន្នន័យប្រមូលបាន គេក៏ឆ្លុះបញ្ចាំងពីប្រភពឥណ្ឌា និងអធិប្បាយតាមទិន្នន័យទាំងអស់នោះ ។

ការលំបាកខ្លាំងបំផុត នៅតែកើតតមកក្រោយទៀត នៅពេលដែលការចាប់អារម្មណ៍របស់អ្នកប្រាជ្ញ ឈានដល់កម្ពុជាសម័យថ្មី និងតាមដានអំពីភាពផ្សេងៗ

នៃវប្បធម៌របស់កម្ពុជា ដូចជា សាសនា អក្សរសិល្ប៍ និងសិល្បៈ ( របាំ និងភ្លេង ) ហើយនិងស្ថាប័ននយោបាយ ។ បន្តិចមក គេបាននិយាយថា កម្ពុជាខ្ចីលក្ខណៈពិសេសសំខាន់ពីប្រទេសសៀម ដែលពួកគេហៅយ៉ាងច្បាស់ថា " សៀមបុរាណ " ។ ការអះអាងនោះ គឺខុសរយៈពេលគ្នាយ៉ាងពិត ( anachronic ) ពីព្រោះ សៀមបុរាណចាប់កំណើតដំបូងពីសតវត្សទី ១៣ ជាងនេះទៅទៀត យើងមានការសោកស្តាយដោយសារតែភាពរាក់កំភែលរបស់អ្នកនិពន្ធ ហើយធំបំផុត ការប្រមូលឯកសារមិនគ្រប់ និងសមត្ថភាពមិនពិតប្រាកដ ។

៣. សំណាងល្អ ស្ថានភាពនេះបានចាប់ផ្តើមជ្រះស្រឡះ ពេលមកដល់មុនទសវត្សឆ្នាំ ៥០ ប៉ុណ្ណោះ ។ គឺនៅពេលភាសាវិទូបានចាប់អារម្មណ៍ផ្ទាល់អំពីខ្មែរ និងជឿជាក់ច្បាស់ថាខ្មែរមិនមែនជាផលិតផលបន្ទាប់បន្សំនៃវប្បធម៌ឥណ្ឌា និងសៀម ។ អ្នកត្រួសត្រាយការសិក្សាភាសាខ្មែរសម័យថ្មីដំបូងគេ គឺលោក ម៉ាទីនី (Martini) នៅប៉ារីស និងលោកស្រី ហេនដឺសុន (Henderson) នៅឡុងដុង ។ គាត់ទាំងពីរនាក់បានសិក្សាហ្វូណោម៉ិចភាសាខ្មែរថ្មី (Modern Khmer phonemics) គឺជាការស្រាវជ្រាវ [១] ដ៏ពេញលេញមួយ ដោយការប្រើប្រាស់គ្រប់វិធី និងឧបករណ៍ដែលបានទទួលពីភាសាសាស្ត្រទូទៅ (general linguistics) ទោះបីពួកគាត់ប្រើប្រាស់អ្នកជំនួយជាជនជាតិខ្មែរម្ចាស់ស្រុកក៏ដោយ ។

ថ្វីបើអ្នកទាំងពីរ នៅស្រុកផ្សេងពីគ្នា មានគោលបំណងខាងបញ្ហាខុសគ្នា ពួកគាត់ទាំងពីរធ្វើកិច្ចការស្ទើរតែដូចគ្នា ដែលរួមមាន :

ក. ការពិនិត្យពិច័យទិន្នន័យដោយម៉ត់ចត់ ។

ខ. ការពិពណ៌នាទិន្នន័យ ដោយប្រៀបធៀបមូលដ្ឋានរបស់វាពីមួយទៅមួយ នៅក្នុងចំណោមភាសាខ្មែរ ហើយក្រោយមក ប្រៀបធៀបជាមួយភាសានៅ

---

(១) សូមមើល, ឯកសារពិគ្រោះ ។

ក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

គ. ប្រមូលទិន្នន័យទាំងនោះបញ្ចូលគ្នា ដើម្បីបង្កើតប្រព័ន្ធសទ្ទវិទ្យាខ្មែរ (the phonological Khmer system) ឡើង ។

នោះគឺជាការមិនអាចជំទាស់បាន ចំពោះដើមកំណើតនៃភាសាវិទ្យាខ្មែរ ដែលគេអោយឈ្មោះយ៉ាងពិត និងត្រឹមត្រូវថាជា " មុខវិជ្ជា " ( discipline ) និងដែលបានដាក់បញ្ចូលទៅក្នុងភាសាវិទ្យាទូទៅ [១] ។

ជាងនេះទៅទៀត លោកស្រី ហេនដឺសុន និងលោក ម៉ាទីនី បានចំណាយពេលវេលាបណ្តុះបណ្តាលវិជ្ជាជាន់ខ្ពស់ ស្តីពីការស្រាវជ្រាវដំបូងរបស់លោក ដល់មនុស្សក្មេងៗ ដែលខ្ញុំក៏នៅក្នុងចំណោមនោះដែរ ។ ពិតប្រាកដហើយ នៅពេលនោះពួកយើងមានគ្នាតិចណាស់ ដែលបានធ្វើការស្រាវជ្រាវអំពីភាសាវិទ្យាអាស៊ីអាគ្នេយ៍ ប៉ុន្តែ យើងបានចាត់ចែងតាស់រំលើងបង្ហាញវិស័យរូបសាស្ត្រ (morphology) វេយ្យាករណ៍ ព្រមទាំងសទ្ទានុក្រមវិទ្យា (lexicography) ។

ជាពិសេស នៅក្នុងវិស័យទាំងនោះ យើងត្រូវបញ្ជាក់អំពីជំនួយដ៏ធំ ដែលការស្រាវជ្រាវចុះអង្កេត និង ការបោះពុម្ពផ្សាយរបស់អ្នកប្រាជ្ញទីទៃៗ ស្តីអំពីភាសាមន-ខ្មែរ បានផ្តល់អោយយើង ហើយគឺខ្ញុំ ជាអ្នកបានទទួលផលប្រយោជន៍ទាំងនោះមុនគេ ដូចដែលយើងនឹងអធិប្បាយជាបន្តបន្ទាប់ ។

ក៏ប៉ុន្តែ បន្តិចក្រោយមក ខ្ញុំបានបែកចេញបន្តិចពីមាតិចំបងនៃការស្រាវជ្រាវនោះ ពីព្រោះតែការប្តេជ្ញាដំបូង និងយ៉ាងមាំរបស់ខ្ញុំ ដើម្បីរាវរកប្រវត្តិនៃភាសាខ្មែរ គឺជាមាតិមួយដែលគេសំរួលហៅថា " Diachronic " ( ប្រវត្តិនៃការរីកចំរើន

---

(១) យើងគួរតែធ្វើការបញ្ជាក់ផងដែរ អំពីឈ្មោះលោក ពីនណូវ (Pinnow) (នៅប៊ែរឡាំង) និងលោកហ្គរហ្គោនីញ៉េវ (Gorgoniev) (នៅម៉ូស្គូ) ទោះជាយ៉ាងណា ពួកគាត់ពិតជាបានចំណាយពេលខ្លីណាស់ក្នុងការសិក្សាពីភាសាវិទ្យាខ្មែរ ពីព្រោះតែពេលវេលាមិនអំណោយផល ។

ឬបរិវត្តន៍ផ្នែកអក្សរសាស្ត្រ ) ។ សំរាប់គោលបំណងនេះ ខ្ញុំបានបង្កើតមាតិកាពីរ :

ក. ខ្ញុំអានគ្រប់អត្ថបទដើមអក្សរខ្មែរ គឺអក្សរថ្ម ( ពីសតវត្សទី ៦ ដល់ ១៨ នៃគ.ស. ) ដោយក្រសែភ្នែកជាភាសាវិទូម្នាក់ ។

ខ. បន្ទាប់មក ខ្ញុំរៀនភាសាសំស្ក្រឹត និងអរិយធមិឥណ្ឌា ។

គ. ខ្ញុំសិក្សាភាសាបាលិ និងឫសគល់នៃពុទ្ធសាសនាថេរវាទ ។

និយាយម្យ៉ាងទៀត ខ្ញុំត្រូវតែបង្កើតមូលដ្ឋានវប្បធមិច្បាស់លាស់មួយ និងរឹងមាំនៅក្នុងការសិក្សាភាសាវិទ្យារបស់យើង ។ និយាយដោយខ្លី អស់រយៈពេល ១០ ឆ្នាំ នៃការស្រាវជ្រាវដ៏នឿយហត់ ធ្វើអោយខ្ញុំអាចសង្កេតឃើញសម័យ ៣ នៅក្នុងប្រវត្តិនៃអក្សរខ្មែរ គឺសម័យបុរាណ កណ្តាល និងទំនើប ។ ដោយពិតទៅ សម័យកាលចុងក្រោយ ជាលទ្ធផលកើតចេញពីការវិវត្តិន៍តៗគ្នា ពីសម័យមុនៗទាំងពីរ ។ នោះហើយ គឺជាកំណើតនៃ Khmerology គឺនៅក្នុងកំឡុងទសវត្សឆ្នាំ ៧០ និងបានសេចក្តីអះអាងមួយផ្សេងទៀតអំពីភាសាវិទ្យាខ្មែរថាជា " មុខវិជ្ជា " មួយ ។

រយះពេលយ៉ាងយូរក្រោយមក ការស្រាវជ្រាវអំពីភាសាខ្មែរទំនើប កាន់តែទូលំទូលាយ និងត្រូវបានអនុវត្តនៅភ្នំពេញនេះឯង ដោយភាសាវិទូដែលបានទទួលការបណ្តុះបណ្តាល ជាងនេះទៅទៀត ពួកគេចេះភាសាខ្មែរគ្រប់គ្រាន់ ហើយថែមទាំងមានសមត្ថភាពបណ្តុះបណ្តាលអ្នកស្រាវជ្រាវក្មេងៗនៅទីនេះបានទៀតផង[(១)] ។ ការអធិប្បាយនេះ ធ្វើក្នុងបំណងសរសើរភាសា ភាសាវិទូទាំងអស់ សូម្បីអ្នកទាំងនោះ ខ្ញុំមិនបានរាប់ឈ្មោះអស់ក៏ដោយ ។ ក្នុងពេលជាមួយគ្នានោះ ខ្ញុំបានបំពេញបង្ហើយកិច្ចការចងក្រងវចនានុក្រមភាសាខ្មែរចាស់ . បារាំង . អង់គ្លេស ( បោះពុម្ព

---

(១) ស៊ិលវ៉ាំង វ៉ូហ្គេលេ បានសំរេចការងារស្រាវជ្រាវដ៏អស្ចារ្យ នៅភ្នំពេញនេះ បន្ទាប់មក ស្នាដៃ ដ៏ល្អកម្រកបាននេះ គេបានបោះពុម្ពផ្សាយក្នុង Journal Asiatique (Paris) និងក្នុង Cahier d'études franco-cambodgiens (Phnom penh).

ឆ្នាំ ១៩៩២ ) ។

ក៏ប៉ុន្តែ ខ្ញុំត្រូវតែបង្ហាញអោយឃើញនូវស្ថានភាពមិនទាន់ពេញលេញមួយទាក់ទងនឹងការប្រើប្រាស់ឯកសារខ្មែរ ។ ការពិតនៅខណៈដែលខ្ញុំជាប់រវល់អានសត្រានិងវិភាគអត្ថបទតាមហេតុផលភាសាវិទ្យា ខ្ញុំបានកត់សំគាល់ឃើញថា សត្រាភាគច្រើនបំផុត មិនដែលមានគេយកមកសិក្សាសំរាប់គោលបំណងឯទៀតឡើយ ។ សត្រាភាគច្រើនបំផុត ដោយពិតទៅ ផ្តល់ជាឯកសារដ៏ច្រើនគគោកសំរាប់ការស្រាវជ្រាវប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងសាសនា ។ ជាងនេះទៀត គេពិបាកនឹងនិយាយថា មានអ្នកស្រាវជ្រាវខ្លះអាចអានអត្ថបទសត្រាចប់ចុងចប់ដើម ដោយឥតបានរត់រកអ្នកជំនួយការជាជនជាតិម្ចាស់ស្រុកឡើយ ។ អ្នកជួយទាំងនោះ ជាអ្នកស្រុកទូទៅដែលអាចចេះត្រឹមតែអានអត្ថបទ ដោយមិនបានស្គាល់បន្តិចអំពីគោលនៃការអានអត្ថបទ ឬនិយាយអោយស្រណុកស្តាប់ គាត់គ្មានដឹងអ្វីបន្តិចអំពីក្បួនខ្នាតភាសាសាស្ត្រ សំរាប់ប្រើប្រាស់សត្រា ។

តាំងពីយូរយារណាស់មកហើយ នៅឆ្នាំ ១៩៨៥ ខ្ញុំបានប្រកាសអំពាវនាវដើម្បីជួសជុលការខ្វះខាតនេះ (១) ថែមទាំងខ្ញុំបានស្ម័គ្រចិត្តជួយ ក្នុងការអានអត្ថបទសិលាចារឹក និងទាំងអត្ថបទសត្រា ។ ប៉ុន្តែ គ្មានឮអ្នកណាម្នាក់ឆ្លើយតបសោះ រហូតមកដល់ឥឡូវនេះ ។ ក្នុងពេលជាមួយគ្នានោះដែរ អ្នកស្រាវជ្រាវទាំងឡាយបានបន្តការងារយ៉ាងរំភើយក្នុងវិស័យផ្សេងៗ និងមុខការផ្សេងៗ ដោយឥតរវល់បន្តិចចំពោះឯកសាររាប់រយជាភាសាខ្មែរ ដែលនៅតែរង់ចាំអ្នកស្រាវជ្រាវពិនិត្យ ជាពិសេស នៅក្នុងបណ្ណាល័យបារាំងធំៗ ។

*( នៅមានត )*

---

(១) បាឋកថាសំដែងនៅសង្គមអាស៊ី (Société Asiatique) (នៅប៉ារីស) នៅមុខចំណោមអ្នកចេះដឹង រួមទាំងអ្នកប្រវត្តិសាស្ត្រកម្ពុជា ខ្លះទៀត ។

# សិលាចារឹកប្រាសាទចក និង ព្រះបាទជ័យវម៌្ម ទី៣

រៀបរៀងដោយ **ហម ឆាយលី**

> សូមឧទ្ទិសជូនលោកស្រីបណ្ឌិត ពៅ សាវរស ដែលបានខិតខំពង្រាយចារិកសាស្ត្រនេះមកដល់ខ្ញុំ ។ ខ្ញុំសូមថ្លែងកតញ្ញុតា និងថ្លែងអំអរគុណដ៏ជ្រាលជ្រៅ ។

លំនាំដើម :

សិលាចារឹកប្រាសាទចក [1] លេខជំរឿន (K 521) ជាឯកសារយ៉ាងសំខាន់ ស្តីអំពីព្រះបាទជ័យវម្មទី ៣ លក្ខណសម្បត្តិ និងស្នាដៃរបស់ទ្រង់ និង ប្រវត្តិខ្លះៗ ដែលទាក់ទងនឹងការទាក់ដីរ នៅប្រទេសកម្ពុជា ។

ខ្ញុំបានប្រទះសិលាចារឹកនេះ ហើយដែលខ្ញុំចង់បង្ហាញ ដូចតទៅនេះ :

១ . ព្រះបាទជ័យវម្មទី ៣

ទ្រង់ឡើងសោយរាជ្យ នៅឆ្នាំ ៧៧២ នៃមហាសករាជ (គ.ស. ៨៥០) ។ ក្រោយពេលសុគតទៅនៅឆ្នាំ ៧៩៩ មហាសករាជ (គ.ស.៨៧៧) ព្រះអង្គទទួលព្រះនាមថា « ព្រះបាទវិស្ណុលោក » ។ សម័យក្សត្រអង្គនោះ រាជធានីមានឈ្មោះថា « ហរិហរាល័យ » នៅតំបន់ស្រុករលួសសព្វថ្ងៃ ។ បើយោងទៅតាមយោបល់នៃអ្នកស្រាវជ្រាវខ្លះថា ព្រះរាជវាំងនៅពេលនោះ ស្ថិតនៅត្រង់កន្លែងប្រាសាទព្រៃមន្ទីរ

---

(1) Cf. Cœdès George, " Inscriptions du Cambodge ", t. IV, EFEO, Paris 1952 : 168-69

បើប្រៀបទៅនឹងព្រះរាជាដទៃទៀត នៅសម័យអង្គក្សត្រអង្គនេះមិនបានទុកស្នាដៃអ្វី ដែលមានភាពដ៏អស្ចារ្យនោះទេ ។ ព្រះអង្គគ្រាន់តែមានសាងសំណង់បន្ថែមខ្លះនៅតាមប្រាសាទផ្សេងៗ មានប្រាសាទត្រពាំងផុង ប្រាសាទគោកពោធិ ជាដើម [1] ។

ឯការគោរពបូជាខាងសាសនាវិញ គេកត់សំគាល់ឃើញថា ព្រះអង្គនិយមជាពិសេសលទ្ធិព្រះនារាយណ៍ [2] ការកត់សំគាល់នេះគឺអាងទៅលើចំណុចពីរ : ទី១ គឺសង្កត់ទៅលើព្រះនាមព្រះអង្គក្រោយពេលសុគតទៅ ដូចបានពោលខាងលើ ។ ទី២ ដោយសារការពិនិត្យលើសិលាចារឹក ជាពិសេស សិលាចារឹកប្រាសាទចក ដែលខ្ញុំនឹងបង្ហាញជូនខាងក្រោមនេះ ។

ក្រៅអំពីនេះ មានសិលាចារឹកផ្សេងទៀត ដែលធ្វើអោយយើងបានដឹងថា ព្រះរាជាអង្គនេះចូលចិត្តប្រពាតព្រៃ បរបាញ់សត្វ និងទាក់សត្វ ។ ក្រៅអំពីសិលាចារឹកប្រាសាទចក មានសិលាចារឹកជាភាសាបាលី សំស្រ្កឹត ដែលគេរកឃើញនៅប៉ាលហាល ស្រុកមោងឫស្សី ( ខេត្តពោធិសាត់ ) ក៏មាននិយាយអំពីរឿងនេះដែរ [3] ដូចជា សិលាចារឹក K 449 មានចែងថា ព្រះបាទវិស្ណុលោក មានអ្នកទាក់ដីរបស់ទ្រង់ពីរនាក់ ម្នាក់ឈ្មោះ កណ្ឌបាសា ម្នាក់ទៀតឈ្មោះ ព្រាហ្មរាសិក ជាអ្នក

---

(1) Cf. GROLIER, B.P, Indochine, Carrefour des Arts, Albin-Michel, Paris 1961: 89-90, Cœdès, G. Etudes cambofgiennes (XXXVIII), " Nouvelles présisions sur les dates d'avenement de quelques rois des dynasties angkoriennes ", BEFEO, XLII, Hanoi 1943-46 : 12

(2) រីបិតារបស់ទ្រង់ ពោលគឺ ព្រះបាទវរ្ម័ទេពទី២ (គ.ស.៨០២-៨៥០) និងព្រះបាទឥន្ទ្រវរ្ម័ (គ.ស. ៨៧៧-៨៨៩) ដែលសោយរាជ្យបន្តពីព្រះអង្គនោះ សុទ្ធសឹងតែជាព្រះរាជានិយមខ្លាំងទៅលើលទ្ធិនៃព្រះឥស្វរ ។

(3) Cf AU, Chhieng " Etudes Philogie Indo-khmére ", Journal Asiatique, t. CCLIV, 1962: 151

ជិនិតរបស់ទ្រង់ ហើយជាអ្នកប៉ិនប្រសប់ ពូកែក្នុងការទាក់ដំរីនេះណាស់ ។ អ្នកទាក់ដំរីទាំងពីរនាក់នេះ តែងតែចេញទៅទាក់ដំរីជាមួយព្រះអង្គជានិច្ច មានថ្ងៃ មួយនោះទ្រង់ ទាក់ដំរីបានបី ៖ មួយឈ្មោះ ស្វេតភៈ ( ដំរីស ) ទីពីឈ្មោះ ស្វេតបុច្ឆក (កន្ទុយស) ទីបីឈ្មោះវ៉ៃស៊ី (1) ។ តាមសិលាចារឹកដទៃទៀត ជាអាទិ៍ សិលាចារឹក ក. ៩៥៦ បានចារទុករឿងនេះថា ទ្រង់បានយាងទៅទាក់ដំរី មានព្រះអង្គម្ចាស់មួយអង្គ ( ឥន្ទ្រវម្ម ) បានយាងហែទៅជាមួយទ្រង់ដែរ (2) ។ ហើយតាមសិលាចារឹកនេះបានបន្ថែមទៀតថា មានថ្ងៃមួយនោះ ព្រះបាទវិស្ណុលោកបានយាងទៅក្រុងហរិបូរៈ ។ ពេលនោះ ស្តេចដំរីរបស់ទ្រង់ « ស្រីជៃសិក្សាធមិ » ត្រូវដាច់បាត់នៅទីនោះ ។ ទើបទ្រង់បញ្ជាអោយអ្នកផងហៅភូមិនោះថា « សារពាច់ » ដោយសារដំរីសារនោះដាច់ ។ តែក្រោយមកទៀត ភូមិនោះហៅក្លាយមកទៀតថា « ភូមិស្រពាច់ » ។

ដូច្នេះ បើតាមសិលាចារឹក ខ្ញុំអាចសន្និដ្ឋានបានថា ៖

ក) ការទាក់ដំរីនេះ មានបំណងដ៏ធំគឺ យកមកប្រើប្រាស់សម្រាប់ស្តេចជាមធ្យោបាយដឹកនាំសម្រាប់គមនាគមន៍ និងការធ្វើដំណើររបស់ព្រះមហាក្សត្រព្រោះមានមុខងាររបស់មន្ត្រីវាំងខ្លះឈ្មោះ « ខ្លោញមុខដំរី » បានន័យតាមភាសាខ្មែរទំនើបថា មេបញ្ជាការខាងដំរី ។

ខ) ព្រះអង្គមិនគ្រាន់តែជាអ្នកទាក់ដំរីយកមកផ្សាំង សម្រាប់ប្រើប្រាស់ប៉ុណ្ណោះទេ គឺទ្រង់ផ្សាំងសម្រាប់ធ្វើសឹកទៀតផង (3) ដូច្នេះ ទ្រង់ជាមេទ័ពផ្នែកទ័ពដំរី ។

---

(1) Cf . Cœdès George, " Etudes Cambogiennes ", XI, La stèle de palhal, BEFEO, XIII, 1913: 27-36

(2) Cf. Cœdès, G. " Inscriptions du Cambodge ", BEFEO, t. VII, 1964: 134

(3) Cf. Cœdès, George, t. VII, 1964: 134

ទ្រង់ប្រកបដោយគុណសម្បត្តិយ៉ាងប្រពៃ ជាក្សត្រក្លាហាន ធ្វើសឹកពុំដែលចុះញ៉មសត្រូវ ហើយព្យាយាមរកសេចក្តីចំរើន ទាំងធម៌ ទាំងវិជ្ជា ទាំងសម្បត្តិជាដរាប [1] ។

២ . អារ្យធម៌ខ្មែរដែលទាក់ទងនឹងដំរី :

ព្រហ្មញ្ញសាសនា ដែលមានដើមកំណើតនៅប្រទេសក្លឹង្គ បានផ្សព្វផ្សាយចូលមកដល់ប្រទេសយើង តាំងតែអំពីដើមប្រវត្តិម៉្លេះ ។ ដូច្នេះ ទើបព្រះមហាក្សត្រសម័យនោះ ដែលគ្រប់គ្រងប្រទេសយើង ទ្រង់និយមសាសនានេះបន្តបន្ទាប់មក ។ ដោយសារការគោរពបូជាដល់សាសនានេះ ព្រះមហាក្សត្រ និងរាស្ត្រខ្មែរ បានខិតខំសាងរូបចម្លាក់ជាច្រើន តំណាងដល់ទេពសាសនា ដូចជារូបព្រះឥន្ទ្រ ដែលមានជំនិះរបស់លោកគឺ « ដំរីក្បាល ៣ » [2] ដែលមានឈ្មោះថា « អៃរាវត្ត » ។ ម្យ៉ាងវិញទៀត នរណាក៏ជួបប្រទះដែរ នូវចម្លាក់ជាច្រើនតាមជញ្ជាំងប្រាសាទនានា គេឃើញអតីតមហាក្សត្រខ្មែរនៅប្រាសាទបាយ័ន ព្រះបាទស្រីជ័យវម៌្មទី ៧ គង់លើព្រះទីនាំងគជេន្ទ្រ បញ្ជាទ័ពយ៉ាងអង់អាចខ្លាំងក្លា ច្បាំងកំចាត់សត្រូវ ។ ចំពោះឯកសារជាក់លាក់ ដែលយើងអាចឃើញបានតាមរយៈសិលាចារឹក ក៏មានវត្ថុច្រើនដែលថែងអំពីដំរី [3] ឬវត្ថុនិទានខ្លះស្តីអំពីអ្នកគង្វាលដំរី [4] ព្រមទាំងមានក្បួនពិធីទាក់ដំរីទៀត ។

---

(1) Cf. POU Saveros " Vocabulaire Khmere relatif aux Eléphants ", *Journal Asitique*, CCLXXIV, 1986 : 401.

(2) នៅក្នុងលទ្ធិព្រហ្មញ្ញសាសនា ទេពនីមួយៗមានជំនិះប្រចាំព្រះអង្គរៀងៗខ្លួន ដែលគេហៅថា ពាហនៈនោះ គឺ : ព្រះឥន្ទ្រ មានដំរីក្បាលបីជាជំនិះ, ព្រះឥសូរ មានគោជាយានជំនិះ, ព្រះនារាយ មានគ្រុឌជាជំនិះ, ព្រះព្រហ្ម មានហង្សជាជំនិះ, ព្រះគនេស មានកណ្តុរជាជំនិះ, ព្រះអគ្គី មានរមាសជាជំនិះ ។

(3) Cf. Cœdès, George, Insciption du Cambodge, t. IV,EFEO, 1952 : 147.

(4) Cf. Pou Saveros, Ibid, 1986 : 318

ផង [1] ព្រោះការទាក់ដំរីនៅស្រុកយើង មានតំបន់ពីរគឺ តំបន់ភ្នំក្រវាញ និងតំបន់ជើងព្រៃ ។

ដូច្នេះ ដំរីជាសត្វមួយដែលមានប្រវត្តិ និងរឿងរ៉ាវច្រើនដែលទាក់ទងនឹងអារ្យធម៌ខ្មែរ ។ ប៉ុន្តែ យើងពុំមានឯកសារពីបុរាណ ដែលស្តីអំពី « គជសាស្ត្រ ជាវិទ្យាសាស្ត្រ » [2] សុទ្ធសាធ ដែលអត្ថាអធិប្បាយអំពីដំរីនោះសោះទេ ។

រីប្រាសាទចកដែលជាប្រាសាទដ៏តូច ហើយបាក់បែកខ្លាំង ដែលស្ថិតនៅប្រមាណបីគីឡូម៉ែត្រខាងទិសពាយ័ព្យនៃទីក្រុងសៀមរាប ។ ប្រាសាទទាំងមូលនេះមានតួប្រាសាទតូចៗពីរតម្រៀបគ្នាទទឹងថ្ងៃ ពោលគឺ ប្រាសាទមួយពីខាងជើង ប្រាសាទមួយទៀតពីខាងត្បូង ។ នៅលើមេទ្វារនៃតួប្រាសាទខាងជើង មានសិលាចារឹកមួយជាភាសាខ្មែរ តែមិនទាក់ទងអ្វីចំនឹងព្រះបាទស្រីជ័យវម្មិទី៣ ឡើយ ។ ដូច្នេះ យើងលើកយកតែសិលាចារឹក ដែលនៅលើមេទ្វារនៃប្រាសាទខាងត្បូងមកបង្ហាញជូននៅទីនេះ និងអារ្យធម៌របស់ខ្មែរយើង ដែលមានប្រវត្តិនៃសត្វដំរីនេះប្រទាក់ប្រទងគ្នាគ្រប់កាលសម័យ ដូចខ្ញុំបានពណ៌នាពីខាងលើស្រាប់ ។

• សិលាចារឹកប្រាសាទចក

(ចម្លងជាអក្សរខ្មែរទំនើប)

(១) ៧៧២ សក គិ នុ ព្រះ បាទ ស្រីជៃវម៌្មទេវ ស្តាច៑ ទៅ វិស្ណុលោក ត រាជបុត្រ (២) វ្រះ បាទបរមេស្វរ វ្រះ ... វ្រៃ ស្លា អនិន ស្វេយ រាជ ឆ្នាំ តបិ ប្រ (៣) ម្វាយ៑ ចាបិ តំម្រ្យ ទុកិ ... លាង៑ មន្ទ តំម្រ្យ រតិ ច្វលិ ត វ្រៃ (៤) នេះ ត ជ្នះ

(1) POU, Saveros, Ibid 1986 : 314

(2) Cf. ELLUL, J., Le coutumier rituel des capteurs d'Eléphant de l'Ouest du Cambodge, these de 3ème Cycle, Paris, EPEHSS, 1983

វិស្ណុគ្រាំម យប៊ ផ្ទំ ត គិ ស្ញំ ប្រត្យាទេស យោល៊ កំ (៥) ម្រតេង៑ អញ៑ វៃស្ណវ ម្វាយ៑ បនិទ្វល៑ ត វ្រះ បាទ វិស្ណុលោក ថា ទ (៦) ហ ញ្យាង វិ ... បិ ស្ថាប រូប អញ៑ ភក្តិ ្យ អញ៑ ឱ្យ តំម្រ្យ (៧) នោះ វិង៑ ឧទៃយ គុះ អំបាន តំម្រ្យ នោះ ត វ្រៃ នេះ បនិទ្វល៑ (៨) ផ្គា ត នេះ ស្ថាបនា រូប្ប កំម្រតេង អញ សក ព្រាហ្មណ ទិ (៩) ក្សា ជ្នះ វិស្ណុគ្រាំម ជូន ភូមិ ត្រេយ៑ ជ្នង៑ប្រាង៑ អ្និ អញ៑ ខ្ញុំ បំច្យាំ (១០) ម្វាយ៑ ជ្នះ តេង៑ ហ្យង៑ ជា ស្វាមិ្យ លោញ លស ជា វ្រះ ខ្លៃ តោ (១១) យ៑ វ្រះ ទ្វាយ មក៑ ជូន៑ ត វ្រះ នេះ ប្រេ បំម្រេ បន្ទល៑ វ្រះ សរិរ. (១២) តេង៑ ហ្យង៑ នុ លោញ៑ លស៑ បង្គំ ថប្វង៑ និវេទន ស្ញំ ភូមិ នុ យេង៑ ខ្ញុំ (១៣) បំច្យំម បំម្រេ ត ជា ចំម្រ្យេង៑ ... វ្រះ បាទ កំម្រតេង៑ អញ៑ ករុណា ប្រ (១៤) សាទ ភូមិ សោតិ អាយ៑ ... អ្នោយប្វរ ចំនត៑ វ្យរ៑ ណ្ឌិវាស ចំន (១៥) ត៑ ទូក៑ ឆ្លោង៑.

## អត្ថាធិប្បាយ និងពន្យល់

### ពាក្យបំព្រួញដែលប្រើក្នុងអត្ថបទនេះ :

ពាក្យខ្មែរចាស់ : ខ.ច. ។ សំស្រ្កឹត : សំ ។

បំបែកពាក្យ : បំ.ពា. ( ត្រូវនឹងពាក្យបារាំងថា : Dérivé ) ។

ពាក្យក្លាយ : ព.ក្លា. ។

E.F.E.O. : École Française d'Extrême-Orient ។

រីឯអត្ថន័យនៃពាក្យផ្សេងៗ ដែលខ្ញុំយកមកពន្យល់ជូនក្នុងទីនេះ គឺយោងទៅតាមស្នាដៃរបស់លោកស្រីបណ្ឌិត ពៅ សាវរស វចនានុក្រមខ្មែរចាស់ - បារាំង អង់គ្លេស, មជ្ឈមណ្ឌលឯកសារ ស្រាវជ្រាវអារ្យធម៌ខ្មែរ, បារិស ឆ្នាំ ១៩៩២ ។

១ - ព្រះបាទស្រីជៃវម្មទេវ : « វម្មទេព » បានជាខ្ញុំសរសេរដូច្នោះ ពីព្រោះនាមរបស់ព្រះមហាក្សត្រខ្មែរសម័យអង្គរ ច្រើនតែភ្ជាប់ពីខាងចុង « វម្ម » ជាពាក្យ

សំស្ក្រឹត ។ សរសេរជាខ្មែរទៅជា វម្មិ, ពម្មិ ។ ឧ. ស្រីសុរិយោវម្មិ ឬ ពម្មិ ( ប្រយត្ន័កុំច្រឡំនឹង វណិ, ពណិ សំ. ឬ វណ្ណ បា. ), ស្រីជ័យវម្មិទី ៧ ។ ព្រះបាទស្រីឥន្ទ្រ-វម្មិ ។ ល ។ វិពាក្យ « ទេព » ខាងចុង អាចហៅសំដៅលើព្រះក៏បាន គឺបុគ្គលដែលខ្ពស់ឆ្នើមលើគេ ដូចជាព្រះមហាក្សត្រ ឬនាហ្មឺនជាន់ខ្ពស់ ។ ( ការសន្ទនាជាមួយលោកស្រីបណ្ឌិត ពៅ សាវរស ) ។

ខ្ញុំពុំមែនជាអ្នកប្រវត្តិសាស្ត្រ, ខ្ញុំគ្មានសមត្ថភាពអ្វីនឹងកែប្រែប្រវត្តិសាស្ត្រខ្មែរទេ ។ ខ្ញុំហ៊ានអះអាងនេះ ដោយសារខ្ញុំបានឃើញសិលាចារឹកជាភាសាខ្មែរផ្ទាល់ភ្នែក ។ ដូច្នេះ សំណូមពរខ្ញុំគឺ សុំអោយអ្នកប្រវត្តិសាស្ត្រខ្មែរ, អ្នកសិក្សាស្រាវជ្រាវ, សាស្ត្រាចារ្យ, និស្សិតនានា ផ្តោតភ្នែកមើលលើឯកសាររបស់ដូនតាយើងផ្ទាល់ និងវិនិច្ឆ័យអោយបានល្អិតល្អន់ផង មិនត្រូវស្តាប់ ឬតាមសេចក្តីអត្ថាធិប្បាយផ្តាប់មុខតែបរទេសនោះទេ ( Cf. K 249, Corpous des Inscriptions du Cambodge, Volume III, planche CXXV ( 1ère ligne ) , Cœdès, G. K 33, IC, t III, EFEO 1951 : 149: 18, 30, 32, 33, et 150. ។

២ . វិស្ណុលោក ៖ ព្រះនាមរបស់ព្រះបាទស្រីជ័យវម្មិទេពទី ៣ ក្រោយអំពីទ្រង់ចូលសុគតទៅ ។ ដូច្នេះ ព្រះបាទស្រីជ័យវម្មិទេពទី ៣ គឺព្រះវិស្ណុលោក ។ សោយរាជ្យ ពីគ.ស. ៨៥០ - ៨៧៧ ។

៣ - ព្រះបាទបរមេស្វរ ៖ ជាព្រះនាមរបស់ព្រះបាទស្រីជ័យវម្មិទេពទី ២ ( បិតារបស់ព្រះបាទស្រីជ័យវម្មិទេពទី ៣ ) ។ ក្រោយអំពីទ្រង់ចូលសុគតទៅ ។ ដូច្នេះព្រះបរមេស្វរ គឺព្រះបាទស្រីជ័យវម្មិទេពទី ២ ។ សោយរាជ្យ ពីគ.ស. ៨០២-៨៥០ ។ គេឃើញនៅក្នុង « សិលាចារឹកស្តុកកក់ធំ » ដែលមានចែងអំពីព្រះអង្គ និងក្រុមគ្រួសាររបស់ទ្រង់ច្រើន ៖ ការបង្កបង្កើតជាក្រុមគ្រួសារ, ការកាន់កាប់ដីធ្លី, ការរៀបចំភូមិ ស្រុក និងការរៀបចំខាងសាសនា ។ តែជាពិសេសទៅទៀត ទ្រង់ជាអ្នកស្ថា-

បនិកនៃរបាក្យត្រខ្មែរ ... ( Cf. Cœdès, G. et Dupont, Pierre " Les stéles de Sdok kak Thom, Phnom Sandak et Prah Vihar ", BEFEO, XLIII, Hanoi 1943-46) ។

៤ . អនិន សំ : ដែលមិននិន្ទា ពាក្យផ្ទុយនឹងនិន្ទា ។

៥ . ញ្យាង ឬ ញាំង ខ.ច. ខិតខំប្រឹងប្រែងធ្វើ ។ ខ.ទ. គឺញាំង តែពុំសូវប្រើក្នុងភាសានិយាយទេ ។

៦ . ប្រត្យាទេស សំ : ឃើញច្បាស់ជាក់ស្តែង ឃើញប្រាកដ ។

៧ . កំម្រតេងអញ ខ.ច. : ហៅចំពោះព្រះ ឬព្រះមហាក្សត្រ ឬជាគ្រូរបស់ព្រះមហាក្សត្រ ។

៨ . ឧទ័ទ សំ : ពេលព្រលឹម ពេលព្រឹក ជោគជ័យ សេចក្តីសង្ឃឹម ។

៩ . ទិក្សា សំ : ពិធីបុណ្យតាមសាសនាព្រាហ្មណ៍សម្រាប់ឆ្លង សម្ពោធ ឬបំបួសសិស្សអោយទៅជាព្រាហ្មណ៍ឡើង ។

១០ . អំបាន ខ.ច. បានមកជាសិទ្ធិ ។ អំបាន < បាន ។

១១ . សកទ្រាហ្មណ សំ : ឈ្មោះនៃព្រះមួយព្រះអង្គក្នុងលទ្ធិព្រះនារាយ។

១២ . ត្រេយជ្នងប្រាង : ជាឈ្មោះភូមិ ឬស្រុក ? តែគេពុំឃើញមានឈ្មោះស្រុកនេះទេ សព្វថ្ងៃនេះ ។

១៣ . ជ្ជិ ឬ អជិ ខ.ច. : ញាតិសាលោហិតជំនាន់មុនឪពុកម្តាយ ។

១៤ . វ្រះឡាយ ខ.ច. : អ្នកបំរើស្តេច ឬបំរើទេព ( ព្រះនីមួយៗ ) ។

១៥ . ប្រសាទ សំ. : ( រាជស័ព្ទ ) ឱ្យ អនុញ្ញាត ប្រទានឱ្យអ្វីទៅនរណាម្នាក់ ។ ប្រយ័ត្ន កុំច្រឡំនឹងពាក្យ « ប្រាសាទ » ។

១៦ . អ្មោយបូរ សំ. : ( អានថា អមោយបូរ ) ជាក្រុងនៃព្រះឥសូរ ។

១៧ . ចំនត ខ.ច. ស្រុក ។ ចំណោត < ចត ឬចាត បានន័យថា គ្រប់គ្រង

អភិបាល ។

<u>ចំណាំ</u> :

ខ្ញុំឆ្លៀតឱកាសនេះពន្យល់ពាក្យ «បំបែកពាក្យ» និង «ពាក្យក្លាយ» ។ ការដែលយើងយកពាក្យរបស់គេ ( ពាក្យបារាំង ) ។ ល ។ មកតម្រូវនឹងពាក្យខ្មែរយើង តែងតែមានចាកអត្ថន័យខ្លះ ដោយច្ចនកាល យើងយល់ពាក្យរបស់គេពុំច្បាស់

ក) បំបែកពាក្យ បំ.ពា. ( ត្រូវនឹងពាក្យបារាំងថា Dérivé ) គឺដោយសារពាក្យដើមជាឫស ខ្មែរយើងបំបែកបានជាពាក្យមួយទៀត ( ជាការធម្មតា របស់ភាសានិមួយៗ ) ។ ឧទាហរណ៍ «កើត» បំបែកពាក្យថា «កំណើត» ។ «ចោទ» បំបែក ពាក្យថា «ចំណោទ» ។ «សង់» បំបែកពាក្យថា «សំណង់» ។ «ចត» បំបែកពាក្យថា «ចំណត» ខ.ច. ឬ «ចាត» បំបែកពាក្យថា «ចំណាត» ។ ល ។

ខ) ពាក្យក្លាយ : ព.ក្លា. ។

ឧទាហរណ៍ទី ១ : ស្វាយដីរីក្លាយ, ស្វាយរហូតក្លាយ, ដំបៅក្លាយ ( ក្លាយ បំបែកពាក្យថា កម្លាយ ឬ ក្លាយ > កម្លាយ ) ។ ការចាកឃ្លាតអំពីភាពដើម ទាំងរាងរៅ ទាំងឱជារស ។ បើ « ពាក្យ » វិញ ការឃ្លាតចាកទាំងរូបរាងនៃពាក្យ ទាំងអត្ថ-ន័យ ។ ឧទាហរណ៍ « ឆ្កោប » ខ.ច. បានន័យថា : យកពន្ធដារខាងអំបិលពីសម័យដើម ។ ពាក្យ « ឆ្កោប » នេះ បំបែកពាក្យជា « ចង្កោប » គឺជាពន្ធអាករនេះ ។ ដូច្នេះ ទូក សំពៅ ឬឈ្មួញទាំងអស់ ត្រូវតែចូលមកបង់ពន្ធអាករជាដាច់ខាត ។ ការដែលចូលមកបង់ពន្ធដារនេះ ជាញឹកញាប់ទៅៗ រៀងរាល់ថ្ងៃ ខែ ទើបពាក្យ « ឆ្កោប » បំបែកពាក្យ បំ.ពា. ( ត្រូវនឹងពាក្យបារាំងថា Dérivé ) គឺដោយ «ឆ្កោប » ក្លាយទៅជា « ជើងកប » ។ ដូច្នេះ នៅកន្លែងណាមួយ ដែលមានគ្រោះថ្នាក់ : ក្រឡាប់រថយន្ត, ភ្លូករទេះ, លិចទូក, សំពៅ, កប៉ាល់ ញឹកញាប់ ឬក្មេងលង់ទឹកញឹកញយទៅ ទើបខ្មែរយើងហៅកន្លែងនេះថា « កន្លែងជើងកប » ។ ( ការសន្ទនា

ជាមួយលោកស្រីបណ្ឌិត ពៅ សាវរស ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩០ ) ។

ឧទាហរណ៍ទី ២ : ក្រុង « យសោធរបុរ » គឺជាក្រុងដែលសាងឡើងដោយព្រះបាទស្រីយសោវម្មទី ១ គឺអង្គរសព្វថ្ងៃ បានន័យថា ជាក្រុងដែលប្រកបដោយយស ឬជ័យជំនះ (ព្រះបាទស្រីយសោវម្ម សោយរាជ្យពីគ.ស. ៨៨៩-៩០០ ។ ព្រះនាមរបស់ទ្រង់ក្រោយពេលចូលសុគតទៅ គឺ ព្រះបរមស៊ីវលោក) ។ ក្រោយមកដោយសារវប្បធម៌ខ្មែរចុះអន់ថយ ខ្មែរវង្វេងលែងស្គាល់អក្សរសាស្ត្រ និងប្រវត្តិសាស្ត្រនៃជាតិខ្លួន ទើបពាក្យនេះហៅក្លាយថា « ស្រីសន្ធរ ឬស៊ីធរ » ជាទីក្រុង នាសម័យកណ្ដាល ។ រហូតមកដល់សព្វថ្ងៃនេះ ខ្មែរហៅក្លាយបន្តមកទៀតថា : « ស្រីសឈរ » ( សូមអានបន្ថែមទៀត ពៅ សាវរស វចនានុក្រមខ្មែរចាស់ - បារាំង - អង់គ្លេស, ឆ្នាំ ១៩៩២ ទំព័រ ៣៨៣ ) ។

## • សិលាចារឹកប្រាសាទចក

( ប្រែជាភាសាខ្មែរទំនើប )

មហាសករាជ ៧៧២ ( គ.ស. ៨៥០ ) មានក្សត្រមួយព្រះអង្គ ព្រះនាមព្រះបាទស្រីជៃវម្មទេវ ដែលបានទៅកាន់ស្ថានព្រះវិស្ណុរួចហើយនោះ ជាព្រះរាជបុត្ររបស់ព្រះបាទបរមេស្វរ ( សូមអានសេចក្ដីពន្យល់ខាងលើ ) ។ ក្សត្រអង្គនេះមានដើមកំណើតនៅស្រុកជ្រៃស្លាអនិន្ទិតបុរ បានឡើងសោយរាជ្យបាន ១៦ ឆ្នាំ ។ ថ្ងៃមួយទ្រង់បានចេញទៅបោះជំរំដើម្បីទាក់ដំរី ។ ដំរីដែលទាក់បាននោះ ក៏រត់ចូលទៅក្នុងព្រៃវិញបាត់ទៅ នៅកន្លែងមួយដែលមានឈ្មោះសព្វថ្ងៃថា វិស្ណុគ្រាមនេះ ។ លុះដល់ពេលយប់ ក្សត្រអង្គនេះចូលព្រះបន្ទំ ទ្រង់សូមឱ្យមាននិមិត្ត ។ ស្ដេចក៏បានឃើញជាក់ច្បាស់នូវកំប្រទេងអញ វៃស្ណវមួយអង្គ មានព្រះបន្ទូលមកកាន់ទ្រង់ថា យើងនឹងឱ្យដំរីនេះមកព្រះអង្គវិញ បើសិនព្រះបាទអង្គខិតខំស្ថាបនារូបព្រះកំម្រតេងអញ

( វៃស្នូវ ) ដោយភក្តី ព្រមទាំងគោរពបូជាដល់ព្រះកំម្រតេងអញ ។

គ្រាន់តែព្រឹកស្វាងឡើង ព្រះបាទស្រីជ័យវម្មិទី ៣ ក៏បានឃើញដីនោះវិញដូចព្រះបំណង ។ ព្រះអង្គក៏មានបន្ទូលដល់ព្រះរាជការនានា ឱ្យកាប់ឆ្ការព្រៃកន្លែងនោះ រួចឱ្យសាងរូបកំម្រតេងអញ « វៃស្នូវ » ហើយឱ្យនាមកន្លែងនោះថា «វិស្នុគ្រាម» ព្រមទាំងគោរពធ្វើបុណ្យតាមសាសនាព្រាហ្មណ៍ផង ។ ព្រះអង្គបានថ្វាយភូមិត្រើយថ្នងប្រាងទុកជាសម្បត្តិរបស់ព្រះកំម្រតេងអញទៀតផង ។ មានញាតិសាលោហិតរបស់អញខ្ញុំមួយ ឈ្មោះតែងហ្យង ដែលត្រូវជាភរិយាលោកលស ដែលត្រូវជាបងថ្លៃនៃទ្រង់ ( ព្រះបាទស្រីជ័យវម្មិទេពទី ៣ ) បានយកភស្តុភារមកថ្វាយដល់ព្រះកំម្រតេងអញ ( វៃស្នូវ ) ហើយបានបញ្ជាឱ្យដល់អ្នកបំរើទាំងអស់ចាំបំរើបូជាដល់ព្រះកំម្រតេងអញនេះ ជំនួសព្រះបាទស្រីជ័យវម្មិទេពទី ៣ ផង ។

តែងហ្យង និងលោញលស ជាអ្នកចម្រៀង បានបង្គំទូលដល់ព្រះបាទស្រីជ័យវម្មិទេពទី ៣ សូមដីមួយកន្លែង ។ ព្រះបាទស្រីជ័យវម្មិទេពទី ៣ ក៏បានអនុញ្ញាតឱ្យដីភូមិនោះ ដែលនៅជិតអ្នោយបូរ គឺនៅតំបន់ពីរណ្ដិវាស និងតំបន់ទូកឆ្លង ដល់តែងហ្យង និងលោញលស ។

ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩២

# បច្ឆាមរណនាម និង នាមព្រះមហាក្សត្រខ្មែរ នៅសម័យអង្គរ

( តាមសិលាចារឹក )

# Posthumous Names and Names of Khmer Kings during Angkorian period

(through inscriptions)

ដោយ **ខង់ សុធារ៉ា**
សាស្ត្រាចារ្យ នៃដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
សកលវិទ្យាល័យភូមិន្ទ ភ្នំពេញ មណ្ឌល ២

ឯកសារប្រវត្តិសាស្ត្រខ្មែរ ចាប់តាំងពីដើមសន្តតិវង្ស រហូតមកដល់សព្វថ្ងៃនេះ គឺសុទ្ធសឹងជាស្នាដៃរបស់អ្នកប្រាជ្ញជនជាតិបារាំង ដែលបានចងក្រងឡើងផ្អែកលើប្រភពនៃឯកសារចិន ឯកសារចាម ឯកសារសិលាចារឹកភាសាសំស្ក្រឹតភាសាខ្មែរ ភាសាសំស្ក្រឹតលាយខ្មែរ និងភាសាបាលី ព្រមទាំងឯកសារកំណត់ហេតុផ្សេងៗ របស់អ្នកជំនួញ ឬអ្នកដំណើរជាតិអឺរ៉ុប ។ អំពីឈ្មោះស្តេចមួយចំនួន ត្រូវបានអ្នកស្រាវជ្រាវបំពេញបន្ថែម តាមរយៈសំនេរជាភាសាចិន ។ ឯកសារភាគច្រើនត្រូវបានចារឹកនៅលើផ្ទាំងសិលា (ពីសតវត្សទី ៦ ដល់ដើមសតវត្សទី ១៤) ដែលអាចធ្វើអោយអ្នកស្រាវជ្រាវដែលចេះអក្សរទាំងនោះ មានភាពងាយស្រួលក្នុងការចងក្រង ប៉ុន្តែ អ្នកស្រាវជ្រាវជំនាន់ក្រោយដែលមិនចេះអក្សរទាំងនោះវិញ មិនសូវយកចិត្តទុកដាក់លើឯកសារដើមដ៏មានតម្លៃអស់ទាំងនោះទេ ។ ទោះជាយ៉ាងណា នៅពេលចាប់ផ្តើមស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរតាមរយៈសិលាចារឹក ទើបខ្ញុំដឹងថា វាមានការលំបាកច្រើន ក្នុងការរកឈ្មោះស្តេចនីមួយៗ ។

ពីព្រោះ នៅក្នុងទំនៀមទម្លាប់ខ្មែរ ព្រះមហាក្សត្រមួយអង្គៗ តែងតែមាន

ព្រះនាមបីយ៉ាងតិច គឺនាមពេលនៅជាព្រះអង្គម្ចាស់ (មុនពេលឡើងសោយរាជ្យ) ពេលសោយរាជ្យ និងនាមពេលក្រោយពេលចូលទិវង្គត ។ ចំណែកនៅតាមសិលាចារឹកនានា តាំងពីសម័យមុនអង្គរ រហូតដល់សម័យអង្គរ បើសិនចារឹកនៅពេលស្ដេចគង់ជាធរមាននៅឡើយ ច្រើនមិនដាក់ព្រះនាមស្ដេច ប៉ុន្តែ បើចារឹកក្រោយពេលស្ដេចចូលទិវង្គត ច្រើនដាក់មរណនាមទេវិញ ។ ការនេះហើយដែលទាមទារអោយអ្នកស្រាវជ្រាវ ចាំបាច់ត្រូវប្រមូលឯកសារយ៉ាងច្រើនមកផ្ទៀងផ្ទាត់គ្នា ។

ម្យ៉ាងទៀត មិនមែនគ្រប់តែព្រះមហាក្សត្រ សុទ្ធតែបានចារឹកមរណនាមខ្លួននោះទេ ដូចជា នៅសម័យមុនអង្គរ យើងឃើញមានព្រះមហាក្សត្រ ប្រហែលជាពីរអង្គប៉ុណ្ណោះ ដែលបានបន្សល់ទុកមរណនាម ។

១. ព្រះបាទជយវរ្ម័នទី១ ( ៦៥៨-៦៨១ គ.ស ) មាននមរណនាមថា «វ្រះកម្រតេងអញ តទៅ សិវបុរ (vraḥ kamrateṅ añ ta dau Çivapura)» (1) ។

២. ព្រះបាទបុស្ករាក្ស មានមរណនាមថា «វ្រះកម្រងតេង អញ ស្រីន្ទ្រលោក (vraḥ kamrateṅ añ Çrīndraloka)» (2) ជាក្សត្រមួយអង្គនៃប្រទេសចេនឡាទឹកលិច ដែលជាប់ខ្សែខាងសោមវង្ស និងជាបុព្វការីជនរបស់ព្រះបាទជយវរ្ម័នទី២ ។

ហេតុនេះ ដើម្បីងាយស្រួលក្នុងការកំណត់ឈ្មោះស្ដេចនៅតាមសិលាចារឹក ដែលមានដាក់តែបច្ឆាមរណនាម ទើបនៅពេលនេះ ខ្ញុំបានរួបរួមបច្ឆាមរណនាម និងនាមរបស់ព្រះមហាក្សត្រ នៅសម័យអង្គរមកបង្ហាញ ពីព្រោះវាមានភាពចាំបាច់ជាងគេ ។

---

(1) Cf. Cœdès George " Inscriptions du Cambodge" Vol. II, K 561, pp. 39-44 et op cit, Vol. IV, K 904, pp. 54-63.

(2) voir, G. Cœdès " Inscriptions du Cambodge " Vol. III pp.170-173 et op cit, Vol. I, K 826, pp.31-36 et op cit, Vol. VIII, p.21 et P. Dupont " La dislocaltion du Tchen-la " dans BEFEO, XLIII p.17.

១. <u>វ្រះបាទ បរមេស្វរ</u> vrah̥ pāda Parameçvara = ព្រះបាទជយវរ្ម័នទី២ ។ Jayavarman II (802-850 AC) ពេលកំពុងសោយរាជ្យនៅឡើយ មានព្រះនាមថា dhūli vrah̥ pāda dhūlijeṅ vrah̥ kamrateṅ añ çri Jayavarmmadeva ដំបូងគ្រងរាជ្យនៅឥន្ទ្របុរ (Indrapura) ដែលជាទឹកដីរបស់ស្តេចអញ សិវកៃវល្យ (Çivakaivalaya) ក្រោយពីព្រះអង្គយាងត្រឡប់មកពីស្រុកជ្វា (Javā) ។ បន្ទាប់មក ហរិហរាលយ (Hariharālaya) អមរេន្ទ្របុរ (Amarendrapura) និងមហេន្ទ្របុរ (Mahendrapura) នៅលើមហេន្ទ្របវ៌ត (Mahendraparvvata) (ភ្នំគូលេន) ដែលព្រះអង្គបានប្រារព្ធពិធីអភិសេកឡើងសោយរាជ្យនៅទីនោះ នាឆ្នាំ ៨០២ នៃគ.ស ហៅថាពិធីកល្យាណសិទ្ធិ (Kālyānasiddhi) ដោយព្រាហ្មណ៍ឈ្មោះ ហិរណ្យទាម (Hiranyadāma) ។ ចុងក្រោយ ព្រះអង្គត្រឡប់មកទីក្រុងហរិហរាលយវិញ រហូតដល់ចូលទិវង្គត ។

ព្រះអង្គបានលើកព្រាហ្មណ៍ សិវកៃវល្យ ជារាជបុរោហិត ជារាជគ្រូ និងបញ្ញត្តអោយតែបច្ឆាជននៃត្រកូលនេះមួយគត់ ជាអ្នកទទួលតំណែងជារាជបុរោហិតមាននាទីរៀបចំពិធីទេវរាជាទៅថ្ងៃក្រោយ ដោយសារគាត់បានរៀនវិជ្ជាអស់ទាំងនេះ (វ្រះវិនាសិខ វ្រះនយោត្តរ វ្រះសំមោហ និងវ្រះសិរស្ចេទ) ពីព្រាហ្មណ៍ហិរណ្យទាម។

ព្រះបាទបរមេស្វរ ជាស្តេចដែលបានចាប់ផ្តើម « បើកសករាជសម័យអង្គរ » គឺបង្កើតលទ្ធិមួយ ដែលតម្រូវអោយព្រះមហាក្សត្រមានឋានៈដូច « អាទិទេព »[3] ។

---

(3) នាមព្រះមហាក្សត្រនៅសម័យអង្គរ ដែលមាននៅលើសិលាចារឹក សុទ្ធសឹងបញ្ចប់ដោយពាក្យ « ទេវះ » នៅបន្ទាប់ពាក្យ «វម៌្ម» ( . វម៌្មទេវះ ) លើកលែងតែស្តេចមួយអង្គ គឺ « ព្រះបាទនឫបតិន្ទ្រវរ្ម័ន » ដែលរជ្ជកាលរបស់ព្រះអង្គ នៅកំឡុងចុងសតវត្សទី ១១ គឺនៅពេលដំណាលគ្នានឹងព្រះបាទជយវរ្ម័នទី ៦ ។

២. វ្រះបាទ វិស្ណុលោក vraḥ pāda Viṣṇuloka = ព្រះបាទជយវរ្ម័នទី៣ (4) Jayavarman III (850-877 AC) ព្រះនាមពេលសោយរាជ្យ «ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រីជយវម៌្មទេវ» ។

ព្រះអង្គជាព្រះរាជបុត្តព្រះបាទ បរមេស្វរ ។ តាំងរាជធានីនៅ ហរិហរាលយ ដដែល ។ ចូលចិត្តខាងការទាក់ដំរី ដើម្បីបង្កើតស្រុក ស្ថាបនា បង្កើតសន្តាន។

រាជបុរោហិត នាមសុក្សវិន្ទុ (Sukṣamavindu) ។

៣. វ្រះបាទ ឦស្វរលោក vraḥ pāda Īçvaraloka = ព្រះបាទឥន្ទ្រវរ្ម័នទី១ Indravarman I (877-889 AC) ព្រះនាមពេលសោយរាជ្យ dhūlī vraḥ pāda dhūli jeṅ vraḥ kamrateṅ añ Çrindravarmmadeva.

ព្រះអង្គកសាងប្រាសាទ បាគង ( ទេវរាជ ) ព្រះគោ ( ឧទ្ទិសដល់បុព្វបុរសរបស់ខ្លួន ) និងស្ថាបនាបារាយណ៍ឥន្ទ្រតដាក ។

ព្រះអង្គជាបងប្អូនជីដូនមួយព្រះបាទ វិស្ណុលោក ។ តាំងរាជធានី នៅ ហរិហរាលយ ។

គ្រូបាធ្យាយព្រះអង្គនាម វាមសិវ ដែលជាចៅព្រាហ្មណ៍ សិវកៃវល្យ និងជាសិស្សព្រាហ្មណ៍ សិវសោម ដែលមានគោរម្យងារថា កម្រតេង៑ សិវាស្រមចាស្ស (Kamrateṅ Çivāçrama Cāss) ( កម្រតេងសិវាស្រមចាស់ ) ។ ស្តេចអញ្ជើញវាមសិវ មានគោរម្យងារថា កម្រតេង៑ សិវាស្រមកន្មេង៑ (Kamrateṅ Çrivāçrama Kanmyaṅ) ( កម្រតេងសិវាស្រមក្មេង ) ។

៤. វ្រះបាទ បរមសិវលោក vraḥ pāda Paramaçivaloka =

---

(4) មុនពេលឡើងសោយរាជ្យ ព្រះនាមជយវធ៌ន Jayavardhana, Cf. Bergaigne A. " Inscriptions sanscrite de Campā et du Cambodge " Paris, 1885-1889 No. XLIV, p.357.

ព្រះបាទយសោវរ្ម័នទី១ Yaçovarman I (889-910 AC)[5] ព្រះនាមពេលសោយរាជ្យ dhūlī vraḥ pāda dhūlī jeṅ vraḥ kamrateṅ añ Çri Yaço-varmmadeva ។

ព្រះអង្គស្ថាបនាទីក្រុងថ្មីមួយទៀតឈ្មោះ យសោធបុរ (cat nagara çri Yaçodharapura) ស្ថាបនាប្រាសាទភ្នំសំរាប់រាជ្យ នៅលើវ្នំកន្តាល (Vnaṃ Kantāl) ( សំស្ក្រឹត ៖ មធ្យាទ្រិ ) មានន័យថា « ភ្នំកណ្តាល » គឺត្រូវគ្នានឹងប្រាសាទភ្នំបាខែង, សាងប្រាសាទលលៃ ( នៅកណ្តាលបារាយណ៍ឥន្ទ្រតដាក ) បារាយណ៍ខាងកើត ( យសោធរតដាក ) និងទំនងជាអ្នកសាងប្រាសាទភ្នំក្រោម និងភ្នំបូកផងដែរ ។

ក្នុងរាជ្យព្រះអង្គ តួអក្សរដែលខ្មែរខ្ចីពីអក្សរព្រហ្មី និងបានអភិវឌ្ឍជាបន្តបន្ទាប់ចាប់តាំងពីសតវត្សទី៦ ត្រូវបានកែច្នៃអោយកាន់តែមានសោភ័ណ និងដាក់ឈ្មោះថា « កម្ពុជាក្សរ » (Kamvujākṣara) ។

រាជបុរោហិតនាម ហិរណ្យរុចិ (Hiranyaruci) ឬស្តេងអញ វ្នំកន្សា (steṅ añ vnamkansā) ត្រូវជាប្អូនរបស់ កម្រតេងសិវាស្រម ។

៥. ព្រះបាទ រុទ្រលោក vraḥ pāda Rudraloka = ព្រះបាទហសិវរ្ម័នទី១ Harṣavarman I (910-922 ? AC) ព្រះនាមពេលសោយរាជ្យ dhūlī vraḥ pāda dhūlījeṅ vraḥ kamrateṅ añ Çri Harṣvarmmdeva.

ព្រះអង្គកសាងប្រាសាទបក្សីចាំក្រុង និងចារឹកកំណាព្យសំស្ក្រឹត្យ យ៉ាងវែងនៅលើសុំទ្វារ ដែលពិពណ៌នាអំពីព្រះរាជវង្សានុវង្សព្រះឥសិកម្ពុ-ទេពអប្សរមេរាជាក្សត្រខាងសូរ្យវង្ស និងព្រះកៅណ្ឌិន្យ-សោមា ជាក្សត្រខាងសោមវង្ស ។

---

(5) see, Chakravarti Adir " The Sdok Kak Thom Inscription " Part II, Calcutta, 1980, pp.73-108.

រាជបុរោហិតនាម កុមារស្វាមិ (Kumārasvāmi) ដែលត្រូវជាក្មួយ កម្រេងតេងសិវាស្រម ។

៦. វ្រះបាទ បរមរុទ្រលោក vraḥ pāda Paramarudraloka = ព្រះបាទ ឦសានវរ្ម័នទី២ Içãnavarman II (925-928 AC) (6) សោយរាជ្យក្នុងកាលៈទេសៈប្រទាញប្រទង់គ្នាជាមួយព្រះបាទជយវរ្ម័នទី៤ ។

៧. វ្រះបាទ បរមសិវបទ vraḥ pāda Paramaçivapada = ព្រះបាទជយវរ្ម័នទី៤ Jayavarman IV (921-941 AC) ព្រះនាមពេលសោយរាជ្យ « ធូលីវ្រះបាទធូលិជេងវ្រះកម្រតេងអញជយវម្មិទេវ » ។

ព្រះអង្គជាប្អូននៃព្រះបាទ យសោវរ្ម័នទី១ សោយរាជ្យប្រជែងជាមួយក្មួយ គឺព្រះបាទ ហសិវរ្ម័នទី១ និង ឦសានវរ្ម័នទី២ ដោយតាំងរាជធានីនៅ ឆោកគរគ្យារ (ឆោកគគីរ Chok Gargyar) គឺកោះកេរ្តិ៍ (7) ។

រាជបុរោហិតនាម ព្រាហ្មណ៍ឦសានមូត្តិ (Içānamūrtti) ដែលត្រូវជាចៅព្រាហ្មណ៍ កម្រតេងសិវាស្រម ។

ព្រះអង្គសាងប្រាសាទភ្នំ សំរាប់រាជ្យមួយនៅទីនោះ ដែលមានខឿន ៧ ជាន់ ។

៨. វ្រះបាទ វ្រហ្មលោក vraḥ pāda Vrahmaloka = ព្រះបាទហសិវរ្ម័នទី២ Harṣavarman II (941-944 AC) ព្រះនាមពេលសោយរាជ្យ « ធូលីវ្រះបាទធូលិជេងវ្រះកម្រតេងអញស្រីហសិវម្មិទេវ » ។

ព្រះអង្គសោយរាជ្យនៅរាជធានីកោះកេរ្តិ៍ របស់ព្រះបាទជយវរ្ម័នទី៤ ជាព្រះបិតា ។

---

(6) Cf. BEFEO, Tome XV, 1915, p.183, et Chakravarti A. op cit, p.135-137

(7) ស្ថិតនៅទិសឦសានទីក្រុងយសោធបុរ (អង្គរ) ចម្ងាយប្រហែល ១០០ គីឡូម៉ែត្រ ។

រាជបុរោហិតព្រាហ្មណ៍ អាត្មសិវ (steṅ añ Ātmaçiva) ត្រូវជាក្មួយព្រាហ្មណ៍ ឰសានមូត្តិ ។

៩. វ្រះបាទ សិវលោក vraḥ pāda Çivaloka = ព្រះបាទរាជេន្ទ្រវម៌្មន (8) Rājendravarman (944-968 AC) ព្រះនាមសំរាប់រាជ្យ «ធូលីវ្រះបាទធូលិជេងវ្រះកម្រតេងអញស្រីរាជេន្ទ្រវម្មិទេវ» ។

ព្រះអង្គត្រូវជាក្មួយព្រះបាទយសោវម៌្មនទី១ និងត្រូវជារជ្ជទាយាទ នៃមហាក្សត្រមហេន្ទ្រវម៌្មន និងព្រះនាងមហេន្ទ្រទេវី ដែលជាប្អូនស្រីព្រះបាទយសោវម៌្មនទី១ សោយរាជ្យនៅនគរភវបុរ បានលើករាជធានីត្រឡប់មកយសោធបុរវិញ ។ នៅសម័យព្រះអង្គ ទឹកដីចេនឡាដីគោក (ភវបុរ) ត្រូវបានភ្ជាប់មក « កម្វុជទេស » ដែលមានរាជធានីធំនៅអង្គរ ។ ព្រះអង្គបានសាងប្រាសាទភ្នំពីរ គឺ ប្រែរូប ( គ.ស ៩៦១ ) និងមេបុណ្យខាងកើត ។

រាជបុរោហិត ព្រាហ្មណ៍ អាត្មសិវ ។

១០. វ្រះបាទ បរមវិរលោក vraḥ pāda Paramaviraloka = ព្រះបាទជយវម៌្មនទី៥ Jayavarman V (968-1001 AC) ព្រះនាមពេលសោយរាជ្យ «ធូលីវ្រះបាទធូលិជេងវ្រះកម្រតេងអញស្រីជយវម្មិទេវ» ។

ព្រះអង្គកសាងបង្ហើយប្រាសាទកែវ ឬតាកែវ ។ រាជគ្រូ ព្រាហ្មណ៍ យជ្ញវរាហ (Yajñavarāha) ។ រាជបុរោហិត ព្រាហ្មណ៍ សិវាចាយ៌្យ (steṅ añ Çivācāryya) ជាចៅរបស់ព្រាហ្មណ៍ អាត្មសិវ ។

១១. វ្រះបាទ ស្រីឧទយាទិត្យវម្មិទេវ vraḥ pāda çri Udayādityavarmmadeva = ព្រះបាទឧទយាទិត្យវម៌្មនទី១ (9) Udayādityavarman I

(8) មុនពេលឡើងសោយរាជ្យ ព្រះនាមគរភេិស្វរៈ (Garbheçvara) ។ Cf. K 806, 1.13. et Cœdès G. I.C. Vol. I, p.107. • (9) Cf, BEFEO, K 682, p.15, n. 2

(1001-1002 AC) ព្រះនាមពេលសោយរាជ្យ « ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រីឧទយាទិត្យវម្មទេវ » ព្រះអង្គសោយរាជ្យមិនបានមួយឆ្នាំផង ក៏ត្រូវបាត់ខ្លួនជាយថាហេតុ ។

១២. <u>វ្រះបាទស្រីជយវីរវម្មទេវ</u> vraḥ pāda çrī Jayavīravarmmadeva ឬ ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រីជយវម្មទេវ = ព្រះបាទជយវរ្ម័ន Jayavarman (1002-1006 AC) ។

១៣. <u>វ្រះបាទ បរមនិវ្វាណបទ</u> vraḥ pāda Paramanirvvāṇapada = ព្រះបាទសូរ្យវរ្ម័នទី១ Suryyavarman I (1002-1050 AC) ព្រះនាមពេលសោយរាជ្យ «ធូលីវ្រះបាទកម្រតេងកំត្វនអញស្រីសូយ៌្យវម្មទេវ» (10) ។ (vraḥ pāda kamrateṅ kamtvan añ çrī Sūryyavarmmadeva) ។

ព្រះអង្គតម្រូវអោយមន្ត្រីទាំងអស់ធ្វើសច្ចាប្រណិធាន ដូចមានចារឹកនៅលើសសរក្លោងទ្វារចូលប្រាសាទភិមានាកាស និងប្រាសាទឃ្លាំងជើង-ត្បូង ។ ព្រះអង្គជាក្សត្រកាន់ព្រហ្មញ្ញសាសនា និកាយព្រះសិវ (11) ។ ព្រះអគ្គមហេសី ព្រះនាមវីរលក្ស្មី ជាប់ខ្សែជាមួយព្រះបាទហរិវរ្ម័នទី១ និង ឦសានវរ្ម័នទី២ ។

ព្រះអង្គកសាងប្រាសាទឃ្លាំងជើង-ត្បូង ភ្នំជីសូរ្យ ភ្នំព្រះវិហារ ស្ថាបនាបង្ហើយប្រាសាទភិមានាកាស និងប្រាសាទវត្តឯកភ្នំ ជាដើម ។

---

(10) លោក សឺដេស ថាព្រះបាទជយវរ្ម័ន និងសូរ្យវរ្ម័នទី១ គឺជាស្តេចតែមួយអង្គ ។ ព្រះនាមវ្រះកម្រតេងអញស្រី ជយវីរវម្មទេវ ប្រើចាប់ពីឆ្នាំ ១០០២-១០០៦ នៃគ.ស បន្ទាប់មក ព្រះអង្គ ប្តូរព្រះនាមថា ធូលីជេងវ្រះកម្រតេងកំត្វនអញស្រី សូយ៌្យវម្មទេវ វិញ ។ Cf. Cœdès G. " Articles sur le pays Khmer " Tome II, Paris 1992, p.73.

(11) តាមលោក ហ្សក សឺដេស អះអាងថា " ព្រះអង្គជាក្សត្រដែលកាន់ពុទ្ធសាសនាដំបូងគេ នៅសម័យអង្គរ " ។ ប៉ុន្តែ លោកបណ្ឌិត អាធិរ ចក្រពត្តិ អ្នកស្រីបណ្ឌិត ពៅ សាវរស និង លោកបណ្ឌិត ឡុង សៀមថា " ព្រះអង្គជាក្សត្រកាន់ព្រហ្មញ្ញសាសនា និកាយព្រះសិវ " ។

រាជបុរោហិត គឺធូលីជេងវ្រះកម្រតេង អញស្រីជយេន្ទ្របណ្ឌិត (dhūlī-jeṅ vraḥ kammrateṅ añ çrī Jayendrapaṇdita) ដែលត្រូវជាប្អូនថ្លៃរបស់ព្រះអង្គ ។ រាជធានី នៅអង្គរ ។

១៤. <u>វ្រះបាទស្រីឧទយាទិត្យវម្មិទេវ</u> vraḥ pāda çrī Udayāditya varmmadeva = ព្រះបាទឧទយាទិត្យវរ្ម័នទី២ Udayāvarman II (1049-1066 AC) ព្រះនាមពេលសោយរាជ្យ «ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រីឧទយាទិត្យវម្មិទេវ ឬ ធូលីជេងវ្រះកម្រតេងកំត្វនអញស្រីឧទយាទិត្យវម្មិទេវ» ។

ព្រះអង្គជាបុត្តព្រះបាទសូរ្យវរ្ម័នទី១ បានបង្កើតក្រុងអង្គរទី២ ដែលផ្ចិតនគរនៅត្រង់ប្រាសាទបាពួន ដែលជាប្រាសាទទេវរាជរបស់ព្រះអង្គ ។ ក្នុងរាជព្រះអង្គ មានការបះបោរបីលើ ។ ការបះបោរដឹកនាំដោយកំវៅ បានបំផ្លិចបំផ្លាញសិវលិង្គ បដិមាព្រះព្រហ្ម ព្រះនរាយណ៍ និងព្រះពុទ្ធ ។

ព្រះអង្គស្ថាបនាបារាយណ៍ខាងលិច ( បារាយណ៍ទឹកថ្លា ) ប្រាសាទមេ-បុណ្យខាងលិច នៅកណ្តាលបារាយណ៍ ដោយតម្កល់ព្រះបដិមាព្រះវិស្ណុផ្ទំ ធ្វើអំពីសំរិទ្ធ ។ លោកជីវតាក្វាន់ ដែលបានមកទស្សនាកម្ពុជទេស នៅឆ្នាំ ១២៩៦ នៃគ.ស ថា ព្រះរូបដែលនៅចំកណ្តាលស្រះនៃប្រាសាទនោះ មានទឹកហូរចេញពីផ្ចិតជាអចិន្ត្រៃយ៍ ព្រះគ្រូ វ្រះកម្រតេងអញស្រី ជយេន្ទ្របណ្ឌិត ។

១៥. <u>វ្រះបាទ សទាសិវបទ</u> vraḥ pāda Sadāçivapada = ព្រះបាទហសិវរ្ម័នទី៣ Harṣavarman III (1066-1080 AC) ព្រះនាមពេលសោយរាជ្យ « ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រីហសិវម្មិទេវ » ។

ព្រះអង្គជារាជបុត្តព្រះបាទសូរ្យវរ្ម័នទី១ ។ ព្រាហ្មណ៍បុរោហិត យោគីស្វរ-បណ្ឌិត [12] (Yogiçvarapaṇdita) ឯកសារលោក ត្រឹង ងា ថារាជបុរោហិត

(12) voir, Cœdès G. I.C. Vol. IV, 176-205

ព្រាហ្មណ៍ ទិវាករបណ្ឌិត (Divākarapaṇḍita) ។

១៦. វ្រះបាទ ស្រីនឫបតីន្ទ្រវម្ម vraḥ pāda çrī Nṛpatindra-varmma ឬ វ្រះបាទកម្រតេងអញស្រីនឫបតីន្ទ្រវម្ម = ព្រះបាទ នឫបតីន្ទ្រវរ្ម័ន (13) Narapatindravarman (1080-1113 AC) ។

ព្រះអង្គគ្រងរាជ្យនៅរាជធានី យសោធបុរ ដោយសារជាប់សាច់ញាតិជាមួយ ឬអាចជាព្រះអនុជព្រះបាទ ឧទយាទិត្យវរ្ម័នទី២ និងហសិវរ្ម័នទី៣ ។

១៧. វ្រះបាទ បរមកៃវល្យបទ vraḥ pāda Paramakaivalya-pada = ព្រះបាទជយវរ្ម័នទី ៦ Jayavarman VI (1080 (14) - 1107 AC) « ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រី ជយវម្មទេវ » ។

រាជបុរោហិត ព្រាហ្មណ៍ យោគីស្វរបណ្ឌិត ។ ត្រឹង ងា ថាទិវាករបណ្ឌិត (Divākarapaṇḍita) ។

១៨. វ្រះបាទ បរមនិស្កលបទ vraḥ pāda Paramaniṣkalpada = ព្រះបាទធរនិន្ទ្រវរ្ម័នទី១ Dharanindravarman I (1107-1113 AC) ព្រះនាមពេលសោយរាជ្យ « ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រីធរណីន្ទ្រវម្មទេវ » ។

១៩. វ្រះបាទ បរមវិស្ណុលោក vrah pāda Paramaviṣnuloka

---

(13) ព្រះអង្គមិនមែនជាស្តេចដែលបានទទួលរាជាភិសេកសោយរាជសម្បត្តិជាផ្លូវការទេ ដោយសារអតីតរាជបុរោហិត របស់ ព្រះបាទហសិវរ្ម័នទី៣ បានក្លាយទៅជាបុរោហិតរបស់ព្រះបាទជយវរ្ម័នទី៦ ។

(14) តាមសិលាចារឹកនោមវ៉ាន់ ចម្ងាយ ១០ គីឡូម៉ែត្រ ទិសឦសាននៃខេត្តកូរ៉ាត់ ចុះកាល បរិច្ឆេទ ១០០៤ សក គឺ គ.ស ១០៨២ ព្រះបាទជយវរ្ម័នទី៦ ត្រាស់បង្គាប់អោយមន្ត្រីជាច្រើន នាក់ថែរក្សា " ទេវាស្រមសមយុគ " គឺប្រាសាទនោមវ៉ាន់របស់ព្រះអង្គ ។ បើតាមសិលាចារឹក នេះ ព្រះអង្គពិតជាឡើងសោយរាជ្យនៅមុនឆ្នាំ ១០៨២ នៃគ.ស ។ Cf. Cœdès G. Vol. III, Paris 1951, pp. 134-136.

= ព្រះបាទសូរ្យវរ្ម័នទី២ (15) Sūryavarman II (1113-1150 AC) ព្រះនាមពេលសោយរាជ្យ « ធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអញស្រីសូយ៌្យវម្មិទេវ » ។

ព្រះអង្គសោយរាជ្យនៅទីក្រុងយសោធបុរ និងបានកសាងប្រាសាទអង្គរវត្ត ប្រាសាទភ្នំព្រះវិហារ និងស្ថាបនាបង្ហើយនូវសំណង់ប្រាសាទភ្នំជីសូរ្យ ។

២០. វ្រះបាទ មហាបរមនិវ្វានបទ vraḥ pāda Mahāparama nirvvāṇapada = ព្រះបាទធរណិន្ទ្រវរ្ម័នទី២ Dharaṇindra varman II (1150-11XX AC) ព្រះនាមពេលសោយរាជ្យ មិនឃើញមានជាភាសាខ្មែរ ។ ព្រះអង្គជាបុត្តព្រះអង្គម្ចាស់ មហីធរាទិត្យ ជាចៅព្រះបាទធរណីន្ទ្រវរ្ម័នទី១ និងជាបងប្អូនជីដូនមួយព្រះបាទសូរ្យវរ្ម័ន ដែលជាបច្ឆាជនព្រះបាទភវវរ្ម័នទី១ (16) ។

២១. វ្រះបាទ ស្រីយសោវម្មិទេវ vraḥ pāda çrī Yaçovarmma deva = ព្រះបាទយសោវរ្ម័នទី២ Yaçovarman II (11XX-1165 AC) ។

២២. វ្រះបាទ ស្រីតិភូវនាទិត្យវម្មិទេវ vraḥ pāda çri Tribhuvanādityavarmmadeva ឬ ( ធូលីវ្រះបាទធូលីជេងវ្រះ ) កម្រតេងអញស្រីតិភូវនាទិត្យវម្មិទេវ = ព្រះបាទត្រីភូវនាទិត្យវរ្ម័ន (17) Tribhuvanādityavarman (1165 ? - 1177 AC) ។

ព្រះអង្គរំជ្រែករាជ្យស្តេចយសោវរ្ម័នទី២ ក្រោយមក នៅឆ្នាំ ១១៧៧ ព្រះអង្គបានច្បាំងចាញ់ចាមពចាម ដែលចូលតាមទន្លេសាបទៅឡោមព័ទ្ធទីក្រុងអង្គរ ហើយ

---

(១៥) បច្ឆាមរណនាមមួយទៀតរបស់ព្រះអង្គ « មហាវិស្ណុលោក » (Mahāviṣṇuloka) Cf. Journal Asiatique, 1883 (2) K 298, pp.199-202, K 296, K 297, pp. 226-228 ; 1962, K 296, K 297, pp. 235-238.

(16) Cf. Cœdès G. " Articles sur le pays Khmer " t. I, Paris, 1989, pp. 170-177.

(17) សិលាចារឹកភ្នំកម ខេត្តចុងដុក កូសាំងស៊ីន K 418, see. Majumda " Inscriptions of Kambuja " Calcutta, 1951, pp. 458-459 ; BEFEO, t. XXIX, 1929, pp. 305-309.

ស្តេចខ្មែរអង្គនេះសុគតនៅក្នុងចម្បាំង ។ ក្រុងអង្គរ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ស្តេចចាម នាមជយឥន្ទ្រវរ្ម័នទី៤ អស់រយៈពេល ៤ ឆ្នាំ ។

២៣. វ្រះបាទ មហាបរមសៅគតបទ vraḥ pāda Mahāparamasaugatapada = ព្រះបាទជយវរ្ម័នទី៧ [18] Jayavarman VII (1181-1218 AC) ។ នាមព្រះអង្គពេលសោយរាជ្យ មិនមានចារឹកលើសិលាចារឹកភាសាខ្មែរ យើងមិនហ៊ានសន្មតយ៉ាងណាឡើយ ។ម្យ៉ាងទៀត សិលាចារឹកស្ទើរតែទាំងអស់ ដែលគេបានរកឃើញនៅកំឡុងរាជ្យព្រះអង្គ សុទ្ធសឹងសរសេរជាភាសាសំស្ក្រឹត ។

ព្រះអង្គកសាងប្រាសាទដ៏ច្រើនលើសលប់នៅដឹបន់អង្គរ ដូចជា ប្រាសាទបាយ័ន (សំរាប់ឧទ្ទិសពុទ្ធរាជ) ព្រះខ័ន ឬ ជយស្រី (ឧទ្ទិសចំពោះព្រះបិតា) នាគព័ន្ធ តាព្រហ្ម (ឧទ្ទិសចំពោះព្រះមាតា) បន្ទាយក្តី តាសោម ក្រោលគោ តានៃ បន្ទាយឆ្មារ តាព្រហ្ម បាទី (តាកែវ) វត្តនគរបាជយ (កំពង់ចាម) ភ្នំបាណន់ (បាត់ដំបង) ... ជាពិសេសគឺ ការកសាងក្រុងអង្គរទី៣ ប្រកបដោយកំពែងថ្មយ៉ាងក្រាស់ ដែលមួយជ្រុង១មានប្រវែង ៣ គីឡូម៉ែត្រ និងគូទឹកយ៉ាងធំសំបើម នៅព័ទ្ធជុំវិញ ។ ក្រុងនេះមានផ្ចិតនៅត្រង់ប្រាសាទបាយ័ន [19] ។

រាជគ្រូនាម ជយកិត្តិបណ្ឌិត (Jayakirttipandita) [20] ... ។

២៤. វ្រះបាទស្រីន្ទ្រវម្មិទេវ vraḥ pāda Çrindravarmmadeva = ព្រះបាទ ឥន្ទ្រវរ្ម័នទី២ [21] Indravarmn II (1220-124X? AC) ព្រះអង្គ

---

(18) Cf. Savaros POU " Novelles Inscriptions du Cambodge II " Paris, 1996, pp.174-182. • (19) សូមមើល ហ្សក សឺដេស «ជយវរ្ម័នទី៧» បកប្រែដោយលោក ជុំ ម៉ៅ ភ្នំពេញ ១៩៣៩, ៩៦ ទំព័រ • (20) Cf. AIBL, IC, t. III, K 226 Banteay Chmar, Paris, 1927. • (២១) ព្រះអង្គមិនបានបន្សល់ទុកនូវសិលាចារឹកជាភាសាខ្មែរ ។ បើតាមសិលាចារឹកភាសាសំស្ក្រឹត នៅ ➜

មិនបានបន្សល់ទុកនូវសិលាចារឹកជាភាសាខ្មែរ គេស្គាល់ព្រះអង្គតែតាមរយះអត្ថបទកំណាព្យភាសាសំស្ក្រឹត ដែលបានចារឹកនៅរជ្ជកាលក្រោយៗ ប៉ុណ្ណោះ ។

២៥. វ្រះបាទ បរមេស្វរបទ vraḥ pāda Parameçvarapada = ជយវរ្ម័នទី៨ Jayavarman VIII (12XX-1295 AC) ព្រះនាមពេលសោយរាជ្យ « ធូលីវ្រះបាទធូលីជេងកម្រតេងអញស្រីជយវម្មទេវ » ។

ក្នុងរាជ្យព្រះអង្គ គេមិនឃើញមានការកសាងសំណង់ថ្មីៗ សំខាន់ៗ ប៉ុន្តែឃើញមានការបំផ្លាញរូបចម្លាក់ បដិមា ដែលទាក់ទងពុទ្ធសាសនា អស់ច្រើនអន្លើ ។

រាជបុរោហិត ព្រាហ្មណ៍ មធុរេន្ទ្ររាជបណ្ឌិត (Madhurendrarāja-paṇḍita) និងព្រាហ្មណ៍[22] ជយមហាប្រធាន (Jayamahāpradhāna) ត្រូវ ជាឪពុកក្មេកព្រះអង្គផងដែរ ។

២៦. វ្រះបាទ ស្រីស្រីន្ទ្រវម្មទេវ vraḥ pāda kamrateṅ añ çrī Çrīndravarmmadeva ឬ វ្រះបាទកម្រតេងអញស្រីស្រីន្ទ្រវម្មទេវ = ព្រះបាទស្រីន្ទ្រវរ្ម័ន Çrīndravarman (1295-1307 AC) ។

ព្រះអង្គស្ថាបនាប្រាសាទថ្មតូចមួយ នៅតំបន់គោកស្វាយចេក (K 754) សព្វថ្ងៃ មានសិលាចារឹកភាសាបាលីមួយផ្ទាំងដំបូងគេរបស់ព្រះអង្គ ដែលមានកាលបរិច្ឆេទ 1230 សក[23] (គ.ស ១៣០៨) ។

ព្រះអង្គគោរពព្រះពុទ្ធសាសនា ។

ព្រះរាជគ្រូ ព្រាហ្មណ៍ យជ្ញវរាហ (vraḥ guru kamrateṅ añ Yajñavarāha) ។

---

ប្រាសាទអង្គរធំ K 567 ចារក្នុងរាជ្យព្រះបាទ ស្រីន្ទ្រជយវរ្ម័ន បានអោយដឹងថា នៅឆ្នាំ ១២៤៣ គ.ស ព្រះអង្គបានចូលទិវង្គតរួចទៅហើយ ។ see, Majumdar, op-cit, Calcutta 1951, pp. 540-548. • (22) see, Majumdar, op-cit, pp. 532-533. • (23) Voir, Çœdès G. op-cit, t. I, 1989, pp. 182-189.

២៧. <u>វ្រះបាទស្រីស្រីន្ទ្រជយវម្មទេវ</u> vraḥ pāda çrī Çrīndrajayavarmmadeva = ព្រះបាទ ស្រីន្ទ្រជយវរ្ម័ន Çrīndra Jayavarman (1307- 133X AC) ។

ព្រះរាជគ្រូ ជយមង្គលាថ៌ (Jayamaṅgalārtha) ។

២៨. <u>វ្រះបាទ ជយវម្មបរមេស្វរ</u> vraḥ pāda Jayavarmmaparameçvara = ព្រះបាទជយវរ្ម័នទី៩ Jayavarman IX (1327-133X AC) ។

រាជបុរោហិតវិទ្យេសវិទ (Vidyeçavida) ... វិទ្យេសធិមន្ត (Vidyeçadhimanta) ។

ព្រះអង្គជាស្តេចចុងក្រោយនៅសម័យអង្គរ នៃវង្ស «វរ្ម័ន» ឬព្រះនាមដែលបញ្ចប់ដោយពាក្យថា (... វម្មទេវ varmmadeva) ។

បើតាមទស្សនៈរបស់សាស្ត្រាចារ្យបណ្ឌិត ពៅ សាវរស ចង់អោយអ្នកប្រវត្តិសាស្ត្រទម្លាប់ហៅនាមព្រះមហាក្សត្រខ្មែរ ដោយរក្សាពាក្យនៅខាងចុងថា «វម្ម» អោយនៅដដែល ។ ព្រោះអី ពាក្យថា «វរ្ម័ន» ដែលយើងនាំគ្នាប្រើរត់មាត់គ្រប់គ្នាសព្វថ្ងៃនេះ ជាពាក្យដែលអ្នកស្រាវជ្រាវបារាំងបង្កើតឡើង ។ នៅក្នុងសិលាចារឹកតាំងពីសម័យមុនអង្គរ ឃើញមានតែពាក្យ «វម្ម» ប៉ុណ្ណោះ ហើយពាក្យនេះឃើញមានប្រើនៅសម័យក្រោយអង្គរថា «ពម្ម» ឬ «ពមិ» ដែលអ្នកប្រវត្តិសាស្ត្រមួយចំនួនសរសេរច្រឡំថា «ពណិ» ទៅវិញ ។

***

# សាស្ត្រារឿង ព្រះមហាសុបក្សីតាបស

*វាចារំលឹក*

កាលនោះ គឺនៅដើមទសវត្សនៃឆ្នាំ ១៩៦០ ។ នៅផ្ទះជីតាខ្ញុំឯស្រែ មានសាស្ត្រាស្លឹករឹតមួយខ្សែ ដែលមានឈ្មោះថា " សាស្ត្រារឿងព្រះមហាសុបក្សីតាបស " ចារជាពាក្យកាព្យ ជាបទពាក្យ ៧ ។ ដើម្បីជាការកែអផ្សុក ខ្ញុំតែងតែយកសាស្ត្រានោះមកអានសាកល្បងមើលកំសាន្តលេងជាញឹកញាយផង ។ សម័យនោះ ខ្ញុំអានសាស្ត្រាមិនទាន់ដាច់បានទាំងអស់ទេ ។ ខ្ញុំអានដាច់បានតិចតួច ហើយអាចយល់សេចក្តីបានខ្លះៗតែប៉ុណ្ណោះ ។ ពីព្រោះសាស្ត្រានោះលោកចារសុទ្ធតែជាអក្សរមូលផង និងតាមអក្ខរាវិរុទ្ធជំនាន់ដើមផង ។ កាលនោះ ខ្មែរយើងមិនទាន់មានក្បួនច្បាប់សរសេរឱ្យបានត្រឹមត្រូវដូចសព្វថ្ងៃនៅឡើយទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំខំព្យាយាមអានហើយអានទៀត អានដដែលៗជាច្រើនលើកច្រើនសា លុះត្រាតែខ្ញុំបានយល់អស់ជាស្ថាពរ នូវរបៀបសរសេរនៃអក្ខរាវិរុទ្ធរបស់ពាក្យនីមួយៗ នាសម័យកាលនោះ ។ ដូច្នោះហើយ ខ្ញុំក៏អាចអានសាស្ត្រា អាចយល់បាននូវសេចក្តី និងខ្លឹមសារនៃរឿងនោះដូចធម្មតា ។

មានថ្ងៃមួយ ខ្ញុំបានអានសាស្ត្រានោះតាំងពីដើម រហូតដល់ចប់ ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ ជាងសាមសិបឆ្នាំបានកន្លងផុតទៅហើយ ខ្ញុំនៅតែនឹកឃើញ ព្រមទាំងចាំសេចក្តីសង្ខេបរបស់សាស្ត្រាស្លឹករឹតនោះនៅឡើយ ។ រីឯការហាត់រៀននោះសាចុះសាឡើងច្រើនដងពីដំបូង វាបានធ្វើឱ្យខ្ញុំនៅចាំមួយភាគខាងដើមនៃរឿងជាកំណាព្យពាក្យ ៧ នោះជារៀងរហូតមកដល់សព្វថ្ងៃនេះ ។ ខ្ញុំសូមចម្លងការចេះចាំទាំងប៉ុន្មានពីសាស្ត្រានោះ ជូនជនានុជនផងគ្នា គ្រាន់នឹងអានកំសាន្ត

លេងផង ទុកជាឯកសារសំរាប់ធ្វើការពិចារណាអំពីខ្លឹមសារនៃរឿងនេះផងទុកជាគតិសំរាប់អប់រំខ្លួនយើងគ្រប់រូបផង ហើយជាពិសេស គឺដើម្បីរក្សាស្នាដៃដែលនៅសេសសល់តែបន្តិចបន្តួចនេះ កុំឱ្យបាត់បង់សូន្យសុងទៅវិញផង ។

សាស្ត្រានោះនិទានពីអ្នកប្រាជ្ញផ្នែកតារាសាស្ត្រដ៏ល្បីល្បាញពីរនាក់ ដែលម្នាក់ប្រកាន់ថា ផែនដីរាងសំប៉ែតមានផ្ទៃរាបស្មើ ហើយស្ថិតនៅនឹងតែមួយកន្លែង, ឯម្នាក់ទៀត ប្រកាន់ថាផែនដីរាងមូលដូចផ្លែក្រូចថ្លុង វិលវង់ជុំវិញព្រះអាទិត្យ ហើយគឺព្រះអាទិត្យឯនោះទេ ដែលស្ថិតនៅនឹងតែមួយកន្លែងនុ៎ះ ។ អាចារ្យទាំងពីរនាក់ពូកែទស្សន៍ទាយដូចៗគ្នា ។ ប៉ុន្តែ ប្រការដែលធ្វើឱ្យអ្នកទាំងពីរយល់ឃើញខុសគ្នា វាក៏បង្កឱ្យទៅជាមានទំនាស់នាំឱ្យបែកបាក់ កើតទៅជាបក្សជាពួកពីរក្រុម ដែលក្លាយទៅជាគូសត្រូវនឹងគ្នា ។ អ្នកទាំងពីរតែងតែកើតចិត្តច្រណែននិន្ទាឈ្នានីសគ្នាមិនចេះចប់ ។ ជានិច្ចកាល ពួកគេមានគំនិតចាំតែផ្ចាញ់ផ្ចាលគ្នា ព្រមទាំងរកឱកាសដើម្បីបំផ្លាញគ្នាទៅវិញទៅមក តែរៀងៗខ្លួន ។

តើមកពីមូលហេតុអ្វី ទើបបានជាអាចារ្យទាំងពីរនាក់កើតចិត្តជាអរិភាពនឹងគ្នាដូច្នោះ ?

គឺជាការងាយយល់ណាស់ ។ ពីព្រោះថា អាចារ្យទាំងពីរនាក់នោះ សុទ្ធតែជាមនុស្សខ្វះគតិបណ្ឌិត មានចរិតជាជនពាល ខ្វះការពិចារណា ខ្វះការអប់រំ ឬបើពោលជាពាក្យសាមញ្ញវិញ លោកថាអាចារ្យទាំងពីរនាក់នោះ ជាមនុស្សគ្មានការចេះដឹង ។ ម្នាក់ៗគិតតែពីប្រកាន់យក " ត្រូវ " តែរៀងៗខ្លួន ដោយគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍សំរាប់បក្សពួកនៃខ្លួនគេផ្ទាល់តែប៉ុណ្ណោះ ។ គឺដោយសារតែឥរិយាបថបែបនេះឯងហើយ ដែលវាបណ្តាលឱ្យមូលហេតុនៃការបែកបាក់សាមគ្គីត្រូវចាប់កំណើតឡើង ។

មានការចោទសួរដ៏សមហេតុផលមួយ ពីសំណាក់ជនានុជនខ្លះថា « បើ

ព្រះពុទ្ធអង្គជាអ្នកទ្រង់ញាណមែននោះ ចុះហេតុអ្វីបានជាព្រះអង្គមិនទ្រង់ញាណថា ផែនដីយើងនេះមានរាងមូល ហើយវិលវង់ជុំវិញព្រះអាទិត្យ ? " ។

គេមិនដែលបានជួបប្រទះអក្សរសាស្ត្រណាមួយដែលសំដែងថា ព្រះពុទ្ធ-អង្គមិនដឹងថាផែនដីមានរាងមូលនោះទេ ហើយគេក៏មិនដែលបានប្រទះគម្ពីរពុទ្ធ-សាសនាណាដែលបរិយាយថា ព្រះពុទ្ធអង្គទ្រង់យកព្រះទ័យទុកដាក់អំពីរឿងផែនដីនោះ ក៏ទេដែរ ។ រីឯចម្លើយទៅនឹងសំណួរនេះ ក៏មិនមែនជាការពិបាកទេ គឺថា ការដែលត្រូវដឹងស្គាល់ ឬយល់អំពីលក្ខណៈនៃភពផែនដី ក៏ដូចជាអំពីភពឯទៀតៗដែរ មានដូចជាព្រះអាទិត្យ ព្រះចន្ទ ព្រះអង្គារ ព្រះពុធ ព្រះព្រហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍ និងភពដ៏ច្រើនអនេកឯទៀតនោះ គឺជាវិជ្ជាមួយដែលទាក់ទិនទៅនឹងវិទ្យាសាស្ត្រសុទ្ធសាធ ។ មានមតិជាច្រើនបានអះអាងថា ករណីនេះមិនមែនព្រះពុទ្ធអង្គលោកមិនបានទ្រង់ញាណនោះទេ ប៉ុន្តែព្រះអង្គទ្រង់បានឈ្វេងយល់ថា ដល់ថ្ងៃក្រោយទៅមនុស្សលោកយើងគង់តែនឹករកឃើញនូវវិជ្ជាអស់ទាំងនេះជាប្រាកដ ។ ប្រសិនបើនៅពេលដែលព្រះអង្គទ្រង់គង់ព្រះជន្មាយុនៅឡើយ ព្រះសម្មាសម្ពុទ្ធទ្រង់លើកយកករណីទាំងអស់នេះមកចូលទៅក្នុងបរមត្ថវិជ្ជារបស់ព្រះអង្គ ទោះបីត្រឹមតែជាការបើកវង់ក្រចកតែប៉ុណ្ណោះក៏ដោយ ក៏វាអាចបង្កឱ្យបែកចេញទៅជាចម្ងល់ និងជាសំណួរបែកជាអួរហួរជាស្ទឹងមិនចេះអស់មិនចេះហើយ ដែលជាហេតុមួយនាំឱ្យមានការឃ្លាតចាកឆ្ងាយចេញពីព្រះធម៌ទាំងប្រាំបីម៉ឺនបួនពាន់ធម្មក្ខន្ធ ដែលព្រះអង្គបានត្រាស់ដឹងដោយព្រះអង្គឯង ហើយដែលព្រះអង្គទ្រង់ឈ្វេងយល់យ៉ាងប្រាកដថានឹងពុំមានមនុស្សលោកណាអាចរកឃើញបានឡើយ ។ ម្ល៉ោះហើយ ព្រះអង្គមុខជាពុំមានឱកាសឯណាឱ្យបានបរិបូណ៌គ្រប់គ្រាន់ ដើម្បីបង្ហាត់បង្រៀនប្រៀនប្រដៅសាវ័ករបស់ព្រះអង្គនូវអស់ទាំងវិជ្ជាដែលព្រះអង្គបានត្រាស់ដឹងនោះទេ ។ ព្រះអង្គមុខជាពុំមានឱកាសឯណានឹងទទួលនូវអស់ពួកមនុស្ស ទេវតាផងទាំងឡាយ ដែលតែងតែ

មានចម្ងល់ មានប្រស្នាផ្សេងៗមកចោទសួរចំពោះព្រះអង្គនោះឡើយ ។ម្យ៉ាងវិញទៀត វិជ្ជាអស់ទាំងនេះគ្រាន់តែជាមុខជំនាញ ជាមុខរបរសំរាប់ជនសាមញ្ញដែលជាអ្នកមានប្រាជ្ញាមុតតែប៉ុណ្ណោះ ពោលគឺ វាពុំមានលក្ខណៈ ឬមានការទាក់ទិនអ្វីឡើយទៅនឹងសាសនារបស់ព្រះអង្គ ។ វិជ្ជានេះ ថ្វីបើគេត្រូវចេះត្រូវដឹងក៏ពិតមែន ប៉ុន្តែវាក៏មិនអាចនាំឱ្យកើតជាគតិបណ្ឌិត ជាការទូន្មានប្រៀនប្រដៅទៅលើផ្នែកសីលធម៌សំរាប់មនុស្សលោករាល់រូបផងដែរ ។ មនុស្សគ្រប់រូបតែងតែប្រាថ្នាចង់បានណាស់នូវសេចក្តីសុខ គឺសុខទាំងខាងផ្លូវកាយផង សុខទាំងខាងផ្លូវចិត្តផង ។ ដើម្បីឱ្យបានសំរេចនូវបំណងប្រាថ្នាអស់ទាំងនេះ មនុស្សយើងត្រូវការជាដំបូងបំផុតនូវសាមគ្គី ។ ធម៌សាមគ្គីនេះ វាកើតចេញមកពីសេចក្តីស្រឡាញ់គ្នា ។ សេចក្តីស្រឡាញ់គ្នា វាកើតចេញមកពីសេចក្តីស្មោះត្រង់នឹងគ្នា មិនចេះក្បត់គ្នា គឺមានយុត្តិធម៌ដ៏ល្អត្រឹមត្រូវរវាងគ្នានឹងគ្នា ។ មនុស្សដែលប្រកបដោយលក្ខណសម្បត្តិដ៏ពិសេសទាំងអស់នេះ លោកហៅថាមនុស្ស « មានគតិបណ្ឌិត ឬមានការចេះដឹង » ដែលផ្ទុយនឹងមនុស្សពាល ព្រហើនកោងកាច មនុស្សក្នុងជំពូកជាអ្នកមានការចេះដឹង គួរណាស់តែត្រូវបានជាទីកោតសរសើរ ជាទីគោរព និងជាគំរូសំរាប់ជនានុជនគ្រប់គ្នា ។ នេះគឺគ្រាន់តែជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់ខ្ញុំយ៉ាងសង្ខេបប៉ុណ្ណោះ ចំពោះរសនៃរឿងព្រះមហាសុបក្សិតាបស ។ វីសេចក្តីពិស្តារ គឺដូចមាននិទាននៅក្នុងសាស្ត្រារឿងមហាសុបក្សិតាបសនេះជាគតិស្រាប់ ។

តើលោកតាអាចារ្យ ដែលគេទទួលស្គាល់ថាជាតាវាវិទូដ៏ល្បីល្បាញ ជាអ្នក មានជំនាញខាងវិជ្ជាទស្សន៍ទាយនោះ ជាមនុស្សប្រភេទណា ?

ជាការគួរឱ្យស្តាយណាស់ ដែលខ្ញុំមិនបានចាំកំណាព្យនៃរឿងព្រះមហាសុបក្សិតាបសនេះតាំងពីដើមដល់ចប់ គឺគ្រាន់តែនៅចាំសាច់រឿងប៉ុណ្ណោះ ។ ប៉ុន្តែខ្ញុំនៅចាំថាកំណាព្យទាំងនោះ ត្រូវបានលោកអ្នកកវីនិពន្ធពាក់តែងចងក្រងឡើង យ៉ាង

សែនពិរោះពន់ពេក គឺមានការចាប់ចុងចួនឥតមានខ្វះចន្លោះត្រង់ណាបន្តិចឡើយ មិនខុសពីកំណាព្យនៅក្នុងរឿងនានាទៀត ដូចជានៅក្នុងរឿងសព្វសិទ្ធិ រឿងបាង្សយន្តជាដើមនោះទេ ដូចដែលយើងមានផ្នែកខាងដើមនៃកំណាព្យរឿងជាឧទាហរណ៍ស្រាប់ ។ មួយវិញទៀត លោកអ្នកកវីនិពន្ធ ក៏មិនបានចារឹកឈ្មោះលោកនៅក្នុងរឿងនោះដែរ លោកមានលើកតែពីឋានន្តរស័ក្តិរបស់លោក ដែលថាលោកគឺជាភ្ញូឈ្លួយក្រឡាហោមប៉ុណ្ណោះ ។

ដើម្បីឱ្យបានជ្រាបពីបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់លោកអាចារ្យទាំងពីរនាក់នោះ សូមអានរឿងព្រះមហាសុបក្សីតាបស ភាគខាងដើមជាកំណាព្យពាក្យ ៧ និងសេចក្តីសង្ខេបជាពាក្យរាយនៃភាគដែលនៅសេសសល់ ដូចមាននិទាននៅដើមទំព័រ ជាបន្តបន្ទាប់ទៅនេះ ។

## រឿងព្រះមហាសុបក្សីតាបស

នេះនឹងសូមថ្លាថ្លែងនិទាន ដូចមាននៅក្នុងព្រះធមិពិត
តាមពាក្យបុរាបុរាណព្រឹទ្ធ ឈ្មោះថាភាសិតមហាឥសី ។
ខ្ញុំជាភ្ញូឈ្លួយក្រឡាហោម កើតព្រមដោយចិត្តគិតគុណាបី
គឺព្រះរតន៍ត្រ័យថ្លៃវង្សី សូមសុខសួស្តីគ្រប់ប្រការ ។
សូមថ្វាយបង្គំបរមបពិត្រ ជាម្ចាស់ជីវិតលើសិរសា
ជាម្លប់គ្រប់គ្រងសព្វសាសនា នូវរាស្ត្រប្រជាទាំងបុរី ។
ខ្ញុំនឹកគុណមាតាបិតា គុណាគ្រូអាចារ្យមហាថ្លាថ្លៃ
ខ្ញុំសុំជួបសុខ មានសិរី សូមផ្ញើមសំដីចែងចរចា ។
ថាកាលពីព្រេងអង្វែងយូរ មានគ្រូពីរនាក់មានប្រាជ្ញា
មួយឈ្មោះនិទេសសាស្ត្រាចារ្យ មួយនោះនាមាគ្រូនិទស ។

អាចារ្យទាំងពីរជាគ្រូធំ នៅក្នុងនិគមស្រុកមានឈ្មោះ
មានខេត្តខណ្ឌគីរីមានជ្រោះ ចន្លោះលង្វែកដែនមយូរ៉ា ។
អាចារ្យទាំងពីរមានកន្លែង ពាក់តែងរោងរៀនក្បួនសាស្ត្រា
ប្រដៅសិស្សគណាគាល់ត្រៀបត្រា ទៅតាមប្រាជ្ញាខ្លួនទីទៃ ។
ឯគ្រូនិទសនោះកាន់ថា ពសុធាសំប៉ែតអណ្តែតវៃ
ដូចកលស្លឹកឈូកក្នុងជលស័យ ក្រោមដីទឹកទ្រ ពទាំងស្រុង ។
ឯគ្រូនិទេសនោះកាន់ថា ពសុធាមូលដូចផ្លែក្រូចត្លុង
វិលឡើងក្រឡាប់គ្មានដើមចុង តួអង្គព្រះអាទិត្យនិត្យនឹងនៅ ។
អាចារ្យនោះស្គាល់ច្រើនក្រៃណាស់ ស្គាល់មេឃអាកាសច្បាស់សន្ធៅ
ស្គាល់គ្រោះតារាដែលចរទៅ ស្គាល់ទឹករាក់ជ្រៅក្នុងសាគរ ។
ស្គាល់ភេទនិមិត្តហេតុវិនាស ស្គាល់គ្រាសតារាដែលចរមក៏
ស្គាល់ច្បាស់ប្រាកដឥតមានភរ នរណារិះរក៏ទាយមិនខុស ។
ចំណេះចំណានគ្មានទើសទាល់ សម្គាល់ប្លែកគ្នាតែត្រង់នោះ
មួយថាដីវិលវល់ឡើងចុះ មួយថាដីដុះនៅនឹងនិត្យ ។
គន់មើលយូរទៅត្រូវទាំងគ្រប់ ទោះថ្ងៃឬយប់ឆ្ងាយឬជិត
ដែលគិតថាវិលឃើញវិលពិត ដែលគិតថានឹងឃើញនឹងថ្កល់ ។
គណៈទាំងពីរបើជួបគ្នា- កាលណាតែងទាស់ឈ្លោះរចល់
ជជែកយកឈ្នះខ្លះតាំងភ្នាល់ ទៅតាមសម្គាល់ជាប្រមាណ ។
អ្នកស្រុកជាន់នោះលុះវិជ្ជា ក៏បែកបាក់គ្នាជាពីរប្រាណ
ពួកឃើញដីនឹងទាំងប៉ុន្មាន រាប់អានចូលខាងគ្រូនិទស ។
ឯពួកឃើញដីវិលផ្កាប់ផ្ងារ ចូលខាងអាចារ្យនិទេសអស់
អាចារ្យនោះកើតបានរបស់ ភោជន៍ភស្តុអខោសោភិនី ។

គ្រានោះនៅមានភៀនពីរនាក់ ស្មោះស្មគ្រស្រឡាញ់គ្នាពេញទី
មួយឈ្មោះនាយទសមានព្យាធិ ទីពីរឈ្មោះទែនសែនទុរគត ។
នាយទសនោះមានអាការរោគ ឆ្កួតជ្រូកមកពីកំណើតសុទ្ធ
ប្រកាច់វិលវល់ញ័ររន្ធត់ ប្រឹងរត់រកគ្រូមើលពុំជា ។
នាយទែននោះមានទុក្ខទោសទ្វេ នៅជាខ្ញុំគេធ្វើការងារ
ពីព្រោះឪពុក[1] លក់ខ្លួនវា ដោយសារចាញ់ភ្នាល់ល្បែងចត្រង្គ[2] ។
លក់ទាល់តែអស់របស់ទ្រព្យ លេងជាប់ដល់ឈើត្រចៀកថ្លង់
ទើបយកនាយទែនទៅលក់បង់ នៅក្នុងស្រុកនោះមានឈ្មោះថា ។
ឧកញ៉ាបរិបុរីរក្ស ចេញប្រាក់បីរយកហាបនា
លោះយកនាយទែនជាបរិវារ ប្រើឱ្យធ្វើការស្មើរពេលលោះ ។
គេប្រើគេស្តីរៀងរាល់ថ្ងៃ សីងឥតសំចៃសីងឯងប្រុស
ល្ងាចប្រើរែកទឹកព្រឹកពុះឧស បើជួនជាខុសគេជេរវាយ ។

លុះចំណេរកាលជាខាងក្រោយនោះបន្តិចមក ទើបនាយ ទស និងនាយទែន បានឮគេពីងឯងមកអំពីអាចារ្យទាំងពីរនាក់ដែលល្បីឈ្មោះទៅទិជិតទិឆ្ងាយ ។ មានកាលថ្ងៃមួយនោះ កុមារអភ័ព្វទាំងពីរនាក់បានស្កាត់រកជួបគ្នា ហើយប្រឹក្សាគ្នាថា

"យើទាំងពីរនាក់ គួរតែទៅរកគ្រូដែលល្បីឈ្មោះនោះឱ្យលោកជួយយើងមើល ក្រែងលោលោកអាចជួយស្រោចស្រង់យើងឱ្យបានរួចផុតពីជំងឺតម្កាត់ និងបានរួចផុតជាអ្នកជានឹងគេឡើងវិញ លែងនៅធ្វើជាខ្ញុំកញ្ជះគេ តទៅទៀត ។ ប្រសិនបើលោកអាចជួយយើងឱ្យរួចផុតពីវាសនាអាក្រក់ទាំងនេះមែន យើងត្រូវតែសុំនៅគាល់ហ្វៅបំរើលោកដែលជាអ្នកមានគុណ មានចំណេះវិជ្ជា មានសីលធម៌ នៅក្នុង

(១) ច្បាប់ក្នុងសាស្ត្រាស្លឹករឹតថា " រាពុក " ។
(២) ច្បាប់ក្នុងសាស្ត្រាស្លឹករឹតថា " ឈើត្រង់ " ។

ខ្លួននេះទើបប្រសើរ ព្រោះអីតាមដែលល្បីត១គ្នាមក ឮថាលោកអាចារ្យទាំងពីរនាក់នោះពូកែណាស់ ។ បើពិតជាពូកែមែននោះ លោកច្បាស់ជាអាចជួយយើងឱ្យរួចផុតពីទុក្ខវេទនាដូចសព្វថ្ងៃនេះបាន ។ កាលណាយើងរួចផុតពីទុក្ខទោសទាំងនេះហើយ យើងនឹងត្រូវខិតខំគោរពកោតខ្លាចលោក ហើយខំស្វាធ្យាយសិក្សារៀនសូត្រពីលោកឱ្យអស់ពីសមត្ថភាព ដើម្បីកសាងខ្លួនយើងឱ្យទៅជាមនុស្សថ្លៃថ្នូរនឹងគេ " ។

កាលបើព្រមព្រៀងគ្នារួចស្រេចហើយ នាយទស និងនាយទៃន ក៏នាំគ្នាទៅកាន់សំណាក់លោកអាចារ្យនិទស ។ ទៅដល់កាលណា សម្លាញ់ទាំងទ្វេហារ ក៏ប្រញាប់ដើរចូលទៅទាំងឱនបន្ទន់សិរសាកាន់កិរិយារាបទាប លុតជង្គង់ក្រាបថ្វាយបង្គំលោកគ្រូ ដែលកំពុងមានសិស្សគណនៅគាល់ត្រៀបត្រា ។ កុមារអភ័ព្វក៏ប្រញាប់ទូលលោកតាអាចារ្យអំពីមូលហេតុនៃការមកដល់របស់ខ្លួនគេ ។ ប៉ុន្តែលោកអាចារ្យហាក់ដូចជាពុំបានយកចិត្តទុកដាក់ដល់អាថិសេចក្តី ដែលនាយទាំងពីរនាក់រ៉ាយរ៉ាប់ប្រាប់នោះទេ ។ លោកបែរជាប្រញាប់សួរទៅនាយកំសត់យើងទាំងពីរនាក់នោះថា :

" នែ, អាក្មេងទាំងពីរនាក់ ចូរក្មេងប្រាប់អញមើល៍ ! តើផែនដី វាមានរាងមូល ឬរាងសំប៉ែត ? "

កុមារទាំងពីរនាក់ហាក់ដូចជាភ័ន្តភាំងមួយសន្ទុះ ទើបនាយម្នាក់ឆ្លើយទាំងប្រថុយប្រថានថា :

" យើងខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំទូលព្រះអង្គថា មូលហេតុដែលនាំឱ្យយើងខ្ញុំព្រះករុណាមកកាន់ទីនេះ គឺដើម្បីសុំឱ្យលោកតាជួយយើងខ្ញុំព្រះករុណា ដោយហេតុថា យើងខ្ញុំព្រះករុណាកំពុងមានអាការរោគ និងមានទុក្ខទោសជាទម្ងន់ គឺខ្លួនខ្ញុំព្រះករុណាមានជំងឺក្អួតជ្រក ហើយសម្លាញ់របស់ខ្ញុំព្រះករុណា កំពុងជាប់ជំពាក់ធ្វើជាខ្ញុំបំរើគេ ព្រោះតែឪពុករបស់វាគ្មានប្រាក់លោះ ។ តើលោកតា អាចជួយរំដោះ

យើងខ្ញុំព្រះករុណាឱ្យរួចផុតពីវាសនាអភ័ព្វទាំងនេះផងបានឬទេ ? ចំពោះបញ្ហាផែនដីវិញនោះ ទោះបីជាវាមានរាងមូលក្តី ឬក៏មានរាងសំប៉ែតក្តី នោះគឺវាហួសពីសមត្ថភាពរបស់យើងខ្ញុំព្រះករុណាឆ្ងាយណាស់ សូមលោកតាអភ័យទោសដល់យើងខ្ញុំព្រះករុណាផងទៅចុះ ។ យើងខ្ញុំព្រះករុណានៅល្ងង់ខ្លៅណាស់ ហើយក៏សុំទូលព្រះអង្គដោយត្រង់ៗតែម្តងថា យើងខ្ញុំព្រះករុណាពុំមានដឹងអ្វីទាល់តែសោះ " ។

គ្រាន់តែឮនាយនោះឆ្លើយថា " មិនដឹង " ដូច្នោះ លោកអាចារ្យនិទសកើតក្តីពិរោធយ៉ាងខ្លាំង ។ លោកអាចារ្យក៏តាំងស្រែកគំហកទៅចៅទាំងពីរនាក់ថា :

" នែ, អាក្មេងពេញពាលទាំងពីរនាក់ ! ពួកអាឯ្អែងហ្នឹងមិនដឹងថាដីរាងមូលឬសំប៉ែតទេឬ ? អាឯ្អែងទាំងពីរនាក់ឆ្កួលអីម៉្លេះ ! អាឯ្អែងឃើញឬទេ គេគ្រប់គ្នាអង្គុយត្រៀបត្រានៅទីនេះ គេសុទ្ធតែលើកតម្កើងទស្សនះរបស់អញ ។ គេមិនមែនជាមនុស្សភ្លើមិនដឹងអីដូចពួកអាឯ្អែងនេះទេ ។ ហ៊ឺះ ! ពួកអាឯ្អែងនេះថោកទាបណាស់ ! មិនគួរអីមកដល់ទីនេះសោះ ។ ចូរឯ្អែងចៀសចេញឱ្យឆ្ងាយពីទីនេះភ្លាមទៅ ! មុននឹងមកដល់ទីនេះ អាឯ្អែងហេតុដូចម្តេចបានជាមិនព្រមសួរគេឯងឱ្យដឹងជាមុនសិន ថាអញនេះត្រូវការអ្វីខ្លះ ។ អញត្រូវការតែមនុស្សណាដែលចេះលើកតម្កើងយោបល់អញតែប៉ុណ្ណោះ ! ។ មនុស្សដូចពួកឯ្អែងនេះ អញឥតត្រូវការទេ ។ ទៅ ! ចៀសចេញឱ្យឆាប់ពីទីនេះ ! " ។

នាយទាំងពីរនាក់ភ័យណាស់ ក៏ប្រញាប់រូតរះដើរចេញមកវិញ ។ ដល់ទីមួយដ៏សមគួរហើយ ទើបនាយទស និងនាយទៃនជំនុំប្រឹក្សាគិតគ្នាថា : " យីហ៎ ! លោកអាចារ្យនេះ ហេតុដូចម្តេចបានជាគាត់កាន់អាកប្បកិរិយាអីបែបហ្នឹង ? សំដីអញ្ចឹងៗ មិនសមអីជាសំដីរបស់អ្នកប្រាជ្ញ ឬបណ្ឌិតជាអ្នកចេះដឹងនោះទេ ។ អំពីរឿងផែនដី វាមានរាងមូល ឬសំប៉ែតនោះ នរណាហ៎ ដូចជាពួកយើងនេះនឹងអាចដឹងបាន ! ។ គ្រាន់តែយើងឆ្លើយថាមិនដឹងប៉ុណ្ណឹង ហេតុម្តេចក៏បានជាគាត់ខឹងនឹង

យើងខ្លាំងម៉្លេះហ្ន៎សម្លាញ់ ? អាចារ្យអីរបៀបនេះ គឺជាមនុស្សខ្វះវិចារណញ្ញាណ ខ្វះសីលធម៌ហួសពេកណាស់ ។ មើលទៅ យើងមិនអាចទៅរកពឹងពាក់គាត់បានទេ ។ ទៅសម្លាញ់ ! យើងទៅរកលោកអាចារ្យមួយទៀត ហើយប្រាកដជាលោកមិនកាន់អាកប្បកិរិយាលេលាបែបនេះទេ ។ តាមធម្មតា ជនណាដែលមានឈ្មោះថាជាគ្រូអាចារ្យ ជននោះត្រូវតែជាអ្នកមានការចេះដឹងជ្រៅជ្រះណាស់ ទាំងខាងផ្លូវលោក ក៏ដូចជាខាងផ្លូវសីលធម៌ ហើយក៏ជាអ្នកអនុវត្តខ្ជាប់ខ្ជួននូវមាគ៌ាជាកុសលទាំងពីរនេះ" ។

លុះគិតឃើញដូច្នោះហើយ សម្លាញ់ទាំងពីរនាក់ ក៏ស្មគ្រចិត្តនាំគ្នាធ្វើដំណើរទៅកាន់សំណាក់នៃអាចារ្យនិទេសម្តង ។ កាលបើគេទៅដល់ភ្លាមហើយ សម្លាញ់ទាំងពីរក៏ចាប់ផ្តើមដើរត្រសងចូលទៅ ព្រមដោយនូវកិរិយាគោរពរាបសា ដូចកាលនាយបានធ្វើលើកមុនជាមួយអាចារ្យនិទសនោះដែរ ។ ស្រាប់តែសម្លាញ់ទាំងទ្វេបារ ក៏ត្រូវទទួលការខកចិត្តមួយសាទៀត មិនខុសពីលើកមុនទេ គឺគេត្រូវទទួលពាក្យជេរប្រមាថកាតទៀន ដូចកាលដែលពួកគេទៅជួបជាមួយនឹងអាចារ្យនិទសអញ្ចឹងដែរ ។ បទពិសោធន៍ទាំងពីរលើកនេះ បានធ្វើឱ្យនាយយើងស្ថិតនៅក្នុងក្តីអស់សង្ឃឹម ឱ្យទៅជាកើតមានអារម្មណ៍ច្រឡំបល់រកគិតអ្វីមិនយល់ទាល់តែសោះ ។ នៅទីបំផុត សម្លាញ់ទាំងពីរប្រាណ ក៏ត្រឡប់ទៅលំនៅឋានរបស់គេរៀងៗខ្លួនវិញទៅទាំងពាំនាំនូវក្តីសោកសៅយកទៅតាមផង ។

គ្រានោះ មានភិក្ខុមួយអង្គព្រះនាមសុបក្សិតាបស ។ ព្រះអង្គគង់នៅក្នុងអារាមមួយដ៏ឆ្ងាយបន្តិចពីស្រុកភូមិ ដែលជាទីកន្លែងកំណើតរបស់ព្រះអង្គ ។ ក្នុងមួយឆ្នាំពីរដង ឬជួនកាលបីដងផងមិនដែលខាន ព្រះអង្គតែងតែនិមន្តទៅលេងស្រុកកំណើត ដើម្បីសាកសួរសុខទុក្ខញោមប្រុសញោមស្រី ព្រមទាំងញាតិសន្តានជាបងប្អូនជិតឆ្ងាយរៀងអាយ ដែលរស់នៅជាប់ជាភូមិផងរបងជាមួយ ក្រៃងលោលោកទាំងនោះ មានបើកើតហេតុភេទមិនស្រួលដោយប្រការណាមួយ ព្រះអង្គនឹងអាច

ជួយយកអាសារបានផង ។ ព្រះភិក្ខុអង្គនេះទ្រង់បានបួសរៀនចំរើនព្រះសម្មាបដិបត្តិអស់កាលជាយូរមកហើយ រហូតដល់បានសំរេចមគ្គផលយ៉ាងគាប់ប្រសើរ ។ ព្រះអង្គបានក្លាយទៅជាទីស្រឡាញ់ និងជាទីគោរពសក្ការៈនៃមនុស្សម្នាផងគ្នាជាទូទៅ ទាំងទីជិតឆ្ងាយ ។ ទ្រង់ប្រកបដោយព្រះគតិបណ្ឌិត សុចរិតទៀងត្រង់ កាន់សច្ចធម៌ខ្ជាប់ខ្ជួន ព្រះអង្គតែងតែធ្វើវត្តប្រតិបត្តិ ទាំងប្រោសអស់សព្វសត្វទាំងឡាយណា ដែលបានចូលអាត្មាមកសុំជ្រកកោន ឬសុំពឹងពាក់នៅក្នុងសំណាក់របស់ព្រះអង្គ ។

សម័យថ្ងៃមួយ ព្រះអង្គនឹកចង់និមន្តទៅលេងស្រុកកំណើតដូចសព្វដង ។ ព្រះអង្គហាក់ដូចជាមានការពិភាល់ថា ឬមួយក៏បិតា ឬមួយក៏មាតា របស់ព្រះអង្គប្រហែលជាមានជំងឺតម្កាត់អ្វីមិនលែងឡើយ ហើយត្រូវការឱ្យព្រះអង្គទៅគង់នៅក្បែរ ជួយមើលធូនថៃផង គ្រាន់នឹងបានជាទីទុកចិត្ត ។ ទ្រង់និមន្តកាត់វាលចូលព្រៃឆ្លងស្ទឹង ឆ្លងព្រៃកម្តង១ វិលងអស់ពេលទៅដ៏យូរ ។ នៅតាមផ្លូវដែលព្រះអង្គធ្លាប់តែនិមន្តទៅដូចសព្វមួយដង ទ្រង់សប្បាយព្រះទ័យជាអនេកនឹងគយគន់មើលអស់ទាំងព្រៃព្រឹក្សាលតាវល្លិផងទាំងឡាយ ដែលកំពុងបែកមែកលាស់ស្លឹកត្រសុំត្រសាយសាខា ព្រមដោយនូវផ្លែផ្កា សាយក្លិនពិដោរក្រអូបភាយម្តង១ តួបផ្សំនឹងសូរស័ព្ទបក្សាបក្សីផងយំខ្សៀវខ្សារ និងហិចហើរកំសាន្តលេងសប្បាយជាមួយគ្នា ហាក់បី-ដូចជាសព្វសត្វទាំងឡាយនោះ កំពុងសំដែងស្វាគមន៍ចំពោះដំណើរនិមន្តន៍មកដល់របស់ព្រះអង្គដែរ ។ រីឯអស់ពួកសត្វចតុប្បាទ ទ្វេបាទ ឯទៀត១ មានទន្សោង ប្រើសក្តាន់ រមាស រមាំង ស្ពាំង ក្ងោក ប៉ោលតោក ខ្លែង ត្មាត ចចាត ទទា មាន់ទោ មាន់ទឹកប្រវឹក ជាដើម នាំគ្នាឈរដក-ករហង់ ឬហើរសម្លឹងមើលមកព្រះអង្គ ក្នុងកិរិយាមួយដែលហាក់ដូចជារាប់អាន ឬធ្លាប់ស្គាល់ព្រះអង្គថាជាមិត្ត រួមជីវិតជាមួយគ្នា ។ មិនដែលមានសត្វសាហាវឯណាប៉ុនប៉ងប្រាថ្នាយាយីព្រះអង្គ ដល់ម្តងសោះឡើយ ។

លុះដល់វេលារសៀលជ្រាលជ្រេព្រះសុរិយាបន្តិចមក ខណៈដែលព្រះអង្គ

កំពុងឆ្លងកាត់ព្រៃស្រោងយ៉ាងធំមួយ ដែលមានល្បះដុះដោយដុំៗ ព្រះអង្គស្រាប់តែពើបប្រទះនឹងពួកចោរប្រាំរយនាក់ ដែលកំពុងនាំគ្នាបំពេញផែនការរបស់គេ ។ ពួកចោរទាំងប្រាំរយនាក់នោះកំពុងបើកអង្គប្រជុំក្រោមអធិបតីភាព និងក្រោមបញ្ជាការរបស់មេពួកគេម្នាក់ ។ គឺគេប្រជុំអំពីការអនុវត្តនូវផែនការប្លន់សំរាប់វេលាយប់នោះឯង ។ កាលបើពួកវាបានឃើញព្រះមហាសុបក្សិនិមន្តមកដល់ហើយ មេរបស់ពួកវាក៏បញ្ជាឱ្យឃាត់ព្រះអង្គទុកសិន ដើម្បីនឹងសាកសួរចម្លើយ ។ ពួកចោរចង់ដឹងណាស់ថាតើភិក្ខុអង្គនេះត្រូវនិមន្តទៅណាមកណាអញ្ចេះ ក៏ជួននឹងបានមកដល់ទីនេះនឹងគេដែរ ។ ដោយហេតុតែពួកគេកើតការងឿងឆ្ងល់ លាយឡំទៅដោយការសង្ស័យយ៉ាងខ្លាំងពន់ពេក ទើបមេចោរ និងកូនចោរទាំងប្រាំរយនាក់សំរេចគ្នាថា ត្រូវតែបង្ខាំងព្រះអង្គទុកមួយអន្លើសិន មិនទាន់អនុញ្ញាតឱ្យព្រះអង្គនិមន្តជាបន្តទៅទៀតឡើយ ។ លុះព្រះអង្គគង់ស្រួលបួលហើយ មេចោរក៏ប្រញាប់សួរទៅព្រះអង្គថា :

" នែ ! ព្រះស្តែងឯងទៅណាមកណា ទើបបានជាមកដល់ទីនេះនឹងគេដែរអ្ហាស ? ព្រះស្តែងឯងមានការអ្វីខ្លះទៅ ទើបបានជាខំដើរអីដូចជារូតរះខ្លាំងម្ល៉េះ ? ចូរព្រះស្តែងប្រាប់យើងឱ្យត្រង់មកមើល ! " ។

ព្រះមហាសុបក្សិ ក៏មានពុទ្ធដីកាប្រាប់ការពិតដល់ពួកចោរ អំពីមូលហេតុ និងទីដៅនៃការធ្វើដំណើររបស់ព្រះអង្គ ។ លុះពួកចោរទាំងប្រាំរយនាក់ស្តាប់ឮជាក់នូវពុទ្ធដីកានេះហើយ មេចោរក៏ទូលតបទៅព្រះអង្គវិញភ្លាមថា :

"ពួកយើងមានផែនការនឹងទៅប្លន់នៅក្នុងស្រុកភូមិកំណើតរបស់ព្រះស្តែងនេះឯងក្នុងយប់នេះ នាវេលាមុនពាក់កណ្តាលអធ្រាត្របន្តិច ។ យើងមានគ្នាប្រាំរយនាក់ ដូចព្រះស្តែងបានឃើញស្រាប់ហើយ ។ យើងមិនអាចផ្លាស់ប្តូរកម្មវិធីរបស់យើងបានទេណា៎ ព្រោះថា ផែនការដែលនឹងត្រូវអនុវត្តនៅវេលាល្ងាចនេះយើងបានរៀបចំរួចរាល់ស្រេចបាច់អស់ហើយ មានការបែងចែកការងារឱ្យទទួល

ខុសត្រូវទៅតាមភូមិសាស្ត្រ និងតាមមុខនាទីរៀងៗខ្លួន ។ អាស្រ័យដោយមូលហេតុដូចយើងបានជម្រាបជូនអម្បាញ់មិញនេះ ព្រះស្តេងគួរតែយល់ហើយថា ព្រះស្តេងឯងត្រូវតែនៅទីនេះ រហូតដល់ពេលដែលយើងសំរេចបាននូវផែនការរបស់យើងរួចរាល់អស់សិន ទើបយើងព្រមអនុញ្ញាតឱ្យព្រះស្តេង បន្តដំណើរទៅមុខទៀត ។ ប្រសិនបើយើងដោះលែងឱ្យព្រះស្តេងទៅនៅពេលនេះ ច្បាស់ជាផែនការដ៏ធំរបស់ពួកយើងនឹងត្រូវទទួលបរាជ័យទាំងស្រុងតែម្តង ។ ព្រះស្តេងឯងប្រាកដជាទៅប្រាប់អស់ទាំងបងប្អូន ញាតិញោម អ្នកស្រុក អ្នកភូមិផង ឱ្យគេដឹងជាមុនពីផែនការរបស់យើង ។ អ្នកទាំងនោះឯង គេច្បាស់ជារៀបចំផែនការទប់ទល់របស់គេ គឺគេច្បាស់ជាចាំតតាំងប្រឆាំងនឹងយើងជាមិនខាន ។ បើពួកគេបានដឹងពីផែនការរបស់យើងជាមុននោះ ពួកគេប្រាកដជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការកំទេចផែនការរបស់យើង ហើយពួកគេនឹងកំទេចបានដោយងាយទៀតផង ។ មិនត្រឹមតែប៉ុណ្ណោះទេ ពួកគេថែមទាំងអាចបង្កឱ្យមានគ្រោះថ្នាក់ដល់គ្នីគ្នារបស់យើងទៀតផង ជាមិនខាន " ។

កាលបើបានឮបញ្ញាដាច់ណាត់របស់មេចោរហើយ ព្រះមហាសុបក្សីតាបស ក៏ប្រញាប់ឆ្លើយអង្វរទៅមេចោរនោះ ដោយព្រះពុទ្ធដីកាយ៉ាងរាបសារថា :

"អាត្មាភាពត្រូវទៅមើលញោមប្រុសញោមស្រី ដែលកំពុងដល់នូវក្តីចាស់ជរា ពីព្រោះអ្នកមានគុណទាំងពីរអង្គាប្រហែលជាកំពុងមានជំងឺតម្កាត់ផងក៏មិនដឹង ។ វិលេងកាលជាច្រើនខែមកហើយ អាត្មាចេះតែរវល់ជាច្រើនពន់ពេក នឹងឆ្លៀតឱកាសផងក៏មិនបាន ។ ទើបតែឥឡូវនេះ អាត្មាអាចឆ្លៀតពេលបាន ក៏គិតថាអាត្មាត្រូវតែប្រញាប់ប្រញាល់ទៅសួរសុខទុក្ខអ្នកមានគុណ ។ អាត្មាសំរេចថាត្រូវតែទៅឱ្យទាន់មុនពេលព្រះសុរិយាលិច ព្រោះអីអាត្មាហាក់ដូចជាមានប្រផ្នូលមិនល្អសោះថា ញោមរបស់អាត្មាមិនសូវជានាទេ ហើយលោកកំពុងត្រូវការរូបអាត្មាជាបន្ទាន់ណាស់ ។ ការឃាត់ឃាំងមិនឱ្យអាត្មាទៅនៅក្នុងពេលនេះ វាធ្វើឱ្យអាត្មាកើតក្តីបារម្ភកាន់តែខ្លាំង

ឡើង១ពេកណាស់ណាំលោកនាយ និងអស់លោកទាំងអស់គ្នា ។ អាស្រ័យហេតុនេះ សូមអស់លោកមេត្តាអនុគ្រោះដល់អាត្មាផង " ។

មេចោរស្តាប់ឮហើយក៏ឆ្លើយភ្លាមឡើងថា :

" ទេ ! មិនបានទេ ! បើយើងបើកឱ្យព្រះស្តេងទៅនោះ គឺច្បាស់ជាបែកការ ។ វាប្រាកដជាគ្មានមូលហេតុឯណា ដែលថាព្រះស្តេងមិនផ្សព្វផ្សាយប្រាប់អ្នកស្រុកភូមិផង បងប្អូន ញាតិសន្តានព្រេងលាន ឱ្យគេបានដឹងជាមុនអំពីគម្រោងការប្លន់របស់យើងនោះទេ ។ មិនដែលមាននរណាឡើយ ដែលបានដឹងរួចជាស្រេចទៅហើយនោះ ថានឹងមានគេទៅព្យាបាទឪពុកម្តាយ និងញាតិសន្តានរបស់ខ្លួន នៅវេលាល្ងាចនេះ ហើយខ្លួនមិនប្រាប់ពីការពិតឱ្យបងប្អូនរបស់ខ្លួនទាំងនោះបានដឹងជាមុន ដើម្បីឱ្យគេអាចប្រុងប្រយ័ត្នបានទាន់សភាពការណ៍នោះទេ ។ នែ, ព្រះស្តេងអើយ ! ចូររង់ចាំនៅទីនេះឯងសិនចុះ លុះដល់ព្រឹកស្អែកនេះឯង សឹមព្រះស្តេងបន្តដំណើរទៅទៀត " ។

ព្រះអង្គឈ្វេងយល់ថា បើព្រះអង្គនៅតែទទូចអង្វរសុំសេចក្តីអនុគ្រោះពីមេចោរនោះដោយត្រង់ៗ ទទេៗ គឺដោយពុំមានដាក់លក្ខខណ្ឌអ្វីសោះនោះ គឺជាការឥតប្រយោជន៍ទេចំពោះព្រះអង្គ ។ ព្រះមហាសុបក្សី ក៏មានពុទ្ធដីកាសាកល្បងអង្វរករទៅមេចោរម្តងទៀត ។ លើកនេះ ព្រះអង្គមានភ្ជាប់នូវការសន្យាជាឧឡារិកជាមួយមេចោរថា :

" អាត្មានឹងមិនផ្សព្វផ្សាយឱ្យនរណាដឹងអំពីរឿងប្លន់នេះទេ កុំថាឡើយដល់ទៅញាតិសន្តាន សូម្បីតែមាតាបិតាបង្កើតរបស់អាត្មានោះ ក៏ឥតអង្គីមានឡើយ ។ សូមលោកនាយទុកចិត្តចុះ នេះគឺជាពាក្យពិតរបស់អាត្មាដែលជាសង្ឃ ។ អាត្មាមានពុទ្ធដីកាដោយស្មោះត្រង់ពិតៗ ឥតភូតភរទេ សូមលោកនាយជឿចុះ " ។

តាមធម្មតា មេចោរនោះមិនដែលយកអង្វរនរណាដល់ម្តងទេ ។ ស្រាប់

តែនៅក្នុងពេលនេះឯងជួនជាដោយចៃដន្យអ្វីម្លេះ ទើបបានជាព្រហ្មលិខិតបណ្ដាល ចិត្តមេចោរឱ្យយល់ព្រមតាមលក្ខខណ្ឌរបស់ព្រះអង្គ ។ ប៉ុន្តែដើម្បីឱ្យកាន់តែប្រាកដ ថែមទៀត មេចោរបានដាក់លក្ខខណ្ឌពីលើនោះជាបន្ថែមថា :

"អើ ! តើនេះវាប្រាកដដូចព្រះស្ដែងពោលចេញមកមែនឬ ? បើពិតដូច្នេះ មែន យើងរីករាយនឹងសុំឱ្យព្រះស្ដែងសន្យាជាមួយយើងយ៉ាងដាច់អហំការថា បើ ព្រះស្ដែងហ៊ានធ្វើឱ្យបែកការ យើងទាំងអស់គ្នានឹងមិនព្រមអនុគ្រោះទោសឱ្យព្រះ ស្ដែងជាដាច់ខាត គឺយើងនឹងសម្លាប់ព្រះស្ដែងចោល ព្រមជាមួយនឹងញោមញាតិ សាច់សាលោហិតរបស់ព្រះស្ដែងឯងផង ឥតមានឱ្យសល់ដល់ម្នាក់ណាឡើយ ។ មើល៍ ! យ៉ាងម៉េចដែរ ព្រះស្ដែងហ៊ានសច្ចាឬទេ ? " ។

មេចោរដាក់លក្ខខណ្ឌនេះឡើង ពីព្រោះវាយល់ដោយប្រាកដក្នុងខ្លួនវាថា ព្រះមហាសុបក្សីនេះ ព្រះអង្គច្បាស់ជាមិនហ៊ានទទួលយកទេ ។ ប៉ុន្តែ វាផ្ទុយពីការ ស្រមៃរបស់មេចោរទៅវិញ ព្រះមហាសុបក្សីជាអ្នកធ្វើវត្តប្រតិបត្តិ កាន់សីល កាន់ សច្ចធម៌ ដ៏ខ្ជាប់ខ្ជួនមួនមាំណាស់ ព្រះអង្គមិនអាចប្រែក្រឡាស់ពាក្យសន្យា ព្រះអង្គ មិនដែលរួញរាដល់ម្ដងណាទេ នៅចំពោះមុខការពោលពាក្យសច្ចៈចេញរួចមកហើយ នោះ ពីព្រោះ ព្រះអង្គតែងតែចិញ្ចឹមអារម្មណ៍ទុកជារៀងរហូតមកថា នរជនណាមិន កាន់ពាក្យសច្ចៈ ហើយបំពារបំពានពាក្យសន្យា នរជននោះឯងពុំមានសេចក្ដីថ្លៃថ្នូរ គឺពុំប្រកបដោយកិត្តិយសទេ ។ ព្រះអង្គក៏មានពុទ្ធដីកាទាំងទឹកព្រះទ័យដ៏ជ្រះស្រឡះ ឆ្លើយតបទៅមេចោរវិញថា :

" ពរ, ជាការប្រាកដណាស់ ! អាត្មាព្រមទទួលយកលក្ខខណ្ឌរបស់លោក នាយ ដោយអាត្មាសុំកុំឱ្យអស់លោកអ្នកទាំងអស់មានក្ដីមន្ទិលសង្ស័យ ឬសៅហ្មង ដោយប្រការណាមួយឡើយ គឺថា ល្ពីកណាតែអាត្មាហ៊ានប្រាប់នរណា ដោយឱ្យ លេចឮពីផែនការរបស់លោកនាយនោះ អាត្មាសុខចិត្តទទួលទោសទណ្ឌទៅតាមកំរិត

ដែលញោមលើកឡើងទាំងប៉ុន្មាននេះ " ។

កាលបើឮពាក្យប្ដេជ្ញាដ៏គួរឱ្យទុកចិត្តបែបនេះហើយ មេចោរក៏សួរទៅកូនចោរទាំងអស់គ្នាឱ្យបញ្ចេញជាមតិឡើង ក្រែងលោក្នុងចំណោមបរិវាររបស់គេមាននរណាម្នាក់ ឬច្រើននាក់ មានបើមើលឃើញនូវផលវិបាកមិនល្អដោយប្រការណាមួយ នោះគេត្រូវតែជួយផ្ដល់ជាយោបល់គ្នា តាមបទបញ្ញាដែលគេបានចែងទុកមក ។ ភាគច្រើននៃកូនចោរ ហាក់ដូចជាមានការជឿទុកចិត្តលើពាក្យសន្យារបស់ព្រះភិក្ខុអង្គនេះ ជាពិសេសគឺ ដោយសារតែគេសំអាងទៅលើលក្ខខណ្ឌដ៏តឹងរ៉ឹងនោះឯង ។ នេះគឺជាបទពិសោធន៍លើកដំបូងបង្អស់ របស់ពួកចោរទាំងប្រាំរយនាក់ ។ ពួកគេក៏អនុញ្ញាតឱ្យព្រះមហាសុបក្សិ និមន្តទៅកាន់ស្រុកកំណើតរបស់ព្រះអង្គ តាមសម្រួលទៅ ។

ព្រះអង្គនិមន្តទៅដល់ស្រុកកំណើតនៅវេលាល្ងាចត្រជាក់ ។ ព្រះអាទិត្យមិនទាន់អស្ដង្គតនៅឡើយទេ ។ ខ្យល់ជំនោរបក់ជាប់ជានិច្ចមិនសូវដាច់ នាំទាំងគន្ធ-ពិដោរនៃរុក្ខជាតិនានាមកជាមួយផង ។ បក្សាបក្សីនាំគ្នាហើរត្រសងត្រឡប់ទៅរកទ្រនំរៀង១ខ្លួនវិញ ។ អ្នកស្រុក អ្នកភូមិផងទាំងឡាយ ដែលបានបញ្ចប់ការងារ នាវេលាថ្ងៃរចហើយ ក៏ម្នីម្នាត្រឡប់ទៅកាន់ផ្ទះសម្បែងទីទៃ១ រៀង១ខ្លួនវិញដែរ ។

លុះនិមន្តដល់ផ្ទះកំណើតហើយ ព្រះមហាសុបក្សិក៏ប្រញាប់ចូលទៅរកអ្នកមានគុណទាំងពីរ ។ កាលបើឃើញព្រះភិក្ខុជាបុត្រនិមន្តមកដល់ហើយ ញោមប្រុសញោមស្រីដែលកំពុងដល់នូវក្ដីជរា ក៏ម្នីម្នាចេញមកទទួល ។ លោកមានជំងឺតម្កាត់បន្តិចបន្តួចផ្សំផងក៏ដោយសារតែជរាភាព ។ ប៉ុន្តែ ការនិមន្តមកនៃបុត្រជាទីស្នេហា បានញ៉ាំងឱ្យជនជរាកើតចិន្តារីករាយយ៉ាងខ្លាំង រហូតដល់មានកម្លាំងពលំស្រួលបួលបរិបូណ៌ឡើងវិញ ។ លោកក៏រៀបចំទទួលអ្នកមានសីលទានដោយសមគួរទៅតាមទំនៀមទម្លាប់ធម្មតា ។ ញាតិកាព្រៀងលានទាំងអម្បាលម៉ាន កាលបើ

បានជ្រាបហើយ ក៏នាំគ្នាមកដល់ជាបន្តបន្ទាប់ មុនក្រោយជាលំដាប់លំដោយ តាមនៅជិត និងនៅឆ្ងាយ ។ ការជួបជុំគ្នាដោយឥតបានគ្រោងទុកជាមុននេះ បានក្លាយទៅជាពិធីអធិកអធមមួយយ៉ាងសប្បាយ សំរាប់ប្រជាជនទាំងក្មេងចាស់ប្រុសស្រី ។ នោះគឺជាពិធីបុណ្យកំសាន្តតូចមួយ ដែលញុំាងឱ្យកើតបរិយាកាសនៃសេចក្តីរីករាយយ៉ាងធំធេង ។ ពុទ្ធបរិស័ទទាំងអស់ចាត់ទុកពេលនេះ ថាជាឱកាសមួយដ៏ល្អពិសេសកម្រមាន ។ គេក៏សំរេចនិមន្តព្រះមហាសុបក្សីឱ្យសូត្រជយន្តោប្រសិទ្ធិពរប្រស់ព្រំព្រមដោយមានការបាចទឹកមន្តផង ។ លុះពិធីនេះកន្លងផុតទៅ ក៏មានការចាប់ផ្តើមនូវការសំណេះសំណាលលេងពីនេះពីនោះបន្តទៅអស់មួយរយៈទៀត ដែលជាធម្មតាគេចូលចិត្តពិភាក្សាពីរឿងផ្សេងៗ ដែលស្ថិតនៅក្នុងក្របខណ្ឌនៃព្រះពុទ្ធសាសនា ។ ពុទ្ធមាមកជនទាំងឡាយ មានចិត្តជ្រះថ្លារីករាយពន់ប្រមាណណាស់ ។

យប់កាន់តែជ្រៅ ។ ពួកពុទ្ធបរិស័ទក៏នាំគ្នាថ្វាយបង្គំលាព្រះមហាសុបក្សី ដើម្បីទៅរកសម្រាកនៅតាមផ្ទះសម្បែងជាបន្តបន្ទាប់គ្នាតែរៀងៗខ្លួន ។ គឺជារាត្រីមួយយ៉ាងស្ងាត់ជ្រងំក្នុងដើមរនោច ។ មេឃភ្លឺស្រឡះយ៉ាងច្បាស់ ។ តារារះព្រោងព្រាត ហាក់បីដូចជាពន្លឺទៀនរាយប៉ាយរាប់សែនរាប់លានដើម ។ មនុស្សម្នាផងគ្នាបាននិទ្រាលង់លក់សែនស្កប់ស្កល់ ជម្រះអស់ក្តីអំពល់ ក្តីហត់នឿយពីវេលាថ្ងៃ ។ ដូចតែសព្វមួយដងដែរ ពុំមានសញ្ញាអ្វីដែលបង្កឱ្យគេមានការនឹកភ័យព្រួយ ឬឱ្យគេបារម្ភឡើយ ។ សត្វពាហណៈ មានគោ ក្របី ដំរី សេះ លា ជាដើម ក៏វានាំគ្នាសម្រាកបំបាត់ការនឿយហត់នាវេលាពីថ្ងៃ ដើម្បីយកកម្លាំងសំរាប់ធ្វើការងារ នៅវេលាថ្ងៃស្អែកទៀត ។ រីឯសុនខនៅគ្រប់ផ្ទះក៏មិនព្រួស ឬលូ បន្តិចសោះឡើយ ។ សត្វលោកគ្រប់គ្នាលក់ក្នុងនិទ្រាដូចត្រូវសណ្តំ ។ សូម្បីតែព្រះមហាសុបក្សី ក៏ព្រះអង្គកំពុងសឹងលក់ពេញល្បក់សែនសុខក្នុងអារម្មណ៍ ដូចអស់ទាំងញាតិញោមឯទៀតដែរ ម្យ៉ាងដោយសារ វេលាយប់យន់នោះ ក៏កាន់តែជ្រៅ ថែមទាំងត្រូវនឹងខ្យល់ជំនោរ

បរិសុទ្ធរហើយៗបក់មកម្ដងៗ កាន់តែបន្ថែមឱ្យស្រួលដំណោកផង ហើយម្យ៉ាងទៀត គឺដោយសារព្រះអង្គនឿយហត់នឹងដំណើរតាមផ្លូវឆ្ងាយ កាលពីវេលាថ្ងៃនោះផង ។

រាត្រីកាលចេះតែកន្លងទៅ នាំទាំងតារាករចរទៅជាមួយដោយសន្សឹមៗផងដែរ ។ បើគេគយគន់មើលទៅផ្កាយយាម ឬផ្កាយសេះ ឬផ្កាយកូនមាន់ គេអាចសន្និដ្ឋានបានតាមការចំណាំនារដូវនោះថា វេលាអធ្រាត្រជិតមកដល់ហើយ ។ យូរៗគេឮសូរបក្សីរាត្រីចរ មានខ្លែងស្រាក លលកខ្មោច ទីទុយ មៀម ជាដើម យំម្ដងៗ ឬជួនកាលនៅឯលើមេឃខ្ពស់ឆ្ងាយ គេឃើញអាចម៍ផ្កាយហោះបានតែមួយប៉ប្រិចភ្នែក រួចហើយក៏បែកជាពន្លឺខ្ចាយរលាយបាត់ទៅ ។ នៅក្នុងពេលជាមួយគ្នានោះ ពួកចោរកំពុងនាំគ្នាធ្វើដំណើរទៅមុខយ៉ាងស្ងៀមស្ងាត់ ក្នុងស្មារតីសែនប្រុងប្រយ័ត្ន ទាំងប្រកបដោយរបៀបរៀបរយគួរឱ្យគយគន់ និងឱ្យកោតសរសើរ ។ ពួកគេបានសំរេចចិត្តរួចហើយថា ទោះបីជាយ៉ាងណាក្ដី ក៏ព្រះមហាឥសីអង្គនេះ ត្រូវតែក្បត់ពាក្យសន្យាដោយចៀសមិនផុតដែរ ។ ពួកគេបានប្ដេជ្ញាយ៉ាងម៉ឺងម៉ាត់ហើយថា ពួកគេត្រូវតែឆក់ប្លន់យករបស់ទ្រព្យណាដែលមានតម្លៃឱ្យបានច្រើនបំផុត រួចហើយសឹមនាំជនក្បត់ទៅកាត់ទោស នៅចំពោះមុខបងប្អូនសាច់ញាតិព្រៀង លានរបស់គេទាំងអស់គ្នា ដើម្បីទុកជាមេរៀនសំរាប់ឱ្យអ្នកទាំងអស់នោះចងចាំ ។ ពួកចោរទាំងប្រាំរយ ប្រដាប់ដោយអាវុធគ្រប់ដៃ មានជាអាទិ៍ កាំបិតកៃ ពូថៅ កាំបិតខ្វេវ កាំបិតផ្គាក់ ដាវ ព្រមដោយនូវព្រួញ ស្នា ដ៏មានមុខស្រួចភ្លឺថ្លាមុតពន់ពេក គួរឱ្យខ្លាច ។

គឺនៅពេលជិតអធ្រាត្រនោះឯងហើយ ដែលព្រឹត្តិការណ៍ដ៏គួរឱ្យតក់ស្លុតរន្ធត់នោះចាប់ផ្ដើម ។ គេស្រាប់តែឮសូរសម្រែកសន្ធាប់ផ្ទុះឡើង បំបាត់សភាពស្ងប់ស្ងាត់នៃរាត្រីកាល ។ ព្រមពេលគ្នានោះ សុនខទាំងឡាយក៏ព្រួសទ្រហឹងអឹងកង, ឯពួកចោរក៏សំរុកចូលមកដល់ទីដៅរៀងៗខ្លួនរួចជាស្រេច ។ រំពេចនោះ ពួកវាបន្លឺស្រែកសន្ធាប់កាន់តែញាប់ឱ្យម្ចាស់ផ្ទះបើកទ្វារ ។ ខ្លះទៀត យកជើងធាក់ទ្វារ ម្ទិម្ទា

ចូលឱ្យបានឆាប់ដល់ខាងក្នុងផ្ទះ ។ អស់ទាំងអ្នកស្រុកអ្នកភូមិផង មិនថាប្រុសស្រី ក្មេងចាស់ដែលកំពុងដេកលក់នៅតាមផ្ទះនីមួយៗ កាលបើត្រូវភ្ញាក់កន្ត្រាក់អារម្មណ៍ ដោយសារសំឡេងក្ដុងក្ដាំង និងសម្រែកសន្ធាប់ទាំងអស់នេះ ក៏ភ្ញាក់ទាំងសើង មម៉ើង រួចក្រោកផ្អើលឆោឡោឡើងជាកោលាហលវិចល់ លាយដោយការភ័ន្តភាំង និងភិតភ័យ ព្រោះមិនទាន់ដឹងការពិតភ្លាមៗ ថាមានរឿងហេតុអ្វីដែលកំពុងកើត ឡើងនេះទេ ។ ក្មេងក្មាងដែលភ័យភិតនឹងព្រឹត្តិការណ៍នេះ ក៏តាំងស្រែកទ្រហោយំ ជាខ្លាំង ក្មេងខ្លះខ្លាចពេកក៏យំឡើងគាំង ឥតទាំងមាននរណារកឱកាសនឹងលួងលោម វាបានឡើយ ។ នៅក្នុងស្ថានភាពបែបនេះ ជាធម្មតា គ្មាននរណាអាចជួយនរណាបាន ទេ ។ រីឯមាគ៌ាតែមួយគត់ សំរាប់អ្នករងគ្រោះត្រូវជ្រើសរើសយកនៅពេលនោះ គឺ មានតែការចុះចាញ់ និងការចុះចូល ហើយបណ្ដោយឱ្យពួកចោរប្រមូលយកអស់ របស់ទ្រព្យជាទីគាប់ចិត្ត មានជាអាទិ៍គឺ លុយកាក់ មាសប្រាក់ កែវកង ព្រមដោយនូវ សំពត់អាវសារសៃ្បផង ដែលប្រជាជនស្លូតត្រង់យើងខំសន្សំទុករាប់ឆ្នាំ រាប់តំណមកហើយប៉ុណ្ណោះទេ ។ អ្នករងគ្រោះទាំងអស់បានត្រឹមតែអង្វរសុំសេចក្ដី សន្ដោសពីពួកចោរបារាយ ដើម្បីកុំឱ្យតែគេធ្វើបាបដល់រាងកាយរបស់ខ្លួន តែ ប៉ុណ្ណោះឯង ។ មិនថាឡើយតែមនុស្សម្នាទេ សូម្បីតែសត្វពាហនៈក៏ភ័យ ផ្អើល ឆោឡោ ខ្លះបុកក្រោលឃ្នង ខ្លះទៀតរត់ទម្លាយរបង រំលងហួសទៅដល់វាលស្រែ ប្រាសយកតែអាយុ យករួចខ្លួនទីទៃៗ តែរៀងខ្លួនដែរ ។

អំពើឆក់ប្លន់នោះបានប្រព្រឹត្តទៅអស់រយៈពេលវេលាមួយសន្ទុះធំ ។ បន្ទាប់មក ពួកចោរនាំគ្នាប្រមូលផ្ដុំជួបជុំគ្នានៅទីកន្លែងមួយចំកណ្ដាលភូមិ ។ ពួកវា មាននាំទាំងមនុស្សសំខាន់ៗដែលពួកវាគ្រោងចាប់នោះមកជាមួយផង ក្នុងនោះក៏មាន ទាំងព្រះមហាសុបក្សិតាបស និងញោមប្រុសញោមស្រីរបស់ព្រះអង្គដែរ ។ មេចោរ បានបញ្ជាឱ្យកូនចោរដាក់អ្នកជាប់ទោសទាំងប៉ុន្មានឱ្យអង្គុយជុំគ្នាមួយកន្លែង រីឯកូន

ចោរទាំងប្រាំរយនាក់ត្រូវមានភារៈនឹងរក្សាការពារផ្នែកសន្តិសុខ ។ បន្ទាប់មក មេចោរក៏ចេញបញ្ជាឱ្យពួកកូនចោរប្រមូលឱ្យអស់នូវរបស់ទ្រព្យដែលពួកគេយកបានទាំងប៉ុន្មានមកទុកមួយកន្លែង ដោយធ្វើការកត់ចំណាំរៀងៗខ្លួន ដើម្បីបង្ហាញឱ្យដឹងថាអ្នកណាយកអ្វី បានប៉ុន្មានៗ ។ លុះរៀបរយរួចរាល់ស្រេចបាច់អស់ហើយ មេចោរក៏ប្រញាប់ចាប់ផ្ដើមបើកការប្រជុំមួយ ក្នុងបំណងដូចដែលគេបានគ្រោងទុករួចមកហើយ គឺគ្រាន់តែប្រកាសឱ្យដឹងអំពីហេតុអ្វី ទើបបានជាពួកគេត្រូវតែចាប់ខ្លួនព្រះមហាសុបក្សិ និងញោមប្រុសញោមស្រីរបស់ព្រះអង្គ ។ ប្រជាជនទាំងអស់ ដែលពួកចោរកែនឱ្យមកចូលរួមនោះ ពួកគេពុំយល់ពីមូលហេតុទេ ។ ម្នាក់ៗចេះតែមានការងឿងឆ្ងល់ និងកើតការសង្ស័យ ថាមុខជានឹងកើតមានរឿងអពមង្គលអ្វីផ្សេងជាបន្ថែមពីលើសោកនាដកម្មដែលទើបនឹងកន្លងទៅមិនទាន់ផុតផងនេះទៀត មិនលែងឡើយ ។ វេលាអធ្រាតទើបតែកន្លងផុតទៅ មិនទាន់បានយូរប៉ុន្មានទេ ។ ព្រឹត្តិ-ការណ៍អាក្រក់បានស្ងប់ស្ងួរទៅវិញហើយ ថ្វីបើវាកំពុងតែស្ថិតនៅដក់ជាប់យ៉ាងខ្លាំងក្នុងអារម្មណ៍នៃប្រជាករទាំងអស់គ្នានៅឡើយនោះក៏ដោយ ។ ម្នាក់ៗចាត់ទុកថាព្រឹត្តិការណ៍នេះជាវាសនាអាក្រក់មួយ ដែលគេមិនធ្លាប់ជួបប្រទះសោះក្នុងមួយជីវិតរបស់គេ ។ ចាប់ពីពេលនេះទៅ អ្វីៗត្រូវរលីងពីខ្លួនអស់ ។ ការស្ដាយស្រណោះនូវទ្រព្យរបស់ជាកេរកោះ និងទ្រព្យរបស់ដែលគេរកបានមកដោយកម្លាំងញើសឈាមរបស់ខ្លួនគេផ្ទាល់នោះ មានទំហំធំធេងពន់ពេកណាស់ រកពាក្យអ្វីមកថ្លែងមិនបានឡើយ ។ ប៉ុណ្ណឹងហើយ តើគេត្រូវជួបនូវការខាតបង់អ្វីទៀតទៅ ? នៅនាវេលាយប់ជ្រៅរំលងអធ្រាត្រទៅហើយនោះ មេចោរក៏ចាប់ផ្ដើមបំបែកសភាពស្ងប់ស្ងាត់ ដោយបន្លឺវាចានៅចំពោះមុខអង្គប្រជុំថា :

" នែអស់អ្នករាល់គ្នា, សូមចាំស្ដាប់ខ្ញុំ ! ។ ខ្ញុំមានសំណួមពរមួយចំនួនដែលខ្ញុំត្រូវចោទសួរចំពោះអស់អ្នករាល់គ្នានៅពេលនេះ " ។ រួចហើយ មេចោរក៏ឧទ្ទាន

ពាក្យសំដីយ៉ាងម៉ឺងម៉ាត់ ច្បាស់ៗ ដូចតទៅ ៖

" ពួកយើងខ្ញុំទាំងអស់គ្នាបានលើកផែនការថាមកប្លន់នៅក្នុងស្រុកក្នុងភូមិនេះ ដូចអស់អ្នករាល់គ្នាបានឃើញនឹងភ្នែកផ្ទាល់ស្រាប់ហើយ ។ មុននឹងពួកយើងចាប់ចេញដំណើរមក ពួកយើងបានគិតគូរទុករួចជាស្រេចហើយថា ផែនការរបស់យើងច្បាស់ជានឹងត្រូវជួបនូវឧបសគ្គពីសំណាក់អស់អ្នករាល់គ្នា ដោយហេតុថា អស់អ្នករាល់គ្នា ច្បាស់ជានឹងត្រៀមអាវុធគ្រប់ដៃដើម្បីតតាំងជាមួយពួកយើង ។ ពួកយើងខ្ញុំឆ្ងល់ណាស់ ដោយសារតែការពិភាល់របស់យើង វាពុំបានកើតឡើងសោះ ។ កិច្ចប្រតិបត្តិការរបស់ពួកយើង ត្រូវបានប្រព្រឹត្តទៅដោយស្រួលបំផុត គឺស្រួលហួសពីអ្វីដែលពួកយើងបានស្មានទុកនោះច្រើនណាស់ ។ ខ្ញុំសុំឱ្យអស់អ្នករាល់គ្នាប្រាប់ខ្ញុំឱ្យត្រង់មកមើល តើប្រការហេតុដូចម្ដេចបានជាអស់អ្នករាល់គ្នា បែរមិនមានចាត់វិធានការត្រៀមការពារ ឬតតាំងប្រឆាំងជាមួយពួកយើងខ្ញុំ ដូច្នេះ ? " ។

សំណួរនេះ ហាក់ដូចជាមកកន្ត្រាក់ស្មារតីរបស់ជនរងគ្រោះទាំងអស់ ឱ្យកាន់តែកើតមានការសង្ស័យថែមទ្វេឡើងទៀត ។ អ្នករងគ្រោះម្នាក់ៗ ឆ្ងល់ណាស់ថា បើពួកចោរទាំងនេះវាប្លន់យកទ្រព្យបានអស់ហើយ ចុះហេតុម្ដេចបានជាពួកវាមិនប្រញាប់ចេញទៅវិញឱ្យឆាប់ទៅ ? តើពួកវានៅមានផែនការអ្វីជាបន្ថែមទៅលើការខាតបង់ទ្រព្យសម្បត្តិរបស់គេទៀត ? ។ ប៉ុន្តែ អ្វីដែលប្រជាករមានការព្រួយបារម្ភជាងគេនាពេលនោះ គឺការចាប់ខ្លួនព្រះមហាសុបក្សិតាបស និងញោមប្រុស ញោមស្រីរបស់ព្រះអង្គ ព្រមទាំងចាស់ព្រឹទ្ធាចារ្យមួយចំនួនទៀត ។

ពេលនោះ បុរសចំណាស់ម្នាក់ដែលគេតែងតែចាត់ទុកគាត់ជាអ្នកមុខអ្នកការ ជាព្រឹទ្ធាចារ្យម្នាក់ប្រចាំភូមិ ដោយសារតែគាត់ធ្លាប់បានបួសរៀន ហើយបានទៅជាអ្នកចេះដឹងជាងគេម្នាក់ដែរ ក៏បានចេញមុខអះអាងជំនួសគេឯង ដើម្បីស្រាយបំភ្លឺទៅនឹងសំណួររបស់មេចោរនោះថា ៖

" ឱលោកម្ចាស់អើយ ! តើមាននរណាទៅ ក្នុងចំណោមពួកយើងខ្ញុំនេះ ជាមនុស្សទ្រង់ញាណ ជាមនុស្សមានវិញ្ញាណទិព្វ អាចប្រមើលឃើញ ឬដឹងពីហេតុភេទដែលអាចនឹងកើតមានឡើងនៅក្នុងពេលជាអនាគតនោះ ? មុនពេលដែលលោកម្ចាស់មកបួន់នៅក្នុងស្រុកភូមិយើងខ្ញុំនេះ តើលោកម្ចាស់មានបានប្រាប់ឱ្យអ្នកណាម្នាក់ដឹងជាមុន ក្នុងចំណោមបងប្អូននៃពួកយើងខ្ញុំទាំងអស់គ្នានេះទេ ? ប្រសិនបើពួកយើងខ្ញុំបានដឹងជាមុន ថាមានពួកលោកម្ចាស់មកប្លន់នោះ ទោះបីជាមានមែនឬមិនមែនក៏ដោយ ក៏ពួកយើងខ្ញុំនាំគ្នាបង្កើតការប្រុងប្រយ័ត្នខ្លះដែរ ។ យ៉ាងហោចណាស់ ក៏យើងខ្ញុំអាចរំដោះនូវរបស់ទ្រព្យណាៗ ដែលមានតម្លៃលក់បានលុយខ្លះដែរ គឺមិនបណ្តោយឱ្យលោកម្ចាស់ប្រមូលយកទាំងអស់អញ្ចឹងទេ " ។

យោលតាមសភាពការណ៍ជាក់ស្តែងដែលទើបនឹងកន្លងផុតទៅថ្មីៗ មេចោរ ហាក់ដូចជាយល់តាមចម្លើយនេះខ្លះៗដែរ ។ ប៉ុន្តែ គេមិនទាន់អស់សង្ស័យនៅឡើយទេ អំពីភាពមិនស្មោះត្រង់របស់ព្រះមហាសុបក្សីនោះ ។ មេចោរក៏ធ្វើជាឆ្លើយតបទៅវិញថា :

" ខ្ញុំដូចជាជឿនូវការអះអាងរបស់ឯងមិនបានទេ ដែលឯងនិយាយថាពួកអ្នកឯងរាល់គ្នា ពុំបានដឹងហេតុការណ៍នេះជាមុននោះ វាហាក់ដូចជាពុំមានការពិតទាល់តែសោះ ។ នៅក្នុងចំណោមគ្នីគ្នារបស់អ្នកទាំងអស់នោះ មានអ្នកដែលបានជ្រាបពីផែនការរបស់ពួកយើងនៅទីនេះជាមុនរួចស្រេចអស់ទៅហើយតើ ! ។ បំណងតែមួយគត់ ដែលពួកយើងចង់បានពីអស់អ្នករាល់គ្នានៅពេលនេះ គឺពួកយើងត្រូវសុំឱ្យអស់អ្នករាល់គ្នា ទទួលសារភាពពីការពិតនេះប្រាប់យើងមក យើងឥតមានយកទោសពៃរ៍អ្វីចំពោះអ្នករាល់គ្នាទេ ។ ខ្ញុំគ្រាន់តែចង់ដឹងពីការពិតប៉ុណ្ណោះ ។ សូមអ្នករាល់គ្នា កុំជួយលាក់លៀមការពិតឱ្យសោះ " ។

បុរសដដែលនោះ ក៏ឆ្លើយប្រាប់ទៅមេចោរវិញថា :

"រឿងពិតនោះ គឺវាដូចអ្វីដែលខ្ញុំបានជម្រាបជូនលោកម្ចាស់អម្បាញ់មិញហ្នឹងឯង ។ ប្រសិនបើមានអ្នកណាម្នាក់នៃបងប្អូនយើងខ្ញុំនេះ បានជ្រាបពីករណីនេះជាមុនមែននោះ គេប្រាកដជាមិនលាក់លៀមធ្វើអ្វីទេ ម្ល៉ោះហើយ វាសមណាស់តែគេដើរប្រកូកប្រកាសប្រាប់ដល់បងប្អូនយើងខ្ញុំឱ្យបានដឹងទាំងអស់គ្នាជាមិនខាន ។ រីឯក្រុមរបស់លោកម្ចាស់ ក៏មុខជាពិបាកនឹងអនុវត្តផែនការឱ្យបានជោគជ័យយ៉ាងស្រួលៗ ដូច្នេះដែរ ? ទាំងអស់នេះ គឺពេញជាពាក្យពិតហើយណា៎ លោកម្ចាស់ ។ តើមានប្រយោជន៍អ្វីចំពោះរូបយើងខ្ញុំទាំងអស់គ្នា ដែលខ្ញុំត្រូវនិយាយភូតភរ លាក់ការពិតពីលោកម្ចាស់នោះ ? ។ សូមលោកម្ចាស់ មេត្តាសាកសួរបងប្អូនឯទៀតៗដែលកំពុងស្ថិតនៅចំពោះមុខលោកម្ចាស់នេះចុះ ដើម្បីជម្រះឱ្យអស់នូវសេចក្ដីមន្ទិលសង្ស័យនោះ ។ យើងខ្ញុំមានព្រះមហាសុបក្សី ដែលកំពុងគង់នៅទីនេះ ជាអ្នកបួសកាន់សីល កាន់សច្ចៈ ព្រះអង្គជាបន្ទាល់សាក្សីស្រាប់ " ។

មកដល់កន្លែងនេះ មេចោរក៏ប្រញាប់ឆ្លើយកាត់សំដីរបស់បុរសនោះថា ៖

" នែ ! អស់លោករាល់គ្នា ! ខ្ញុំសូមប្រញាប់បញ្ចប់សេចក្ដីយ៉ាងខ្លី ដើម្បីបញ្ជាក់ប្រាប់អ្នករាល់គ្នាតែម្ដង ពីអ្នកណាដែលបានដឹងពីផែនការរបស់យើងនោះ គឺគ្មានអ្នកណាក្រៅពីព្រះស្ដែងនេះទេណា៎ " (មេចោរនោះ ក៏លើកដៃចង្អុលសំដៅទៅព្រះមហាសុបក្សី ដែលកំពុងគង់នៅស្ងៀម ពុំមានចេញព្រះពុទ្ធដីកាថាអ្វីឡើយ) ។ បន្ទាប់មក មេចោរក៏បន្តវាចា ដោយសួរតទៅទៀតថា ៖ " តើជាការប្រាកដមែនឬដែលថា ព្រះស្ដែងមួយរូបនេះពុំមានប្រាប់ញោមញាតិឱ្យបានដឹង ថានឹងមានរឿងអាស្រូវត្រូវធ្លាក់មកលើអ្នកទាំងអស់គ្នា នៅវេលាយប់នេះ ? ខ្ញុំហាក់ដូចជានៅមិនទាន់អស់ចិត្ត គឺមិនអាចជឿជាក់នៅឡើយទេ ។ សូមអស់អ្នករាល់គ្នាបញ្ជាក់ការពិតប្រាប់យើងជាបន្ថែមទៀតមកមើល ! " ។

ម្នាក់ៗឆ្លើយឡើងសឹងតែព្រមៗគ្នាថា " ទេ, ព្រះអង្គឥតបានប្រាប់ពួក

យើងខ្ញុំឱ្យដឹង សូម្បីតែបន្តិចណានោះ ក៏ឥតមានដែរណាំលោកម្ចាស់អើយ ! " ។

ជាចុងក្រោយបង្អស់ មេចោរនោះក៏សួរទៅមាតាបិតារបស់ព្រះមហាសុបក្សិ ក្នុងន័យដូចគ្នា ។ ជនជរាទាំងពីររូបក៏ឆ្លើយប្រកែកដូចអ្នកមុនៗដែរ ។ មេចោរ ហាក់ដូចជាកើតការចម្លែកនៅក្នុងចិត្តពេកណាស់ ។ ព្រឹត្តិការណ៍ដែលកំពុងកើតមានចំពោះមុខគេក្នុងពេលនេះ វាហាក់ដូចជាការស្រមើស្រមៃរបស់គេទៅវិញ ។ មេចោរកំពុងតែមានអារម្មណ៍មួយថា ខ្លួនគេហាក់ដូចជាកំពុងយល់សប្តិ ។ រឿងនេះដូចជារកឱ្យគេជឿផងមិនបានទេ តែគឺជាការពិតដែលកំពុងតែកើតមានឡើងនៅចំពោះមុខភ្នែកស្រស់ ។ គេមានអារម្មណ៍ថា មេរៀនបែបនេះ គឺជាបទពិសោធន៍មួយដ៏កម្រមានណាស់ ហើយក៏ប្រហែលជាមិនមានអ្នកណាអាចមានវាសនានឹងជួបប្រទះព្រឹត្តិការណ៍បែបនេះទេ ។

មកដល់ទីនេះ មេចោរក៏មានជំនឿជាក់ក្នុងចិត្តឥតមានសង្ស័យតទៅទៀតឡើយ ថាពាក្យពេចន៍ដែលគេបានស្តាប់កន្លងមកអម្បាញ់មិញនេះទាំងប៉ុន្មាន គឺប្រាកដជាឧទ្ទានចេញមកពីទឹកចិត្តដ៏សែនស្មោះសរមែន ។ ប៉ុន្តែ ដើម្បីជម្រះមន្ទិលឱ្យជ្រះស្រឡះអស់ពីក្នុងសតិអារម្មណ៍របស់គេ មេចោរក៏និយាយទៅកាន់ព្រះមហា-សុបក្សិម្តង ។ លើកនេះ មេចោរបានប្រែសំដី ពីភាពក្រអឺតក្រទម មុតៗ ខ្លាំងៗ មកជាការប្រើសំដីថ្នម កាន់កិរិយាគួរសមបន្តិចវិញថា ៖

" ឥឡូវ ខ្ញុំសុំព្រះស្តែងមេត្តាបំភ្លឺនូវករណីអស់ទាំងនេះម្តង ដើម្បីឱ្យពួកយើងខ្ញុំទាំងអស់គ្នាបានយល់ បានជ្រួតជ្រាបឱ្យសព្វសេចក្តីមកមើល ថាតើព្រះអង្គពិតជាឥតមានប្រាប់ពីឧបទ្ទវហេតុ នាវេលាយប់មិញនេះឱ្យបងប្អូនយើងដឹងជាមុនមែនឬ ? បើពិតដូច្នេះមែន បានន័យជាប្រាកដថា ព្រះស្តែងបានគោរពពាក្យសន្យាដែលយើងបានធ្វើជាមួយគ្នានោះ ។ ព្រឹត្តិការណ៍ដែលទើបតែនឹងកន្លងមិនទាន់ផុតទៅផងនេះ ក៏វាបង្ហាញឱ្យពួកយើងខ្ញុំយល់រួចជាស្រេចទៅហើយ ។ ប៉ុន្តែពួកយើង

ខ្ញុំចង់សុំឱ្យព្រះស្តែងមេត្តាជួយបញ្ជាក់ប្រាប់យើងខ្ញុំថែមទៀតមកមើល ថាការដែលព្រះស្តែងមិនហ៊ានក្បត់ពាក្យសន្យាជាមួយពួកយើងខ្ញុំទាំងអស់គ្នានេះ តើដោយសារតែព្រះស្តែងខ្លាចពួកយើងខ្ញុំចាប់ព្រះស្តែងយកទៅសម្លាប់ ព្រមជាមួយនឹងញោមប្រុសញោមស្រីរបស់ព្រះស្តែងផង ឬមួយក៏ដោយសារមូលហេតុអ្វីផ្សេងពីនេះទៀត ? " ។

ព្រះមហាសុបក្សី ទ្រង់មានពុទ្ធដីកាតបទៅមេចោរនោះវិញថា :

" អាត្មាជាអ្នកបួស ជាអ្នកកាន់សីល កាន់សច្ចធម៌ ។ ក្នុងមួយជីវិតរបស់អាត្មានេះ អាត្មាមិនដែលហ៊ាន ហើយក៏មិនដែលបានប្រព្រឹត្តអំពើអ្វីឱ្យខុសពីគន្លងធម៌ទេ ។ ដូចជា សច្ចធម៌នេះជាដើម អាត្មាបានកាន់ បានរក្សាយ៉ាងខ្ជាប់ខ្ជួននៅក្នុងខ្លួន ក្នុងស្មារតីរបស់អាត្មាជានិច្ច ដូចជាកុសលធម៌ឯទៀតៗដែរ ។ យ៉ាងណាមិញពាក្យសន្យាដែលអាត្មាបានយល់ព្រម បានធ្វើសច្ចាជាមួយលោកនាយរួចមកហើយនោះ អាត្មាមិនអាចក្បត់បានទេ ។ អាត្មាត្រូវតែតាំងចិត្ត តាំងស្មារតី គោរពចំពោះពាក្យសន្យានោះឱ្យបាន ព្រោះថា នរជនណាដែលបានព្រមព្រៀងគ្នារួចហើយ ថាខ្លួនពិតជាសុខចិត្តសុខកាយគោរពពាក្យសន្យា គោរពគោលការណ៍ ឬគោរពច្បាប់ដែលបានដាក់ចេញមកជាមួយគ្នា ប៉ុន្តែ គេបែរជាមិនបានគោរព ឬមិនព្រមគោរពទៅវិញ នរជននោះ បើស្លាប់ទៅវិញទៅ ទើបវាប្រសើរជាង ។ នរជននោះ បើទោះបីជានៅរស់ ក៏គឺរស់បានត្រឹមតែរូបរាងប៉ុណ្ណោះឯង ពោលគឺ នរជននោះលែងអាចទទួលបាននូវសេចក្តីថ្លៃថ្នូរតទៅទៀតហើយ គឺគេត្រូវតែបាត់បង់អស់នូវខ្លឹមសារជាមនុស្សអ្នកមានចិត្តក្លាហាន អ្នកមានកិត្តិយស ព្រមទាំងត្រូវបាត់បង់អស់នូវការទុកចិត្តទុកថ្លើម និងសេចក្តីគោរពពីជនានុជនទាំងឡាយ ។ ជននោះ បើទោះបីជារស់នៅតទៅទៀត គឺគេត្រូវតែខ្មាសសង្គមជាតិ និងខ្មាសខ្លួនឯងផង ជារៀងរហូត គឺរហូត

( នៅមានត )

# ប្រវត្តិ ក្រុងពាលី

ប្រមូលចងក្រងដោយ **អៅ ឆន**
នៅពុទ្ធសាសនបណ្ឌិត្យ

**ក្រុងពាលី** ជាឈ្មោះពិធីកម្មមួយ ត្រូវបានគេលើកយកមកនិយាយ ដំណាលតៗគ្នា ជាច្រើនបែបច្រើនយ៉ាង, នៅទីនេះ ខ្ញុំលើកយកតែសេចក្តីដំណាល ពីរបែប មកជំរាបជូនដូចតទៅ :

សេចក្តីដំណាល, ក្នុងពេលកន្លងទៅយូរយារហើយ គឺចាប់តាំងពេលកទីក កដី ជាដំបូងមកម្ល៉េះ ថាមាននាគ ២ ជាបងប្អូននឹងគ្នា, បងឈ្មោះ **ក្រុងពាលី** ប្អូនឈ្មោះ **ព្រះភូមិ** ជាអ្នកមានរឹទ្ធិខ្លាំងពូកែ បានបង្កើតមនុស្ស សត្វ ព្រៃព្រឹក្សា លតាវល្លិគ្រប់យ៉ាង នៅលើផែនដី និងនៅក្នុងទឹក ហើយតាំងខ្លួនជាម្ចាស់ទឹកម្ចាស់ដី មុនដំបូងបង្អស់ ។ សម័យក្រោយមក មិនជាយូរប៉ុន្មាន, ព្រះពុទ្ធមួយព្រះអង្គទ្រង់ ព្រះនាមបទុមុត្តរៈ បានឧប្បត្តិឡើង [1] ។ ព្រះអង្គមានបំណងប្រមូលមនុស្ស សត្វ ទាំងអស់អោយចូលមកកាន់សាសនារបស់ព្រះអង្គ ។ ព្រះពុទ្ធអង្គនោះបានស្តេចយាង ទៅកាន់លំនៅស្ថានក្រុងពាលី សុំបិណ្ឌបាតទីស្ថានមួយកន្លែងរបស់ក្រុងពាលី ចំនួន ៣ ជំហាន ដើម្បីទុកជាអារាមគង់សំរេចសំរាន្តព្រះឥរិយាបថ សំដែងធម៌ប្រោស វេនេយ្យសត្វក្នុងទីនោះ ។

(1) ឧប្បត្តិ ( អានថា អុប៉ះដឹក ឬ ឧបាត់ ) = កើតឡើង, ត្រាស់ដឹងឡើង

ក្រុងពាលីបានយល់ព្រមតាមសេចក្ដីស្នើសុំ ហើយបានប្រាប់ថា អ្នកចូរឈានវាស់យកដីទុកជាអារាមចុះ ។ ព្រះអង្គបាននិមិត្តព្រះកាយដ៏ធំ ហើយឈានយកដី, ព្រះអង្គឈានតែមួយជំហានប៉ុណ្ណោះ ក៏ផុតពីក្រុងពាលី ។ ដោយរក្សានូវសច្ចវាចា, ក្រុងពាលីពុំមានតវ៉ាអ្វីឡើយ ព្រមប្រគេនទឹកដីទៅព្រះបទុមុត្តរៈ ហើយខ្លួនឯងក៏ថយចេញទៅក្រៅចក្រវាល ។ តែមុននឹងចៀសចេញទៅនោះ បានធ្វើសំណូមពរផ្ដាំផ្ញើនឹងព្រះពុទ្ធអង្គនោះថា បើអ្នកណាមួយនឹងធ្វើកិច្ចជាមង្គល ដូចជា ការរៀបអាពាហ៍ពិពាហ៍, ការសង់លំនៅស្ថានថ្មី ជាដើម អ្នកនោះគប្បីនឹករលឹក ហើយធ្វើការបូជាដោយបង្អែម ចំអាប នំ ចំណី ដល់យើងខ្ញុំជាម្ចាស់ទឹកដីមុនដំបូងផង យើងខ្ញុំផ្ដល់អោយគេ នូវសុភមង្គលវិបុលសុខក្នុងកិច្ចការនោះៗ ។ លុះផ្ដាំស្រេចហើយ ក៏អន្តរធានបាត់ទៅនៅទិសអាគ្នេយ៍ នាវេលាអរុណោទ័យ ។

រឿងមួយបែបទៀត ក្នុងព្រហ្មញ្ញសាសនា លោកពោលថា **ក្រុងពាលី** ជាអ្នកមានមហិទ្ធិឫទ្ធិអស្ចារ្យម្នាក់ ដែលមនុស្សផងទាំងពួងតែងគោរពខ្លបខ្លាចអំណាចបារមី, ឯព្រះព្សិស្ណុ និងព្រះនារាយណ៍ ជាបងប្អូននឹងគ្នា ក៏មានឫទ្ធិខ្លាំងក្លាណាស់ដែរ ។ ព្រះព្សិស្ណុចង់ដណ្ដើមឧត្ដមភាពខាងឫទ្ធិផ្ដាច់មុខ ក៏បានប្រើព្រះនារាយណ៍ជាប្អូន អោយទៅផ្ចាញ់ក្រុងពាលី ។ កាលបានទទួលបញ្ជាហើយ ព្រះនារាយណ៍ ក៏កាលាខ្លួនជាមនុស្សតឿម្នាក់ ចូលទៅសុំដី ៣ ជំហានពីក្រុងពាលី ។ ក្រុងពាលីគិតថា ដី ៣ ជំហានមិនជាច្រើនទេ ហើយក៏ព្រមអោយតាមសុំ ។ ព្រះនារាយណ៍ បានឈានមួយជំហានដំបូងទៅដាន់ព្រហ្មលោក, ជំហានទី២ ទៅដាន់នៅបាតាល ឯជំហានទី៣ ជាន់ចំក្បាលក្រុងពាលីលិចទៅក្នុងដី ។ តែមុននឹងលិចបាត់ទៅក្នុងដី ក្រុងពាលីបានធ្វើសំណូមពរ ដូចក្នុងរឿងខាងដើមដែរ ។

ហេតុនេះឯងហើយ ដែលនាំអោយមានក្រុងពាលីរហូតសព្វថ្ងៃ ។

ម្យ៉ាងទៀត តាមរឿងបែបទី២ នេះ ឃើញថាក្រុងពាលីមិនមែនជានាគ

ទេ គឺជាអាទិទេពខ្លាំងពូកែមួយរូបក្នុងព្រហ្មញ្ញសាសនា ។

រីឯរបៀបធ្វើពិធី និងរៀបរណ្តាប់សែនក្រុងពាលី គឺ :

## ១)- ពិធីក្រុងពាលី

ពិធីក្រុងពាលី ជាពិធីបែបព្រហ្មញ្ញសាសនាសុទ្ធសាធ តែខ្មែរយើងក៏និយមធ្វើរាល់ការងារមង្គលផ្សេងៗដែរ មានការងារមង្គលសង់លំនៅឋានថ្មី ជាដើម, ... ។ របៀបធ្វើក្រុងពាលី, លោក ជា គាន មន្ត្រីនៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ និយាយថា : ពីបុរាណ, ពិធីក្រុងពាលី ត្រូវបានរៀបចំជាពីរផ្នែក មួយផ្នែកសំរាប់ព្រះភូមិ និងមួយផ្នែកទៀត សំរាប់ក្រុងពាលី ។

ក្រោយបានរៀបចំរណ្តាប់សែនក្រុងពាលីសព្វគ្រប់ហើយ លោកអាចារ្យត្រូវប្រារព្ធសែនព្រះភូមិ ។ ឯពាក្យដែលត្រូវសូត្រសែនក្រុងពាលី និងព្រះភូមិនោះមិនដូចគ្នាទេ តាមវោហាររបស់អាចារ្យអ្នកដឹកនាំធ្វើពិធី មានច្រើន ឬតិច ឈ្លាសវៃ ឬមិនឈ្លាស ។

• **ពាក្យសែនព្រះភូមិ :** *អញខ្ញុំឱនអង្គអភិវាទវន្ទា លើកករប្រណម្យបង្គំវន្ទី សូមអញ្ជើញព្រះភូមិរាជា អ្នកគ្រប់គ្រងភារាជាម្ចាស់ធរណីឋាន ។ បពិត្រអ្នកអើយ សូមអញ្ជើញអ្នកមកកាន់ស្ថានលំនៅយើងខ្ញុំឆាប់ៗរ៉ា យើងខ្ញុំបានប្រុងប្រៀបរៀបចំប្រដាប់ប្រដា គ្រឿងសំណែនសែនព្រេនរួចស្រេចហើយណា អាហារដ៏ត្រកាលពិសី ដ្បិតយើងខ្ញុំបានឫក្សពារពេលាល្អ រៀបចំពិធី ... ( ប្រាប់ឈ្មោះពិធី ) ;*

*សូមភូមិ សូមជ័យ កុំបីអ្នកខាយាំងឡើយណា យើងខ្ញុំបូជាក្រយាអោយអ្នកសេពសោយ ទោះបីយើងខ្ញុំធ្វើការមុខក្រោយ ព្រែងថ្លស់ព្រែងធ្លោយ កុំបីអ្នកយកទោសា សោយស្រេចស្តេចចរយាត្រា សូមពរជយាទុកនៅលើយើង*

*ខ្ញុំគ្រប់ប្រាណ សៀវយទុក្ខសៀវយទោស ចង្រៃគ្រប់យ៉ាង សូមស្រឡះអស់ពីប្រាណ ឥតមានអំពល់ខ្វល់ជាទុក្ខ ទាំងថ្ងៃនេះទៅមុខ ប្រទះតែសុខ ដូចចិត្តប៉ងប្រាថ្នា ទៅហោង ! ។*

សូត្រចប់ អាចារ្យកាច់ក្បាលមាន់ ១ ចិតច្រមុះជ្រូកបន្តិច បង្អែម ចំអាបគ្រប់មុខ មួយមុខបន្តិចៗ ដាក់ទៅក្នុងពៃព្រះភូមិ ដែលតាំងនៅខាងឆ្វេងពៃក្រុងពាលី តម្កល់ទុកមួយអន្លើសិន ទើបសូត្រសែនក្រុងពាលី តទៅទៀតថា :

• ពាក្យសែនក្រុងពាលី « *បទុមុត្តរោ ច បុត្តាយំ អត្ថនិយេ វេវតោ ទក្ខិណោ កស្សបោ ពុទ្ធោ* » ,

*បពិត្រពិរោះស្មោះស្មាន យើងខ្ញុំប្រណិធាន លើកករប្រណម្យវន្ទី សូមអញ្ជើញស្ដេចក្រុងពាលី តម្កែងប្រថពី ឮសូរកំពូលទ្វីបា សូមអញ្ជើញនាងអណ្ដែងសុភទ្រា អញខ្ញុំវន្ទាអញ្ជើញព្រជាទកុទ្ធលំ អ្នកមានឫទ្ធិក្លាខ្លាំងលើសលប់ដោយអំណាចដោយបុណ្យឆាប់ឆុត សូមអញ្ជើញព្រះបាទទសរតន៍ ឫទ្ធីក្លាំងក្លាត់ ពន្លឹកពន្លឹពេកពន់ ទើបអញ្ជើញនាងវង្សាពិនន់ ឫទ្ធីនូវបុណ្យប្រកបដោយលក្ខណា ។*

*ដ្បិតថ្ងៃនេះ លោក ... ( ឈ្មោះ ងារម្ចាស់កិច្ចការ ) និងលោកស្រី ... ( ឈ្មោះ ) បានរៀបចំពិធី ... (ឈ្មោះពិធី) ។ យើងខ្ញុំបានឫក្សពារពេលាល្អ ហើយបានរៀបចំគ្រឿងភោជនាហារថ្មី នំ ចំណីប្រពៃស្រេព ប្រសើរស្អាងស្អាត កំណាត់តម្កល់ដោយខ្នាត ចិទប្រាក់ ៤ បាត ដោតជមឆ្វេងស្ដាំ សំពត់ប្រវែងហត្ថ ៥ ដោយនូវចំណាំ ចាំអញ្ជើញអ្នកមកជាមង្គលក្សេមក្សាន្ត ដ្បិតអ្នកជាតិជាប្រធានព្ទសួរភូមិឋាន ឥតមានអ្នកណាប្រៀបផ្ទឹមឡើយនៃ ទោះព្រះបានត្រាស់ច្រើនក្រៃ លោកសឹងអាស្រ័យព្រះគុណអ្នកជាប្រធាន សាងថ្នល់ ជីកស្រះ ស្ពានលើកផ្ទះលំនៅឋាន សឹងបានដូចចិត្តប្រាថ្នា សាងព្រះចេតិយសីមា ព្រះវិហារ*

*សាលា ទុកនៅប្រយោជន៍អង្គប្រាណ ទោះស្តេច មន្ត្រីយោធា ទោះរាស្ត្រប្រជា វន្ទាអ្នកជាប្រធាន ។*

*សូមអញ្ជើញស្តេចក្រុងពាលី នាងគង្ហីងព្រះធរណី មកទទួលក្រយាបូជា ដែលយើងខ្ញុំបានរៀបចំថ្វាយដល់អ្នក មានបាយសី ស្លា បារី ទៀន ធូប ផ្កាភ្ញី សូករៈ កុក្កដះ ស្រូវអង្ករ ល្ង សណ្តែក ពោត ចេក ដំឡូង ដូង ស្លា សំពត់ អាវឆ្នៃងស្តាំ ប្រេង ម្សៅ ផ្លែឈើគ្រប់មុខ គ្រឿងឧបភោគ បរិភោគ មានបង្អែម និងចំអាប ជាដើម ។ កាលបើលោកសេពសោយឆ្អែតស្កប់ស្កល់ហើយ សូមលោកប្រទានពរសព្ទសាធុការជូនដល់លោក ... និងលោកស្រី ... សូមអោយមានជោគជ័យ វិបុលសុខគ្រប់ប្រការ ឈ្នះអស់មារសត្រូវគ្រប់ទិសទី, សត្រូវមកពីមុខអោយរំលង សត្រូវមកពីខ្នងអោយរលាយ សត្រូវមកពីឆ្ងាយអោយក្លាយមកជាមិត្ត សត្រូវជិតអោយខ្លបខ្លាចអំណាចបារមីលោក ... លោកស្រី ... ។ សូមរកស៊ីមានបានត្រជាក់ត្រជំ សុខដុមរមនា តរៀងទៅ ។*

( អាចារ្យបាចលាជ បាចផ្កា បាញ់ទឹកអប់, ភ្លេងលេងកំដរ )

## ២)- រៀបរណ្តាប់សែនក្រុងពាលី

ក) រៀបបាយសី : - បាយសី ៧ ថ្នាក់ ១ គូ (តំណាងពោជ្ឈង្គ ៧)

- បាយសី ៥ ថ្នាក់ ១ គូ (តំណាងភទ្ទកប្បយើងនេះ)
- បាយសី ៣ ថ្នាក់ ១ គូ (តំណាងរតនត្រ័យ ឬត្រៃលក្ខណ៍)
- បាយសីប៉ាឆាម ១ គូ
- ជម ៨

គ) រណ្តាប់ផ្សេងៗ :

- ដូវខ្ចីចិតរួច ចំនួន ២ ផ្លែ
- ចេកពងមាន់ ២ ស្និត

- ក្រួច ១ គូ
- ទឹកអប់ ១ គូ
- ទឹកសំបួរ ១ ផ្តិល
- ខ្មៀយ ១ ដាក់ផ្កាឈូកពីលើ
- កុក្កុដៈ ១ គូ ( មាន់ )
- ម្លូ ស្លា ៥ម៉ាត់
- ទៀន ធូប
- ពៃព្រះភូមិ ១ (*)

- ល្មុត ១ គូ
- សំពត់អាវឆ្វេង-ស្តាំ
- ស្រូវ អង្ករ ល្ង សណ្តែក
- ផ្កាឈូក ៣ ទង
- ចង់រង ១ គូ
- ក្បាលសូករៈ ១ គូ ( ជ្រូក )
- បារី ៥
- ផ្កាភ្ញី
- ពៃក្រុងពាលី ១ (•)

***



រាងពៃ ព្រះភូមិ



រាងពៃ ក្រុងពាលី

---

(*) ពៃព្រះភូមិ មាន ៣ ជ្រុង ( ពៃច្រមុះជ្រូក ) ។

(•) ពៃក្រុងពាលី មាន ៤ ជ្រុង ខ្នាត ១ ហត្ថ នៃអ្នកធ្វើពៃ ។

# សេចក្តីប្រកាសរួមរបស់សិក្ខាសាលា
## ស្តីពី
# ការលើកកំពស់ការប្រតិបត្តិពុទ្ធសាសនា
## ខេត្តស្វាយរៀង, ថ្ងៃទី ២១-២៥ ខែធ្នូ ឆ្នាំ ១៩៩៨

សិក្ខាសាលាស្តីពី « ការលើកកំពស់ការប្រតិបត្តិពុទ្ធសាសនា » បានប្រព្រឹត្តទៅនៅវត្តជម្ពូព្រឹក្សា ឃុំសង្ឃ័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង គឺជាសិក្ខាសាលាលើកដំបូង ដែលមន្ទីរធម្មការនិងសាសនា និងមេគណខេត្តស្វាយរៀង បានរៀបចំឡើងដោយគំនិតផ្តួចផ្តើមរបស់ឯកឧត្តម ឡុយ សុផាត អភិបាលខេត្តស្វាយរៀង និងដោយមានការជួយឧបត្ថម្ភដ៏សំខាន់ ទាំងជាថវិកា ទាំងជាស្មារតី ដល់ដំណើរការប្រព្រឹត្តទៅនៃសិក្ខាសាលានេះពីអង្គការជំនួយសូត្តូស៊ូជប៉ុន (JSRC = SVA)។

អង្គសិក្ខាសាលាបានប្រព្រឹត្តទៅក្រោមអធិបតីភាពនៃព្រះសាសនមុនី ជេត ឱន មេគណខេត្តស្វាយរៀង, នៃមន្ត្រីជាន់ខ្ពស់របស់ក្រសួងធម្មការ និងសាសនា, និងមន្ត្រីជាន់ខ្ពស់របស់ខេត្តស្វាយរៀង ។

ចូលរួមជាសមាជិកនៃសិក្ខាសាលា មានព្រះសង្ឃ ១២២ អង្គ និងអាចារ្យគណៈកម្មការវត្ត ចំនួន ១១១ នាក់ ដែលនិមន្ត-អញ្ជើញមកពី ១១៦ វត្ត នៅក្នុងខេត្តស្វាយរៀង, ព្រះសង្ឃមួយអង្គ និងអាចារ្យពីរនាក់ និមន្ត និងអញ្ជើញមកពីខេត្តកំពង់ស្ពឺ ព្រមទាំងព្រះមេគណ និងតំណាងព្រះមេគណ និមន្តមកពីខេត្តបាត់ដំបង, កំពង់ចាម, ក្រចេះ, ព្រៃវែង, និងតាកែវ ។

ក្នុងរយៈពេល ៥ ថ្ងៃ ចាប់ពីថ្ងៃ ២១ ដល់ថ្ងៃ ២៥ ខែធ្នូ ឆ្នាំ ១៩៩៨ នៃដំណើរការរបស់ខ្លួន អង្គសិក្ខាសាលាបានស្តាប់ :

- សុន្ទរកថាបើកសិក្ខាសាលា របស់ឯកឧត្តម ស្រី មណ្ឌល អភិបាលខេត្ត

វង ខេត្តស្វាយរៀង ។

- របាយការណ៍ស្វាគមន៍របស់លោក ទេព ធន់ នាយកមន្ទីរធម្មការ និងសាសនា ។

- ឱវាទព្រះសាសនមុនី ជេត ឱន មេគណខេត្តស្វាយរៀង,

- មតិសំណេះសំណាលរបស់ឯកឧត្តម ឈេន អៀម រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ។

- ប្រធានបទស្តីពី «វត្តជាមជ្ឈមណ្ឌលវប្បធម៌» ដោយឯកឧត្តម យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា ។

- ប្រធានបទស្តីពី « ការគ្រប់គ្រងវត្តអារាម និងព្រះសង្ឃ » ដោយលោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ ។

- ប្រធានបទស្តីពី « ព្រះពុទ្ធសាសនា និងអភិវឌ្ឍន៍សង្គម » ដោយព្រះតេជព្រះគុណ ពៅម គិមតេង ប្រធានអង្គការសន្តិសេនា ខេត្តស្វាយរៀង ។

- ប្រធានបទស្តីពី « ការប្រើប្រាស់គម្ពីរព្រះត្រៃបិដក និងពុទ្ធិកសិក្សា » ដោយសម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម អគ្គាធិការនៃពុទ្ធិកសិក្សា ។

- មតិសំណេះសំណាល របស់ឯកឧត្តម ឡូយ សុផាត អភិបាលខេត្តស្វាយរៀង ។

- មតិសំណេះសំណាល របស់លោក តេ ស៊ូកា កូជី នាយកនៃអង្គការជំនួយស្ទូតូស៊ូជប៉ុន (JSRC = SVA) ភ្នំពេញ, និង

- បទពិសោធន៍ការងារអភិវឌ្ឍន៍សង្គមតាមរយៈវត្តអារាម ដោយលោក ម៉ិច សុខា មន្ត្រីតំណាងអង្គការជំនួយស្ទូតូស៊ូជប៉ុន (JSRC = SVA) ។

អង្គសិក្ខាសាលាបានធ្វើទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលបណ្តុះកូនឈើរបស់អង្គការសន្តិសេនា នៅឃុំបាទី ស្រុកចន្ទ្រា និងវត្តពោធិបន្ទាយ នៅឃុំប្រសូត្រ

ស្រុកស្វាយទាប, នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមនៃវត្តល្វើន ឃុំដូនស ស្រុកស្វាយជ្រំ, វត្តអំពិលពោធិ ឃុំម្រោម ស្រុករមាសហែក និងវត្តមង្គលការាម ស្រុកស្វាយជ្រំ ។

អង្គសិក្ខាសាលាបានពិភាក្សាផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមក យ៉ាងផុលផុស និងស្មោះស្មគ្រ ។

នៅទីបញ្ចប់, អង្គសិក្ខាសាលាទាំងមូលបានសំរេចជាឯកច្ឆ័ន្ទថ្លែងសេចក្តីប្រកាសរួម ដូចខាងក្រោម :

១. ខិតខំពង្រឹងគុណភាពព្រះសង្ឃ ដោយរៀបចំសាលាពុទ្ធិកសិក្សា ទាំងខាងធម្មវិន័យ ទាំងខាងបឋមសិក្សា ដែលក្រសួងធម្មការ និងសាសនា បានកំណត់រួចហើយ ដោយប្រមូលចងក្រងសាលាធម្មវិន័យ និងសាលាពុទ្ធិកបឋមសិក្សាអោយទៅជាប្រព័ន្ធកំរងសាលា និងកំរងវត្ត តាមចំនួនតិចច្រើន ដែលអាចប្រមូលផ្តុំគ្នាបាន ។

២. ពង្រឹងគុណភាពខាងការគ្រប់គ្រងវត្ត និងព្រះសង្ឃ ដោយធ្វើបញ្ជីសារពើភ័ណ្ឌ កត់ត្រា :

ក) ចំនួនព្រះសង្ឃក្នុងវត្ត

ខ) ចំនួនគរុភ័ណ្ឌជាចលនៈ និងអចលនវត្ថុ របស់វត្ត

គ) ចំនួនឧបាសក ឧបាសិកា ចំណុះជើងវត្ត

ឃ) ចំណូល-ចំណាយប្រចាំឆ្នាំ របស់វត្ត

ង) ធ្វើរបាយការណ៍ប្រគេនព្រះគ្រូអនុគណ ព្រះមេគណ មន្ទីរធម្មការ និងពុទ្ធបរិស័ទចំណុះជើងវត្ត នៅក្នុងឱកាសបុណ្យវិសាខបូជា រៀងរាល់ឆ្នាំ ។

៣. ត្រូវធ្វើប្លង់គោលរបស់វត្ត និងប្រើប្រាស់ដីធ្លីវត្តអោយមានសណ្តាប់ធ្នាប់ ទៅតាមប្លង់គោល ។

៤. ពង្រឹងសមត្ថភាពខាងជំនាញ និងខាងរដ្ឋបាល របស់គណៈគណ, អាចារ្យ, គណៈកម្មការវត្ត និងកំណត់បែងចែកអោយបានច្បាស់លាស់ពីតួនាទី និងភារកិច្ចរបស់ចៅអធិការ, គ្រូសូត្រស្តាំ - ឆ្វេង, អាចារ្យ និងគណៈកម្មការវត្ត ។

៥. យកចិត្តទុកដាក់ប្រែក្លាយវត្តអារាម អោយទៅជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន ដោយបង្កើតអោយមាន :

* បណ្ណាល័យ ( ហោត្រ័យ ) សំរាប់តម្កល់គម្ពីរ ក្បួនខ្នាត
* សួនឧទ្យាន ប្រកបដោយរុក្ខជាតិមានប្រយោជន៍
* សាងសង់សំណង់ថ្មី ប្រកបដោយសិល្បៈ ក្បូរក្បាច់ខ្មែរ, និង
* ចូលរួមកាន់តែសកម្ម ក្នុងកិច្ចអភិវឌ្ឍន៍សង្គម និងការការពារបរិដ្ឋាន វប្បធម៌ សង្គម និងធម្មជាតិ ។

៦. សំណូមពរដល់ក្រសួងធម្មការ និងសាសនា ចេញលិខិតបទដ្ឋាន ពាក់ព័ន្ធនឹងបញ្ហាទាំងឡាយខាងលើអោយបានឆាប់ ដើម្បីអនុវត្តអោយបានឯកភាពគ្នា ។

ធ្វើនៅវត្តជម្ពូព្រឹក្សា ខេត្តស្វាយរៀង, ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៨

| | | |
|---|---|---|
| ណាងព្រះសង្ឃ | តំណាងរដ្ឋអំណាចមូលដ្ឋាន | តំណាងក្រសួងធម្មការនិងសាសនា |
| ត្ថលេខា **ជេក ឌិន** | ហត្ថលេខា **ឡូយ សុផាក** | ហត្ថលេខា **ដោក ណារិន** |
| មគណខេត្ត | អភិបាលខេត្ត | អនុរដ្ឋលេខាធិការ |

តំណាងអាចារ្យ, គណៈកម្មការវត្ត

ហត្ថលេខា **រស់ យាន**

អាចារ្យ

# ទស្សនកិច្ចការងាររបស់គណៈប្រតិភូជប៉ុន នៃ ក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

គណៈប្រតិភូជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ដឹកនាំដោយព្រះតេជព្រះគុណ យ៉ាម៉ាដា (YAMADA) បាននិមន្ត និងអញ្ជើញមកបំពេញទស្សនកិច្ចការងារ នៅកម្ពុជា រយៈពេល ១០ ថ្ងៃ ចាប់ពីថ្ងៃទី ១៤ ដល់ថ្ងៃ ២៣ មករា ១៩៩៩ ។

ក្នុងរយៈពេលស្នាក់នៅច្រើនថ្ងៃនៅកម្ពុជា គណៈប្រតិភូបានបំពេញទស្សនកិច្ចការងារនៅពុទ្ធសាសនបណ្ឌិត្យ, ទស្សនកិច្ចមើលការសិក្សា និងការប្រើប្រាស់សៀវភៅ នៅវត្តទួលទំពូង ក្រុងភ្នំពេញ, នៅវត្តតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ នៅវត្តជ្រោយអំពិល ស្រុកកៀនស្វាយ ខេត្តកណ្តាល និងនៅទីកន្លែងជាច្រើនទៀត ។

នៅថ្ងៃ ១៥ មករា ១៩៩៩ វេលាម៉ោង ៨ ព្រឹក គណៈប្រតិភូនៃ WCRP/Japan បានជួបសន្ទនាការងារជាមួយពុទ្ធសាសនបណ្ឌិត្យ ដែលនៅក្នុងឱកាសនោះ ខាងជប៉ុនមាន ព្រះតេជព្រះគុណ យ៉ាម៉ាដា ប្រធានគណៈប្រតិភូ , ព្រះតេជព្រះគុណ ហាយ៉ាស៊ី , លោក សេគិគូជី សមាជិកគណៈប្រតិភូ និងលោក តេប៉ាំរ៉ុយកា កូជី នាយកអង្គការជំនួយស្ងួតស៊ូជប៉ុន (JSRC) ប្រចាំក្រុងភ្នំពេញ ; ខាងកម្ពុជាមាន ឯកឧត្តម ស្រី វណ្ណផ្ទង់ រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា, លោក យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា និងលោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ ។ ក្រៅពីនេះមាន មន្ត្រីរាជការនៃពុទ្ធសាសនបណ្ឌិត្យ និងមន្ត្រីនៃអង្គការ JSRC មួយចំនួនបានចូលរួមផងដែរ ។

មានមតិស្វាគមន៍ក្នុងឱកាសនោះ ឯកឧត្តម ស្រី វណ្ណផ្ទង់ រដ្ឋលេខាធិការ

បានសំដែងក្នុងនាមរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ក្នុងនាមរដ្ឋលេខាធិការ និងមន្ត្រីរាជការនៃពុទ្ធសាសនបណ្ឌិត្យ នូវគារវភក្តីភាព ចំពោះព្រះតេជព្រះគុណ យ៉ាម៉ាដា ប្រធានគណៈប្រតិភូ និងសមាជិកគណៈប្រតិភូ, ចំពោះលោក តេស៊ូកា កូជី នាយកអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ជាមួយនឹងការកត់សំគាល់ របស់លោកថា ការកើតមានពុទ្ធសាសនបណ្ឌិត្យបន្តការងារឡើងវិញ និងការកើតមានអគារថ្មីដ៏ធំស្កឹមស្កៃ សំរាប់ជាកន្លែងធ្វើការរបស់ពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងការបោះពុម្ពឡើងវិញនូវសៀវភៅធម៌ និងសៀវភៅវប្បធម៌ទូទៅ ដែលអង្គការមនុស្សធម៌នានារបស់ជប៉ុន បានឧបត្ថម្ភឡើងតាមរយៈអង្គការជំនួយសូតូស៊ូជប៉ុន នៅភ្នំពេញនោះ បានធ្វើអោយព្រះសង្ឃ និងប្រជាពលរដ្ឋ មានមោទនភាពយ៉ាងខ្លាំង ។

ឯកឧត្តមបានថ្លែងអំណរគុណនិងដឹងគុណដ៏ជ្រាលជ្រៅ ដោយពុំមានថ្ងៃភ្លេច ចំពោះអង្គការជំនួយសូតូស៊ូជប៉ុន, សប្បុរសជនជប៉ុន និងអង្គការមនុស្សធម៌ទាំងឡាយនៅប្រទេសជប៉ុន ជាពិសេស អង្គការរីស្សូ កូសី-កៃ និងក្រុមប្រឹក្សាពិភព



កិច្ចសន្ទនា ស្ដីពីការងារបោះពុម្ព, ការចែកផ្សាយ ឆ្នាំ ១៩៩៨ និងផែនការឆ្នាំ ១៩៩៩
( រូបថត JSRC=SVA )

លោក ដើម្បីសាសនា និងសន្តិភាព ក្នុងការជួយស្តារព្រះពុទ្ធសាសនា និង កសាងពុទ្ធ-សាសនបណ្ឌិត្យឡើងវិញ ។ ឯកឧត្តម ក៏បានលើកសំណូមពរសុំអោយ WCRP បន្តជួយពុទ្ធសាសនបណ្ឌិត្យ ពីរ-បីឆ្នាំទៀត ទំរាំពុទ្ធសាសនបណ្ឌិត្យ មានលទ្ធភាពដំណើរការខ្លួនឯងបាន ។

បន្ទាប់មក លោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ បានរាយការណ៍ជម្រាបគណៈប្រតិភូ អំពីលទ្ធផលការងារបោះពុម្ព, ការងារចែកផ្សាយ និងប្រាក់ចំណូលដែលបានមកពីការលក់សៀវភៅ ដោយបញ្ជាក់ថា ការងារបោះពុម្ពឆ្នាំ ១៩៩៨ បានចប់សព្វគ្រប់តាមផែនការ ប៉ុន្តែការចែកផ្សាយមានដំណើររអាក់រអួល បណ្តាលមកពីសភាពការណ៍នយោបាយមិនអំណោយផលល្អ និងមានភ្លៀងធ្លាក់ច្រើន ខុសធម្មតា ។ នៅក្នុងឆ្នាំ ១៩៩៩ នេះ យើងនឹងអនុវត្តអោយបានសំរេច តាមផែនការដែលបានលើកឡើង ។

ពិធីនេះបានបញ្ចប់ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល បន្ទាប់ពីបានទស្សនាសំណង់អគារពុទ្ធសាសនបណ្ឌិត្យថ្មី និងថតរូបរួមគ្នាជាប់នឹងនឹងរថយន្តដឹកសៀវភៅទុកជាអនុស្សាវរីយ៍ផង ។




( រូបថត JSRC=SVA )

# ពិធីប្រគល់សៀវភៅ របស់ ក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព ប្រទេសជប៉ុន ចំពោះសាលាពុទ្ធិកសិក្សានានា ក្នុងខេត្តកំពង់ធំ




ព្រះសត្ថាបារមី មេគណខេត្តកំពង់ធំ ទទួលសៀវភៅជានិមិត្តរូប ពីព្រះតេជព្រះគុណ យ៉ាម៉ាដា ប្រធានគណៈប្រតិភូនៃអង្គការ WCRP (រូបថត JSRC=SVA)

កាលពីថ្ងៃ ១៦ មករា ១៩៩៩ វេលាម៉ោង ២ រសៀល ពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ និងសាសនា បាននាំយកសៀវភៅបោះពុម្ពឆ្នាំ ១៩៩៨ ដោយអង្គការជំនួយសូតូស៊ូជប៉ុន (JSRC = SVA) និងឧបត្ថម្ភថវិកាបោះពុម្ពពីក្រុមប្រឹក្សាពិភពលោកដើម្បីសាសនានិងសន្តិភាព (WCRP/Japan) ១១ មុខ មាន ចំនួន ៨១៤ ក្បាល ទៅប្រគល់ជូនសាលាពុទ្ធិកសិក្សា ៧៤ ក្នុងខេត្តកំពង់ធំ ។

ពិធីនេះបានប្រព្រឹត្តទៅ នៅក្នុងសាលប្រជុំខេត្ត កំពង់ធំ ក្រោមអធិបតីភាពព្រះតេជព្រះគុណព្រះសត្ថាបារមី មេគណខេត្តកំពង់ធំ ឯកឧត្តម ប៉ា សុជាតិវង្ស

អភិបាលរងខេត្តកំពង់ធំ ដោយមានមន្ត្រីសង្ឃស្រុក គ្រប់ស្រុក មន្ត្រីរាជការរបស់មន្ទីរធម្មការនិងសាសនា ខេត្ត-ស្រុក ព្រមទាំងពុទ្ធបរិស័ទជាច្រើនរូបចូលរួម ។

ដោយឡែក គណៈប្រតិភូជប៉ុននៃក្រុមប្រឹក្សាពិភពលោកដើម្បីសាសនានិងសន្តិភាព ដឹកនាំដោយព្រះតេជព្រះគុណ យ៉ាម៉ាដា រួមដំណើរដោយលោក តេស៊ូ-កា កូជិ នាយកអង្គការជំនួយសូត្ទស៊ូជប៉ុន នៅភ្នំពេញ និងលោក យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ ក៏បាននិមន្ត-អញ្ជើញចូលរួមជាអធិបតីក្នុងពិធីនោះដែរ ។

សៀវភៅទាំង ១១ មុខនោះ រួមមាន :

ក). សៀវភៅធម៌ និងសៀវភៅរឿងធម៌ទូទៅ ចំនួន ៥១៤ ក្បាល គឺ :

- បព្វជ្ជាខន្ធក សង្ខេប ៧៤ ក្បាល
- សាមណេរវិន័យ ៧៤ ក្បាល
- អនុមោទនាវិធី ៧៤ ក្បាល
- បណ្ដាំក្រមង៉ុយ ៧៤ ក្បាល
- រឿងហង្សយន្ត ៧៤ ក្បាល
- រឿងទុំទាវ ៧៤ ក្បាល
- រឿងក្រុងសុភមិត្ត ៧៤ ក្បាល

ខ). ទស្សនាវដ្ដីកម្ពុជសុរិយា ៤ លេខ ចំនួន ២៥៦ ក្បាល គឺ :

- លេខ ១/៩៨ ៧៤ ក្បាល
- លេខ ២/៩៨ ៧៤ ក្បាល
- លេខ ៣/៩៨ ៧៤ ក្បាល
- លេខ ៤/៩៨ ៧៤ ក្បាល

ពិធីនេះបានចាប់ផ្ដើម ដោយព្រះសង្ឃស្វាធ្យាយជយន្តោប្រសិទ្ធិពរជ័យ ។ កម្មវិធីជាបន្តបន្ទាប់ គឺរបាយការណ៍សង្ខេប របស់ លោកនាយកមន្ទីរធម្មការ និង

សាសនាខេត្ត ស្តីពីស្ថានភាពពុទ្ធិកសិក្សាក្នុងខេត្តកំពង់ធំ ។ បន្ទាប់មកទៀត ព្រះតេជព្រះគុណយ៉ាម៉ាដា បានថ្លែងសង្កថាសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅ ប្រកបដោយសោមនស្សរីករាយ ដែលបានមកប្រគល់សៀវភៅចំពោះសាលាពុទ្ធិក-សិក្សានានា នៅក្នុងខេត្តកំពង់ធំនេះ ។ ព្រះតេជព្រះគុណបានសង្កត់ថា សៀវភៅទាំងនេះ មានសារសំខាន់មិនត្រឹមតែសំរាប់តែបព្វជិតប៉ុណ្ណោះទេ ប៉ុន្តែ សំរាប់មនុស្សទាំងអស់គ្នា ។ នៅពេលនេះ គណៈប្រតិភូជប៉ុននៃក្រុមប្រឹក្សាពិភពលោកដើម្បី សាសនានិងសន្តិភាពមានឱកាសដ៏ប្រពៃ ដោយបានមកប្រគល់ដោយផ្ទាល់ នូវសៀវភៅធម៌ និងសៀវភៅវប្បធម៌ទូទៅ ចំនួន ៨១៤ ក្បាល ចំពោះសាលាពុទ្ធិក-សិក្សានានាក្នុងខេត្តនេះ ។ នេះជាឱកាសដ៏មានតម្លៃសំរាប់អង្គការ WCRP សូមថ្លែងសេចក្តីរីករាយដែលបានចូលរួមក្នុងពិធីដ៏ឧឡារិកនេះ ។

បន្ទាប់ពីពិធីប្រគល់សៀវភៅជានិមិត្តរូបរួចមក, លោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ បានប្រគេន និង ជម្រាបត្រួសៗអំពីភារកិច្ច និងសកម្មភាព របស់ពុទ្ធសាសនបណ្ឌិត្យបច្ចុប្បន្ន ក្នុងការស្តារពុទ្ធសាសនា និងសីលធម៌សង្គម ចាប់តាំងពីវិជ្ជាស្ថាននេះ ត្រូវបានអនុញ្ញាតអោយដំណើរការឡើងវិញ នៅក្នុងឆ្នាំ ១៩៩២ មក ។ ការយកចិត្តទុកដាក់ជាពិសេសរបស់ពុទ្ធសាសនបណ្ឌិត្យ នោះគឺការងារបោះពុម្ពសៀវភៅធម៌ និងសៀវភៅវប្បធម៌ទូទៅ ជាមួយនឹងការចេញផ្សាយទស្សនាវដ្តី «កម្ពុជសុរិយា» ប្រចាំត្រីមាសផងដែរ ដែលជាទស្សនាវដ្តីផ្សព្វផ្សាយអក្សរសាស្ត្រពុទ្ធសាសនា, អក្សរសាស្ត្រជាតិ, វប្បធម៌ ប្រពៃណីជាតិ ព្រមទាំងអត្ថបទគោលការណ៍សំខាន់ៗដទៃទៀត សំរាប់បំរើសេចក្តីត្រូវការរបស់ព្រះសង្ឃនិងពុទ្ធបរិស័ទ ។

សៀវភៅ និងទស្សនាវដ្តីកម្ពុជសុរិយា ដែលបានបោះពុម្ព និងចែកផ្សាយចាប់តាំងពីឆ្នាំ ១៩៩២ មកនោះ ពុទ្ធសាសនបណ្ឌិត្យបានទទួលការឧបត្ថម្ភបោះពុម្ពពីអង្គការជំនួយសូត្វស៊ូជប៉ុន (JSRC) ប្រចាំនៅភ្នំពេញ និងពីអង្គការមនុស្សធម៌

នានានៃប្រទេសជប៉ុន មានអង្គការ រិស្ស្យូ កូសី-កៃ, អង្គការ WCRP ជាដើម ។

ស្តីពីការប្រើប្រាស់ និងថែទាំសៀវភៅ, លោកនាយកពុទ្ធសាសនបណ្ឌិត្យ បានទូល និងជម្រាបថា :

១). សៀវភៅដែលពុទ្ធសាសនបណ្ឌិត្យបានប្រគល់ នៅពេលនេះក្តី ឬនៅពេលក្រោយៗទៀតក្តី ចំពោះវត្តណា គឺជាកម្មសិទ្ធិរបស់វត្តនោះ ។ ព្រះសង្ឃអង្គណា ឬគ្រហស្ថរូបណា ក៏អាចខ្ចីរៀនបាន ប៉ុន្តែ ត្រូវតែបង្វិលសងវត្តវិញ ក្រោយពេលអានចប់ តាមកាលកំណត់ និងជួយថែទាំអោយបាននៅគង់វង្សល្អ ។

២). វត្តនីមួយៗ ត្រូវមានបញ្ជីកត់ត្រាសៀវភៅចូលជាបន្ត តាមលំដាប់កាលបរិច្ឆេទ ដោយបញ្ជាក់ពីឈ្មោះអ្នកផ្តល់សៀវភៅនោះៗផង ?

៣). ព្រះតេជព្រះគុណចៅអធិការ លោកអាចារ្យ គណៈកម្មការវត្ត សុំយកព្រះទ័យ យកចិត្តទុកដាក់ប្រែក្លាយវត្តអារាមរបស់យើង អោយទៅជាមជ្ឈ-មណ្ឌលវប្បធមិរបស់ប្រជាជន ដោយបង្កើតអោយមានបណ្ណាល័យនៅក្នុងវត្ត សំរាប់តម្កល់ក្បួនច្បាប់ គម្ពីរដីកា និងជួយទិញសៀវភៅពីពុទ្ធសាសនបណ្ឌិត្យ យកមកតម្កល់ទុកក្នុងបណ្ណាល័យវត្ត សំរាប់សាធារណជនបានរៀនសូត្រ ។ ធ្វើបានយ៉ាងនេះ វត្តរបស់យើងនឹងទៅជាឃ្លាំងចំណេះដឹង ជាបណ្ណាល័យ ជាសារមន្ទីរនៃវប្បធមិរបស់ប្រជាជន នៅមូលដ្ឋាននីមួយៗ ។

ថ្លែងក្នុងឱកាសនោះដែរ ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលរងខេត្តកំពង់ធំ បានសំដែងអំណរគុណចំពោះអង្គការជំនួយសូតូស៊ូជប៉ុន សប្បុរសជនជប៉ុនពិសេស ក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនានិងសន្តិភាព ក្នុងការរួមវិភាគទានធ្វើអោយពុទ្ធសាសនានៅកម្ពុជា មានពន្លឺរស្មីឡើងវិញ ។សូមអង្គការដ៏ឧត្តុង្គឧត្តមទាំងអស់នេះ សំរេចបានជោគជ័យក្នុងគ្រប់ភារកិច្ច ដើម្បីបុព្វហេតុនៃសន្តិភាព និងវិបុលសុខគ្រប់ប្រការ សំរាប់មនុស្សជាតិ ។

***

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



រូបថត ពុទ្ធសាសនបណ្ឌិត្យ

ឆ្នាំទី ៥៣ លេខ ២

ខែ មេសា - ឧសភា - មិថុនា

ព.ស ២៥៤៣

គ.ស ១៩៩៩

ភ្នំពេញ

**ក្របមុខ ៖** សកម្មភាពបណ្ណាល័យកណ្តាល នៃ ពុទ្ធសាសនបណ្ឌិត្យ, ក្រុងភ្នំពេញ សិស្ស និស្សិត មកពីមហាវិទ្យាល័យនានា និងព្រះសង្ឃ បាននិមន្ត-អញ្ជើញចូលមកសិក្សា ស្រាវជ្រាវ មានចំនួនកាន់តែច្រើនរៀងរាល់ថ្ងៃ ។

( រូបថត ពុទ្ធសាសនបណ្ឌិត្យ )

ពុទ្ធសាសនបណ្ឌិត្យ
អំណោយឥតថ្លៃ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

គ.ស ១៩៩៩

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ភ្នំពេញ ។

យើងខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្ដីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាពរវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្បធម៌ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

## Acknowledgement

The *Kambujasuriya Magazine* is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC = SVA), Phnom Penh.

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ

## I. អត្ថបទរដ្ឋបាល


- ប្រកាសស្ដីពីការបង្កើតគណៈកម្មការពិនិត្យ និងវាយតម្លៃតំឡើងថ្នាក់បុគ្គលិកមន្ត្រីរាជការ ........ ១
- លិខិតថ្លែងអំណរគុណចំពោះព្រះតេជព្រះគុណ ហ្សិនដូ ម៉ាតស៊ូណាហ្គា ( Zendo Matsunaga ) ........ ៤


## II. អក្សរសាស្ត្រពុទ្ធសាសនា


- ធម្មនុញ្ញ នៃ ពុទ្ធសាសនា ( ឱម ខែម ) ........ ៧
- ម៉េចក៏ចាំបួស ម៉េចក៏ចាំសឹក ( ផល ទិត ) ........ ២១


## III. អក្សរសាស្ត្រទូទៅ


- អ្វីជា Khmerology ? (ត-ចប់) ( ពៅ សាវរស ) ........ ៣៦
- សិលាចារឹករកឃើញថ្មី នាឆ្នាំ ១០១៤ (ឡុង សៀម ) ........ ៤៦
- រឿងព្រះមហាសុបក្សីតាបស (ត-ចប់) ( ធន់ ហ៊ិន ) ........ ៥៤
- អ្នករៀនដើម្បីជាតិ ( កស ៣៤/១៩៦២/២ ) ........ ៦៣
- ល្បែងអង្គញ់ និងចម្រៀងបោះអង្គញ់ ( គង់ វេទ ) ........ ៦៦
- ល្បើកក្រើនជាតិ ( កស ៣៤/១៩៦២/២ ) ........ ៧៣


## IV. កំណត់ និង ប្រវត្តិការណ៍


- ពិធីទទួលសៀវភៅបោះពុម្ពឆ្នាំ ១៩៩៩ ........ ៧៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងធម្មការ និងសាសនា
លេខ : ៥៨ ក.ធ.ស

*ភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩*

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការពិនិត្យ និងវាយតំលៃតំលើងថ្នាក់បុគ្គលិកមន្ត្រីរាជការ

------

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត / ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស.រកម ០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស./១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា
- យោងសេចក្តីសំរេចលេខ : ១៩ កធស. ចុះថ្ងៃទី ២៥ ខែ មករា ១៩៩៩

ស្តីពីការងារបែងចែកភារកិច្ចថ្នាក់ដឹកនាំក្រសួងធម្មការ និងសាសនា

. អនុលោមតាមការងារចាំបាច់របស់ក្រសួង

## សំរេច

*ប្រការ ១* : បង្កើតឱ្យមានគណៈកម្មការមួយ សំរាប់វាយតំលៃតម្លើងឋានន្តរសក្តិ ឬថ្នាក់ដល់មន្ត្រីបុគ្គលិករាជការក្នុងក្រសួងធម្មការ និងសាសនា ។ គណៈកម្មការនេះមានឈ្មោះថា « គណៈកម្មការចំណាត់ថ្នាក់ » សរសេរកាត់ថា : គ.ក.ច ។

*ប្រការ ២* : គណៈកម្មការចំណាត់ថ្នាក់ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១ . ឯឧត្តម *ជា សាវឿន* | រដ្ឋមន្ត្រី | ប្រធាន |
| ២ . ឯកឧត្តម *ស្រី វិណ្ណផង់* | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣ . ឯកឧត្តម *ឈន អៀម* | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤ . ឯកឧត្តម *ដោក ណារិន* | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥ . ឯកឧត្តម *អ៊ីស្មាឯល ឧស្មាន* | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦ . ឯកឧត្តម *គ្រួច សារី* | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧ . ឯកឧត្តម *សៅ វ៉ន* | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨ . ឯកឧត្តម *ហ្សាការីយា អាដាម* | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩ . លោក *សេង ណាត* | អនុប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញ កិច្ច ( លេខាកត់ត្រា ) | |

*ប្រការ ៣* : គណៈកម្មការចំណាត់ថ្នាក់ « គ.ក.ច » មានភារកិច្ច :

. វាយតំលៃលើសមត្ថភាពធ្វើការងារជំនាញ ការគោរពវិន័យ សាមគ្គីភាពរបស់អ្នករាជការក្រោមឱវាទក្រសួងដើម្បីតំលើងឋានន្តរសក្តិ ឬថ្នាក់ ។

- ប្រមូលយកបញ្ជីឈ្មោះមន្ត្រីបុគ្គលិករាជការ ដែលត្រូវស្នើតំលើងឋានន្តរសក្តិ ឬថ្នាក់ ឱ្យបាននៅថ្ងៃទី ១៣ ខែមេសា ក្នុងឆ្នាំនីមួយៗ ។
- ធ្វើតារាងតំលើងឋានន្តរសក្តិ ឬថ្នាក់ ឱ្យបានហើយស្រេចក្នុងត្រីមាសទី៤ នៃឆ្នាំនីមួយៗ ( ត្រីមាសទី ៤ នៃឆ្នាំខ្មែរ ) ។
- ចុះឈ្មោះក្នុងតារាងតំលើងឋានន្តរសក្តិ ឬថ្នាក់ តាមចំនួនកន្លែងដែលមាននៅសល់ទំនេរ និងតាមចំណាយដែលមានគ្រោងទុកក្នុងថវិកា ។
- រៀបចំរក្សាសិទ្ធិឈ្មោះមន្ត្រីបុគ្គលិករាជការក្នុងតារាងតំឡើងឋានន្តរសក្តិ ឬថ្នាក់ ដែលមិនទាន់បានទទួលការតំឡើងឆ្នាំនេះ ឱ្យទទួលបានអាទិភាពមុនគេ សំរាប់ឆ្នាំបន្ទាប់ ។
- សហការយ៉ាងជិតស្និទ្ធជាមួយថ្នាក់ដឹកនាំគ្រប់នាយកដ្ឋាន ។

*ប្រការ ៤ :* សេចក្តីសំរេចមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ខា សាខឿន**

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

" ដើម្បីជូនជ្រាប "
- មន្ទីរធម្មការ និងសាសនា គ្រប់ខេត្ត-ក្រុង
- គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង

" ដើម្បីអនុវត្តន៍ "
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា
លេខ ៖ ៣២៣ កធស / ពប

រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា
សូមសំដែងវន្ទនកិច្ចចំពោះ
ព្រះតេជព្រះគុណ ZENDO MATSUNAGA
ប្រធានអង្គការជំនួយសូត្តស៊ូជប៉ុន (JSRC=SVA), តូក្យូ

ព្រះតេជព្រះគុណប្រធាន ជាទីគោរព,

ថ្ងៃទី ១២ ឧសភា ១៩៩៩ មន្ត្រីសង្ឃ និងមន្ត្រីរាជការ ក្រោមឱវាទក្រសួងធម្មការ និងសាសនា បានប្រារព្ធពិធីជួបសំណេះសំណាលជាមួយលោក TEZUKA KOJI នាយកអង្គការជំនួយសូត្តស៊ូជប៉ុន ក្នុងស្មារតីសាមគ្គីភាព និងភាតរភាព ដើម្បីជូនពរ និងបំពាក់មេដាយស្ថាបនាជាតិជូនលោក ក្នុងឱកាសដែលលោកត្រូវបានបញ្ចប់បេសកកម្មការងារដ៏ឧត្តុង្គឧត្តម នៅកម្ពុជា ។

ក្នុងនាមក្រសួងធម្មការ និងសាសនា, ក្នុងនាមព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរ និងក្នុងនាមខ្ញុំព្រះករុណាផ្ទាល់, ខ្ញុំព្រះករុណា មានអារម្មណ៍រីករាយណាស់ ដោយអង្គការជំនួយសូត្តស៊ូជប៉ុន បានឧបត្ថម្ភដល់ការស្តារវិស័យពុទ្ធសាសនា នៅកម្ពុជា មានការរីកចំរើនឡើងវិញ ហើយជួយឧបត្ថម្ភការបោះពុម្ពសៀវភៅ និងឯកសារទាំងឡាយ រួមទាំងសៀវភៅសំរាប់ពុទ្ធិកសិក្សាគ្រប់ប្រភេទ គ្រប់ថ្នាក់, សៀវភៅធម៌ និងសៀវភៅវប្បធម៌ទូទៅ ដែលផ្តល់វិភាគទានយ៉ាងធំធេង ដល់ការធ្វើអោយរស់ឡើងវិញនូវពុទ្ធសាសនាមួយ តម្រង់ទិសទៅរកការអភិវឌ្ឍន៍ និងជួយថែទាំ

សុខុមាលភាពប្រជាជនខ្មែរ ទាំងស្មារតី ទាំងសម្ភារៈ ក៏ដូចជាថែទាំសំរាប់អោយមានការលើកស្ទួយសន្តិភាព ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។

ចាប់តាំងពីឆ្នាំ ១៩៩២ រហូតមកដល់ពេលនេះ, ការណ៍ពិតបានបញ្ជាក់អោយឃើញថា ព្រះពុទ្ធសាសនានៅកម្ពុជា បានរីកចំរើនក្នុងសន្ទុះថ្មី ដោយបានទទួលការឧបត្ថម្ភពីពុទ្ធសាសនិកជន សប្បុរសជន ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ជាពិសេស ការឧបត្ថម្ភពីអង្គការជំនួយស្ងួតូស៊ូជប៉ុន (JSRC = SVA) ប្រចាំនៅកម្ពុជា ។

នៅកម្ពុជាបច្ចុប្បន្ន, មានវត្តដែលបានជួសជុល និងកសាងឡើងវិញចំនួន ៣.៦០០ វត្ត និងមានព្រះសង្ឃ ចំនួន ៤៧.០០០ អង្គ ។ ពុទ្ធិកសិក្សាបានឈានពីកំរិតបឋមសិក្សា ដល់ឧត្តមសិក្សា គឺមាន ៖

- សាលាពុទ្ធិកបឋមសិក្សា ២៤៧, សមណសិស្ស ៧,១៩៧ អង្គ
- សាលាពុទ្ធិកមធ្យមសិក្សា ៤, សមណសិស្ស ៦៤០ អង្គ
- សាលាពុទ្ធិកមហាវិទ្យាល័យ ១, សមណសិស្ស ៨២ អង្គ
- សាលាធម្មវិន័យ ៤១៤, សមណសិស្ស ៧,៩៨៥ អង្គ

ឯពុទ្ធសាសនបណ្ឌិត្យ បានបំពេញតួនាទីជាស្នូលមួយយ៉ាងសំខាន់ ក្នុងការស្តារវិស័យពុទ្ធសាសនា និងសីលធម៌សង្គម ចាប់តាំងពីវិជ្ជាស្ថាននេះ ត្រូវបានរៀបចំអោយដំណើរការឡើងវិញ នៅក្នុងឆ្នាំ ១៩៩២ មក ដោយបានទទួលការឧបត្ថម្ភយ៉ាងឧត្តុង្គឧត្តមពីអង្គការជំនួយស្ងួតូស៊ូជប៉ុន (JSRC = SVA) ។

ដោយហេតុនេះ លទ្ធផលការងារគ្រប់ផ្នែកដែលពុទ្ធសាសនបណ្ឌិត្យ និងអគ្គាធិការដ្ឋានពុទ្ធិកសិក្សា សំរេចបានកន្លងមកហើយក្តី ព្រមទាំងការងារដែលនឹងត្រូវបន្តធ្វើទៅខាងមុខទៀតក្តី គឺពិតជាពុំអាចកាត់ផ្តាច់ចេញពីជំនួយឧបត្ថម្ភរបស់អង្គការជំនួយស្ងួតូស៊ូជប៉ុន (JSRC = SVA) បានឡើយ ។ ក្នុងរយៈពេលជាង

៨ ឆ្នាំកន្លងទៅនេះ លោក TEZUKA KOJI នាយកអង្គការជំនួយសូត្តូស៊ូជប៉ុន ប្រចាំនៅកម្ពុជា គឺជាសកម្មជនមួយរូប និងជាមន្ត្រី ដ៏មានប្រជាប្រិយបំផុតរបស់អង្គការជំនួយសូត្តូស៊ូជប៉ុន ។ រួមជាមួយសហការីរបស់លោក, លោក TEZUKA KOJI បានចំណាយពេលយ៉ាងច្រើន និងបានយកអស់កម្លាំងកាយ-ចិត្ត ដើម្បីបំពេញការងារជួយលើកស្ទួយពុទ្ធសាសនា, ការសិក្សាអប់រំ និងវប្បធម៌ នៅកម្ពុជា។

ឆ្លើយតបទៅនឹងបុព្វហេតុខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចផ្តល់មេដាយស្ថានាជាតិ ជូនលោក TEZUKA KOJI នៅក្នុងឱកាសដែលលោកត្រូវបានបញ្ចប់បេសកកម្មការងាររបស់លោក នៅកម្ពុជា ។

ជាទីបញ្ចប់, ខ្ញុំព្រះករុណា សូមសំដែងនូវអំណរព្រះគុណ និងកតញ្ញូតាធម៌ ដ៏ជ្រាលជ្រៅ ចំពោះព្រះតេជព្រះគុណប្រធាននៃអង្គការជំនួយសូត្តូស៊ូជប៉ុន, ចំពោះសមាជិក សមាជិកាទាំងអស់ របស់អង្គការនេះ ទាំងនៅក្នុងប្រទេសជប៉ុន ទាំងនៅក្នុងនានាប្រទេស ដែលបានផ្តល់ជំនួយឧបត្ថម្ភយ៉ាងឧត្តុង្គឧត្តមដល់ការថែរក្សាសម្បត្តិវប្បធម៌ និងសម្បត្តិនានា របស់ប្រជាជនកម្ពុជា ។ សូមព្រះតេជព្រះគុណ អស់លោក លោកស្រី បានប្រកបដោយពលភាព និងសុខភាពបរិបូណ៌ ក្រោមម្លប់សន្តិភាពពុទ្ធសាសនា ដ៏ស្ថិតស្ថេរ !

សូមអោយសត្វលោកទាំងអស់ បានរស់នៅក្នុងសន្តិភាព, សេចក្តីសុខក្សេមក្សាន្ត និងសុភមង្គល !

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៩

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ជា សាវឿន

# ធម្មនុញ្ញនៃពុទ្ធសាសនា (*)

រៀបរៀងដោយ **ឱម ខែម**

## I. សេចក្ដីផ្ដើម

ព្រះពុទ្ធសាសនាជាសាសនាធំមួយ ក្នុងចំណោមសាសនាធំៗក្នុងលោក កើតជាយូរយារណាស់មកហើយ, មានប្រជាជនរាប់លាននាក់ ជាពុទ្ធសាសនិក ។ ទីតាំងនៃសាសនានេះគឺ ប្រទេសឥណ្ឌា ។ ព្រះសមណគោតម ទ្រង់ជាមេដឹកនាំបង្កើតឡើង ។ ក្រោយពីពេលដែលព្រះអង្គបានសំរេចនូវដំណែងជាព្រះពុទ្ធ ដោយសេចក្ដីព្យាយាមដ៏មោះមុតរបស់ព្រះអង្គមក ទ្រង់តែងបំពេញព្រះករណីយកិច្ចជាសាស្ដា គឺស្ដេចយាងទៅប្រកាសផ្សាយព្រះសាសនាក្នុងទីកន្លែងផ្សេងៗ ; អ្នកមានសទ្ធាជ្រះថ្លាព្រមជឿបដិបត្តិតាមព្រះអង្គ មានចំនួនច្រើនឡើងៗ ជាលំដាប់ ។ អ្នកប្រព្រឹត្តតាមរមែងបានទទួលផល គឺសេចក្ដីសុខ សេចក្ដីចំរើន តាមសមគួរដល់សេចក្ដីប្រតិបត្តិ ។

វិធីទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺ :

១. ទ្រង់ប្រដៅអោយដឹងពិត ឃើញពិត ក្នុងសភាវៈដែលគួរដឹង គួរឃើញ ។

២. ទ្រង់ប្រដៅមានហេតុ មានផល ដែលអ្នកស្ដាប់អាចត្រិះរិះពិចារណាឃើញពិតបាន ។

៣. ទ្រង់ប្រដៅជាអស្ចារ្យ គឺអ្នកបដិបត្តិតាមរមែងបានប្រយោជន៍តាមសមគួរដល់សេចក្ដីបដិបត្តិរបស់ខ្លួន ។

---

(*) ឱវាទបាដិមោក្ខ, គោលច្បាប់នៃពុទ្ធសាសនា

## II. ព្រះពុទ្ធ

### ១. ឆាកជីវិត និងកាយវិការព្រះពុទ្ធអង្គ

មុននឹងសិក្សាធម្មនុញ្ញ ( គោលច្បាប់ ) នៃព្រះពុទ្ធសាសនា យើងគួរស្គាល់តួអង្គព្រះពុទ្ធសិន ។ មានលក្ខណៈ ២ យ៉ាង សំរាប់សំគាល់គឺ :

ក). ឆាកជីវិតព្រះពុទ្ធអង្គ

ទោះបីយើងពុំបានរស់នៅក្នុងសម័យពុទ្ធកាល ប៉ុន្តែយើងអាចស្គាល់ឆាកជីវិតព្រះពុទ្ធអង្គដោយរូបចម្លាក់ និងគំនូរផ្សេងៗ ដែលគេឆ្លាក់ ឬគូរផ្នែកណាដែលសំខាន់ ដូចជា :

- ព្រះពុទ្ធអង្គទ្រង់ប្រសូត,
- ការជួបប្រទះនឹងទេវទូត (ភេទ) ទាំង ៤ គឺ មនុស្សចាស់ជរា ឈឺ ស្លាប់ និងអ្នកបួស,
- ការយាងចេញសាងព្រះផ្នួស,
- ការធ្វើទុក្ករកិរិយា,
- ការជួបប្រទះនឹងពួកមារ,
- ការសំរេចព្រះសម្ពោធិញ្ញាណ,
- ការចូលបរិនិព្វាន,

ខ). កាយវិការព្រះពុទ្ធអង្គ ឬ មុទ្រៈ

សព្វថ្ងៃនេះ គេបានស្រាវជ្រាវរកឃើញនូវរូបចម្លាក់ព្រះពុទ្ធអង្គច្រើនបែប ប្រកបដោយព្រះកាយវិការប្លែកៗ គឺ :

- *ឈានមុទ្រៈ* ឬ កាយវិការសមាធិ,
- *ភូមិស្បសិមុទ្រៈ* ឬ កាយវិការយកព្រះធរណីធ្វើជាសាក្សី,
- *អភយមុទ្រៈ* ឬ កាយវិការអបរំកុំអោយភ័យខ្លាចអ្វីៗដែលពុំទាន

បានពិចារណា,

- *ធម្មចក្កមុទ្រ:* ឬ កាយវិការកំពុងធ្វើអត្ថាធិប្បាយអំពីអរិយសច្ចៈ បង្វិលដំណើរសេចក្ដីដូចជាកង់រទេះ,

- *វរមុទ្រ:* ឬ កាយវិការអប់រំអោយមានចិត្តសប្បុរស,

- *វិតកមុទ្រ:* ឬ កាយវិការកំពុងពិចារណារកខុសត្រូវ ។

**សង្ខេប** : លក្ខណៈពិសេសនៃព្រះកាយវិការរបស់ព្រះពុទ្ធអង្គ គួរកត់សំគាល់គឺ ទឹកព្រះភក្ត្រញញឹមជាដរាប ដូចជារកឃើញនូវអាថិកំបាំងអ្វីមួយ ដ៏សែនជ្រៅ ។

## ២. សិក្សាពុទ្ធប្បវត្តិសង្ខេប

- ព្រះ **សិទ្ធត្ថ-គោតម** ទ្រង់ប្រសូតនៅថ្ងៃសុក្រ ១៥ កើត ខែវិសាខ ឆ្នាំច ក្រោមដើមសាលព្រឹក្ស ក្នុងឱទ្យាន*លុម្ពិនី* ក្បែរក្រុង *កបិលព័ស្តុ* និងនគរ *ទេវទហៈ* នៃប្រទេសឥណ្ឌា មុនពុទ្ធសករាជ ៨០ ឆ្នាំ ។

- ព្រះបិតាព្រះនាម *សុទ្ធោទនៈ* ព្រះចៅក្រុងកបិលព័ស្តុ នៃដែនសក្យៈ ; ព្រះមាតាព្រះនាម *សិរីមហាមាយា* ( ក្សត្រិយ៍ នៃក្រុងទេវទហៈ ) ។

- បន្ទាប់ពីប្រសូតបាន ៧ ថ្ងៃ ព្រះមាតាក៏ចូលទិវង្គតចោលសិទ្ធត្ថកុមារ អោយនៅកំព្រា តែព្រះរាជកុមារត្រូវបានទទួលការចិញ្ចឹមបីបាច់ថ្នាក់ថ្នមពីព្រះបិតុច្ឆា ( ម្ដាយមីងខាងបិតា ) របស់ព្រះអង្គព្រះនាម *មហាបជាបតិគោតមី* រហូតដល់ព្រះ អង្គធំដឹងក្ដី ។

- ព្រះជន្មាយុបាន ១៦ ព្រះវស្សា *ព្រះសិទ្ធត្ថ* ទ្រង់ទទួលរាជាភិសេកជាព្រះ ចៅក្រុងកបិលព័ស្តុ ដោយមានព្រះនាង *យសោធរាពិម្ពាទេវី* ជាអគ្គមហេសី ( ព្រះ រាជធីតារបស់ព្រះបាទ *សុប្បពុទ្ធ* និងព្រះនាង *អមិតា* ក្សត្រសោយរាជ្យនៅនគរ

ទេវទហៈ ជាកោលិយវង្ស) ហើយទ្រង់មានព្រះរាជបុត្រមួយអង្គ ព្រះនាម *រាហុលកុមារ* ។

- ព្រះជន្មាយុបាន ២៩ ព្រះវស្សា ក្រោយពេលដែលទ្រង់ទតយល់នូវទេវទូតទាំង ៤ : ជរា-ព្យាធិ-មរណៈ-អ្នកបួស ព្រះសិទ្ធត្ថទ្រង់នឿយណាយក្នុងភេទជាឃរាវាស ក៏ទ្រង់យាងចេញចាកព្រះរាជវាំងទាំងកណ្ដាលអធ្រាត្រ ទៅបំពេញបព្វជ្ជា ស្វែងរកសម្ពោធិ ។ លុះទៅដល់មាត់ស្ទឹង *អនោមា* ជាព្រំដែននៃរដ្ឋសក្យៈនិងរដ្ឋមល្លៈ ព្រះសិទ្ធត្ថក៏ចូលកាន់ភេទជាបព្វជិត ដោយការអធិដ្ឋាន ។

- ព្រះសមណសិទ្ធត្ថបានចូលទៅសិក្សាក្នុងសំណាក់តាបស ២ រូប ឈ្មោះ *អាឡារតាបសកាលាមគោត* និង *ឧទកតាបសរាមបុត្រ* ដែលជាគ្រូល្បីល្បាញ មានសិស្សគណជាច្រើន ដោយទ្រង់យល់ថា ការសិក្សា និងវិធីប្រតិបត្តិតាមតាបសទាំង ២ នាក់នេះ អាចកំចាត់នូវសេចក្ដីទុក្ខបាន ។ តែព្រះអង្គអស់សង្ឃឹម ដោយចំណេះដឹង និងវិធីប្រតិបត្តិដែលព្រះអង្គទទួលពីតាបសទាំង ២ នាក់នោះ ពុំអាចអោយព្រះអង្គចេញចាកពីសេចក្ដីទុក្ខដែលរួបរឹតក្នុងសន្ដានចិត្តព្រះអង្គបានឡើយ ។ ទីបំផុតព្រះអង្គក៏យាងចេញចាកពីទីនោះ ហើយសំរេចព្រះទ័យថា នឹងស្វែងរកពោធិញ្ញាណនោះដោយខ្លួនឯង ។ លុះទៅដល់តំបន់មួយឈ្មោះ *ឧរុវេលាសេនានិគម* ទ្រង់បានទតឃើញថា ភូមិប្រទេសទីនេះ មានព្រៃខៀវខ្ចី មានទឹកស្ទឹងនេរញ្ជរាថ្លាដូចកញ្ចក់ជាទីស្ងប់ស្ងាត់គួរដល់ការប្រកបព្យាយាម ដើម្បីស្វែងរកមោក្ខធម៌ ( ធម៌សំរាប់ធ្វើខ្លួនអោយរួចផុតពីសេចក្ដីទុក្ខ : កើត ចាស់ ឈឺ ស្លាប់ ) ទើបទ្រង់ជ្រើសរើសយកទីនោះ ដើម្បីបំពេញភាវនាធម៌ តទៅ ។

- ក្រោយបំពេញភាវនាធម៌ប្រកបដោយព្យាយាម និងដោយទុក្ករកម្មអស់ពេល ៦ វស្សា ព្រះសមណសិទ្ធត្ថបានទៅដល់គោលដៅ គឺយល់ឃើញច្បាស់នូវសម្ពោធិញ្ញាណនោះ នៅលើរតនបល្ល័ង្ក ក្រោមដើមពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹង

*នេរញ្ជរា* ក្នុងដែនមគធរដ្ឋ នៃប្រទេសឥណ្ឌា ក្នុងវេលាព្រះអាទិត្យរះបំព្រាង១ នៃថ្ងៃ ១៥ កើត ខែវិសាខ ឆ្នាំរកា មុនគ្រិស្តសករាជ ៥៨៨ ។ ព្រះសមណសិទ្ធត្ថទ្រង់បាន ព្រះនាមហៅថា « *ព្រះពុទ្ធ* » ចាប់ពីថ្ងៃនោះរហូតមក ។

## III. បឋមទេសនា ( ការសំដែងធម៌លើកដំបូង )

ក្រោយពីបានការត្រាស់ដឹងជាព្រះពុទ្ធហើយ ព្រះអង្គបានរៀបចំផែនការ ផ្សព្វផ្សាយនូវអ្វីដែលព្រះអង្គបានត្រាស់ដឹង ដល់អ្នកដែលពុំទាន់ដឹងដទៃទៀត ក្នុង ជម្ពូទ្វីប ។ ព្រះអង្គទ្រង់បានយាងចេញពីស្ទឹងនេរញ្ជរាឆ្ពោះទៅតំបន់មួយឈ្មោះព្រៃ *ឥសិបតនមិគទាយវ័ន* ដែលជាទីស្នាក់អាស្រ័យរបស់បញ្ចវគ្គិយ៍ ក្រុមអ្នកបួស ៥ នាក់ គឺ *កោណ្ឌញ្ញៈ, វប្បៈ, ភទ្ទិយៈ, មហានាម, អស្សជិ* ដែលធ្លាប់តាមបំរើ ព្រះអង្គ កាលដែលកំពុងប្រព្រឹត្តទុក្ករកិរិយា ហើយដែលចេញចោលព្រះអង្គ ក្នុងពេល ដែលព្រះអង្គងាកទៅឆាន់ចង្ហាន់ដែលជាផ្លូវកណ្តាលវិញ ។ ទីនោះ ព្រះសម្មាសម្ពុទ្ធ បានបង្ហាញដល់អ្នកបួសទាំង ៥ អំពីសច្ចធម៌ដែលព្រះអង្គបានរកឃើញ និងកើត ឡើងដល់ព្រះអង្គក្រោយអ្នកបួសនោះចេញចោល ។ ព្រះអង្គបានអោយឈ្មោះ សច្ចធម៌របស់ព្រះអង្គដែលរកឃើញនោះថា *អរិយសច្ចៈ* ប្រែថា *ការពិតដ៏ប្រសើរ បំផុត* ។ ន័យសំខាន់ៗ របស់ការសំដែងធម៌លើកដំបូង ដែលព្រះអង្គបានសំដែងប្រាប់ ដល់អ្នកបួសទាំង ៥ នោះមាន ៖

១. ទ្រង់ចាប់ផ្តើមនិទានពីផ្លូវចាស់ ២ យ៉ាង ដែលគេធ្លាប់ដឹងថាផ្លូវពុំ អាចរកនិព្វាន គឺការរំលត់ទុក្ខបាន ព្រោះជាផ្លូវឆ្វេង និងស្តាំនិយមជ្រុលពេក ( អន្ត-ធម៌ ) គឺបើមិនតឹងពេក ក៏ធូររលុងពេក ។

២. ទ្រង់បង្ហាញពីផ្លូវថ្មី ដែលទើបតែរកឃើញ ឈ្មោះ *មជ្ឈិមបដិបទា* ជាផ្លូវកណ្តាល មិនធូរពេក មិនតឹងពេក ជាផ្លូវអាចអោយកើតបញ្ញា ធ្វើអោយកើត

សេចក្តីដឹងប្រាកដ ធ្វើអោយកើតការស្ងប់ ធ្វើអោយរំលត់ទុក្ខបាន ។

៣. ទ្រង់បញ្ជាក់ថា ផ្លូវកណ្តាលដ៏ប្រសើរនោះមាន ៨ ប្រការគឺ :

- *សម្មាទិដ្ឋិ* ត្រូវមានប្រាជ្ញាយល់ត្រូវ
- *សម្មាសង្កប្បៈ* ត្រូវមានសេចក្តីត្រិះរិះត្រូវ
- *សម្មាវាចា* ត្រូវមានការនិយាយស្តីត្រឹមត្រូវ
- *សម្មាកម្មន្តៈ* ត្រូវមានអំពើត្រូវ
- *សម្មាអាជីវៈ* ត្រូវមានការចិញ្ចឹមជីវិតត្រូវ
- *សម្មាវាយាមៈ* ត្រូវមានសេចក្តីព្យាយាមត្រូវ
- *សម្មាសតិ* ត្រូវមានការរលឹកត្រូវ
- *សម្មាសមាធិ* ត្រូវមានការតម្កល់ចិត្តអោយបានត្រូវ

៤. ព្រះអង្គបានបង្ហាញថា ជីវិតមនុស្សពោរពេញទៅដោយសេចក្តីទុក្ខវេទនា និងបញ្ហាគ្រប់បែបយ៉ាង ។ កើតមកក៏ទុក្ខ, ជរាក៏ទុក្ខ, ឈឺក៏ទុក្ខ, ស្លាប់ក៏ទុក្ខ ; ជួបនឹងមនុស្សជាទីសំអប់ក៏ទុក្ខ, បែកពីអ្នកជាទីស្រឡាញ់ក៏ទុក្ខ, មិនអាចបំពេញបំណងបានក៏ទុក្ខ, ... ។ រួមសេចក្តីអោយខ្លីទៅ ព្រះអង្គទ្រង់សំដែងថា សេចក្តីទុក្ខទាំងឡាយនេះកើតឡើង ព្រោះតែការប្រកាន់ភ្ជាប់ថា *នេះជាអញ នេះជារបស់អញ* ។ ព្រះអង្គបានហៅធាតុពិតរបស់ទុក្ខ ដែលមានទាំងអស់នេះថា *ទុក្ខអរិយសច្ចៈ* ប្រែថា ទុក្ខគឺជាសច្ចធម៌ដែលគួរដឹងជាទីបំផុត ។

ទ្រង់បង្ហាញអោយដឹងទៅដល់ជម្រៅរបស់ទុក្ខនេះថា *កើតឡើងព្រោះហេតុ* ដែលមានឈ្មោះថា *តណ្ហា* គឺ សេចក្តីប្រាថ្នា, ចំណង់ ។ ព្រះអង្គហៅការពិតនៃហេតុរបស់ទុក្ខនេះថា *ទុក្ខសមុទយអរិយសច្ចៈ* ប្រែថា ហេតុដែលនាំអោយកើតទុក្ខ ជាសច្ចធម៌ដែលគួរដឹងជាទីបំផុត ។

ទ្រង់បង្ហាញអោយដឹងថា មានសភាវធម៌មួយឈ្មោះ *និរោធ* ដែលជា

សភាវៈប្រាសចាកទុក្ខ គ្មានទុក្ខ ដែលគេអាចទៅដល់បាន និងសំរេចបាន ។ ព្រះអង្គហៅការពិតនេះថា *ទុក្ខនិរោធអរិយសច្ចៈ* ប្រែថា ការរំលត់ទុក្ខជាសច្ចធម៌ ដែលគួរដឹងជាទីបំផុត ។

ជាចុងក្រោយ ទ្រង់ក៏បង្ហាញពីវិធីសំរាប់ទៅអោយដល់សភាវធម៌ដែលហៅថានិរោធ ឬសភាវៈដែលមិនមានទុក្ខនោះ ។ វិធីនោះគឺ *អរិយមគ្គ* ទាំង ៨ ។ ព្រះអង្គបានហៅផ្លូវនេះថា *ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ* ប្រែថា បដិបត្តិដែលជាផ្លូវសំរាប់ទៅកាន់ទីរំលត់ទុក្ខ ជាសច្ចធម៌ដែលគួរដឹងជាទីបំផុត ។

នៅចុងបញ្ចប់នៃធម្មទេសនា *កោណ្ឌញ្ញៈ* បានត្រាស់ដឹងនូវលោកុត្តរធម៌ថ្នាក់សោតាបត្តិផលជាដំបូងក្នុងលោក ដែលជាការបញ្ជាក់ថា ការត្រាស់ដឹងដែលព្រះអង្គទទួលបាននោះ ជាសច្ចធម៌ពិតមែន ។

ធម៌ទេសនាលើកដំបូងនេះ ត្រូវបានអ្នកប្រាជ្ញលោកហៅថា *ធម្មចក្កប្បវត្តនសូត្រ* គឺព្រះសូត្រដែលប្រព្រឹត្តទៅដូចជាកង់វិលទៅមុខ ហើយចាប់ពីពេលនោះឯង ដែលព្រះធម៌របស់ព្រះពុទ្ធអង្គវិលទៅមុខ រហូតដល់សព្វថ្ងៃនេះ ។

## IV. ពុទ្ធសាវ័ក និង បេសកកម្មរបស់លោក

### ក). ពុទ្ធសាវ័កដំបូងៗ

នៅពេលសំដែងធម្មចក្កប្បវត្តនសូត្រចប់ អ្នកបួសទាំង ៥ ក៏បានសុំបួសជាមួយព្រះសម្មាសម្ពុទ្ធ ។ ព្រះអង្គបានហៅអ្នកបួសទាំង ៥ នោះថា *ភិក្ខុ* ដែលប្រែថា « *អ្នកឃើញភ័យនៅក្នុងវដ្តសង្សារ* » ។ ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅជាមួយភិក្ខុសង្ឃទាំង ៥ អង្គ អស់រយៈពេលមួយរដូវវស្សា ( ៣ខែ ) ព្រមទាំងបានប្រោសសំដែងធម៌អប់រំដល់ភិក្ខុទាំង ៥ នោះ រហូតបានសំរេចជាព្រះអរហន្ត ។ ក្នុងវស្សានោះផងដែរ ព្រះអង្គបានបំបួសបុរស ៥៥ រូបថែមទៀត អោយទៅជាភិក្ខុសង្ឃ និង

បង្រៀន អប់រំ ហ្វឹកហាត់ អោយចេះដឹងក្នុងព្រះធម៌ដែលព្រះអង្គបានត្រាស់ដឹង រហូតដល់បានសំរេចជាព្រះអរហន្តគ្រប់អង្គទាំងអស់ ព្រមទាំងបានទទួលគ្រហស្ថ មួយគ្រួសារជាសាវ័កព្រះអង្គ ទៀតផង ។ ទ្រង់បានហៅសាវ័ក ដែលជាគ្រហស្ថ នោះថា *ឧបាសក* សំរាប់បុរស និង *ឧបាសិកា* សំរាប់ស្ត្រី ប្រែថា *អ្នកដែលចូលជិត ព្រះរតនត្រ័យគឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ* ។ ពេលនោះ ព្រះអង្គមានភិក្ខុសង្ឃ ជាព្រះអរហន្ត ចំនួន ៦០ រូប ( ៦១ នឹងព្រះអង្គផង ) ។

ខ)_ បេសកកម្មរបស់ពុទ្ធសាវ័ក

លុះផុតរដូវវស្សាហើយ ព្រះសម្មាសម្ពុទ្ធបានកោះប្រជុំភិក្ខុទាំង ៦០ រូប ហើយបានណែនាំភិក្ខុសង្ឃទាំង ៦០ រូប ជាសិស្សដ៏ចំណានទាំងនោះអោយចេញ ប្រកាសផ្សាយពុទ្ធវចនៈ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ជនជាច្រើន ដើម្បី អនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ព្រះអង្គបានរំលឹកថា អ្នកទាំងឡាយ កុំទៅពីរនាក់តាមផ្លូវជាមួយគ្នា ; ចូរសំដែងធម៌ អោយពិរោះបទដើម បទកណ្តាល និងបទចុង ; ចូរប្រកាសនូវព្រហ្មចរិយធម៌ ប្រកប ដោយអត្ថ និងព្យញ្ជនៈ អោយពេញបរិបូណ៌ ។

ក្រោយពីបានផ្តល់ឱវាទដល់ភិក្ខុដែលជាបរិស័ទទាំង ៦០ រូបហើយ ព្រះ សម្មាសម្ពុទ្ធក៏បានយាងធ្វើដំណើរទៅកាន់រដ្ឋមគធៈ ដែលជារដ្ឋមួយមានការរីកចំរើន និងសំបូរទៅដោយបញ្ញាវ័ន្ត មេសាសនា និងលទ្ធិផ្សេងៗ ។ ទីនោះ ព្រះអង្គបានធ្វើ អោយមេលទ្ធិដ៏មានឥទ្ធិពល ៣ នាក់ និងសាវ័ករបស់គេចំនួន ១០០០ នាក់ លះបង់ លទ្ធិបូជាភ្លើងរបស់ខ្លួនចេញ ហើយស្មគ្រចិត្តមកបួសជាមួយព្រះអង្គទាំងអស់គ្នា ។ ហេតុការណ៍នេះ បានធ្វើអោយកក្រើករំពើដល់មជ្ឈដ្ឋានមហាជន ក្សត្រ ព្រាហ្មណ៍ មេសាសនា និងសាសនិកសាសនាដទៃយ៉ាងខ្លាំង ។ ពួកគេទាំងអស់នោះ បាននាំគ្នា និយាយគ្នាដោយរំភើបថា មានព្រះអរហន្តកើតឡើងក្នុងលោកហើយ លោកជាព្រះ

ព្រះពុទ្ធដែលត្រាស់ដឹងដោយព្រះអង្គឯង ជាអ្នកបរិបូណ៌ដោយពហុវិជ្ជា និងមានការប្រព្រឹត្តល្អឥតខ្ចោះ, លោកជាអ្នកមានដំណើរជីវិតដ៏ល្អប្រពៃ ជាអ្នកប្រាជ្ញប្រចាំពិភពលោក ជាអ្នកពូកែក្នុងការប្រៀនប្រដៅអប់រំមនុស្សដោយគ្មានគូប្រៀប ។ ទាំងមនុស្សទាំងទេវតា ដ៏ច្រើនសន្ធឹកសន្ធាប់ បានចូលមកថ្វាយបង្គំសុំលោកធ្វើជាគ្រូ ។

ជោគជ័យដ៏ធំរបស់ព្រះអង្គ លើមេលទ្ធិបូជាភ្លើងទាំង ៣ នាក់ បានធ្វើអោយព្រះបាទពិម្ពិសារ ក្សត្រក្នុងរដ្ឋមគធៈក្លាយទៅជាពុទ្ធបរិស័ទដ៏មានកម្លាំងមួយអង្គ ក្នុងការជួយផ្សព្វផ្សាយពុទ្ធសាសនា ។ ក្នុងរយៈពេលត្រឹមតែ ៦ ខែ ប៉ុណ្ណោះ ព្រះអង្គបានទទួលបេក្ខជនមកបួសជាព្រះសង្ឃដល់ទៅជាង ១000 អង្គ និងឧបាសកឧបាសិកា ដល់ទៅរាប់ពាន់នាក់ ។

រីឯសារីបុត្ត និងមោគ្គល្លាន ដែលសិក្សាប្រតិបត្តិតបធម៌ ក្នុងសំណាក់គ្រូឈ្មោះសញ្ជ័យ អស់ពេលដ៏យូរនោះ ពុំបានរកឃើញពន្លឺត្រាស់ដឹងអ្វីឡើយ ។ ថ្ងៃមួយសារីបុត្តបានជួបនឹងព្រះអស្សជិត្ថេរ ជាវីករបស់ព្រះសម្មាសម្ពុទ្ធ ។ ក្រោយពីបានស្តាប់នូវធម្មបរិយាយរបស់ព្រះអស្សជិត្ថេររួចមក ក៏កើតមានសេចក្តីជ្រះថ្លា ហើយបានទៅបបួលមោគ្គល្លានជាមិត្ត ទៅសុំបួសក្នុងសំណាក់ព្រះពុទ្ធបរមគ្រូ ។ ៧ ថ្ងៃក្រោយពីបួសមក មោគ្គល្លានបានសំរេចនូវសាវកបារមីញាណ ។ ឯព្រះសារីបុត្ត កន្លងកន្លះខែពីថ្ងៃបួសមក ក៏បានសំរេចនូវសាវកបារមីញាណ ។

## V. សាវកសន្និបាតប្រគល់ដំណែងអគ្គសាវ័ក និងប្រកាសធម្មនុញ្ញពុទ្ធសាសនា

ដោយឃើញចំនួនពុទ្ធបរិស័ទកាន់តែមានច្រើនឡើងៗដូច្នេះហើយ ព្រះអង្គ ក៏បានរៀបចំធ្វើមហាសន្និបាតមួយឡើង ដើម្បីប្រកាសធម្មនុញ្ញនៃសាសនាព្រះអង្គដល់មនុស្សជាតិទាំងពួងជាផ្លូវច្បាប់ និងជាសាកលថា ពុទ្ធសាសនាបានកើតមាន

ក្នុងលោកហើយ ។ មហាសន្និបាតនោះ ធ្វើនៅថ្ងៃ ១៥ កើត ខែមាឃ ( កុម្ភៈ ) ឆ្នាំរកា ក្រោយពេលព្រះអង្គបានត្រាស់ដឹងហើយចំនួន ៩ ខែ នៅវត្តវេឡុវ័ន ( វត្តព្រៃឫស្សី ) ជិតក្រុងរាជគ្រឹះនៃរដ្ឋមគធៈ ដោយមានព្រះភិក្ខុសង្ឃបួសផ្ទាល់នឹងព្រះអង្គចំនួន ១២៥០ រូប ដែលសុទ្ធសឹងជាព្រះអរហន្ត ចូលរួមជាសមាជិកមហាសន្និបាត ។

ក្នុងឱកាសនៃមហាសន្និបាតនោះ ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសប្រគល់ដំណែងអគ្គសាវ័កដល់ព្រះថេរៈពីរអង្គគឺ ៖

- អគ្គសាវ័កទី ១ ដល់ព្រះសារីបុត្ត ជាឯតទគ្គៈខាងបញ្ញា ។
- អគ្គសាវ័កទី ២ ដល់ព្រះមោគ្គល្លាន ជាឯតទគ្គៈខាងឫទ្ធិ ហើយទ្រង់ប្រកាសពុទ្ធធម្មនុញ្ញ គឺគោលច្បាប់នៃពុទ្ធសាសនា ដល់សមាជិកសាវកសន្និបាតទាំងអស់ សំរាប់ធ្វើជាក្រឹត្យក្រមអនុវត្ត និងដើម្បីប្រកាសផ្សព្វផ្សាយដល់មហាជនទាំងពួង អោយបានដឹងអំពីគោលការណ៍ ដែលព្រះពុទ្ធសាសនាត្រូវប្រកាន់យក ។ ធម្មនុញ្ញនៃពុទ្ធសាសនានេះ ព្រះអង្គអោយឈ្មោះថា *ឱវាទបាដិមោក្ខ* មានទាំងអស់ ១១ មាត្រា(*) គឺ ៖

| | |
|---|---|
| ១. *សព្វបាបស្ស អករណំ* | មិនធ្វើបាបទាំងពួងជាដាច់ខាត, |
| ២. *កុសលស្សូបសម្បទា* | បំពេញកុសលអោយបរិបូណ៌, |
| ៣. *សចិត្តបរិយោទបនំ* | ធ្វើចិត្តរបស់ខ្លួនអោយស្អាតល្អ, |
| ៤. *និព្វានំ បរមំ វទន្តិ ពុទ្ធា* | និព្វានជារបស់ដ៏ឧត្តមដែលព្រះពុទ្ធទាំងឡាយត្រាស់សំដែង, |
| ៥. *ខន្តិ បរមំ តបោតីតិក្ខា* | ការអត់ធន់ជាតបធម៌ដ៏ឧត្តម, |
| ៦. *ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ* | អ្នកបួសណាដែលសម្លាប់សត្វ អ្នកបួសនោះមិនមែនជាសមណៈក្នុងពុទ្ធសាសនាទេ, |

(*) «មាត្រា» ក្នុងសៀវភៅ ឱវាទបាដិមោក្ខ ថា « កំណ្ឌ » ។

៧. *មត្តញ្ញុតា ច ភត្តស្មឹ* បរិភោគអាហារដោយស្គាល់ប្រមាណ,

៨. *បន្តញ្ច សយនាសនំ* ពេញចិត្តកន្លែងដេក និងទីអង្គុយដែលស្ងប់ស្ងាត់,

៩. *អធិចិត្តេ ច អាយោគោ* ព្យាយាមធ្វើចិត្តរបស់ខ្លួនអោយទៅជាអធិចិត្ត,

១០. *អនុបវាទោ អនុបឃាតោ* កុំតិះដៀលគេ កុំបៀតបៀនគេ,

១១. *បាដិមោក្ខេ ច សំវរោ* ចូរសង្រួមនៅក្នុងច្បាប់ គោលការណ៍របស់ខ្លួន ។

ឱវាទដែលព្រះអង្គបានសំដែងទាំង ១១ មាត្រានេះ គឺជាធម្មនុញ្ញមួយដែលមានលក្ខណៈសំបូរគ្រប់គ្រាន់ទាំងអស់ ដែលអាចអោយសមាជិកម្នាក់ៗ បង្ហាញនូវភាពរួមរបស់សាសនាខ្លួនក្នុងរយៈពេលដ៏ខ្លីបំផុត សំរាប់អ្នកដែលចង់ដឹង និងជារង្វាស់សំរាប់វាស់ថា អ្នកណាមួយជាសមាជិករបស់ពុទ្ធសាសនាពិតប្រាកដ ។

## VI. ៤៥ឆ្នាំ នៃព្រះករណីយកិច្ចជាសាស្តា

ចាប់តាំងពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធបរមគ្រូ បើកមហាសន្និបាតនោះមក គោលមាគ៌ាធម្មនុញ្ញនៃពុទ្ធសាសនា ក៏បានរីកសាយភាយទូទាំងជម្ពូទ្វីបដ៏ឆាប់រហ័ស ។ នៅទីណាក៏តែងតែឮសូរមាត់អួតសរសើរអំពីការកើតឡើងនៃព្រះពុទ្ធ សរសើរអំពីធម៌ដែលមានសច្ចភាព និងអួតនូវគុណរបស់ព្រះសង្ឃ ដែលបរិសុទ្ធគ្រប់ទីកន្លែង ឯចំនួនពុទ្ធបរិស័ទក៏កើនឡើងយ៉ាងឆាប់រហ័ស ។ ពេលនោះឯងដែលកិត្តិគុណ ១០ យ៉ាងរបស់ព្រះសម្មាសម្ពុទ្ធ បានកើតឡើងដោយការប្រសិទ្ធិនាមរបស់ពុទ្ធបរិស័ទ និងជនជាតិជម្ពូទ្វីបទាំងមូល ។ ពុទ្ធសាសនិកជនទាំងនោះ បានហៅព្រះអង្គថាជា :

១. *អរហំ* គឺអ្នកដែលមានដួងចិត្តបរិសុទ្ធស្អាត គ្មានកិលេស គ្មានរាគៈ

ទោសះ មោហះ ។

២. *សម្មាសម្ពុទ្ធោ* គឺអ្នកដែលបានត្រាស់ដឹងរកឃើញនូវអរិយសច្ចទាំង ៤ ដោយព្រះអង្គឯងមុនគេ ដោយពុំមានអ្នកណាប្រាប់ណែនាំឡើយ ។

៣. *វិជ្ជាចរណសម្បន្នោ* គឺជាអ្នកប្រាជ្ញមានចំណេះវិជ្ជាច្រើន ខ្ពង់ខ្ពស់ គ្មាននរណាប្រៀប និងមានការប្រព្រឹត្តកិរិយាមារយាទដ៏ល្អឥតខ្ចោះ ។

៤. *សុគតោ* គឺអ្នកដែលមានដំណើរជីវិតដ៏ល្អ និងបានសំរេចនូវគោលដៅជីវិត គឺផុតទុក្ខដោយជោគជ័យ ។

៥. *លោកវិទូ* គឺជាអ្នកជ្រាបច្បាស់ត្រៃលោក ជាអ្នកដឹងរឿងរ៉ាវ និងដំណើររបស់ជីវិត សង្គម ពិភពលោក និងវដ្តសង្សារ ដោយជាក់ច្បាស់ ។

៦. *អនុត្តរោ* ជាអ្នកប្រសើរដោយសីលាទិគុណ រកបុគ្គលណាស្មើគ្មាន ។

៧. *បុរិសទម្មសារថិ* គឺអ្នកហ្វឹកហាត់ថ្នាក់ខ្ពស់ ដែលពូកែអប់រំ ហ្វឹកហ្វឺនបុរសស្ត្រីទាំងឡាយអោយក្លាយទៅជាបណ្ឌិត និងសំរេចនូវនិព្វាន ដោយពុំអាចរកនរណាមកប្រៀបធៀបបានឡើយ ។

៨. *សត្ថា ទេវមនុស្សានំ* គឺជាសាស្តា ជាគ្រូរបស់មនុស្សសាមញ្ញ របស់ពួកអ្នកមន្ត្រី រាជការ ព្រះមហាក្សត្រ ទេវតា ឥន្ទ ព្រហ្មទាំងឡាយ ។

៩. *ពុទ្ធោ* គឺជាព្រះពុទ្ធជាអ្នកដឹងអំពីអ្វីដែលហៅថាទុក្ខរបស់ជីវិត មូលហេតុរបស់ទុក្ខនោះ ការរំលត់ទុក្ខ និងវិធីសំរាប់រំលត់ទុក្ខទាំងនោះ ។

១០. *ភគវា* គឺជាអ្នកពូកែវែកញែកធម៌ បែងចែកធម៌ អោយទៅតាមពួក តាមក្រុម តាមប្រភេទ និងជាអ្នកធ្វើការអ្វីដែលតែងមានជោគជ័យ មានគេជ្រោមជ្រែង គាំទ្រ គ្រប់ទីកន្លែងទាំងអស់ ។

ពុទ្ធគុណទាំង ១០ ព្រះនាមនេះ លោកអាចសង្ខេបអោយមកនៅត្រឹមតែ ៣ យ៉ាងគឺ :

១. *បញ្ញាគុណ* ព្រះអង្គជាបញ្ញាជន ជាអ្នកប្រាជ្ញ ជាបណ្ឌិត មានបញ្ញាចេះដឹងសព្វសារពើ ជាសព្វញ្ញូ ជាអ្នកដឹងនូវអ្វីដែលជាបញ្ហាជីវិត និងវិធីរំលត់នូវហេតុនៃបញ្ហានោះ ។

២. *ករុណាគុណ* ព្រះអង្គជាអ្នកដែលមានព្រះទ័យពោរពេញទៅដោយមេត្តា គឺស្រឡាញ់ អាណិតដល់មនុស្សសត្វទាំងអស់ និងករុណា គឺមានព្រះទ័យជួយសង្គ្រោះមនុស្សសត្វអោយរួចផុតពីសេចក្តីទុក្ខដោយព្រះធម៌ទេសនា អស់រយៈពេល ៤៥ ឆ្នាំគត់ ។

៣. *វិសុទ្ធិគុណ* ព្រះអង្គជាមនុស្សបរិសុទ្ធ គ្មានកិលេស ។ ជនណាដែលនឹករលឹកព្រះអង្គ យកព្រះអង្គជាទីពឹង បានធ្វើការបូជា ធ្វើបុណ្យនឹងព្រះអង្គ អ្នកនោះរមែងបាននូវសេចក្តីសុខដ៏លើសលប់ ។

ពុទ្ធគុណទាំង ១០ ឬទាំង ៣ នេះ បានធ្វើអោយពិភពលោកយើងកែប្រែនូវមុខមាត់របស់ខ្លួនពីបាតដៃមកខ្នងដៃ ។ ជនទាំងឡាយដែលគ្មានជំនឿលើខ្លួនឯងថាអាចកំណត់នូវជតាជីវិតរបស់ខ្លួន ព្រោះជីវិតនេះត្រូវបានលិខិតមកជាស្រេចហើយដោយព្រហ្ម ដោយអាទិទេពផ្សេងៗនៃសាសនាទេវនិយមដទៃនោះ បានភ្ញាក់បើកភ្នែក ក្រោកឈរ កម្រើកដៃជើង និងជឿច្បាស់លើខ្លួនឯងថា ខ្លួនគេអាចឆ្លងផុតពីបញ្ហាជីវិត និងសេចក្តីទុក្ខទាំងនោះបាន ដោយសេចក្តីព្យាយាមរបស់គេ និងតាមការណែនាំរបស់ព្រះពុទ្ធដែលជាគ្រូ និងជាអ្នកហ្វឹកហាត់ដោយពិតប្រាកដ ។

## VII. បច្ឆិមវាចា

គួរស្តាយណាស់ ដែលធម្មជាតិមិនអាចមិនប្រែប្រួល ។ ជីវិតដែលកើតឡើងត្រូវតែស្លាប់ ។ ជីវិតព្រះសម្មាសម្ពុទ្ធ ក៏មិនអាចមានករណីពិសេសដែលធម្មជាតិលើកលែងបានដែរ ព្រះអង្គបានចាកលោកនេះទៅដោយស្ងៀមស្ងាត់ បន្ទាប់ពី

បំពេញករណីយកិច្ចក្នុងឋានៈជាព្រះពុទ្ធ ដើម្បីសត្វលោកអស់រយៈកាល ៤៥ ឆ្នាំ ។ នៅចុងឆ្នាំទី ៨០ នៃព្រះជន្មាយុ ដែលត្រូវនឹងថ្ងៃ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ ព្រះពុទ្ធបរមគ្រូរបស់ពិភពលោកយើង ក៏យាងចូលបរិនិព្វាននៅចន្លោះក្រោមដើមសាលព្រឹក្សទាំងគូ ដែលមានមែកទោរទន់ដោយផ្ការយីងរយោង នាវេលាទៀបភ្លឺ ក្រោយពីបានផ្តាំជាចុងក្រោយបង្អស់ថា ៖

• *យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា* ម្នាលអានន្ទ, ធម៌ក្តី វិន័យក្តី ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយ ចំពោះអ្នកទាំងឡាយ លុះអំណើះឥតពីតថាគតទៅ ធម៌ និងវិន័យ នោះឯង ជាគ្រូរបស់អ្នកទាំងឡាយហើយ !

• *វយធម្មា សង្ខារា* សង្ខារទាំងឡាយ មានការវិនាសសោះសូន្យជាធម្មតា !

• *អប្បមាទេន សម្បាទេថា* អ្នកទាំងឡាយ, ចូរញុំាងករណីយកិច្ចទាំងពួងអោយសំរេច ដោយសេចក្តីមិនប្រមាទចុះ !

***

ឯកសារជំនួយស្មារតី

- ពុទ្ធប្បវត្តិកថា ( ឈឹម ស៊ុមន៍ ) បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ
- ឱវាទបាដិមោក្ខ ( ចាប ពិន ) បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ
- មគ្គទេ្ទសក៍ជីវិត ឥន្ទបញ្ញោភិក្ខុ ហ. មណីចិន្តា
- គិហិបដិបត្តិ ( ជួន ណាត ) បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ
- ប្រស្នាត្រៃគុណ ( ឈឹម ទូច ) បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ
- មហាបរិនិព្វានកថា ( សូ ហាយ, ផល ទិត ) ពុទ្ធសាសនបណ្ឌិត្យ
- វចនានុក្រមខ្មែរ របស់ពុទ្ធសាសនបណ្ឌិត្យ

# ម៉េចក៏ចាំបួស ម៉េចក៏ចាំសឹក

*ភ.ភ.ន.– យើងបានដកស្រង់យកអត្ថបទកំណាព្យដែលពោលថា « ម៉េចក៏ចាំបួស ម៉េចក៏ចាំសឹក » របស់លោក ផល ទិត និពន្ធក្នុងឆ្នាំ ១៩៥៦ កាលលោកនៅជាលេខាធិការ របស់ក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ មកចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ២ ឆ្នាំ ១៩៩៩ នេះ ដើម្បីបកស្រាយបំភ្លឺ ដូចតទៅ ៖*

ពាក្យប្រាំពីរ

*មុននឹងដើរត្រូវតាមផ្លូវត្រង់ ត្រូវចេះរិះចង់ស្ពង់កំហុស*
*បើឃើញត្រង់ណាជាផ្លូវខុស ប្រាជ្ញប្រាណជាតិមនុស្សកុំប្រព្រឹត្ត ฯ*
*ផ្លែស្លែងវែងពុលជាទោសកាច តែមានគុណអាចកែជីវិត*
*ស្ដៅ-ម្រះក្រាស់ដោយជាតិល្វីងពិត តែគង់មានឫទ្ធិកែរោគបាន ฯ*
*ភ្លើងក្ដៅហៅកាចកំណាចក្រៃ តែជាតម្លៃនៃចង្ក្រាន*
*ជាតិស្រាស្រវឹងវឹងស៊ុងប្រាណ តែគង់ផ្សំបានជាឱសថ ฯ*
*កាំបិតពិតជាគ្រឿងប្រហារ តែអាចប្រើការកាប់អុសដុត*
*ជាតិបរមាណូមានទោសផុត តែមានគុណសុទ្ធផុតដូចគ្នា ฯ*
*រីឯពាក្យថ្កោលដោលដេញសួរ ទោះបីគ្មានគួរជួរម្ដេចម្ដា*
*ក៏គង់មានគុណច្រើនមហិមា មកជាមួយគ្នាអចិន្ត្រៃយ៍ ฯ*
*• រឿង **បួស រួច សឹក** ជាប្ញកខ្មែរ មិនសមខ្លះដែរតែប្រពៃ*
*ព្រោះបួសជាបុណ្យគុណច្រើនក្រៃ ជួយភ្ជាប់និស្ស័យសាងសុចរិត ฯ*
*អ្នកដែលបានបួសជាផ្នួសពេញ ដល់សឹកមកវិញហៅ **បណ្ឌិត***
*ហៅក្លាយមកទៀតថា **អន្ទិត** នេះពិតជាឈ្មោះខ្ពស់ពណ្ណរាយ ฯ*

សម័យអង្គរដ៏ថ្កើងថ្កាន
អន្និតធ្លាប់បានឋានទូលាយ
ជាគ្រូអាចារ្យជាចៅហ្វាយ
ធ្វើការទាំងឡាយថ្វាយក្សត្រា ។

ផ្លូវរដ្ឋរាប់អានក្នុងឋានខ្ពស់
លើកសិទ្ធិកិត្តិយសខ្ពស់ថ្លៃថ្លា
ផ្លូវរាស្ត្រចាស់ស្រុកខ្មែរគ្រប់គ្នា
រាប់ថាឈ្មោះហ្នឹងសឹងពិសិដ្ឋ ។

រហូតកំណាន់ប្រកាន់ថា
កម្លោះស្លូតណាគ្មានគំនិត
មិនបាននាមថាជាអន្និត
នោះពិតជាគេមិនឱ្យកូន ។

នៅក្នុងសម័យនៃសង្គ្រាម
ហូរឈាមចេញចាកអង្គតាដូន
អក្សរសាស្ត្រខ្មែរស្ទើរសាបសូន្យ
តើកូនទេវតាណាមកជួយ ។

មិនគឺអ្នកបួសនោះឬអ្វី
ដែលសាងស្មារតីលៃលើកស្ទួយ
ទល់ទប់ឧបសគ្គវាក់ទុក្ខព្រួយ
ប្រឹងជួយស្ទួយទូលមូលរក្សា ។

ខ្មែរជាជាតិតូចតែពូជពេជ្រ
ទោះក្រីក្រម្តេចក៏បានភ្លា
ចេះអានសរសេរគួរអក្ខរា
ស្មើរតែគ្រប់គ្នាក្នុងមណ្ឌល ។

ការនេះពេញជាមិនចាញ់ដៃ
ជនជាតិដទៃនាសាកល
ខ្មែរជាជាតិតូចតែដូចដល់
ចិត្តនឹងរឹងថ្កល់យល់កាលវែង ។

ព្រោះបានមានមិត្តចិត្តត្រង់ហួស
គឺការកាន់ផ្នួសបួសហ្នឹងឯង
ដែលពាំនាំខ្មែរអោយបែរស្វែង
ប្រឹងប្រែងក្រែងបាត់ខ្ជាត់វាសនា ។

អ្នកបួសស្ពាយបាត្រដើរបិណ្ឌបាយ
ក៏គ្មានអន្តរាយដល់ជនណា
លោកមិនដែលញាំងអ្នកជ្រះថ្លា
ឱ្យខូចសទ្ធាឬធនធាន ។

ព្រោះពុទ្ធសាសនាថ្លាឧត្តម
ប្រកាន់និយមរឿងឱ្យទាន
ប៉ុន្តែមិនឱ្យអន្តរធាន
បាត់បង់សន្តានខាងស្រង់សត្វ ។

ទោះបីសុំគេមកភោក្តា(*)
ក៏គ្មានអាជ្ញាទៅអារកាត់
ពួកអ្នកឱ្យទានឥតមានខ្វាត់
សទ្ធា-សម្បត្តិនៅធម្មតា ។

(*) ភោក្តា (កិ.) ឆាន់, សី, បរិភោគ

ប្រៀបដូចសត្វឃ្មុំផ្ទឹសំបុក
ហើរត្រាច់តត្រុកមែកព្រឹក្សា
ខ្វាត់ខ្វែងស្វែងត្រីបទឹកដមផ្កា
យកទៅសង់ជាផ្ទិតឃ្មុំបាន ។
បុប្ផាផ្កាចាយផ្សាយក្លិនក្លែប
ដែលត្រូវឃ្មុំក្រេបទឹកដមប្រាណ
ក៏ឥតស្រពោនស្វិតរំខាន
តាំងនៅតាមឋានដូចប្រក្រតី ។
ទាំងក្លិនទាំងពណ៌ក៏នៅស្រស់
ដូចដើមទាំងអស់ឥតប្រែអ្វី
អាចបិចលេចចេញក្តិបផ្លែខ្ចី
កើនពូជប្រក្រតីឥតបីខាត ។
ឯឃ្មុំក៏ផឹកទឹកដមផ្កា
យកទៅសាងជាផ្ទិតដ៏ស្អាត
ចិញ្ចឹមកូនចៅផៅរួមជាតិ
ដោយឥតមានខាតទៅខាងណា ។
គឺផ្កាក៏ឥតវិបរិតខូច
នៅកើតតពូជជាធម្មតា
រីឃ្មុំផ្សុំពីទឹកដមផ្កា
ក៏បានកើតជាប្រយោជន៍ធំ ។
រឿងនេះប្រៀបបាននឹងអ្នកបួស
កាន់ផ្នត់បទផ្នួសភេទឧត្តម
ប្រឹងប្រែងស្វែងរកគុណដ៏ធំ
ដូចជាសត្វឃ្មុំអីចឹងឯង ។
អ្នកឱ្យឥតខូចភោគសម្ប័ទ
ឥតខ្វាត់សទ្ធាចិត្តចាត់ចែង
អ្នកបួសបានហើយក៏ប្រឹងប្រែង
ប្រព្រឹត្តខ្លួនឯងស្វែងរកគុណ ។
ក្រៅពីខ្លួនលោកយោគដល់ញាតិ
ផ្សព្វផ្សាយដល់ជាតិឥតខាតស៊ុន
ខ្មែរយើងថ្កើងថ្កានមានកិត្តិគុណ
ដោយបុណ្យអ្នកបួសជួយទ្រទ្រ ង់ ។
រួមមកពីមួយជួយជាក់ច្បាស់
ខាងអក្សរសាស្ត្រឱ្យគង់វង្ស
ពីរជួយអប់រំផ្សំតម្រង់
ឱ្យខ្មែរខ្ពស់ខ្ពង់ខាងចរិយា ។
បីជួយឱ្យបានជាមណ្ឌល
ផ្តួចផ្តល់ឧបត្ថម្ភកុមារា
កូនខ្មែរក្សត់ក្រយ៉ាងម្តេចម្តា
ទៅនៅសិក្សាបានទាំងអស់ ។
បួនជួយឱ្យជាតិចេះចងផ្តុំ
រួមជាសង្គមជុំគ្នារស់
ឱ្យចេះធ្វើទានទ្រព្យរបស់
មានចិត្តសប្បុរសសង្គ្រោះខ្សត់ ។

សង្គ្រោះអ្នកបួសជាអាចារ្យ
សង្គ្រោះពលករដែលក្រខ្សត់
• ព្រោះតែការបួសនេះសំខាន់
ផ្ដាំតកូនចៅចៅវែងឆ្ងាយ
បើមិនបួសយូរច្នេរបព្វជ្ជា
តែកម្លោះណាឱ្យថ្លោះខាន
ទំនៀមនេះឯងគេតែងក្រិត
- មួយគឺឱ្យមនុស្សទាំងមានក្រ
- ពីរគឺឱ្យខ្មែរស្រែចំការ
បើទុកជារៀនមិនជាក់ច្បាស់
• ការបួសកើតបុណ្យមានគុណខ្ពស់
ទ្រទ្រង់ជាតិយើងឡើងថ្កើងថ្កាន
ជនណានឿយណាយកាយកើតស្លាប់
ជននោះបួសស្វែងលែងប្រែភាព
ជនណាមិនទាន់ទ្រាន់ជិនណាយ
ជននោះបួសដែរតែមួយភាំង
• ការបួសដើម្បីភ្ជាប់និស្ស័យ
តែកុំខាតពេញឥតចំណេញ
រៀនទាំងផ្លូវធម៌ទាំងផ្លូវលោក
សឹកមកជួយជាតិជួយសាសនា
មិនបង់បាយជាតិញាតិសន្ដាន
បានជួយជាតិសាសន៍ដូចគេដែរ

សង្គ្រោះកុមារដែលនៅវត្ត
សង្គ្រោះជនបទដែលអត់បាយ ។
ទើបខ្មែរប្រកាន់មិនជិនណាយ
ត្រូវតែប្រុងកាយបួសកុំខាន ។
ត្រឹមចេញវស្សាសឹកក៏បាន
មុខជាលែងបានប្រពន្ធល្អ ។
ដើម្បីទាញចិត្តមនុស្សឱ្យស
ទៅរៀនច្បាប់ល្អឱ្យស្គាល់ច្បាស់ ។
ចេះសរសេរចារអក្សរសាស្ត្រ
អន់ណាស់អានបានសរសេរបាន ។
រៀបរាប់មិនអស់ហួសប្រមាណ
កុំភ្លឹកនឹកស្មានថាចោកទាប ។
មិនចង់នៅជាប់អំពើបាប
រៀងរាបរហូតអស់ជីវី ។
នៅឃើញសប្បាយក្នុងកាមខ្លាំង
ក៏តាំងសឹកមករកកាមវិញ ។
ខាងល្អប្រពៃឱ្យពេញលេញ
ត្រូវចេញកសាងខាងសិក្សា ។
ចេះដឹងគរគោកតែគ្រប់គ្នា
ដូចគេរាល់គ្នាអីចឹងដែរ ។
បំណាច់ខ្លួនប្រាណកើតជាខ្មែរ
មិនបែរជាស្អប់ទម្លាប់ឪ ។

• ឥឡូវការប្ដូរហួសសម័យ
មិនចាំបាច់ប្ដូរឱ្យហួសផ្លូវ
គេក្រេបវិជ្ជាតាមចិត្តចង់
ចាំប្ដូរធ្វើអីឱ្យតែអន់
ពីដើមស្រុកទេសយើងលិចលង់
យើងប្ដូរដើម្បីរៀនអក្ខរា
ឥឡូវរីកកើនចំរើនណាស់
មានទាំងតម្រិះចំណេះខ្ពស់
ដំណើរសម័យមានថ្ងៃយប់
តើយើងជាជាតិធ្លាប់ឈ្មោះល្បី
ម្ដេចក៏មិនប្រែកែសម្រួល
ផ្លាស់ប្ដូរទម្លាប់ឱ្យគាប់ជា
• សំដីនេះមិញពេញជាសម
ព្រោះឃើញតែគោលដែលដើរទៅ
សម័យថ្មីនេះរឿងការប្ដូរ
ព្រោះមួយវាស្ត្រខ្មែរនៅពេញចិត្ត
បានរៀនបានស្ងូត្ររហូតអស់
ឆ្មៀតពេលប្រព្រឹត្តគិតរកត្រូវ
ទីបីដូចយើងប្រាប់ខាងដើម
ជាអ្នកក្រខ្សត់អត់គ្រប់មុខ
• បើនឹងបញ្ជាក់ឱ្យយល់ងាយ
អំពីស្នាដៃអ្នកប្ដូរខ្មែរ

កាលពេលសព្វថ្ងៃលោកតម្រូវ
គេត្រូវនៅជាយុវជន ។
ចេះជាងលោកសង្ឃក្នុងបច្ចុប្បន្ន
នាំគេរិះគន់ទ្រាន់រិះគន់ ។
បានជាពឹងសង្ឃខាងសិក្សា
ទ្រទ្រង់ភាសាជាតិឱ្យរស់ ។
ខាងអក្សរសាស្ត្ររៀនមិនអស់
ចាំប្ដូរឱ្យអស់កម្លាំងអី ។
វិលឥតឈរឈប់ជាប្រក្រតី
កើតនៅលើដីកម្ពុជា ។
សម្របឱ្យស្រួលតាមវេលា
តាមពេលវេលាព្រមគ្នាទៅ ? ។
តែចូលច្រឡំពុំទាន់ជ្រៅ
ឯឋានឋិតនៅពុំសូវគិត ។
នឹងថាវាហួសក៏ពុំពិត
ពីរពួកអន្ទិតក៏មានផ្លូវ ។
ដូចពួកគ្រហស្ថពេលឥឡូវ
ដឹកនាំម៉ែឪទៅរកសុខ ។
អំពីដង្ហើមកូនអ្នកស្រុក
ក៏ជាបន្ទុកការប្ដូរដែរ ។
យើងនឹងអធិប្បាយបើកបកកេរ្តិ៍
ដែលបែរបែកផលជាច្រើនយ៉ាង ។

ការបួសប្រៀបបាននឹងគល់ឈើ
ដែលល្អិតទៅលើបែកមែកធាង
ជាទីប៉ិចផ្កាផ្លែច្រូងច្រាង
ជាព្រេងសំណាងអ្នកបេះធី ។
គល់ពិតតែមួយតែជួយទ្រ
ឱ្យល្អមែកធាងសន្លឹកខ្ចី
បើកាប់គល់ជាច់ដាច់ពីដី
មែកធាងអាងអីមិនរលំ ។

នៅពេលសព្វថ្ងៃសម័យណាស់
តែផ្លាស់មិនផុតពីចាស់ទុំ
ដូចក្មេងជាតិខ្មែរទាំងតូចធំ
នៅតែទៅផ្ដុំសុំដេកវត្ត ។
អ្នកស្រុកចំណាយចាយធនធាន
ច្រើនសែនច្រើនលានគ្មានកំណត់
សាងកុដិសាលាពេញគ្រប់វត្ត
តើពិតប្រាកដមកពីអ្វី ។

គឺមកពីចិត្តគេជ្រះថ្លា
នឹងពុទ្ធសាសនាព្រះជិនស្រី
ដែលមានអ្នកបួសជាសាក្សី
ទើបគេឃ្មាតខ្មីគ្មានគិតស្ដាយ ។
ដល់កើតជាឋានទីលំនៅ
លាភនេះធ្លាក់ទៅក្មេងទាំងឡាយ
នៅបួសនៅរៀនតាមសប្បាយ
បន្ធូរប្រាក់ម្ដាយឪពុកបាន ។

បើអស់លោកសង្ឃពីវត្តវ៉ា
តើកុដិសាលាម្ដេចនឹងមាន
ក្មេងខ្មែរក្រីក្រអន្តរធាន
រកទីតាំងប្រាណពុំបានពិត ។
មិនត្រឹមប៉ុណ្ណោះអស់ព្រះសង្ឃ
ព្រះទ័យស្រោចស្រង់ក្នុងអាណិត
ដឹកនាំបាសកឱ្យដក់ចិត្ត
ជួយគិតពីការសិក្សាជាតិ ។

អ្នកស្រុកជឿបុណ្យស៊ុនចំណាយ
រៃប្រាក់កាសចាយដោយចិត្តស្អាត
សាងសាលារៀនមានព្រោងព្រាត
គ្មានខាតថវិការាជការសោះ ។
គ្រប់វត្តសុទ្ធសឹងប្រឹងប្រិតប្រៀន
សាលារៀនគ្មានចន្លោះ
គ្រប់ភូមិកុះករទោះកៀនកោះ
សាលាដូចបោះទៅតម្កល់ ។

បើគ្មានព្រះសង្ឃអ្នកដឹកនាំ
ឱ្យមនុស្សជឿមាំក្នុងមគ្គផល
តើងាយអ្នកណានឹងគិតយល់
ជួយផ្ដល់រាជការបានប៉ុណ្ណឹង ។

សម្តេចបិតាជាអម្ចាស់
ក៏ទ្រង់បានត្រាស់ច្បាស់ឱ្យដឹង
ជាញឹកញយណាស់ពីរឿងហ្នឹង
ឱ្យជាតិយើងដឹងសព្វគ្រប់ហើយ ។

• ដូច្នេះការបួសគ្មានចង្រៃ
គ្មានហួសសម័យឯណាឡើយ
ទោះមានជនខ្លះធ្វើព្រងើយ
ប្រែខ្នងឆ្លងឆ្លើយថាថោកទាប ។

ហ៊ានបួសព្រោះតែហ៊ានលះចិត្ត
ដែលធ្លាប់ឆ្អើងគិតប្រកាន់ភាព
ដើម្បីឱ្យបានបាត់ពីបាប
ម្តេចខ្លាចថោកទាបមកដល់កាយ ។

គេប្រឹងប្រព្រឹត្តចិត្តឱ្យស្អាត
ព្រឹកឡើងកាន់បាត្រដើរបិណ្ឌបាយ
ស្លៀកពាក់ក៏អន់មិនឆើតឆាយ
កោរសក់អត់បាយឆ្ងាយពីផ្ទះ ។

ច្បាប់បួសអីចឹងគឺតឹងតែង
ឱ្យមនុស្សលះលែងចិត្តមានះ
ចេះឱនទោនទាបក្រាបសំពះ
សមនឹងឃ្លាល្បះភាសិតថា ។

« ទាសៈទម្លាយបង់មានះ
ជរះទម្លាយរូបសោភា
ថ្លែងរឿងព្រះពុទ្ធផុតវេរា
យាចកឈ្មោះថាថោកទាបពិត » ។

• ដូច្នេះអ្នកបួសហួសពីទាប
ព្រោះភាពពឹងគេសាងជីវិត
តែបើមើលពង់ត្រង់ផ្លូវចិត្ត
នោះពិតជាថ្លៃឥតអ្វីស្មើ ។

ព្រោះអីព្រះសង្ឃដែលទ្រង់សីល
មិនមែនខូចខិលឬខ្ជិលធ្វើ
របៀបសុំទៀតក៏ផ្ទាក់លើ
ដូចយើងស្រាយរើខាងលើស្រាប់ ។

មិនមែនដូចស្មូមដើរសូមទាន
ដែលដាក់ទុកប្រាណថាអភ័ព
សុំគេតាមចិត្តឥតទម្លាប់
គេស្អប់គេខ្ពើមឆ្អើមគ្រប់គ្នា ។

ព្រោះខ្ជិលកសាងអាងតែសុំ
មារយាទធ្វើយំព្រួយកំព្រា
របៀបរាប់ឱ្យតែគេមេត្តា
ត្រង់គុណល្អជាគ្មានធ្វើសោះ ។

រីឯព្រះសង្ឃខ្ពង់ជាងហ្នឹង
មិនធ្វើអីចឹងឱ្យអាប់ឈ្មោះ
ហើយទាំងចរិយាក៏គ្មានមោះ
ល្មមដោះពាក្យគេនិន្ទាបាន ។

ធ្វើខ្លួនជូនគេជាស្រែបុណ្យ
ប្រព្រឹត្តសាងគុណគាប់កល្យាណ
ជួយថែរសង្គ្រោះញាតិសន្តាន
ជួយជាតិដូចបានថ្លែងមកហើយ ។

• ខ្មែរមិនទាន់ខ្លាំងតាំងចិត្តហួស
ទ្រាំនឹងការបួសយ៉ាងហ្នឹងឡើយ
មានតែស្តើងស្តួចដែលល្ងួចឆ្លើយ
ព្រោះគេដល់ត្រើយសើយត្នូទដាក់ ។

ឯសាលារៀនមានច្រើនពិត
តែស្រេចនឹងចិត្តដែលគេស្មគ្រ
មិនបួសក៏រៀនគ្មានឧបសគ្គ
ឡើងថ្នាក់ទៅលើប្រសើរក្រៃ ។

តែបើគេចង់ទ្រង់ចីពរ
ដើម្បីកាន់ធម៌ដ៏ប្រពៃ
បួសចុះប្រុសប្រាជ្ញកុំខ្លាចភ័យ
វាគ្មានទោសពៃរ៍ទៅអ្វីទេ ។

រាជការសង្គមបានខំរៀប
របៀបសិក្សាជាហូរហែ
ចែកជាពីរផ្លូវឥតផ្លាស់ប្រែ
ស្រេចតែកូនចៅទៅសិក្សា ។

របៀបមួយផ្នែកបែកបច្ចុប្បន្ន
សំរាប់យុវជនពុំបព្វជ្ជា
មួយទៀតហៅពុទ្ធិកសិក្សា
សំរាប់ជនណាជាបព្វជិត ។

ដូច្នេះការរៀនមានពីរផ្លូវ
សុទ្ធតែត្រឹមត្រូវគ្មានរខិត
ចង់រៀនខាងណាស្រេចលើចិត្ត
កុំគិតជាល្បែងប្រជែងគ្នា ។

កុំរុញអ្នកបួសឱ្យហួសខុស
ផុតពីឋានមនុស្សទៅសួគ៌ា
អ្នកបួសមិនមែនជាតិទេវតា
គឺជាតិខេមរាដូចគ្នាដែរ ។

ហើយជាយុវជនបន្តវង្ស
មានពូជមានពង្សពីឈាមខ្មែរ
ដូចជាយុវជនទាំងពួងដែរ
មិនមែនក្លាយបែរខ្មែរពីប្រាណ ។

ប៉ុន្តែអ្នកបួសហួសពីគេ
ត្រង់ចែកចិត្តរេជាពីរស្ថាន
គឺមួយស្វែងរកសួគ៌និព្វាន
ពីរកសាងប្រាណក្នុងបច្ចុប្បន្ន ។

មុននឹងទៅសួគ៌គួរតែសាក
បែរងាកសាងខ្លួនឱ្យគ្រប់គ្រាន់
មិនមែនឡើងសួគ៌ដោយចៃដន្យ
ទាំងពេលបច្ចុប្បន្នអីចឹងទេ ។

មួយទៀតការបួសហើយវិលសឹក តាមយើងរិះនឹករកពាក្យកែ
ឃើញថាជាគុណគួរកុំប្រែ ត្រូវទុកហូរហែឱ្យវែងឆ្ងាយ ។
ព្រោះបួសហើយសឹកឫកនេះថ្លៃ ឱ្យទាន់សម័យដែលប្រែក្លាយ
. ទីមួយឱ្យកូនខ្មែរទាំងឡាយ ជាប់ចិត្តស្និទ្ធកាយតាមដូនតា ។
ឱ្យសមនឹងពាក្យដ៏សំខាន់ ដែលថាខ្មែរកាន់ពុទ្ធសាសនា
កុំកាន់តែមាត់ចិត្តសាវ៉ា កាន់គ្រាន់ឃោសនាយកបុណ្យសក្តិ ។
សម្តេចឪយើងដែលទ្រង់ធម៌ ជាឧទាហរណ៍ដ៏ជាក់លាក់
គឺទ្រង់កាន់វង្សជាខ្មែរម្នាក់ ព្រះទ័យស្មោះស្មគ្រទំនៀមជាតិ ។
ទ្រង់កាន់ព្រះផ្នួសបួសជាសង្ឃ តាមបែបព្រះវង្សពង្សនរនាថ
សមជាក្សត្រខ្មែរឥតប្រែឃ្លាត អ្នកជាតិនិយមពុទ្ធសាសនា ។
. ទីពីរឱ្យខ្មែរប្រកាន់ខ្ជាប់ នូវបទទម្លាប់ដ៏ថ្លៃថ្លា
ដែលឱ្យយើងចេះសង្គ្រោះគ្នា ដូចបានពណ៌នាខាងដើមហើយ ។
ព្រោះអីបើយើងលែងបួសវិញ ក៏គ្មានចំណោញប៉ុន្មានឡើយ
យូរទៅអ្នកបួសកាន់តែស្តើយ ដល់ហើយក៏បាត់រលត់បង់ ។
ដល់ផុតអ្នកបួសជំនួសព្រះ គ្រហស្ថអ្នកលះទ្រព្យស្រោចស្រង់
ដាច់សូន្យដូចគ្នាជាពិតត្រង់ ព្រោះគ្មានព្រះសង្ឃជាសាក្សី ។
រលាយអស់វត្តរលត់ឈឹង កូនខ្មែរធ្លាប់ពឹងតើបានអ្វី
វានឹងធ្លាក់ធ្ងន់សាជាថ្មី ដល់ម្ចាស់ផែនដីក្នុងការស្រោយ ។
បើនាំគ្នាបួសឱ្យបន្ទាប់- បន្តគ្នាជាប់ខ្សែស្រឡាយ
សាសនាពិតជាមិនអន្តរាយ អាចតាំងនៅឆ្ងាយអង្វែងបាន ។
ហើយបើយើងប្រឹងឱ្យព្រមគ្នា លើកស្ទួយសាសនាឱ្យថ្កើងថ្កាន
ខ្ពង់ខ្ពស់ជាងនេះទៅទៀតបាន យើងហ៊ានថាធូរដល់សង្គម ។

ព្រោះមនុស្សជឿបុណ្យគុណាមគ្គផល
រីតតែជួយផ្តល់ការឧបត្ថម្ភ
ខាងកិច្ចសិក្សាការអប់រំ
មួយភាគយ៉ាងធំសមឥតខ្ចះ ។
ជាតិអាចសំចៃលៃថវិកា
ពីសាងសលាពីសាងផ្ទះ
ពីការផ្គត់ផ្គង់កូនចៅខ្លះ
ទុកយកទៅប៉ះការខ្វះខាត ។
នៅក្នុងវិស័យដទៃផ្សេង
ចំរើនក្រៃលែងដល់រដ្ឋជាតិ
ប្រសិនជាលុបទម្លាប់ស្អាត
នេះទៅតើជាតិចំណេញអី ។

• បើនឹងនិយាយថាការបួស
វានាំឱ្យហួសសម័យថ្មី
ខាតពេលដែលត្រូវសាងផែនដី
សាងជាតិឃ្លាតខ្ចីឱ្យក្រៃលែង ។
ថានេះវិះត្រូវតែនៅខុស
មិនគិតវ័យមនុស្សឱ្យជាក់ស្តែង
តើអ្នកណាហ្ន ! ទៅកំហែង
ឱ្យក្មេងនៅស្មើរធ្វើការងារ ។
គេចែកផ្នែកមនុស្សទាំងប្រុសស្រី
តាមវ័យទាំងបីមកយូរយារ
ទីមួយគឺវ័យនៃកុមារ
ជាវ័យត្រូវការសិក្សាមុន ។
ពីរគឺវ័យហៅកណ្តាល
ជាកាលត្រូវមនុស្សកសាងទុន
ទីបីជាវ័យកសាងគុណ
ធ្វើបុណ្យធ្វើទានសីលភាវនា ។
អ្នកបួសច្រើនក្មេងស្វែងរៀនសូត្រ
តាំងចិត្តស្លូតបូតតាមដូនតា
បួសហើយចាប់ផ្តើមការសិក្សា
ល្មមវ័យកាលណាក៏សឹកវិញ ។
មកលៃប្រឌិតផលិតផល
ជួយជាតិជិតដល់យ៉ាងពេញលេញ
ប្រកបរបររកចំណេញ
បំពេញមុខងារជាពលរដ្ឋ ។
រីឯយុវជនមិនបានបួស
ក៏មិនជ្រុលជ្រួសហួសបែបបទ
ទោះបីមិនចូលជាសិស្សវត្ត
ក៏គង់ចូលបទសិក្សាដែរ ។
មិនដែលម៉ែឪស្គាល់ត្រូវខុស
ណាមួយប្រទូស្តប្រទេចជេរ
ដល់ក្មេងក្នុងវ័យសិក្សាដែរ
ឱ្យបែរត្រឡប់ឈប់រៀនឡើយ ។

គ្មានការបង្ខំដឹបង្ខិត- មានតែលោមចិត្តថាកូនអើយ
ខំរៀនសូត្រកុំព្រងើយ ខ្លួននាងធំហើយត្រូវចេះខ្មាស ។
ទាន់នាងនៅក្មេងវ័យវែងឆ្ងាយ កុំឱ្យនឹកស្ដាយដល់ទៅចាស់
តែមានគ្រួសារការច្រើនណាស់ គ្មានពេលណាផ្លាស់វិលវិញទេ ។
ដូច្នេះថាបួសនាំឱ្យខាត ឱ្យខូចការជាតិដូចពាក្យកេ
យើងហ៊ានឆ្លើយថាមិនពិតទេ ដូចពោលហួរហែមកនេះឯង ។
មួយទៀតបើបួសជ្រុលហួសវ័យ ព្រោះលៃមិនទាន់ក្នុងកាលក្មេង
រឿងនេះក៏គ្មានចម្លែកផ្សេង វាតែងតែមានជាធម្មតា ។
ទោះមិនអ្នកបួសក៏ហួសដែរ ព្រោះខ្មែរឱហាតជាតិសិក្សា
ខ្លះរៀនពីវ័យកុមារា ដល់ចាស់វស្សាក៏មិនឈប់ ។
. ទីបីប្រយោជន៍ខាងអប់រំ លើកស្ទួយសង្គមខាងសេពគប់
ព្រោះអីការបួសជាទំនប់ ជួយទប់កូនខ្មែរឱ្យកែខ្លួន ។
ជួយផ្ដល់សំណាងខាងខាងនិស្ស័យ ឱ្យស្គាល់ទោសពៃរ៍អបាយបួន
ចេះកាន់វិន័យយ៉ាងមាំមួន ចេះហាត់ពត់ខ្លួនខាងចរិយា ។
ផ្នែកនេះជាភាគមួយយ៉ាងធំ ខាងផ្ដល់សង្គមឱ្យថ្លៃថ្លា
កូនខ្មែរដែលបានចូលបព្វជ្ជា សាសនាអប់រំសមគ្រប់កាយ ។
ឱ្យចេះគោរពច្បាប់ខុសត្រូវ ស្គាល់គុណម៉ែឪគ្រូបាធ្យាយ
ស្គាល់តូចស្គាល់ធំផងទាំងឡាយ ស្គាល់ញាតិជិតឆ្ងាយមិនវិបត្តិ ។
ស្នេហាជាតិសាសន៍រាជបល្ល័ង្ក រួបរួមកម្លាំងថ្នើមប្រម៉ាត់
គាំពាររក្សាព្រះមហាក្សត្រ មិនឱ្យសូន្យបាត់ពីសាវតារ ។
ឱ្យចេះជួញចិត្តប្រឌិតផល ជីកស្រះលើកថ្នល់ផលសាធារណ៍
សាងកុដិសាលាព្រះវិហារ ជួយថែរក្សារាជការប្រមុខរដ្ឋ ។

ដល់សឹកមកវិញចិត្តប្រពៃ
មានចិត្តស្លូតត្រង់ក្នុងកម្មបថ
បើមិនបានច្រើនគង់កើនខ្លះ
តាមភ័ព្វនិស្ស័យព្រេងវាសនា
● ដូច្នេះបួសសឹកឬកពិសេស
បើកាន់សាសនាតាមម៉ែឪ
បើមិនបួសយូរច្ចូរតាមស្មគ្រ
ព្រោះមិនជាធ្ងន់ខ្លួនប៉ុន្មាន
នូវច្បាប់វិន័យពុទ្ធសាសនា
នូវគោលគំនិតព្រះជាម្ចាស់
តើធម៌ព្រះពុទ្ធផុតសម័យ
ដល់ជាតិប្រជាពលនិករ
● យើងសូមបញ្ជាក់មួយវគ្គទៀត
ចំពោះបញ្ហាការប្រតិបត្តិ
អ្នកខ្លះបួសហើយលាត់សើយខិល
ត្រូវទានពាសពោរជោរហ៊ឺហា
ឱ្យបួសយ៉ាងហ្នឹងជាត់តម្លៃ
ដូចដែករឹងប៉េះត្រូវច្រេះស៊ី
សំដីទាំងនេះយើងរិះគិត
តែបើរៀបរាប់តាមបរិយាយ
សាសនាព្រះពុទ្ធបរិសុទ្ធថ្លៃ
គ្មានរើសមុខមាត់ចិត្តយ៉ាងណា

ព្រោះជាបនិស្ស័យដែលហាត់ពត់
ជាក់ផ្ចិតជាប់តាមផ្លូវសាសនា ។
មិនមែនស្រឡះបង់អាសា
តាមបែបដូនតាជាប់តទៅ ។
ជួយជាតិប្រទេសជាច្រើនផ្លូវ
នោះត្រូវតែឆ្លៀតបួសកុំខាន ។
ផ្លាស់គ្នាម្តងម្នាក់ឱ្យគ្រប់ប្រាណ
ហើយឱ្យយើងបានស្គាល់ច្បាស់លាស់ ។
នូវច្បាប់ចរិយាខាងធម្មសាស្ត្រ
នូវភាពកម្រាស់ជម្រៅធម៌ ។
ឬឱ្យទោសពៃរ៍លំអក់ពណ៌
ឬក៏ជាធម៌ដឹកនាំសត្វ ។
ដោយឆ្លៀតជ្រៀតយកពាក្យមកស្អាត់
តាមខ្សែបន្ទាត់ពុទ្ធសាសនា ។
រប៉ូចរប៉ិលខ្ជិលសិក្សា
មានពាក្យគេថាគ្រប់ទិសទី ។
នាំតែហិនហៃប្រពៃណី
ល្មេចល្មើទម្លុះឱ្យធ្លុះធ្លាយ ។
ក៏ឃើញថាពិតឥតប្រែក្លាយ
យើងអាចដោះស្រាយយ៉ាងនេះថា ។
ជាទីអាស្រ័យជនគ្រប់គ្នា
ឱ្យតែជ្រះថ្លាក៏បួសបាន ។

ព្រោះជាសាសនាប្រសើរក្តាត់ របស់មនុស្សសត្វគ្រប់គ្រប់ប្រាណ
ជនណាជ្រះថ្លាក្នុងសន្តាន ក៏អាចបួសបានដូចដូចគ្នា ។
តែបើបួសហើយល្មើយគំនិត ប្រព្រឹត្តល្មើសច្បាប់នៃសាសនា
ព្រះពុទ្ធជាម្ចាស់លោកត្រាស់ថា លោកគ្មានធានាជននោះឡើយ ។
បើគេដាំក្រូចបានផលក្រូច បើគេសាងខូចអាក្រក់ហើយ
មិនអាចចៀសវាងផលនេះឡើយ នេះជាពាក្យឆ្លើយល្មមគ្រប់គ្រាន់ ។
មួយទៀតបើយើងនឹងដោះស្រាយ ឱ្យឃើញវែងឆ្ងាយនាបច្ចុប្បន្ន
យើងអាចប្រៀបធៀបឱ្យជាក់ស្ប៊ន ចែកជាថ្នាក់ជាន់តាមតម្លៃ ។
អ្នកបួសពួកខ្លះក្រាស់ដោយបាប ប្រព្រឹត្តថោកទាបខុសវិន័យ
ពិតមែន, ប៉ុន្តែបើប៉ាន់ថ្លៃ ប្រៀបមើលតម្លៃទោសនិងគុណ ។
គង់ឃើញថាគោលការប្រព្រឹត្ត ជ្រុលខាងសុចរិតច្រើនជាងមុន
គឺមានការធ្វើអំពើបុណ្យ និងគុណបវរល្អច្រើនណាស់ ។
រីឯការទ្រុស្តខុសចរិយា ពានព្រៃសិក្ខាដោយឥតខ្មាស
វាជាភាគតូចស្តួចស្តើងណាស់ យកមកប្រកាសក៏មិនសម ។
មួយទៀតច្បាប់សង្ឃអង្គល្អិតខ្ពស់ ជាងច្បាប់គ្រហស្ថខាងអប់រំ
ហើយច្បាប់នេះទៀតជ្រៀតក្រឹត្យក្រម មានតូចមានធំជាច្រើនស្ថាន ។
ចំណែកអ្នកបួសដែលជ្រួសចិត្ត ជ្រុលខាងប្រព្រឹត្តចិត្តបំពាន
ចំពោះក្រឹត្យក្រមធំប្រធាន ក៏លោកមិនហ៊ានបំពានដែរ ។
ជ្រុលជ្រួសថ្លោះធ្លោយដោយនិស្ស័យ ត្រឹមតែទោសពៃរ៍តូរស្តីជេរ
ត្រង់ហ៊ានជាខ្នាំងនឹងច្បាប់ខ្មែរ យើងឃើញហើយដែរកម្រណាស់ ។
កំហុសតិចតួចស្តួចស្តើងហ្នឹង បើតែលៃថ្លឹងគង់ឃើញច្បាស់
វានៅតែត្រង់ត្រូវល្អណាស់ ជាងត្រឹហាវាសផងទាំងឡាយ ។

គ្រហស្ថអស់ត្រឹមច្បាប់ផែនដី
ក្រៅនេះសេរីមានទូលាយ
ចង់ធ្វើយ៉ាងម៉េចហៅសប្បាយ
ក៏គ្មានគិតកាយក្រែងអាបត្តិ ។
រឿងស្រីរឿងស្រាបារាំច្រៀង
ស្តាប់ស្នូរស័ព្ទសៀងច្រៀងប្រតិព័ទ្ធ
ស្រែកបោកក្រញ៉ូវពុំក្រែងមាត់
ដើរលាត់ដើរសើយតាមចិត្តចង់ ។
ដើរលេងលំហែក្បែរមុខរាំង
ត្រៀបត្រាលើតាំងកៅអីបង់
មើលកុនមើលល្ខោនឡុករាំវង់
ឆ្ងៀតដើរចែចង់ផ្លូវស្នេហា ។
មានប្ដីប្រពន្ធរួមស្នេហ៍ស្និទ្ធ
ផ្ដេកផ្ដិតផ្លូវកាមតាមប្រាថ្នា
ជិះកង់ជិះឡានស្រែកឡូឡា
ចង់ធ្វើយ៉ាងណាក៏គ្មានភ័យ ។
គ្មានភិតគិតភ្ញាក់នឹកនាំក្រែង
អាបត្តិអាំប្រែងច្បាប់វិន័យ
ឯលោកសង្ឃវិញគ្មាននិស្ស័យ
លោកគ្មានអស់ដៃអីដល់ម្ល៉ឹង ។
បើធៀបប្រៀបប្រឹតចិត្តជាបុណ្យ
ជញ្ជីងទោសគុណទប់ទល់ថ្លឹង
វាចែកដូចចែងថ្លែងអីចឹង
ពណ៌នាប៉ុណ្ណឹងជាទំនង ។

ប៉ុន្តែសូមមិត្តរួមសាសនា
យល់ឱ្យច្បាស់ថាការខុសឆ្គង
របស់អ្នកបួសទាំងនោះផង
ទោះជាសៅហ្មងតូចក៏ដោយ ។
ក៏ច្បាប់វិន័យកាត់ក្រីទោស
មិនដែលសន្ដោសអនុគ្រោះឱ្យ
លោកដែលប្រព្រឹត្តចិត្តថ្លោះធ្លោយ
ត្រូវប្រែកែក្រោយឱ្យសក្តិសម ។
ពីព្រោះករណីយកិច្ចលោកសង្ឃ
ដោយត្រង់តឺដៅការអប់រំ
ឱ្យល្អចរិយាជាប្រថម
ទើបគេមកខំប្រឹងអត់បាយ ។
ចុះបើមកបួសជ្រែសបណ្ដោយ
បណ្ដោតចិត្តឱ្យនៅភាយមាយ
ធ្វើតាមតែចិត្តគិតសប្បាយ
យកតាមតម្រោយគ្រឹហាវាស ។
ការបួសចិញ្ចឹមចិត្តដូច្នេះ
ពិតជាគ្មានខ្មេះគួរឱ្យខ្មាស
បួសតាំងពីក្មេងវែងដល់ចាស់
គ្មានផ្លាស់ចរិយាមារយាទប្រាណ ។

| | |
|---|---|
| ការបួសនោះទៀតក៏គ្មានន័យ | មានតែទោសពៃរ៍អន្តរធាន |
| ការខ្លួនក៏ខាតជាតិក៏ខាន | បង់បាយមិនបានប្រយោជន៍អ្វី ។ |
| អ្នកបួសលោកដឹងខ្លួនយ៉ាងនេះ | បានជាលោកចេះតាំងស្មារតី |
| ប្រព្រឹត្តអប់រំទាំងចាស់ថ្មី | ឃើញគួរគប្បីមិនសូវឆ្គង ។ |
| អ្នកស្រែធ្វើស្រូវរដូវកាល | ស្ទុះស្ទាស្រើបស្រាលដោយបំណង |
| ចង់បានផលច្រើនជាងមិត្តផង | ដោយនូវតន្លងផ្លូវសុចរិត ។ |
| រីឯអ្នកបួសក៏ដូច្នោះ | ប្រឹងប្រែងស្រាយដោះខាងផ្លូវចិត្ត |
| យកជ័យជំនះឈ្នះអស់មិត្ត | ដោយការប្រព្រឹត្តអប់រំប្រាណ ។ |
| • អស់មិត្តទាំងឡាយរួមសាសនា | មានចិត្តជ្រះថ្លាដែលបានអាន |
| សូមមិត្តមេត្តាកុំរំខាន | នឹកស្មានថាខ្ញុំក្រុមទៅក្រោយ ។ |
| ខ្ញុំក្រងចងជាបទបរិយាយ | នេះគឺដោះស្រាយការថ្លោះធ្លោយ |
| ដែលអស់យុវជនជំនាន់ក្រោយ | បណ្ដោយតាមចិត្តបំបិទគុណ ។ |
| មិនបើឱ្យឃើញភាគផលល្អ | ដែលកកើតពីទីស្រែបុណ្យ |
| ជាដែលជម្រកមកពីមុន | ជាគុណជួយកែកូនខ្មែរអើយ ! ។ |

***

• ពុទ្ធឱវាទ :

មានវាចាល្អ តែមិនធ្វើតាម

ប្រៀបបានទៅនឹងផ្កាមានពណ៌ស្រស់ល្អ តែឥតក្លិនក្រអូប ។

# អ្វីជា KHMEROLOGY ?

( ត . ចប់ )

ដោយលោកស្រីបណ្ឌិត **ពៅ សាវរស**

បកប្រែពីអត្ថបទភាសាអង់គ្លេស ដោយ **ខង់ សុធារ៉ា**

## III. ស្ថានភាពបច្ចុប្បន្នរបស់ KHMEROLOGY

១. គេអាចយល់បានអំពីសេចក្តី ដែលទើបនឹងរាយខាងលើថា ភាសាសាស្ត្រខ្មែរ បង្កើតបានជាវិជ្ជាអ្នកប្រាជ្ញ ដូច្នេះ វាជាអ្នកដឹកនាំក្នុងការកសាង Khmerology ឡើង ។ ហេតុផលភាគច្រើន ដែលបានរាយការណ៍ក្នុងកំឡុងពេលជាមួយគ្នានោះ (synchrony) បង្កើតបានជាទស្សនៈល្អមួយ សំរាប់អត្ថិភាពនៃប្រវត្តិភាសាខ្មែរ ក្នុងពេលអនាគតដ៏ឆាប់ ដើម្បីជាក្បួនខ្នាត និងបង្កលក្ខណៈងាយស្រួលដល់អ្នកសិក្សាទាំងអស់ ។

ផ្ទុយទៅវិញ នៅមានសេសសល់ការខ្វះខាតខ្លះ ដែលយើងត្រូវសង្កត់ធ្ងន់យ៉ាងម៉ឺងម៉ាត់ ហើយបញ្ហាធំចំបងពីរ ត្រូវតែដោះស្រាយជាបន្ទាន់ បើយើងចង់រក្សាការស្រាវជ្រាវអោយរីកចំរើននៅតាមគន្លងវិទ្យាសាស្ត្រ ។

បញ្ហាទី១ គឺនៅនឹងផ្នែក ឥឡូវនេះនៅក្នុងប្រទេស សកម្មភាពឧត្តមសិក្សាបានផ្តើមដំណើរការឡើងវិញហើយ ទោះជានៅមានដំណើរតតេះតតះក៏ដោយ ក៏និស្សិតកម្ពុជាក្មេងៗ គប្បីចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាលដ៏រឹងមាំមួយ ។ ក្នុងនាមជាជនម្ចាស់ស្រុក ហើយនិយាយភាសាខ្មែរ យើងគួរតែជំរុញនិស្សិតនោះអោយរៀនមើលអត្ថបទខ្មែរ (សម័យបុរាណ និងកណ្តាល) ដើម្បីប្រមូលទិន្នន័យពាក្យជាវគ្គៗ ។ ជាឧទាហរណ៍ របៀបធ្វើចំណាត់ប្រភេទនៃភាសាសាស្ត្រ គំរូភាសាសាស្ត្រ

ដែលភាសាវិទូនានាជាតិកំពុងធ្វើការស្រាវជ្រាវអំពីភាសាខ្មែរសម័យថ្មី ដែលពួកគេនឹងត្រូវការសំរាប់ប្រៀបធៀបការស្រាវជ្រាវ ។

បញ្ហាទី២ ត្រូវការយើងយកចិត្តទុកដាក់កាន់តែខ្លាំង និងដំណោះស្រាយបន្ទាន់យ៉ាងសមរម្យ ។ តាមពិត គ្មានទាល់តែសោះ នូវចំណេះដឹងខ្ពង់ខ្ពស់ ដែលសំដែងចេញដោយគ្មានពឹងផ្អែកគម្ពីរយោងនោះទេ ។ នៅទីនេះ ខ្ញុំចង់និយាយអំពី **វចនានុក្រម** ដែលជាឯកសារយោងដ៏ឯក សំរាប់អ្នកស្រាវជ្រាវទាំងអស់ ទុកជានៅក្នុងវិស័យនៃការស្រាវជ្រាវអ្វីក៏ដោយ ( រយៈពេលយ៉ាងយូរកន្លងមក និងពេលវេលាដំណាលគ្នា ) ។

យើងគ្រប់គ្នាត្រូវការវចនានុក្រមល្អ និងទៀងទាត់ ដើម្បីនឹងបំពេញការសិក្សារបស់យើងរៀង១ខ្លួន ។ វចនានុក្រមភាសាខ្មែរសម័យកណ្តាល គឺនៅខ្វះយ៉ាងក្រៃឡែត ចំណែកក្តីសង្ឃឹមអោយបានវចនានុក្រមខ្មែរកណ្តាលនោះ គឺគួរអោយស្តាយ វានៅឆ្ងាយណាស់ ។ ពីព្រោះ អត្ថបទសត្រាភាគច្រើន នៅតែរង់ចាំការសិក្សា ។

បញ្ហាប្លែកម្យ៉ាងទៀត គឺចំពោះភាសាខ្មែរថ្មី ។ យើងមានភ័ព្វច្រើនណាស់ រហូតមកដល់ឥឡូវនេះ ដោយមានវចនានុក្រម ដែលជាស្នាដៃឆើតរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ហើយគឺស្ថាប័ននេះឯង ដែលទទួលបើកសន្និសីទនាពេលនេះ ។ ប៉ុន្តែជាការពិត វចនានុក្រមនេះត្រូវសិក្សាឡើងវិញអោយទាន់សម័យ ហើយស្នាដៃស្រាវជ្រាវខ្លះទៀត ហើយនិងគម្ពីរសម្រាប់ជាបង្អែកខ្លះទៀត ក៏ដូចគ្នានេះដែរ ។ បើគំរោងការនេះ មានការយល់ព្រមពីអ្នកស្រាវជ្រាវទូទៅ យើងនឹងមានសមត្ថភាពបង្កើតវាបាន ទោះបីកាលៈទេសៈប្រទេសជាតិសព្វថ្ងៃពិបាកយ៉ាងណាក៏ដោយ ។ ដោយសារការស្រាវជ្រាវខាងពាក្យជាមូលដ្ឋានភាគច្រើន ខ្ញុំបានធ្វើដោយយកចិត្តទុកដាក់រួចជាស្រេច រហូតមកដល់ឥឡូវនេះ អស់រយៈពេលប្រហែល ២០ ឆ្នាំហើយ

ហើយលទ្ធផលនេះ អាចរកបានតាមរយៈអត្ថបទជាច្រើនរបស់ខ្ញុំ ដែលបានបោះពុម្ពផ្សាយ ។

២. ឥឡូវនេះ ខ្ញុំចាប់និយាយអំពីវិស័យដុនដាបនៃការស្រាវជ្រាវអក្សរ.សិល្ប៍ ដែលត្រូវមានទាំងទំរង់ផ្សេងៗនៃអក្សរសាស្ត្រផងដែរ ។ ពីព្រោះតាមខ្នាតនៃលោក អក្សរសិល្ប៍មានការទាក់ទងយ៉ាងជិតស្និទ្ធ ឬយ៉ាងហោចណាស់ ក៏មានការពឹងផ្អែកជាមួយសិល្បៈជាចំបង ដូចជា ភ្លេង ល្ខោន និងសិល្បៈផ្ទាល់ខ្លួន ( ថ្នាក់ទាប ឬខ្ពស់ ) ហើយការបង្កើតមុខវិជ្ជាទាំងអស់នោះឡើង ដោយឈរលើមូលដ្ឋានប្រវត្តិសាស្ត្រ បន្ទាប់មក លើបញ្ញា និងលើទស្សនះវិជ្ជា ។

មានគំនិតខុសមួយដែលមិនងាយរលត់ ទាក់ទងនឹងសកម្មភាពខួរក្បាលរបស់មនុស្សខ្មែរ គឺថា ខ្មែរចេះត្រឹមតែនិទានរឿងប៉ុណ្ណោះ ដូច្នេះហើយ វាគ្មានទាល់តែសោះនូវសារជាតិបញ្ញា ឬចិត្តវិទ្យាដែលគេអាចរកបានពីកិច្ចការអក្សរសិល្ប៍ខ្មែរ ។ គំនិតខុសនេះ គឺជនជាតិខ្មែរខ្លួនឯងបានចិញ្ចឹមទុក ដូច្នេះហើយ ធ្វើអោយការស្រាវជ្រាវអក្សរសិល្ប៍បានត្រឹមតែការសរសេររ៉ាយរ៉ាប់ដំណើររឿង និងជីវិតអ្នកនិពន្ធ និងការសរសេរផ្សាយស្នាដៃមួយចំនួន ដែលគេបានបោះពុម្ពផ្សាយរួច (book reviews) ។

ក្រៅពីនេះ ដូចដែលខ្ញុំបាននិយាយពីខាងលើរួចមកហើយ អំពីសទ្ទានុក្រមវិទ្យា នៅតែមានអត្ថបទសរសេរដៃ ដែលមើលទៅដូចជានៅជាប់ជិតមុនសម័យថ្មី (pre-modern times) ដែលយើងត្រូវអាន ត្រូវស្គាល់ ត្រូវបែងចែកជា « ប្រ.ភេទ » (genres) ឬ « អនុប្រភេទ » (sub-genres) ... ។ ល ។ យើងដាច់ខាតចង់ស្គាល់បនាទ្រីស្តិ៍ និងបច្ចេកទេសនៃសត្រានោះ មុននឹងយើងបាននិយាយអំពីអក្សរសិល្ប៍សម័យថ្មី ។ គេមិនអត់ឱនអោយទេ អ្នកណាដែលធ្វើគរថ្លង់ ចំពោះនិរន្តរភាពនៅក្នុងជីវិតនៃសហគមន៍មួយ និងនៅក្នុងស្នាដៃទាំងឡាយរបស់គេ ដែល

ក្នុងនោះ មានទាំងអក្សរសិល្ប៍ផងដែរ ហើយគឺអក្សរសិល្ប៍នេះឯង ដែលស្ថិតនៅក្នុងខ្នាតនៃនិរន្តរភាព ។

បន្ទាប់មក យើងត្រូវតែត្រឡប់ទៅអតីតកាលយូរលង់ ដើម្បីរកប្រភពនៃអក្សរសិល្ប៍ខ្មែរទាំងមូល ។ នោះជាកិច្ចការមួយដ៏សំបើម កំពុងរង់ចាំអ្នកទាំងអស់ ដែលខ្វល់ខ្វាយខាងការស្រាវជ្រាវអក្សរសិល្ប៍ ។ ផ្ទុយទៅវិញ យើងត្រូវតែធ្វើអោយសំរេចកិច្ចការណាមួយនៅក្នុងអនាគតដ៏ខ្លីខាងមុខ ។ ចំណែកកិច្ចការដែលគួរអោយញញើតជាងនេះទៅទៀតនោះ គឺការសិក្សាពេញលេញអំពីកំណាព្យខ្មែរ ដែលយើងគ្មានបានធ្វើអ្វីទាំងអស់ខាងផ្លូវវិទ្យាសាស្ត្រ(១) លើសនោះទៅទៀត ទំនុកនៃក្រុមបទចំរៀងប្រពៃណីទាំងមូល ដែលតម្រូវអោយអ្នកស្រាវជ្រាវចាប់យកអោយបាននូវលក្ខណៈពិសេសរបស់ភ្លេង និងសោភណវិទ្យា ។

កិច្ចការទាំងអស់នេះ ត្រូវការមនុស្សច្រើននាក់ ។ ការពិត អ្នកស្រាវជ្រាវទាំងអស់ត្រូវរួមគ្នាជាក្រុមការងារ ធ្វើការដោយក្ដីឧិបាត និងប្រើបច្ចេកទេសអក្សរ-សិល្ប៍មួយដែលសក្ដិសមនឹងកេរ្តិ៍ឈ្មោះជាបច្ចេកទេស ។ ចុងបញ្ចប់ ត្រូវការអ្នកចំណាប់បរិបូណ៌ខាងភាសាខ្មែរយើងបានកូនសោរឆ្ពោះទៅកាន់ Khmerology ។

៣. នេះជាបញ្ហាក្រោយបង្អស់ ប៉ុន្តែ មានឯកសារមិនតិចជាងគេទេ ដែលត្រូវអោយយើងពិនិត្យ គឺអំពីការស្រាវជ្រាវប្រវត្តិសាស្ត្រដែលមានន័យទូលំទូលាយ ។ ប្រវត្តិសាស្ត្រនៃប្រទេសមួយ មិនមែនរៀបរាប់ត្រឹមតែការបន្តដំណែងរបស់ស្ដេច

---

(១) មានគំនិតខុសគ្នាជាក់ស្ដែងមួយទៀត អំពីការនិយាយមិនចេះចប់ ហើយអំពីការតែងកាព្យ នៅពេលអ្នកស្រាវជ្រាវណាមួយប្រកាសនូវចំណាប់អារម្មណ៍របស់គេលើកំណាព្យខ្មែរ។ ដូច្នេះ គេមិនដែលមានការខំប្រឹងប្រែងណាមួយសោះតាំងពីយូរណាស់មកហើយ នៅក្នុងការឱ្យន័យ « កំណាព្យ » ដែលតាមយើងដឹង វាត្រូវការនូវចំណេះដឹងគ្រប់គ្រាន់ខាងនិយណ្ឌវិទ្យា (semantics) ខាងរចនាវិទ្យា (stylistics) ទាំងផ្សេងៗជាច្រើននៃសិល្បៈ និងទំនាក់ទំនង ។ ដូចជា ប្រពៃណី និងទំនៀមទម្លាប់អ្នកស្រុក (folklore) បរិស្ថានវិទ្យា និងសង្គមវិទ្យា ។

សោយរាជ្យ ឬអ្នកដឹកនាំសំខាន់ៗទេ ឬមិនមែនតែព្រឹត្តិការណ៍ដែលបានកើតឡើងជាបន្តបន្ទាប់ មានសង្គ្រាមជាដើម ហើយនិងការពិពណ៌នាច្រំដែលៗ នូវព្រឹត្តិការណ៍ និងរបស់របរប្រើប្រាស់ ឬកេរដំដែលសិល្បៈទាំងឡាយនោះទេ ប៉ុន្តែ ប្រវត្តិសាស្ត្រនិយាយអំពីសត្វលោកទូទៅ អំពីគំនិតរបស់ពួកគេ អំពីសកម្មភាពរបស់ពួកគេ អំពីរបៀបនៃជីវិតរបស់ពួកគេក្នុងភាពជាបុគ្គល ជាសមាជិកនៃសហគមន៍ ។

មិនចាំបាច់ខ្ញុំសង្កត់ធ្ងន់ទៅលើយោបល់រួមគ្នា នៃការសិក្សាប្រវត្តិសាស្ត្រនាពេលបច្ចុប្បន្ន នៅក្នុងសកលលោកនេះអោយបានវែងឆ្ងាយ និងទូលំទូលាយទេ[១] ។ ក្នុងករណីនេះ យើងត្រូវតែទទួលស្គាល់ថា យើងដឹងអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាតិចតួចណាស់ ។ យើងបានស្គាល់រួចមកហើយអំពីវង្សត្រកូល នៃព្រះមហាក្សត្រខ្មែរបុរាណ[២] ស្នាដៃវត្ថុប្រើប្រាស់ ឬវត្ថុសិល្បៈរបស់ពួកគេ[៣] អំពីចំណែកមួយនៃស្ថាប័ននយោបាយ និងរដ្ឋបាល នៅក្នុងសម័យអតីត ។

---

(១) នៅក្នុងសម័យយើងនេះ អ្នកនិពន្ធដ៏ពូកែ ទោះជាអ្នកប្រវត្តិវិទ្យា ឬសង្គមវិទ្យា ទោះជាគេជាជនជាតិនៃទ្វីបទាំងអស់ ( អឺរ៉ុប អាស៊ី អាមេរិកទាំងពីរ ) និងគេយល់ស្របគ្នាអំពីខ្នាតពីរនៃការស្រាវជ្រាវប្រវត្តិសាស្ត្រ គឺថា ព្រឹត្តិការណ៍ទាំងឡាយកើតក្នុងរយៈពេលមួយច្បាស់លាស់ ហើយបរិវត្តន៍ដ៏យូរយារនៃសង្គមមួយ ត្រូវលេចចេញមកដល់ដូចសព្វថ្ងៃនេះបានបង្កប់ នៅក្នុងការបង្រួមអោយតូចនៃពិភពលោកទាំងមូល ( globalization ) ។

(២) ដែលនៅតែមានកន្លែងបង្កប់ប្រស្នា ហេតុដូច្នេះ វាទាមទារការពិនិត្យយ៉ាងម៉ត់ចត់ពីអ្នកប្រវត្តិសាស្ត្រ ។

(៣) ជាថ្មីម្តងទៀត ភាគច្រើន គេត្រូវតែធ្វើខាងវិស័យនេះ ដូចជាការធ្វើអោយជាប់ជិតគ្នានៃគម្លាតរវាងបដិមាសាស្ត្រ និងសិលាចារឹក ការអានអត្ថបទខ្មែរបុរាណដោយយកចិត្តទុកដាក់បន្តប់មក ការបង្កើតរូបភាពពិតៗនៃទស្សនះរបស់ខ្មែរ ។ បទពិសោធន៍នៃការសិក្សាសិលាចារឹកខ្មែរយ៉ាងយូររបស់ខ្ញុំ អាចចំរាញ់យកតួនាទីពិតប្រាកដរបស់ព្រះក្នុងព្រហ្មញ្ញសាសនានៅ ក្នុងសង្គមខ្មែរបុរាណ ដែលគេអាចបញ្ជាក់បានយ៉ាងងាយ តាមរយៈកេរដំណែលបច្ចុប្បន្នរបស់វា នៅក្នុងសហគមន៍នាពេលសព្វថ្ងៃនេះ ។

សេចក្ដីដែលបានអធិប្បាយទាំងអស់នេះ យើងដឹងតែប៉ុណ្ណឹង គឺមកទល់ត្រឹមទសវត្សឆ្នាំ ១៩៦០ ដោយសារកិច្ចការរបស់លោកសឺដេស ។

ចំណែកឯប្រទេសកម្ពុជាសម័យក្រោយអង្គរ ការចេះដឹងរបស់យើងមានដូចគ្នានេះដែរ ពីព្រោះ គេបានផ្ដល់អោយយើងយ៉ាងច្រើនហូរហៀរ នូវអ្វីដែលគេហៅជាភាសាបារាំងថា " histoire événementielle " ( ប្រវត្តិព្រឹត្តិ-ការណ៍ ) ដែលគេទាញយកមកពីពង្សាវតារជាច្រើន ។ បន្ទាប់មក អ្នកប្រវត្តិសាស្ត្រសហសម័យ ( ដែលកំពុងរស់នៅជាមួយយើងសព្វថ្ងៃ ) ខិតខំយ៉ាងខ្លាំងក្នុងការវិភាគទៅលើសម័យអពមង្គលខ្មែរក្រហម ហើយជាទូទៅ យើងនៅតែមានបញ្ហាដែលត្រូវដោះស្រាយអំពីផ្ទៃ ( សង្គម, សីលធម៌ ឬនយោបាយពិតៗ ) ខាងក្រោយនៃរាល់ព្រឹត្តិការណ៍ ដែលយើងបានដឹងកន្លងមក ។

សរុបសេចក្ដីទៅ យើងនៅសល់បញ្ហាទូទៅ ស្ដីអំពីអ្វីដែលជាសារជាតិនៃសង្គមមនុស្ស ដែលគេហៅថា " កម្ពុជា " ថាតើសង្គមសព្វថ្ងៃនេះ បានវិវត្តចេញមកពីសង្គមមុនៗ ដោយរបៀបយ៉ាងម៉េច ... ។ល។

ចម្លើយមិនអាចធ្លាក់មកពីលើមេឃបានទេ វាទាល់តែយើងខិតខំយ៉ាងខ្លាំង សិក្សាដោយប្រុងប្រយ័ត្ន នូវឯកសារសំណេរជាខ្មែរទាំងឡាយ ដែលបានផលិតឡើងដោយមនុស្សដែលយើងចង់ដឹងនោះឯង ។ ពិតណាស់ហើយ យើងមាននូវសិលាចារឹកខ្មែរបុរាណគ្រប់ទាំងអស់ ហើយសំរាប់សម័យកាលបន្ទាប់ពីបុរាណហ្នឹងមក ដូចដែលខ្ញុំបាននិយាយពីខាងដើមរួចមកហើយ ថាមានសត្រាដ៏ច្រើនសន្ធឹកសន្ធាប់ និយាយអំពីអ្វីដែលហៅថា " អត្ថបទស្ថាប័ន " (institutional) ជាពិសេសគេបានរក្សាទុកវានៅក្នុងបណ្ណាល័យធំៗ នៅទីក្រុងប៉ារីស ។ អត្ថបទទាំងនោះ គេហៅជាភាសាខ្មែរថា ក្រឹត្យក្រម ច្បាប់ ទំនីម តាមគេនិយម ។

## IV. សេចក្ដីសន្និដ្ឋាន

ដូច្នេះ ខ្ញុំបានបំភ្លឺបញ្ហាចំបងខ្លះៗ ដែលរង់ចាំអ្នកស្រាវជ្រាវទាំងអស់ ដែលបានខ្វល់ខ្វាយគិតដល់ខេមរវិទ្យា ហើយពួកគេត្រូវតែយកមកពិនិត្យមុននឹងនាំគ្នាចរចាអំពី " KHMEROLOGY " គឺថា Khmerology ទាក់ទិននឹងកិច្ចការស្រាវជ្រាវវិទ្យាសាស្ត្រមួយ នៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រនៃសាកលលោកទាំងមូល ។ ប្រការនេះ តម្រូវអោយយើងម្នាក់ៗមាននៅក្នុងខ្លួន នូវការបណ្ដុះបណ្ដាល ខាងវិជ្ជាឧត្ដមសិក្សា នូវវិន័យ និងថែមទាំងគំនិតឧត្ដុង្គឧត្ដម ហើយនិងការដឹងអោយពេញលេញ អំពីអ្វីដែលគេបានបង្កើតរួចតាំងពីយូរយារណាស់មកហើយ ។ គឺថា តាំងពីទសវត្សទី១ នៃសតវត្សទី២០ ក៏រិតនៃការរីកចំរើនខ្ពស់បំផុត នៃកំណើតរបស់ KHMEROLOGY គឺនៅរវាងឆ្នាំ ១៩៧០ ។ ដូច្នេះ KHMEROLOGY គឺជារបស់ក្មេងមួយ ក៏ប៉ុន្ដែ គេអាចយកទៅប្រៀបជាមួយនឹងកំណាព្យវីរកថាមួយបាន ។ គ្មានអ្នកណាម្នាក់អាចមកបំភ័ន្តការរីកចំរើនរបស់ Khmerology និងអនាគតរបស់វាបានឡើយ ។

ផ្ទុយទៅវិញ យើងគ្រប់គ្នាត្រូវតែសំដែងក្ដីគោរពជាក់ស្ដែងចំពោះព្រលឹងរបស់បុព្វគុរុទាំងអស់ ។ ជាបន្ថែមទៀត ចំពោះអស់លោកភាសាវិទូ ដែលខ្ញុំបាននិយាយពីខាងដើម សូមយើងទាំងអស់គ្នាចាំឈ្មោះរបស់លោក ហេនឌ្រិក ខេន, លោក អេត្យេន អេម៉ូនីញ៉េ លោក ហ្សក សឺដេស, លោក អូ ឈឿង, លោក ប៉ែរណាដ ហ្វីលីព ហ្គ្រោលីយេរ វិញ្ញាណក្ខន្ធរបស់អ្នកប្រាជ្ញសង្ឃ ដែលព្រះអង្គបានបង្រៀននៅក្នុងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនេះឯង ។ ក្នុងនាមជាសិស្សលំអុតលំឱនម្នាក់ ខ្ញុំសូមសំដែងនូវគារវកិច្ចដោយកតញ្ញូកតវេទិតាធម៌ ដ៏ជ្រាលជ្រៅចំពោះគុរុទាំងអស់នោះ ។

ឥឡូវនេះ ខ្ញុំងាកមកនិយាយអំពីបញ្ហាផ្ទាល់ខ្លួន ដែលជាផ្នែកដ៏សប្បាយ

រីករាយបំផុតនៃបាឋកថារបស់ខ្ញុំ ។

ជាកាតព្វកិច្ច ខ្ញុំត្រូវតែសំដែងអំណរគុណដ៏ស្មោះចំពោះក្រសួង និង បុគ្គលផ្សេងៗ ។ ដំបូងចំពោះ Heinrich Boell Stiftung នៅប៊ែរឡាំង ដែលមានសប្បុរសធម៌អញ្ជើញខ្ញុំមកទីនេះ បន្ទាប់ពីខ្ញុំអវត្តមានអស់ជាច្រើនឆ្នាំ ធ្វើអោយខ្ញុំបានជួយឧត្តមសិក្សាតាមសមត្ថភាព និងបានជួយញាតិមិត្តរបស់ខ្ញុំ ។ បន្ទាប់មកសូមថ្លែងអំណរគុណចំពោះស្ថាប័នឧត្តមសិក្សាផ្សេងៗ ដែលបានទាក់ទិនធំជាងគេបង្អស់ គឺ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលជាដង្ហើម និងជាបេះដូងនៃប្រទេសកម្ពុជា ។ ជាចុងក្រោយបង្អស់ សូមថ្លែងអំណរគុណចំពោះបណ្ឌិត ពៅ ធនវឍ ចំពោះការទទួលខ្ញុំជាភ្ញៀវដោយធម៌ ព្រមទាំងមិត្តភក្តិជាច្រើន ដែលចេញមកដោយសុទ្ធចិត្ត និងបានហុចដៃមកជួយខ្ញុំដោយសេចក្តីស្រឡាញ់ ។

បើគេគ្រប់គ្នាយល់ពាក្យ " **ធម៌** " ថាជា " សណ្តាប់ ឬរបៀប " ពាក្យនោះឯងមានន័យផងដែរថា យុត្តិធម៌ ក្តីទៀងត្រង់ និងក្តីស្រឡាញ់ ( **មេត្តាករុណា** ) មិនគ្រាន់តែមាននៅក្នុងអតីតកាលយូរអង្វែងមកហើយទេ ប៉ុន្តែក៏មាននៅក្នុងទូទាំងសាកលលោក នាពេលបច្ចុប្បន្នកាលនេះផងដែរ ។ នៅក្នុងកាលៈទេសៈបច្ចុប្បន្នកាលនេះ ខ្ញុំសូមបួងសួងចំពោះព្រះពុទ្ធជាម្ចាស់ និងអាទិទេព ព្រហ្មញ្ញ - សាសនាទាំងអស់ថា សូមអោយ **ធម៌** សោយរាជ្យសាជាថ្មី នៅក្នុងប្រទេសនេះ យាវតចន្ទ្រាទិត្យ មាន លេយ ដូចបុព្វបុរសរបស់ខ្ញុំធ្លាប់និយាយ គឺថា ដរាបព្រះអាទិត្យ និងព្រះច័ន្ទនៅមាន ឬនិយាយម្យ៉ាងទៀតថា ជារៀងរហូត ។

***

# ឯកសារពិគ្រោះជំរើស


Aymonier, E.

1883 " Quelques notions sur les inscriptions en vieux Khmer, *Journal Asiatique,* Avril-Juin : 441-505, Août-Septembre : 199-228.

1884 *L'épigraphie Kambodjienne,* Saigon.

Barth, A.

1885 *Inscriptions sanscrites du Cambodge,* Paris.

Bergaigne, A.

1893 *Inscriptions sanscrite du Campã et du Cambodge,* Paris.

Buddhist Institute

1958 *Vacanãnukram Khmaer,* Phmon penh, 5th edition.

Coedès, G.

1937-66 *Inscriptions du Cambodge,* 8 vol., EFEO, Hanoi-Paris.

Henderson, E.A.J.

1952 " The main Features of Cambodian Pronunciation ", *Bull. of the school of Or. and Afr. Studies* 14, 1 :149-74

Kern, H.

1879 " Opschriften op oude bouwwerken in Kambodga ", *Bijdragen tot de Tal- , Land- , en Volkenkunde* 26 : 268-72.

Martini, F.

1949 " Apercu phonologique du cambodgien ", *Bull. de la Soc. de ling. de Paris* XLII : 113-31

Pou, S.

1989 *Nouvelles Inscriptions du Cambodge,* I, EFEO, Paris.

1992 *An Old Khmer-French-English Dictionary,* Paris.

1993 " Isur/Içvara, ou Çiva, au Cambodge ", Orientalia *Lovaniensia Periodica* 24 : 143-77.

1994 " Visnu/Nãrãy au Cambodge ", *Or. Lov. Periodica* 25 : 175-95

1995 " Indra et Brahma au Cambodge ", *Or. Lov. Periodica* 26 : 141-61.

1997a " L'épigraphie khmère ", *Angkor et dix siècles d'art khmer,* Paris : 53-61.

1997b " Khmer epigraphy ", *Sculpture of Angkor and ancient Cambodia. Millenium of Glory,* Washington 53-61.

1998 " Ancient Cambodia's Epigraphy : a socio-linguistic look ", Leiden.

forthcom " Ancient Cambodia's Epigraphy : the Concept of Merit-making and Merit-offering ",Paris.

forthcom " Praçasta Kamvujā " Leuven.

Pou, S., et Vogel, S.

1995 " Introduction à l'étude du vieux khmer ", *Cahiers d'études franco-cambodgiens* 4 : 1-41.

---

• ពុទ្ធភាសិត :

គន្ធពិដោរនៃផ្កា មិនក្រអូបច្រាសខ្យល់បានទេ
តែកេរ្តិ៍ឈ្មោះរបស់មនុស្សល្អ ទើបផ្សព្វផ្សាយបញ្ច្រាសខ្យល់
គ្រប់ទិសទីបាន ។

# សិលាចារឹករកឃើញថ្មីមួយ នាឆ្នាំ ១០១៤ និងអត្ថន័យខាងសង្គមប្រវត្តិសាស្ត្រ

ដោយបណ្ឌិតសាស្ត្រាចារ្យ **ធ្យូខ សៀម**
សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ, និង
សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ

សិលាចារឹករកឃើញថ្មីមួយ នាឆ្នាំ ១០១៤ នៃគ.ស បានត្រូវសរសេរឡើងនៅលើសិលាស្តម្ភ ដែលមានកំពស់ ១,៥១ ម. ទទឹង ០,៨៥ ម. និងកំពស់ ១៣ ស.ម ។

សព្វថ្ងៃ សិលាចារឹកនេះបានត្រូវគេចុះក្នុងបញ្ជីក្រោមលេខថ្មី ៦២៦ ហើយបានត្រូវរក្សាទុកនៅក្នុងសារមន្ទីរអភិរក្សអង្គរ ទីក្រុងសៀមរាប ។ បន្ទាប់មកទៀត ក្រសួងវប្បធម៌ប្រទេសកម្ពុជា បានចុះបញ្ជីសិលាចារឹកនេះសាជាថ្មី ក្នុងលេខ Ka 17 ជាលេខនៅក្នុងបញ្ជីដែលបានត្រូវរៀបចំឡើងដោយបណ្ឌិតខាងបុរាណវិទ្យា *មីសែល ត្រាណេ* ។

តាមសេចក្តីអោយការណ៍របស់អ្នកទទួលខុសត្រូវមួយរូប នៅសារមន្ទីរអង្គរ គឺលោក *អ៊ុន ផល្លី* សិលាចារឹក ឆ្នាំ ១០១៤ នៃគ.ស នេះ ដែលគេពុំដឹងច្បាស់អំពីប្រភពដើមរបស់វា បានទទួលភ័ព្វវាសនាប្រកបដោយនាដ្យកម្មមួយដ៏អាណោចអាធ័ម ដោយហេតុថា សិលាចារឹកបានត្រូវពួកចោរប្លន់ ហើយដាក់ក្នុងរថយន្តបរតម្រង់ទៅប្រទេសជិតខាង ជាមួយចម្លាក់ក្លោងទ្វារមួយ (linteau) ព្រមទាំងរូបចម្លាក់ទ្វារបាល (dvārapāla) ។ ជាសំណាងល្អ គ្រឿងបេតិកភ័ណ្ឌដ៏មានតម្លៃបំផុត បានត្រូវទីបញ្ជាការយោធាសៀមរាបចាប់បាន ហើយបានប្រគល់ដ៏ត្រឹមត្រូវ

ដល់សារមន្ទីរអភិរក្សអង្គរ នាឆ្នាំ ១៩៩៤ ។

សិលាចារឹកនេះ បានត្រូវចារឡើងនៅលើសិលាស្តម្ភទាំងសងខាង ។ នៅលើចំហៀងទីមួយ ឬ (ផ្នែក A) មានអក្សរ ៩៧ បន្ទាត់ សរសេរឡើងដោយអក្សរក្រមសម័យអង្គរដ៏ល្អឆើតឆាយ ហើយទាំងអស់នេះគឺសរសេរជាភាសាខ្មែរទាំងមូល ។ នៅលើចំហៀងទីពីរ នៃសិលាស្តម្ភ (ផ្នែក B) មាន ៥៩ បន្ទាត់ ( ៣០ បន្ទាត់ សរសេរជាភាសាខ្មែរ ហើយ ២៩ បន្ទាត់ សរសេរជាភាសាសំស្ក្រឹត ) ។ អក្សរនៅលើផ្នែកទាំងពីរនេះ ពុំសូវល្អដូចជាអក្សរនៅផ្នែកទីមួយទេ ហើយនៅទីនេះ អក្សរក្នុងមួយបន្ទាត់នៅលើសិលាស្តម្ភ មានបរិមាណប្រហាក់ប្រហែលគ្នានឹងអក្សរបីបន្ទាត់ នៅលើបន្ទាត់ក្រដាសសធម្មតា ។

សិលាចារឹកឆ្នាំ ១០១៤ នៃគ.ស ( ឬ Ka 17 ) បានត្រូវអាន និងថតម្តងជាពីរដង ដោយអ្នកនិពន្ធនៃនិក្ខេបបទនេះ ( បណ្ឌិត ឡុង សៀម ) ។ ក្រុមនិស្សិតសាកលវិទ្យាល័យភូមិន្ទ បានទៅផ្តាមនៅឆ្នាំ ១៩៩៥ ហើយនៅឆ្នាំ ១៩៩៧ សិលាចារឹកនេះ ក៏ត្រូវបានផ្តាមសាជាថ្មីទៀត ដោយក្រុមអ្នកស្រាវជ្រាវដឹកនាំដោយបណ្ឌិត *ឡុង សៀម* និងបណ្ឌិត *មីសែល ត្រាណេ* នៅពេលជាមួយគ្នានេះ ក៏សូមបញ្ជាក់ផងដែរថា ក្រោមការដឹកនាំរបស់អ្នកស្រាវជ្រាវទាំងពីររូបនេះ នៅក្នុងក្របខ័ណ្ឌនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងវប្បធម៌ សិលាចារឹកមួយចំនួនធំ បានត្រូវផ្តាមឡើងជាពិសេសដោយក្រុមនិស្សិត ហើយនៅក្នុងចំណោមនេះ នៅមានសិលាចារឹកថ្មីៗមួយចំនួនទៀតផង ។ គួរកត់សំគាល់ថា សិលាចារឹកប្រទេសកម្ពុជា ចំនួនប្រហែល ១២០០ បានត្រូវតម្កល់ទុកនៅបណ្ណាល័យនៃសាលាចុងបូព៌ាបារាំង នៅទីក្រុងប៉ារីស ។

ការសិក្សាតាមសិលាចារឹក Ka 17 បានត្រូវកំរិតតែត្រឹមអត្ថបទផ្នែក A ហើយអត្ថបទផ្នែក B នឹងទុកសំរាប់ធ្វើជាការសិក្សាបន្តនៅពេលក្រោយដ៏ខ្លី ។

អត្ថបទនៅលើផ្ទៃក A បានត្រូវសរសេរជាភាសាខ្មែរសុទ្ធសាធ ប្រកបដោយឃ្លាប្រយោគ ដែលច្បាស់ល្អខុសប្រក្រតី គឺជាអត្ថបទដែលបានរៀបរាប់អំពីការទិញ លក់ ដីភូមិមែនហើយ ក៏ប៉ុន្តែគេអាចសន្មតបានថា សិលាចារឹកនេះជាអត្ថបទអក្សរសិល្ប៍ ដែលស្ថិតនៅលើតថភាពក្នុងជីវភាពជាក់ស្តែងរបស់មហាមន្ត្រីមួយរូប នៅក្នុងរជ្ជកាលព្រះបាទ *សូរ្យវរ្ម័នទី១* ( ១០០២ . ១០៥០ ) ។ នៅក្នុងក្របខ័ណ្ឌខេមរនីយកម្ម ឬការអភិវឌ្ឍន៍ភាសាខ្មែរអោយទៅជាភាសាជាតិ យើងអាចឃើញបានថា សិលាចារឹកសំខាន់ៗទាំងឡាយនៃរជ្ជកាលព្រះបាទ *សូរ្យវរ្ម័នទី១* ដូចជា សិលាចារឹកស្តីអំពី សម្បថតម្រួតពល ជាដើម ( K 292 គ.ស ១០១១ ) បានត្រូវសរសេរឡើងជាភាសាខ្មែរហើយ មិនមែនជាភាសាសំស្ក្រឹតទេ ។

ភាគទី១ នៃសិលាចារឹក Ka 17 បានពណ៌នាអំពីពិធីដ៏ឧឡារិកនៅក្នុងសវនាការ នៃព្រះបាទ *ស្រីសូរ្យវរ្ម័ទេវ* ( សូរ្យវរ្ម័នទី១ ) នៅប្រាសាទនៃចតុទ្វារនៃទីក្រុង *ជេយេន្ទ្រនគរី* នៅចំពោះមុខមហាមន្ត្រី នៃព្រះបរមរាជវាំង នៅថ្ងៃ ពុធ ទី ៥ កើត ខែមិគសិរ ឆ្នាំ ៩៣៦ នៃមហាសករាជ ។ នៅក្នុងពិធីសវនាការ ព្រះមហាក្សត្របានមានព្រះបន្ទូលបង្គាប់ដល់មន្ត្រីជាន់ខ្ពស់ទាំងឡាយដែលជាមហាបណ្ឌិត អោយចេញទៅធ្វើចំណារនៃអាជ្ញាធររបស់ព្រះអង្គ នៅព្រះវិហារសិវលិង្គ នៅស្រុកមធ្យទេស ដើម្បីផ្សព្វផ្សាយអំពីព្រំប្រទល់ដីទាំងឡាយ ដែលជាកម្មសិទ្ធិខាងដីធ្លីរបស់មហាមន្ត្រីជាន់ខ្ពស់មួយរូបគឺ ព្រះកំស្តែង អញ *លក្ស្មីបតិវរ្ម័ន* ជាបន្តបន្ទាប់តាំងពីឆ្នាំ ៩៣២ ដល់ឆ្នាំ ៩៣៦ នៃមហាសករាជ ដើម្បីជាគុណប្រយោជន៍ដល់ព្រះវិហារសិវលិង្គ គឺមានជាអាទិ៍ ភូមិនានា ភូមិគ្រឹះទាំងឡាយ ព្រៃព្រឹក្សា ព្រមទាំងស្រែទាំងឡាយ ។ ល ។

សិលាចារឹក Ka 17 បានពណ៌នាអំពីសាសនាព្រាហ្មណ៍ ដែលបានប្រ. ព្រឹត្តនៅព្រះវិហារសិវលិង្គ មានជាអាទិ៍ ពិធីបូជាយញ្ញដល់ព្រះព្រហ្ម ពិធីបូជាយញ្ញដល់

ព្រះមាតា ( ឬពិធីបូជាយញ្ញរំលឹកដល់គុណមាតា ) និងពិធីអភិសេកដល់ព្រះសុវណ្ណ-លិង្គ ។ ពិធីអស់ទាំងនេះបានត្រូវប្រារព្ធឡើងដើម្បីធ្វើសច្ចានុមតិ លើច្បាប់កាន់កាប់កម្មសិទ្ធិលើទ្រព្យសម្បត្តិ ដែលជាភូមិករ(*) ថ្មីៗ ដែលជារបស់វត្តអារាម ។

មែនពិត តាមអត្ថន័យនៃសិលាចារឹក Ka 17 ច្បាប់ប្រើប្រាស់កម្មសិទ្ធិនៃវត្តអារាម គឺវត្តសិវលិង្គ បានមានដល់មហាមន្ត្រីដែលជាសេដ្ឋី នាម *លក្សីបតិវរ្ម័ន* ដែលជាមេក្លោងនៃមហាគ្រួសារកាន់សាសនាធំមួយ ។ កថាខ័ណ្ឌនៃអត្ថបទ ( បន្ទាត់ ៤៦, ៤៧, ៥៦ ) បានបញ្ជាក់ច្បាស់ថា ញាតិសាលោហិត ឬកូនចៅទាំងឡាយរបស់មហាមន្ត្រី *លក្សីបតិវរ្ម័ន* តទៅអនាគត គឺមានសិទ្ធិពេញលេញក្នុងការកាន់កាប់ទ្រព្យសម្បត្តិជាភូមិករ របស់វត្តអារាមសិវលិង្គ នៅមធ្យមទេស ។

អត្ថបទសិលាចារឹក Ka 17 តាំងពីបន្ទាត់ទី៤ រហូតដល់ចប់ បានពណ៌នារៀបរាប់ដ៏ល្អិតល្អន់អំពីការប្រឹងប្រែងឥតឈប់ឈរ របស់មហាមន្ត្រី *លក្សីបតិវរ្ម័ន* ដើម្បីអាចកាន់កាប់ទ្រព្យសម្បត្តិ ដែលជាដីធ្លីរបស់ជនានុជន ( ជាពិសេសគឺ ដីធ្លីរបស់វណ្ណៈអនុជន ដែលប្រកបដោយឋានន្តរនាម វាប vap ) សំរាប់ជាគុណប្រ-យោជន៍ដល់វត្តអារាម សិវនិយម ។ សកម្មភាពក្នុងការកាន់កាប់ដីធ្លីទាំងនេះ បានលេចចេញជារូបរាងដោយការទិញដូរ និងដោយមធ្យោបាយផ្សេងៗ ដែលយើងនឹងធ្វើអត្ថាធិប្បាយតទៅនេះ អំពីព្រឹត្តិការណ៍សង្គមប្រវត្តិសាស្ត្រខ្លះៗ ដូចតទៅ ៖

១. សកម្មភាពខាងលក់ដូរ និងទិញដីធ្លី បានប្រព្រឹត្តទៅតាមការបង់តម្លៃដោយថ្នូរ ។ ជំនួសដោយរូបិយវត្ថុ គឺមានការប្រើប្រាស់លោហធាតុមានតម្លៃ ចាន ឆ្នាំង ក្រណាត់ សំពត់ សត្វពាហនៈ ( គឺមានទាំង ក្របី សេះ ដំរី គោ ) ។ នៅក្នុងអត្ថបទសិលាចារឹក Ka 17 ពុំមានបញ្ជាក់អំពីករណី នៃការយកខ្ញុំបំរើទៅប្រើប្រាស់សំរាប់ធ្វើជារូបិយប័ណ្ណក្នុងការទិញដូរដីធ្លីឡើយ ទោះបីករណីបែបនេះគឺជាព្រឹត្តិ-

---

(*) « ភូមិករ » គួរសរសេរជា « ភូមិឋាន » ឬ « ភូមិលំនៅ » ទើបត្រឹមត្រូវ

ការណ៍ ដែលមាននៅក្នុងសម័យអង្គរក៏ដោយ ។

២. របៀបរបបចងការប្រាក់ ឬមាស បានប្រព្រឹត្តទៅដោយយកការខ្ពស់បំផុត គឺយកការ ១០០% ហើយដែលមានបញ្ជាក់ដោយពាក្យខ្មែរថា « បុល » ដូចជា បុលមាស ជាដើម ។ ជាឧទាហរណ៍ អត្ថបទសិលាចារឹក Ka 17 បានសរសេរថា នៅឆ្នាំ ៩៣៤ នៃមហាសករាជ មហាមន្ត្រី *លក្សីបតិវរ្ម័ន* បានអោយបុគ្គល *វាប លេ* បុលមាសសុទ្ធ ២លិង ដើម្បីបង់ពន្ធដារជូនរាជការ ដោយយកការ ១០០% គឺគុណនឹង ២ ហើយ *វាប លេ* ត្រូវតែសងមាស ៤ តម្លឹងដល់មហាមន្ត្រី *លក្សីបតិវរ្ម័ន* ។ ក៏ប៉ុន្តែ នៅពេលនេះ *វាប លេ* គ្មានមាសសង ហើយគាត់ត្រូវតែប្រគល់ដីមួយកន្លែងរបស់គាត់ទៅមហាមន្ត្រី *លក្សីបតិវរ្មន* ។ នៅក្នុងអត្ថបទសិលាចារឹកដទៃ នៅក្នុងសម័យអង្គរ មានករណីនៃរបៀបរបបចងការប្រាក់ ដោយយកការប្រាក់ ១០០% ហើយរបៀបរបបចងការប្រាក់ អាចធ្វើឡើងដោយវិធីយកការ ហើយវិធីចងការនេះបានធ្វើឡើងមិនមែនចំពោះតែប្រាក់ប៉ុណ្ណោះទេ គឺចំពោះមាស ចំពោះវត្ថុមានតម្លៃ ចំពោះសត្វពាហនៈ និងចំពោះដីធ្លី ជាដើម ។ ល ។

៣. ទ្រព្យសម្បត្តិជាដីធ្លី និងភូមិកររបស់ជនានុជន ដែលត្រូវអង្គការតុលាការមានមន្ទិលសង្ស័យ ហើយចោទប្រកាន់ថាជាខ្មាំង ឬជាជនដែលខ្សឹខ្សាំងប្រឆាំងព្រះរាជា បានត្រូវរឹបអូស និងពិន័យបញ្ចូលមកជាទ្រព្យសម្បត្តិសាធារណៈ ។ តាមសិលាចារឹក Ka 17 នាឆ្នាំ ៩៣៣ នៃមហាសករាជ គ្រួសារមួយមាននាមត្រកូលជា *ពោ* (vo) បានត្រូវផ្តន្ទាទោស និងពិន័យ ដោយហេតុថា សមាជិកនៃគ្រួសារនេះបានមានសញ្ចេតនាខ្សឹខ្សាំង ប្រឆាំងនឹងព្រះបាទ *សូរ្យវរ្ម័នទី១* ម្ល៉ោះហើយ ដីធ្លីទាំងឡាយ ព្រមទាំងព្រះវិហារខាងព្រះពុទ្ធសាសនា ឈ្មោះ *សុខាវាស* កសាងដោយត្រកូល *ពោ* បានត្រូវរឹបអូស ហើយប្រគល់អោយទៅមហាមន្ត្រីជាសេដ្ឋី នាម *លក្សីបតិវរ្ម័ន* ហើយតមកព្រះមហាក្សត្របានបញ្ជាដល់មហាមន្ត្រីនេះ អោយស្ថាបនារូប

សិវលិង្គមកដាក់ជំនួសនៅទីអាសនៈ ដែលតម្កល់រូបបដិមារបស់ព្រះសម្មាសម្ពុទ្ធ នៅទីនោះវិញ ។

តាមរយៈនៃព្រឹត្តិការណ៍រៀបរាប់ដោយសិលាចារឹក Ka 17 ខាងលើនេះ គេអាចសន្និដ្ឋានបានថា ព្រះបាទ *សូរ្យវរ្ម័នទី១* មានហឫទ័យទោរទន់ទៅខាងសាសនាព្រាហ្មណ៍ជាងពុទ្ធសាសនា ហើយទោះបីជាព្រះអង្គប្រកបដោយមរណនាមថា ព្រះបាទ *បរមនិវាំបទ* (paramanivarnapada) បានសេចក្តីថា ព្រះមហាក្សត្រដែលចូលព្រះបរិនិព្វានហើយ ពាក្យនេះ គេច្រើននិយមថាជាបច្ចេកពាក្យខាងពុទ្ធ-សាសនា ក៏ប៉ុន្តែពាក្យ និព្វាន (និវាន) ក៏មានប្រើនៅក្នុងព្រហ្មញ្ញសាសនាផងដែរ ។ តាមឯកសារសិលាចារឹក ព្រះបាទ *សូរ្យវរ្ម័នទី១* ជាព្រះមហាក្សត្រដែលធ្វើពិធីសក្ការបូជាព្រះសិវ ។ ព្រះអង្គបានប្រកាន់តាមសិវនិយមយ៉ាងខ្ជាប់ខ្ជួន ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានយកលទ្ធិសិវនិយម មកធ្វើជាគ្រឹះនៃរបបគ្រប់គ្រងរបស់ព្រះអង្គ ដែលបានធ្វើអោយប្រទេសកម្ពុជា ប្រកបដោយវិសាលភាពដ៏ធំធេងជាងក្នុងរជ្ជកាលព្រះមហាក្សត្រដទៃ ដែលបានឡើងសោយរាជ្យមុនព្រះអង្គ មិនតែប៉ុណ្ណោះ ព្រះអង្គបានទទួលកេរដំណែលដែនដី លើហ្គ័រ នៅម៉ាឡាយូ ពីព្រះបិតាព្រះអង្គទៀតផង ។

តាមសិលាចារឹកព្រះវិហារ K 380 ព្រះបាទ *សូរ្យវរ្ម័នទី១* ដោយការធ្វើសមាធិ និងពិធីបូជាយញ្ញ ព្រះអង្គបានធ្វើអោយព្រះអាទិទេពនៅ *លិង្គបុរៈ* (Linga pura) គឺ *វត្តភូ* យាងមកសណ្ឋិតនៅឯព្រះវិហារ *សិខរីស្វរៈ* (Çikhariçvara) គឺនៅឯប្រាសាទព្រះវិហារ លើភ្នំដងរែកវិញ ។

***

# ឯកសារពិគ្រោះ (Bibliographie)

Coedès, G

1937, Inscriptions du Cambodge, Ecole Française d'Extrême-Orient, Vol. 1 Hanoi.

1942, Inscriptions du Cambodge, Ecole Française d'Extrême-Orient, Vol. 2, Hanoi.

1951, Inscriptions du Cambodge, Ecole Française d'Extrême-Orient, Vol. 3, Paris.

1952, Inscriptions du Cambodge , Ecole Française d'Extrême-Orient, Vol. 4, Paris.

1953, Inscriptions du Cambodge, Ecole Française d'Extrême-Orient, Vol. 5, Paris.

1954, Inscriptions du Cambodge, Ecole Française d'Extrême-Orient, Vol. 6, Paris.

1964, Inscriptions du Cambodge, Ecole Française d'Extrême-Orient, Vol. 7, Paris.

1966, Inscriptions du Cambodge, Ecole Française d'Extrême-Orient, Vol. 8, Paris.

Long, Seam

1989, Toponymes et realités socio-économiques et culturèlles de l'ancien Cambodge (d'après les textes des inscriptions) - Premier Symposium franco-soviétique sur l'Asie du Sud-Est : " La réappropriation du patrimoine culturel dans le contexte du mouvement nationaliste et de la colonisation en Asie du Sud-Est, Moscou, p.144-150.

Long, Seam

1992, Dictionnaire du vieux-khmer d'après les inscriptions du Cambodge du VIème au XIème siècle, Moscou, ( ce dictionnaire traduit en français et en ruse, a été déposé à la Bibliothèque Centrale de l'Académie des Siences de Russie, sous le Nº 46818 (4).

Maha Bidu, Krasem

1958, Silacarik Nagar vat. Phnom Penh, Institut Bouddhique.

Majumdar, R.C
1953, Inscriptions of Kambuja, Calcuta.

Maspéro, C.,
1925, La Géographie Politique de l'Indocine aux environs de 960 A.D. Etudes Asiatiques, t.2; Paris

24- Matrtin Marie A.,
1971, Introduction à l'Ethnobotanique du Cambodge, thèse pour le Doctorat du 3è cycle. Paris.

Parmetier, M.,
1916, Cartes de l'Empire Khmer d'après la situation des inscriptions datés, - BEFEO, t.16. 3.

28- Savros, Lewitz
1970, Textes en Khmer Moyen. Inscriptions modernes d'Angor Vat, - BEFEO, LVII.

***

- ពុទ្ធភាសិត :

ឈ្នះខ្លួនឯង ជាមហាជោគជ័យមួយ ធំជាងឈ្នះសត្រូវមួយពាន់នាក់ ក្នុងលានប្រយុទ្ធទៅទៀត ។

# សាស្ត្រារឿង
# ព្រះមហាសុបក្សីតាបស
( ត - ចប់ )

ដល់ខ្លួនលោចាកផុតលោកយើងនេះបាត់ទៅ ទើបសេចក្តីខ្មាសនោះវារលត់អស់ពីខ្លួនដែរ ប៉ុន្តែកេរ្តិ៍ឈ្មោះអាក្រក់របស់ជននោះ មិនអាចលុបបាត់ទៅជាមួយនឹងការរលាយរូបនៃបុគ្គលនោះបានទេ ។ នេះឯងហើយដែលជាសតិអារម្មណ៍ ដ៏ធំចម្បងរបស់អាត្មា ។ រឿងមួយទៀត ដែលសំខាន់ដែរនោះ គឺថា ប្រសិនបើអាត្មាក្បត់ពាក្យសន្យារបស់អាត្មាជាមួយលោកនាយ វាសនាអាក្រក់ទាំងឡាយនឹងកើតមានដល់ភាគីទាំងសងខាងរបស់យើង ។ សូមលោកនាយពិចារណាមើលចុះ វាមិនខុសពីអ្វីដែលញោមជាព្រឹទ្ធាចារ្យនៅក្នុងភូមិនេះ ទើបនឹងផ្តល់ជាចម្លើយទៅនឹងសំណួររបស់លោកនាយ ព្រោះរឿងនេះ វាងាយយល់ទេ ។ ប្រសិនបើបងប្អូនជាអ្នកស្រុកអ្នកភូមិទាំងអស់គ្នា បានជ្រួតជ្រាបអំពីផែនការរបស់លោកនាយជាមុននោះ បងប្អូនយើងប្រាកដជាមិនទុកឱកាសឱ្យពួកលោកនាយប្រមូលយកអស់ទ្រព្យរបស់ជាកេរកោះរបស់គេបានមែន ។ សោតឯផែនការរបស់លោកនាយ វាក៏ត្រូវតែទទួលបរាជ័យផងដែរ ។ មិនតែប៉ុណ្ណោះ អំពើឃោរឃៅក៏នឹងត្រូវកើតមានឡើង ដោយចៀសមិនផុតជាដាច់ខាតហើយណាំលោកនាយ ! ។ ព្រោះអ្វី ? ព្រោះថា បណ្តា ជនដែលនៅក្នុងស្រុក ក្នុងភូមិនេះ គេមុខជាមិនបណ្តោយឱ្យលោកនាយចូលមកប្រមូលយកអស់ទាំងទ្រព្យរបស់ជាកេរកោះរបស់គេអស់ដោយងាយៗបែបនេះទេ ។ បណ្តាជនគេមុខជាកាន់អាវុធប្រយុទ្ធគ្រប់ដៃ គេនឹងត្រៀមចាំវ៉ៃតតាំងប្រឆាំងនឹងពួកលោកនាយ ដែលជាហេតុនាំឱ្យអន្តរាយដល់អាយុជីវិត ដល់ខ្លួនប្រាណនៃភាគីទាំងសងខាងផង ឬបើនិយាយម្យ៉ាងទៀតថា យើងទាំងអស់គ្នានឹងក្លាយទៅជាអ្នករងគ្រោះទាំង

អស់ មានទាំងអ្នកស្លាប់ មានទាំងអ្នកនៅរស់ អ្នកខ្លះក៏រងរបួសធ្ងន់ទៅ ខ្លះទៀតក៏នឹងរងរបួសស្រាលមិនលែងឡើយ ។ រួចហើយ ជាផលវិបាកនៃការប្រើហឹង្សាយកឈ្នះចាញ់គ្នានេះ វានឹងកើតមានការចងគំនុំគុំគួនគ្នា ដែលនឹងញ៉ាំងឱ្យមានការសងសឹកគ្នា ចងអាឃាតវវាងគ្នានឹងគ្នា មិនចេះអស់មិនចេះហើយសោះឡើយ ។ ដោយសារតែអាត្មា បានប្រមើលឃើញវាសនាអាក្រក់ក្នុងបច្ចុប្បន្នកាល និងទៅថ្ងៃមុខដូច្នេះឯងហើយ ទើបបានអាត្មាយល់ដោយប្រាកដថា ការកាន់យកនូវពាក្យសច្ចាដែលអាត្មាបានធ្វើជាមួយលោកនាយរួចមកហើយ តាំងអំពីវេលាថ្ងៃនោះ គឺជាការប្រសើរពន់ពេកណាស់ ។ សូមបងប្អូន ញាតិញោមទាំងអស់ ថ្លឹងថ្លែងមើលចុះ ។ ចំពោះឯទ្រព្យរបស់ យើងអាចរកបានតាមសេចក្ដីព្យាយាម គឺខំរកស៊ីតាមសម្មាអាជីវោ ឬដោយសេចក្ដីសុចរិតត្រឹមត្រូវ ហើយទ្រព្យសម្បត្តិទាំងនេះនឹងអាចស្ថិតស្ថេរគង់វង្សនៅបានយ៉ាយូរអង្វែង ព្រមទាំងអាចកើតបានកាន់តែច្រើនថែមឡើងទៀតផង ។ ចំណែកឯអាយុជីវិតនៃយើងរាល់គ្នា ឱ្យតែវាផុតរលត់បាត់នៅពេលណាមួយហើយ យើងមិនអាចរកយកមកវិញបានឡើយ ទោះបីជាតាមដោយវិធីណាក៏ដោយ ព្រោះហេតុដូច្នេះឯងហើយ ទើបបានជាអាត្មាចៀសវាងឱ្យផុតនូវគុណវិបត្តិអស់ទាំងនេះណា ! ។ សូមលោកនាយ និងញាតិញោមទាំងឡាយមេត្តាជ្រាប និងអភ័យទោសឱ្យអាត្មា តាមការគួរផងទៅចុះ" ។

កាលបើបានឮការលាតត្រដាងអំពីការពិតដូច្នេះហើយ ប្រជាករជាអ្នករងគ្រោះទាំងអស់ ក៏កើតមានប្រតិកម្មខុសៗគ្នា នៅក្នុងអារម្មណ៍រៀងៗខ្លួនរបស់គេ ។ អ្នកខ្លះគិតថា ព្រះមហាសុបក្សីរអង្គនេះ មិនគួរឡើយមកក្បត់ជាមួយនឹងញោមញាតិរបស់ខ្លួនអញ្ចឹងសោះ :" ការដែលព្រះអង្គធ្វើដូច្នេះ មិនគួរអីនឹងត្រូវអនុគ្រោះឱ្យផងបានទេ ។ ធ្វើបែបនេះ បានចំជាមានន័យថាព្រះអង្គឃុបឃិត សមគំនិតជាមួយពួកចោរ គឺព្រះអង្គជាអ្នកបើកឱកាសឱ្យទៅពួកចោរមកឆក់ប្លន់មាតាបិតា ព្រមទាំងញាតិ

របស់ព្រះអង្គផ្ទាល់ ។ ព្រះអង្គគួរណាស់តែលះបង់នូវពាក្យសន្យាជាមួយចោរនោះចោលទៅ ។ ការក្បត់ជាមួយជនពាលមានចិត្តជាចោរសាមាន្យ វាមិនអាចឱ្យទៅជាបាបកម្មអ្វីទេ ជាពិសេស ព្រះអង្គបានជ្រាបពីផែនការរបស់ពួកចោរនេះជាមុនហើយទៀតផង ។ បើទោះជាបាប ក៏វាមិនធ្ងន់ធ្ងរអ្វីជាងការទុកឱ្យមាតាបិតា និងញោមញាតិទាំងអស់របស់ខ្លួនទទួលរងគ្រោះដោយចោរកម្មដ៏សាហាវនេះដែរ រហូតដល់ម្នាក់ៗទៅជាក្រុរបាម ។ តើឱ្យគេទៅរកស៊ីយ៉ាងម៉េចនឹងបានមានឡើងវិញនោះ ? ព្រះអង្គគួរតែថ្លឹងថ្លែងអំពីផលវិបាកទាំងពីរនេះឱ្យឃើញផង ។ ការក្បត់ពាក្យសន្យាជាមួយចោរ ម្ដេចក៏បានទៅជាបាបកើត ? " ។ ប្រជាករខ្លះទៀត យល់ផ្ទុយពីខាងលើនេះថាព្រះមហាសុបក្សិអង្គនេះព្រះអង្គបានថ្លឹងថ្លែងត្រូវមែន ។ " បើកុំតែព្រះអង្គមានព្រះទ័យស្មោះត្រង់ទៅលើពាក្យសច្ចៈនោះ កុំអីសង្គ្រាមដ៏សាហាវ តូចមួយនឹងកើតមានឡើងជាក់ជាមិនខាន ដែលប្រាកដជានឹងបណ្ដាលឱ្យបងប្អូនយើងទទួលរងនូវការខូចខាតខ្លាំងជាងនេះទៅទៀត, គឺនឹងត្រូវខូចខាតយ៉ាងខ្លាំង ទាំងទ្រព្យសម្បត្តិទាំងអាយុជីវិត ។ ណ្ហើយ ! យើងសុខចិត្តឱ្យបង់តែទ្រព្យទៅចុះ កុំឱ្យតែខ្លួន ឬកូនចៅយើងស្លាប់ ឬរងរបួសនោះ ។ ព្រឹត្តិការណ៍ ដ៏សែនអភ័ព្វនេះ យើងគួរតែចាត់ទុកវាដូចជាការចម្លងគ្រោះសំរាប់យើងរាល់គ្នាផងទៅចុះ ឱ្យតែបានគង់វង្សអាយុ បើវាសនាយើងនៅមាន យើងគង់តែនឹងរកស៊ីមានបានវិញទៀត ជាមិនខានទេ " ។

បងប្អូនយើងមួយចំនួនទៀត ហាក់ដូចជាពុំមានយោបល់អ្វីទាំងអស់ ។ អ្វីៗចំពោះគេកំពុងតែច្របូកច្របល់ រកគិតអ្វីក៏ពុំយល់ដែរ ។ គេមិនដឹង ថាតើត្រូវវិនិច្ឆ័យពីព្រឹត្តិការណ៍នេះ ដូចម្ដេចទៅវិញទេ ។

ផ្ទុយទៅវិញ ប្រតិកម្មរបស់មេចោរ បែរជាពញ្ញាក់ស្មារតីរបស់បងប្អូនប្រជាករទាំងអស់ឱ្យភ្ញាក់ឡើងស្រឡាំងកាំងគ្រប់គ្នា ហាក់បីដូចជាមានអ្វីមួយមកកន្ត្រាក់អារម្មណ៍របស់គេ ឱ្យដូចជាគេកំពុងត្រូវភ្ញាក់ពីដំណេកដ៏ជ្រៅមួយអញ្ចឹងដែរ

បានជាយ៉ាងដូច្នោះ ពីព្រោះ គេឃើញមេចោរនោះដើរឱនលំទោនសំដៅទៅព្រះមហាសុបក្សី ទាំងកើតក្ដីរំភើបនៅក្នុងចិត្ត ។ លុះទៅដល់ហើយ មេចោរក៏លុតជង្គង់នៅជិតព្រះបាទារបស់ព្រះអង្គ រួចលើកហត្ថាទាំងទ្វេប្រណម្យថ្វាយបង្គំយ៉ាងគោរពរាបសាបំផុត ព្រមដោយនូវវាចាយ៉ាងផ្អែមល្ហែម ពោរពេញដោយក្ដីកតញ្ញូថា : "យើងខ្ញុំព្រះករុណាបានប្រព្រឹត្តនូវអំពើជាអកុសលដ៏សែនថោកទាបណាស់ ។ ស្ថិតនៅចំពោះមុខព្រះអង្គនាពេលនេះ ខ្ញុំព្រះករុណាសូមសារភាពនូវទោសកំហុសទាំងអស់ ហើយខ្ញុំព្រះករុណាសូមប្ដេជ្ញាចិត្តថ្វាយព្រះអង្គជាមហោឡារិកថា ចាប់ពីពេលនេះតទៅមុខ ខ្ញុំព្រះករុណាលែងប្រព្រឹត្តអំពើលាមកដូច្នេះទៀតហើយ ។ អស់កាលជាច្រើនឆ្នាំកន្លងមកនេះ អវិជ្ជា គឺសេចក្ដីល្ងង់ខ្លៅបានដឹកនាំយើងខ្ញុំព្រះករុណាឱ្យឃ្លាតចាកឆ្ងាយពីសេចក្ដីល្អ ។ ទើបតែក្នុងថ្ងៃនេះឯងតែម្ដង ដែលព្រះជាម្ចាស់បាននាំយើងខ្ញុំព្រះករុណាឱ្យមានវាសនាមកជួបជាមួយនឹងអរិយបុគ្គល ជាអ្នកមានចិត្តស្អាតបរិសុទ្ធដ៏កម្ររកបាន ដែលកំពុងគង់នៅទីនេះស្រាប់ ។ ខ្ញុំព្រះករុណាកើតចិន្តាស្នេហាចំពោះបព្វជាភេទដូចព្រះអង្គណាស់ ។ អាស្រ័យហេតុនេះ សូមព្រះអង្គមេត្តាយល់ព្រមប្រោសសត្វលោក ដោយព្រមទទួលយកខ្ញុំព្រះករុណាឱ្យបានចូលសិក្សាក្នុងឋានៈជាសិស្សគណរបស់ព្រះអង្គ ចាប់ពីថ្ងៃនេះតទៅ ។ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសឱ្យខ្ញុំព្រះករុណាចូលខ្លួនសាងព្រះផ្នួស ក្នុងសំណាក់របស់ព្រះអង្គជារៀងរហូត ។ នេះគឺជាកិត្តិយសមួយដ៏សែនធំធេងពន់ពេកណាស់ កាលបើបានបំរើព្រះអង្គ ហើយខ្ញុំព្រះករុណាសូមប្ដេជ្ញាជាបន្ថែមទៀតថា នឹងខិតខំរៀនសូត្រ កាន់សីលទាន ធ្វើវត្តប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួនមួនមាំ សមស្របតាមគន្លងព្រះពុទ្ធសាសនា មិនឱ្យឃ្លៀងឃ្លាតដោយប្រការណាមួយឡើយ ។ សូម
ព្រះអង្គមេត្តាប្រោសសត្វ តាមការគួរផងចុះ " ។

អ្នកភូមិទាំងប៉ុន្មាន សឹងតែមិនជឿត្រចៀកគេបន្តិចសោះ នៅពេលដែល

គេបានស្តាប់ឮមេចោរចេះថ្លាថ្លែងដោយនូវពាក្យពេចន៍ ដ៏ពិរោះពិសាដូច្នោះ ។ គ្មាននរណាម្នាក់នឹកស្មានថា មេចោរឧទ្ទានចេញមកនូវពាក្យពេចន៍បែបនេះទេ ។ គេឆ្ងល់ណាស់ ថាតើពាក្យពេចន៍ទាំងអស់នេះ វាពិតជាចេញមកពីក្រអៅនៃបេះដូងដ៏បរិសុទ្ធរបស់មេចោរមែន ឬក៏គ្រាន់តែជាសំដីដែលឧទ្ទានចេញមក ក្នុងល្បិចបោកប្រាស់ប៉ុណ្ណោះទេ ។ ការប្រែប្រួលដ៏ឆាប់រហ័សហួសពេកយ៉ាងនេះ ហាក់ដូចជាមិនអាចប្រព្រឹត្តទៅកើតទេ ជាពិសេស ចំពោះមនុស្សទាំងឡាយណាដែលធ្លាប់តែងប្រកាន់យកនូវឥរិយាបថរបឹងរឹងរូស ដូចក្រុមចោរទាំងប្រាំរយនាក់នោះជាដើម ។ អ្នករងគ្រោះទាំងអស់កំពុងទន្ទឹងទាំងអន្ទះសា ចាំមើលព្រឹត្តិការណ៍ដ៏ចម្លែកនេះ ថាតើវានឹងវិវឌ្ឍទៅជាយ៉ាងណាទៀត ទាំងអារម្មណ៍របស់គេភ័យផង អរផង ។ ក្នុងពេលនោះព្រះមហាសុបក្សិមិនទាន់ទាំងបានមានពុទ្ធដីកាឆ្លើយតបថាអ្វីនៅឡើយផង ក៏ស្រាប់តែមេចោរបែរមុខទៅរកកូនចោរទាំងអស់គ្នា រួចមានវាចាយ៉ាងសមគួរ ប៉ុន្តែដាច់ខាតថា ៖

"អស់អ្នករាល់គ្នា ជាទីស្នេហា ! ខ្ញុំសឹងតែរកវាចាអ្វីមកថ្លែង ដើម្បីជាអំណរគុណដល់អស់លោករាល់គ្នាមិនបានទេ ចំពោះសេចក្តីស្មោះត្រង់ និងសេចក្តីស្នេហារបស់អ្នករាល់គ្នាចំពោះរូបខ្ញុំ ។ យើងបានធ្វើការជាមួយគ្នាអស់កាលជាយូរមកហើយ នៅតែក្នុងការប្រព្រឹត្តអំពើទុច្ចរិត គឺចោរកម្មនេះ ដែលជាមុខរបរនៃយើង ។ យើងបានយល់ចិត្តយល់ថ្លើមគ្នាទៅវិញទៅមកយ៉ាងល្អប្រពៃ ធ្វើឱ្យមេត្រីភាព និងសាមគ្គីភាពរវាងយើងទាំងអស់គ្នា ស្ថាល់នូវភាពរឹងប៉ឹងមួយដែលមិនមាននរណាអាចមកកំទេច ឬបំបែកបំបាក់បានឡើយ ។ ប៉ុន្តែពេលនេះ អស់អ្នករាល់គ្នាបានឮពីសេចក្តីឧទ្ទិសរបស់ខ្ញុំស្រាប់ហើយ ។ នេះគឺជាពាក្យពិតរបស់ខ្ញុំ ដែលនឹងឥតមានការងាករេបន្តិចណាទេ ។ ខ្ញុំកំពុងចាត់ទុកព្រះភិក្ខុអង្គនេះ ថាជាបុគ្គលដ៏ឧត្តុង្គឧត្តម ថាព្រះអង្គគឺជាទីសក្ការៈសំរាប់រូបខ្ញុំ ។ ហេតុនេះ ខ្ញុំសូមអធ្យាស្រ័យពីសំណាក់

របស់អស់អ្នករាល់គ្នាជាមុន ហើយខ្ញុំសុំឱ្យអស់អ្នករាល់គ្នា មេត្តាបោះបង់នូវមុខរបរទុច្ចរិត ដូចដែលយើងបានប្រព្រឹត្តកន្លងមកហើយនោះចោលចេញទៅ ។ សូមអស់អ្នករាល់គ្នាខំបង្វែរអារម្មណ៍ឆ្ពោះទៅលើការរកស៊ីតាមសម្មាអាជីវោ ដូចបងប្អូនយើងទាំងនេះវិញ ។ ខ្ញុំសុំឱ្យអ្នករាល់គ្នារីករាយចិត្តនឹងប្រគល់ទ្រព្យរបស់ ដែលឆក់ឆក់ប្លន់បានទាំងប៉ុន្មាននោះ ទៅបងប្អូនយើងវិញរៀង១ខ្លួន កុំឱ្យមាននៅសេសសល់ដល់បន្តិចណាឡើយ ។ នេះឯងណា៎ ជាសំណូមពរដ៏ទទូចរបស់ខ្ញុំមុនគេ ។ រួចហើយបន្ទាប់ពីនេះទៅ វាស្រេចតែនៅលើការសំរេចចិត្តរបស់អស់អ្នករាល់គ្នាទេ ថាតើអ្នករាល់គ្នាត្រូវត្រឡប់ទៅរស់នៅតាមដោយផ្ទះសម្បែងវិញ ឬក៏សុខចិត្តទៅជាមួយខ្ញុំ ។ ប៉ុន្តែ ទោះបីជាអស់អ្នករាល់គ្នាចង់សំរេចថាយ៉ាងណា១នោះ យើងគួរតែចាំស្តាប់ពុទ្ធដីការបស់ព្រះភិក្ខុសង្ឃអង្គនេះសិន " ។

មេចោរក៏ក្រាបថ្វាយបង្គំព្រះមហាសុបក្សី ៣ ដង ក្នុងបំណងថាសុំនិមន្តព្រះអង្គឱ្យបញ្ចេញប្រតិកម្មចំពោះអ្វី១ដែលកំពុងប្រព្រឹត្តទៅនេះ ។ កូនចោរទាំងអស់គ្នា ក៏ធ្វើតាមនាយរបស់ខ្លួនដែរ ។ តាមពិតទៅ កូនចោរទាំងអស់មានចិន្តាសោមនស្សរីករាយរួចជាស្រេចទៅហើយ នៅពេលដែលពួកគេកំពុងស្តាប់នាយរបស់ពួកគេសំដែងពីការផ្លាស់ប្តូរឥរិយាបថរបស់គេពីអាក្រក់មកជាល្អវិញនោះ ។ ពួកគេបានត្រៀមខ្លួនរួចជាស្រេចទៅហើយថា ពួកគេនឹងប្រគល់ជូនទ្រព្យទាំងអស់ទៅម្ចាស់គេវិញ តាំងពីមុនពេលដែលមេរបស់ពួកគេលើកជាសំណូមពរឡើងម្ល៉េះ ។ ការប្រគល់ទ្រព្យរបស់ជូនទៅម្ចាស់គេវិញទាំងអស់នោះ ត្រូវបានកូនចោរប្រែចិត្តទាំងប្រាំរយនាក់អនុវត្តទៅ ទាំងបញ្ចេញវាចាបង្ហាញឱ្យឃើញនូវទឹកចិត្តរបស់ពួកគេថា ពួកគេមានវិប្បដិសារីយ៉ាងខ្លាំងចំពោះអំពើផ្តាំផ្តុង ដែលពួកគេបានប្រព្រឹត្តកន្លងមកទាំងប៉ុន្មាននោះ ។

កូនចោរទាំងអស់ មានសេចក្តីស្វាមីភក្តិចំពោះនាយរបស់ពួកគេណាស់ ។

ពួកគេតែងតែចាត់ទុកនាយរបស់ពួកគេ ថាជាមេដឹកនាំដ៏ល្អប្រពៃម្នាក់ ។ ចាប់តាំងពីពួកគេរួបរួមគ្នាបង្កើតជាបក្សពួកចោរកម្មរាប់ឆ្នាំកន្លងមកហើយ នាយរបស់ពួកគេមិនដែលបង្កជារឿងអ្វីឱ្យបរិវារណាម្នាក់ មានការអាក់អន់ស្រពន់ចិត្តដោយប្រការណាមួយឡើយ ។ ពួកគេតែងតែទទួលបាននូវភាពយុត្តិធម៌ពីមេកោយ របស់ពួកគេជានិច្ច ។ មិនតែប៉ុណ្ណោះ មេរបស់ពួកគេថែមទាំងជួយពួកគេនៅរាល់ពេលណាដែលពួកគេមានធុរៈម្តងៗ ។ កាលណាមានបើត្រូវធ្វើការសំរេចចិត្តសំខាន់អ្វីមួយ នាយរបស់ពួកគេមិនដែលធ្វើដោយអត្តនោម័ត ពោលគឺ ធ្វើតាមតែចិត្តឯងនឹកឃើញនោះទេ ។ ផ្ទុយទៅវិញ មេរបស់ពួកគេតែងតែបើកការប្រជុំគ្នាមិនដែលខាន ដើម្បីពិគ្រោះពិចារណាប្តូរយោបល់គ្នាទៅវិញទៅមក តាមធម្មតា ។ នាយរបស់ពួកគេនោះតែងតែលើកកិត្តិយសជានិច្ចចំពោះយោបល់ណា ដែលភាគច្រើនយល់ឃើញថាល្អជាងគេ ។ ការដែលពួកគេទទួលបាននូវការអប់រំមួយ ដែលញ៉ាំងឱ្យពួកគេចេះយល់ចិត្តយល់ថ្លើមគ្នា ចេះយោគយល់គ្នា មានចិត្តស្មោះត្រង់រវាងគ្នានឹងគ្នា គឺជាកត្តាដ៏សំខាន់នៃការពង្រឹងនូវសាមគ្គីភាព មេត្រីភាព និងការបង្កើតឡើងនូវភាតរភាពពិតប្រាកដ នៅក្នុងសង្គមដ៏តូចមួយរបស់ពួកគេនោះ ។ ថ្វីបើគេជាមេចោរមែន ប៉ុន្តែគឺជាមេចោរដែលប្រកបដោយ " គតិបណ្ឌិត " ចំពោះកូនចោរជាបរិវាររបស់គេ ។ ព្រោះហេតុដូច្នេះហើយ ទើបបានជាកូនចោរទាំងអស់កើតចិន្តាស្នេហា ចំពោះនាយនាយរបស់គេរកអ្វីមកប្រៀបផ្ទឹមស្មើផងមិនបានទេ ។ មេដឹកនាំដែលល្អ គឺមេដឹកនាំដែលស្មោះត្រង់ជាមួយកូនចៅរបស់ខ្លួន ពុំមានការលាក់លៀម ឬមានពុតត្បុតចំពោះអ្នកដែលនៅខាងក្រោមអំណាចរបស់ខ្លួននោះសោះឡើយ ។ នេះហើយជាគន្លឹះនៃការដឹកនាំដែលល្អប្រពៃ ជាសេចក្តីថ្លៃថ្នូរសំរាប់មនុស្ស ។

កូនចោរ ដែលបានប្រែខ្លួនទៅជាអ្នកមានចិត្តជាឡើងវិញ តាមនាយចៅហ្វាយរបស់ពួកគេនោះ ក៏ស្រែកឡើងសឹងតែព្រមៗគ្នាថា : "ជយោ ! លោកនាយ !

ពួកយើងខ្ញុំទាំងអស់គ្នា សុខចិត្តធ្វើអ្វីៗទាំងអស់តាមសំណើ ដ៏ថ្លៃថ្លារបស់លោកនាយ ! ។ ពួកយើងខ្ញុំសុំតាមបំរើលោកនាយ ជានិច្ច ! " ។

គ្មាននរណាអាចវាស់បាននូវសេចក្តីរីករាយរបស់បងប្អូនប្រជាជនដែលទើបនឹងបានទទួលរងគ្រោះអម្បាញ់មិញនោះឡើយ បន្ទាប់ពីបានទទួលមកវិញទាំងអស់នូវរបស់ទ្រព្យរៀងៗខ្លួន ដែលបានក្លាយទៅជាកម្មវត្ថុនៃការអស់សង្ឃឹមរបស់គេអស់មួយរយៈពេលខ្លីមក ដោយពុំមានបាត់បង់អ្វីសូម្បីបន្តិចសោះ ។ ព្រមពេលជាមួយគ្នានឹងសម្រែកជ័យឃោសដែលបន្លឺឡើងដោយកូនចោរទាំងប្រាំរយនាក់នោះ ព្រះអាទិត្យក៏ចាប់រះឡើងល្មមហាក់បីដូចជាព្រះអង្គកំពុងយាងចេញមកធ្វើជាបន្ទាល់សាក្សីនៃការផ្លាស់ប្តូររបស់ពួកចោរពីការប្រព្រឹត្តនូវអំពើអាក្រក់ទៅជាការកាន់យកនូវអំពើល្អវិញ ពុំនោះសោតគឺហាក់ដូចជាព្រះអង្គកំពុងចូលរួមចំណែករីករាយនឹងព្រឹត្តិការណ៍នេះដោយផ្ទាល់តែម្តង ឬដើម្បីញ៉ាំងពិធីនេះឱ្យកាន់តែអធិកអធមថែមឡើងទៀតផង និងជាការប្រសិទ្ធិពរជូនដល់អ្នកដែលទើបនឹងមានសទ្ធាចំពោះកុសលធម៌ផង ព្រមទាំងជួយកំចាត់បង់នូវភាពងងឹតអន្ធការ និងសភាព-ការណ៍ស្មុគស្មាញឱ្យជ្រះស្រឡះចេញអស់ទៅផង ។

ព្រះសុរិយាកាន់តែលេចឡើងភ្លឺច្បាស់ ជះកម្មរស្មីពាសពេញទីកដីនៃភូមិឋាននោះ ។ មនុស្សម្នាអាចមើលឃើញគ្នាទៅវិញទៅមកយ៉ាងច្បាស់ ។ ម្នាក់ៗសឹងប្រកបដោយទឹកមុខញញឹមញញែមឡើងស្រស់បំព្រង ជាសញ្ញាប្រាប់ថា ព្រឹត្ដិ-ការណ៍អកុសលអម្បាញ់មិញនេះ ត្រូវបានគេបំភ្លេចអស់គ្មានសល់ ហើយត្រូវជំនួសទៅដោយបរិយាកាសដ៏សែនរីករាយមួយ ដែលឥតមាននរណាម្នាក់គិតស្មានដល់ថានឹងអាចកើតមាននោះសោះឡើយ ។ នេះឯងហើយជាបុណ្យបារមីនៃអរិយបុគ្គលដែលព្រះអង្គខំសន្សំសន្សំបានមក តាមការកសាងនូវកុសលធម៌ ការធ្វើវត្តប្រតិបត្តិនានាតាមគន្លងព្រះពុទ្ធសាសនា ។

ព្រះមហាសុបក្សី ដែលទ្រង់សណ្តាប់នូវការកែប្រែឥរិយាបថរបស់ពួកចោរទាំងប្រាំរយនាក់នោះ ដោយព្រះទ័យរីករាយឥតឧបមា ក៏ទ្រង់មានព្រះពុទ្ធដីកាយល់ព្រមទទួលយកមេចោរនោះជាសិស្សគណ តាមសំណូមពរ ។ រីឯកូនចោរទាំងអស់ដែលមានស្វាមីភក្តិបំផុត ចំពោះនាយចៅហ្វាយរបស់ពួកគេនោះ ក៏នៅតែមិនទាន់ដាច់ចិត្តចោលចៅហ្វាយនាយរបស់ពួកគេទេ ។ ពួកគេទាំងអស់គ្នាបានក្រាបថ្វាយបង្គំចំពោះព្រះមហាសុបក្សី ដើម្បីឱ្យព្រះអង្គទ្រង់ព្រះមេត្តាសន្តោសប្រោសដល់ប្រាណរបស់ពួកគេផង ឱ្យដូចអ្វីដែលព្រះអង្គទើបនឹងបានធ្វើចំពោះលោកនាយរបស់ពួកគេ ។ ពួកគេសុំចូលខ្លួនទៅតាមដង្ហែលោកនាយរបស់ពួកគេ ព្រមទាំងសុំសាងផ្នួសបួសជាអ្នកកាន់សីល កាន់វត្តប្រតិបត្តិឱ្យខ្ជាប់ខ្ជួនមួនមាំ នៅក្នុងសំណាក់របស់ព្រះមហាសុបក្សី ដើម្បីរៀនសូត្រឱ្យបានចេះដឹង និងឱ្យបានជាទីគោរពនៃអស់ជនានុជនផង ។

ព្រះមហាសុបក្សីតាបស ទ្រង់កើតព្រះចិន្តារីករាយពន់ពេក នឹងទទួលយកចោរប្រែចិត្តទាំងប្រាំរយនាក់ឱ្យបានចូលបួសរៀននៅក្នុងសំណាក់របស់ព្រះអង្គ ។ នៅក្នុងថ្ងៃជាមហានក្ខត្តឫក្សនោះ ប្រជាជននៅក្នុងភូមិ ក៏បានស្មគ្រចិត្តរៀបចំពិធីជប់លៀងភ្ញៀវកិត្តិយស និងប្រគេនយាគូចំពោះព្រះមហាសុបក្សីតាបស ។ គឺជាមហាពិធីមួយ ដែលមិនធ្លាប់មានសោះតាំងពីដើមមក ។ ព្រះនាមរបស់ព្រះមហាសុបក្សី កាន់តែល្បីរន្ទឺ ឮសុះសាយទៅដល់ទីជិតទីឆ្ងាយ រហូតទៅដល់លោកមហាសេដ្ឋីបុរីរក្ស ។ តាមសំណូមពរផ្ទាល់របស់លោកសេដ្ឋី ព្រះមហាសុបក្សីបាននិមន្តទៅកាន់គេហដ្ឋានរបស់លោក ដែលនៅទីនោះ ព្រះអង្គបានជួយសង្គ្រោះដល់កុមារទាំងពីរប្រាណឱ្យបានរួចផុតពីអភ័ព្វនោះទៅ ។

# អ្នករៀនដើម្បីជាតិ

ហៃកុមារ ចូរខំនាំគ្នា រៀនអក្សរសាស្ត្រ
ចូរកុំរត់លេង ត្រូវនឹកអៀនខ្មាស ហាត់អានឱ្យច្បាស់
សរសេរឱ្យត្រូវ ។

រៀនសូត្រឱ្យចេះ អស់អាថ៌ចំណេះ កុំឱ្យសត្រូវ
ញាំញីលើក្បាល ចិរកាលតទៅ នាំឱ្យអាស្រូវ
ជោកដល់ជាតិទៀត ។

រដ្ឋខ្មែរតូចណាស់ ចូរប្រែក្រឡាស់ រិះរេរកស្មៀត
កុំនៅឡេឡ ខាតពេលបង់សៀត នាងអើយខំឆ្លៀត
ទាន់នាងនៅក្មេង ។

ចូរនាងជឿថា រដ្ឋនឹងថ្លៃថ្លា ដោយសារនាងឯង
ដែលខំស្វាធ្យាយ ដើម្បីចាត់ចែង តាំងផ្ទះសម្បែង
ឱ្យល្អដូចគេ ។

ន.មោ.ក.ខ ហាត់អានឱ្យល្អ កុំនៅទំនេរ
ដីសខ្មៅដៃ ព្យាយាមសរសេរ កុំចាំត្រូវជេរ
រៀនសោះគេថា ។

កុំដូចមនុស្សខ្លាក់ តាមតែគេញាក់ ឆ្វេងស្ដាំតាមការ
ពួកជនបែបនេះ មានក្នុងតម្រា ថានាំអាត្មា
ទៅរកក្ដីទុក្ខ ។

១.២.៣.៤ បូកសងតាមក្បួន គុណចែកតាមមុខ
កុំធ្វេសប្រហែស ខំឡើងគ្រប់ស្រុក ទើបរដ្ឋបានសុខ

រស់រានក្សេមក្សាន្ត ។

អនាគតគឺអ្នក ដូច្នេះត្រូវស្មគ្រ កុំទំរន់ប្រាណ
នឿយហត់កុំត្អូញ យកចេះឱ្យបាន ខ្លួននាងថ្កើងថ្កាន
ពីព្រោះនឿយមុន ។

ខំគួសខំគួរ អស់ទាំងគំនូរ ធ្ងន់ស្រាលខំពុន
ចំណោះនេះហើយ ដែលនាំនូវគុណ បុណ្យសក្តិទ្រព្យធន
ដល់ជាតិដល់អ្នក ។

ជំនួញជួញប្រែ ជាតិគេធ្វើតែ បន្លំលួចលាក់
បិទភ្នែកខ្មែរស៊ី ព្រោះជាតិខ្មែរខ្វាក់ នាងអើយគួរភ្ញាក់
ខំរុលទៅមុខ ។

រៀនដើម្បីអ្វី ដើម្បីទឹកដី ចូរចងចាំទុក
រដ្ឋកម្ពុជា កេរ្តិ៍ម៉ែឪពុក សាងបានជាស្រុក
ដោយសារសាច់ឈាម ។

បើជាតិត្រូវការ នាងកុំសាវ៉ា ថយក្រោយទីមទាម
ស្ទុះស្មគ្របំរើ ឱ្យទាន់ពេលភ្លាម នោះទើបដល់ពាម
គឺសុខសប្បាយ ។

ទោះរស់ទោះស្លាប់ ស្រីប្រុសប្រញ៉ាប់ ត្រូវបូជាកាយ
ដល់មាតុភូមិ កុំបីនឿយណាយ ជីវិតកុំស្តាយ
ស្តាយត្រង់តែជាតិ ។

បើសត្រូវជិះជាន់ ព្រួតតកុំគ្រាន់ វាយវាឱ្យឃ្លាត
កុំដេកផ្សងព្រេង ត្រូវវាយឱ្យព្រាត់ វាយឱ្យខ្ចាយខ្ចាត់
ចាកពីទឹកដី ។

*ត្រូវប្តូរជីវិត ស្លាប់រស់កុំគិត ណានាងប្រុសស្រី*
*រស់នៅខ្ញុំគេ មិនប្រសើរអី ស្លាប់ព្រោះបូរី*
*ជយោស្លាប់ចុះ ។*

*បើនាងបណ្តោយ ដល់ទៅថ្ងៃក្រោយ គ្មានបញ្ញាផ្លុះ*
*ព្រោះខ្ជិលពុំរៀន គំនិតទុញចុះ ដល់ដឹងថាខុស*
*ចាស់ជ្រលទៅហើយ ។*

*ពេលកន្លងទៅ អ្នកនាងស្រែកហៅ ពុំវិលវិញឡើយ*
*នៅក្មេងត្រូវប្រឹង កុំធ្វើព្រងើយ នៃអ្នកនាងអើយ*
*មកទៅ ! មកទៅ ! ។*

*មកទៅសាលា នាងកណ្ឌៀតក្តារ ក្រាបលាម៉ែឪ*
*បបួលមិត្តភក្តិ កុំគិតកាក់នៅ ខំរៀនណាពៅ*
*អ្នកនាងកូនខ្មែរ ។*

*ម៉ែឪសប្បាយ ចិត្តលោកខ្វល់ខ្វាយ ខិតខំធ្វើស្រែ*
*នាងសង្វាតរៀន ឱ្យបានពូកែ កុំយំឡែឡែ*
*ខ្មាស់ជាតិជិតខាង ។*

*គុណគ្រូត្រូវស្គាល់ យប់ថ្ងៃនាងគាល់ ផ្ចិតផ្ចង់សំអាង*
*គឺគ្រូនេះហើយ ដែលជួយកសាង វាសនាសំណាង*
*ឱ្យនាងរាល់គ្នា ។*

*ចូរនាងចងចាំ អស់ទាំងបណ្តាំ ខាងលើនេះណា*
*ព្រឹកស្អែកត្រៀមខ្លួន ចេញចរយាត្រា ឆ្ពោះទៅសាលា*
*ខំសិក្សាអីយ ។*

កម្ពុជសុរិយា 34 /1962 /2

# ចូលឆ្នាំថ្មី
# ល្បែងអង្គញ់ និងចម្រៀង

ស្រាវជ្រាវ រៀបរៀងដោយ **គង់ វេង**
មន្ត្រីចូលនិវត្តន៍ ខេត្តកំពង់ចាម

**កកន.** ល្បែងអង្គញ់ ជាល្បែងកំសាន្តប្រជាប្រិយមួយក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ហើយមានរបៀបលេងស្ទើរតែដូចគ្នានៅតាមតំបន់នីមួយៗ ។ គណៈកម្មការនិពន្ធចុះផ្សាយអត្ថបទស្តីពី « ល្បែងអង្គញ់ » ក្នុងទស្សនាវដ្ដីកម្ពុជសុរិយានេះ ដើម្បីផ្ដល់ពត៌មានដល់គ្នាទៅវិញទៅមកក្នុងការស្រាវជ្រាវផង និងដើម្បីជាការផ្ទេរចំណេះដឹងពីមនុស្សជំនាន់មុន ទៅមនុស្សជំនាន់ក្រោយៗផង ។

តាមទម្លាប់ពីបុរាណកាល, ក្នុង ១ ឆ្នាំ លោកចែករដូវជា ៣ គឺ ហេមន្តរដូវ គិម្ហរដូវ និងវស្សានរដូវ ។ ក្នុងរដូវទាំង ៣, រដូវនីមួយៗមាន ៤ ខែដូចគ្នា ។

តាមចន្ទគតិ, ក្នុង ១ ខែ ចែកជាពីរផ្នែកគឺ ផ្នែកខាងខ្នើត និងផ្នែកខាងរនោច ។ សម្រាប់កាលនិយមនេះ ក្នុងរដូវមួយៗ សុទ្ធតែត្រូវរាប់យកខាងកាឡបក្ស ( រនោច ) ជាដំបូង រួចទៅបញ្ចប់ខាងសុក្កបក្ស ( ខ្នើត ) ដូចៗគ្នាទាំងអស់ ។

ដូចជា *ហេមន្តរដូវ* ( រដូវរងា ) រាប់ពីថ្ងៃ ១ រោច ខែកត្តិក ដល់ថ្ងៃពេញបូរមី ខែផល្គុន ;។ *គិម្ហរដូវ* ( រដូវក្ដៅ ) រាប់ពីថ្ងៃ ១ រោច ខែផល្គុន ដល់ថ្ងៃពេញបូរមី ខែអាសាឍ ; *វស្សានរដូវ* ( រដូវភ្លៀង ) រាប់ពីថ្ងៃ ១ រោច ខែអាសាឍ ដល់ថ្ងៃពេញបូរមី ខែកត្តិក ។ រួមទាំង ៣ រដូវជា ១២ ខែ ត្រូវជា ១ ឆ្នាំ ។

ក្នុងអំឡុងពេល ១២ ខែ, បុព្វបុរសខ្មែរបានបង្កើតបុណ្យប្រពៃណីជាច្រើន ប៉ុន្តែបុណ្យជាទីនិយម និងចម្បងជាងគេនោះគឺ បុណ្យភ្ជុំបិណ្ឌ និងចូលឆ្នាំ ។

បុណ្យចូលឆ្នាំ លោកកំណត់ប្រារព្ធឡើងជាផ្លូវការត្រឹម ៣ ថ្ងៃ ដោយចាប់ផ្ដើ ពីថ្ងៃទី ១៣ ឬ ១៤ មេសា ហើយត្រូវបិទទៅវិញជាកំហិត នៅថ្ងៃទី ១៥ ឬថ្ងៃទី ១៦ ខែមេសា រៀងរាល់ឆ្នាំ ។

ក្នុងរយៈពេល ៣ ថ្ងៃ នៃពិធីបុណ្យនេះ ប្រជាជាតិយើងទាំងប្រុស ទាំងស្រី ទាំងចាស់ ទាំងក្មេង តែងនិយមនាំគ្នាលេងល្បែងកំសាន្តប្រជាប្រិយជាច្រើនប្រភេទ ៖ លោតអន្ទាក់ លាក់កន្សែង ចាប់កូនខ្លែង ស្ដេចចង់ ក្រុងមាន់ ទាញព្រ័ត្រ ទាត់សី ចោលឈូង បិទមុខបិទពួន និងបោះអង្គុញ ។ល។

គួរឱ្យស្ញើចសរសើរពេកណាស់ ចំពោះឧត្តមគតិនៃបុព្វបុរសខ្មែរយើងដែលចេះតាក់តែងច្នៃប្រឌិតល្បែងប្រជាប្រិយទាំងឡាយ ទុកជាកេរដំណែលឱ្យកូនចៅជំនាន់ក្រោយលេងកំសាន្តសប្បាយ តាមរដូវកាល ។

បើពិនិត្យមើលចលនានៃល្បែងប្រជាប្រិយទាំងនោះ, យើងឃើញមានសញ្ញា ៣ ប្រការគឺ ៖

១)․ លោតអន្ទាក់ ចាប់កូនខ្លែង ទាញព្រ័ត្រ ទាត់សី ចោលឈូង និងបោះអង្គុញ ជាប្រភេទល្បែងដែលនាំឱ្យយឺតសរសៃ ឱ្យស្រួលខ្លួន ឱ្យមានកម្លាំងច្រើនបង្កើនសាច់ដុំ ពង្រឹងថាមពល និងសុខភាព ។

២)․ ក្នុងល្បែងនេះដដែល, ការលោតបានខ្ពស់ លោតបានឆ្ងាយ រត់គេចលឿន រហ័ស បោះត្រង់ បាញ់ត្រង់ គឺជាប្រភពជំនួយដល់វិស័យការពារជាតិ ។

៣)․ លាក់កន្សែង ក្រុងមាន់ ស្ដេចចង់ បិទមុខបិទពួន និងចោលឈូង ជាល្បែងផ្ដល់នូវលំហាត់ពិនិត្យ សង្កេត ស្ដាប់សូរ យកការណ៍ បង្កើនភាពរហ័សរហួន ភាពក្លាហាន និងបញ្ញាស្មារតីវាងវៃ ។

ដូចនេះ យើងមានមោទនភាពណាស់ ចំពោះគុណសម្បទានៃល្បែងទាំងនោះ ព្រោះយើងបានកំណត់ឈ្មោះថាជា ៖

- « ល្បែងបរិសុទ្ធ » លេងក្នុងស្មារតីសាមគ្គីភាព ឥតស៊ី ឥតសង ។

- « ល្បែងគ្មានឡប់លោក់ កេងបន្លំលើគ្នា » ព្រោះមានភាពជាក់ស្តែង លេងនឹងដៃ អាស្រ័យនឹងភ្នែក សប្បាយក្នុងគ្រួសារ ។

- « ល្បែងកាយសម្ពន្ធ ឬអត្តពលកម្ម » ព្រោះនាំមកនូវសុខភាព ភាពក្លាហាន និងបង្កើតបាននូវប្រាជ្ញគំនិត និងប្រាជ្ញាញាណ ។

តទៅនេះ សូមជម្រាបជូននូវទស្សនីយភាពនៃល្បែងអង្គញ់ ។

អង្គញ់ ជាគ្រាប់រុក្ខជាតិមួយប្រភេទ ដែលមានទំហំពី ៤ ទៅ ៥ ស.ម រាងមូលសំប៉ែត ពណ៌ក្រហមក្រមៅ ( ក្រហមចាស់ ) រលោង មានភាពរឹង ស្វិត មិនងាយបែក ។ ដូនតាយើងបានយកគ្រាប់អង្គញ់នេះ ធ្វើជាឧបករណ៍សម្រាប់នាំកូនចៅ ឱ្យលេងកំសាន្តក្នុងរដូវបុណ្យចូលឆ្នាំ ហៅថា « ល្បែងបោះអង្គញ់ » ។

• <u>របៀបលេង :</u>

ក). គូអ្នកលេង, គេនិយមចែកគូអ្នកលេងជា ២ ក្រុម : ប្រុសម្ខាង ស្រីម្ខាង ឬប្រុស ឬស្រីទាំងសងខាង ហើយម្ខាងៗត្រូវមានអ្នកលេងចំនួនស្មើគ្នាគឺ ១ ទល់នឹង ១, ២ ទល់នឹង ២ ឬក៏ច្រើនគូ ទល់នឹងច្រើនគូ ។

ខ). ពេលលេង, គ្រាប់អង្គញ់ គេហៅ « កោយ (មេអង្គញ់) » ។ ដំបូងគេផ្តើមចែកកោយឱ្យក្រុមនីមួយៗ មានចំនួនស្មើគ្នា ។

គ). កោយដែលមានក្នុងក្រុមម្ខាងៗ ត្រូវរំលែកចំនួនជាពីរ : មួយចំនួនសម្រាប់ដាំ ( ទុកជាមេ ឬបង្គោល ), មួយចំនួនទៀត ទុកសម្រាប់បោះ ។

• <u>ក្បាច់ក្នុងពេលលេង :</u>

ដំបូង ភាគីទាំងសងខាងដាំកោយ, របៀបដាំកោយ គេដាំឱ្យសេសគូ គឺ ៣.៥.៧ ( តាមបំណងអ្នកលេងចង់ដាំតិច ឬច្រើន ) ។ គេដាំឱ្យមានរាងជាត្រី-ត្រីកោណ ។ នៅចំកណ្តាលហៅ គោល ឬមេកណ្តាល, បន្ទាប់មកហៅ ចង្កេះ, តមក

ទៀតហៅ ជើងវ្សេង ។

១). ការផ្ដើមបោះ, ក្នុងការចាប់ផ្ដើមនេះ គេមិនបាច់បួលយកមុន យកក្រោយអ្វីទេ ស្រេចតែគេនិយាយមត់គ្នាថាខាងណាបោះមុន ខាងណាបោះក្រោយ ។ បើក្រុមណាមួយដែលបានបោះមុន បោះត្រូវកោយដាំដួលទាំងអស់, ក្រុមនោះមានលទ្ធភាពឆ្លងទៅធ្វើក្បាច់ទី ២ គឺ « ស៊ីគោល » ។ តែបើដួលមិនអស់ទេ នោះក្រុមម្ខាងទៀត ត្រូវចាប់ផ្ដើមបោះជាស្វ័យប្រវត្តិ ។

២). ក្បាច់ស៊ីគោល, របៀបស៊ីគោល គឺគេឈរ ដាក់កោយបោះលើក្បាលជង្គង់ យិតមេដៃ ឬម្រាមដៃមួយបាញ់តម្រង់ផ្ដួលកោយដាំ ( ដូចរបៀបបោះដំបូងដែរ ) ។ បើក្រុមណាបាញ់ផ្ដួលកោយដាំអស់, ក្រុមនោះមានសិទ្ធិចូលទៅកាន់ក្បាច់មួយទៀតគឺ « ស៊ីប៉ារ៉េត » ។

៣). របៀបស៊ីប៉ារ៉េត, ក្បាច់នេះឃើញមានលេងខុសគ្នា តាមទម្លាប់របស់អ្នកស្រុក អ្នកភូមិ តែជាទូទៅឃើញមានលេងពីរបែប : មួយបែប គេដាក់កោយបោះលើខ្នងជើង ឬគេត្បៀតកោយបោះនឹងមេជើង ហើយឈានបោះតម្រង់ផ្ដួលរំលំកោយដាំ, មួយបែបទៀត គេដាក់កោយបោះលើផែនដី យិតម្រាមដៃមួយផ្ទប់នឹងដីបាញ់តម្រង់ផ្ដួលកោយដាំ ។ បើផ្ដួលកោយដាំបានអស់ គេមាននាទីទៅធ្វើក្បាច់មួយទៀត ហៅថា « ក្បាច់ត្រកងឆា » ។

៤). ក្បាច់ត្រកងឆា, របៀបត្រកងឆា គឺគេបង្វិលកោយបោះឱ្យវិល (ដូចក្មេងបង្វិលកង់) ត្រកងតម្រង់ទៅផ្ដួលកោយដាំ ដូចរបៀបបោះដែរ ។ អំពើបែបនេះ បើធ្វើបានសម្រេចអស់ គេនឹងបន្តទៅធ្វើក្បាច់មួយទៀត ហៅថា « ក្បាច់ត្រកងទប់ » ។

៦). ក្បាច់ត្រកងទប់, របៀបត្រកងទប់ គឺគេបង្វិលកោយបោះឱ្យវិលទៅមុខ ដូចក្បាច់ត្រកងឆាដែរ, តែនៅពេលកោយបោះកំពុងវិលទៅមុខ ទៅដល់ជិត

កោយដាំ គេយកដៃខ្ទប់វាឱ្យដួល ក្បែរពីមុខ ឬទន្ទឹមនឹងកោយដាំ ។ បើកោយត្រកង នោះលឿនជ្រុលទៅហួសកោយដាំ ( ដោយខ្ទប់មិនទាន់ ) គេសន្មតថាខូច ឬស្អុយ ។ ពេលនោះ ក្រុមជាដៃគូម្ខាងទៀត ត្រូវចាប់ផ្ដើមនាទីរបស់ខ្លួនវិញម្ដង ។ បើបាន សម្រេចអស់, គេអាចទៅបំពេញក្បាច់ទី ៦ ហៅថា « ក្បាច់ចាក់កន្ទែក » ។

៦)_ ក្បាច់ចាក់កន្ទែក, របៀបក្បាច់នេះ គឺគេដាក់កោយបោះនៅលើ ជង្គង់ ដើរតែជើង ១ ដោយផ្ដើមចេញពីទីកំណាត់ តម្រង់ទៅបោះផ្ដួលកោយដាំ ដូច ក្បាច់ស៊ីប៉ារ៉េតដែរ ។ នៅពេលដាក់កោយបោះលើជង្គង់ ហើយដើរលោតតែជើង ម្ខាងនេះ បើកោយបោះនៅលើជង្គង់ត្រូវធ្លាក់ក្ដី ជើងម្ខាងដែលលើកអង្គញ់ទៅធ្លាក់ ប៉ះនឹងដីក្ដី, នាទីនោះហៅថា ស្អុយ ( មោឃៈ ) ។

ប៉ុន្តែ បើក្រុមម្ខាងណាក៏ដោយ ដែលអាចបញ្ចប់កិច្ចការរបស់ខ្លួនដោយ ជោគជ័យ ក្រុមនោះត្រូវមានសិទ្ធិឆ្លងទៅបំពេញក្បាច់ទី ៧ ជាក្បាច់ចុងបញ្ចប់បាន ហៅថា « ក្បាច់ដាច់សា » ។

៧)_ ក្បាច់ដាច់សា ឬបោះជោះ, ក្បាច់នេះ គេលេងដូចក្បាច់ទី២ ដែរ ។ បើក្រុមណាបោះផ្ដួលកោយដាំបានទាំងអស់ហើយ, ក្រុមនោះឈ្មោះថាឈ្នះ ។ រង្វាន់ ជ័យជំនះរបស់ក្រុមនោះគឺជោះ ជោះគ្រប់សមាជិកនៃក្រុមដែលចាញ់ ។

របៀបជោះ, គេនិយមជោះក្បាលជង្គង់ ។ របៀបដាក់អង្គញ់ជោះមាន ពីរបែប ៖ មួយបែបគេផ្ទាប់អង្គញ់ពីរ ៖ ១ រាប ១ បញ្ឈរ កាន់ផ្ដោបនឹងប្រអប់ដៃ ហើយលើកជោះ ។ មួយបែបទៀត គេដាក់អង្គញ់រាប ១ លើក្បាលជង្គង់ រួចយក អង្គញ់ ១ ទៀតជោះពីលើអង្គញ់រាបនោះ ។ ជោះយ៉ាងនេះ គឺកុំអោយឈឺពេក ។ នៅតាមតំបន់ស្រុក ភូមិខ្លះ គេជោះគ្នានឹងបំពង់ត្នោតកំបែក ដើម្បីឱ្យឮសូរខ្លាំង ទាំង មិនសូវឈឺផង ។

កន្លែងលេងខ្លះទៀត គេមិនប្រើរង្វាន់ជោះទេ គេណាត់គ្នាបូតច្រមុះ ឬ

ច្រៀង ១ បទ ឬក៏រាំមួយក្បាច់ ដែលជារង្វាន់ដាច់សានីមួយៗ ។

ល្បែងបោះអង្គញ់ នៅតាមតំបន់ស្រុក ភូមិ ជាច្រើន គេច្រើននិយម លេងតាមក្បាច់ខាងលើនេះ ( ទុកជាមេរបៀប ) តែកន្លែងខ្លះ នៅពេលបច្ចុប្បន្ន នេះ គេយល់ថាលេងតាមក្បាច់ខាងលើនេះច្រើនពេក យូរពេក ក្រឃើញឈ្នះ-ចាញ់ ទើបគេនាំគ្នាបង្រួញឱ្យខ្លី គឺដាំកោយហើយ នាំគ្នាបោះជោះតែម្ដង ។

នៅទីបញ្ចប់ សូមជូនចម្រៀងក្នុងសកម្មភាពលេងអង្គញ់មួយ ( តាម លំនាំបទ « ខាវ៉ាន » ។ អត្ថបទចម្រៀងនេះ ជាកំណាព្យពាក្យ ៧ តែអាចច្រៀង តាមលំនាំបទខាវ៉ានបាន ។

បំណងរបស់ខ្ញុំគឺ ចង់ឱ្យចម្រៀងនេះទៅជាចម្រៀងព្រាប់កាយវិការ ឬក៏ ជារបាំអង្គញ់មួយ ។

បើគណៈកម្មការនិពន្ធទស្សនាវដ្ដីកម្ពុជសុរិយាពុំយល់ទាស់ទេ សូមកែ សម្រួលបទចម្រៀងនេះឱ្យបានទៅជាចម្រៀងព្រាប់កាយវិការ មានលក្ខណៈជាបទ ចម្រៀងប្រពៃណី ជាទីនិយមរបស់ជនានុជនយើងតទៅ តាមការគួរ ។

## ចម្រៀងបោះអង្គញ់

*- ផ្គរលាន់ខែចេត្រផ្គរផ្គួនៗ　　ផ្គរត្រូវតាមក្បួនតាមចំណាំ*
*ផ្គរនាំសួស្ដីផ្គរស្រែកផ្ដាំ　　ឱ្យខ្មែរចូលឆ្នាំលេងសប្បាយ ។*
*- យើងលេងអង្គញ់តាមទម្លាប់　　ចិត្តចបកាន់ខ្ជាប់ មិនរសាយ*
*ប្រពៃណីខ្មែរមិនប្រែក្លាយ　　សូមរីកសុសសាយកេរដូនតា ។*

ដំបូងគ្នាយើងដាំកោយ ! ( ស្រែករួមគ្នា )

កាយវិការ - រត់ទៅដាំកោយ ដោយគោះអង្គញ់បន្តរផង ។

- អង្គញ់ដាំហើយគ្នាយើងបោះ ត្រូវអស់មិនអស់តាមសញ្ញា
អស់កោយពីដៃឥតតវ៉ា បោះត្រូវប៉ុនណាសាខាងយើង ។
- ឥឡូវដល់សាមិត្តម្ខាងទៀត មិត្តអើយផ្លាស់ផ្លៀតឱ្យគ្រាន់ឡើង
ត្រូវមួយសងមួយដួលខ្ទាតប៉ើង យើងនឹងបានឡើងក្បាច់ស៊ីគោល ។
- អង្គញ់យើងដាក់ផ្ទប់ជង្គង់ ម្រាមដៃពត់ពង់ផ្ទាត់បញ្ចូល
តម្រង់ជើងវៀងឬមេគោល ដងខ្លួនកុំយោលប្រឹងសង្កេត ។
- ស៊ីគោលចប់ហើយមិនមានជ័យ បញ្ចេញថ្វីដៃស៊ីប៉ារ៉េត
កោយដាក់ផ្ទាល់ដីភ្នែកសង្កេត ត្រូវត្រឹមផ្សៀងទ្រេតមិនបានការ ។
- អីចឹងដល់វេនខាងខ្ញុំម្ដង បោះកោយត្រកង ត្រកងឆា
ជ្រុលហួសកោយដាំខុសក្រឹត្យា ទុកជាអសារក្ដារខ្ញុំឈប់ ។
- ដល់វេនមិត្តហើយស្ងួមញញឹម រីករាយសង្ឃឹមត្រកងទប់
ត្រជាញ់ឱ្យត្រង់រត់តាមខ្ទប់ ចាប់វាឱ្យឈប់ផ្ទាត់បន្ត ។
- កោយដួលអស់ហើយដៃមិត្តខេង ខ្ញុំសូមសំដែងចិត្តត្រេកអរ
នេះចំជាដៃថ្លៃបវរ សូមមិត្តបន ចាក់កន្ទែក ។
- កោយដាក់ខ្នងជើងលោតតម្រង់ ស្មារតីផ្ចិតផ្ចង់កុំរារែក
ផ្ទួលអស់កោយដាំចប់កន្ទែក ឈ្នះអស់គ្រប់ផ្នែកឆ្នើមអស្ចារ្យ ។
- កន្ទែកឈ្នះហើយមិនទាន់គ្រាន់ ចង់បានរង្វាន់ត្រូវបោះសា
ដូចក្បាច់ដំបូងសមប្រាថ្នា ក្បួនលោកចែងថាត្រូវបានជោះ ។
- ជោះចុះ ! ជោះចុះ ! ជោះថ្មម១ អង្គញ់ដាក់អមដោយអនុគ្រោះ
ជង្គង់ខ្ញុំខ្ចីប្រណីលោះ មិត្តមានកិត្តិយ ជោះយកជ័យ ។

កំពង់ចាម, ខែ កុម្ភៈ ១៩៩៩

# ល្បើកក្រើនជាតិ

## កាព្យពាក្យ ៧ តាមលំនាំអក្សរ

*យុនបណ្ណានុរក្ស ប៊ូ - ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ*
រៀបរៀង

ក - កបកើតមកជាកូនខ្មែរ
ខ - ខំគិតកែប្រែគំនិត
គ - គួរសេពគប់លោកបណ្ឌិត
ឃ - ឃើញត្រូវពិតរួចសឹមថា ។
ង - ងើបមើលជាតិខ្មែរដូចគ្នា
ច - ចូរសមគ្គាជួយរដ្ឋា
ឆ - ឆប្រកបដោយបញ្ញា
ជ - ជួយស្តីថាតឿនកូនចៅ ។
ឈ - កុំឈប់ស្ងៀមមើលបំណាំ
ញ - ញឹកខាងចាំពាក្យប្រដៅ
ដ - ដឹងឱ្យគ្រប់កុំល្ងង់ខ្លៅ
ឋ - ថែមចេះជ្រៅច្រើនទៅមុខ ។
ឌ - កុំដុកដាន់ដោលគ្នាឯង
ឍ - ឍើបួកខែងចង់ស្រណុក
ណ - ណាត់ញុះញង់ឱ្យអុកឡុក
ត - តោងសំកុកគិតឱ្យជ្រៅ ។
ថ - ថប់ទៅមុខក្រែងវិនាស
ទ - កុំទ័សទាសចោលលំនៅ
ធ - ធៀបដូចទូក ឬសំពៅ
ន - នៅមិននឹងមួយកន្លែង ។
ប - បើបានធំកុំស្អប់តូច
ផ - ផាត់កាត់ខូចចេញឱ្យស្តែង
ព - ពិតជាប្រុសខំប្រឹងប្រែង
ភ - ភ័យខ្លាចក្រែងជាតិខ្ញុំគេ ។
ម - មកពីខិតខំរៀនសូត្រ
យ - យោងឱ្យរបូតប្រឹងរិះរេ
រ - រកឧបាយកលគ្មាន់គ្នេរ
ល - លើកជាតិគេជាតួយ៉ាង ។
វ - កុំវិលវល់ទៅតាមខ្យល់
ស - សូមកុំឆ្ងល់នឹងសំណាង

*ហ - ហាមចិត្តខ្លួនកុំឱ្យអាង ឡ - កុំឡូងឡាងទាស់ទែងគ្នា ។*

*អ - អងស្អងជាតិចាស់បុរាណ អា - អាងភូមិឋាននៃវិជ្ជា*

*ឥ - ឥតប្រយោជន៍កុំនឹកនា ឦ - ឱ្យភាវនាតែចំរើន ។*

*ឧ, ឩ - ឧស្សាហ៍តែងក្បួនច្បាប់ ឫ, ឬ - កាន់កាប់ការឱ្យច្រើន*

*ឭ, ឮ - ត្រូវខំធ្វើឱ្យកើន ឯ, ឰ - ចំរើនប្រទេសជាតិ ។*

*ឱ - ឱ្យសុខាដល់គ្នីគ្នា ឳ - ឱបរាំងរាកុំឱ្យឃ្លាត*

*អុំ,អំ - ចូរខំកុំវិវាទ អាំ, អះ - ទើបជាតិខ្មែរថ្កើងអើយ !*

***

• ឆ្កួតបីប្រការ

លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង

អំពើពាលា ឆ្កួតនេះហៅមហា ឆ្កួតក្រៃកន្លង ។

ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងឆ្គង លោកពុំឱ្យសេព

ឱ្យវៀរជាម្តង វាតែងឱ្យហ្មង ភ្លេចភ្លាំងស្មារតី ។

ឱ្យភ្លេចក្តីគាប់ ភ្លេចទាំងខ្លួនស្លាប់ ភ្លេចសាស្ត្រសួស្តី ភ្លេចសីលភ្លេចទាន

ភ្លេចញាណវឌ្ឍី ភ្លេចច្បាប់ប្រក្រតី ឆ្កួតបីប្រការ ។

ច្បាប់កូនចៅ

# ពិធីទទួលសៀវភៅពុទ្ធសាសនា បោះពុម្ពឆ្នាំ ១៩៩៩ អំណោយរបស់អង្គការ រីស្សូ កូសី-កៃ, ជប៉ុន



លោក ឱម ខែម ថ្លែងស្វាគមន៍ចំពោះគណៈប្រតិភូ ( រូបថត ព.ប )

ថ្ងៃទី ៣០ ខែមេសា ឆ្នា ១៩៩៩ វេលាម៉ោង ៩ និង ៣០ នាទីព្រឹក ពុទ្ធសាសនបណ្ឌិត្យ បានរៀបចំពិធីទទួលសៀវភៅបោះពុម្ពឆ្នាំ ១៩៩៩ ចំនួន ២២,០០០ ក្បាល ពីលោកហ្សូកូ មីស៊ូតានី (Shoko Mizutani) ប្រធានគណៈប្រតិភូនៃអង្គការ រីស្សូ កូសី-កៃ, ប្រទេសជប៉ុន ។

ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម សៅ វ៉ន អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា, លោក ឱម ខែម នាយក

ពុទ្ធសាសនបណ្ឌិត្យ, លោក តេស៊ូកា កូជី ប្រធានអង្គការជំនួយសូតូស៊ូជប៉ុន ប្រចាំនៅកម្ពុជា និងសហការី ព្រមទាំងសមាជិកគណៈប្រតិភូនៃអង្គការ វីស្សូ កូសី-កៃ ជាច្រើនរូបផង ។

សៀវភៅដែលបានទទួលក្នុងឱកាសនោះ រួមមាន :

| | | |
|---|---|---|
| I. | - ប្រជុំកងធម៌ ភាគ ១ | ៣000 ក្បាល |
| | - ប្រជុំកងធម៌ ភាគ ២ | ៣000 ក្បាល |
| II. | ចតុប្បារិសុទ្ធិសីល | ២000 ក្បាល |
| III. | - កច្ចាយនូបត្ថម្ភក ភាគ ១ | ២000 ក្បាល |
| | - កច្ចាយនូបត្ថម្ភ ភាគ ២ | ២000 ក្បាល |
| IV. | - កង្ខាវិតរណី ភាគ ១ | ២000 ក្បាល |
| | - កង្ខាវិតរណី ភាគ ២ | ២000 ក្បាល |
| | - កង្ខាវិតរណី ភាគ ៣ | ២000 ក្បាល |
| | - កង្ខាវិតរណី ភាគ ៤ | ២000 ក្បាល |
| V. | វេយ្យាករណ៍ សំស្ក្រឹត | ២000 ក្បាល |

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម យី យន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា បានរាយការណ៍ជំរាបគណៈប្រតិភូពាក់ព័ន្ធទៅនឹងចំណុចពិសេសពីរគឺ : អគារពុទ្ធសាសនបណ្ឌិត្យ និងស្ថានភាពទូទៅនៃពុទ្ធសាសនា នៅកម្ពុជា ។ ឯកឧត្តមបានបញ្ជាក់ថា អគារដ៏ធំនេះជាគំរោងរបស់ខ្ញុំ នៅឆ្នាំ ១៩៩៤ ។ អង្គការ វីស្សូ កូសី-កៃ បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ក្នុងទឹកប្រាក់ជិត ៥0.000 ដុល្លារ សហរដ្ឋអាមេរិក ដែលថវិកានេះបានមកពីពលិកម្មរបស់សមាជិកម្នាក់ៗ មិនបរិភោគអាហារ ៣ ដង ក្នុងមួយខែ ។ ឯកឧត្តមបានថ្លែងក្នុងនាមពុទ្ធសាសនិកកម្ពុជា និងខ្លួនលោកផ្ទាល់ នូវអំណរគុណចំពោះវិភាគទានដ៏សប្បុរស ពីសមាជិកទាំងអស់

នៃអង្គការ រីស្សូ កូសី-កៃ ។ ឯកឧត្តមបានបញ្ជាក់ថា អគារនេះត្រូវបានស្ថាបនាហើយរួចរាល់ នៅថ្ងៃ ២០-៥-៩៨ ហើយពិធីសម្ពោធបើកអោយប្រើប្រាស់អគារថ្មីនេះ បានប្រារព្ធឡើងនៅថ្ងៃ ២៨-៥-៩៨ ក្រោមអធិបតីភាព សម្តេច ជា ស៊ីម ប្រធានរដ្ឋសភា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ របស់ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ និងលោក Yoshinobu Minami ប្រធានអង្គការ រីស្សូ កូសី-កៃ ឥឡូវ អគារនេះបានក្លាយជាស្ថាបត្យកម្មរបស់ខ្មែរ ដែលបានទទួលការកោតសរសើរមិនដាច់ពីមាត់ ពីសំណាក់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។ អគារនេះបានបំពេញតួនាទីដ៏សំខាន់ដល់ពុទ្ធសាសនាថេរវាទ នៅកម្ពុជា ។

ក្រោយពីពិធីសម្ពោធរួច រហូតមកដល់បច្ចុប្បន្ន មានអ្នកអានជាង ៥០០០ នាក់ ចូលមកសិក្សាស្រាវជ្រាវនៅបណ្ណាល័យកណ្តាលនេះ ។ ហើយសាលប្រជុំដែលយើងកំពុងអង្គុយសន្ទនាគ្នានេះ ក៏មានកម្មវិធីជួបជុំអ្នកស្រាវជ្រាវខាងផ្នែកសាសនា វប្បធម៌ សិល្បៈ អក្សរសាស្ត្រខ្មែរ ក្នុងមួយខែម្តង រៀងរាល់ខែ ដើម្បីផ្តល់ពត៌មានគ្នាទៅវិញទៅមកក្នុងការស្រាវជ្រាវផង និង ដើម្បីជាការផ្ទេរចំណេះដឹងពីមនុស្សជំនាន់មុន ទៅមនុស្សជំនាន់ក្រោយៗផង ហើយកម្មវិធីជួបជុំរៀងរាល់ខែមានមន្ត្រីសង្ឃ មន្ត្រីរាជការ មាននិស្សិត និងមានសមណសិស្ស ចូលរួមមិនតិចជាង ១៥០ នាក់ឡើយ ។

ស្តីពីស្ថានភាពពុទ្ធសាសនានៅកម្ពុជា ឯកឧត្តម យី ធន់ បានមានប្រសាសន៍បញ្ជាក់ថា បច្ចុប្បន្ននេះនៅកម្ពុជា មានវត្តចំនួន ៣,៦០០ និងមានព្រះសង្ឃ ៤៧,០០០ អង្គ ។ ចំណែកការសិក្សាអប់រំផ្នែកព្រះពុទ្ធសាសនា មានការរីកចំរើនឈានពីកំរិតបឋមសិក្សា ដល់ឧត្តមសិក្សា គឺមាន :

- សាលាធម្មវិន័យ ៤១៣, សមណសិស្ស ៧៩៨៥ អង្គ
- សាលាពុទ្ធិកបឋមសិក្សា ២៤៧, សមណសិស្ស ៧១៥៧ អង្គ

នៃអង្គការ រីស្សូ កូសី-កៃ ។ ឯកឧត្តមបានបញ្ជាក់ថា អគារនេះត្រូវបានស្ថាបនាហើយរួចរាល់ នៅថ្ងៃ ២០.៥.៩៨ ហើយពិធីសម្ពោធបើកអោយប្រើប្រាស់អគារថ្មីនេះ បានប្រារព្ធឡើងនៅថ្ងៃ ២៨.៥.៩៨ ក្រោមអធិបតីភាព សម្តេច ជា ស៊ីម ប្រធានរដ្ឋសភា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ របស់ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ និងលោក Yoshinobu Minami ប្រធានអង្គការ រីស្សូ កូសី-កៃ ឥឡូវ អគារនេះបានក្លាយជាស្ថាបត្យកម្មរបស់ខ្មែរ ដែលបានទទួលការកោតសរសើរមិនដាច់ពីមាត់ ពីសំណាក់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។ អគារនេះបានបំពេញតួនាទីដ៏សំខាន់ដល់ពុទ្ធសាសនាថេរវាទ នៅកម្ពុជា ។

ក្រោយពីពិធីសម្ពោធរួច រហូតមកដល់បច្ចុប្បន្ន មានអ្នកអានជាង ៥០០០ នាក់ ចូលមកសិក្សាស្រាវជ្រាវនៅបណ្ណាល័យកណ្តាលនេះ ។ ហើយសាលប្រជុំដែលយើងកំពុងអង្គុយសន្ទនាគ្នានេះ ក៏មានកម្មវិធីជួបជុំអ្នកស្រាវជ្រាវខាងផ្នែកសាសនា វប្បធម៌ សិល្បៈ អក្សរសាស្ត្រខ្មែរ ក្នុងមួយខែម្តង រៀងរាល់ខែ ដើម្បីផ្តល់ពត៌មានគ្នាទៅវិញទៅមកក្នុងការស្រាវជ្រាវផង និង ដើម្បីជាការផ្ទេរចំណេះដឹងពីមនុស្សជំនាន់មុន ទៅមនុស្សជំនាន់ក្រោយៗផង ហើយកម្មវិធីជួបជុំរៀងរាល់ខែមានមន្ត្រីសង្ឃ មន្ត្រីរាជការ មាននិស្សិត និងមានសមណសិស្ស ចូលរួមមិនតិចជាង ១៥០ នាក់ឡើយ ។

ស្តីពីស្ថានភាពពុទ្ធសាសនានៅកម្ពុជា ឯកឧត្តម យី ធន់ បានមានប្រសាសន៍បញ្ជាក់ថា បច្ចុប្បន្ននេះនៅកម្ពុជា មានវត្តចំនួន ៣,៦០០ និងមានព្រះសង្ឃ ៤៧,០០០ អង្គ ។ ចំណែកការសិក្សាអប់រំផ្នែកព្រះពុទ្ធសាសនា មានការរីកចំរើនឈានពីកំរិតបឋមសិក្សា ដល់ឧត្តមសិក្សា គឺមាន :

- សាលាធម្មវិន័យ ៤១៣, សមណសិស្ស ៧៩៨៥ អង្គ
- សាលាពុទ្ធិកបឋមសិក្សា ២៤៧, សមណសិស្ស ៧១៥៧ អង្គ

- សាលាពុទ្ធិកមធ្យមសិក្សា ៤, សមណសិស្ស ៦៤០ អង្គ
- សាលាពុទ្ធិកមហាវិទ្យាល័យ ១, សមណសិស្ស ៨២ អង្គ

ហើយនៅពាក់កណ្ដាលឆ្នាំ ១៩៩៩ នេះ នឹងមានបើកសាលាពុទ្ធិកមធ្យមសិក្សាមួយទៀត នៅខេត្តព្រៃវែង ។ លោកបានគូសបញ្ជាក់ថា បច្ចុប្បន្ននេះ ព្រះសង្ឃជាសមណសិស្សបានប្រើប្រាស់សៀវភៅពុទ្ធសាសនារបស់យើងគ្រប់កំរិត ជាពិសេសសៀវភៅដែលឧបត្ថម្ភដោយអង្គការ វីស្វ៉ា កូសី-កៃ ។ យើងបានបោះពុម្ពសៀវភៅ ៥ ចំណងជើង មាន ១០ ភាគ នៅខែមករា និងកុម្ភៈ ហើយសៀវភៅទាំងនេះត្រូវបានប្រគល់ជូនទៅពុទ្ធសាសនបណ្ឌិត្យ ជាបន្តបន្ទាប់ រហូតដល់ខែមីនា ។

បន្ទាប់មក លោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ បានរាយការណ៍ជូនគណៈប្រតិភូអំពីការប្រើប្រាស់សៀវភៅ និងប្រាក់ចំណូលដែល បានពីការលក់សៀវភៅ ដោយបានបញ្ជាក់ថា ចំនួនសៀវភៅដែលពុទ្ធសាសន-បណ្ឌិត្យ បានទទួលជាបន្តបន្ទាប់ពីអង្គការជំនួយស្វូតស៊ូ ជប៉ុន (JSRC = SVA) ត្រូវបានចាត់ចែងតម្កល់ទុកនៅបណ្ណាល័យកណ្ដាលពុទ្ធសាសនបណ្ឌិត្យ, ផ្ញើទៅតម្កល់ទុកនៅបណ្ណាល័យសំខាន់ៗ ក្នុងក្រុងភ្នំពេញ និងសាខាបណ្ណាល័យនៃពុទ្ធសាសន-បណ្ឌិត្យទាំង ១៦ នៅតាមបណ្ដាខេត្ត ក្រុង ព្រមទាំងប្រគេនមន្ត្រី



សកម្មភាពដឹកសៀវភៅទៅកាន់ខេត្ត ក្រុង (រូបថត ព.ប)

សង្ឃជាន់ខ្ពស់ក្នុងប្រទេស ដោយពុំមានគិតថ្លៃ ហើយមួយចំនួនទៀត ត្រូវបានដាក់លក់ជាសាធារណៈនៅក្រុងភ្នំពេញ និងផ្ញើទៅលក់នៅតាមខេត្ត ដើម្បីសន្សំទុនទុកបោះពុម្ពខ្លួនឯង នៅពេលអនាគត ។

លោក ឱម ខែម បានបញ្ជាក់ថា នៅក្នុងឆ្នាំ ១៩៩៩ នេះ ថវិកាដែលបានពីការលក់សៀវភៅ ឧបត្ថម្ភដោយអង្គការរិស្សូ កូសី-កៃ មានចំនួន ១៤.៨៥៧.៩០០ រៀល បូកនឹងថវិកាលក់សៀវភៅក្នុងឆ្នាំមុនផង មានចំនួន ៤៦.៥៥៥.៥០០ រៀល ។

ឆ្លើយតបដោយក្ដីរំភើបរីករាយរបស់លោកនាថ្ងៃនេះ លោកប្រធានគណៈប្រតិភូ ហ្សូកូ មីស៊ូតានី ( Shoko Mizutani ) បានមានប្រសាសន៍បញ្ជាក់ថា បច្ចុប្បន្ននេះ អង្គការរិស្សូកូសី-កៃ មានសមាជិក ៦ លាននាក់ បានធ្វើពលិកម្មមិនបរិភោគអាហារ ៣ ដង ក្នុងមួយខែ ដើម្បីជាអំណោយសំរាប់សន្តិភាព និងសុភមង្គល ចំពោះមនុស្សជាតិ ។ ថ្ងៃនេះ ជាឱកាសដ៏មានតម្លៃសំរាប់អង្គការ រិស្សូ កូសី-កៃ នៅក្នុងពិធីនេះ នៅពុទ្ធសាសនបណ្ឌិត្យ ។




ឯកឧត្តម សៅ វ៉ន ទទួលសៀវភៅពីលោក ShokoMizutani ( រូបថត ព.ប )

បន្ទាប់ពីទទួលសៀវភៅជានិមិត្តរូបរួចមក ឯកឧត្តម សៅ រិន អនុរដ្ឋ-លេខាធិការក្រសួងធម្មការ និងសាសនា បានសំដែងនូវអំណរគុណ និងការដឹងគុណដ៏ជ្រាលជ្រៅបំផុត ចំពោះវិភាគទានដ៏ធំធេងរបស់អង្គការ រីស្សូ កូសី-កៃ ក្នុងការជួយស្តារព្រះពុទ្ធសាសនានៅកម្ពុជា អោយមានពន្លឺរស្មីឡើងវិញ និងជួយអោយពុទ្ធ-សាសនបណ្ឌិត្យដំណើរការបានល្អ ។ ឯកឧត្តម បានមានប្រសាសន៍សង្កត់ធ្ងន់ថា បើគ្មានជំនួយឧបត្ថម្ភពីសប្បុរសជន នៅប្រទេសជប៉ុន ជាពិសេស ពីអង្គការ រីស្សូ កូសី-កៃ ទេ នោះយើងពុំអាចស្តារវិស័យពុទ្ធសាសនា និងសីលធម៌សង្គមរបស់យើងអោយមានរីកចំរើនឆាប់រហ័ស ដូចសព្វថ្ងៃនេះបានទេ ។ ក្នុងបុព្វហេតុសន្តិភាព សេចក្តីសុខក្សេមក្សាន្ត និងសុភមង្គលនៃមនុស្សជាតិ សូមបេសកកម្មរបស់អង្គការ រីស្សូ កូសី-កៃ ទទួលបានជោគជ័យគ្រប់ប្រការ !

ពិធីនេះបានចប់ នៅវេលាម៉ោង ១១ និង ៤៥ នាទី ក្នុងបរិយាកាសរីករាយស្និទ្ធស្នាល និងថតរូបរួមគ្នាទុកជាអនុស្សាវរីយ៍ផង ។



( រូបថត ពុទ្ធសាសនបណ្ឌិត្យ )

## មុននឹងអានអត្ថបទក្នុងទស្សនាវដ្ដីនេះ សូមកែតម្រូវពាក្យខុសអោយត្រូវសិន

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|
| ៧ | ១៨ | អស្ចារ្យ | អស្ចារ្យ |
| ១៤ | ២១ | កក្រើករំពើ | កក្រើករំពើក |
| ១៥ | ១៣ | ជាវ័ករបស់ | ជាសាវ័ករបស់ |
| ១៧ | ១៤ | សាស្តារ | សាស្តា |
| ២២ | ១៨ | អ្នកបួសស្ដាយបាត្រ | អ្នកបួសស្ពាយបាត្រ |
| ២២ | ២៤ | ភោកា, សី | ភោក្តា, ស៊ី |
| ២៣ | ០៥ | តាំនៅ | តាំងនៅ |
| ២៤ | ១២ | ប្រមានណា | ប្រមាណា |
| ២៦ | ២០ | សាសាលារៀន | សាងសាលារៀន |
| ៣១ | ០៣ | ខំរៀនស្ងូត្រកុំព្រងើយ | ខំរៀនស្ងូត្រទៅកុំព្រងើយ |
| ៣១ | ១៤ | ... ខាងខាងនិស្ស័យ | ... ខាងនិស្ស័យ |
| ៣១ | ២៣ | ជួយថែវរក្សារាជការប្រមុខរដ្ឋ | ជួយថែវរាជការប្រមុខរដ្ឋ |
| ៣៥ | ១៣ | មិនបើ ឱ្យ ... | មិនបើកឱ្យ ... |
| ៦២ | ១៤ | ក៏បាស្មគ្រចិត្ត | ក៏បានស្មគ្រចិត្ត |
| ៦៧ | ២ | ចាប់ផ្ដើ | ចាប់ផ្ដើម |
| ៦៨ | ២៣ | ត្រី-ត្រីកោណ | ត្រីកោណ |
| ៧១ | ១៧ | ... លេងស្បាយ | ... លេងសប្បាយ |
| ៧១ | ១៨ | ចិត្តចបកាន់ខ្ជាប់ | ចិត្តប្រកាន់ខ្ជាប់ |
| ៧២ | ៧ | ... មិនមានជ័យ | ... មិត្តមានជ័យ |
| ៧២ | ១៥ | សូមមិត្តបន | សូមមិត្តបន្ត |
| ៧២ | ១៧ | ច្រើពត្ត | ច្រើនត្ត |
| ៨០ | ៥ | ប្រនប្រសាសន៍ | ប្រសាសន៍ |

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



រូបថត ពុទ្ធសាសនបណ្ឌិត្យ


ឆ្នាំទី ៥៣ លេខ ៣ ខែ កក្កដា - សីហា - កញ្ញា

ព.ស ២៥៤៣ គ.ស ១៩៩៩

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

គ.ស ១៩៩៩

ក្របមុខ : ទិដ្ឋភាពរួមនៃពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៨ ក្រោមអធិបតីភាពសម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី នាសាលសន្និសីទចតុមុខ រាជធានី ភ្នំពេញ

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました

この本が、日本の宗教者とカンボジアの人々との友情のきずなとなりカンボジアの宗教と文化の発展に貢献できれば幸いです

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគំរោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ដើម្បីសាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន (JSRC = SVA) ភ្នំពេញ ។

យើងខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្ដីនេះ បានជាវិភាគទានដល់ការរក្សាមិត្តភាពរវាងប្រជាជនជប៉ុន ជាមួយប្រជាជនកម្ពុជា និងដល់ការថែរក្សាសម្បត្តិវប្បធម៌ និងសម្បត្តិសាសនា របស់ប្រជាជនកម្ពុជា ។

## Acknowledgement

The *Kambujasuriya Magazine* is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC = SVA), Phnom Penh.

We pray that this magazine would contribute to the friendship between Japanese and Cambodian people and to the preservation of Khmer culture and religion.

# មាតិកាអត្ថបទ

## I. អត្ថបទរដ្ឋបាល

• សារលិខិតថ្លែងអំណរព្រះករុណាធិគុណ ........................ ១

## II. អក្សរសាស្ត្រពុទ្ធសាសនា

• តម្លៃសាមគ្គី និងផលអាក្រក់នៃការបែកសាមគ្គី ( ឱម ខែម ) ............ ៤
• សេចក្តីបរិសុទ្ធនៅត្រង់ណា ( ឱម ខែម ) ........................ ១៨

## III. អក្សរសាស្ត្រទូទៅ

• ការបកស្រាយបំភ្លឺបញ្ហាមួយចំនួនពាក់ព័ន្ធនឹងវិស័យ
ធម្មការ និងកិច្ចការសាសនា (រដ្ឋមន្ត្រីក្រសួងធម្មការ) ........................ ២៦
• សិលាចារឹកតាព្រហ្ម k 39 ខេត្តតាកែវ ( វង់ សុធារ៉ា ) ........................ ៣៧
• ក្រមុំព្រហ្មចារី ( ផល ទិត ) ........................ ៤៨
• លក្ខណ៍របស់បុរសស្ត្រី ( ព្រូច ភុំ ) ........................ ៥២
• ចាស់ទុំរិលក្បុង ( មៀច ប៉ុណ្ណ ) ........................ ៥៦

## IV. កំណាត់ និង ប្រវត្តិការណ៍

• អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ........................ ៦០
• សុន្ទរកថាស្វាគមន៍ របស់ឯកឧត្តមរដ្ឋមន្ត្រី ជា សាវឿន ........................ ៦៧
• សុន្ទរកថា សម្តេច ជា ស៊ីម ក្នុងមហាសន្និបាតមន្ត្រីសង្ឃ ........................ ៧២
• សេចក្តីថ្លែងយោបល់របស់ឯកឧត្តមរដ្ឋមន្ត្រី ជា សាវឿន
ក្នុងសម័យប្រជុំពេញអង្គ ស្តីពីស្ថានភាពពុទ្ធសាសនា ........................ ៧៨
• សង្ឃប្រកាសរួម របស់ មហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ........................ ៨៩

# សារលិខិត
# ថ្លែងអំណរព្រះករុណាធិគុណ

--------

សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម សីហនុ និងសម្តេចព្រះរាជអគ្គមហេសី នរោត្តមមុនីនាថ សីហនុ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់

បពិត្រព្រះករុណាថ្លៃវិសេស,

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ស្តីពី « កិច្ចពង្រឹងការប្រតិបត្តិពុទ្ធសាសនា » បានប្រព្រឹត្តទៅនៅរាជធានី ភ្នំពេញ ក្នុងបរិយាកាសសាមគ្គីភាព និងភាតរភាពខ្ពស់ ហើយទទួលបានលទ្ធផលគួរអោយអបអរយ៉ាងក្រៃលែង ។ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ទ្រង់ជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ក្នុងអង្គមហាសន្និបាត ។

ក្នុងរយៈពេល ៣ ថ្ងៃ គឺពីថ្ងៃទី ១០ ដល់ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ១៩៩៩, អង្គមហាសន្និបាតមន្ត្រីសង្ឃ បានពិភាក្សាប្តូរយោបល់យ៉ាងច្រើន ទាក់ទងនឹងរបៀបវារៈ ៤ ដែលជាកម្រងយុទ្ធវិធីនៃកិច្ចពង្រឹងការប្រតិបត្តិពុទ្ធសាសនា គឺ :

1). ការគោរពប្រតិបត្តិធម៌-វិន័យ និងអភិសមាចាររបស់ព្រះសង្ឃ និងពុទ្ធបរិស័ទ ។

2). ការគ្រប់គ្រងវត្តអារាម ធ្វើអោយវត្តអារាមនីមួយៗ មានដំណើរប្រព្រឹត្តទៅល្អ, ត្រឹមត្រូវ ប្រាសចាកអធិករណ៍ ក្រោមការដឹកនាំ ដ៏មានប្រសិទ្ធភាពរបស់លោកគ្រូចៅអធិការវត្ត ។

3). ពង្រឹងគុណភាពពុទ្ធិកសិក្សា ដើម្បីអភិវឌ្ឍធនធានបព្វជិតពុទ្ធសាសនិក សំដៅលើកកំពស់កិត្យានុភាពព្រះភិក្ខុសង្ឃ និងជ្រោងទង់ព្រះធម៌ របស់

ព្រះពុទ្ធបរមគ្រូអោយតាំងនៅខ្ពស់ត្រដែត ជានិរន្តរ៍ !

4). ពង្រឹង « អំណាចពុទ្ធចក្រ » គឺអំណាចរបស់មន្ត្រីសង្ឃដឹកនាំគ្រប់លំដាប់ថ្នាក់ ដើម្បីគ្រប់គ្រងបព្វជិតពុទ្ធសាសនិក និងវត្តអារាម អោយបានចំរើន ល្អលាស់ មានសណ្តាប់ធ្នាប់ល្អ និងរួមចំណែកដ៏សកម្ម ក្នុងការអភិវឌ្ឍន៍សង្គម ។

ចំណុចពិភាក្សាទាំងឡាយក្នុងអង្គមហាសន្និបាត ដែលមន្ត្រីសង្ឃទាំងពីរគណៈបានព្រមព្រៀងគ្នាហើយ ដើម្បីដាក់ចេញជាគោលការណ៍ប្រតិបត្តិ ត្រូវបានរៀបចំជាអត្ថបទ « សង្ឃប្រកាសរួម » និងឡាយព្រះហស្តលេខាដោយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ទុកជាអត្ថបទផ្លូវការ ហើយផ្សព្វផ្សាយជាសាធារណៈសំរាប់ព្រះសង្ឃទាំងពីរគណៈ និងពុទ្ធបរិស័ទ ប្រតិបត្តិតាម ដោយគ្មានការបែងចែកឡើយ ។

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងមន្ត្រីរាជការ បំរើការនៅក្រសួងធម្មការ និងសាសនា សូមលំឱនកាយថ្វាយអំណរព្រះករុណាទិគុណ ព្រមទាំងកតញ្ញូតាធម៌ ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះករុណាថ្លៃវិសេសទាំងពីរព្រះអង្គ ដែលទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រទានព្រះរាជទ្រព្យចំនួន ១០.០០០ ដុល្លារសហរដ្ឋអាមេរិក ឧបត្ថម្ភដំណើរប្រព្រឹត្តទៅនៃអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ នេះ ។ ព្រះរាជទ្រព្យនេះ ត្រូវបានចំណាយប្រើប្រាស់ក្នុងស្មារតីសន្សំសំចៃខ្ពស់ ដើម្បីជាគុណប្រយោជន៍ដល់ការងារមហាសន្និបាតមន្ត្រីសង្ឃទាំងស្រុង ដែលញ៉ាំងអោយបរិយាកាសមហាសន្និបាតទាំងមូល គ្របដណ្តប់ដោយបញ្ញាភ្លឺថ្លា និងមេត្រីភាពដ៏ត្រជាក់ត្រជុំបំផុត ក្រោមព្រះរាជាធិបតីភាពដឹកនាំរបស់សម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ ។

ឆ្លៀតឱកាសដ៏ប្រសើរនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមសំដែងគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងស្វាមីភ័ក្តិ ឥតងាករេ ចំពោះព្រះករុណាថ្លៃវិសេស ដែលទ្រង់បាន

បំពេញដោយជោគជ័យនូវព្រះរាជបេសកកម្មជាប្រវត្តិសាស្រ្ត ក្នុងការបង្រួបបង្រួមផ្ទះផ្សារជាតិ ហើយឈានទៅអភិវឌ្ឍន៍ប្រទេសតាមទិសស្លោក សន្តិភាព បង្រួបបង្រួមជាតិ និងអភិវឌ្ឍន៍សង្គម ។ ព្រះរាជមាគ៌ានយោបាយដឹកនាំប្រទេសជាតិ និងតម្រង់ទិសសង្គម ដែលព្រះករុណាជាអម្ចាស់ទ្រង់កំពុងអនុវត្តសព្វថ្ងៃ គឺពិតជាត្រឹមត្រូវ ភ្លឺស្វាង នាំមុខទៅរកការលើកស្ទួយជីវភាពប្រជាពលរដ្ឋជាកូន-ចៅ ចៅទួតរបស់ព្រះអង្គ ដើម្បីរស់នៅត្រជាក់ត្រជំ, សម្បូរសប្បាយ និងសុខក្សេមក្សាន្ត ។

ជាថ្មីម្តងទៀត ក្នុងនាមមន្ត្រីសង្ឃទីរាជាគណៈ ទីឋានានុក្រម និងមន្ត្រីធម្មការ ដែលនិមន្ត-អញ្ជើញមកពីខេត្ត-ក្រុងទាំង ២៤, ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមឧទ្ទិសព្រះមហាកុសល ដែលកើតឡើងពីការរៀបចំអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី ៨ ថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសី និងសូមសំបូងសង្រួងដល់ទេព្តារក្សាស្វេតច្ឆ័ត្រ, ព្រះបារមីនៃព្រះអតីតមហាក្សត្រ, និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមតាមជួយថែរក្សាការពារព្រះករុណាថ្លៃវិសេសទាំងពីរព្រះអង្គ សូមបានប្រកបដោយព្រះបរម-សុខុមាលភាពបរិបូណ៌ ព្រះពលានុភាពខ្លាំងក្លា និងមានព្រះជន្មយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ជាម្លប់ដ៏ត្រជាក់ត្រជុំគ្រប់ដណ្តប់លើកូនចៅ ចៅទួត របស់ព្រះអង្គ អស់កាលជាអង្វែងតទៅ !

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស

ធ្វើនៅរាជធានី ភ្នំពេញ, ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩

ទូលព្រះបង្គំជាខ្ញុំ

**ជា សាវឿន**

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

# តម្លៃនៃសាមគ្គី និង ផលអាក្រក់នៃការបែកបាក់សាមគ្គី

ឱម ខែម
ដកស្រង់រៀបរៀង

## I. សេចក្តីផ្តើម :

ក្រោមពន្លឺនៃព្រះពុទ្ធសាសនា ប្រជារាស្ត្រកម្ពុជាយើងនឹងបន្តឈានជើងចូលសតវត្សទី ២១ ។ អ្វីដែលតួនាទីសំខាន់សំរាប់ពេលបច្ចុប្បន្ន និងអនាគតរបស់កម្ពុជា គឺ សុខសន្តិភាព ស្ថិរភាព អហឹង្សា ភាពសុខដុមរមនា ក្នុងស្មារតីបង្រួបបង្រួមសាមគ្គី ឯកភាពជាតិ ប្រកបដោយក្តីស្រឡាញ់រាប់អានគ្នា មានភាពអត់ឱនយោគយល់ សន្តោសប្រណីគ្នាក្នុងមេត្តាធម៌ យុត្តិធម៌ សច្ចធម៌ ដើម្បីឈោងចាប់វឌ្ឍនភាព ភាពរុងរឿងថ្កើងថ្កានឡើងវិញ មានកិត្តិយស មានឋានៈស្មើមុខស្មើមាត់នឹងប្រទេសនានា ក្នុងសហគមន៍ប្រជាធិបតេយ្យអន្តរជាតិ ។

បទពិសោធន៍ និងវិចារណញ្ញាណ បានបង្ហាញអោយឃើញថា យើងនឹងរកឃើញផ្លូវសុខសាន្តមួយដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ លុះណាតែយើងទាំងអស់គ្នាស្រុះចិត្តមូលគំនិតយកព្រះធម៌ជាផ្លូវសំរាប់អប់រំកាយ-ចិត្ត-ស្មារតី ដើម្បីជម្រុះចោលនូវគំនុំ ការច្រណែននិន្ទា និងការសងសឹកគ្នាតាមមធ្យោបាយហឹង្សា ។

ជាការពិតណាស់, សង្គ្រាមប្រឡូកវ៉ាយគ្នាដោយអាវុធជាង ៣ ទសវត្សបានផុតរលត់ទៅហើយមែន តែស្មារតីហឹង្សានិយម ពុំទាន់បានផុតរលត់នៅឡើយទេ អាស្រ័យដោយស្រមោលអតីតកាលនៃការបែកបាក់សាមគ្គី បានចាក់ឫសជ្រៅនៅ

ក្នុងសង្គមជាតិយើង ។ ដូច្នេះ តោងតែយើងខិតខំសំរាតកាយ-ចិត្ត-ស្មារតីទាំងអស់គ្នា សម្រួចយកព្រះធម៌នៃព្រះសម្មាសម្ពុទ្ធជាមនោគមវិជ្ជាជាតិ ដើម្បីកប់អោយជ្រៅនូវភាពសៅហ្មងពីអតីតកាល ហើយប្រមូលផ្តុំកម្លាំងសាមគ្គីប្រជាជាតិទាំងមូលដើរឆ្ពោះទៅមុខតាមគន្លងធម្មាធិបតេយ្យពិតប្រាកដនៃព្រះពុទ្ធបរមគ្រូ និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ តាមគោលការណ៍នៃនីតិរដ្ឋ ។

កិច្ចការដ៏ធំធេងនេះ ទាមទារការបន្តចូលរួមវិភាគទានដ៏សកម្មថែមទៀតពីមន្ត្រីសង្ឃដឹកនាំគ្រប់លំដាប់ថ្នាក់ និងពីព្រឹទ្ធាចារ្យទាំងឡាយ ដើម្បីណែនាំ រំលឹកដាស់តឿនឧបាសក ឧបាសិកា និងប្រជាពលរដ្ឋគ្រប់វ័យរបស់យើង អោយយល់ពី « តម្លៃនៃសាមគ្គី និងផលអាក្រក់នៃការបែកបាក់សាមគ្គី » តាមរយៈការសំដែងធម៌ទេសនា ឬតាមពិធីផ្សេងៗ នៅគ្រប់ទីកន្លែងជាប្រចាំ សំដៅបង្កើតឡើងនូវបរិយាកាសសុខក្សេមក្សាន្តថ្មី ប្រកបដោយជំនឿទុកចិត្តគ្នាទៅវិញទៅមកក្នុងសង្គមជាតិយើង ។

## II. តម្លៃនៃសាមគ្គី និងផលអាក្រក់នៃការបាក់បែកសាមគ្គី :

សូមលើកយកពុទ្ធភាសិតមកតម្កល់ទុកជាគោលថា :

*សុខា សង្ឃស្ស សាមគ្គី, សមគ្គានំ តបោ សុខោ*

« ការព្រមព្រៀងគ្នានៃពួកក្រុម នាំអោយមានសុខស្រួល, សេចក្តីព្យាយាមរបស់អ្នកដែលមានការព្រមព្រៀងគ្នា នាំអោយបានសុខស្រួល » ។ នេះជាឱវាទនៃព្រះសក្យមុនីគោតមបរមគ្រូរបស់យើង ។

មនុស្សដែលមានចំនួនតាំងពីបួនប្រាំនាក់ឡើងទៅ រហូតរាប់រយរាប់ពាន់នាក់ ហៅថាពួក ឬក្រុម ដែលតាមភាសាបាលីថា « សង្ឃ » ប្រែថា ពួក ឬក្រុម ។ ក្នុងពួកក្រុមនីមួយៗ បើមានសាមគ្គី គឺការព្រមព្រៀងគ្នា ទើបបានសេចក្តីសុខ ។ ឯ

សេចក្តីសុខនោះ គឺស្រួល ឥតលំបាកចិត្ត ឥតទាស់ទែងគ្នា ឥតមានហេតុដែលនាំអោយស្អុះស្អាប់ក្នុងចិត្ត ។

ពួកក្រុមដែលមានការព្រមព្រៀងគ្នា ត្រូវការបំពេញករណីយកិច្ចណាមួយ, សេចក្តីព្យាយាមនោះ នឹងនាំអោយបានសុខស្រួលទៀត គឺថា នឹងបានសំរេចតាមបំណង ឥតមានឧបសគ្គណាមួយមកស្កាក់ដំណើរបានឡើយ ព្រោះសាមគ្គីជាគ្រឿងឧបករណ៍មួយដ៏ធំក្រៃលែង ជាកម្លាំងចលករមួយដ៏ខ្លាំងក្លាបំផុត ឬជាអាវុធមួយដ៏សក្តិសិទ្ធិបំផុត ។

អាស្រ័យហេតុនេះ យើងអ្នកប្រាថ្នាសេចក្តីសុខចំរើន គួរតែរកឧបាយបង្កើត « សាមគ្គីធម៌ » អោយកើតឡើង ព្រោះសាមគ្គីធម៌នេះ មិនមែនកើតឡើងដោយឯកឯងទេ ត្រូវតែរកឧបាយបង្កើត ទើបកើតឡើងបាន ។

ឯឧបាយបង្កើត « សាមគ្គី » នោះ មានដូចតទៅ ៖

១. ប្រជុំគ្នារឿយៗ តាមកាលបរិច្ឆេទ ដើម្បីពិគ្រោះរកប្រយោជន៍,

២. ចូលទៅកាន់ទីប្រជុំ ទាំងក្រោកចាកទីប្រជុំ ត្រូវមានសាមគ្គី,

៣. មិនត្រូវយករឿងដទៃក្រៅអំពីរបៀបវារៈមកនិយាយ,

៤. ត្រូវគោរពស្តាប់គ្នា ក្នុងការពិគ្រោះកិច្ចការណាមួយ,

៥. និយាយការណាមួយ គប្បីវៀរចាកអគតិធម៌,

៦. ត្រូវរកឧបាយនិយាយអោយមានសាមគ្គីធម៌រឿយៗ,

៧. ត្រូវធ្វើខ្លួនគ្រប់គ្នាអោយតាំងនៅក្នុងសច្ចធម៌, គោរពស្តាប់ប្រធាន,

៨. ត្រូវនិយាយដោយពាក្យទន់ផ្អែម ទាំងប្រកបដោយសារប្រយោជន៍ ។

សេចក្តីដែលពោលមកខាងលើនេះ ឃើញថា ការព្រមព្រៀងគ្នាជាចំណុចសំខាន់ក្នុងពួកក្រុមនិមួយៗ ។ ការព្រមព្រៀងគ្នានោះមាន ៣ យ៉ាងគឺ ៖

១. ការព្រមព្រៀងគ្នាដោយកាយ ហៅថា « កាយសាមគ្គី » ,

២. ការព្រមព្រៀងគ្នាដោយវាចា ហៅថា « វចីសាមគ្គី » ,

៣. ការព្រមព្រៀងគ្នាដោយចិត្ត ហៅថា « មនោសាមគ្គី ឬចិត្តសាមគ្គី »,

ដូចម្តេចហៅថា ការព្រមព្រៀងគ្នាដោយកាយ វាចា និងចិត្ត ?

• ការព្រមព្រៀងគ្នាដោយកាយ បានសេចក្តីថា ក្នុងពួក ឬក្រុមនីមួយៗ ដែលជាសង្គមតូច ឬធំ កាលបើមានកិច្ចការអ្វីមួយដែលត្រូវធ្វើរួមគ្នា, ឥតមានអ្នកណាមួយហ៊ានសំងំលាក់ខ្លួនឡើយ គឺទៅរួបរួមជាមួយគ្នាជួយបំពេញកិច្ចការនោះតាមកាលវេលាដែលបានកំណត់ទុក វៀរលែងតែមានធុរៈផ្ទាល់ខ្លួន ជាធុរៈចាំបាច់ ហើយបានអោយដំណឹងជាមុន ។

• ការព្រមព្រៀងគ្នាដោយវាចា បានសេចក្តីថា ក្នុងឱកាសដែលពួកក្រុមមានការប្រជុំបញ្ចេញយោបល់រៀងខ្លួន ចំពោះកិច្ចការណាមួយដែលត្រូវបង្កើត ត្រូវធ្វើ, អង្គប្រជុំក្នុងពួកក្រុមនោះចេះស្តាប់គ្នាទៅវិញទៅមក បើឃើញថា អ្នកណាមានវាចាសមហេតុផលហើយ ក៏អនុលោមភ្លាម មិនមានគំនិតគិតប្រឆាំង ហើយចេះតែស្រែកតវ៉ា ដោយមិនសមតាមហេតុផលឡើយ ។ បើអ្នកណាម្នាក់ស្តាប់ទីប្រជុំដែលថ្លែងសេចក្តីនោះមិនពេញចិត្តខ្លួន ក៏សូមឱកាសថ្លែងអោយទីប្រជុំស្តាប់នូវយោបល់របស់ខ្លួន ទោះបីគេទទួលយក ឬមិនទទួលយក ក៏មិនអាក់អន់ស្រពន់ចិត្ត ។ មនុស្សភាគតិចក្នុងទីប្រជុំ ត្រូវអនុលោមស្របតាមមនុស្សភាគច្រើនជាដរាប ។

• ការព្រមព្រៀងគ្នាដោយចិត្ត បានសេចក្តីថា មានចិត្តស្មើគ្នា មានអធ្យាស្រ័យត្រូវគ្នា មិនធ្វើចិត្តអោយបែកកន្ទែកចេញពីគ្នា មិនតាំងចិត្តដណ្តើមប្រជែងយកឈ្នះគ្នា គឺធ្វើចិត្តអោយស្របរួមជាមួយគ្នា ។ ការធ្វើចិត្តដូច្នេះ ជាការកម្រណាស់ ព្រោះតាមគម្ពីរក្នុងព្រះពុទ្ធសាសនាថា មនុស្សក្នុងលោកនេះ គឺមានកាយក៏ផ្សេងគ្នា ចិត្តក៏ផ្សេងគ្នាដែរ, ទាំងកាយទាំងចិត្តមិនដូចគ្នាទេ ( នានត្តកាយា នានត្តសញ្ញី ) ។ នេះជាសេចក្តីពិតមែន ព្រោះរូបកាយនៃមនុស្សរាប់សែនរាប់លាននាក់ សុទ្ធតែផ្សេង

ពីគ្នា បើមិនផ្សេងច្រើនក៏គង់ផ្សេងបន្តិចបន្តួច សូម្បីកូនភ្លោះក៏គង់ផ្សេងគ្នាខ្លះដែរ ល្មមអោយចំណាំបាន ឥតមានច្រឡំគ្នាឡើយ ។ រូបកាយផ្សេងពីគ្នាយ៉ាងណា ចិត្តក៏ផ្សេងគ្នាយ៉ាងនោះដែរ ។ អ្នកមានគំនិតប្រាជ្ញាដែលប្រាថ្នាចង់បានសេចក្ដីសុខ រវាងខ្លួន និងអ្នកដទៃក្នុងពួកក្រុម ឬសង្គមនីមួយៗនោះ ត្រូវតែប្រដៅចិត្ត ពត់ចិត្ត រក្សាចិត្ត សម្របសម្រួលចិត្តរបស់ខ្លួនអោយស្របរួមជាមួយគ្នា មិនដណ្ដើមប្រជែងយកឈ្នះគ្នា បោះបង់អស្មិមានះចេញ ដើម្បីយកឱកាសអោយមនោសាមគ្គី ឬចិត្ត-សាមគ្គី គឺការព្រមព្រៀងគ្នាតាមផ្លូវចិត្តកើតឡើងក្នុងពួកក្រុមរបស់ខ្លួន វៀរលែងតែមនុស្សខ្លះក្នុងពួកក្រុមជាមួយ ដែលជាមនុស្សទុរជន មានគំនិតអាក្រក់ មានសេចក្ដីយល់ខុសយ៉ាងជាក់ច្បាស់, មនុស្សបែបនេះ មិនត្រូវសម្របចិត្តអនុលោមបានឡើយ ត្រូវតែរួមគ្នាបដិសេធមនុស្សដែលមានគំនិតអាក្រក់នោះចេញ កុំអោយនៅក្នុងពួក ឬក្នុងសង្គមជាមួយឡើយ ។

ពួកក្រុម ឬសង្គមណាមួយ ដែលមានការព្រមព្រៀងគ្នាហើយ កាលបើត្រូវការនឹងបំពេញមុខការណាមួយ ដែលមានប្រយោជន៍ជាសាធារណៈ សូម្បីការនោះធំ ហើយកម្រផងយ៉ាងណាក្ដី, បើក្រុម ឬសង្គមនោះ មិនបោះបង់សេចក្ដីព្យាយាមចោលទេ កិច្ចការទាំងនោះគង់នឹងបានសំរេចតាមបំណងបានយ៉ាងឆាប់រហ័សជាប្រាកដ ដោយអាស្រ័យសាមគ្គីយ៉ាងមាំមួន ព្រោះសាមគ្គីចាត់ជាកម្លាំងចលករដ៏ធំ និងជាអាវុធអាចការពារសត្រូវ ឧបសគ្គ គ្រោះថ្នាក់ ភយន្តរាយ មិនអោយចូលមកបៀតបៀនបានឡើយ ។ យ៉ាងណាមិញ :

- សត្វកណ្ដៀរ មាឌតូចៗ ប៉ុន្តែវាមានការប្រឹងប្រែងមិនឈប់ នាំគ្នាជញ្ជូនដីពូនជាដំបូកមានកំពស់ពីរ-បីជំហរមនុស្ស សម្រាប់ជ្រកកោន ពួនសំងំរបស់វាបាន ។

- ឆ្កែព្រៃ មានមាឌតូចៗជាងឆ្កែស្រុកសោះ ប៉ុន្តែ វាសាមគ្គីគ្នាបង្កើតជាកម្លាំងមួយ អាចហ៊ានចោមរោមខាំខ្លា រាជសីហ៍ ដែលជាម្រឹគធំៗ ដ៏មានអំណាចកាច

សាហាវក្រៃលែងយកទៅស៊ីបាន ។

ព្រះពុទ្ធបរមគ្រូជាម្ចាស់ ទ្រង់ឧស្សាហ៍សំដែងអំពីសាមគ្គីធម៌នេះប្រាប់ពុទ្ធបរិស័ទជាញឹកញយណាស់ ទ្រង់សរសើរសាមគ្គីរស ថាជាកិច្ចត្រូវបំពេញ ព្រមទាំងអានិសង្សនៃសាមគ្គីធម៌ ដោយអនេកបរិយាយ ព្រោះហេតុថា សាមគ្គីនេះជាគុណជាតិប្រសើរបំផុតក្នុងការស្វែងរកសន្តិសុខ ដើម្បីប្រទេសជាតិ សាសនា របស់ខ្លួន ។ សាមគ្គីនេះ ទុកដូចជាស្ពានមុខនៃសន្តិសុខ និងវឌ្ឍនធម៌ ។ ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ទ្រង់មិនដែលសំដែងសរសើរអំពីការបំបែកបំបាក់សាមគ្គីថាជាហេតុផ្តល់នូវសន្តិភាព និងវឌ្ឍនភាពសោះឡើយ មានតែទ្រង់សំដែងបំភ្លឺចំពោះពុទ្ធ-បរិស័ទអោយយល់ពីផលអាក្រក់នៃការបែកបាក់សាមគ្គី អោយប្រយ័ត្នមិនអោយបែកសាមគ្គីជារឿយៗណាស់, ព្រោះការបែកបាក់សាមគ្គី ជាហេតុមួយនាំអោយជាតិសាសនា របស់ប្រទេសនីមួយៗអន្តរាយវិនាសទៅជាប្រាកដ ។

ការបំបែកសាមគ្គី លោកពោលថាជាទោសធំបំផុត ។ បណ្តាទោសទាំងអស់, ការញុះញង់បំបែកបំបាក់សាមគ្គី ត្រូវទទួលទោសកំហុសយ៉ាងធ្ងន់ជាងទោសឯទៀតៗ ។ ដូចយ៉ាងទោសអនន្តរិយកម្មទាំង ៥ (*) លោកលើកយក " សង្ឃភេទ " ( ការបំបែកពួកក្រុម ) ថាជាទោសធំបំផុត ។ សមដូចជាពុទ្ធភាសិតក្នុងគម្ពីរចុល្លវគ្គវិនយបិដក ត្រង់សង្ឃភេទក្ខន្ធកៈថា : " *អបាយិកោ នេរយិកោ កប្បដ្ឋោ សង្ឃ-ភេទកោ វគ្គរតោ អធម្មដ្ឋោ យោគក្ខេមា បធំសតិ សង្ឃំ សមគ្គំ ភិន្ទិត្វា កប្បំ និរយម្ហិ បច្ចតិ* " ភិក្ខុអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនតម្កល់នៅក្នុងធម៌ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរកតាំងនៅអស់មួយកប្ប រមែងឃ្លាតចាកធម៌ជា

(*) មាតុឃាត សម្លាប់មាតា, បិតុឃាត សម្លាប់បិតា, អរហន្តឃាត សម្លាប់ព្រះអរហន្ត លោហិតុប្បាទ ប្រទូស្តព្រះពុទ្ធអង្គ រហូតដល់ញ៉ាំងព្រះលោហិតអោយពុះពង ឬអោយជាំជាំ, សង្ឃភេទ ញ៉ាំងសង្ឃអោយបែកគ្នា ។

គ្រឿងក្បេមចាកយោគៈ ។ ភិក្ខុអ្នកបំបែកសង្ឃដែលកំពុងតែមានសេចក្ដីព្រមព្រៀងគ្នា រមែងឆេះនៅក្នុងនរកអស់មួយកប្ប ។

ក្នុងការបែកសាមគ្គី ដែលរមែងអោយផលអាក្រក់ គឺសេចក្ដីវិនាសហិនហោចនោះ គួរនាំយករឿងមួយ ដែលមានក្នុងគម្ពីរព្រះពុទ្ធសាសនាមកថ្លែងបញ្ជាក់ដោយសង្ខេប ទុកជាឧទាហរណ៍សំរាប់ពិចារណា ដូចតទៅនេះ :

មានរដ្ឋ ១ ឈ្មោះវជ្ជី មានពួកក្សត្រលិច្ឆវីជាអ្នកគ្រប់គ្រង, ក្សត្រទាំងនោះ ព្រមទាំងមន្ត្រី បណ្ដារាស្ត្រ និងយុវជនដែលសិក្សាក្នុងសាលារៀន មានសាមគ្គីព្រមព្រៀងគ្នាល្អណាស់ ។ ក្នុងដែលវជ្ជីនោះ មានការប្រជុំគ្នាញឹកញយណាស់ ពិនិត្យមើលកិច្ចការដែនដីទាំងមូល ព្រមទាំងមានការគោរពគ្នាទៅវិញទៅមក ចេះរក្សាបវេណីធម៌យ៉ាងប្រសើរ ម្ល៉ោះហើយដែនវជ្ជីនោះមានកិត្តិយស កេរ្តិ៍ឈ្មោះ ផ្សាយចេញឮសាយសុសដល់ប្រទេសនានា ថាដែនវជ្ជីជាប្រទេសមានសាមគ្គីមាំមួនណាស់ ឥតមានសត្រូវណានឹងចូលទៅលុកលុយបាន ។ ព្រះបាទអជាតសត្តុរាជ សោយរាជ្យនៅក្នុងដែនមគធៈ ជាប្រទេសធំស្ដុកស្ដម្ភ មានព្រះរាជបំណងនឹងលើកទ័ពទៅវាយដែនវជ្ជីនោះអោយខ្ទេចខ្ទី ដោយមានកំហឹងចំពោះពួកស្ដេចលិច្ឆវី ក្នុងរឿងសេដ្ឋកិច្ចជាយូរហើយ ប៉ុន្តែពុំអាចនឹងលើកទ័ពចូលទៅបាន ព្រោះបានដឹថា ក្នុងដែនវជ្ជីនោះពួកក្សត្រលិច្ឆវី មន្ត្រី និងបណ្ដារាស្ត្រ មានសាមគ្គីព្រមព្រៀងគ្នា ចងបាច់គ្នាមាំមួនណាស់ ។ ទើបព្រះបាទអជាតសត្តុរាជ ទ្រង់រិះរកមធ្យោបាយផ្សេងៗ ដើម្បីនឹងលើកទ័ពទៅវាយដែនវជ្ជីនោះអោយបានដោយងាយ ។ តមក ទ្រង់បានសំរេចព្រះរាជហឫទ័យថា ត្រូវធ្វើនយោបាយសម្ងាត់ ដើម្បីបំបាក់បំបែកសាមគ្គីរបស់ពួកស្ដេចលិច្ឆវីអោយបានមុនសិន សឹមលើកទ័ពទៅវាយជាខាងក្រោយ ។ លុះសំរេចព្រះរាជហឫទ័យ ទ្រង់ចាត់ប្រើវស្សការព្រាហ្មណ៍ ជាវិនិច្ឆយាមាត្យ ជាអ្នកនយោបាយ យ៉ាងសំខាន់ម្នាក់ អោយទៅបំបាក់បំបែកជនក្នុងដែនវជ្ជី ដោយប្រើឧបាយកលធ្វើជាចាប់

ទោសវស្សការព្រាហ្មណ៍នោះ ហើយដេញចេញអំពីដែនមគធៈ ដើម្បីអោយពួកក្សត្រក្នុងដែនវជ្ជីទទួលវស្សការព្រាហ្មណ៍នោះអោយនៅក្នុងដែនវជ្ជីដោយឥតរង្កៀស ។ កាលបើវស្សការព្រាហ្មណ៍ទៅដល់ដែនវជ្ជី ពួកក្សត្រលិច្ឆវី ក្រោយដែលបានដឹងថាព្រាហ្មណ៍នោះ ត្រូវព្រះបាទអជាតសត្តុរាជបណ្តេញចេញ ក៏ទទួលវស្សការព្រាហ្មណ៍នោះអោយនៅដោយសុខស្រួល ព្រមទាំងអោយឋិតនៅក្នុងតំណែងជាវិនិច្ឆយាមាត្យ ដូចកាលនៅក្នុងដែនមគធៈ ។ វស្សការព្រាហ្មណ៍ មុនដំបូងបានធ្វើការថ្វាយចំពោះក្សត្រលិច្ឆវីដោយយកចិត្តទុកដាក់ ហាក់ដូចជាមានការស្មោះត្រង់ណាស់ចំពោះដែនវជ្ជី នាំអោយពួកក្សត្រលិច្ឆវីពេញព្រះរាជហឫទ័យឥតមានរង្កៀសអ្វីឡើយ ហើយបានទាំងប្រគល់ឋានៈជាអ្នកបង្ហាត់បង្រៀនវិជ្ជាផ្សេងៗ ដល់ពួកយុវក្សត្រលិច្ឆវីទាំងឡាយផងទៀត ។ វស្សការព្រាហ្មណ៍ បានដឹងថាពួកក្សត្រលិច្ឆវី ឥតមានសេចក្តីរង្កៀសអ្វីនឹងខ្លួន និងឃើញថាពួកក្សត្រទាំងនោះមានការធ្វេសប្រហែសហើយ ក៏ចាប់ផ្តើមធ្វើវិទ្ធង្សនាបំបាក់បំបែក តាំងពីយុវជនដែលកំពុងសិក្សា ដោយវិធីខ្សិបខ្សៀវនឹងយុវជន ១ នាក់ៗ រាល់ថ្ងៃ បណ្តាលអោយយុវជនកើតមានសង្ស័យអស់ជំនឿកគ្នាបន្តិចម្តងៗ យូរទៅៗ ពួកក្មេងៗក៏បែកគ្នាជាបក្សជាពួក យូរៗទៅទៀតក្សត្រ មន្ត្រី ក៏បែកបាក់គ្នា តទៅទៀត ពួកប្រជាពលរដ្ឋ ក៏បែកបាក់គ្នាទៀត កើតទៅជាបក្សពួក លែងជឿគ្នាទៅវិញទៅមក រហូតដល់ទៅក្នុងដែនវជ្ជី បែកសាមគ្គីលែងរួបរួមគ្នាកើត ។

ព្រះបាទអជាតសត្តុរាជ កាលបើបានជ្រាបថា ក្នុងដែនវជ្ជីនោះមានការបែកបាក់សាមគ្គីហើយ ឥតមានការរួបរួមគ្នាដូចកាលមុនទេ ក៏លើកទ័ពចូលទៅវាយដែលវជ្ជីនោះបានសំរេចដូចបំណងភ្លាម ។

និទានកថាសង្ខេបខាងលើនេះ គួរជនទាំងឡាយដែលប្រាថ្នាចង់បានសុខចំរើន គប្បីពឹងពិចារណាយកទុកជាឧទាហរណ៍ ហើយប្រុងប្រយត្នរក្សាសាមគ្គី

អោយបានមាំមួន កុំអោយបែកបាក់គ្នាអោយសោះ បើទុកជាមានហេតុអ្វីកើតឡើងក្នុងសង្គម ជាហេតុគួរអោយមានទោមនស្ស គួរអោយឈឺចាប់ក្នុងសង្គមដែលបណ្ដាលកើតមកអំពីពួកជនក្នុងសង្គមជាមួយ ឬអំពីជនដទៃ ដែលជាសាមគ្គីភេទកៈ ( អ្នកបំបែកបំបាក់សាមគ្គី ) ក៏ត្រូវតែខំប្រឹងទប់ចិត្តអត់ធន់ចំពោះហេតុនោះៗអោយបាន ហើយត្រូវប្រុងស្មារតីប្រយត្ន គិតពិចារណាអោយទាន់ពេល កុំអោយសង្គមរបស់ខ្លួនប្រេះឆា បាក់បែកក កុំអោយធ្លាក់ទៅក្នុងសាមគ្គីភេទ ទោះបីមានហេតុដ៏ធ្ងន់យ៉ាងណាក៏ដោយ ក៏ត្រូវតែខំប្រឹងទប់ទល់រក្សាសង្គមរបស់ខ្លួនអោយមានសាមគ្គីជាដរាបតទៅ ព្រោះការបែកសាមគ្គីក្នុងសង្គមនីមួយៗ នាំអោយមានផលអាក្រក់ច្រើនយ៉ាងគឺ :

- សុខកាយសប្បាយចិត្តរលាយអស់ ទុក្ខព្រួយលំបាកកើតឡើង,
- សង្គមរបស់ខ្លួនខ្សោយកម្លាំង មានសត្រូវប្រឆាំងកាន់តែច្រើន,
- ពួកជនក្នុងសង្គម មានចិត្តក្ដៅក្រហាយជានិច្ច,
- កិត្តិយស និងកេរ្ដិ៍ឈ្មោះរបស់សង្គមត្រូវអាប់ឱន,
- កិច្ចការរបស់ជនក្នុងសង្គម តែងជួបនឹងឧបសគ្គផ្សេងៗ,
- ជួនកាលសង្គមរបស់ខ្លួន ត្រូវរលាយរលត់ទៅក៏មាន ។

ឯការបំបែកបំបាក់សាមគ្គី បង្កើតអសន្តិសុខ ធ្វើអោយអន្តរាយដល់សាមគ្គីធម៌នេះកើតឡើង ដោយសារហេតុច្រើនប្រការគឺ ដោយសារ *ឧបក្កិលេស*, ដោយសារ *អគតិធម៌* និងដោយសារ *ទិដ្ឋិ* ជាដើម ។

• ហេតុទី ១ ដោយសារ *ឧបក្កិលេស* ១៦ យ៉ាងគឺ :

១. *អភិជ្ឈាវិសមលោភៈ* សេចក្ដីលោភ ចង់បានហួសហេតុ បំពារបំពានរំលោភចង់បានតែរបស់គេ ។

២. *ទោសៈ* ប្រទូស្ត ឬបៀតបៀនគេ ។

៣. *កោធៈ* ក្រោធខឹង, ធ្វើទុក្ខបុកម្នេញគេ ។

៤. *ឧបនាហៈ* ចងគំនុំ ឬចងក្រោធទុក ។

៥. *មក្ខៈ* លុបគុណ ឬវេរឃើគុណគេ ។

៦. *បលាសៈ* វាយឫកស្មើ, លើកតម្កើងខ្លួន ។

៧. *ឥស្សា* ឫស្យាច្រណែនឈ្នានីសគេ ។

៨. *មច្ឆរិយៈ* កំណាញ់ស្វិតស្វាញ ។

៩. *មាយា* មានពុតត្បុតអាក្រក់ ឬបិទបាំងទោសខ្លួន ហើយទម្លាក់ទៅលើអ្នកដទៃ ។

១០. *សាថេយ្យ* អួតអាង, អែបបន្លំខ្លួន ។

១១. *ថម្ភៈ* កោងកាចព្រហើន, ចចេសមុខរឹង ។

១២. *សារម្ភៈ* អួតថាគ្រាន់, ដណ្ដើមពូកែតែឯង ។

១៣. *មានៈ* ប្រកាន់ខ្លួន, ឆ្មើងកន្ទ្រើង ។

១៤. *អតិមានៈ* មើលងាយគេ, ប្រមាថបៀតបៀនគេ ។

១៥. *មទៈ* ស្រវឹងឈ្លក់ក្នុងលាភ, យស, សុខ, សរសើរ ។

១៦. *បមាទៈ* ធ្វេសប្រហែស, ភ្លេចស្មារតី ។

• ហេតុទី ២ ដោយសារ *អគតិធម៌ ៤* យ៉ាងគឺ :

១. *ឆន្ទាគតិ* សេចក្ដីលំអៀង ឬយល់មុខ ព្រោះស្រឡាញ់ ។

២. *ទោសាគតិ* សេចក្ដីលំអៀង ឬផ្ដន្ទាទោស ព្រោះស្អប់ ។

៣. *មោហាគតិ* សេចក្ដីលំអៀង ឬកិកកុក ព្រោះល្ងង់ ។

៤. *ភយាគតិ* សេចក្ដីលំអៀង ឬរណេបរណឺបអែបអប ព្រោះខ្លាច ។

• ហេតុទី ៣ ដោយសារ *ទិដ្ឋិ ឬសត្រូវធំ* ២ យ៉ាងគឺ :

១. *សស្សតទិដ្ឋិ ឬអត្តទិដ្ឋិ* យល់ឃើញថា មានតែអញ, ... ។

១. *ឧច្ឆេទទិដ្ឋិ* យល់ថាសូន្យ គឺមិនជឿបុណ្យបាប, ... ។

ធម៌ដ៏លាមកប៉ុណ្ណេះជាដើម សុទ្ធតែផ្ទួនបំបែកសាមគ្គី, ជាមេបំផ្លាញសាមគ្គីអោយអន្តរាយសាបសូន្យទៅ ។ ដូច្នេះ គួរសប្បុរសជនចៀសវាងអោយស្រឡះ កុំបណ្ដោយអោយធម៌ដ៏ទន់ខ្សោយចូលមកដឹកនាំខ្លួនយើង គប្បីប្រើឧបាយប្រាជ្ញាញាំញីធម៌ទន់ខ្សោយនេះវិញ ទើបអាចបណ្ដុះសាមគ្គីរវាងសាសនិក ឬមនុស្សជាតិផងគ្នាអោយកើតឡើងបាន រួចហើយគប្បីខ្នះខ្នែងស្វែងរកធម៌ដែលនាំអោយកើតសាមគ្គី, រកឧបាយផ្សះផ្សាការបាក់បែកប្រេះឆាអោយជាប់ជិតស្និទ្ធឡើងវិញ ។

សាមគ្គីនឹងកើតឡើងបាន ឬសូម្បីប្រេះឆាទៅហើយ នឹងផ្សាតអោយជាបវិញបាននោះ ដោយអាស្រ័យធម៌ច្រើនប្រការគឺ សង្គហធម៌ និងសារាណិយធម៌ជាដើម ។

សង្គហធម៌ ៤ យ៉ាងគឺ :

១. *ទាន* ការអោយទេយ្យវត្ថុ ឬចែករំលែកអានុភាព និងសមត្ថភាពតាមការគួរ ។

២. *បេយ្យវជ្ជៈ* ការពោលវាចាគួរអោយចង់ឮ ចង់ស្ដាប់ ឬឧស្សាហ៍រាក់ទាក់ដោយពាក្យពិរោះចំពោះជនទូទៅមិនរើសមុខ ។ ឧស្សាហ៍រំលឹកដាស់តឿនប្រាប់ប្រយោជន៍ ច្បាប់ទម្លាប់ និងសេចក្ដីខុសត្រូវ ។

៣. *អត្ថចរិយា* ការប្រព្រឹត្តអំពើជាប្រយោជន៍ដល់គ្នានឹងគ្នា ឬប្រយោជន៍អោយកើតឡើងដល់ខ្លួន ព្រមទាំងអ្នកដទៃ ។

៤. *សមានត្តតា* ការតាំងខ្លួនស្មើៗ មិនរឹងត្អឹង មិនប្រកាន់ខ្លួនដោយជាតិ, ត្រកូល យសសក្តិ និងទ្រព្យសម្បត្តិ ។

សារាណិយធម៌ ៦ យ៉ាងគឺ :

១. *មេត្តាកាយកម្ម* ការងារដែលត្រូវធ្វើតាមផ្លូវកាយ ត្រូវប្រកបដោយ

មេត្តា ឬមេត្រីចិត្តដល់គ្នានិងគ្នា ។

២. *មេត្តាវចីកម្ម* កិច្ចការដែលត្រូវចាត់ចែងដោយសំដី ត្រូវប្រកបដោយមេត្តា ។

៣. *មេត្តាមនោកម្ម* អំពើដែលធ្វើក្នុងចិត្ត ត្រូវប្រកបដោយមេត្តា ។

៤. *លាភៈ* ការចែករំលែកលាភ, យស, សុខ, សរសើរដល់គ្នា ។

៥. *សីលៈ* ដំណើរមានសណ្តាប់ធ្នាប់ល្អ មានរបៀបបែបបទ និងសេចក្តីប្រព្រឹត្តត្រូវគ្នា ។

៦. *ទិដ្ឋិ* សេចក្តីយល់ឃើញត្រូវ, ចុះសម្រុងគ្នា ឬលទ្ធិត្រូវគ្នា ។

ធមិជ៏ឧត្តមប៉ុណ្ណេះជាដើម សុទ្ធតែជាមេ ឬជាបច្ច័យអោយកើតសាមគ្គីទាំងជាគ្រឿងផ្សាសាមគ្គី ដែលប្រេះឆាអោយជាប់មាវិញបាន ។ កាលបើស្វែងរកមេឬធមិជាបច្ច័យអោយកើតសាមគ្គី ឬធមិជាគ្រឿងផ្សាសាមគ្គីអោយកើតឡើងបានហើយ គួរតែស្វែងរកចំណីអាហារជាគ្រឿងថែរក្សាសាមគ្គីអោយមានជីវិតរស់នៅជាសកម្ម តទៅទៀត ។

ឯធមិជាចំណីអាហារសំរាប់ចិញ្ចឹមបីបាច់ថែរក្សាសាមគ្គីអោយមានជីវិតលូតលាស់ឡើង ដែលហៅថា " សាមគ្គីរក្ខា " នោះ មាន ៦ យ៉ាងគឺ :

១. *វិរិយៈ* សេចក្តីព្យាយាមក្លៀវក្លា ។

២. *ខន្តិ* សេចក្តីអត់ធន់ ឬអត់ធ្មត់ចំពោះការងារ ។

៣. *សច្ចៈ* សេចក្តីស្មោះត្រង់ដល់គ្នា, មិនក្បត់ចិត្តគ្នា ។

៤. *អធិដ្ឋាន* ការតាំងខ្ជាប់ខ្ជួនដោយឧបាយបញ្ញា ។

៥. *មេត្តា* សេចក្តីរាប់អានគ្នា ដោយស្និទ្ធស្នាល ។

៦. *បរិច្ចាគៈ* ការចែករំលែកដោយសង្គ្រោះ ឬដោយបូជាគុណ ។

សាមគ្គីរក្ខាទាំង ៦ យ៉ាងនេះ ទុកដូចជាចំណីអាហារសម្រាប់បំប៉នសាមគ្គី

អោយរីកធាត់ធំ មានកម្លាំង, ពុំនោះទុកដូចជាជីជាតិសំរាប់ស្រោចស្រង់ ប្រស់ព្រំសាមគ្គីដែលទើបនឹងដុះដាល អោយល្វតលាស់ អោយរីកចំរើនឡើង ។

ក៏សាមគ្គីនោះឯង បើប្រាសចាកធម៌ទាំងនេះហើយ ក៏រមែងរលត់រលាយក្លាយជាស្វិតស្រពោនទៅ ឬក៏បែកបាក់រលាយបាត់ទៅដោយឆាប់រហ័សពុំខាន ។ ព្រោះហេតុនោះ ជនអ្នកមានបំណងល្អចំពោះសាសនា, ប្រទេសជាតិ និងចំពោះលោកទាំងមូល ចង់អោយបានសន្តិភាព និងវឌ្ឍនភាព រុងរឿងអស់កល្បកប្បនោះ គប្បីតម្កល់ខ្លួនអោយតាំងនៅក្នុងឧត្តមធម៌ទាំងអស់ ដូចបានរៀបរាប់មកជា សង្ខេប ទើបសាមគ្គីធម៌, សីលធម៌, វឌ្ឍនធម៌ ដុះដាលល្វតលាស់ឡើង ហើយចេះតែចំរើនជាសកម្មតទៅ ។

កាលបើជាតិ សង្គមណា មានសាមគ្គីធម៌, សីលធម៌, វឌ្ឍនធម៌ និងអារ្យធម៌ ល្វតលាស់ហើយ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ទ្រង់សំដែងថា " នឹងត្រូវទទួលនូវអានិសង្សនៃសាមគ្គីរស ៧ យ៉ាង " គឺ :

១. *ទិដ្ឋធម្មេ សមគ្គានំ សុខំ ឧប្បជ្ជតិ* សេចក្តីសុខរបស់ពួកជនអ្នកព្រមព្រៀងគ្នា រមែងកើតឡើងក្នុងបច្ចុប្បន្ន ។

២. *ឧត្តរី សព្វា វុឌ្ឍិ ឧប្បជ្ជតិ* វឌ្ឍនធម៌គ្រប់យ៉ាងរមែងកើតមានឡើងយ៉ាងក្រៃលែង ។

៣. *ពុទ្ធាទយោ សមគ្គេ បសំសន្តិ* បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម រមែងសរសើរចំពោះពួកជនដែលព្រមព្រៀងគ្នា ។

៤. *បរេ ជនា ន អវមញ្ញន្តិ* ជនទាំងឡាយដទៃនឹងមិនហ៊ានមើលងាយ ។

៥. *សមគ្គានំ គាមេ ចោរកម្មំ ន ហោតិ* ចោរកម្មក្នុងស្រុករបស់អ្នកព្រមព្រៀងគ្នា មិនមាន ។

៦. *កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ* កិត្តិសព្ទដ៏ល្អរមែងល្បីល្បាញ។

៧. *កាយស្ស ភេទា បរម្មរណា សុគតី សគ្គំ លោកំ ឧបបជ្ជតិ* លុះបែកធ្លាយរាងកាយទៅ បន្ទាប់ពីសេចក្ដីស្លាប់ ក៏រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

ធម៌ទាំង ៧ ប្រការនេះ ទុកដូចជារង្វាន់មួយដ៏មានតម្លៃសំរាប់ជូនចំពោះពពួកជន ឬប្រទេសជាតិណា ដែលមានសេចក្ដីព្រមព្រៀងគ្នា ដូចជាដែនវជ្ជី នាសម័យពុទ្ធកាល ដែលមានរបៀបគ្រប់គ្រងល្អ ដឹកនាំល្អ ដោយអាស្រ័យធម៌សាមគ្គីជាហេតុ ទើបក្រុងវេសាលីដែលជារាជធានីនៃដែននោះ ទៅជាក្រុងមួយដ៏រុងរឿងបំផុត មានអារ្យធម៌ល្បីល្បាញ ផ្សាយទៅគ្រប់ទិសទី ព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រៀបប្រដូចទៅនឹងស្ថានសួគ៌ឈ្មោះ ចាតុម្មហារាជិកា ទាំងទ្រង់ព្យាករណ៍ថា " បើអ្នកដែនវជ្ជី នៅតែមានសាមគ្គី ប្រព្រឹត្តតាមអបរិហានីយធម៌ដូច្នេះ ដែនវជ្ជីនោះនឹងចំរើនរុងរឿងឥតអាក់ ឥតមានប្រទេសណាហ៊ានទៅលុកលុយក្នុងផ្ទៃក្នុងប្រទេសនេះបានឡើយ ។

តែគួរអោយស្ដាយជាទីបំផុត ដោយសម័យតមក អ្នកដែនវជ្ជីបែកសាមគ្គីគ្នាទៅជាគណៈបក្សផ្សេងៗ បៀតបៀនគ្នា កាប់សម្លាប់តែគ្នាឯង មិនយូរប៉ុន្មានក៏ត្រូវសហារដ្ឋមគធៈលើកកងទ័ពចូលមកវាយលុកទាល់តែដែនវជ្ជីរលាយរលត់រលប់ឈ្មោះបាត់ពីផែនទីលោករហូតដល់សព្វថ្ងៃ ព្រោះទោសនៃការបែកសាមគ្គីនេះឯង ។

ចូរជនានុជនក្នុងកម្ពុជរដ្ឋបានចំរើនល្អតលាស់ដោយវិជ្ជា និងវិបុលសុខគ្រប់ ហើយរួបរួមគ្នាកសាងប្រទេសជាតិ និងលើកស្ទួយព្រះពុទ្ធសាសនា អោយបានរីកចំរើនជាភិយ្យោភាព តរៀងទៅ !

សូមព្រះពុទ្ធសាសនា និងប្រទេសកម្ពុជា មានសាមគ្គីធម៌ !

សូមព្រះពុទ្ធសាសនា និងប្រទេសកម្ពុជា ប្រាសចាកសាមគ្គីភេទ !

# សេចក្ដីបរិសុទ្ធនៅត្រង់ណា ?

ឱម ខែម
ដកស្រង់រៀបរៀង

សេចក្ដីបរិសុទ្ធជាគូនឹងសេចក្ដីមិនបរិសុទ្ធ ។ សេចក្ដីបរិសុទ្ធគឺអ្វី ? សេចក្ដីបរិសុទ្ធ គឺស្អាតកាយ, ស្អាតវាចា, ស្អាតចិត្ត, មិនសៅហ្មងដោយអំពើអាក្រក់ណាមួយ ដែលគួរអោយអ្នកផងតិះដៀលបាន ។ ឯសេចក្ដីមិនបរិសុទ្ធ មានដំណើរផ្ទុយគ្នានឹងសេចក្ដីបរិសុទ្ធ ដូចបាននិយាយមកហើយនេះ ។

ក្នុងគម្ពីរធម្មបទដ្ឋកថា ខុទ្ទកនិកាយ មានសេចក្ដីពន្យល់ថា :

• មនុស្សប្រភេទណាក៏ដោយ ទោះជាខ្ពស់ក្ដី ជាន់កណ្ដាលក្ដី ជាន់ទាបក្ដី ជាអ្នកចេះលៃលករៀបចំទុកដាក់កាយអោយសមរម្យទៅតាមឋានៈរបស់ខ្លួន មិនប្រព្រឹត្តច្រឡើសបើស ជាអ្នកចេះរស់អនុលោមតាមច្បាប់សំរាប់ផ្លូវលោក និងច្បាប់សំរាប់ផ្លូវធម៌ ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ មិនប្រើកម្លាំងកាយរំលោភអោយប្រព្រឹត្តទៅហួសហេតុហួសទំនង មានការប្រហារជីវិតសត្វ និងការលោភល្មួចឆក់ដណ្ដើមរឹបជាន់ យកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយអយុត្តិធម៌ជាដើម, ជាអ្នកមានឫកពាសុភាពរាបសាល្អ ទាំងមានចរិយាធម៌ និងអបចាយនធម៌ចំពោះអ្នកដទៃមិនរើសមុខ យ៉ាងនេះជាដើម ហៅថា *កាយបរិសុទ្ធ* បរិសុទ្ធស្អាតដោយកាយ ។

• មនុស្សណាមួយ កាលបើបញ្ចេញវាចានិយាយអំពីអ្វី វាចានោះឯងមិនដែលបៀតបៀនអោយកើតសេចក្ដីរង្កៀសដល់អ្នកដទៃ ច្រើនតែនិយាយពាក្យណាដែលនាំអោយមានប្រយោជន៍ ជាវាចាសុភាពរាបសាពិរោះ មិនទ្រគោះបោះបោក

ប្រមាថមើលងាយអ្នកដទៃ, ជាសំដីគួរគេជ្រះថ្លា គួរគេចង់ស្តាប់ វាងផុតពីវចីទុច្ចរិតទាំង ៤ យ៉ាង(*) មិននាំអោយប៉ះពាល់ខូចសិទ្ធិអ្នកដទៃ យ៉ាងនេះជាដើម ហៅថា *វាចាបរិសុទ្ធ* បរិសុទ្ធស្អាតដោយវាចា ។

• មនុស្សណាមួយ បានសង្រួមប្រុងប្រយ័ត្នសំអាតចិត្តរបស់ខ្លួនអោយបរិសុទ្ធអោយតាំងនៅក្នុងកុសលធម៌ ប្រាសចាកមនោទុច្ចរិតទាំង ៣ យ៉ាង(**) មិនបណ្តោយអោយចិត្តក្រេវក្រោធ លោភលន់ ឈ្នានីស ច្រណែននិន្ទាគេ យ៉ាងនេះជាដើម ហៅថា *ចិត្តបរិសុទ្ធ* បរិសុទ្ធស្អាតដោយចិត្ត ។

អ្នកដែលបានកើតមក មានជីវិតរស់នៅក្នុងលោកនេះ មានសញ្ញាតិជាមនុស្សនីមួយៗ គប្បីញ៉ាំងកាយ វាចា ចិត្ត អោយស្ងប់រៀបរយល្អទៅតាមច្បាប់លោក និងច្បាប់ធម៌ ដែលមានកំរិតទុកមក ពុំគួរបើកអំណាចបណ្តោយអោយកាយ វាចា ចិត្ត ប្រព្រឹត្តពាយងាយតាំងនៅខាងក្រៅច្បាប់ឡើយ ព្រោះថា ការដែលបានទទួលសុខភាព, វឌ្ឍនភាព និងជោគជ័យគ្រប់ជំពូករបស់មនុស្សសត្វនីមួយៗ រមែងកើតអំពី កាយ វាចា ចិត្តដ៏បរិសុទ្ធល្អ, ឯការដែលបានទទួលទុក្ខទោស គ្រោះថ្នាក់អពមង្គលគ្រប់ជំពូក ក៏រមែងកើតមកអំពីកាយ វាចា ចិត្ត មិនបរិសុទ្ធល្អដែរ ព្រោះកាយ វាចា ចិត្ត ទាំង ៣ នេះ ទុកដូចជាទ្វារ សំរាប់បើកឱកាសអោយសុខ និងទុក្ខហូរចូលមក ឬថាជាប្រធាន ជានាទីមុខក្រសួង ជាអ្នកបង្កហេតុអោយកើតសុខ និងទុក្ខក៏បាន ។ ព្រោះហេតុនោះ សេចក្តីបរិសុទ្ធ និងសេចក្តីមិនបរិសុទ្ធិទាំងពីរនេះ ដែលកើតឡើងហើយ រមែងអោយផលដល់បុគ្គលអ្នកធ្វើចំពោះខ្លួនឯង បើនិយាយសាមញ្ញវោហារថា អ្នកណាធ្វើ ក៏ជារបស់អ្នកនោះ ឥតមានអ្នកណាធ្វើអោយអ្នកណាបរិសុទ្ធិ ឬសៅហ្មងបានឡើយ ។ រីប៉ែកខាងលទ្ធិព្រាហ្មណ៍ មានសេចក្តីប្រកាន់ថា

---

(*) និយាយកុហក, និយាយញុះញង់, និយាយចាក់ដោតគេ, និយាយពាក្យឥតប្រយោជន៍ ។

(**) សំឡឹងរំពៃចង់បានរបស់គេ, ចងចិត្តប្រទូស្តគេ, ឃើញខុសចាកគន្លងធម៌ ។

• អំពើបាបណាមួយដែលបុគ្គលធ្វើហើយ គេអាចលាងជម្រះបណ្តេញ ឬបន្សាត់ចោលបានដោយធ្វើពិធី មានងូតទឹកជាដើម គឺពេលដែលកំពុងងូតទឹកជម្រះមន្ទិលកាយ បាបនោះឯងក៏ជ្រះស្អាត អណ្តែតរសាត់ទៅតាមខ្សែទឹកជាមួយនឹងមន្ទិលកាយដែរ ។ មានលទ្ធិដទៃខ្លះទៀត ប្រកាន់ថា អំពើបាបណាមួយ ទោះបីធ្ងន់ក្តី ស្រាលក្តីដែលបុគ្គលធ្វើហើយ គេអាចទៅលន់តួអង្វរករ សូមខមាទោសចំពោះព្រះម្ចាស់សួគ៌ ដើម្បីអោយព្រះម្ចាស់សួគ៌នោះ ប្រោសប្រាណគ្រាប្រណីលើកទោសកំហុសរបស់ខ្លួនចោលចេញបាន ដូចគ្នានឹងព្រះមហាក្សត្រម្ចាស់ផែនដី ទ្រង់ប្រោសប្រាណលើកទោសព្រះរាជទានដល់អ្នកធ្វើខុសអោយផុតចាកព្រះរាជអាជ្ញាដែរ យ៉ាងនេះជាដើម ។

ចំណែកខាងព្រះពុទ្ធសាសនា មានសេចក្តីផ្ទុយគ្នានឹងលទ្ធិទាំងនោះថា *អំពើបាបដែលបុគ្គលធ្វើដោយខ្លួនឯង រមែងស្មោហហ្មងដោយខ្លួនឯង មិនធ្វើបាបដោយខ្លួនឯង រមែងបរិសុទ្ធិដោយខ្លួនឯង ។ សេចក្តីបរិសុទ្ធិ និងសេចក្តីសៅហ្មងរមែងកើតចំពោះខ្លួនអ្នកធ្វើតែម្យ៉ាងប៉ុណ្ណោះ មិនមែនកើតចំពោះហេតុដទៃឡើយ* ។ បុគ្គលដែលសៅហ្មងព្រោះអកុសលកម្ម ដែលបរិសុទ្ធចាកសេចក្តីសៅហ្មង ព្រោះកុសលកម្មប្រកបដោយប្រាជ្ញាដែលយល់ត្រូវ ។ អ្នកណាពិចារណាឃើញច្បាស់ដោយប្រាជ្ញាថា ការប្រព្រឹត្តធ្វើអកុសលកម្ម គឺអំពើជាអ-កុសលផ្សេងៗ មានសម្លាប់សត្វ និងលួចលាក់ឆក់ដណ្តើម កំហែង ឬប្រវ័ញ្ចយកទ្រព្យសម្បត្តិរបស់គេដោយអយុត្តិធម៌ជាដើម អំពើទាំងនេះសុទ្ធតែជាកម្មមានទោសជាផ្លូវអបាយ មិនប្រព្រឹត្តទៅជាប្រយោជន៍ដល់ខ្លួន និងអ្នកដទៃ ហើយក៏លះបង់ គឺមិនធ្វើអកុសលកម្មនោះតទៅទៀត អ្នកនោះឈ្មោះថាជាអ្នកបរិសុទ្ធិស្អាត សូម្បីជាអ្នកមានសេចក្តីសៅហ្មងឌិតដាមជាប់មកអំពីមុខខ្លះ ព្រោះអកុសលកម្មដែលខ្លួនធ្វើដោយសេចក្តីប្រហែសធ្វេស ល្ងង់ខ្លៅ ក៏គង់ត្រឡប់ទៅជាបរិសុទ្ធស្អាត

ដោយកុសលកម្មដែលធ្វើក្នុងកាលជាខាងក្រោយដោយពិត សមដូចពុទ្ធភាសិតថា :

*យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ*

*សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។*

អ្នកណាធ្វេសប្រហែសក្នុងកាលពីមុន លុះកាលជាខាងក្រោយមក ក៏ងាកបែរទៅជាមិនធ្វេសប្រហែសវិញ អ្នកនោះទើបឈ្មោះថាធ្វើលោកអោយភ្លឺស្វាងរុងរឿង ដូចជាព្រះច័ន្ទដែលចេញផុតពីពពក ។

អធិប្បាយបញ្ជាក់ពុទ្ធភាសិតនេះថា ជនណាមួយ កាលពីពេលមុនមកជាអ្នកមានសេចក្តីធ្វេសប្រហែសវង្វេងជ្រុល ធ្វើអំពើអាក្រក់ណាមួយដោយកាយ វាចា ចិត្ត ដែលអ្នកប្រាជ្ញលោករិះគន់ថាជាអំពើលាមកកខ្វក់សៅហ្មងមិនស្អាត លុះកាលជាខាងក្រោយមក ក៏បែរជាភ្ញាក់គំនិតដឹងខ្លួនជាខុស ហើយលះបង់សេចក្តីធ្វេសប្រហែស វង្វេងដែលធ្លាប់តែប្រព្រឹត្តធ្វើអំពើអាក្រក់នោះៗចោលចេញ ហើយប្រព្រឹត្តធ្វើតែអំពើល្អដោយកាយ វាចា ចិត្ត មានអោយទានរក្សាសីលជាដើម ជននោះឯងឈ្មោះថាធ្វើខ្លួនអោយមានពន្លឺភ្លឺអោយបរិសុទ្ធស្អាត ទាំងកេរ្តិ៍ឈ្មោះរបស់ជននោះសោត ក៏ក្រអូបផ្សាយទៅកាន់ទិសទីទាំងពួង ដោយសេចក្តីរុងរឿងក្នុងលោកនេះ ប្រៀបដូចជាព្រះច័ន្ទពេញវង់ដែលលឿនឃ្លាតចេញផុតពីមន្ទិល មានពពកជាដើម ដូច្នេះឯង ។

សេចក្តីដែលពណ៌នាមកប៉ុណ្ណេះនេះ ដើម្បីបញ្ជាក់អោយឃើញថា ក្រៅអំពីខ្លួនរបស់ខ្លួនឯង អ្នកណានឹងអាចធ្វើអ្នកណាអោយបរិសុទ្ធ ឬសៅហ្មងនោះពុំបានឡើយ ។

មានជនពួកខ្លះក្នុងលោកនេះ មានសេចក្តីយល់ថា សេចក្តីបរិសុទ្ធ និងសេចក្តីមិនបរិសុទ្ធសំរេចមកតែអំពីចិត្ត សូម្បីកុសលក្តី អកុសលក្តី ក៏សំរេចមកអំពីចិត្តដែរ ឬដំណើរទៅកាន់សុគតិក្តី ទៅកាន់ទុគ្គតិក្តី ក៏សំរេចមកតែអំពីចិត្តដែរ

ហេតុនោះ យើងមិនចាំបាច់ធ្វើទេ ចាំដល់ពេលណាដែលយើងត្រូវការសេចក្ដីល្អគឺបុណ្យ ឬក៏ក្នុងពេលជិតស្លាប់ សឹមយើងតាំងចិត្តអោយបរិសុទ្ធស្អាតល្អ ដើម្បីឈោងចាប់យកសុគតិតែម្ដង ។ អ្នកមានគំនិតយល់ដូច្នេះ ប្រហែលជាស្មានថា ចិត្តនេះជាធម្មជាតិងាយស្រួល អាចប្រដៅហ្វឹកហាត់ពត់តម្រង់ទៅយ៉ាងណាៗក៏បានបែបបទភ្លាមៗយ៉ាងនោះតាមបំណងខ្លួនទេដឹង ? ការយល់ដូច្នេះ មិនត្រូវបែប មិនត្រូវទំនង មិនសមហេតុផលសោះឡើយ ។ បើតាមពិតនោះ ធម្មជាតិទាំង ៣ យ៉ាងគឺកាយវាចាចិត្តនេះ មានលក្ខណៈពិបាកបង្ហាត់ទូន្មានប្រៀនប្រដៅអោយបានបែបបទដោយអាការផ្សេងគ្នាយ៉ាងនេះ ឯកាយដែលអាចធ្វើអ្វីទៅបានគ្រប់យ៉ាង ដូចជាចេះសរសេរអក្សរល្អក្ដី ចេះធ្វើគ្រឿងអលង្ការអំពីមាស និងប្រាក់ សំរាប់តាក់តែងកាយនៃបុរស និងស្ត្រីអោយមានក្បាច់ក្បូរភ្ញីវល្លិល្អក្ដី ចេះគូររូបគំនូរដ៏វិចិត្រល្អក្ដី ដូច្នេះជាដើម លុះណាតែបានរៀនបានហាត់អោយស្ទាត់ទុកជាមុន ទើបកាយនោះឯងអាចប្រើការអោយសំរេចប្រយោជន៍ទៅបាន ។ ចំណែកខាងវាចាគឺ សំដីសោតទៀត ក៏ប្រហែលគ្នា ដូចជាចេះនិយាយការអ្វីអោយគេស្ដាប់ ឬក៏ចេះថ្លែងសុន្ទរកថាជាដើមក្នុងទីប្រជុំជន មិនមានការទាស់ឆ្គងទៅបាន លុះណាតែបានគិតហាត់អានអោយស្ទាត់ទុកជាមុនសិនដែរ ទើបវាចានោះឯង ជាសំដីពិរោះចាប់ចិត្តដល់អ្នកស្ដាប់គួរគេយកតម្រាប់តាម ។ កាយនិងវាចាទាំងពីរនេះ ជាធម្មជាតិមើលឃើញច្បាស់ដោយភ្នែក ស្ដាប់ឮច្បាស់ដោយត្រចៀក ម៉េចគង់ពិបាកបង្ហាត់ទូន្មានម្ល៉េះទៅហើយ ចំណង់បើចិត្តជាអតិសុខុមជាតល្អិតក្រៃលែង គ្មានរូប ពណ៌ សណ្ឋានទ្រង់ទ្រាយអ្វីជាគ្រឿងប្រាកដសោះផង សមនឹងពិបាកទូន្មានយ៉ាងណាទៅទៀត, ហេតុនោះ ការទូន្មានហាត់ចិត្តអោយបានបែបបទបរិសុទ្ធស្អាតនោះ មិនមែនជាការងាយទេ ក្រជាទីបំផុត ព្រោះចិត្តនោះជាធម្មជាតិល្អិតឆ្មារហួសវិស័យនឹងប្រដូច មានសន្ទុះលឿនរហ័សក្រៃលែងនឹងរកអ្វីមកប្រៀបអោយស្មើពុំបាន ជាធម្មជាតិឆាប់ប្រែប្រួល, ឆាប់ញាប់ញ័រ, ឆាប់

ឃ្លេងឃ្លោង, ឆាប់ឆ្អែតឆ្អា ម្តងដូច្នេះ ម្តងដូច្នោះ នឹងចាប់ពត់តម្រង់អោយត្រង់ល្អ តាមបំណងខ្លួនភ្លាមៗនោះ បានដោយក្រពេកណាស់, មិនមែនជាការងាយស្រួល ដូចជនខ្លះដែលមានសេចក្តីយល់ឆ្វេង ដូចបានពោលមកហើយនោះទេ ។

ម្យ៉ាងទៀត មានជនពួកខ្លះយល់ថា សេចក្តីបរិសុទ្ធក្នុងជីវិតរបស់មនុស្សម្នាក់ៗដែលកើតឡើងក្នុងលោកនេះ គឺមកពីមានជាតិ គោត្រ ត្រកូល ពូជពង្សដ៏ខ្ពង់ខ្ពស់ ឬមកអំពីមានទ្រព្យសម្បត្តិច្រើន ទើបឈ្មោះថាជាសេចក្តីបរិសុទ្ធស្អាតរបស់មនុស្ស, ការយល់ដូច្នេះ ទុកជាគំនិតយល់ឆ្វេងខុសផ្ទុយគ្នានឹងសេចក្តីពិត បើតាមពិតមែននោះ គឺសេចក្តីបរិសុទ្ធស្អាតនៅត្រង់កាយ វាចា ចិត្ត ដែលមិនប្រព្រឹត្តធ្វើអកុសលកម្មណាមួយ ទើបចាត់អោយឈ្មោះថាជាសេចក្តីបរិសុទ្ធស្អាត របស់មនុស្សក្នុងទីនេះបាន មិនមែនបរិសុទ្ធព្រោះតែមានជាតិ គោត្រ ត្រកូល ពូជពង្សដ៏ខ្ពង់ខ្ពស់នោះទេ, មិនមែនបរិសុទ្ធព្រោះតែមានទ្រព្យច្រើននោះទេ សមដូចព្រះពុទ្ធភាសិតថា ៖

*កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ*
*ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា ។*

សត្វទាំងឡាយរមែងបរិសុទ្ធស្អាតដោយគុណធម៌ ៥ យ៉ាង(*) នេះគឺ ៖ កម្ម ១ វិជ្ជា ១ ធម៌ ១ សីល ១ ជីវិតដ៏ឧត្តម ១ មិនមែនបរិសុទ្ធដោយសារគោត្រ ត្រកូល ឬដោយសារទ្រព្យសម្បត្តិទេ ។ គុណធម៌ទាំង ៥ យ៉ាងនេះ ជាសេចក្តីប្រតិបត្តិដុសខាត់ខាងផ្លូវកាយ វាចា ចិត្ត របស់សត្វអោយបរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង មិនមែនបរិសុទ្ធដោយហេតុដទៃឡើយ ។ ព្រោះហេតុនោះ ពុទ្ធសាសនិកជនគួរជ្រាបថា បើប្រាថ្នាសេចក្តីបរិសុទ្ធអោយកើតឡើងចំពោះខ្លួន ត្រូវតែខ្លួនយើង

---

(*) ធម៌ ៥ យ៉ាងនេះ មានអធិប្បាយក្នុងគម្ពីរបរមត្ថមញ្ជូសាដីកាវិសុទ្ធិមគ្គ ត្រង់សីលនិទ្ទេស

ប្រតិបត្តិធ្វើបំពេញកិច្ចផ្ទាល់ដោយខ្លួនយើង ឬសេចក្ដីសៅហ្មងកើតឡើងដល់ខ្លួនហើយ ត្រូវតែខ្លួនយើងលាងជម្រះសំអាតផ្ទាល់ដោយខ្លួនយើង នឹងទៅពឹងពាក់រកអ្នកដទៃអោយគេធ្វើជំនួសខ្លួនពុំបានឡើយ, សេចក្ដីនេះប្រៀបដូចជនពីរនាក់ ជនម្នាក់បរិភោគអាហារស្កប់ស្កល់ហើយ ឃើញជនម្នាក់ទៀត មិនទាន់បរិភោគអាហារសោះ កំពុងមានសេចក្ដីស្រេកឃ្លាន ហើយចង់ចែកឆ្អែតរបស់ខ្លួនអោយទៅអ្នកដែលកំពុងឃ្លាននោះបានឆ្អែតដូចខ្លួនផង តើជនឆ្អែតនោះ អាចបេះរំលែកឆ្អែតចែកទៅជនឃ្លាននោះខ្លះផងបានឬទេ ? ។ មួយទៀត ប្រៀបដូចជនម្នាក់កំពុងអន្ទះអន្ទែងដោយសេចក្ដីស្រេកឃ្លាន បានឃើញជនម្នាក់ចូលមកជិត ហើយចង់ចែកឃ្លានរបស់ជនអោយទៅជនម្នាក់នោះអោយគេជួយឃ្លានដូចខ្លួនផង តើជនឃ្លាននោះនឹងអាចបេះរំលែកឃ្លានចែកអោយទៅជនឯទៀត អោយគេជួយឃ្លានខ្លះផងបានដែរឬទេ ? ។ តាមពិត ជនទាំងពីរនាក់ គឺជនឆ្អែតនិងជនឃ្លាន នឹងបេះរំលែកឆ្អែតនិងឃ្លានអោយដល់គ្នានឹងគ្នាទៅវិញទៅមកពុំបានសោះឡើយ មានឧបមាយ៉ាងណា, ឯសេចក្ដីបរិសុទ្ធ និងសេចក្ដីមិនបរិសុទ្ធនេះ រមែងកើតឡើងអំពីខ្លួនរបស់ខ្លួនឯងអ្នកណាមួយនឹងអាចបេ រំលែកសេចក្ដីបរិសុទ្ធ និងសេចក្ដីមិនបរិសុទ្ធអោយដល់គ្នាទៅវិញទៅមកពុំបានសោះឡើយ ក៏មានឧបមេយ្យដូច្នោះឯង ។

ផលល្អ និងផលអាក្រក់ដែលលេចចេញមកពីសេចក្ដីបរិសុទ្ធ និងសេចក្ដីមិនបរិសុទ្ធនៃកាយវាចាចិត្តនោះ អាចបង្ហាញអោយឃើញជាក់ស្ដែង ក្នុងបច្ចុប្បន្ននេះ ដែលត្រូវទទួលសុខ និងទុក្ខផ្សេងៗគ្នានោះ មិនចាំបាច់ទាញតួយ៉ាងមកចង្អុលប្រាប់ក្នុងទីនេះទេ សូមពិចារណាពិនិត្យសង្កេតមើលដោយប្រាជ្ញាដ៏ជ្រាលជ្រៅ នៅជុំវិញ ខ្លួន ក៏គង់ឃើញបានដោយមិនលំបាក ។

ហេតុនោះ ពុទ្ធសាសនិកជាអ្នកចង់បានសេចក្ដីសុខ និងសេចក្ដីចំរើនអោយកើតមានដល់ខ្លួនគ្រប់វេលានេះ ត្រូវតែតាំងសតិ គឺស្មារតីអោយយាមល្បាត

ប្រចាំនៅនឹងទ្វារកាយវាចាចិត្តជានិច្ច ដើម្បីទប់រាំងអកុសលផ្សេងៗ មានអភិជ្ឈា និងទោមនស្សជាដើម កុំអោយចូលមកបៀតបៀនបាន, បើពុំដូច្នោះទេ មុខជានឹងត្រូវទទួលទុក្ខទោស គ្រោះថ្នាក់ណាមួយតាមគួរដល់យថាកម្ម ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ព្រោះតែសេចក្តីមិនបរិសុទ្ធនៃកាយវាចាចិត្តនោះឯងជាហេតុ ។

ពណ៌នាអំពីសេចក្តីបរិសុទ្ធជាគូនិងសេចក្តីមិនបរិសុទ្ធ ក្រោមចំណងជើងថា សេចក្តីបរិសុទ្ធនៅឯណា ? ចប់ដោយសង្ខេប ឯវិ ។

***

*អ្នកលបធ្វើអំពើអាក្រក់ក្នុងទីស្ងាត់កំបាំង*
*តាមពិត អ្នកដទៃមើលមិនឃើញមែន,*
*ប៉ុន្តែអ្នកដែលមើលឃើញច្បាស់នោះ គឺខ្លួនឯងនេះឯង !*

# ការបកស្រាយបំភ្លឺបញ្ហាមួយចំនួនពាក់ព័ន្ធនឹងវិស័យធម្មការ និងកិច្ចការសាសនា

គ.ភ.ន.‗ តាមសេចក្ដីអញ្ជើញរបស់ឯកឧត្តមប្រធានគណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងឯកឧត្តម ឈន អៀម រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា បានអញ្ជើញទៅបកស្រាយបំភ្លឺបញ្ហាមួយចំនួនពាក់ព័ន្ធនឹងវិស័យធម្មការ និងកិច្ចការសាសនា លើចំណុចដូចខាងក្រោម ៖

១‗ ទស្សនាទានក្នុងការពង្រឹង និងពង្រីកតួនាទីរបស់ព្រះពុទ្ធសាសនា ក្នុងសង្គមជាតិកម្ពុជា ដើម្បីរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយនិរន្តរភាព ដោយសង្កត់ធ្ងន់លើតួនាទី និងភារកិច្ចនៃវត្តអារាមចំពោះសហគមន៍ និងតួនាទីរបស់សហគមន៍ចំពោះវត្តអារាម ។

២‗ វិធានការសំខាន់ៗ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ។

អត្ថបទបកស្រាយបំភ្លឺ មានអត្ថន័យនិងខ្លឹមសារ ដូចតទៅ ៖

ដើម្បីឆ្លើយតបទៅនឹងសំណួរទាំងពីរនេះ, ខ្ញុំមានកិត្តិយស និងសេចក្ដីសោមនស្សដើម្បីរំលឹកឡើងវិញនូវប្រវត្តិនៃពុទ្ធសាសនាបន្តិច មុននឹងឈានចូលដល់ការបកស្រាយសំណួរខាងលើ, ពីព្រោះការយល់ច្បាស់នូវមូលហេតុ ទើបយើងគិតគូររកការដោះស្រាយ ឬមាគ៌ាដោះស្រាយបានត្រឹមត្រូវ ។

អ្នកប្រាជ្ញជាច្រើនបានសរសេរថា ពុទ្ធសាសនាបានផ្សព្វផ្សាយចូលមកប្រតិស្ឋាននៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពុទ្ធសករាជទីបី ។ ចាប់ពីពេលនោះមក

ពុទ្ធសាសនាថេរវាទរបស់យើងបានរួមសុខទុក្ខ លិចអណ្តែត ជាមួយនឹងជំនឿងទៀតៗ ( ជំនឿពុទ្ធសាសនិកមហាយាន, ជំនឿព្រាហ្មណិក, ជំនឿជីវនិយម ) ដែលប្រជាជនធ្លាប់បានគោរពកាន់តាមរួចមកហើយ ។ បន្តិចម្តងៗ ពុទ្ធសាសនាថេរវាទដណ្តើមបានជំនឿ និងការឧបត្ថម្ភពីមហាជន រហូតដល់បានទទួលឋានៈជាសាសនារបស់រដ្ឋ ។ មុនឆ្នាំ ១៩៧០ យើងមាន ៣.៣៦៩ វត្ត និងមានបព្វជិត ៦៦.០៦២ អង្គ ។ ការប្រតិបត្តិធម៌-វិន័យសាសនា ព្រមទាំងការរៀនសូធ្យផ្នែកគន្ថធុរៈ និងវិបស្សនាធុរៈ ត្រូវបានកត់សម្គាល់ឃើញថាមានការរីកចំរើនយ៉ាងល្អប្រសើរ ។ ពុទ្ធ-សាសនា ( គឺឱវាទប្រៀនប្រដៅរបស់ព្រះពុទ្ធ ឬព្រះធម៌ ) ភិក្ខុសង្ឃ និងវត្តអារាមបានក្លាយជាកម្លាំងរស់ដ៏សំខាន់របស់សង្គមជាតិ រួមចំណែកក្នុងការអភិវឌ្ឍន៍សង្គម។ ក្នុងបណ្តាកម្លាំងទាំងបី, ភិក្ខុសង្ឃគឺជាកម្លាំងដើរតួសំខាន់ ។ ប៉ុន្តែកម្លាំងនេះ ដែលបានបន្តប្រពៃណីដ៏រុងរឿងតាំងពីជាងពីរពាន់ឆ្នាំមកហើយ ទាំងខាងបញ្ញា - ស្មារតី សីលធម៌ និងទាំងការគ្រប់គ្រង-ចាត់តាំង ត្រូវបានបំផ្លាញអស់ក្នុងអំឡុងឆ្នាំ ១៩៧៥ ១៩៧៩ ។ នោះគឺជាការបំផ្លាញរាល់តម្លៃខាងស្មារតី និងខាងតម្លៃខាងសម្ភារៈយ៉ាងធ្ងន់ធ្ងររបស់ព្រះពុទ្ធសាសនា ។ រហូតមកដល់ពេលនេះ យើងពុំទាន់ស្តារ និងកសាងតម្លៃដែលបានបាត់បង់នោះឡើងវិញ អោយបានប្រហាក់ប្រហែលពីមុននៅឡើយទេ ។ គឺនៅក្នុងបរិបទនេះហើយ ដែលគណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍របស់រដ្ឋសភា មានប្រាថ្នាចង់ស្វែងយល់អំពីដំណើរអភិវឌ្ឍន៍នៃវិស័យធម្មការ និងកិច្ចការសាសនា ។

ចាប់តាំងពីពេលត្រូវបានបង្កើតឡើងវិញ នៅដើមឆ្នាំ ១៩៩២ ក្រសួងធម្មការ បានទទួលបន្ទុកការងារធម្មការ និងពុទ្ធិកសិក្សា បន្តពីក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ដោយភ្ជាប់ជាបវិស័យបីគឺ : វិស័យធម្មការ វិស័យពុទ្ធិកសិក្សា និងពុទ្ធសាសនបណ្ឌិត្យ ។

១. ចំពោះវិស័យធម្មការ ក្រសួងបានយកចិត្តទុកដាក់ពិតតួរខ្ពស់ ក្នុងការលើកស្ទួយពុទ្ធសាសនា ព្រមទាំងភិក្ខុសង្ឃ និងវត្តអារាមផង ក្នុងឋានៈជាអង្គការចាត់តាំងមួយរបស់សង្គម ប្រកបដោយតម្លៃខាងបញ្ញា - ស្មារតីខ្ពស់ ដើម្បីអាចរួមចំណែកអភិវឌ្ឍន៍សង្គម ដែលបានគាំទ្រនិងឧបត្ថម្ភខ្លួន ។ ជាការណ៍ពិត ពុទ្ធសាសនាមិនមែនគ្រាន់តែជាទស្សនវិជ្ជាមួយសំរាប់អោយពួកបញ្ញវន្ត ឬលោកអាចារ្យ លើកយកមកជជែកគ្នាក្នុងរង្វង់អ្នកចេះដឹងប៉ុណ្ណោះទេ, ប៉ុន្តែ ពុទ្ធសាសនា គឺជាមាគ៌ានៃជីវិតរបស់ប្រជាជនយើង, របស់សង្គមយើង ។ នៅក្នុងព្រះធម៌ដែលជាឱវាទប្រៀនប្រដៅរបស់ព្រះពុទ្ធ និងនៅក្នុងសកម្មភាពជាក់ស្តែងរបស់ព្រះអង្គ ក្នុងការបំរើសង្គមរយះពេល ៤៥ ឆ្នាំ, មានឧទាហរណ៍ច្រើនណាស់ ដែលបញ្ជាក់អោយឃើញថាពុទ្ធសាសនា គឺជាមាគ៌ាអនុវត្តជាក់ស្តែងសំរាប់ការរស់នៅរបស់មនុស្ស, គឺដូចជាទស្សនៈលើកស្ទួយកិត្តិយសមនុស្ស ដោយហាមឃាត់ការលក់ដូរ ឬជួញមនុស្ស, ការផ្តល់សេរីភាពក្នុងការគិត ឬទស្សនៈអំពីនយោបាយ សន្តិសុខ យុត្តិធម៌ . ល . ។ នៅមានដំបូន្មានជាច្រើនទៀត ទាក់ទងនឹងសម្មាអាជីវៈ គឺការចិញ្ចឹមជីវិតដោយត្រឹមត្រូវគោលការណ៍អភិវឌ្ឍន៍សេដ្ឋកិច្ចបំបាត់ភាពក្រីក្រ បញ្ចប់ទុក្ខទោសក្នុងជីវិត តាមផ្លូវសីលធម៌ សំដៅបង្កើតជីវភាពរីករាយនៅក្នុងបច្ចុប្បន្ននេះ ។

ព្រះធម៌ ឬឱវាទប្រៀនប្រដៅដ៏មានអត្ថន័យជ្រាលជ្រៅរបស់ព្រះពុទ្ធតម្រូវអោយមានការផ្សព្វផ្សាយអោយបានជ្រួតជ្រាបចូលជ្រៅទៅក្នុងសន្តានចិត្តប្រជាជន តាមរយះភិក្ខុសង្ឃជាងប្រាំម៉ឺនអង្គ ( ៥០.០៨១ ) ដែលគង់នៅក្នុងបណ្តាវត្ត ៣.៦៨៥ វត្ត ក្នុងទូទាំងប្រទេស និងតាមរយះការបោះពុម្ពផ្សាយជាសៀវភៅ និងទស្សនាវដ្តីរបស់ពុទ្ធសាសនបណ្ឌិត្យ ។

ប៉ុន្តែ ព្រះភិក្ខុសង្ឃដែលមានកាន់តែកើនឡើងប្រមាណជាង ៥ ម៉ឺនអង្គនេះ មិនទាន់មានគុណសម្បត្តិ ( សីលធម៌ អភិសមាចារ ) និងសមត្ថភាពចំណេះដឹង

ខាងធម៌អាថ៌ជ្រាលជ្រៅ និងជំនាញខាងទេសនាផ្សព្វផ្សាយ ដើម្បីអោយពុទ្ធបរិស័ទអាចយល់ដឹង និងទទួលយកបាននូវធម៌អាថ៌ដ៏ជ្រាលជ្រៅនោះឡើយទេ ។ នេះក៏ជាកម្មវត្ថុដ៏ចម្បងមួយដែលក្រសួងធម្មការ ត្រូវពុះពារដោះស្រាយ ពីព្រោះថា ព្រះភិក្ខុសង្ឃបច្ចុប្បន្ន មានតែបរិមាណច្រើនជាងគុណភាព ពហុស្សូត្រ ឬអ្នកចេះដឹងជាបព្វជិតមានតិចតួចបំផុត បព្វជិតមួយចំនួនបានបួសក្នុងពុទ្ធសាសនា គឺពុំមែនដោយសារមានជំនឿក្នុងសាសនា ដើម្បីរំដោះខ្លួនចេញពីសង្សារភពទេ, ប៉ុន្តែ ដោយសារចង់បានលាភសក្ការៈ សន្សំទ្រព្យ ឬគេចវេះពីជីវភាពតោកយ៉ាកជាគ្រហស្ថ ។

ក្នុងករណីនេះ គោលការណ៍របស់ក្រសួង គឺជំរុញការសិក្សាអប់រំរបស់ភិក្ខុសង្ឃ ទាំងក្រៅប្រព័ន្ធ ( រៀនធម្មវិន័យ ) ទាំងក្នុងប្រព័ន្ធ គឺពុទ្ធិកសិក្សា តាមទិសដៅកែសម្រួលកម្មវិធីសិក្សានៅថ្នាក់បឋម និងមធ្យមសិក្សា សំដៅភ្ជាប់ចំណេះដឹងទៅនឹងការបំរើសង្គម និងសំដៅបង្កើតអោយមានឡើងវិញនូវអ្នកប្រាជ្ញ ឬបណ្ឌិតក្នុងជួរសង្ឃ ដើម្បីដឹកនាំព្រះពុទ្ធសាសនាអោយបានរុងរឿងក្នុងស្ថានភាពថ្មី តាមរយៈការរៀបចំអោយបានសមស្របនឹងកាលៈទេសៈនូវកម្មវិធីនៃពុទ្ធិកឧត្តមសិក្សា ។ ជាមួយនឹងការសិក្សាផ្នែកគន្ថធុរៈ ឬផ្នែកបរិយត្តិនេះ ក្រសួងធម្មការ ក៏បានកំណត់ទិសដៅជំរុញការបដិបត្តិត្រឹមត្រូវតាមក្រឹត្យវិន័យ សីលសិក្ខាបទពុទ្ធសាសនា ផងដែរ ។ ការបដិបត្តិដ៏ត្រឹមត្រូវនេះ ផ្អែកលើការចេះដឹងក្រឹត្យវិន័យ, សីលសិក្ខាបទច្បាស់លាស់ និងការហាត់ធ្វើសមាធិ ដែលនឹងត្រូវកំណត់នៅក្នុងកម្មវិធីសិក្សាថ្មី ។

ការគ្រប់គ្រងបព្វជិតរាប់ម៉ឺនអង្គ និងការអភិបាលវត្តរាប់ពាន់វត្ត អោយរក្សាបានសណ្តាប់ធ្នាប់ល្អ និងប្រតិបត្តិតាមធម៌វិន័យសមស្រប គឺជាបន្ទុកដ៏ធ្ងន់ធ្ងររបស់ក្រសួងព្រះសង្ឃរាជទាំងពីរគណៈ និងអាជ្ញាធរសង្ឃគ្រប់លំដាប់ថ្នាក់, ហើយក៏ជាភារកិច្ចទទួលខុសត្រូវរបស់ក្រសួងធម្មការ និងមន្ទីរធម្មការខេត្ត-ក្រុង, ស្រុកខ័ណ្ឌ ផងដែរ ។ ក្នុងពេលខាងមុខដ៏ខ្លី, ក្រសួងធម្មការ និងក្រសួងព្រះសង្ឃរាជ នឹង

ជួបពិគ្រោះយោបល់ ដើម្បីរៀបចំការអប់រំរយៈពេលខ្លី សំរាប់គណៈមេគណ, គណៈអនុគណ, ស្ដីពីការងារគ្រប់គ្រងបព្វជិត, ការគ្រប់គ្រងប្រាក់ចំណូលចំណាយ, គ្រប់គ្រងគរុភណ្ឌវត្ត, ការតែងតាំងគណៈកម្មការវត្ត និងអាចារ្យ ។ ការងារទាំងនេះ សំដៅលើកកំពស់តួនាទីវត្តអារាម ហើយជាពិសេស តួនាទីរបស់ភិក្ខុសង្ឃចំពោះ ពុទ្ធបរិស័ទ និងប្រជាជនរស់នៅជុំវិញវត្ត ។ ក្នុងបណ្ដាឆ្នាំកន្លងទៅ អង្គការក្រៅរដ្ឋា-ភិបាលជាច្រើនបានបើវគ្គអប់រំខ្លីៗ ស្ដីពីសិទ្ធិមនុស្ស, ស្ដីពីការអប់រំសុខភាព, រក្សាអនាម័យ ស្ដីពីបញ្ហាច្រើនទៀត ទាក់ទងនឹងសេវាកម្មបំរើសង្គម ឬការអភិវឌ្ឍន៍សង្គម, ឬក៏សកម្មភាពកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចជា ការបង្កើតអោយមានធនាគារស្រូវ, ការផ្ដល់ប្រាក់អោយខ្ចីធ្វើដើមទុនជាដើម ។ ប៉ុន្ដែ លទ្ធផលជាផ្លែផ្កាចេញពីការអប់រំទាំងនោះបានស្ដួចស្ដើងណាស់ បណ្ដាលមកពីកត្តាផ្ទាល់ខ្លួនរបស់ភិក្ខុសង្ឃទាំងនោះផង កត្តាសម្ភារះ និងថវិកាផង ។ បណ្ដាកត្តាទាំងពីរនេះ កត្តាផ្ទាល់ខ្លួន ឬកត្តាអត្តនោម័តិ គឺជាកត្តាគ្របសង្កត់ ។ ដូច្នេះ វាទាមទារអោយមានការអប់រំសមស្របដើម្បីកែប្រែទម្លាប់ និងផ្នត់គំនិតខុសឆ្គងរបស់បព្វជិតយើង ។ យ៉ាងណាមិញ ភិក្ខុសង្ឃក្នុងវត្តនីមួយៗ រួមទាំងចៅអធិការ គ្រូសូត្រស្ដាំ-ឆ្វេងផង ឋិតនៅឆ្ងាយពីពុទ្ធបរិស័ទ-មិនបានយកគំរូតាមព្រះពុទ្ធដែលបានបំរើសង្គមអស់រយៈពេល ៤៥ ឆ្នាំ ដោយឥតគិតពីសេចក្ដីនឿយហត់នោះទេ ។ សាលារៀនបឋមសិក្សា រហូតដល់សាលាមធ្យមសិក្សាខ្លះផង គឺវត្តបានកសាងឡើងសំរាប់កុមារា-កុមារីរៀនសូត្រ ប៉ុន្ដែ មេវត្ត ឬចៅអធិការ ពុំសូវឆក់យកឱកាសនិមន្តទៅជួបសំណេះសំណាលធមិអាថ៌ ឬភ្ជាប់ទំនាក់ទំនងជាមួយយុវសិស្ស-លោកគ្រូ-អ្នកគ្រូផងទេ ។ ភិក្ខុសង្ឃយើងរង់ចាំគេនិមន្ត ទើបចុះទៅភូមិជួបជាមួយពុទ្ធបរិស័ទ : *លោកមិនបានចេញទៅប្រោសសត្វទេ ប៉ុន្ដែទុកអោយសត្វដើរមកអោយលោកប្រោសវិញ* ។ ការខ្វះខាតដ៏គួរអោយសោកស្ដាយនេះ ទុកឱកាសអោយសាសនាដទៃ ចូលមកផ្សព្វផ្សាយ

សាសនារបស់គេ ដើម្បីអូសទាញកូន-ចៅយើងអោយចូលកាន់សាសនារបស់គេ ។

ផ្អែកលើមូលហេតុដូចបានរៀបរាប់សង្ខេបខាងដើម ក្រសួងបានគិតគូរ និងរិះរកវិធីជួយលើកកិត្យានុភាពរបស់ភិក្ខុសង្ឃ និងលើកឥទ្ធិពលរបស់វត្តអារាម សំដៅទាក់ទាញជំនឿ និងសទ្ធាជ្រះថ្លា ព្រមទាំងការឧបត្ថម្ភពីប្រជាជន តាមរយៈការអប់រំ ការរៀបចំវត្តអារាមអោយក្លាយជាមជ្ឈមណ្ឌលផ្សព្វផ្សាយចំណេះដឹង ( សូមអានអត្ថបទសង្ឃប្រកាសរបស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទី៨ ទំព័រ....... .) និងការពង្រីក និងបង្កើនគុណភាពនៃពុទ្ធិកសិក្សា ។

២. ពុទ្ធិកសិក្សា គឺជាកម្មវត្ថុចម្បងមួយរបស់ក្រសួង ដែលបានចាត់ទុកពុទ្ធិកសិក្សានេះថាជាគ្រឹះនៃសេចក្តីថ្លៃថ្នូរ និងសេចក្តីរុងរឿងរបស់ពុទ្ធសាសនា ។ ពេលណាពន្លឺពុទ្ធិកសិក្សាកាន់តែភ្លឺច្រាលឡើង, អន្ធការភាពដែលគ្របដណ្តប់លើពុទ្ធសាសនា នាពេលបច្ចុប្បន្ន កាន់តែរួញថយទៅ ។ ក្នុងទស្សនៈនេះហើយ ទើបក្រសួងបានដាក់ផែនការ ពិនិត្យរៀបចំកែលំអកម្មវិធីសិក្សាទាំងបីភូមិសិក្សា ដើម្បីតម្រង់ទិសការសិក្សារបស់សមណសិស្ស និងសមណនិស្សិត អោយបានសមស្របទៅនឹងការរីកចំរើននៃសង្គមជាតិយើង នាពេលបច្ចុប្បន្ន ។

ជាការណ៍ពិត, ពុទ្ធិកសិក្សាដែលកំពុងប្រព្រឹត្តទៅសព្វថ្ងៃ គឺជាការសិក្សាដែលទើបតែចាប់ផ្តើមដំណើរការឡើងវិញ ក្នុងឆ្នាំ ១៩៨៨ ប៉ុណ្ណោះ ដោយក្រុមប្រឹក្សាជាតិរណសិរ្ស ហើយក្រសួងធម្មការបានទទួលការងារនេះបន្តនៅក្នុងឆ្នាំ ១៩៩២ រហូតមកដល់បច្ចុប្បន្ន ។ ក្នុងអាណត្តិទីមួយនៃរាជរដ្ឋាភិបាល ពុទ្ធិកសិក្សាបានដំណើរលើមូលដ្ឋានកម្មវិធីសិក្សាចាស់ ដែលបានប្រើប្រាស់ក្នុងបណ្តាឆ្នាំ ៦០ ។ ម្ល៉ោះហើយ វិធីសាស្ត្របង្រៀន និងមុខវិជ្ជាសិក្សាមួយចំនួន តម្រូវអោយមានការសើរើរៀបចំឡើងវិញ ទាំងផ្នែកបច្ចេកទេសបង្រៀនទាំងផ្នែកសម្ភារៈសិក្សា សំដៅធ្វើអោយពុទ្ធិកសិក្សាបច្ចុប្បន្ន បានប្រែក្លាយជាវិភាគទានដ៏សំខាន់ដល់ការអភិវឌ្ឍន៍

ធនធានមនុស្ស សមស្របតាមការរីកចំរើននៃយុគសម័យ ។

ក្នុងវិស័យអភិវឌ្ឍពុទ្ធិកសិក្សា, ក្រសួងធម្មការ និងសាសនា សូមជម្រាបគណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍របស់រដ្ឋសភាអោយបានជ្រាបថា ពុទ្ធិកសិក្សាក្នុងរយៈពេលប៉ុន្មានឆ្នាំ មានការរីកចំរើនខាងបរិមាណគួរអោយកត់សម្គាល់ ទាំងផ្នែកសិក្សាធម្មវិន័យ ( ក្រៅប្រព័ន្ធ ) ។ យ៉ាងណាមិញ ក្នុងក្នុងរយៈពេលចំនួន ១០ ឆ្នាំប៉ុណ្ណោះ សាលាពុទ្ធិកសិក្សាបានកើតឡើងចំនួន ២៧១ កន្លែង, និងមានសមណសិស្ស ៨.៤៦៣ អង្គ, ពុទ្ធិកវិទ្យាល័យចំនួន ៧ កន្លែង ( រួមទាំងសាលាពុទ្ធិកមធ្យមសិក្សាសំរោងអណ្តែត ឯកជនមួយផង ) ដែលមានចំនួនសមណសិស្សមធ្យមសិក្សាទាំងពីរកំរិត ប្រមាណ ១.០៣៧ រូប ។ រីឯពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងបើកទ្វារជាផ្លូវការនៅឆ្នាំសិក្សាខាងមុខ ។ ក្រសួងបានចាត់ទុកការងារឧត្តមសិក្សានេះ ថាជាការងារមួយបើកច្រកអោយសមណនិស្សិត កាន់តែមានទស្សនៈទូលំទូលាយ បង្កលក្ខណៈងាយស្រួលដល់ការស្រូបយកគំនិត, លោកទស្សនៈថ្មីៗ ពីពិភពខាងក្រៅ ដើម្បីធ្វើការអភិវឌ្ឍន៍សង្គមជាតិយើងស្របទៅតាមសណ្តាប់ធ្នាប់ពិភពលោកថ្មី ។

ប៉ុន្តែ អ្វីជាឧបសគ្គរាំងដំណើរអភិវឌ្ឍន៍នេះ គឺធនធានមនុស្ស ជាពិសេស អាចារ្យ ឬគ្រូពុទ្ធិកបឋមសិក្សា និងគ្រូមធ្យមសិក្សា ។ ទោះបីសាលាពុទ្ធិកបឋមសិក្សាមានរាប់រយកន្លែងក៏ដោយ ដូចបានជម្រាបខាងដើម, ប៉ុន្តែគ្រូក្របខណ្ឌពិតប្រាកដ សំរាប់បំរើការងារបង្រៀន ទើបតែមានចំនួន ៣២ រូបប៉ុណ្ណោះ ដែលបានចេញទៅបំរើការហើយ ។ ក្នុងពេលខាងមុខ នឹងមានគ្រូក្របខណ្ឌចំនួន ៣០ រូប ទៀត ដែលនឹងត្រូវចេញទៅបង្រៀននៅសាលាបឋមសិក្សា នាឆ្នាំសិក្សាខាងមុខ ។

យោងតាមមាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញ, វាក្យខណ្ឌចុងក្រោយនៃមាត្រានេះ

បានថែងថា « រដ្ឋជួយផ្សព្វផ្សាយ និងលើកតម្កើងសាលាបាលី និងពុទ្ធិកសិក្សា ។ ទោះជាយ៉ាងនេះក្តី, ការអនុវត្តជាក់ស្តែង ពុំទាន់សមស្របតាមខ្លឹមសារដែលចែងនៅក្នុងរដ្ឋធម្មនុញ្ញទេ ។ សាលាពុទ្ធិកបឋមសិក្សាជាច្រើនបានដំណើរការទៅទាំងត្រដាបត្រដួស ដោយគ្រូស្មគ្រចិត្តដែលមានវ័យជរា មកជួយបង្រៀនភាសាបាលី និងធម៌វិន័យសាសនា, ឯមុខវិជ្ជាផ្លូវលោក ត្រូវបានរ៉ាប់រងដោយគ្រូរបស់ក្រសួងអប់រំ ដែលបានទទួលប្រាក់ឧបត្ថម្ភពីចៅអធិការ ឬពីវត្ត ។ សភាពការណ៍ដូចនេះ មិនអាចដំណើរការបានរហូតនោះទេ ហើយសាលាពុទ្ធិកបឋមសិក្សាមួយចំនួន បានបិទទ្វារទៅវិញជាបណ្តើរៗទៅហើយ ។

អាស្រ័យហេតុនេះ ក្រសួងធម្មការ សូមសំណូមពរក្នុងឱកាសនេះផងដែរ ដោយស្នើរសុំអោយរាជរដ្ឋាភិបាល អនុគ្រោះផ្តល់ថវិកាតាមការស្នើសុំ ដើម្បីក្រសួងធម្មការ មានលទ្ធភាពជ្រើសរើសគ្រូពុទ្ធិកបឋមសិក្សា សំរាប់បង្រៀននៅសាលាដែលខ្វះខាតគ្រូ ។ ក្រសួងសូមជម្រាបគណៈកម្មការក្នុងទីកចិត្តក្រៀមក្រំថាសមណសិស្សជាច្រើនរូប គឺជាអភព្វបុគ្គលចេញពីគ្រួសារក្រខ្សត់ ឬរស់នៅតាមតំបន់ឆ្ងាយៗ ដែលគ្មានសាលារៀន ។ ម្ល៉ោះហើយ យុវជនក្រីក្រទាំងនោះ ក៏ចេះតែបន្តរស់នៅក្នុងស្ថានភាពអវិជ្ជារហូតមក ។ ច្រកតែមួយសំរាប់អោយគេទទួលការអប់រំបាន គឺមានតែការសាងផ្នួស ដែលអាចអោយគេរៀនធម៌អាថ៌ អក្សរសាស្ត្រជាតិ អប់រំកាយវាចាចិត្ត ទៅតាមបែបមួយ មានប្រយោជន៍ដល់ជីវភាពអនាគតរបស់គេ ។ ដោយប្រការនេះហើយ បានជាមានសមណសិស្សខ្លះ មានវ័យចាស់ ស្ទើរតែហួសវ័យសិក្សាទៅហើយ សុខចិត្តអង្គុយរៀនជាមួយយុវសមណសិស្ស ដោយមិនគិតពីការអៀនខ្មាស ដើម្បីរំដោះខ្លួនពីអវិជ្ជា ហើយប្រហែលជាអាចជួយអោយគេអាចរស់នៅប្រកបដោយភាពសុខដុមក្នុងសង្គមគ្រួសារអនាគត ប្រសិនបើគេសឹកចាកផ្នួសទៅ ។

៣ . ក្នុងទិសដៅលើកស្ទួយពុទ្ធិកសិក្សាអោយរីវត្តរីកចំរើនប្រកបដោយគុណភាព, ក្រសួងធម្មការ ក៏បានយកចិត្តគិតគូរខ្ពស់ក្នុងការជំរុញអោយពុទ្ធសាសនបណ្ឌិត្យ បំពេញការងារស្រាវជ្រាវ បោះពុម្ព និងបើកទ្វារបណ្ណាល័យសំរាប់សាធារណជន ទាំងបព្វជិតទាំងគ្រហស្ថ ចូលអានសៀវភៅ ឯកសារកម្រៗ ដែលពុទ្ធសាសនបណ្ឌិត្យមានលទ្ធភាពរកបាន ។ ក្នុងរយៈពេលមួយដ៏ខ្លី គឺពីឆ្នាំ ១៩៩២ មកដល់ឆ្នាំ ១៩៩៩ នេះ ពុទ្ធសាសនបណ្ឌិត្យបានចេញដំណើរពីគ្មានទីតាំងធ្វើការ ដោយខ្ចីកុដិលោកធ្វើជាការិយាល័យ រហូតដល់មានអគារស្ដឹមស្ដៃ តាំងនៅក្នុងទីឋានប្រជាប្រិយ៍ បង្កើតបានឡើងវិញនូវបណ្ណាល័យមួយ មានឯកសារដ៏សម្បូរ ទាំងភាសាជាតិ និងភាសាអន្តរជាតិ និងមានបច្ចេកទេសទុកដាក់ ថែរក្សាសៀវភៅ ឯកសារយ៉ាងទាន់សម័យ បោះពុម្ពសៀវភៅជាភាសាជាតិ ដែលធ្លាប់មានពីមុន សំរាប់បំរើពុទ្ធិកសិក្សា និងការចេះដឹងរបស់ព្រះសង្ឃ និងគ្រហស្ថ ចេញផ្សាយទស្សនាវដ្ដីកម្ពុជសុរិយា រៀងរាល់ត្រីមាសឡើងវិញដោយទៀងទាត់ បន្តការងាររបស់ក្រុមជំនុំព្រះត្រៃបិដកឡើងវិញ និងបានបោះពុម្ពព្រះត្រៃបិដកឡើងវិញចំនួនមួយពាន់ចប់ ដោយការឧបត្ថម្ភថវិកាពីអង្គការសាសនាជប៉ុន សំរាប់ចែកអោយដោយឥតគិតថ្លៃ ដល់បណ្ដាវត្តអារាមសំខាន់ៗរបស់យើងក្នុងប្រទេស ។

ប៉ុន្តែ ក្រុមជំនុំព្រះត្រៃបិដក និងក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ទាំងពីរនេះរបស់ពុទ្ធសាសនបណ្ឌិត្យ នៅមិនទាន់បំពេញការងាររបស់ខ្លួនអោយបានដូចដើម នៅឡើយទេ ដោយសារខ្វះធនធានមនុស្សដែលមានសមត្ថភាពធ្វើការងារនេះបាន ។ ក្នុងពេលខាងមុខ ក្រសួងបានគ្រោងសុំថវិការដ្ឋ ដើម្បីធ្វើការជ្រើសរើសសមណនិស្សិតមួយចំនួន ដែលមានចំណេះដឹងខាងភាសាបាលី ធមិអាចជ្រៅជ្រះ ចេញពីពុទ្ធិកវិទ្យាល័យ ដើម្បីហ្វឹកហ្វឺនសមណនិស្សិតទាំងនោះ អោយមានជំនាញក្នុងការបកប្រែភាសាបាលីជាភាសាខ្មែរ ដែលអាចបំរើការងារក្នុងក្រុមជំនុំព្រះត្រៃបិដក និង

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ។

គួរកត់សម្គាល់ថា ពុទ្ធសាសនបណ្ឌិត្យ ជាស្ថាប័នមួយរបស់ក្រសួងធម្មការ និងសាសនា នឹងមានលទ្ធភាពរស់រានបាន និងបំពេញការងារបានយ៉ាងជោគជ័យ ដោយមិនផ្អែកទាំងស្រុងទៅលើការដឹងនាំរបស់ក្រសួង និងលើថវិការបស់រដ្ឋឡើយ ។ ជោគជ័យការងាររបស់ពុទ្ធសាសនបណ្ឌិត្យ កើតចេញមកពីកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងមានការទាក់ទងរកមូលនិធិពីអន្តរជាតិ ដើម្បីដំណើរការគំរោងការងារតូចៗ ដូចជា ការងារបោះពុម្ពសៀវភៅ ការងារស្រាវជ្រាវតូចតាច ... ។ ក្នុងករណីទំនាក់ទំនងអន្តរជាតិ និងការស្រាវជ្រាវនេះ ក្រសួងមានទិសដៅជំរុញខ្លាំងក្នុងបំណងធ្វើអោយពុទ្ធសាសនបណ្ឌិត្យបានឈ្មោះជាវិជ្ជាស្ថានស្រាវជ្រាវមួយ ដែលត្រូវបានវិជ្ជាស្ថានអន្តរជាតិឯទៀត ទទួលស្គាល់ ហើយអាចធ្វើសហប្រតិបត្តិការស្រាវជ្រាវជាមួយគ្នាបាន ក្នុងវិស័យពាក់ព័ន្ធ ឧទាហរណ៍ ការស្រាវជ្រាវអំពីគ្រូថ្នាំខ្មែរ គ្រូព្យាបាលជំងឺឆ្កួត គ្រូចូលរូប . ល . ។

គឺនៅក្នុងបរិបទនេះហើយ ដែលក្រសួងធម្មការ និងសាសនា បានខ្វល់ខ្វាយរកមន្ត្រីដែលមានសមត្ថភាពខ្ពស់ មានចំណេះដឹងខាងភាសាបរទេសច្បាស់លាស់ និងមានបទពិសោធន៍ក្នុងការគ្រប់គ្រងស្ថាប័ន និងចេះដឹកនាំការស្រាវជ្រាវបានផង ដើម្បីដឹកនាំវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យអោយបំរើសកម្មភាពស្រាវជ្រាវអក្សរសាស្ត្រជាតិ, ប្រពៃណី ទំនៀមទម្លាប់ជាតិ អក្សរសាស្ត្រសាសនា ទស្សនវិជ្ជា និងប្រវត្តិសាស្ត្រសាសនា រួមចំណែកធ្វើអោយសាកលវិទ្យាល័យពុទ្ធសាសនាតែមួយរបស់ជាតិ ប្រែក្លាយជាសាកលវិទ្យាល័យជាតិ ដ៏មានកេរ្តិ៍ឈ្មោះមួយនៅអាស៊ីអាគ្នេយ៍ ។ ប្រសិនបើបំណងនេះសំរេចបាន ក្រសួងមានជំនឿថា ការគោរពប្រតិបត្តិពុទ្ធសាសនា ក្នុងលក្ខណៈត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាតក្ដី ពហុសុតភាព (Erudition) ក្នុងពុទ្ធសាសនមណ្ឌលកម្ពុជាក្ដី ពុទ្ធិកមហាវិទ្យាល័យ ឬពុទ្ធិកសាកល

វិទ្យាល័យរបស់យើងក្នុងអនាគតក្តី នឹងទទួលបានការកោតសរសើរ, ធនធានមនុស្ស ក្នុងវិស័យពុទ្ធសាសនា ឬអក្សរសាស្ត្រ នឹងសំបូរ ហើយបញ្ញាញាណរបស់ជាតិយើង នឹងមានពន្លឺចែងចាំង នាំអោយកើតសុខសន្តិភាពដ៏ឋិតថេរចិរកាល ។

ការរៀបរាប់ដ៏សង្ខេប អំពីភារកិច្ចការងារទាំងបីផ្នែកខាងលើ គឺជាទស្សនវិស័យការងាររួម ដែលក្រសួងធម្មការ និងសាសនា ខិតខំធ្វើអោយបានសំរេចជាបណ្តើរៗ នៅក្នុងអាណត្តិទីពីរ របស់រាជរដ្ឋាភិបាល និងមានប្រាថ្នាធ្វើអោយទស្សនវិស័យការងាររួមនេះ ប្រែក្លាយជាទស្សនវិស័យជាប់លាប់សំរាប់អាណត្តិបន្តបន្ទាប់នៃរាជរដ្ឋាភិបាល តទៅ ។

ភ្នំពេញ, ថ្ងៃទី ២៦ កក្កដា ១៩៩៩

## ក្តៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ

ក្តៅ - ក្តួលឆួលឆេះប្រេះបែកធ្លាយ

ស៊ី - សងជេរវាយរលាយមិត្ត

រាក់ - ទាក់រាប់អានមិនបានស្និទ្ធ

ខកចិត្តគិតកែប្រែប្រេះប្រាណ ។

ត្រជាក់ - ថ្នាក់ថ្នមព្រមរែបប្រាណ

ស៊ី - ល្មមប្រមាណបានសុខកាយ

ជ្រៅ - ជ្រះល្អះល្អិតគិតវែងឆ្ងាយ

កិច្ចកលឧបាយផ្សាយមិត្តភាព ។

# សិលាចារឹកក្រុពហ្ម K 39 នៅវត្តបាទី ខេត្តតាកែវ

# L'Inscription Khmer K 39 de Taprom Vat Bati, la province de Takeo

ដោយ **ខង់ សុធារ៉ា**
សាស្ត្រាចារ្យនៃដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ

សិលាចារឹកនេះ លោកអែម៉ូនីញេ រកឃើញនៅវត្តបាទី ខេត្តបាទី សព្វថ្ងៃគឺខេត្តតាកែវ ចុះកាលបរិច្ឆេទឆ្នាំ ១៩៧៤ គ.ស. អក្សរចំនួន ២៣ បន្ទាត់ ដែលមានលក្ខណៈជាអក្សរជ្រៀង ចារលើផ្ទាំងសិលាស្តម្ភ សព្វថ្ងៃត្រូវប្រេះជាពីរចំណែក ។ អត្ថបទបង្ហាញនូវការធ្វើសច្ចាប្រណិធាន និងការរៀបរាប់អំពីតង្វាយចំពោះព្រះវិហារ មាន : វត្ថុ សត្វ និងមនុស្ស អំពីការធ្វើបុណ្យ និងអំពីសាក្សី ព្រមទាំងពាក្យបណ្តាសា ។

អត្ថបទចាប់ផ្តើមឡើងដោយពាក្យ « មួយនេះសោត » ដែលជាការបញ្ជាក់ថា វាមិនមែនជាចំណុចចាប់ផ្តើមនៃអត្ថបទនោះទេ គឺផ្នែកខាងដើមនៃអត្ថ-បទនេះ អាចត្រូវបាត់បង់ដោយប្រការណាមួយមិនខាន ។

ចំពោះអក្ខរាវិរុទ្ធ ដែលគេប្រើប្រាស់នៅសម័យនោះគ្មានឯកភាព សូម្បីស្មេរជាមនុស្សតែមួយក៏ដោយ ដូចជា :

ពាក្យ ទង្វ (ប.៦) ឬ ទំង (ប.១៨) មានន័យត្រូវនឹងពាក្យបច្ចុប្បន្នថាទាំង
ទង្វ (ប.៨) ឬ ទង (ប.១០) ឬ ទំង (ប.៧) . ទង់ (ទង់ខ្មោច, ទង់ជាតិ)
ត្រស្យ (ប.៣) ឬ ត្រស (ប.២១) . ត្រាស់ ជាដើម ។

ខាងក្រោម គឺជាអត្ថបទសិលាចារឹកទាំងស្រុង ដែលយើងសរសេរជាអក្សរសម័យថ្មី ។

# អត្ថបទ

(១) មូយ្នីសោត[១] អញ្ញប្រាថ្នា[២] ទោះបិ[៣] អញបងបញ្ចស្តូន[៤] អំពិយ[៥] នេះទៅ[៦]

(២) វស្ទូមអញបានជាមហាចក្កពិ្តរាជ[៧] ល្ហះហ[៨] ព្រះស្រិអារយមែត្រី

(៣) យ[៩] អ្នកត្រស្ស[១០] បានជាព្រះពុទ្ធអ្នកចូលនិព្វាន អញខ្ញុំសូម ចូលផោង[១១] អ្នកហាង[១២] ។

(៤) សភ្តមស្សតុ[១៣] ១៤៩៦[១៤] សកចនក្សត្រ[១៥] បូរមិផគុន[១៦] ព្រហាស្ស

(៥) ម្បតិពារ[១៧] ឪកខុណាទិព្វាសេនសែង[១៨] នុគ្រ[១៩] មានចិត្រ

(៦) សារធា[២០] ថ្វេ[២១] ព្រះពុទ្ធអង៥[២២] ខ្ញុំ១១[២៣] ក្របិ្យ៤[២៤] នុស្រេហ១២[២៥] នុទង្វ[២៦] ។

(៧) អារាមផោង នុទំងធំម១[២៧] ពិតាន៤ ឆាត២[២៨] នា

(៨) ទង្វថ្វាយកំលុងពិហារសោត ៦៦ ទងយូហា៧[២៩]

(៩) គ្រា១ឱ[៣០] ទេស្នាព្រះអភិធាមិពាចប[៣១] មហាជាថ[៣២] ពាចប

---

(១) មួយនេះសោត (២) ខ្ញុំ ( មាន ? ) ប្រាថ្នា (៣) ទោះបី (៤) ខ្ញុំបង់បញ្ចក្ខន្ធ (៥) អំពី (៦) ទៅ (៧) មហាចក្កពត្តិរាជ = ស្តេច + មហាចក្រពត្តិ (៨) លុះ (៩) ព្រះអារ្យមេត្រី (១០) ត្រាស់ (១១) ផង ឬជាមួយ (១២) ហោង (១៣) សុភមស្តុ (១៤) ឆ្នាំ ១៤៩៥ នៃមហា សករាជ ត្រូវនឹង គ.ស ១៥៧៤ គឺនៅអំឡុងសម័យលង្វែក (១៥) ឆ្នាំច (១៦) ថ្ងៃពេញបូណ៌ ខែផល្គុន (១៧) ព្រហស្បតិ (១៨) ឪកខុនសេនា ? សែង = លោកសែង (មើលអធិប្បាយ) (១៩) គ្រូ ឬគ្រូសារ (២០) សទ្ធា ឬសាទ្ធិា ឬស្រទ្ធា (២១) ធ្វើ (២២) ៥អង្គ (២៣) អ្នកបំរើ ១១ នាក់ (២៤) ក្របី ៤ ក្បាល (២៥) ស្រែចំនួន ១២ (២៦) ទាំង (២៧) ទង់ធំ (២៨)឴ឆ័ត្រ ២ (២៩) តាំងយូ ៧ ( បណ្ឌិត ពៅ សាវរស ថាបី ) ច្បាប់ដើមយ៉ាងនេះ " "

( ឆ្លងទៅទំព័រម្ខាង )

(១០) មហាពុទ្ធគុន[៣៣] អានុសំទង[៣៤] អានុសំព្រះហ[៣៥] ចំមលា

(១១) លោងបុន[៣៦] ផោង នាទានសបភ្យញ្ញ[៣៧] ផោង ស្បងគ្រប[៣៨] ហោង

(១២) មួយ្យឝ្មិសោត ឪកខុណាទិព្វាសេនសែង នុគ្រូគាត[៣៩] និម្ន[៤០] អ្នកសំតេចព្រះធម្ម

(១៣) ត្រៃលោក[៤១] នុអ្នកសំតេចព្រះធម្មវង្សានុអ្នកសំតេចព្រះធម្មឃោសា នុក្រំត័

(១៤) ង[៤២] ថេរានុថេរ[៤៣] ភិក្សុសុស័យ[៤៤] ផោង មោកជុំនុំ ចៅវឥន្ទ

(១៥) សុធរ នុចៅវហ្លួងព្រះឃ្លាង[៤៥] ចៅវឥន្ទប្រញា ចៅវសុភាវង្សា

(១៦) ចៅវតេជោធ្វបេស មោកជុំនុំទុក្កដោះខ្ញុំ[៤៦] មួយ បាសមចិ (ត)

(១៧) មេគនគ្រូ១ បាសុកមេពុំងារកូន៦ មេកែវលេ ... វមោក

(១៨) ជុំនុំ នាខ្ញុំទំងនេះ ថ្វាយព្រះស្រីយរតនត្រៃយ[៤៧] នាព្រះពិហារ

(១៩) នុ ...មហាថេរបវរសាស[៤៨] នេះជាចៅវត្រ ទោះបេ[៤៩] មាន បោងផ្ខន[៥០] ក្ខូ

(២០) នចៅវ បេមោកឆ្នសស្រេតិ[៥១] ពីព្វាយោក[៥២] ជាខ្ញុំម ថ្វេឪយជាកំត្យ

(២១) ង[៥៣] ព្រះពុទ្ធអំម្បាលខ្សេច[៥៤] មោកត្រសងឯក្រោយ ឯភ្នេកក្តិ[៥៥] កំម្បី

(២២) ប្រោសអ្នកនោះបានលេយ សុភា[៥៦] នាជួយរេ[៥៧] ឪយនោ ទៅនៅមួយ

អន្លេ[៥៨] ...

---

(៣០) ច្បាប់ដើមសរសេរ ឱ អានថា ឱ =ឱយ (៣១) អោយទេសនា ព្រះអភិធម្មពាចប់ (៣២) មហាជាតក (៣៣) គុណា (៣៤) អានិសង្សទង់ (៣៥) អានិសង្សព្រះពុទ្ធរូប (៣៦) អានិសង្សចម្លងបុណ្យ ឬពិធីឆ្លងបុណ្យ (៣៧) សំ. វ្យញ្ជន (មើលអធិប្បាយ) (៣៨) សឹងគ្រប់ (៣៩) គ្រូសាររបស់គាត់ (៤០) និមន្ត (៤១) ធម្មត្រៃលក្ខណ៍ (មើលអធិប្បាយ) (៤២) កម្រពាង ឬគម្ពែង (មើលអធិប្បាយ ) (៤៣) ថេរានុថេរ (៤៤) ភិក្ខុសង្ឃ (៤៥) ម្ហូប (សូមមើល ពៅ សាវរស BEFEO, t.LXX, 1981, pp.120-125. ) (៤៦) ទុកឈ្មោះ អ្នកបំរើ ឬខ្ញុំកំដរ (៤៧) ព្រះស្រីរតនត្រ័យ (៤៨) មើលអធិប្បាយ (៤៩) ទោះបើ (៥០) បង ប្អូន (៥១) ឆ្នាស់ ស្រដី (ឬសំដីឆ្នាស់) (៥២) ពិពាតយក ឬបៀតបៀនយក (៥៣) កម្តីង ឬមិនដឹង (៥៤) ខ្សាច់ (៥៥) ឯភ្នែកក្តី (៥៦) ចៅក្រម (៥៧) ជួយរើស (៥៨) មួយកន្លែង

(២៣) ... នាបរមពចិនារក[៥៩] នាលោង ។

## អក្សរបកជាអក្សរឡាតាំង

1- mūy ni sot añ nan prāthnā doḥ pi añ paṅ pañcaskan aṃbīy neḥ do-

2- v sūm añ pān jā mahācakkarbvatirāj luḥh braḥ sri ārayamaitrī-

3- y ªnak trāss pān jā braḥ buddh ªnak cūl nibvān añ khñuṃm sūm cūl phoṅ ªnak haṅ

4- sabhbamassatu 1496 sak ca naksatr pūramī phagun brahāssa-

5- mpatībār ok khuṇ dibvāsenasaeṅ nu grū mān citr

6- sāradhā thve braḥ buddh aṅ 5 khñuṃ 11 krapīy 4 nu sreh 12 nu daṅṅ

7- ārām phoṅ nu daṃṅ dhaṃm 1 bitān 4 chāt 2// nā

8- daṅṅ thvāy kaṃluṅ bihār sot 66 daṅ yūh 7 //

9- grā 1 o[y] desnā braḥ abhidhārm 3 cap mahājāth 3 cap

10- mahābudhagun ānusaṃ daṅ ānusaṃ braḥh caṃmalā

11- loṅ pun phoṅ nā dān sap bhyañj phoṅ syaṅ grap hoṅ //

12- mūy ni sot ok khuṇ dibvāsenasaeṅ [nu] grū gāt niman ªnak saṃtec braḥ dhamma

13- trailāk nu ªnak saṃtec dhammavaṅsā nu ªnak saṃtec braḥ dhammaghosā nu kraṃtắ-

14- ṅ therarānuther bhīksususắgh phoṅ mok juṃnuṃ cauv inda-

---

(៥៩) រពិចិនរក ឬនរករវិចិ ។

15- sudhar nu cauv hluoṅ braḥ ghlāṅ cau indaprañā cauv subhāvaṅsā

16- cauv tejodhūpes // mok juṃnuṃ duk jmoḥ khñuṃ mūy pā sam cit

17- me gan grū 1 pā suk me būṃṅā kūn 6 me kaev le ...v // mok

18- juṃnuṃ nā khñuṃ daṃṅ neḥ thvāy braḥ sriy ratanatraiy nā braḥ bihār

19- nu ... mahāther pavarasās neḥ jā cauv vatr // doḥ pe mān poṅ ph-on kū-

20- n cauv pe mok chnas sratī bibvā yok jā khñuṃm thve oy jā kaṃ tya-

21- ṅ braḥ buddh aṃmpāl khsec mok tras e kroy e bhnek kti kaṃmpī

22- pros ªnak noḥ pān ley subhā nā juoy re [s] oy no ... dau nau mūy anle...

23- ... nā pāp abacinārak nā hoṅ

## អត្ថបទបកប្រែ

(១) មួយនេះសោត ខ្ញុំមានប្រាថ្នា ទោះបីខ្ញុំបង់បញ្ចក្ខន្ធអំពី (លោក) នេះទៅ (២) សូម(អោយ)ខ្ញុំបានជាស្តេចចក្រពត្តិ (មួយអង្គ) ។ លុះ (ដល់) ព្រះស្រីអារ្យមេត្រី (៣) ស្តេចត្រាស់បានជាព្រះពុទ្ធ (មួយអង្គ) រួចចូល(បរិ)និព្វាន (សូម) ខ្ញុំ(ដែលជា) អ្នកបំរើបានចូល (និព្វាន) ជាមួយព្រះអង្គហោង ។

(៤) សុភមស្តុ ១៤៨៦ (សក) នៃមហាសករាជ ឆ្នាំច ពេញបូរមី ខែផល្គុន ថ្ងៃព្រហ-(៥) ស្បតិ ឱកខុនទិព្វាសេនា សែង [(១)] និងគ្រួសារមានចិត្ត (៦) សទ្ធា ធ្វើ (ឬសាង) ព្រះពុទ្ធរូប ៥ អង្គ (ថ្វាយ) អ្នក បំរើ ១១ នាក់ ក្របី ៤ ក្បាល ស្រែ ១២ ជាមួយ

(៧) និងអារាម (គឺសួនកំសាន្ត) ផង មានទង់ធំ ១ (កំណាត់ធ្វើជា) ពិតាន ៤ ឆ័ត្រ ២ (៨) នាំ ទង់ថ្វាយ (ទុកប្រើប្រាស់នៅ ក្នុង) វិហារចំនួន ៦៦ តាំងយូ ៣ (៩) នៅពេលនោះ (គាត់) អោយ (លោក) ទេសនា ព្រះអភិធម្ម ចំនួន ៣ ចប់ មហាជាតក ចំនួន ៣ ចប់ (១០) មហាពុទ្ធគុណ អានិសង្ស ទង់ អានិសង្សព្រះបដិមាករ (១១) (ព្រមទាំងអានិសង្សពិធី) ឆ្លងបុណ្យផង ក្នុងពេល ធ្វើទានសព្វបែបយ៉ាង តាំងពីម្ហូបអាហារផង សឹងគ្រប់មុខហោង ។

(១២) មួយនេះ ទៀតសោត ឱកខុនទិព្វាសេនាសែង និងគ្រួសាររបស់គាត់ និមន្តអ្នកសម្តេចព្រះធម្ម (១៣) ត្រៃលក្ខ (២) អ្នកសម្តេចព្រះធម្មវង្សា និងអ្នកសម្តេចព្រះធម្មឃោសា និងព្រះគម្តែង (៣) (សង្ឃ) (១៤) ថេរានុថេរ ភិក្ខុសង្ឃផងមកជំនុំ ។ (អញ្ជើញ) ចៅ ឥន្ទ (១៥) សុធរ ចៅ (៤) ហ្លួងព្រះឃ្លាំង ចៅឥន្ទប្រាជ្ញា ចៅសុភាវង្សា (១៦) ចៅតេជោ ធូបេស មកជំនុំ (ចារ) ឈ្មោះទុក ។ អ្នកបំរើឈ្មោះ ជាសមចិ (ត) (១៧) មេ គន ១ គ្រួសារ បាសុក មេពុំងារ និងកូន៦នាក់ មេ កែវ ... (ក៏) មកជំនុំ នាពេល (ដែល) អ្នកបំរើទាំងនេះ ត្រូវ (លើក) ថ្វាយ (ជាបំរើ) ព្រះស្រីរតនត្រ័យនៅព្រះវិហារ (នេះ) (១៨) (ដែលមានព្រះ) មហាថេរ (៥) បវរសាសន៍នេះ ជាចៅអធិការវត្ត ។ ទោះបើបង ប្អូន កូ- (២០) ន ចៅ (ណា) មកឆ្នាស់ស្រដីវិវាតយកអ្នកបំរើ (ទាំងនេះ ត្រឡប់វិញ ដោយ)ធ្វើជាមិនដឹង(២១) (សូម) ព្រះពុទ្ធដ៏ច្រើនដូចគ្រាប់ខ្សាច់ (ដែល) មកត្រាស់នៅពេលខាងក្រោយ (ឬ) នៅក្នុងពេលនេះក្តី កុំបី (២២)ប្រោសអ្នក ទាំងនោះឡើយ ។ លោកខាងសភា (អ្នកកាត់ក្តីឬចៅក្រម) ជួយរើសអ្នក (បំរើ ?) ទាំងនោះ ... ទៅនៅមួយកន្លែង (២៣) ... នា (ស្ថាន) នរកអវិចីឯនាយហោង ។

## អត្ថាធិប្បាយ

១. តាមបណ្ឌិត ពោ សាវរស ឋានន្តរនាមនេះខ្ចីសៀម ដែលសរសេរថា « ឱក » ។

នៅសម័យកណ្តាល (គឺសម័យក្រោយអង្គរ) ខ្មែរយើងសរសេរថា " ឪក-ឪក- ឱក-អក " បន្ទាប់មក សរសេរថា " ឱក " វិញ ។ បើតាមក្បួន " ព្រះរាជក្រិត្យ ក្រមចៅហ្វាយស្រុក " ដែលបោះពុម្ពផ្សាយដោយលោក ញ៉ុក ថែម តាមទស្សនាវដ្តី " កម្ពុជ-សុរិយា " ឆ្នាំ ១៩៤៦ ខែកុម្ភៈ ទំព័រ ៧៦-៩៤ គឺជាអត្ថបទដែលស្រង់ពីច្បាប់ដើម នៅឆ្នាំ ១៨២៨ គ.ស. បង្ហាញអោយដឹងថា ឋានន្តរនាម ៖

ឱកញ្ញា សំគាល់ឋានៈរដ្ឋមន្ត្រី និងអភិបាលខេត្តធំៗនៅក្នុងប្រទេស ដូចជា ខេត្ត ពោធិសាត់ ត្បូងឃ្មុំ បាភ្នំ កំពង់ស្វាយ និងទ្រាំង ជាដើម ។

ឱកឃុន ឬអកខុន សក្តិ ៩ ហ៊ូពាន់ មានមុខងារជាជំទប់ ចៅហ្វាយស្រុកសក្តិ ១០ ហ៊ូពាន់

ឱកហ្លួន ឬអកហ្លួន សក្តិធំជាងគេ គឺ ៤ ហ៊ូពាន់ មានមុខងារជាជំទប់ ចៅហ្វាយស្រុកសក្តិ ៩ និង ៨ ហ៊ូពាន់ សក្តិតូចជាងគេ ២ ហ៊ូពាន់ ដែលមាន មុខងារជាចៅមឿង ។

ឱកពាន់ ឬអកពាន់ សក្តិធំជាងគេគឺ ៣ ហ៊ូពាន់ មុខងារជាជំទប់ ចៅហ្វាយស្រុក សក្តិ ៧ និង ៦ ហ៊ូពាន់ សក្តិតូចជាងគេ ២ ហ៊ូពាន់ មុខងារជា ជំទប់ចៅមឿង ។

ឱកហ្លួង ឬអកហ្លួង សក្តិធំជាងគេគឺ ២ ហ៊ូពាន់ មុខងារជាយោក្ប័ត្រ ក្រឡាបញ្ជី ចៅហ្វាយស្រុក សក្តិ ៧ និង ៦ ហ៊ូពាន់ សក្តិតូចបំផុតគឺ ១ ហ៊ូពាន់ មុខងារជាជំទប់ចៅបាន ។

ឋានន្តរនាមទាំង ៤ នេះ សំគាល់មន្ត្រីថ្នាក់កណ្តាល គឺនៅថ្នាក់ខេត្តផង និងនៅមូលដ្ឋានផង ស្របតាមខេត្តធំ ឬតូច ។

ដូច្នេះ ឱកខុណសេនាសែង អាចជាជំទប់នៃចៅហ្វាយស្រុកខេត្តទ្រាំង ព្រោះបើ ខេត្តបាទីវិញ នៅសម័យនោះ ចៅហ្វាយខេត្តសក្តិ ៨ ហ៊ូពាន់ ដែលមានចៅ

មឿង ៤ ឡើងសួយ ។

២. គឺសំគាល់ព្រះសង្ឃជាន់ខ្ពស់ ឬរាជាគណៈ ? ដោយសារបច្ចេកពាក្យ ឋានន្តរនាមថា « អ្នកសម្តេចព្រះ » នៅពីមុខនាមបញ្ញត្តិរបស់ព្រះអង្គ ។ នាមទាំងនេះឃើញថាគ្មាននៅក្នុងចំណោមនាមបញ្ញត្តិ នៃសង្ឃជាន់ខ្ពស់ទាំងឡាយ ដែលលោកមហាពិទូរក្រសេមបានរួបរួមឡើង តាមការស្រង់ចេញពីសិលាចារឹកនគរវត្តរបស់លោកឡើយ ។ នាមទាំងនេះ សុទ្ធតែបង្កប់នូវអត្ថន័យទាក់ទងនឹងបច្ចេកពាក្យក្នុងពុទ្ធសាសនា ដូចជាៈ

- ធម្មត្រៃលក្ខ មានន័យថា " លក្ខណធម៌ជាវិជ្ជមានបី " គឺ *អនិច្ច* = ដំណើរមិនទៀងទាត់ ឬធម្មភាព ដែលឈានទៅរកសេចក្តីវិនាស បាត់បង់ទៅវិញ *ទុក្ខ* = សេចក្តីឈឺចាប់ខ្លោចផ្សា និង*អនត្តា* = មិនមែនជារបស់ខ្លួន ។ តាមបណ្ឌិត សាវរស ថាពាក្យ « ធម្មត្រៃលោក » បែបនេះអាចមកពីអ្នកចារធ្វើអោយខុសអក្ខរាវិរុទ្ធនៃពាក្យ " ធម្មត្រៃលោក " ដែលមានន័យថា " លោកទាំងបីនៃធម៌ " ។
- ធម្មវង្សា មានន័យថា " វង្សនៃព្រះធម៌ "
- ធម្មឃោសា មានន័យថា " ការឃោសនាព្រះធម៌ "

៣. ព្រះគម្តែងសង្ឃ មានការប្រើក្លាយមកពីបច្ចេកពាក្យសំរាប់បុគ្គលខ្ពង់ខ្ពស់ អានព្រះមហាក្សត្រ និងព្រាហ្មណ៍ ឬអាទិទេព ឬក៏ទីស្ថានរបស់អាទិទេព នៅសម័យមុនអង្គរ *(វ្រះកម្រតាងអញ ឬវ្រះកម្រតាញអញ)* សម័យអង្គរ *(វ្រះកម្រតេងអញ)* បន្ទាប់មក យើងឃើញគេប្រើប្រាស់ពាក្យនេះជាបន្តទៀត នៅសម័យក្រោយអង្គរ ជាពិសេស នៅលើសិលាចារឹកនគរវត្ត ដែលគេហៅព្រះពុទ្ធថា *ព្រះពុទ្ធកំម្រតែង* ឬពាក្យ*ព្រះកម្រតែង* (សិលាចារឹកនគរវត្តលេខ ២) ហើយដែលចុងក្រោយមក បច្ចេកពាក្យនេះ សម្រេចរូបស័ព្ទមកជា*ព្រះគម្តែង* ។

៤. ចៅ ជាគោរមន្យនាមនៅសម័យកណ្តាល សំរាប់សំគាល់មនុស្សប្រុសដែលមានចំណេះវិជ្ជាផ្លូវលោក និងផ្លូវធម៌ ពោលគឺ ជាអ្នកដែលធ្លាប់បានបួសរៀន ។

ម្យ៉ាងទៀត ពាក្យ « ចៅ » ត្រូវបានគេយកប្រើសំគាល់ន័យ « មេ ឬ អធិបតី » ដូចជា ចៅវត្ត មានន័យថា មេវត្ត ឬ ចៅអធិការវត្ត ។ សព្វថ្ងៃ ពាក្យនេះ នៅប្រើប្រាស់នៅឡើយដែរ ដូចជា ចៅសង្កាត់ ចៅហ្វាយស្រុក ... ។ តាមច្បាប់ក្រុមចៅហ្វាយស្រុកដដែល បង្ហាញអោយឃើញនូវការប្រើប្រាស់បច្ចេកពាក្យ « ចៅ » ដោយភ្ជាប់ជាមួយពាក្យដទៃទៀត សំរាប់សំគាល់ឋានៈមន្ត្រីថ្នាក់ក្រោមនៃនគរ ដែលមានសក្តិធំ ត្រឹម ២ ហ៊ូពាន់ ដូចជា :

- ចៅមឿង គឺជាមេស្រុក ដែលត្រូវនឹងមេឃុំ ឬចៅសង្កាត់ នាពេលបច្ចុប្បន្ន ។
- ចៅបាន គឺឋានៈបន្ទាប់ពីចៅមឿង ។
- ចៅហ្លួង គឺឋានៈជាចាស់ស្រុក ឬព្រឹទ្ធាចារ្យនៅក្នុងភូមិ ។ ក្រៅពីនេះ នៅមានឋានន្តរនាមដ៏ខ្ពង់ខ្ពស់មួយទៀត ថាចៅហ្វាយទឡ្ហះ - គឺឋានៈស្មើរដ្ឋមន្ត្រីទី ១ ឬនាយករដ្ឋមន្ត្រី ។

៥. មហាថេរ គឺសំគាល់ព្រះសង្ឃអង្គណា ដែលចាស់វស្សា គឺបួសជាប់យ៉ាងយូរតាំងពីក្មេងរហូតដល់ចាស់ ។ នៅកម្ពុជា ខ្ញុំមិនដឹងថា តើការអោយគោរមងារថា « មហាថេរ » ដល់ព្រះសង្ឃអង្គណាមួយ តើព្រះសង្ឃអង្គនោះ ត្រូវតែបួសជាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំនោះទេ ប៉ុន្តែបើតាមព្រះតេជព្រះគុណមុទិតាថេរោ ព្រះសង្ឃស្រីលង្កា ដែលបង្រៀននៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតសព្វថ្ងៃ មានសង្ឃដីកាថា នៅស្រីលង្កា ព្រះសង្ឃដែលទទួលបានគោរមងារ « មហាថេរ » ទាល់តែបួសជាប់ក្នុងរយៈពេលចាប់ពី ៣០ ឆ្នាំឡើង ។

***

# ឯកសារពិគ្រោះ

1- Saveros POU, BEFO t. LXX, Paris 1981, pp. 120-25.
2- Saveros POU, Nouvelles Inscriptions du Cambodge I, Paris 1989.
3- Saveros POU, Nouvelles Inscriptions du Cambodge II, Paris 1996.
4- L'Académie des Inscriptions et Belle-Lettres, Inscriptions du Cambodge, t.I , Paris 1926.
៥. មហាពិទ្ធរក្រសេម សិលាចារឹកនគរវត្ត សេដូរែក CEDORECK ប៉ារី. 1984 ។
៦. ញ៉ុក ថែម ព្រះរាជក្រិត្យ ក្រមចៅហ្វាយស្រុក ក្នុងកម្ពុជសុរិយា លេខ ១០_១២ ឆ្នាំ ១៩៤៥ ដល់លេខ ២ ឆ្នាំ ១៩៤៦ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

*អក្សរសាស្ត្រខ្មែរ ខ្មែរត្រូវថែធ្មួន*
*អោយបានខ្ជាប់ខ្ជួន គង់វង្សគត់មត់*
*ព្រោះអក្សរជាតិ គោលជាតិប្រាកដ*
*អក្សររលត់ ជាតិក៏រលាយ ។*

ធ.ព

# ផ្ទាំងសិលាចារឹកដើម



# ក្រមុំព្រហ្មចារី (*)

ពាក្យប្រាំពីរ

នារីដែលមានវ័យវឌ្ឍនា ជួបចូលជន្មាដឹងសេចក្តី
អាយុគ្រប់ការបូរាណស្តី ហៅថា **យុវតី** ស្ត្រីក្រមុំ ។
នាមនេះពិរោះខ្ពស់ពន់ពេក ឮហើយគួរព្រេកព្រេងភិរម
បូរាណបានថែមពាក្យមួយផ្សំ គឺហៅ « ក្រមុំព្រហ្មចារី » ។
ស័ព្ទនេះបើប្រែកែអភិប្រាយ សំដៅយកកាយជាតិស្ត្រី
ដែលនៅក្រមុំសុទ្ធពិសី ដូចសំពត់ថ្មីគ្មានប្រឡាក់ ។
មិនដែលប្រឡែងសំដែងតួ ដើរចូលផ្លូវជួក្នុងរឿងស្នេហ៍
គឺមិនដែលសោះរឿងរួមរ័ក្ស នឹងប្រុសល្ងចលាក់ប្រពៃណី ។
ក្រមុំក្រុមនេះចាស់ដូនតា ហៅថា « ក្រមុំព្រហ្មចារី »
តម្កើងឋានៈមារយាទស្ត្រី ខ្ពង់ខ្ពស់ពិសីស្មើលោកសង្ឃ ។
ព្រោះអីព្រះសង្ឃលោកទ្រង់សីល វៀររឿងខូចខិលខាងបកស្បង់
គឺផ្លូវកាមេស្នេហ៍ភិសវង់ (**) បរិសុទ្ធស្អាតអង្គល្អប្រពៃ ។
គួរគេបូជាសក្ការៈ តម្កើងឋានៈខ្ពង់ខ្ពស់ក្រៃ
គួរគេគោរពប្រណម្យដៃ ធ្វើទានថ្វាយទេយ្យធម៌ផង ។
រីឯនារីឫកពិសី ហៅ « ព្រហ្មចារី » ល្អម៉ត់ម៉ង
តែងមានកិត្តិយសល្អកន្លង អ្នកផងពេញចិត្តថា « ប្រពៃ » ។

---

(*) លោក ផល ទិត រៀបរៀង និងបានចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា លេខ ២ ឆ្នាំ ១៩៧១

(**) ភិសវង់ = គួរអោយចាប់ចិត្តស្រឡាញ់, គួរអោយស្នេហា, ...

ប្រុសៗគ្រប់ប្រាណតែងប្រាថ្នា ជ្រើសរើសភរិយារូបនិស្ស័យ
ស្មើរតែគ្រប់រូបតែងរំពៃ ជាដំបូងដែគី « បរិសុទ្ធ » ។
ព្រោះគេយល់ថាយុវតី បង់ព្រហ្មចារីរែងមានពុត
ស្រើបស្រាលអាលកាមគុណដុត រក្សាបរិសុទ្ធខ្លួនពុំបាន ។
អោយប្រុសមួយពីរញូក់ញីលេង សប្បាយជាល្បែងល្បងកំសាន្ត
រួចហើយវិលវេរិះកែប្រាណ លុបដានថាខ្លួនក្រមុំស្អាត ។
ទើបយកប្តីក្រោយដោយនូវច្បាប់ ធ្វើឫកចំណាប់មិនខ្មាសញាតិ
ឆ្លងកេរ្តិ៍ពូជដូចអាក្រាត ជួជាតិអប្រិយដល់ប្តីទៀត ។
គេថ្កោលទោសប្តីថាល្ងើពេក ល្ងង់ដូចជារែកចំចោលម្សៀត
ស្ត្រីពេញនគរចរចង្កៀត ម្តេចភ្លើមកឆ្កៀតយកដែលគេ ។
សម្បត្តិផងស្ត្រីដែលសម្រាំង សម្រិតបិទបាំងរក្សាថៃ
ជាកេរមរតកមកពីម៉ែ គួរថែបរិសុទ្ធទុកអោយប្តី ។
បើប្រុសមួយពីរដឹងសម្ផស្ស បម[*] រូបស្រូបរសរួមចិត្តស្ត្រី
រួចរាល់ទើបរេរកស្វាមី បើប្តីបានដឹងនឹងយ៉ាងណា ។
ខ្មាសអើយសែនខ្មាសផ្តាសអោយស៊ុន ម្លេះសមប្រុសមុនយល់ចរិយា
នឹងសើចចំអកប្តីនាងថា ភរិយាគាត់ឯងសល់ពីអញ ។
បើមានប្តីពិតរួចគិតលះ លែងដាច់ស្រឡះអស់ស្រឡាញ់
ជាមេម៉ាញពិតឥតបើកាញ់ នោះគួរស្រឡាញ់រួមស្នេហ៍ស្និទ្ធ ។
គឺបើមេម៉ាញមេម៉ាញចំ គឺបើក្រមុំក្រមុំពិត
កុំតែក្រមុំបន្លំបិទ ធ្លាប់សាកស្នេហ៍ស្និទ្ធស្រេចទៅហើយ ។

(*) បម = ថ្នម ; ពាក្យបរិវារសំរាប់និយាយផ្សំនឹងពាក្យបី : បីបមថ្នមត, បីបមបំពេ ។

អាស្រូវនារីដែលស្មោះត្រង់ គ្មានចិត្តណាចង់ផ្លាស់ប្តូរឡើយ
តែបានសង្សារណាមួយហើយ បងអើយអូនសូមផ្ញើវាសនា ។
បំណងប៉ងយកជាគូស្និទ្ធ គ្រោះរស់ជីវិតជាមួយគ្នា
ឯប្រុសចិត្តព្រានគ្មានមេត្តា បំពេញតណ្ហាហើយបោះបង់ ។
កាលមកល្បួងលោមហ៊ានស្បែស្បថ គួរជឿប្រាកដថាពិតត្រង់
ដល់ព្រមជូនប្រាណតាមចំណង់ គេភ្លេតហើយបង់គេចកែដោះ ។
ខ្លះថាមេបាដាក់កំហិត ខ្លះចោទថាចិត្តស្រីមិនស្មោះ
ខ្លះស្តាយភាពខ្លួននៅកម្លោះ គេមានផ្លូវដោះបោះបង់បាន ។
ខ្លះថាស្រីដែលគេនិយាយ ចែចង់បានងាយខុសលំអាន
យកជាគ្រួសារពិតពុំបាន គេយកកំសាន្តប៉ុណ្ណឹងទេ ។
ឯនារីវិញពេញជាខុស ឆាប់ជឿចិត្តប្រុសទ្រុស្តឪម៉ែ
ស្លួងចិត្តគិតថាមិនអីទេ លង់ស្នេហ៍គេប្រាប់ស្តាប់លែងឮ ។
រសជាតិស្នេហាវាសែនឆ្ងាញ់ ពេលឈ្លក់ស្រឡាញ់ឃើញថាភ្លឺ
ដល់កើតវិបត្តិខ្ទាត់ពន្លឺ ខ្លះទៅជាឈឺរីងរៃប្រាណ ។
ខ្លះក្តៅហួសពេកបែកព្យាបាទ ធ្វើអត្តឃាតឃ្លាតចាកឋាន
យំយែកស្រែកថាខ្ញុំខុសប្រាណ មិនស្មានថាគេហ៊ានប្រែចិត្ត ។
ខ្លះធ្វើមុខក្រាស់មិនផ្លាស់ខុស រកប្រុសមួយដៃរកែឈឺចិត្ត
បានបាត់បានបង់លង់ចរិត បង់ក្រិត្យទៅជាស្រីពេស្យា ។
ខ្លះចេះមារយាទធ្វេតលាក់ទុក ថាខ្លួនបរិសុទ្ធអស់ក្រឡា
សុភាពបុរសពេញចិន្តា បង្ខំមេបាអោយចូលស្តី ។
យកជាប្រពន្ធបង្កើតបុត្រ ស្មានថាបរិសុទ្ធល្អពិសី
ក្រោយមកដល់ដឹងថាជាស្រី បង់ព្រហ្មចារីមុនទៅហើយ ។

ខកចិត្តគិតកែប្រែគំនិត ដកក្តីទុកចិត្តសោះអង្គើយ
*ជូនកាលត្រូវលះលែងកន្តើយ នេះហើយជាទោសព្រោះស្នេហា ។*
*អាដែងស្នេហ៍តវាកើតទុក្ខ អាស្រូវឪពុកម្តាយខ្លោចផ្សា*
*តើគួរបន្ទោសខុសអ្នកណា បើតាមខ្ញុំថា គឺខ្លួនឯង ។*
*ភ្លើតភ្លើនលូកភ្លើងថាស្រណុក ឱបដុំប្រហុកទុកជាល្បែង*
*ដល់ក្តៅដល់ស្អុយទើបចំបែង ស្រែកយំក្តែងៗលែងកែបាន ។*

***

កាលបើឃើញភ័យ ពីចម្ងាយ
ត្រូវគេចអោយឆ្ងាយ កុំចង់យល់
តែបើភ័យភិត ជិតមកដល់
ត្រូវតស៊ូទល់ អោយក្លាហាន ។
ការពារទុកមុន ជាគុណទ្វេ
ចាំកែជាក្រោយ បានដោយស្ពាន
អ្នកប្រាជ្ញលោកប្រាប់ ជនគ្រប់ប្រាណ
ថាត្រូវអោយមាន កិច្ចការពារ ។

# លក្ខណ៍របស់បុរសស្ត្រី

( តាមតម្រាបុរាណ )

## I. បុរសគ្រប់លក្ខណ៍ ៖

បុរសដែលប្រកបដោយលក្ខណៈ ២៦ ប្រការ ហៅថាបុរសគ្រប់លក្ខណ៍ គឺ ៖

១. ឧស្សាហ៍ខ្នះខ្នែងធ្វើការងារ រៀនសូត្រ មិនប្រកាន់ខ្លួន
២. មិនចេះលួចប្លន់កេងកិបឆបោក
៣. មិនឈ្លានពានចំពោះកូនប្រពន្ធអ្នកដទៃ
៤. មិនរំភើបញាប់ញ័រភ័យផ្តេសផ្តាស
៥. មិននិយាយកុហកភូតភរអោយលើសពីការណ៍ពិត
៦. មិននិយាយត្រាប់ឱ្យគេរៀនខ្នាស
៧. បានឮដំណឹងអ្វីហើយ វិនិច្ឆ័យសិន ទើបជឿជាក្រោយ
៨. ធ្វើការងារមិនរួសរាន់ពេក មិនយឺតយូរពេក
៩. មិនចេះនិយាយបំផ្លើសសើចលេង
១០. ចេះទទួលភ្ញៀវពន្លីមិនរើសមុខ
១១. មានថ្នាំកែរោគបំរុងទុកមិនខ្វះក្នុងពេលត្រូវការ
១២. មិនប្រាប់ការណ៍សម្ងាត់ដល់អ្នកដទៃ
១៣. មិនផ្ញើរបស់ទុកនឹងបុគ្គលមិនគួរផ្ញើ
១៤. មានចិត្តអត់ធន់ តស៊ូមិនរួញរាចំពោះកិច្ចការ
១៥. មានស្វាមីភ័ក្តិចំពោះនាយចៅហ្វាយ

១៦- មិនចេះឡិកឡក់ចំពោះស្រីក្រមុំ

១៧- ស្គាល់ចំណោញស្គាល់ខាត

១៨- រកប្រដាប់តុបតែងខ្លួនអោយភរិយា បុត្រធីតា និងខ្លួនឯង

១៩- មិនទិញជឿនូវរបស់ប្រើប្រាសគ្រប់យ៉ាង

២០- ដឹងគុណ តបគុណ សរសើរគុណ នៃអ្នកមានគុណ

២១- គោរពតាមឱវាទមាតាបិតា ញាតិមិត្រ និងអ្នកប្រាជ្ញ

២២- ចេះអត់ទ្រាំស្ដាប់នូវពាក្យដែលស្ដីបន្ទោស ប្រដៅ

២៣- មានកាយវាចាសមរម្យមិនឆ្គង

២៤- អោយដំណឹងមនុស្សក្នុងផ្ទះហើយសឹមចេញទៅ

២៥- ចេះវាយប្រដៅកូនដោយរំពាត់យ៉ាងតូច

២៦- ខឹងឆាប់បាត់ មិនចងកំហឹងទុក

## II. ស្ត្រីគ្រប់លក្ខណ៍

ស្ត្រីដែលប្រកបដោយលក្ខណៈ ៣១ ប្រការ ហៅថាស្ត្រីគ្រប់លក្ខណ៍ គឺ :

១- មិនចេះអេចអូចនិយាយដើមគេ

២- ចេះគួរសមទទួលមាតាបិតា និងស្វាមី

៣- ដឹងគុណ តបគុណមាតាបិតាញាតិសន្ដានទាំងពីរខាង

៤- មិនចេះដេកថ្ងៃ

៥- មិនវង្វេង ភ្លេចមុខភ្លេចក្រោយ

៦- ចេះថែទាំរបស់ទ្រព្យ

៧- មិនផិតក្បត់ស្វាមី

៨- មិនចេះប្រច័ណ្ឌស្វាមី

៩. គ្មានកលមាយា

១០. មិនរំសាយសក់អោយគេឃើញ

១១. មានចិត្តអត់ធន់ធ្ងន់ធ្ងរ

១២. មានជើងស្រាល មិនតន្ត្រំក្តុងក្តាំង

១៣. មិនឈរ ឬអង្គុយសំពៀងកាយអោយគេឃើញ

១៤. មិនដើរញឹកញ៉ក់កាច់រាង

១៥. ចេះសង្រួមភ្នែក មិនក្រឡេករឡេមរឡាម

១៦. មានដំណើរល្អ មិនគ្រលែងកាយចំទយគូទ

១៧. មិនបង់បោយញាក់ស្មាគ្រលែងដើមដៃ

១៨. មានសំឡេងតិចឡាប់លាស់

១៩. មិនចេះឡេះឡោះលេងសើច

២០. មិននិយាយផ្តោះផ្តងចំពោះបុរស

២១. មិនទម្រន់ ធ្វើការណា ធ្វើទាល់តែហើយការនោះ

២២. ទៅណាឆាប់ត្រឡប់វិញ

២៣. ចេះទុកដាក់ឥវ៉ាន់ ក្នុងពេលគួរទុកដាក់

២៤. ចេះរៀបចំផ្ទះសម្បែង

២៥. ចេះតុបតែងគ្រឿងឧបភោគ-បរិភោគ

២៦. ខ្លាចចិត្តស្វាមី មាតាបិតា ហើយគោរពតាមឱវាទ

២៧. បរិភោគចំណីអាហារក្រោយមាតាបិតា និងស្វាមី

២៨. ឈប់បរិភោគមុនមាតាបិតា និងស្វាមី

២៩. ដេកលក់ក្រោយស្វាមី

៣០. ភ្ញាក់មុនស្វាមី

៣១. មានមេត្តាករុណា ចេះធ្វើបុណ្យទាន

បុរសស្ត្រីដែលប្រកបដោយលក្ខណៈគ្រប់ពេញលេញ ហៅថាប្រុសគ្រប់លក្ខណ៍ ស្រីគ្រប់លក្ខណ៍ ។ លក្ខណៈបុរសស្ត្រីគ្រប់លក្ខណ៍ដូចខាងលើនេះ បើតាមសម័យបច្ចុប្បន្ននេះ ឃើញថាមានលក្ខណៈខ្លះហួសសម័យទៅហើយ ។ ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ បើបុរសស្ត្រីណាប្រកបដោយលក្ខណៈដូចបានបរិយាយជាគោលៗក្នុងទីនេះ បុរសស្ត្រីនោះ គួររាប់ថាជាមនុស្សគ្រប់លក្ខណ៍បានដោយបរិបូណ៌ ។

ស្រាវជ្រាវដកស្រង់ដោយ

ព្រួច ភុម

## ឈើពុកកុំដាក់ត្នូធអខ្ទុយ

-----

**ឈើ** . បាក់រលំខ្ទេចមែកត្រួយ

**ពុក** . ផុយរលួយនៅដោយដី

**កុំ** . ដើរជាន់លេងធ្វើបែបប្ញី

**ដាក់** . នេះនោះអីសង្កត់វា ។

**ត្នូធ** . គង់ជំទែងជំទយលើ

**អខ្ទុយ** . ភ្លីភ្លើប្រយត្ន៎ពារ !

ប្រយត្ន៎ប៉ះខ្ទួយ ! គ្នូទគ្រាំគ្រា !

ពាក្យប្រៀបឃ្លោងឃ្លាគួរគិតចុះ !

ញ.ស.

# ចាស់ទុំរិលក្បុង

បទពាក្យ ៧

ទំនៀមទម្លាប់ប្រពៃណី ចារចែងអំពីច្បាប់សង្គម
ខ្មែរគ្រប់ជំនាន់តែងនិយម អប់រំធ្វើតាមលំអានចាស់ ។
សង្គមរម្យទមមានសណ្តាប់ ចាត់ទុកដូចច្បាប់យ៉ាងជាក់ច្បាស់
ជាក្រិតបន្ទាត់រំលឹកដាស់ មានចាស់ព្រឹទ្ធាចារ្យនាំផ្លូវ ។
ទំនាក់ទំនងស្រីនិងប្រុស ក្រមុំកំលោះជាទូទៅ
ធ្វើតាមលំអានបានត្រឹមត្រូវ ពុំមានអាស្រូវដល់កេរ្តិ៍ឈ្មោះ ។
ជូនតាចាស់ទុំអបអរក្រៃ ហើយវាយតម្លៃក្រៃខ្ពង់ខ្ពស់
អោយពរអោយជ័យផ្តល់កិត្តិយស អោយគេបានរស់មានសេរី ។
ប៉ុន្តែបើមានការបំពារ បំពានពាធាប្រពៃណី
លួចស្រឡាញ់គ្នាតាមព្រៃផ្សៃ រំលោភបំភ្លៃភ្នែកមេបា ។
ជួនកាលមានកូនពូនជាគភ៌ ពោះធំ (*) អធមិចាកសីលា
ញាតិមិត្តផៅពង្សបរិហារ គេថាក្រមុំលួចផើមព្រៃ ។
បើមានមនុស្សឈឺក្នុងគ្រួសារ គឺខ្មោចមេបាដែលរំពៃ
មើលឃើញកំហុសប្រពៃណី ហើយក៏លកលៃដាក់ទោសទណ្ឌ ។
ចាស់ទុំក្នុងផ្លូវពង្សវង្សា ជាញាតិកាពុំរួសរាន់
បណ្តោយអោយមានសាហាយស្មន់ ពាក់ព័ន្ធកេរ្តិ៍កោះរីងសៅហ្មង ។

---

(*) ផើម

ពីងគ្រូគន់គួររកប្រភព ជំងឺឧបទ្រពនេះជាម្តង
តើមានមូលហេតុពីអ្វីផង បំណងព្យាបាលរោគអោយជា ។
ឬកហាររអត្តៈដាក់ខែថ្ងៃ គន់គួរកែច្នៃឆ្នាំផ្សំគ្នា
លេខហោរាឆ្លើយតាមគណនា ថាគ្មានរោគាអ្វីបៀតបៀន ។
ទំនាយទាយថាខ្មោចចាស់ទុំ ខេខឹងក្តៅងំគុំឈ្លានពាន
ចាស់ស្រុកបណ្តោយញាតិព្រៀងលាន អោយមានវិបត្តិភ្លាត់សីលធម៌ ។
ថាក្មេងទៅចុះអត់ដឹងក្តី មិនយល់ពីអ្វីអាក្រក់ល្អ
ឃើញភ្លាមស្ទុះភ្លែតស្នេហ៍រីករវ ទាល់តែមានគភ៌ទើបភិតភ័យ ។
ចំណែកឯជនជាចាស់ស្រុក គួរមើលទុក្ខសុខក្មេងប្រុសស្រី
ពិនិត្យសង្កេតប្រក្រតី កុំបីប្រហែសអោយថ្លស់ការ ។
បើមានវិបត្តិភ្លាំងភ្លាត់ធ្លោយ ព្រោះហេតុបណ្តោយតាមយថា
នាំរឿងអាស្រូវដល់គ្រួសារ ទើបបានអាត្មាឈឺក្រៀមក្រំ ។
ទំនាយហោរាចារប្រាយប្រាប់ ត្រូវរៀបរណ្តាប់សែនចាស់ទុំ
ទើបជាសះស្បើយបានសុខុម តែត្រូវរៀបចំតាមតម្រា ។
កំឡោះក្រមុំដែលខុសឆ្គង ប្រព្រឹត្តកន្លងក្រឹត្យមេបា
លបលួចប្រព្រឹត្តអនាចារ ត្រូវសុំខមាទោសអប្រិយ ។
យាយតាចាស់ទុំនៅក្នុងភូមិ មូលមកជួបជុំទាំងប្រុសស្រី
ចូលរួមសែនព្រេនសុំអភ័យ លោះលោប្រណីពីដូនតា ។
ធ្វើម្តេចខុសម្តងឆ្គងមួយថ្ងៃ សូមលោកប្រណីអត់ទោសា
ថ្ងៃក្រោយរាងចាលលែងបំពារ លើក្រឹត្យគ្រួសារប្រពៃណី ។
ក្រមុំកំលោះសាមីជន ក្រួញក្រាបបន្ទន់ឱនសិរសី
លន់តួសារភាពអស់ទោសពៃរ៍ ចាសទុំប្រណីឈប់ប្រកាន់ ។

សូមលោកមេត្តាអោយពរជ័យ ដល់ប្រពន្ធប្តីដែលភពភ័ន្ត
ចាប់ដៃយកគ្នាប្តីប្រពន្ធ បានសុខនិរន្តរ៍វៀងតទៅ ។
ឯតាចាស់ស្រុកសូមស្រាកស្រាន្ត ទោសាប៉ុន្មានកុំសល់នៅ
ថ្ងៃក្រោយមិនធ្វេសអោយអាស្រូវ គ្រប់គ្រងកូនចៅអោយបានល្អ ។
សង្គមជាន់ចាស់អនុវត្ត តាមក្រិតបន្ទាត់ក្រមសីលធម៌
ជឿជាក់លើមាតាបវរ គឺទម្លាប់ល្អនៃសង្គម ។
មកដល់សម័យវិទ្យាសាស្ត្រ បរិយាកាសប្រាស់ប្រស់ព្រំ
វិវត្តិពីតូចឈានទៅធំ ផ្លាស់ប្តូរសង្គមអារម្មណ៍ថ្មី ។
គេប្រែនិយមសម្ភារៈ ជឿជាក់លើភពទំនើបថ្មី
ជឿថាលោកៈយើងសព្វថ្ងៃ បច្ចេកទេសថ្មៃអោយផ្លេកផ្លោះ ។
គំនិតនិយមហួសសម័យ ដើរបញ្ច្រាសន័យអ្វីទាំងអស់
ទស្សនៈចាស់នោតគេបង់បោះ មិនមានស្របសោះយុគសម័យ ។
កូនមិនស្តាប់ម៉ែមិនស្តាប់ឪ ចាស់ទុំប្រដៅឥតស្រស់ស្រាយ
ថាចាស់គំរិលគួរនឿយណាយ ដើរតាមសម័យគេមិនទាន់ ។
ក្រមុំកំលោះទាក់ទងគ្នា តាមដោយផ្លូវផ្កាប៉ានល្បុកលាន់
មិនខ្វល់ខ្លាចក្រែងមានពាក់ព័ន្ធ ឬខ្មាសអៀនអស់ជនត្រៀបត្រា ។
នេះហៅសីលធម៌ដាច់កន្លុះ ធម្មក្រឹត្យធ្លាយធ្លុះអស់អសារ
ដូចខ្លែងដាច់ខ្សែលើវេហាស៍ គ្មានខ្លាចអ្នកណាស្រេចទំនើង ។
ពេលណាស្នេហាដាច់ខ្សែប្រវ៉ាំង ស្នេហ៍ខ្លាំងស្នេហ៍ខ្លោចក្តៅជាងភ្លើង
ភ្លាំងភ្លាត់មានគភ៌យុវជនយើង អាងឡើងលេបថ្នាំចាក់ចងស្បូន ។
អាងវិទ្យាសាស្ត្រទំនើបក្រៃ អាងថ្នាំសម័យទប់គភ៌កូន
ទោះខូចទោះខិលក៏រួចខ្លួន ម៉ែឪតាដូនមិនដឹងដាន ។

សប្បាយតាមចិត្តគិតតាមចង់ ចាស់ទុំរិលក្បុងធ្វើមិនបាន
តើគាត់ដឹងអីបើគ្មានដាន បើផើមទើបបានចាប់ទោសា ។
ទោះបានរួចខ្លួនពីចាស់ទុំ សូមកុំត្រេកអរថាអស្ចារ្យ
អាចបំបិទភ្នែកនូវអស់អាថិ (១) ចង់ធ្វើយ៉ាងណាបានតាមចិត្ត ។
រោគអេដស៍ជាអ្នកចាំដាក់ទោស ផ្តល់នូវកំហុសជនទុច្ចរិត
ក្បត់ប្រពៃណីក្បត់ការពិត អេដស៍ចាំពិនិត្យកាត់ទោសា ។
ចាំមើលអស់អ្នកកើតរោគអេដស៍ តើអាងគ្រូពេទ្យវេជ្ជសាស្ត្រា (២)
រោគនេះតើគ្រូណាមើលជា ទោះពេទ្យសូត្រគាំក៏ចាញ់ដៃ ។
ចាស់ទុំជូនពាសូមកុំអន់ អាក់ចិត្តស្រពន់ហាប្ញទ័យ
ពួកអ្នកហាក់លោតហួសសម័យ គង់បរាជ័យយ៉ាងជាក់ច្បាស់ ។
វាជាជំងឺយុគសម័យ ប្រឡងប្រល័យវិទ្យាសាស្ត្រ
បង្អាប់បង្អាក់វិបល្លាស ផ្តួលវិទ្យាសាស្ត្រស្រឡះដៃ ។
ដូច្នេះគប្បីចេះយល់យោគ យកបុរាណបូកទំនើបថ្មី
បុរាណណាល្អគួរលេកលៃ កែច្នៃយកធ្វើជាគំរូ ។
សម័យលោតផ្លោះផ្លោងកោងកាច គួរខ្លាចកុំយកមកធ្វើគ្រូ
កុំរឹតបន្តឹងកុំបន្ធូរ គិតគូរយកតាមខ្សែកណ្តាល ។
ទម្លាប់ចាស់មានចរិតល្អ កែឆ្នៃបន្តអោយត្រូវកាល
ប្រតិបត្តិពង្រីកអោយដុះដាល តអង្វែងកាលវៀងទៅអីយ ។

**មៀច ប៉ុណ្ណ**

---

(១) អានថា : អា

(២) អានថា : វេជ-សាស្ត្រា

# អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៨

ថ្ងៃ ១០ – ១១ – ១២ កក្កដា ១៩៩៩



ក្នុងពិធីឡាយព្រះហស្តលេខាលើសង្ឃប្រកាសរួម ( ១២ - ០៧ - ៩៩)

( រូបថត ពុទ្ធសាសនបណ្ឌិត្យ )

នៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ១៩៩៩ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ ទូទាំងប្រទេសលើកទី ៨ ប្រចាំឆ្នាំថោះ ឯកស័ក ព.ស ២៥៤៣ បានប្រារព្ធឡើងក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសី និងក្រោមអធិបតីភាពនៃសម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ប្រធានព្រឹទ្ធសភា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ មហាសន្និបាតបាន

ប្រព្រឹត្តទៅយ៉ាងសុខក្សេមក្សាន្ត និងយ៉ាងមហោឡារិក នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ ។

បានយាង និមន្ត និងអញ្ជើញ ចូលរួមក្នុងឱកាសនោះ មាន :

- សម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- សម្តេចព្រះមហាថេរ - ព្រះមហាថេរ ទីរាជាគណៈ និងមន្ត្រីសង្ឃ ទីឋានានុក្រម ព្រះមេគណខេត្ត ក្រុង
- ឯកឧត្តមសមាជិកព្រឹទ្ធសភា ឯកឧត្តមអ្នកតំណាងរាស្ត្រ
- ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ ជាសមាជិករាជរដ្ឋាភិបាល
- ឯកឧត្តមអនុរដ្ឋលេខាធិការ និងទីប្រឹក្សា នៃក្រសួងធម្មការនិងសាសនា
- លោកប្រធាន លោកស្រីប្រធាន មន្ទីរធម្មការនិងសាសនាខេត្ត ក្រុង ។

ក្រៅពីនោះ គេឃើញព្រះសង្ឃ ពុទ្ធបរិស័ទ និងមន្ត្រីរាជការនៃក្រសួងធម្មការ និងក្រសួងនានា បាននិមន្ត អញ្ជើញចូលរួមយ៉ាងច្រើនកុះករ ។

នៅវេលាម៉ោង ៨ និង ៣០ នាទី សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ប្រធានព្រឹទ្ធសភា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានអញ្ជើញដល់កន្លែងប្រារព្ធពិធី ដោយមានឯកឧត្តម ជា សាវឿន ឯកឧត្តម ឈេន អៀម ឯកឧត្តម ស្រី វណ្ណផ្លង់ ឯកឧត្តម ដោក ណារិន ឯកឧត្តម ក្រូច សារី ឯកឧត្តម ហ្សាការិយា អាដាំម ឯកឧត្តម យី ធន់ និងមន្ត្រីរាជការក្រសួងធម្មការ មន្ត្រីរាជការក្រសួងនានា ជាច្រើនរូបទៀត ចាំទទួលស្វាគមន៍នៅជណ្តើររថយន្ត និងដោយមាននារីជូនកម្រងផ្កា និងភ្លេងត្រែទ័ព ប្រគំសំដែងវន្ទនកិច្ចជាកិត្តិយសផង ។

សម្តេចប្រមុខរដ្ឋស្តីទីបានអញ្ជើញឆ្លងកាត់ជួរមន្ត្រីរាជការ ដែលឈរអមផ្លូវជារបងកិត្តិយស រួចបង្ហួសចូលទៅកាន់សាលសន្និសីទ ឡើងលើវេទិកាកិត្តិយស ថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជទាំងពីរគណៈជាប្រធាន និងធ្វើ

គារវកិច្ចចំពោះភ្ញៀវកិត្តិយសជាតិ ដែលរួមមានមន្ត្រីរាជការ និងជូនជី ប្រមាណ ៥៥០ នាក់ ឈរទទួលស្វាគមន៍សម្តេច ។

បន្ទាប់ពីព្រះសង្ឃស្វាធ្យាយជយន្តោប្រសិទ្ធិពរចំពោះសម្តេចប្រមុខរដ្ឋស្តីទីរួចមក ពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ក៏បានចាប់ផ្តើមដោយគោរពទង់ជាតិ និងបទសរភញ្ញច្រៀង និងសូត្រដោយ និស្សិតសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ភ្នំពេញ ។ កម្មវិធីជាបន្តបន្ទាប់គឺ :

- សុន្ទរកថាស្វាគមន៍ របស់ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ចំពោះសម្តេចប្រមុខរដ្ឋស្តីទី និងថ្លែងនូវអំណរព្រះមហាករុណាទិគុណព្រមទាំងកតញ្ញូតាធម៌ ដ៏ជ្រាលជ្រៅចំពោះព្រះករុណាថ្លៃវិសេសទាំងពីរព្រះអង្គ ដែលទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន នូវទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារសហរដ្ឋអាមេរិក ឧបត្ថម្ភដំណើរប្រព្រឹត្តទៅនៃអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ព្រមទាំងបានថ្លែងបញ្ជាក់ពីគោលបំណង និងសញ្ញាជាវិជ្ជមានថ្មីៗ លេចឡើងទាក់ទងនឹងដំណើរប្រព្រឹត្តទៅ និងខ្លឹមសារនៃអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ នេះ ដែលមិនធ្លាប់មានពីមុន ( សូមអានសុន្ទរកថា ទំព័រ .... ) ។

- សុន្ទរកថាបើកមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ របស់សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រ ។ សម្តេចបានសំដែងក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈ នូវកតញ្ញូតាធម៌ ដ៏ខ្ពង់ខ្ពស់បំផុតថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងជូនក្រសួងធម្មការ និងសាសនា ដែលបានរៀបចំកម្មវិធីដ៏ឧត្តុង្គឧត្តមនេះឡើង ដើម្បីលើកតម្កើងព្រះពុទ្ធសាសនារបស់រដ្ឋយើង ព្រមជាមួយនឹងព្រះពរបវរមហាប្រសើរ សូមអោយអង្គ មហាសន្និបាតសំរេចការងារជោគជ័យត្រចះត្រចង់ តាមរបៀបវារៈ និងកម្មវិធីដែលបានគ្រោងទុក ។

បន្ទាប់ពីមានមតិផ្ដាំផ្ញើការងារដ៏មានសារសំខាន់មួយចំនួនពាក់ព័ន្ធទៅនឹងការប្រតិបត្តិពុទ្ធសាសនារួចមក សម្ដេច ជា ស៊ីម ប្រមុខរដ្ឋស្ដីទី បានផ្ដល់ថវិកាចំនួន ៣ លានរៀល ឧបត្ថម្ភដល់ដំណើរការងារមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ និងថ្វាយបង្គំលាព្រះសង្ឃ ដែលមានសម្ដេចព្រះសង្ឃរាជជាប្រធាន ជម្រាបលាភ្ញៀវទាំងអស់ អញ្ជើញត្រឡប់ទៅកាន់គេហដ្ឋានវិញ ដោយមានការជូនដំណើរដូចកាលសម្ដេចអញ្ជើញមកដល់ដែរ ។ ( សូមអានសុន្ទរកថានេះ នៅទំព័រ ...... ) ។

ពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ បានបញ្ចប់នៅវេលាម៉ោង ១០ និង ៣០ នាទី ក្នុងបរិយាកាសរីករាយ និងអធិកអធមក្រៃលែង ។

•

ចាប់ពីរសៀលថ្ងៃទី ១ និងថ្ងៃបន្តបន្ទាប់ សម័យប្រជុំពេញអង្គបានដំណើរការងាររបស់ខ្លួន នៅទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ក្រោមប្រធានបទនៃ « កិច្ចពង្រឹងការប្រតិបត្តិពុទ្ធសាសនា » ។

សម្ដេចព្រះសង្ឃរាជទាំងពីគណៈទ្រង់ជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ដោយមានមន្ត្រីសង្ឃគណៈមហានិកាយ ៥៧ អង្គ មន្ត្រីសង្ឃគណៈធម្មយុត្តិកនិកាយ ៣៨ អង្គ និងមន្ត្រីធម្មការ ៥៦ រូប និមន្ត អញ្ជើញមកពីខេត្ត-ក្រុងទាំង ២៤ ជាសមាជិកសមាជិកា នៅក្នុងសម័យប្រជុំពេញអង្គ ។

ក្នុងរសៀលថ្ងៃទី ១ នេះ ចាប់ពីម៉ោង ២:០០ ដល់ម៉ោង ៥:៣០ អង្គមហាសន្និបាត បានស្ដាប់ :

- សេចក្ដីថ្លែងយោបល់ របស់ឯកឧត្ដម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ស្ដីពី « ស្ថានភាពទូទៅនៃពុទ្ធសាសនា នៅកម្ពុជា » ។
- ព្រះយោបល់ណែនាំការពិភាក្សា របស់សម្ដេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ និងសម្ដេចព្រះសង្ឃរាជគណៈមហានិកាយ លើរបៀបវារៈទាំង ៤

ដែលជាកម្រងយុទ្ធវិធី នៃកិច្ចប្រតិបត្តិពុទ្ធសាសនា គឺ :

១. ការគោរពប្រតិបត្តិធម៌-វិន័យ និងអភិសមាចារ របស់ព្រះសង្ឃ និងពុទ្ធបរិស័ទ ។

២. ការគ្រប់គ្រងវត្តអារាម ធ្វើអោយវត្តអារាមនីមួយៗ មានដំណើរប្រ-ព្រឹត្តទៅល្អ, ត្រឹមត្រូវ ប្រាសចាកអធិករណ៍ ក្រោមការដឹកនាំដ៏មានប្រសិទ្ធភាព របស់លោកគ្រូចៅអធិការវត្ត ។

៣. ពង្រឹងគុណភាពពុទ្ធិកសិក្សា ដើម្បីអភិវឌ្ឍន៍ធនធានបព្វជិតពុទ្ធ-សាសនិក សំដៅលើកកំពស់កិត្យានុភាពព្រះភិក្ខុសង្ឃ និងជ្រោងទង់ព្រះធម៌ របស់ព្រះពុទ្ធបរមគ្រូ អោយតាំងនៅខ្ពស់ត្រដែត ជានិរន្តរ៍ !

៤. ពង្រឹង « អំណាចពុទ្ធចក្រ » គឺអំណាចរបស់មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ ( ថេរសភា ព្រះមេគណ ព្រះគ្រូអនុគណ លោកគ្រូចៅអធិការវត្ត ) ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនា, វត្តអារាម អោយបានរីកចំរើន ល្អលាស់ និងមានសណ្តាប់ធ្នាប់ល្អ ។

ថ្ងៃទី ១១-១២ កក្កដា ១៩៩៩

អង្គមហាសន្និបាតបានពិភាក្សាឬយោបល់យ៉ាងផុលផុស ដោយបានសំដែងមតិផ្ទាល់ខ្លួនទៅលើខ្លឹមសារនៃរបៀបវារៈ ព្រមទាំងបានវែកញែកបំភ្លឺ និងផ្តល់យោបល់បន្ថែមទៅលើការអនុវត្តន៍ជាក់ស្តែងផង ។

រីឯចំណុចពិភាក្សាទាំងឡាយក្នុងអង្គមហាសន្និបាត ដែលមន្ត្រីសង្ឃទាំងពីរគណៈបានព្រមព្រៀងគ្នាហើយ ក៏ត្រូវបានរៀបចំជាអត្ថបទសេចក្តីព្រាង « សង្ឃប្រកាសរួម » ដើម្បីដាក់ចេញជាគោលការណ៍ប្រតិបត្តិ និងសុំយោបល់អនុម័តពីអង្គមហាសន្និបាត ។

នៅថ្ងៃបញ្ចប់ អង្គមហាសន្និបាតស្តាប់ និងរួមយោបល់កែសម្រួលសេចក្តីព្រាងសង្ឃប្រកាសរួម ដែលមាន ៩ ចំណុច ចែងពីសេចក្តីសង្កេត និងសេចក្តីសន្និដ្ឋាន និង ៧ ចំណុច ចែងពីគោលការណ៍សំរាប់អនុវត្តជាក់ស្តែង ។

បន្ទាប់ពីបានពិភាក្សាប្តូរយោបល់អស់ពេលដ៏យូរមក, អង្គមហាសន្និបាតបានឯកភាពលើសេចក្តីព្រាងសង្ឃប្រកាសរួមនេះទាំងស្រុង ដោយគ្រាន់តែសុំអោយលុបពាក្យ « លើត្បូង » ក្នុងឃ្លា «... ព្រះករុណាជាម្ចាស់ជីវិតលើត្បូង » អោយនៅត្រឹមតែ « ... ព្រះករុណាជាអម្ចាស់ជីវិត » ព្រោះពាក្យថា « លើត្បូង » សំរាប់តែគ្រហស្ថនិយាយទៅកាន់ព្រះមហាក្សត្រ, សំរាប់ព្រះសង្ឃនិយាយទៅកាន់ព្រះមហាក្សត្រ ថា « ... ព្រះករុណាជាម្ចាស់ជីវិត » ប៉ុណ្ណោះ ។

បន្ទាប់ពីបានអានជាលើកទី ៣ សម្តេចព្រះសង្ឃរាជទាំងពីរគណៈបានឡាយព្រះហស្តលេខាលើអត្ថបទ « សង្ឃប្រកាសរួម » នេះ ទុកជាអត្ថបទផ្លូវការ ហើយផ្សព្វផ្សាយជាសាធារណៈ សំរាប់ព្រះសង្ឃទាំងពីរគណៈ និងពុទ្ធបរិស័ទប្រតិបត្តិតាម ដោយគ្មានការបែងចែកឡើយ ។

អង្គមហាសន្និបាតមន្ត្រីសង្ឃ បានស្វាធ្យាយមេត្តាធម៌ « *សព្វេ បុរត្ថិមាយ ...* » បិទការប្រជុំ នៅវេលា ម៉ោង ៩ និង ១៥ នាទី ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល ។

សេចក្តីសន្និដ្ឋាន

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី ៨ ប្រចាំឆ្នាំថោះ ព.ស ២៥៤៣ ដែលបានដំណើរការមមាញឹកអស់រយៈពេល ៣ ថ្ងៃ ពីថ្ងៃ ១០ ដល់ថ្ងៃ ១២ កក្កដា ១៩៩៩ បានប្រព្រឹត្តទៅក្នុងបរិយាកាសសាមគ្គីភាព និងភាតរៈភាពខ្ពស់ ហើយទទួលបានលទ្ធផលគួរអោយអបអរយ៉ាងក្រៃលែង ។ ឆ្លងតាមការ

ងាររបស់មហាសន្និបាត, សមាជិក សមាជិកា សុទ្ធតែបានតាមដានស្តាប់ដោយយកព្រះទ័យ យកចិត្តទុកដាក់កនូវការពិភាក្សា ដោយត្រិះរិះពិចារណាលើខ្លឹមសារនៃ រ. បៀបវារៈដែលបានកំណត់ ។ ក្នុងការពិភាក្សា អង្គមហាសន្និបាតបានឯកភាពគ្នាចំពោះគោលគំនិតធំៗរបស់ប្រធានបទ តែវានៅត្រង់ថាតើមន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ មានលក្ខណសម្បត្តិ និងលទ្ធភាពធ្វើបានប្រកបដោយប្រសិទ្ធភាពប៉ុនណា ។

អង្គមហាសន្និបាត បានចាត់ទុកសុន្ទរកថាបើកមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ របស់សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ជាព្រះរាជតំណាង ដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងសុន្ទរកថាស្វាគមន៍ និងសេចក្តីថ្លែងយោបល់របស់ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ថាជាប្រធានបទនាំមុខមួយយ៉ាងសំខាន់ បង្កើតបានស្មារតីឯកភាពព្រះសង្ឃពុទ្ធសាសនិកកម្ពុជា, ជាគំរូឯកភាពជាតិដ៏ត្រចះត្រចង់មួយរបស់ប្រទេសកម្ពុជា ឈានទៅបញ្ចប់សហស្សវត្សទី ២ ក្នុងប៉ុន្មានខែខាងមុខនេះ ។

អង្គមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ក្នុងរយះពេល ៣ ថ្ងៃ ពិតជាមានខ្វះត្រង់អន្លើខ្លះ ទាំងការរៀបចំ ទាំងផ្នែកបដិសណ្ឋារកិច្ច ប៉ុន្តែអ្វីដែលទទួលបានគឺអង្គមហាសន្និបាតបានប្រព្រឹត្តទៅដោយរៀបរយ និងទទួលបានលទ្ធផលល្អគួរអោយមានមោទនភាពណាស់ ។ នេះគឺជាលទ្ធផលនៃការយកព្រះទ័យទុកដាក់ របស់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងក្រសួងធម្មការ ដើម្បីធ្វើអោយព្រះសង្ឃ និងពុទ្ធ. បរិស័ទយល់ដឹងតួនាទីរបស់ខ្លួននៅក្នុងការប្រតិបត្តិធម៌-វិន័យ សំដៅធ្វើអោយព្រះពុទ្ធសាសនារក្សាបានតម្លៃខ្ពស់ខាងសីលធម៌ និងរក្សាបាននូវទីតាំងរបស់ខ្លួន ក្នុងសង្គម ក្នុងភាពបរិសុទ្ធត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និងអភិសមាចារ ព្រមទាំងប្រមូលបាននូវជំនឿ និងការឧបត្ថម្ភរបស់ប្រជារាស្ត្រចំពោះពុទ្ធសាសនា និងរក្សាបាននូវឋានៈជាសាសនារបស់រដ្ឋ តទៅ ។

ឌិម ខែម

# សុន្ទរកថាស្វាគមន៍ របស់

## ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## ក្នុងឱកាសបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៨

## ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ១៩៩៩

----------

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់,
- សូមនមស្ការ សម្តេចព្រះមហាថេរ និងព្រះថេរានុត្ថេរៈ ជាទីសក្ការៈ,
- សូមគោរព សម្តេចប្រមុខរដ្ឋស្តីទី ប្រធានព្រឹទ្ធសភា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង,
- សូមគោរព សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងពុទ្ធបរិស័ទជាទីមេត្រី,

ថ្ងៃនេះ ជាទិវានក្ខត្តឫក្ស ប្រកបដោយបរិយាកាសសុខក្សេមក្សាន្ត ដែលអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ប្រចាំឆ្នាំថោះ ឯកស័ក ព.ស ២៥៤៣ បានប្រារព្ធឡើងក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសី និងក្រោមអធិបតីភាពនៃសម្តេចប្រមុខរដ្ឋស្តីទី ប្រធានព្រឹទ្ធសភា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដោយមានការចូលរួមជាកិត្តិយសនៃភ្ញៀវជាតិ ដ៏កុះករ ។ វត្តមានដ៏ខ្ពង់ខ្ពស់ របស់សម្តេចព្រះរាជតំណាង របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងពុទ្ធបរិស័ទទាំងឡាយនៅក្នុងឱកាសនេះ មិនត្រឹមតែជាមហាកិត្តិយស ចំពោះពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃក្នុងថ្ងៃនេះប៉ុណ្ណោះទេ, តែវត្តមាននេះ ក៏ជាសក្ខីភាពបញ្ជាក់

នូវការគោរព និងសទ្ធាជ្រះថ្លា ចំពោះព្រះពុទ្ធសាសនារបស់ប្រជាជនកម្ពុជា ដែលបានប្រតិបត្តិតាមព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន អស់កាលដ៏យូរលង់មកហើយផងដែរ ។

ក្នុងនាមក្រសួងធម្មការ និងសាសនា ក្នុងនាមពុទ្ធសាសនិកខ្មែរទូទាំងប្រទេស និងក្នុងនាមផ្ទាល់ខ្លួន, ខ្ញុំព្រះករុណា ខ្ញុំបាទ សូមលំឱនកាយថ្វាយអំណរព្រះករុណាទិគុណ ព្រមទាំងកតញ្ញូតាធម៌ ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះករុណាថ្លៃវិសេសទាំងពីរព្រះអង្គ ដែលទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន នូវទឹកប្រាក់ចំនួន ១០.០០០ ដុល្លារសហរដ្ឋអាមេរិក ឧបត្ថម្ភដំណើរប្រព្រឹត្តទៅ នៃអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ នេះ ។

ការប្រារព្ធអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំនីមួយៗ គឺជាការបន្តប្រពៃណី ដ៏ល្អប្រសើរ របស់មន្ត្រីសង្ឃខ្មែរ តាំងពីសម័យបុរាណរៀងមក ។ មហាសន្និបាតមន្ត្រីសង្ឃឆ្នាំនេះ នឹងប្រព្រឹត្តទៅរយៈពេល ៣ ថ្ងៃ គឺថ្ងៃទី ១០ ថ្ងៃទី ១១ និងថ្ងៃទី ១២ កក្កដា ១៩៩៩ ដើម្បីពិនិត្យមើលលទ្ធផលនៃការអនុវត្តសេចក្តីសំរេច របស់ មហាសន្និបាតមន្ត្រីសង្ឃក្នុងឆ្នាំកន្លងទៅ និងពិភាក្សាប្តូរយោបល់លើការងារពុទ្ធសាសនា នាពេលបច្ចុប្បន្ន សំដៅ :

• លើកកំពស់ការគោរពប្រតិបត្តិធម៌-វិន័យ របស់ភិក្ខុសង្ឃ និងពុទ្ធបរិស័ទ អោយស្របតាមគោលការណ៍ នៃពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និងអភិសមាចារពុទ្ធសាសនា ;

• ពង្រឹងការគ្រប់គ្រងវត្តអារាម ធ្វើអោយវត្តអារាមនីមួយៗ មានដំណើរប្រព្រឹត្តទៅល្អ, ត្រឹមត្រូវ, ប្រាសចាកអធិករណ៍ ក្រោមការដឹកនាំដ៏មានប្រសិទ្ធភាពរបស់លោកគ្រូចៅអធិការ ;

• ពង្រឹងគុណភាពពុទ្ធិកសិក្សា ដើម្បីអភិវឌ្ឍធនធានបព្វជិតពុទ្ធសាសនិកសំដៅលើកកំពស់កិត្យានុភាពព្រះភិក្ខុសង្ឃ និងជ្រោងទង់ព្រះធម៌របស់ព្រះពុទ្ធបរម

ត្រូ អោយតាំងនៅខ្ពស់ត្រដែត ជានិរន្តរ៍ !

ជាការណ៍ពិតណាស់, ប្រជាជនកម្ពុជា ធ្លាប់បានទទួលពន្លឺព្រះធម៌របស់ព្រះពុទ្ធបរមគ្រូ តាំងពីឆ្នាំ ៣០៩ នៃគ្រិស្តសករាជ ។ ចាប់ពីពេលនោះមក ព្រះពុទ្ធ-សាសនា បានក្លាយជាស្នូលនៃវប្បធម៌របស់ប្រទេស និងបានទទួលការឧបត្ថម្ភគាំពារពីព្រះមហាក្សត្រ ពីរាជរដ្ឋាភិបាល និងពីប្រជាពលរដ្ឋទូទាំងប្រទេស ។ យ៉ាងណាមិញ, ព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គមិនគ្រាន់តែជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដ៏ឆ្នើមមួយអង្គប៉ុណ្ណោះទេ, ប៉ុន្តែព្រះអង្គទ្រង់បានសាងព្រះផ្នួសក្នុងព្រះពុទ្ធសាសនា ហើយទ្រង់បានព្រះរាជានុញ្ញាតអោយព្រះរាជបុត្រ និងប្រជារាស្ត្រជាកូនចៅព្រះអង្គសាងផ្នួសទ្រទ្រង់ពុទ្ធសាសនាតាមសទ្ធាជ្រះថ្លារៀងៗខ្លួន ថែមទៀត ។ ព្រះពុទ្ធសាសនា ត្រូវបានចារឹកទុកក្នុងរដ្ឋធម្មនុញ្ញថាជាសាសនារបស់រដ្ឋ ។ ប្រជារាស្ត្របានយកសាសនាព្រះពុទ្ធជាទីពឹងជាប្រទីបបំភ្លឺផ្លូវដើរក្នុងជីវិតរបស់ខ្លួន និងធ្វើជាមូលដ្ឋាននៃការស្តាបនាមាតុប្រទេសឆ្ពោះទៅរកសន្តិភាព យុត្តិធម៌ និងសន្តោសអធ្យាស្រ័យគ្នា ។ នៅក្នុងបាវចនា របស់ព្រះរាជាណាចក្រកម្ពុជា ពុទ្ធសាសនាជាប្រធានពាក្យមួយដ៏សំខាន់ ក្នុងចំណោមបា-វ-ចនាទាំងបី គឺ ជាតិ សាសនា ព្រះមហាក្សត្រ ។ ដូចនេះ ព្រះពុទ្ធសាសនា បានក្លាយជាត្រីវិស័យដឹកនាំប្រជាជាតិខ្មែរយើងឆ្ពោះទៅរកសេចក្តីសុខ និងសេចក្តីថ្លៃថ្នូរ, ហើយពលរដ្ឋខ្មែរបានប្រកាន់យកព្រះពុទ្ធសាសនា ជាមាគ៌ានៃជីវភាពរស់នៅរបស់ខ្លួនតរៀងមក ។ ហេតុនេះ, តួនាទីសំខាន់របស់ពុទ្ធសាសនានៅកម្ពុជា ស្តែងចេញតាមតួនាទីរបស់វត្តអារាម, តួនាទីរបស់ព្រះសង្ឃ និងតួនាទីអប់រំសីលធម៌ មិនអាចខ្វះមួយណាបានឡើយ ។ គឺនៅក្នុងបរិបទនេះហើយ ដែលមហាសន្និបាតប្រចាំឆ្នាំ ជាប្រពៃណីរបស់មន្ត្រីសង្ឃ ត្រូវបានរៀបចំឡើង ។

នៅក្នុងឆ្នាំនេះ, មានសញ្ញាជរិជ្ជមានថ្មីៗបានលេចឡើង ទាក់ទងនឹង

ដំណើរប្រព្រឹត្តទៅ និងខ្លឹមសារនៃអនុសំវច្ឆរមហាសន្និបាត ។ នោះគឺជាព្រះគំនិតផ្តួចផ្តើមរបស់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ដែលបានសំរេចជាឯកច្ឆ័ន្ទ យកទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ធ្វើជាទីប្រជុំរបស់មន្ត្រីសង្ឃទាំងពីរគណៈ ក្នុងអំឡុងពេល ៣ ថ្ងៃ ក្រោមព្រះរាជាធិបតីភាពរួមរបស់សម្តេចព្រះសង្ឃ-រាជទាំងពីរព្រះអង្គ ។ ប្រធានបទពិភាក្សានៅក្នុងអង្គមហាសន្និបាត នឹងត្រូវបានសម្តេចព្រះសង្ឃរាជទាំងពីរគណៈលើកឡើង និងណែនាំការពិភាក្សា ទាក់ទងនឹងការប្រតិបត្តិធម៌-វិន័យ និងអភិសមាចាររបស់បព្វជិត និងពុទ្ធបរិស័ទ, ការគ្រប់គ្រងវត្តអារាម, និងការលើកកំពស់គុណភាពពុទ្ធិកសិក្សា, ធម្មវិន័យ, និងវិបស្សនាធុរៈ ផងដែរ ។ ចំណុចពិភាក្សាទាំងឡាយក្នុងអង្គមហាសន្និបាត ដែលមន្ត្រីសង្ឃទាំងពីរគណៈបានព្រមព្រៀងគ្នាហើយ ដើម្បីដាក់ចេញជាគោលការណ៍ប្រតិបត្តិ នឹងត្រូវបានរៀបចំជាអត្ថបទសង្ឃប្រកាស ចុះព្រះហស្តលេខាដោយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ហើយផ្សព្វផ្សាយជាសាធារណៈ សំរាប់ព្រះសង្ឃទាំងពីរគណៈ និងពុទ្ធបរិស័ទប្រតិបត្តិតាម ដោយគ្មានការបែងចែកឡើយ ។ សកម្មភាពទាំងអស់នេះ គឺសំដៅពង្រឹង និងពង្រីកសមធម៌, សាមគ្គីធម៌, ឯកត្តធម៌ និងការយោគយល់ទូលំទូលាយក្នុងបណ្តាព្រះសង្ឃពុទ្ធសាសនិកកម្ពុជាទាំងមូល ។

ជាការច្បាស់ណាស់, ព្រះធម៌របស់ព្រះពុទ្ធ មិនជាប់ជំពាក់ដោយវប្បធម៌ដោយសង្គមមនុស្សពិសេសណាមួយ ឬដោយពូជជាតិមនុស្ស ឬក៏ក្រុមជាតិមនុស្សណាមួយទេ ។ ព្រះធម៌របស់ព្រះពុទ្ធ មានរសជាតិតែមួយ គឺ *វិមុត្តិរស* ប្រៀបដូចជាទឹកហូរចេញមកពីប្រភពផ្សេងៗ ហើយហូរចាក់ទៅក្នុងសមុទ្រ ដែលមានរសជាតិតែមួយគឺ *រសជាតិប្រៃ* នោះឯង ។ នៅក្នុងស្មារតីនេះ និងចាប់ពីពេលនេះតទៅឯកភាពព្រះសង្ឃពុទ្ធសាសនិក ក៏ដូចជាឯកភាពជាតិរបស់មាតុភូមិកម្ពុជា នឹងកាន់តែបានពង្រឹង ហើយឈានទៅកាន់កិត្តិយសល្បីល្បាញ, សេចក្តីថ្លៃថ្នូរ និងភាពសម្បូរ

សប្បាយនៃសម័យកាលមហានគរ ដ៏រុងរឿងឡើងវិញ ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្វាយព្រះពរ បវរមហាប្រសើរ ចំពោះសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ សម្តេចព្រះមហាថេរ និងព្រះថេរា-នុត្ថេរៈគ្រប់ព្រះអង្គ,

សូមជូនពរ បវរមហាជោគជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ចំពោះសម្តេចប្រមុខរដ្ឋស្តីទី ប្រធានព្រឹទ្ធសភា ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង,

សូមជូនពរ បវរសួស្តី ចំពោះសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងពុទ្ធបរិស័ទទាំងអស់ សូមបានប្រកបដោយពរទាំង ៥ ប្រការ : អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ !

ចុងក្រោយបង្អស់ ហើយដែលមានសារសំខាន់បំផុត, ខ្ញុំព្រះករុណា ខ្ញុំបាទ សូមឧទ្ទិសព្រះរាជកុសលមហាប្រសើរ ថ្វាយចំពោះព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមសីហនុ និងសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ សូមព្រះអង្គបានប្រកបដោយព្រះពលានុភាពខ្លាំងក្លា ព្រះសុខុមាលភាពដ៏ល្អគ្រប់យ៉ាង និងព្រះជន្មាយុយឺនយូរ អស់កាលជាអង្វែងតទៅ !

សូមអរគុណ,

សូមអរព្រះគុណ,

# សុន្ទរកថា

## សម្តេច **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី

## និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រ

## ក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី ៨

## នាថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៩




សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទី ថ្លែងសុន្ទរកថាបើកមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨

( រូបថត ពុទ្ធសាសនបណ្ឌិត្យ )

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់,
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ ជាទីមេត្រី,

- អស់លោក លោកស្រី ជាពុទ្ធបរិស័ទ ព្រមទាំងបងប្អូនជនរួមជាតិ ជាទីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសដ៏វិសេសវិសាល នៃពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី ៨ នេះ ជាដំបូងបង្អស់ ខ្ញុំព្រះករុណា ខ្ញុំ ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈ សូមសំដែងនូវកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ថ្វាយសម្តេចសង្ឃរាជទាំងពីរគណៈ និងជូនក្រសួងធម្មការ និងសាសនា ដែលបានរៀបចំកម្មវិធីដ៏ឧត្តុង្គឧត្តមនេះឡើង ដើម្បីលើកតម្កើងព្រះពុទ្ធសាសនារបស់រដ្ឋយើង អោយបានស្ថិតស្ថេរគង់វង្សជារៀងរហូត តទៅ ។

ខ្ញុំព្រះករុណា ខ្ញុំ សូមនាំមកថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណៈនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈ ដែលទ្រង់សព្វព្រះរាជហឫទ័យប្រទានថ្វាយថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមជាមួយនឹងព្រះពរបវរមហាប្រសើរ សូមអោយអង្គមហាសន្និបាតសំរេចបានជោគជ័យដ៏ល្អត្រចះត្រចង់ តាមរបៀបវារៈ និងកម្មវិធី ដែលបានគ្រោងទុក ។

ក៏ដូចជាប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស ដែលជាពុទ្ធសាសនិកជន ខ្ញុំព្រះករុណា ខ្ញុំ មានក្តីសោមនស្សរីករាយស្វាគមន៍ចំពោះអង្គសន្និបាត និងមានជំនឿមុតមាំថា ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ នឹងយកព្រះទ័យទុកដាក់ដ៏ខ្ពង់ខ្ពស់ ដើម្បីដោះស្រាយបញ្ហាផងទាំងឡាយ ដែលជាឧបសគ្គរាំងដល់ដំណើរជាប្រក្រតី នៃព្រះពុទ្ធ-សាសនានៅពេលបច្ចុប្បន្ន និងរកវិធីដ៏សក្តិសិទ្ធិ សំដៅទ្រទ្រង់ទៅមុខនៃព្រះពុទ្ធ-សាសនារបស់យើងតទៅអនាគតផង ។

ដូចឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា បានថ្លែងមុននេះស្រាប់

តាំងពីបុរាណកាលរៀងមក ព្រះពុទ្ធសាសនាបានដើរតួនាទីជាប្រវត្តិសាស្ត្រ ដោយបានរួមចំណែកដល់ភាពថ្កុំថ្កើងរុងរឿង និងកិត្យានុភាពនៃមាតុភូមិអង្គរ ដោយបានថែរក្សាលើកតម្កើងអត្តសញ្ញាណជាតិកម្ពុជា ភាសា អក្សរសាស្ត្រ វប្បធម៌ សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរដ៏ល្អបវរ ព្រមទាំងបង្ហាញផ្លូវរស់នៅដ៏សុខសាន្តដល់ខេមរជនគ្រប់រូប អោយដើរឆ្ពោះទៅកាន់សន្តិភាព វិបុលភាព និងសុភមង្គល ដោយចៀសវាងអំពើហឹង្សា អកុសលកម្ម បាបកម្មផងទាំងឡាយ ។

ក្នុងដំណើរវែងឆ្ងាយបត់បែនក្នុងប្រវត្តិសាស្ត្រជាតិយើង ទីវត្តអារាម ព្រះសង្ឃ គម្ពីរដីកា ក្បួនច្បាប់ និងពុទ្ធសាសនិកជន បានស្មោះស្ម័គ្របូជាផ្តាច់ទ្រទ្រង់ព្រះពុទ្ធសាសនាអោយបានរីកចំរើន សមស្របនឹងតថភាពសង្គមជាតិ ហើយមានដំណើរទៅមុខ ទន្ទឹមគ្នានឹងការអភិវឌ្ឍន៍ប្រទេសជាតិ ។ ទាំងនេះបានបង្កើតឡើងនូវមោទនភាព និងមានឥទ្ធិពលស៊ីជម្រៅជ្រួតជ្រាបក្នុងដួងចិត្តជនកម្ពុជាគ្រប់រូបគ្រប់ ស្រទាប់វណ្ណៈ គ្រប់ទិសទី រហូតដល់មានការទទួលស្គាល់ជាផ្លូវការជាសាសនារបស់រដ្ឋ ។

នាដំណាក់កាលបច្ចុប្បន្ននេះ ព្រះពុទ្ធសាសនាដែលស្ទើរតែផុតរលត់សូន្យសុង ក្នុងកំឡុងឆ្នាំ ១៩៧៥ - ១៩៧៩ បានរីកចំរើនឡើងវិញក្នុងសន្ទុះថ្មី ដោយបានទទួលការឧបត្ថម្ភពីពុទ្ធសាសនិកជនដ៏សប្បុរស ទាំងក្នុង និងក្រៅប្រទេស ។

ជាការពិតហើយ ជាមួយនឹងការរីកចំរើននេះ បញ្ហាថ្មីៗបានកើតឡើងដែលទាមទារនូវការដោះស្រាយមួយដ៏សមហេតុផល ។

ខ្ញុំព្រះករុណា ខ្ញុំ សូមរួមចំណែកទាក់ទាញអារម្មណ៍អង្គសន្និបាត អោយចាប់អារម្មណ៍អំពីតួនាទីព្រះពុទ្ធសាសនានៅក្នុងសង្គម តាមរយៈតួនាទីរបស់វត្តអារាម ព្រះសង្ឃ និងការអប់រំ ឃោសនាផ្សព្វផ្សាយអំពីព្រះធម៌ ពុទ្ធឱវាទ សីលធម៌ ចរិយាធម៌ ដើម្បីបង្កើនជំនឿទុកចិត្តរបស់ពុទ្ធសាសនិកជនទៅលើព្រះពុទ្ធសាសនា និងតម្រង់ទិសសង្គម និងយុវវ័យជំនាន់ក្រោយអោយបន្តគោរពចំពោះព្រះធម៌របស់ព្រះ

សម្មាសម្ពុទ្ធនៃយើង ។ ដើម្បីសំរេចការងារនេះ ទាមទារនូវការពង្រឹងឡើងវិញ នូវប្រព័ន្ធពុទ្ធិកសិក្សាអោយបានសុក្រឹត្យត្រឹមត្រូវ និងមានគុណភាពពិតប្រាកដ ព្រមជាមួយនឹងការបង្កើនសមត្ថភាពរបស់ពុទ្ធសាសនបណ្ឌិត្យក្នុងការបោះពុម្ព ចងក្រងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវគម្ពីរដីកា ក្បួនច្បាប់ និងឯកសារផ្សេងៗទៀត ។

សំខាន់ជាងគេមុនអ្វីៗទាំងអស់ គឺត្រូវកសាងអោយបាននូវសាមគ្គីភាពក្នុងជួរពុទ្ធសាសនិកជន ជាពិសេស ក្នុងជួរព្រះសង្ឃទាំងពីរគណៈ ដែលត្រូវដើរតួជាគំរូដល់ប្រជារាស្ត្រយើង ។ ព្រះសង្ឃត្រូវដើរនាទីអោយបានសមស្របទៅនឹងការលើកតម្កើងតួនាទីដ៏ខ្ពង់ខ្ពស់ជាសាសនារបស់រដ្ឋ ។ ការប្រកាន់និកាយធម្មយុត្តិ ឬមហានិកាយ គឺចំណុះលើជំនឿរបស់ពុទ្ធសាសនិកជន ។ សាមគ្គីភាពនៃនិកាយទាំងពីរ គឺជាសរសរទ្រូងនៃភាពគង់វង្សរុងរឿង រីកចំរើនរបស់ព្រះពុទ្ធសាសនា ។

អាស្រ័យដោយលទ្ធភាពរបស់រដ្ឋយើងនៅមានកំណត់ ហើយជីវភាពប្រជាពលរដ្ឋយើងនៅជនបទ ក៏នៅជួបការលំបាកជាច្រើនប្រការ ខ្ញុំព្រះករុណា ខ្ញុំសូមអំពាវនាវដល់ព្រះតេជព្រះគុណព្រះមេគណ ព្រះគ្រូអនុគណ ព្រះគ្រូចៅអធិការគ្រប់វត្ត សូមមេត្តាយកព្រះទ័យទុកដាក់បន្តទៀត ចំពោះការកសាងសមិទ្ធផលជាប្រយោជន៍សាធារណៈ ដែលមិនផ្ទុយនឹងគន្លងនៃព្រះពុទ្ធសាសនា ដូចជាការកសាងផ្លូវថ្នល់ ជីស្រះ ប្រឡាយទឹក . ល . រួមជាមួយនោះ សូមព្រះមេត្តាបន្តផ្តល់ការគាំទ្រដល់ការងារមនុស្សធម៌ និងសង្គមកិច្ច ដូចជាទំនុកបំរុងដល់ចាស់ព្រឹទ្ធាចារ្យគ្មានកូនចៅថែទាំ កុមារកំព្រា និងប្រជារាស្ត្រជួបគ្រោះភ័យដោយប្រការផ្សេងៗ ។

កិច្ចការទាំងនេះ ទោះធំឬតូច, ច្រើនឬតិចក្តី សុទ្ធតែមានឥទ្ធិពលចូលជ្រៅក្នុងជីវភាពសង្គម ដែលញាំងអោយតួនាទីនៃព្រះពុទ្ធសាសនា កាន់តែរីកចំរើនរឹងមាំទៅអនាគត ។

សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទី

គោរពសក្ការៈ,

ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាទីគោរពស្នេហា,

ក្រោមពន្លឺនៃព្រះពុទ្ធសាសនា ប្រជារាស្ត្រកម្ពុជាយើងនឹងបន្តឈានជើងចូលសតវត្សទី ២១ ។ អ្វីដែលតួនាទីសំខាន់សំរាប់ពេលបច្ចុប្បន្ន និងអនាគតរបស់កម្ពុជាគឺ សុខសន្តិភាព ស្ថិរភាព អហិង្សា ភាពសុខដុមរមនាក្នុងស្មារតីបង្រួបបង្រួមសាមគ្គី ឯកភាពជាតិ ប្រកបដោយក្តីស្រឡាញ់រាប់អានគ្នា មានភាពអត់ឱន យោគយល់ សន្តោសប្រណីគ្នាក្នុងមេត្តាធម៌ យុត្តិធម៌ សច្ចធម៌ ដើម្បីឈោងចាប់វឌ្ឍនភាព ភាពរុងរឿងថ្កើងថ្កានឡើងវិញ មានកិត្តិយសឋានៈស្មើមុខស្មើមាត់នឹងប្រទេសនានាក្នុងសហគមន៍ប្រជាធិបតេយ្យអន្តរជាតិ ។

បទពិសោធន៍ និងវិចារណញ្ញាណ បានបង្ហាញអោយឃើញថា យើងនឹងរកផ្លូវសុខសាន្តមួយ ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ លុះណាតែយើងទាំងអស់គ្នាស្រុះចិត្តមូលគំនិតយកព្រះធម៌ជាផ្លូវសំរាប់អប់រំកាយចិត្ត ស្មារតី ដើម្បីជម្រុះចោលនូវគំនុំការច្រណែននិន្ទា និងការសងសឹកគ្នាតាមមធ្យោបាយហឹង្សា ។

ជាការពិតណាស់ សង្គ្រាមប្រហូសរ៉ាយគ្នាដោយអាវុធជាង ៣ ទសវត្សបានរលត់ផុតទៅហើយ ។ តែស្មារតីហឹង្សានិយមពុំទាន់ផុតរលត់នៅឡើយទេ អាស្រ័យស្រមោលនៃអតីតកាលបានចាក់ជ្រៅនៅក្នុងសង្គមជាតិយើង ។ ដូច្នេះ គោងតែយើងទាំងអស់គ្នា ខិតខំសំអាតកាយចិត្តស្មារតីទាំងអស់គ្នា សម្រួចយកព្រះធម៌នៃព្រះសម្មាសម្ពុទ្ធជាមនោគមវិជ្ជាជាតិ ដើម្បីកប់អោយជ្រៅនូវភាពសៅហ្មងពីអតីតកាល ហើយប្រមូលផ្តុំកម្លាំងជាតិដើរឆ្ពោះទៅមុខតាមគន្លងនៃលទ្ធិប្រជាធិប-តេយ្យពិតប្រាកដ តាមគោលការណ៍នៃនីតិរដ្ឋ ។

ទាំងនេះជាកិច្ចការដ៏ធំមួយ ដែលខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមព្រះមេត្តារួមព្រះវិភាគទានរៀងៗខ្លួន ដើម្បីណែនាំ

រំលឹកដាស់តឿនដល់ឧបាសក ឧបាសិកា និងពុទ្ធសាសនិកជន តាមព្រះធម្មទេសនា ឬតាមពិធីផ្សេងៗ នៅគ្រប់ទីកន្លែងជាប្រចាំ សំដៅបង្កើតឡើងនូវបរិយាកាសថ្មីប្រកបដោយជំនឿទុកចិត្តគ្នាទៅវិញទៅមកក្នុងសង្គមជាតិយើង ។ ធ្វើបែបនេះ ព្រះសង្ឃ និងទីវត្តអារាម នឹងរួមចំណែកជាកម្លាំងធានាសំរាប់ស្ថិរភាពសង្គម អោយបានសុខដុមរមនា និងចំរុងចំរើនជានិច្ចនិរន្តរ៍តរៀងទៅ ។

ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវដល់ហាក៏ម ទូន និងឥស្លាមសាសនិក ព្រមទាំងសាសនិកនៃសាសនាផ្សេងៗទៀត សូមមេត្តាចូលរួមបំពេញកិច្ចការជាកុសល ជាគុណប្រយោជន៍ដល់ការពង្រឹងសន្តិភាព ស្ថិរភាព ការបង្រួបបង្រួមផ្សះផ្សាជាតិ ការកសាងប្រទេសជាតិ និងការបន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រ ដែលជាភាគធំនៅជួបប្រទះការលំបាកក្នុងជីវភាពប្រចាំថ្ងៃ និងក្នុងជីវិតរស់នៅ ។

ខ្ញុំព្រះករុណា ខ្ញុំ សូមប្រសិទ្ធពរបវរមហាប្រសើរ ថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជូនឯកឧត្តម លោកជំទាវ លោកស្រី ភ្ញៀវកិត្តិយសជាតិ និងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយព្រះពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ប្រកបដោយក្តីសុទិដ្ឋិនិយម ចំពោះលទ្ធផលដ៏ល្អប្រពៃនៃអង្គមហាសន្និបាត ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ខ្ញុំព្រះករុណា ខ្ញុំ សូមប្រកាសបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី ៨ ចាប់ពីពេលនេះតទៅ ។

សូមអរព្រះគុណ - អរគុណ

# សេចក្ដីថ្លែងយោបល់ របស់
## ឯកឧត្ដម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
# ក្នុងមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៨
## នាសម័យប្រជុំពេញអង្គ នៅទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
## ថ្ងៃទី ១០-១១-១២ ខែកក្កដា ឆ្នាំ ១៩៩៩



សេចក្ដីថ្លែងយោបល់របស់ឯកឧត្ដម ជា សាវឿន ស្ដីពីស្ថានភាពពុទ្ធសាសនា
( រូបថត ពុទ្ធសាសនបណ្ឌិត្យ )

- សូមក្រាបបង្គំថ្វាយបង្គំ សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ជាទីគោរពសក្ការៈ,
- សូមនមស្ការ សម្ដេចព្រះមហាថេរ និងព្រះអង្គមេគណខេត្ត-ក្រុង ជាទីគោរព,
- សូមគោរពអស់លោក និងលោកស្រីជាប្រធានមន្ទីរធម្មការខេត្ត-ក្រុង ជាទីមេត្រី,

មហាសន្និបាតមន្ត្រីសង្ឃឆ្នាំនេះ បានផ្ដល់មហាកិត្តិយសដ៏ត្រកាលមួយ

ចំពោះក្រសួងធម្មការ និងសាសនា ដោយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ទ្រង់មានព្រះតម្រិះផ្តួចផ្តើម និងអនុម័តជាឯកច្ឆ័ន្ទ យកទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ធ្វើជាកន្លែងប្រជុំរួមពេញអង្គរបស់មន្ត្រីសង្ឃទាំងពីរគណៈ ដើម្បីពិភាក្សាដោះស្រាយការងារព្រះពុទ្ធសាសនា ។ ខ្ញុំព្រះករុណា-ខ្ញុំ សូមកោតសរសើរដោយស្មោះ ចំពោះព្រះតម្រិះផ្តួចផ្តើមដ៏មានអត្ថន័យបំផុតនេះ ពីព្រោះថា មហាសន្និបាតមន្ត្រីសង្ឃ រួមគណៈសង្ឃទាំងពីរដូចនេះ មិនធ្លាប់ដែលមានពីមុនមកទេ ហើយការប្រជុំរួមរបស់គណៈសង្ឃទាំងពីរ នាពេលនេះ គឺជានិមិត្តសញ្ញានៃការទទួលខុសត្រូវរួមរបស់សង្ឃ និងការកើតមានឯកភាពសង្ឃមួយដ៏រឹងមាំ ឋិតថេរ ឈានទៅធានាឯកភាពជាតិកម្ពុជាមួយ ជាអមតៈនាដើមសហស្សវត្សទីពីរ ដោយជោគជ័យ ។

ខ្ញុំព្រះករុណា-ខ្ញុំ មិនលើកបញ្ហានយោបាយ ស្តីពីឯកភាពជាតិ មកអធិប្បាយក្នុងឱកាសនេះទេ, ប៉ុន្តែ ខ្ញុំព្រលករុណា-ខ្ញុំ គ្រាន់តែសូមសេចក្តីអនុញ្ញាតគូសបញ្ជាក់យ៉ាងខ្លីថា ព្រះតម្រិះរបស់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ សំរេចអោយមានមហាសន្និបាតមន្ត្រីសង្ឃរួមទាំងពីរគណៈ គឺជាឧទាហរណ៍ ដ៏លេចធ្លោបំផុត, ជាគំរូឯកភាពមួយ ធានានូវនិរន្តរភាពព្រះពុទ្ធសាសនា នៅក្នុងប្រទេសកម្ពុជា, ក៏ដូចអត្ថិភាពគង់វង្សនៃប្រទេសកម្ពុជា ដូច្នោះដែរ ។

ក្នុងឋានៈជាពុទ្ធសាសនិកមួយរូប, ខ្ញុំព្រះករុណា-ខ្ញុំ មានជំនឿមុតមាំថា អត្ថិភាពគង់វង្សរបស់ពុទ្ធសាសនាក្តី, របស់ប្រទេសជាតិក្តី គឺពុទ្ធសាសនិកជនកម្ពុជា និងប្រជាពលរដ្ឋកម្ពុជា ជាអ្នកទទួលខុសត្រូវចាត់ចែងវាសនាអោយពុទ្ធសាសនា និងប្រទេសជាតិរបស់ខ្លួន ដោយខ្លួនឯង ។ ពីព្រោះព្រះពុទ្ធបរមគ្រូបានប្រែតប្រដៅដូច្នេះថា « ខនឯងគឺជាទីជម្រក ឬជាទីពឹងរបស់ខ្លួនឯង, គ្មានបុគ្គលណាផ្សេងអាចជាទីជម្រក ឬជាទីពឹងរបស់ខ្លួនកើតទេ » ។ ព្រះពុទ្ធអង្គបានទូន្មានអោយបុគ្គលម្នាក់ៗចេះអភិវឌ្ឍខ្លួនដោយខ្លួនឯង ហើយសំរេចការរំដោះខ្លួនដោយខ្លួនឯង ពីព្រោះ មនុស្ស

មានអំណាចរំដោះខ្លួនឯង អោយផុតពីចំណងគ្រប់យ៉ាង តាមរយៈសេចក្តីព្យាយាម និងប្រាជ្ញាផ្ទាល់ខ្លួន ។

នៅក្នុងបរិបទនេះ, ខ្ញុំព្រះករុណា-ខ្ញុំ សូមចាត់ទុកមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ នេះ ថាជាការជួបប្រជុំពិសេសមួយ តម្រូវអោយអង្គមហាសន្និបាតទាំមូលផ្តោតអារម្មណ៍ទៅលើការប្រតិបត្តិពុទ្ធសាសនារបស់យើង ដែលកំពុងឆ្លងកាត់ពាក្យរិះគន់ជាច្រើនប្រការ ថាខ្វះការដឹកនាំ និងថែទាំល្អ ប្រៀបបានទៅនឹង *«សន្ទូងដុះរីកល្អតលាស់ក្នុងស្រែ ខ្វះការថែទាំ»* ដូច្នោះ ។ នេះជាបញ្ហាមួយមានសារសំខាន់ សំរាប់ការរីកចំរើន និងការរស់រានមានជីវិត នៃពុទ្ធសាសនាយើង តទៅមុខទៀត ។

ដោយហេតុនេះ ប្រធានបទ ឬកម្មវត្ថុ នៃការពិភាក្សាផ្លាស់ប្តូរយោបល់របស់សម្តេចព្រះមហាថេរ និងព្រះមេគណខេត្ត-ក្រុង នៅក្នុងមហាសន្និបាតមន្ត្រីសង្ឃនេះអាចនឹងតម្រង់ទិស សំដៅ :

* ធ្វើអោយពុទ្ធសាសនា រក្សាបាននូវតម្លៃខាងសីលធម៌, តម្លៃខាងស្មារតី និងទីតាំងរបស់ខ្លួនក្នុងឋានៈជាកម្លាំងចលករដល់ការអភិវឌ្ឍន៍សង្គម និងបញ្ញាស្មារតី ដែលមិនផ្ទុយពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ដើម្បីជាគុណប្រយោជន៍ដល់សហគមន៍ និងដល់សង្គមជាតិកម្ពុជាទាំងមូល ។

* ធ្វើអោយពុទ្ធសាសនា ប្រមូលបាននូវជំនឿ និងការឧបត្ថម្ភរបស់ពុទ្ធ-បរិស័ទ និងរក្សាបាននូវឋានៈជាសាសនារបស់រដ្ឋតទៅ ។

សម្តេចជាអម្ចាស់ ព្រះករុណាគ្រប់ព្រះអង្គ និងអស់លោក លោកស្រីបានជ្រាប និងបានដឹងហើយថា មានផលផនបាកបន្សល់ទុកប៉ុនណា នៅក្នុងសង្គមជាតិយើង ក្រោយប្រទេសជាតិបានចេញផុតពីសង្គ្រាមបំផ្លិចបំផ្លាញជាងពីរទស្សវត្សកន្លងទៅ ។ គេបានបានកត់សំគាល់ឃើញថា :

គ. ស្ថានភាពសេដ្ឋកិច្ច សង្គម ពិតមែនមានការប្រឹងប្រែងស្តារឡើងវិញ តែសេដ្ឋកិច្ចនៅលំបាកច្រើនណាស់, កំណើនប្រជាជនបានកើនឡើងដល់ ១១ លាននាក់, ដីស្រែរាប់ពាន់ហិកតា នៅមិនទាន់បានរំដោះរួចផុតពីគ្រាប់មីហ៊ុមព័ទ្ធ និងច្រើនពាន់ហិកតាទៀត បានប្រែក្លាយទៅជាតំបន់រោងចក្រឧស្សាហកម្មអស់ទៅហើយ, ...

ខ. វប្បធម សិល្បៈ អក្សរសាស្ត្រ ស្តារឡើងវិញ មិនទាន់បានស្មើនឹងសម័យមុនសង្គ្រាមផង, ... ស្រាប់តែប្រពន្ធ័ឃោសនាបែបទំនើបនៅកម្ពុជា កំពុងធ្វើអោយសីលធមិសង្គមរបស់ជាតិយើង រង្គោះរង្គើ និងវេចរិលបណ្តើរៗទៅហើយ

គ. ពុទ្ធសាសនាដែលបានកផ្តុំជាប្រព័ន្ធសីលធមិ និងចរិយាធមិ ដ៏ជាប្រៈពៃណីរបស់ប្រទេសកម្ពុជា និងជារបាំងដ៏មានសារសំខាន់យ៉ាងក្រៃលែង សំរាប់រក្សាការពារប្រពៃណី និងវប្បធមិជាតិ រាប់ពាន់ឆ្នាំមកហើយនោះ ត្រូវបានគេធ្វើអោយអន្តរាយ និងលុបបំបាត់អស់កាលដ៏វែង បណ្តាលអោយមានការធ្លាក់ចុះខាងសីលធមិ និងចរិយាធមិយ៉ាងសំបើម នៅក្នុងសង្គមខ្មែរគ្រប់ស្រទាប់ ។

នៅឆ្នាំ ១៩៦៩ ប្រទេសកម្ពុជាយើងមានវត្តពុទ្ធសាសនា ចំនួន ៣.៣៦៩ និងមានព្រះសង្ឃ គឺភិក្ខុ-សាមណេរ ចំនួន ៦៥.០៦២ អង្គ នៅតាមខេត្ត ក្រុង ទាំង ២០ ។ លុះដល់ឆ្នាំ ១៩៧០-១៩៧៥ សង្គ្រាមស៊ីវិលបានធ្វើអោយខូចខាតដល់វត្ត មួយចំនួនធំ ដោយការបាញ់ផ្លោង និងការទម្លាក់គ្រាប់បែក ។ ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ របបប្រល័យពូជសាសន៍ បានកាប់សម្លាប់ប្រជារាស្ត្រ ធ្វើគត់ព្រះសង្ឃ និងបំផ្លាញវត្តអារាម ប្រាសាទបុរាណ អោយខូចខាតខ្ទេចខ្ទាំជាខ្លាំង ។ ចាប់ពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ ១៩៩៩ នេះ វត្តដែលរងការបំផ្លិចបំផ្លាញក្នុងរបប ប៉ុល ពត ត្រូវបានជួសជុលឡើងវិញ និងបានកសាងថ្មីបន្ថែម កើនបានចំនួន ៣.៦៨៥ វត្ត និងមានព្រះសង្ឃ គឺភិក្ខុ-សាមណេរ ចំនួន ៥០.០៨១ អង្គ នៅតាមខេត្ត ក្រុងទាំង ២១ ។

ម្យ៉ាងទៀត ក្រោយការកាប់សម្លាប់រង្គាល និងបំផ្លាញយ៉ាងខ្ទេចខ្ទី ក្នុងឆ្នាំ

១៩៧៥-១៩៧៩ របស់ពួកប៉ុលពតមក ព្រះសង្ឃដែលជាបញ្ញវន្ត ត្រូវបានបាត់បង់ស្ទើរអស់រលីង ជាប្រការមួយដែលធ្វើអោយព្រះសង្ឃពុទ្ធសាសនិករបស់យើងបច្ចុប្បន្នមានអតុល្យភាពយ៉ាងខ្លាំងរវាងគុណភាព និងបរិមាណ គឺគុណភាពទាប ទាំងចំណេះដឹង ទាំងចំណេះបដិបត្តិ រួមទាំងទំនាបគុណភាពនៃអង្គការគ្រប់គ្រងសង្ឃគ្រប់ថ្នាក់ផង ដែលជាហេតុធ្វើអោយ « អានុភាពនៃពុទ្ធចក្រ » គឺអំណាចដែលដឹកនាំភិក្ខុសង្ឃ និងពុទ្ធបរិស័ទ ទៅកាន់សេចក្ដីបរិសុទ្ធ ក៏ចុះខ្សោយដែរ ។ នេះជាសេចក្ដីសន្និដ្ឋានរួម ដាក់ប្រគេន-ជូនអង្គមហាសន្និបាត ដើម្បីពិចារណា ។

បើនិយាយពីអំណាចពុទចក្រវិញ, នៅក្នុងរយៈពេលកន្លងទៅ ទាំងក្រសួងសម្តេចព្រះសង្ឃរាជ ទាំងក្រសួងធម្មការ និងសាសនា និងទាំងមន្ទីរធម្មការ និងសាសនាខេត្ត ក្រុង គ្រប់ថ្នាក់ មានការខិតខំធំធេងណាស់ ដើម្បីរៀបចំអង្គការគ្រប់គ្រងភិក្ខុសង្ឃ ហើយសំរេចរៀបចំបានគ្រប់ឋានានុក្រមអស់ហើយ សំរាប់គណៈ-មហានិកាយ, ឯគណៈធម្មយុត្តិកនិកាយ នៅខ្វះចន្លោះនៅឡើយ, ប៉ុន្តែ សមត្ថភាព និងប្រសិទ្ធភាពអនុវត្តការងារគ្រប់គ្រងសង្ឃ សំដៅរួមចំណែកស្តារ និងកសាងសង្គមជាតិ អោយបានរីកចំរើនជឿនលឿន ដូចប្រទេសជិតខាងក្នុងដំបន់, នៅខ្វះខាតនៅឡើយ ។

ដោយសារទំនាបនៃគុណភាពនេះ ទើបទំនាស់ ឬអធិករណ៍ រវាងសង្ឃ និងសង្ឃ រវាងសង្ឃ និងគ្រហស្ថ កើតមានឡើងមិចេះចប់ ធ្វើអោយកិត្តិស័ព្ទនៃពុទ្ធសាសនា នាពេលបច្ចុប្បន្ន ត្រូវចុះឱនអ័ព្ទ ។ ម្យ៉ាងទៀត ជំនឿនិងការប្រតិបត្តិធមិ-វិន័យរបស់បព្វជិតខ្លះ និងពុទ្ធបរិស័ទមួយចំនួន ក៏បានចោទជាបញ្ហា ធ្វើអោយពុទ្ធសាសនាបាត់បង់តម្លៃ និងសេចក្ដីថ្លៃថ្នូរ និងប្រជាប្រិយភាពយ៉ាងធ្ងន់ធ្ងរ ។

ប៉ុន្មានឆ្នាំនេះ មានតែអង្គការពុទ្ធសាសនាជប៉ុនប៉ុណ្ណោះ ដែលបានចូលមកជួយស្តារវិស័យពុទ្ធសាសនា និងវប្បធមិកម្ពុជា, ទន្ទឹមនោះ មានច្រើនតែអង្គការ

គ្រឹស្តសាសនា បានចូលមកផ្សព្វផ្សាយសាសនារបស់គេ ។ តើព្រះសង្ឃ និងវត្តអារាម ពុទ្ធសាសនិកយើង ប្រកាន់អាកប្បកិរិយាយ៉ាងណា ដើម្បី :

- ស្តារ និងកសាងកេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់ខ្លួន អោយរីកស្ទុះស្វាយឡើងវិញ ?

- ប្រមូលកម្លាំងបញ្ញា កាយ ចិត្ត ក្នុងឋានៈជាអង្គការចាត់តាំងមួយរបស់សង្គម ដើម្បីរួមចំណែកអភិវឌ្ឍសង្គម ?

ឆ្លើយតបទៅនឹងសំណួរនេះ គឺមានតែពង្រឹងការបដិបត្តិពុទ្ធសាសនាអោយល្អប្រសើរ ពីព្រោះ :

• អត្ថិភាពនៃពុទ្ធសាសនារបស់យើងនាពេលបច្ចុប្បន្ន កំពុងចោទជាបញ្ហានៅក្នុងសតិអារម្មណ៍របស់មហាជន និងប្រជាជន ដែលបានសំដែងនូវសេចក្តីព្រួយបារម្ភចំពោះគុណធម៌ និងសីលធម៌ នៃពុទ្ធសាសនា ។

• បច្ចុប្បន្ននេះ ព្រះសង្ឃដ៏បរិសុទ្ធរបស់យើង កំពុងតែត្រូវហ៊ុមព័ទ្ធដោយបព្វជិតអលជ្ជី និងជនទុច្ចរិតមួយចំនួន ដែលបានធ្វើអោយសៅហ្មងដល់ភាពបរិសុទ្ធនៃពុទ្ធសាសនា ។

• កង្វះសមត្ថភាពជំនាញខាងធម៌-វិន័យ និងអភិបាលកិច្ចល្អ របស់មន្ត្រីសង្ឃថ្នាក់ខ្ពស់ រហូតដល់ចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង, អាចារ្យ និងគណៈកម្មការវត្ត បានធ្វើអោយពុទ្ធបរិស័ទពុំមានសទ្ធាជ្រះថ្លាចំពោះបព្វជិត ដែលប្រព្រឹត្តប្រាសចាកសីលធម៌ ផ្ទុយពីគោលការណ៍នៃអភិសមាចារពុទ្ធសាសនា និងអភិសមាចារសង្គម ។ យ៉ាងណាមិញ :

- បញ្ហាវែអង្គាសអនាធិបតេយ្យច្រើនរូបភាព នៅតែបន្តសកម្មភាពអនាធិបតេយ្យឥតអៀនខ្មាស ឥតក្រែងរអែង ។ សកម្មភាពរបស់ពួកគេមានច្រើនរូបភាព, ជួនកាលគេដាក់តាំងព្រះពុទ្ធរូបលើរ៉ឺម៉ក អូសដើរសុំប្រាក់កាសចិញ្ចឹមជីវិត

ឃោសនាថាយកទៅកសាងនេះ កសាងនោះ, ជួនកាលគេបង្កើតជាក្រុម វាយកម្លាំងគ្នាដើររៃអង្គាសតាមផ្ទះ, តាមទីផ្សារ និងគ្រប់ច្រកល្ហក . ល . ធ្វើអោយប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ និងកេរ្តិ៍ឈ្មោះព្រះពុទ្ធសាសនា, ...

- ព្រះសង្ឃនៅឃ្លាតឆ្ងាយពីពុទ្ធបរិស័ទ មិនសូវបានគិតគូរថែទាំ អប់រំពុទ្ធ.បរិស័ទរបស់លោក ។ ព្រះសង្ឃខ្លះដែលមានឋានៈជាចៅអធិការ ពុំបានគិតគូរពង្រីកតួនាទីរបស់លោកអោយលាតសន្ធឹង គ្របដណ្តប់លើពុទ្ធបរិស័ទជើងវត្តរបស់លោកឡើយ, ផ្ទុយទៅវិញ កំពុងតែបង្រួញតួនាទីរបស់លោកអោយនៅត្រឹមតែមួយវត្តប៉ុណ្ណោះ ។

- អាចារ្យ គណៈកម្មការវត្ត មួយចំនួន បំរើសកម្មភាពសាសនាច្របូកច្របល់ ដោយ :

* ការប្រើប្រាស់ដីធ្លីវត្ត ពុំមានសណ្តាបធ្នាប់

* ការប្រើប្រាស់បច្ច័យវត្ត មិនបានត្រឹមត្រូវតាមគោលការណ៍ នៃហិរញ្ញ.កិច្ច, បញ្ជីកត់ត្រាចំណូលចំណាយ ខ្វះការគ្រប់គ្រងម៉ត់ចត់, ... បង្កើតអោយមានទំនាស់ និងបាត់បង់ប្រាក់កាស ខ្វះការទទួលខុសត្រូវ,

- ការខិតខំសិក្សារៀនសូត្ររបស់បព្វជិតខ្លះ គួរអោយសរសើរ, តែការសិក្សាមុខវិជ្ជាខ្លះរបស់បព្វជិតទាំងនោះខុសទំនង លាយឡំដោយគ្រហស្ថ និងទីស្ថានមិនសមរម្យ មិនសមស្របនឹងអភិសមាចារពុទ្ធសាសនា បង្កើតអោយមានការបរិ.ហាររិះគន់ដោយប្រការផ្សេងៗ ។

• មានបាតុភាពមួយចំនួនបានកើតចេញពីពួកជនទុច្ចរិត ដែលបានតាំងខ្លួនជាព្រះបាទធម្មិក ជាគ្រូបារមី ជាអ្នកសច្ចំ ។ សង្គមខ្មែរបច្ចុប្បន្ន កំពុងបិតក្នុងចិត្តវិបល្លាសតាមរយៈជនពាលទាំងនោះ ដោយហេតុល្ងង់ខ្លៅ ខ្វះការយល់ដឹងត្រឹមត្រូវ ។ ចំណែកព្រះភិក្ខុសង្ឃ ក៏បានទទួលការអប់រំតិចតួច ។ ប្រជាជនយើងភាគច្រើន ខ្វះ

ការត្រិះរិះរកហេតុផល, ការភ័យខ្លាចបន្សល់ទុកពីរបប ប៉ុល ពត មិនទាន់លុបលាង ជ្រះស្រឡះនៅឡើយផង ស្រាប់តែលេចចេញនូវរូបភាពបន្លំបោកប្រាស់របស់ពួកអ្នកសច្ចំ, គ្រូបារមី ដើរផ្សព្វផ្សាយបំភ័យអោយប្រជាជនបន្តភ័យខ្លាច តទៅទៀត ។ ប៉ុន្មានឆ្នាំនេះ ពិសេស ប៉ុន្មានអាទិត្យកន្លងទៅថ្មីៗនេះ មានពួកជនទុច្ចរិតតាំងខ្លួនជាអ្នកសច្ចំ ជាគ្រូបារមី ដើរឃោសនាប្រាប់ថា នឹងមានយមរាជ យមបាលមកយកជីវិតស្រីក្រមុំណាដែលទុកសក់វែង, ... ។ តើព្រះភិក្ខុសង្ឃរបស់យើងមានចំណេះដឹង យល់ការរាក់ជ្រៅ អាចអប់រំ ណែនាំដល់គ្រហស្ថ ក្នុងស្ថានភាពបែបនេះបានឬទេ ? ទាំងអស់នេះ ទាក់ទងដល់ព្រះពុទ្ធសាសនារបស់យើង ។

ខ្ញុំព្រះករុណា ខ្ញុំ យល់ឃើញថា បញ្ហានេះអាចទាក់ទងដល់ព្រះពុទ្ធសាសនាយ៉ាងហោចណាស់ ក៏មានការពាក់ព័ន្ធដល់ចំណុច ៣ យ៉ាងដែរ :

• ទីមួយ : ព្រះពុទ្ធសាសនា ជាសាសនាប្រកបដោយហេតុផល បង្ហាញផ្លូវទៅកាន់វិមុត្តិ ។ ប្រវត្តិសាស្ត្របានបញ្ជាក់ថា ប្រទេសកម្ពុជាបានទទួលយកព្រះពុទ្ធសាសនាមកគោរពបូជា តាំងពីពុទ្ធសតវត្សទី ៣ ។ បើគិតមកដល់ឥឡូវនេះ, ពុទ្ធ-សាសនា មានអាយុកាលជាងពីរពាន់ឆ្នាំហើយ, ហើយត្រូវបានប្រជាជនកម្ពុជា ចាត់ទុកជាសាសនារបស់រដ្ឋ ។ ដូច្នេះ ពុទ្ធសាសនាជាកេតនភ័ណ្ឌរបស់ជាតិ តម្រូវអោយពលរដ្ឋទាំងអស់ ទោះជាបព្វជិត ឬគ្រហស្ថ យកចិត្តទុកដាក់ការពារកិត្តិយស សេចក្តីថ្លៃថ្នូរ និងតម្លៃជាអមតៈនៃពាក្យប្រដៅរបស់ពុទ្ធបរមគ្រូ ។

• ទីពីរ : ពុទ្ធសាសនា បានក្លាយជាសាច់ ឈាម របស់ប្រជាជនខ្មែរ និងជាមាគ៌ានៃជីវិតរបស់ខ្មែរ តាំងពីកើតរហូតដល់ស្លាប់ ។ ពេលដែលព្រះពុទ្ធសាសនាបានស្ថិតស្ថេរគង់វង្ស រីកចំរើននៅក្នុងសង្គមខ្មែរ, ពេលនោះ សង្គមខ្មែរក៏បានស្ថិតស្ថេរគង់វង្សរីកចំរើន សុខសាន្តដែរ ។ ពេលណា ពុទ្ធសាសនាត្រូវអន្តរាយ ពេលនោះសង្គមខ្មែរ ក៏ត្រូវវិនាសអន្តរាយដែរ ដូចដែលយើងទាំងអស់គ្នាបានដឹង បានជួបប្រទះ

រួចមកហើយ ។

• ទីបី : ព្រះពុទ្ធសាសនា មានតួនាទីសំខាន់ ដែលស្តែងចេញតាមរយៈតួនាទីរបស់វត្តអារាម, តួនាទីរបស់ព្រះសង្ឃ និងតួនាទីអប់រំសីលធម៌ ។ ទាំង ៣ នេះ ជាកម្លាំងរស់ដ៏សំខាន់របស់សង្គមជាតិយើង មិនអាចខ្វះមួយណាបានឡើយ ។ នៅក្នុងការកសាងសង្គមជាតិយើង គេពុំអាចខ្វះកម្លាំងចលកររបស់ពុទ្ធសាសនា របស់ព្រះសង្ឃ និងរបស់វត្តអារាមបានទេ ។ ក្នុងស្ថានភាពបច្ចុប្បន្ន យើងគប្បីគិតគូរខ្ពស់ដល់ការស្តារកម្លាំងទាំង ៣ នេះ អោយមានកិត្យានុភាព, មានឥទ្ធិពល និងមានអានុភាពខ្លាំងក្លាឡើង គឺ កិត្យានុភាពព្រះសង្ឃ, ឥទ្ធិពលវត្តអារាម និងអានុភាពពុទ្ធចក្រ ( អង្គការគ្រប់គ្រងសង្ឃ ) សំដៅទាក់ទាញជំនឿ និងទំនុកចិត្ត ព្រមទាំងការគាំទ្ររបស់ប្រជាជនពុទ្ធសាសនិកយើង តាមរយៈ

*១. លើកកំពស់កិត្យានុភាពព្រះសង្ឃ*

- ពង្រឹង និងពង្រីកពុទ្ធិកសិក្សាគ្រប់កំរិតអោយបានទូលំទូលាយ និងសាលាធម្មវិន័យផង សំដៅបណ្តុះបណ្តាលអោយមានអ្នកប្រាជ្ញបណ្ឌិតក្នុងជួរសង្ឃ ដែលមានសមត្ថភាពឃោសនាអប់រំពុទ្ធសាសនា និងមានសមត្ថភាពពន្យល់ណែនាំចំណេះដឹង សំរាប់លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ ។

- ជំរុញអោយមានការគោរពប្រតិបត្តិធម៌-វិន័យម៉ឺងម៉ាត់ តាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និងអភិសមាចារ សំដៅបង្កើនជំនឿជ្រះថ្លាក្នុងពុទ្ធសាសនា និងការគោរពគាំទ្រពីប្រជាជនពុទ្ធសាសនិក ។

- បង្កើនសកម្មភាពចូលរួមក្នុងកិច្ចការសង្គម ជួយលើកកំពស់ជីវភាពប្រជាពលរដ្ឋជួបការលំបាក, និងចូលរួមក្នុងការងារមនុស្សធម៌, បង្កើនសមានចិត្តរួមសុខរួមទុក្ខ ជាមួយពុទ្ធបរិស័ទដ៏ក្រខ្សត់របស់យើង ។

*២. លើកឥទ្ធិពលវត្តអារាម*

- ធ្វើអោយវត្តអារាមនីមួយៗ ក្លាយជាមជ្ឈមណ្ឌលផ្តល់ចំណេះដឹង ទាំងផ្លូវលោក ទាំងផ្លូវធម៌ និងជាមជ្ឈមណ្ឌលរក្សាទុកសៀវភៅធម៌អាថ៌ ក្បួនច្បាប់វប្បធម៌ ប្រពៃណី ដោយបង្កើតអោយមានបណ្ណាល័យ មានសៀវភៅគ្រប់មុខវិជ្ជា, មានសាលាធម្មវិន័យ ឬសាលាបាលី និងមានឧទ្យានប្រកបដោយរុក្ខជាតិមានប្រយោជន៍ ។

- ណែនាំ និងអប់រំពុទ្ធបរិស័ទ ( ភិក្ខុ សាមណេរ គ្រហស្ថ ) អោយស្រឡាញ់វិជ្ជា, អោយមានទម្លាប់អានសៀវភៅ, អោយស្មារតីត្រះរិះ, ចេះវិនិច្ឆ័យត្រឹមត្រូវ និងចូលរួមកាន់តែសកម្មក្នុងកិច្ចអភិវឌ្ឍន៍សង្គម និងការការពារបរិដ្ឋានវប្បធម៌ សង្គម និងធម្មជាតិ ។

- សាងសង់សំណង់ថ្មី ត្រូវគិតគូរដល់ការថែរក្សាសិល្បៈនិងក្បូរក្បាច់ខ្មែរ

- ធ្វើអោយវត្តអារាមនីមួយៗ មានដំណើរប្រព្រឹត្តទៅត្រឹមត្រូវ, ម៉ត់ចត់ប្រាសចាកអធិករណ៍ ក្រោមការគ្រប់គ្រង ដឹកនាំដ៏មានប្រសិទ្ធភាពរបស់លោកគ្រូចៅអធិការវត្ត ។

*៣. លើកកំពស់អានុភាពពុទ្ធចក្រ*

- ពង្រឹងសមត្ថភាពជំនាញខាងធម៌-វិន័យ និងខាងអភិបាលកិច្ចល្អរបស់មន្ត្រីសង្ឃ, ចៅអធិការ, គ្រូសូត្រស្តាំ-ឆ្វេង, អាចារ្យ និងគណៈកម្មការវត្ត សំដៅពង្រឹងគុណភាពខាងការគ្រប់គ្រងវត្ត គ្រប់គ្រងភិក្ខុសង្ឃ និងពុទ្ធបរិស័ទ ដោយធ្វើបញ្ជីកត់ត្រា :

ក). ចំនួនព្រះសង្ឃក្នុងវត្ត

ខ). ចំនួនគរុភ័ណ្ឌជាចលនៈ និងអចលនវត្ថុ របស់វត្ត

គ). ចំនួនឧបាសក ឧបាសិកា ចំណុះជើងវត្ត

ឃ). ចំណូល-ចំណាយប្រចាំឆ្នាំរបស់វត្ត

ង). ធ្វើរបាយការណ៍ប្រចាំឆ្នាំប្រគេនព្រះគ្រូអនុគណ ព្រះមេគណ និង មន្ទីរធម្មការ រៀងរាល់ឆ្នាំ ។

- ត្រូវធ្វើប្លង់មេរបស់វត្ត និងប្រើប្រាស់ដីធ្លីវត្ត អោយមានសណ្តាប់ធ្នាប់តាមប្លង់មេ ។

ការរៀបរាប់ទាំងប៉ុន្មានខាងលើនេះ គ្រាន់តែជាយោបល់មួយចំនួន ដែលខ្ញុំព្រះករុណា-ខ្ញុំ យល់ថានឹងបានជាជំនួយស្មារតីក្នុងការត្រិះរិះពិចារណា សំរាប់ការពិភាក្សាភ្ជាប់ទៅនឹងកម្រងយុទ្ធវិធីទាំង ៤ នៃកិច្ចពង្រឹងការប្រតិបត្តិពុទ្ធសាសនា នៅប្រទេសយើង ។

សូមជូនពរ សូមអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៨ ប្រព្រឹត្តទៅប្រកបដោយដោយជោគជ័យ ត្រចះត្រចង់ !

សូមព្រះគុណ, សូមអរគុណ,

## ប្រយ័ត្ន ៤

*១ . ហោរា ប្រយ័ត្នមាត់រអិល*

*២. ជាងទង កាន់សីលប្រយ័ត្នទៀង*

*៣. ចៅក្រម ប្រយ័ត្នការលំអៀង*

*៤. អ្នកផ្ទៀង ប្រយ័ត្នបាត់អក្ខរា ។*

សុត្តន្តប្រីជា ឥន្ទ

# សេចក្ដីប្រកាសរួម របស់
# អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៨
# ថ្ងៃ ១០ - ១១ - ១២ កក្កដា ១៩៩៩

---------

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៨ ស្ដីពី « កិច្ចពង្រឹងការប្រតិបត្តិព្រះពុទ្ធសាសនា » តាមព្រះតម្រិះផ្ដួចផ្ដើមរបស់សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ និងសម្ដេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ បានប្រព្រឹត្តទៅនៅរាជធានី ភ្នំពេញ ក្រោមព្រះបរមរាជូបត្ថម្ភរបស់ព្រះករុណាជាអម្ចាស់ជីវិត ចំពោះដំណើរការងារនៃអង្គមហាសន្និបាត ។

សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ទ្រង់ជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ក្នុងអង្គមហាសន្និបាត ។

ចូលរួមជាសមាជិកនៃមហាសន្និបាត មានមន្ត្រីសង្ឃគណៈមហានិកាយ ចំនួន ៥៧ អង្គ មន្ត្រីសង្ឃគណៈធម្មយុត្តិកនិកាយ ចំនួន ៣៨ អង្គ និងមន្ត្រីធម្មការចំនួន ៥៦ នាក់ ដែលនិមន្ត-អញ្ជើញមកពីខេត្ត-ក្រុង ទាំង ២៤ ។

ក្នុងរយៈពេល ៣ ថ្ងៃនៃដំណើរការងាររបស់ខ្លួន គឺពីថ្ងៃ ១០ ដល់ថ្ងៃ ១២ កក្កដា ឆ្នាំ ១៩៩៩ អង្គមហាសន្និបាតមន្ត្រីសង្ឃ បានស្ដាប់ ៖

- សុន្ទរកថាស្វាគមន៍របស់ ឯកឧត្តម ជា សាវឿន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា,

- សុន្ទរកថាបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី ៨ របស់សម្ដេច ជា ស៊ីម ប្រមុខរដ្ឋស្ដីទី ប្រធានព្រឹទ្ធសភា និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃព្រះករុណាជាអម្ចាស់ជីវិត,

- សេចក្ដីថ្លែងយោបល់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ស្ដីពី ស្ថានភាពព្រះពុទ្ធសាសនា នៅកម្ពុជា ។

អង្គមហាសន្និបាតបានស្ដាប់ព្រះយោបល់ណែនាំការពិភាក្សា របស់សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ លើរបៀបវារៈទាំង ៤ ដែលជាកម្រងយុទ្ធវិធី នៃកិច្ចប្រតិបត្តិព្រះពុទ្ធសាសនា សំដៅលើកស្ទួយកេរ្តិ៍ឈ្មោះ កិត្តិយស សេចក្ដីថ្លៃថ្នូររបស់ព្រះសង្ឃពុទ្ធសាសនិកកម្ពុជា និងតម្លៃនៃសច្ចធម៌របស់ព្រះពុទ្ធជាបរមគ្រូ ។

អង្គមហាសន្និបាត បាន ៖

១- រំលឹកឡើងវិញនូវព្រះតម្រិះផ្ដួចផ្ដើមរបស់សម្ដេចព្រះសង្ឃរាជ ដែលទ្រង់បានព្រមព្រៀងជាឯកច្ឆន្ទ ធ្វើការប្រជុំអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃឆ្នាំនេះរួមគ្នារវាងមន្ត្រីសង្ឃទាំងពីរគណៈ នៅទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ។ ព្រះតម្រិះដ៏ថ្លៃថ្លានេះ ជាសញ្ញាដ៏វិជ្ជមានគួរអោយគោរពកោតសរសើរក្រៃលែង ។

២- ទទួលស្គាល់សារសំខាន់នៃព្រះពុទ្ធសាសនា ថាជាស្នូលនៃវប្បធម៌របស់ប្រទេសជាតិ ហើយដែលត្រូវបានចារឹកក្នុងរដ្ឋធម្មនុញ្ញ ជាសាសនារបស់រដ្ឋ ។ ក្នុងឋានៈនេះ សាមគ្គីភាពក្នុងជួរពុទ្ធសាសនិក ជាពិសេស ក្នុងជួរព្រះសង្ឃទាំងពីរគណៈ ត្រូវតែបានជាគំរូដល់ប្រជាពលរដ្ឋយើង ។ សាមគ្គីភាពនៃនិកាយសង្ឃទាំងពីរគឺជាសសរទ្រូងនៃភាពគង់វង្ស រុងរឿង រីកចំរើន របស់ព្រះពុទ្ធសាសនា ក៏ដូចជាភាពគង់វង្ស រុងរឿង រីកចំរើន របស់ប្រទេសកម្ពុជា ដូច្នោះដែរ ។

៣- កត់សម្គាល់ឃើញថា ប្រជាពលរដ្ឋកម្ពុជាបានយកព្រះពុទ្ធសាសនា ជាទីពឹង ទីរលឹក និងជាមាគ៌ានៃជីវិតរបស់ខ្លួន ហើយធ្វើជាមូលដ្ឋានស្ថាបនាជាតិ ឆ្ពោះទៅកាន់សន្តិភាព លើមាគ៌ាអហិង្សា សន្ដោស យោគយល់ អធ្យាស្រ័យគ្នា ទៅវិញទៅមក ។

៤. ចង្អុលប្រាប់ថា ពេលណា ព្រះពុទ្ធសាសនារីកចំរើន ឋិតថេរ គង់វង្ស នៅក្នុងសង្គមខ្មែរ ពេលនោះ ប្រជាពលរដ្ឋខ្មែរក៏បានរីកចំរើន សុខសាន្ត សំបូរ សប្បាយផងដែរ ។ ពេលណា ព្រះពុទ្ធសាសនាត្រូវវិនាសអន្តរាយ ពេលនោះ សង្គមជាតិយើង និងប្រជាពលរដ្ឋ ក៏ត្រូវវិនាសអន្តរាយ និរាសព្រាត់ប្រាស ដូចដែលយើងបានទទួលរងទុក្ខសោកកន្លងមកហើយ ។

៥. កំណត់ចំណាំថា បទពិសោធន៍ និងវិចារណញ្ញាណ បានបង្ហាញថា យើងនឹងអាចរកផ្លូវសុខសាន្តមួយ ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិរបស់យើងបាន លុះត្រាតែយើងទាំងអស់គ្នាស្រុះចិត្ត មូលគំនិត យកព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ជាវិធីអប់រំកាយចិត្ត ដើម្បីជម្រុះចោលនូវគំនិតគុំគួនគ្នា ច្រណែនឈ្នានីស សងសឹក ព្យាបាទតាមមធ្យោបាយហិង្សា ។

ផ្អែកលើការសង្កេត និងសេចក្តីសន្និដ្ឋានខាងលើនេះ អង្គមហាសន្និបាតទាំងមូលបានសំរេចជាឯកច្ឆន្ទ ចេញសេចក្តីប្រកាសរួម ដូចខាងក្រោម ៖

១. ខិតខំលើកកំពស់កិត្យានុភាពព្រះសង្ឃ តាមរយៈការប្រឹងប្រែងពង្រឹងគុណភាពពុទ្ធិកសិក្សាទាំងបីភូមិសិក្សា ព្រមទាំងការសិក្សាធម៌វិន័យ និងវិបស្សនាធុរៈផង ធ្វើអោយធុរៈទាំងពីររបស់ព្រះពុទ្ធសាសនា ក្លាយទៅជាករណីយកិច្ចអចិន្ត្រៃយ៍របស់ព្រះសង្ឃ ។

២. ពង្រឹងគុណភាពខាងការគ្រប់គ្រងវត្តអារាម ដោយធ្វើបញ្ជីកត់ត្រា ៖

ក) ចំនួនព្រះសង្ឃក្នុងវត្ត,

ខ) ចំនួនគរុភ័ណ្ឌជាចលនៈ និងអចលនទ្រព្យ និងបេតិកភ័ណ្ឌវប្បធម៌របស់វត្ត,

គ) ចំណូល-ចំណាយ របស់វត្ត,

ឃ) រៀបចំប្លង់មេរបស់វត្ត និងប្រើប្រាស់ដីធ្លីវត្ត អោយមានសណ្តាប់

ផ្ទាប់ ទៅតាមបួងមេ ។

ង) ធ្វើរបាយការណ៍ប្រចាំឆ្នាំប្រគេនព្រះគ្រូអនុគណ ព្រះមេគណ និង ចម្លងជូនមន្ទីរធម្មការ ដើម្បីជ្រាប និងធ្វើសហការ ។

៣. ខិតខំពង្រឹងសមត្ថភាពជំនាញខាងធម៌-វិន័យ និងខាងអភិបាលកិច្ច របស់មន្ត្រីសង្ឃថ្នាក់មេគណ អនុគណ ចៅអធិការ រួមទាំងគណៈកម្មការវត្ត អាចារ្យវត្តផង ដើម្បីកំណត់បែងចែកមុខការ និងភារកិច្ច របស់ថ្នាក់នីមួយៗ អោយបានច្បាស់លាស់ ។

៤. ខិតខំបន្តកសាងវត្តអារាមអោយទៅជាមជ្ឈមណ្ឌលវប្បធម៌ របស់ប្រជាជន រួមចំណែកដ៏សកម្មក្នុងការអភិវឌ្ឍន៍សង្គម តាមរយៈការបង្កើតអោយមាន :

* បណ្ណាល័យ ប្រកបដោយសៀវភៅ ឯកសារយ៉ាងសំបូរ ។
* ធ្វើអោយទីអារាមទាំងមូល ក្លាយជាឧទ្យានប្រកបដោយរុក្ខជាតិ មានប្រយោជន៍ ។
* សាងសង់សំណង់ថ្មីៗ ត្រូវមានស្មារតីគិតគូរដល់ការថែរក្សាអត្ត-សញ្ញាណសិល្បៈ និងស្ថាបត្យកម្មជាតិ ។
* ចូលរួមកាន់តែសកម្មក្នុងការថែរក្សាបរិដ្ឋាន វប្បធម៌-សង្គម-ធម្មជាតិ និងកិច្ចការអភិវឌ្ឍសង្គម តាមរយៈធ្វើផ្លូវ ជីកស្រះ សាលារៀន . ល . ។

៥. អង្គមហាសន្និបាត បានឯកភាពគោរពរាល់សេចក្តីសំរេចទាំងឡាយ របស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃនៃគណៈសង្ឃទាំងពីរ ដែលបានប្រកាន់យករួចមកហើយ លើមូលដ្ឋានយោគយល់ អធ្យាស្រ័យទៅវិញទៅមក ។

៦. ព្រះសង្ឃទាំងពីរគណៈ បានសំរេចព្រះទ័យជាឯកច្ឆន្ទថា ចាប់ពីពេលនេះតទៅ គណៈសង្ឃទាំងពីរ នឹងបន្តធ្វើអោយកាន់តែជិតស្និទ្ធ ក្នុងស្មារតីភាតរភាព

គោរព ស្រឡាញ់ដោយស្មោះត្រង់បំផុត ឥតមានគំនិតប្បៀតបៀន យកប្រៀបលើគ្នាឡើយ ។

៧. អង្គមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំលើកទី ៨ នេះ សូមអបអរសាទរជាមហោឡារិក និងធ្វើសំណូមពរដោយទទូច សូមអោយមានការប្រជុំរួមជាប្រវត្តិសាស្ត្ររបស់មន្ត្រីសង្ឃពុទ្ធសាសនិកកម្ពុជាទាំងពីរគណៈដូចនេះ បានប្រព្រឹត្តទៅជារៀងរាល់ឆ្នាំ អស់កាលជាអង្វែងតទៅ ។

ធ្វើនៅរាជធានី ភ្នំពេញ, ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ១៩៩៩

| | |
|---|---|
| សម្តេចព្រះសង្ឃរាជគណៈមហានិកាយ | សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ |
| ព្រះមហាសុមេធាធិបតី | ព្រះសុគន្ធាធិបតី |
| ព្រះហស្តលេខា និង ត្រា | ព្រះហស្តលេខ និត្រា |
| **ទេព វង្ស** | **បួរ គ្រី** |

បានឃើញ

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

ហត្ថលេខា និងត្រា

**ជា សាវឿន**

# ចំណោទ ៨ យ៉ាង

*ចំណោទនេះអ្នកប្រាជ្ញតែងឡើងក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះនរោត្តម ដែលនគរយើងធ្លាក់ទៅជាអាយ័ត(*) នៃបរទេស ។ ចំណោទទាំង ៨ នេះ គេតែងពួកក្មេងៗអ្នកស្រុកយើងយកទៅប្រើរាប់ចង្អុលរកអ្នកចាំទី នៅក្នុងល្បែងខ្ទប់មុខរត់ពួន « បិទពួន » គឺល្បែងលេងដោយអ្នកម្ខាងឈរខ្ទប់មុខ អ្នកម្ខាងរត់ពួន ... !*

*ចំណោទទាំង ៨ នោះគឺ :*

| | |
|---|---|
| *១. ចាក់ទឹកដូង* | *អំផុងមួយពាន់* |
| *២. កាច់ឈើឈ្នាន់* | *អន្ទាន់អន្ទង* |
| *៣. កាច់របង* | *រំលងសីមា* |
| *៤. កន្ទុយត្រីប្រា* | *មេនាងខក* |
| *៥. កន្ទុយត្រីផ្ទក់* | *មេនាងកែវ* |
| *៦. អកកំបោរ* | *ប្រចាំថង់* |
| *៧. បំពង់ឫស្សី* | *ប្រចាំវែក* |
| *៨. ក្បាលទំពែក* | *ក្អែកជុះដាក់ប៉ក ។* |

## ស្រាយចំណោទទាំង ៨

ទី១. ម៉ាស៊ីនទឹក, ទី២. តំបាញ, ទី៣. ខ្សែលួស, ទី៤. រាស្ត្រយកគ្នាលែងរើសពូជ, ទី៥. រាស្ត្រយកប្រពន្ធពូជស្តេច, ទី៦. ស្តេចអោយមានគ្រាន់តែចាំវាំង, ទី៧. នាម៉ឺនគ្រាន់តែជួសប្រយោជន៍អោយគេ, ទី៨. អ្នកស្នេហាជាតិតែខ្មៅក ជាប់គុក និរទេស សម្លាប់ចោល ។

យូ . អ៊ិន

---

(*) អាយ័ត = ដែលពឹងផ្អែកលើអ្នកដទៃ, ដែលឥតអំណាចលើខ្លួន

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ក្នុងពិធីបុណ្យខួប ៣០ ឆ្នាំ នៃការសោយព្រះទិវង្គតសម្ដេច ជួន ណាត (រូបថត ព.ប.)

ឆ្នាំទី ៥៣ លេខ ៤
ព.ស ២៥៤៣

ខែ តុលា - វិច្ឆិកា - ធ្នូ
គ.ស ១៩៩៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

គ.ស ១៩៩៩

# មាតិកាអត្ថបទ

## I. អត្ថបទរដ្ឋបាល


• ប្រកាសស្ដីពីការផ្ទេរភារកិច្ច និងការតែងតាំងមន្ត្រីរាជការ ........ ១
• សេចក្ដីសំរេច ........ ៣


## II. អក្សរសាស្ត្រពុទ្ធសាសនា


• ពុទ្ធសាសនា និងចរិយធម៌ ( ឌិម ខែម ) ........ ៥
• សន្តិភាពក្រោមពន្លឺ និងម្លប់ នៃពុទ្ធសសនា ( ឌិម ខែម ) ........ ១០


## III. អក្សរសាស្ត្រទូទៅ


• សម្ដេចព្រះសង្ឃរាជ ជួន ណាត ជាអ្នកប្រាជ្ញកើតពី
សង្គមខ្មែរដ៏បរិសុទ្ធ ( ឌិម ខែម ) ........ ១៦
• សិលាចារឹកថ្មី Ka 77 នៅភូមិណាផាង ( ថៃ ) និង
សិលាចារឹកបន្ទាយទ័ព Ka 67 នៅថ្មពួក ( វង់ សុធារ៉ា ) ........ ២២
• ប្រវត្តិនៃការបង្កើតខ្លែង « ឯក » ( អ៊ុក សៅបុល ) ........ ៣២
• អំពីពុទ្ធទំនាយ ( ធន់ ហ៊ិន ) ........ ៣៨
• វប្បធម៌សន្តិភាព ( គង្គ ប៊ុនឈឿន ) ........ ៧៧
• ញញឹមសន្តិភាព ( គង្គ ប៊ុនឈឿន ) ........ ៧៩


## IV. កំណត់ និង ប្រវត្តិការណ៍


• ពិធីបុណ្យខួប ៣០ ឆ្នាំ នៃការសោយព្រះទិវង្គត
សម្ដេចព្រះសង្ឃរាជ ជួន ណាត ........ ៨១

ក្រសួងធម្មការ និង សាសនា
លេខ : ២៦៥ កធស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ភ្នំពេញ, ថ្ងៃទី ៣០ ខែ ១១ ឆ្នាំ ១៩៩៩*

# ប្រកាស
## ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

---------

### រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស.រកម.០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា
- បានឃើញលិខិតលេខ ២២០ លខ.កច របស់សាលាខេត្តកំពង់ចាម ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការសុំតែងតាំងលោក ងួន វ៉ាន់ធន្ធី
- អនុលោមតាមតម្រូវការចាំបាច់របស់ក្រសួងនិងសម្ថភាពរបស់មន្ត្រីរាជការ

## សំរេច·

**ប្រការមួយ** : ផ្ទេរភារកិច្ច និងតែងតាំងលោក **ខួន ហ៊ាន់ចន្ទី** ពីនាយកមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ចាម អោយមកទទួលភារកិច្ចជានាយកស្តីទីពុទ្ធសាសនបណ្ឌិត្យ ។

**ប្រការ ២** : នាយកខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (ការិយាល័យបុគ្គលិក ) ការិយាល័យផែនការ និងគណនេយ្យ មន្ទីរធម្មការ និងសាសនាខេត្តកំពង់ចាម និងលោក **ខួន ហ៊ាន់ចន្ទី** ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

**ប្រការ ៣** : សេចក្តីសំរេច និងសេចក្តីប្រកាសទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤** : សេចក្តីប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ជា សាវឿន**

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសារណៈ
- សាលាខេត្តកំពង់ចាម
- មន្ទីធម្មការនិងសាសនាគ្រប់ខេត្ត-ក្រុង

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ២

  " ដើម្បីអនុវត្ត "

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ ២៧៧ កធស.ប្រក

ភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

# សេចក្តីសំរេច

រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨.៧២. ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ១៣.អនក្រ.បក. ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និង សាសនា ។
- បានឃើញអនុក្រឹត្យលេខ ៤០២.អនក្រ.កត. ចុះថ្ងៃទី ២៣ កក្កដា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ ២៥៧ របស់ក្រសួងចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីរចនាសម្ព័នការិយាល័យក្រោមឱវាទនាយកដ្ឋាន និងអង្គ-ភាពមូលដ្ឋានចំណុះក្រសួងធម្មការ និងសាសនា ។
- អនុលោមតាមការចាំបាច់របស់ក្រសួង ។

## សំរេច

**ប្រការមួយ** : ប្រគល់ភារកិច្ចជូនលោក **ឱម ខែម** បច្ចុប្បន្នជាទីប្រឹក្សាអម ក្រសួងធម្មការ និងសាសនា អោយទទួលបន្តជានិពន្ធនាយករងនៃ

ទស្សនាវដ្ដីកម្ពុជសុរិយា, ដូចមានចែងក្នុងសេចក្ដីសំរេចរបស់ក្រសួងលេខ ១០/៩៤ កធស.ពប ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ១៩៩៣, និងទទួលបន្ដជួយការងារបោះពុម្ពសៀវភៅរបស់ពុទ្ធ-សាសនបណ្ឌិត្យ ។

**ប្រការ២ :** សេចក្ដីសំរេចលេខ ១៥០/៩៩ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ១៩៩៩ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣ :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញ-វត្ថុ នាយកដ្ឋានធម្មការ នាយកដ្ឋានពាហិរសាសនា នាយកដ្ឋានឃោសនាអប់រំផ្សព្វផ្សាយធម៌ទេសនា អធិការដ្ឋានពុទ្ធិកសិក្សា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ អធិការកិច្ច និងសាមីជន ត្រូវអនុវត្តតាមសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

**រដ្ឋមន្ត្រី**

ហត្ថលេខា និង ត្រា

**ជា សាវឿន**

ចម្លងជូន :

- ក្រសួងពត៌មាន " ដើម្បីជ្រាបជាពត៌មាន "
- ឯកឧត្ដមរដ្ឋលេខាធិការ
- ឯកឧត្ដមអនុរដ្ឋលេខាធិការ
- គ្រប់អង្គភាពចំណុះក្រសួង " ដើម្បីជូនជ្រាប "
- ដូចប្រការមួយ " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

# ពុទ្ធសាសនា និង ចរិយធម៌

មនុស្សយើងជាសត្វសង្គម រស់នៅក្នុងសង្គម មានឥទ្ធិពលលើសង្គម និងទទួលឥទ្ធិពលពីសង្គមគ្រប់ពេលវេលា ។ សង្គមនឹងទៅជាសង្គមល្អ ក៏ព្រោះមនុស្សក្នុងសង្គមជាមនុស្សល្អដែរ ។ មនុស្សល្អ គឺមនុស្សដែលមានមារយាទល្អ, មារយាទថ្លៃថ្នូរ ។

ណ្ហើយ ! អត្ថគម្ពីរភាពទុកនាទីអោយអ្នកសង្គមវិទូ និងអ្នកបរមត្ថទៅចុះ ក្នុងទីនេះ យើងនិយាយងាយៗ ទៅតាមមើលឃើញ ទៅតាមដឹង មិននិយាយទៅតាមជើងគម្ពីរសុទ្ធពេកទេ ។

ព្រះពុទ្ធសាសនា មានព្រះវិន័យបញ្ញត្តិ ជាខបង្គាប់មិនអោយធ្វើ និងព្រះធម៌ ជាខអនុញ្ញាតអោយប្រព្រឹត្តតាម ទាំងបព្វជិត ទាំងគ្រហស្ថ សមល្មមតាមឋានៈ និងវ័យ ជាគោលដែលមនុស្សគ្រប់រូបឋិបត្តិបាន ។ ភាពជាអ្នកមានមារយាទល្អ មារយាទថ្លៃថ្នូរ ជាចរិយធម៌ដែលបុគ្គលគ្រប់រូប គ្រប់វ័យ ត្រូវប្រតិបត្តិជានិច្ច, ព្រះពុទ្ធសាសនា បានសំដែងចរិយាដើម្បីអប់រំមនុស្សអោយមានមារយាទល្អ, មារយាទថ្លៃថ្នូរ ដូចតទៅនេះ :

១. អប់រំអោយវៀរការបៀតបៀនគ្នា មិនថាដោយផ្លូវត្រង់ ឬ ផ្លូវអម, អោយចិញ្ចឹមជីវិតតែក្នុងផ្លូវប្រពៃ ( សម្មាអាជីវៈ ) អោយចេះជួយគ្នាទៅវិញទៅមក តាមកម្លាំងដែលអាចធ្វើបាន ។

២. អប់រំអោយនិយាយតែពាក្យពិត មានសារប្រយោជន៍, សមតាមបុគ្គល, ស្ថានទី និងកាលសម័យ ។

៣. អប់រំអោយមានសុចរិតទៀងត្រង់ចំពោះមុខងារ នាទី, ខ្មាសបាប ខ្លាចបាប ជាដើម ។

ព្រះពុទ្ធទ្រង់បញ្ញត្តិវិន័យ ក៏ដើម្បីរក្សាសេចក្តីរៀបរយ មានសាមគ្គី រស់នៅជាមួយគ្នាដោយមេត្តាធម៌ មានការយោគយល់គ្នាទៅវិញទៅមក ។ បើសង្គមមនុស្សប្រព្រឹត្តតាមឱវាទដែលព្រះពុទ្ធបានសំដែងទុក យ៉ាងហោចត្រឹមតែសីល ៥ ក៏គង់បានប្រយោជន៍ និងសេចក្តីសុខច្រើនជាងអ្នកមិនប្រព្រឹត្តដែរ ។ តើសីល ៥ មានសេចក្តីសំខាន់ដូចម្តេចខ្លះ ក្នុងការអប់រំអោយក្លាយេសភាពពីមនុស្សអាក្រក់ មកជាមនុស្សល្អ ? សីល ៥ នោះគឺ :

**១. បាណាតិបាត** *អោយវៀរសម្លាប់សត្វ ។ ខនេះ ប្រដៅអោយបណ្តុះពូជ គឺ មេត្តាករុណាដល់មនុស្សសត្វគ្រប់ប្រភេទ, មិនអោយប្រទូសរ៉ាយបៀតបៀនរាងកាយដល់គ្នានឹងគ្នាគ្រប់វិធី ។*

**២. អទិន្នាទាន** *អោយវៀរការលួច ។ ខនេះ ជាការហាមមិច្ឆាជីវៈ ( រកស៊ីទុច្ចរិត ), អោយប្រឹងប្រែងរកស៊ីដោយកម្លាំង និងសេចក្តីអង់អាចរបស់ខ្លួនគឺ សម្មាអាជីវៈ ( រកស៊ីចិញ្ចឹមជីវិតក្នុងផ្លូវសុចរិត ) ។*

**៣. កាមេសុ មិច្ឆាចារ** *អោយវៀរការប្រព្រឹត្តខុសក្នុងកាម ។ ខនេះ ប្រដៅអោយមានសន្តោស ត្រេកអរចំពោះតែភរិយារបស់ខ្លួន ដើម្បីការពារការបែកបាក់គ្នាក្នុងពួក ក្នុងក្រុម អោយមានការទុកចិត្តគ្នាទៅវិញទៅមក ។*

**៤. មុសាវាទ** *ហាមមិនអោយនិយាយកុហក ក៏ដើម្បីអោយមនុស្សចេះសាងប្រយោជន៍ដោយពាក្យសំដី និងសាងមិត្តភាពរវាងមនុស្សផងគ្នា ។*

**៥. សុរា** *ហាមមិនអោយផឹកទឹកស្រវឹង, ប្រយោជន៍កុំអោយមនុស្សភ្លេចខ្លួនក្នុងការសាងឋានៈ និងធ្វើជីវភាពអោយផុតចាកដំណៀលផ្សេងៗដែលកើតអំពីការប្រព្រឹត្តរាយមាយ ។*

*សីល ៥ នេះជាគោលមូលដ្ឋានដំបូងបង្អស់ សំរាប់អបរំមនុស្សអោយ*

មានសណ្តាប់ធ្នាប់ត្រឹមត្រូវល្អ ។

បើយើងពិចារណាទៅតាមហេតុផលពិតៗ អាចឃើញថាសីល ៥ នេះ ជាកាតព្វកិច្ចរបស់សង្គមមនុស្សត្រូវតែប្រព្រឹត្ត ព្រោះមនុស្សយើង ដោយធម្មជាតិ រមែងស្អប់ខ្ពើមការប្រទូសរ៉ាយ កាប់សម្លាប់គ្នា, លួចប្លន់ ប្រវ័ញ្ចទ្រព្យសម្បត្តិគ្នា, លួចប្តីកូនប្រពន្ធគ្នាតាមចិត្តចង់, និយាយភូតភរ បញ្ឆោតគ្នា ។ ការមិនមានរបៀបរៀបរយក្នុងសង្គម ក៏ព្រោះតែមនុស្សមិនចេះគោរពសិទ្ធិគ្នា, ប្រព្រឹត្តរំលោភលើរាងកាយ, ទ្រព្យសម្បត្តិគ្នា តាមអំពើចិត្ត ។

ចំពោះសីលទី ៥ គឺ « សុរា » តាមទស្សនៈអ្នកខ្លះ ជាពិសេស ទស្សនៈអ្នកនិយមសុរាថា សុរានាំអោយឆ្ងាញ់បាយ បើផឹកច្រើនទើបអោយទោស ; ខ្លះថា សុរានាំអោយមានសតិបញ្ញា ។ តើអ្នកអានយល់យ៉ាងណា ?

រឿងសុរានេះ តាមទស្សនៈព្រះពុទ្ធសាសនា ថាជាកិច្ចត្រូវវៀរអោយផុត ។ ព្រោះហេតុថា សុរាជាប្រភពនៃសេចក្តីវិនាសច្រើនយ៉ាងណាស់ ។ ក្នុងគម្ពីរព្រះត្រៃបិដក មានសំដែងបញ្ជាក់ទោសកើតអំពីការផឹកសុរា ៦ យ៉ាងគឺ :

១. សុរា នាំអោយខាតបង់ទ្រព្យ ។ ជីវិតយើង បើខ្វះអាហារនឹងត្រូវស្លាប់, ចំណែកសុរា បើមិនផឹក ក៏មិនស្លាប់ដែរ ។ ហេតុនោះ សុរាចាត់ជាវត្ថុធ្វើអ្នកផឹកអោយចាយវាយទ្រព្យដោយមិនចាំបាច់ ។

២. សុរា នាំអោយកជម្លោះ ។ អ្នកដែលផឹកសុរា ដោយច្រើនធ្វើអ្វីខុសពីមនុស្សធម្មតា អាចនិយាយឡកឡឺយអោយកូនប្រពន្ធគេ ឥតខ្មាសអៀនឥតកោតញញើត, បើមានគេធ្វើអោយខុសចិត្ត សូម្បីតែបន្តិចបន្តួច ក៏បញ្ចេញសេចក្តីខឹងដូចភ្លើងឆេះព្រៃ បណ្តាលអោយមានជម្លោះ វាយតប់ កាប់សម្លាប់គ្នា ។ ការវិវាទគ្នាព្រោះឥទ្ធិពលសុរា មានច្រើនជាងរឿងដទៃទាំងអស់ ។

៣. សុរា នាំអោយកើតរោគ ។ សុរាជាថ្នាំពិសមួយបែប តែជាថ្នាំពិស

មិនធ្វើសេចក្ដីអន្តរាយដល់អ្នកផឹកភ្លាមៗ ដូចថ្នាំពិសឯទៀតទេ, ជាថ្នាំពិស អោយទោសពិបាកយល់ គឺអោយបន្តិចម្ដងៗ បើមិនសង្កេត មិនដឹង ; សុរា បន្ថយកម្លាំងកាយ និងជីវិតអ្នកផឹកគ្រប់ពេលវេលា ។

តាមតម្រាបរទេស បានបញ្ជាក់រោគដែលកើតព្រោះការផឹកសុរា មានច្រើនប្រភេទណាស់ ដូចជា :

ក) សុរា ធ្វើក្រពះអាហារ និងពោះវៀន អោយដំបៅ,

ខ) សុរា ធ្វើអ្នកផឹកអោយញ័រដៃជើង ភ្នែកស្រវាំង វិកលចរិត ដែលគេហៅថា « ឆ្កួតសុរា » ។

គ) សុរា បើផឹកតែល្មមសមគួរ ធ្វើជីពចរអោយមានចលនារហ័សជាងប្រក្រតី បើផឹកច្រើន ធ្វើជីពចរអោយខ្សោយ មានចលនាមិនស្មើគ្នា វែងខ្លីៗ ទីបំផុតក៏បាត់ស្មារតី ។

ឃ) សុរា នាំអោយកើតរោគទឹកនោមផ្អែម ឈឺតាមសន្លាក់ដៃជើង បេះដូងតាំង ( ឈប់ដើរ ) ។

ង) សុរា នាំអោយអ្នកផឹកដកដង្ហើមឃើតៗ មិនស្មើគ្នា ។

មិនតែប៉ុណ្ណោះ សុរានាំអោយកើតរោគច្រើនប្រការទៀតគឺ រោគស្រវឹងស្រា, រោគគ្រុនព្រោះសុរា, រោគនឿយណាយអាហារ មិនទឹកឃ្លាន, ស្ពឹកស្រពន់ , ភ្លេចងាយ, និយាយផ្ដេសផ្ដាស, ... ។

៤) សុរា នាំអោយត្រូវដំណៀល ។ យ៉ាងណាមិញ, អ្នកស្រវឹងស្រាដោយច្រើនសំដែងកិរិយាមិនគួរមើល មិនគួរស្ដាប់ ធ្វើសេចក្ដីរំខានដល់អ្នកជិតខាង ដោយការច្រៀងរាំរឡេវឡ ប្រព្រឹត្តអំពើលាមកផ្សេងៗ, សូម្បីតែផឹកហើយព្យាយាមរក្សាមារយាទយ៉ាងល្អ ក៏គង់ត្រូវគេរិះគន់ តិះដៀល ប្រមាថថាជាមនុស្សប្រមឹកដែរ ; នឹងទៅទីស្ថានណា ច្រើនសាងសត្រូវដើម្បីខ្លួនឯង ។

៥) សុរា នាំអោយមិនចេះខ្មាសអៀន ។ មនុស្សយើង តាមធម្មតាមានសេចក្ដីខ្មាសអៀន នឹងទៅណាមកណា តែងតែស្លៀកពាក់រៀបរយ បើនិយាយក៏ប្រយ័ត្នសំដី, តែបើត្រូវពិសសុរាចូលហើយ ក្លាយជាមនុស្សមានការគិតប្លែកៗ ប្រព្រឹត្តខុសទំនង ដូចជា ដេកតាមផ្លូវដើរក៏បាន អង្គុយលើវត្ថុស្មោកគ្រោកក៏បាន អាក្រាតកាយក្នុងទីសាធារណៈក៏បាន ធ្វើកាយវិការមិនគួរមើលក៏បាន គឺថា អោយតែស្រវឹង សុទ្ធតែ « ក៏បាន » ទាំងអស់ ។

៦) សុរា ធ្វើអោយខ្សោយបញ្ញា ។ បញ្ញាជាគុណសម្បត្តិ គឺការឈ្លាសវៃ ស្គាល់ល្អ អាក្រក់ នឹងការវិនាស-ចំរើន, បញ្ញាកើតមាន ព្រោះហេតុឧស្សាហ៍ ៣ យ៉ាងគឺ : ស្ដាប់ . គិត . អប់រំ (*) ។ ចំណែកមនុស្សប្រមឹក គ្មានឱកាសនឹងប្រកបហេតុទាំង ៣ យ៉ាងនេះទេ រវល់តែគិតរឿងសុរា ឬរឿងនៃសេចក្ដីវិនាសផ្សេងៗ តាមតែសុរាដឹកនាំអោយធ្វើ, ដោយហេតុនេះ បញ្ញាទើបកើតមិនបាន សូម្បីតែមានហើយ ក៏ត្រូវសាបសូន្យទៅវិញជាប្រាកដ ។

គម្រាពេទ្យមាននិយាយថា សុរាដែលផឹកចូលទៅ រមែងធ្វើខួរក្បាលអោយថយគុណសម្បត្តិ ម្ដងបន្តិចៗ, នឹងគិតអ្វីៗ ច្រើនមានលក្ខណៈរាយមាយ, មិនច្បាស់លាស់, អស់សេចក្ដីវាងវៃ ។

សេចក្ដីដែលពណ៌នាមកប៉ុណ្ណេះ ជាការតបឆ្លើយនឹងទស្សនៈអ្នកសុរានិយមបានដោយគ្រប់គ្រាន់ ហើយក៏បញ្ជាក់អោយឃើញថា សីល ៥ មានសារសំខាន់យ៉ាងណាខ្លះ, បើមនុស្សមិនប្រព្រឹត្ត តើមានអ្វីកើតឡើង ។ សូមអ្នកអានពិចារណា តាមការគួរ ។

**ឱម ខែម**

(*) សុតាមយបញ្ញា . ចិន្តាមយបញ្ញា . ភាវនាមយបញ្ញា ។

# សន្តិភាព
# ក្រោមពន្លឺ និង ម្លប់នៃពុទ្ធសាសនា

ពន្លឺពុទ្ធសាសនា គឺពុទ្ធវចនៈដែលព្រះពុទ្ធអង្គបានសំដែងទូន្មានសាវ័ក និងពុទ្ធបរិស័ទអស់រយៈពេល ៤៥ ឆ្នាំ ហើយដែលមកដល់ពេលនេះ ត្រូវបានគេចងក្រងបោះពុម្ពជាគម្ពីរព្រះត្រៃបិដកនេះឯង ។ គឺព្រះត្រៃបិដកនោះឯងហើយ ដែលជាពន្លឺ និងជាមគ្គុទ្ទេសក៍ប្រាប់ផ្លូវនាំទៅកាន់សេចក្តីសុខពេញលេញ សុភមង្គល សេចក្តីក្សេមក្សាន្ត និងសន្តិភាព សំរាប់មនុស្សទូទៅលើសកលលោក ។

ម្លប់ពុទ្ធសាសនា គឺអហិង្សា គឺសន្តិភាព គឺខន្តី ។ សន្តិភាព គឺជាទិសដៅកំពូលរបស់ពុទ្ធសាសនា ។ ស្មារតីខន្តី ( សន្តោស, អធ្យាស្រ័យ ) ជាឧត្តមគតិមួយជាទីនិយមបំផុតនៃវប្បធម៌ និងអរិយធម៌ពុទ្ធសាសនា ក្នុងអំឡុងប្រវត្តិសាស្ត្រដ៏វែងជាង ២៥០០ ឆ្នាំកន្លងទៅ ។ ហឹង្សា ( អំពើឃោរឃៅ ) ក្នុងរូបភាពបែបណាមួយក៏ដោយ ក្រោមលេសអ្វីមួយក៏ដោយ គឺជាអំពើប្រឆាំង និងជាអំពើផ្ទុយស្រឡះនឹងពាក្យប្រៀនប្រដៅ គឺព្រះធម៌ របស់ព្រះសម្មាសម្ពុទ្ធ ។

នៅសល់ពេលតែជាង ២០០ ម៉ោងទៀត សតវត្សនៃសង្គ្រាមនឹងត្រូវបញ្ចប់ពេលវេលារបស់ខ្លួន, យើងនឹងធ្វើដំណើរទៅដល់ក្លោងទ្វារនៃសតវត្សថ្មី គឺសតវត្សនៃសន្តិភាព ។ តួនាទីសំខាន់សំរាប់ពេលបច្ចុប្បន្ន និងអនាគតរបស់កម្ពុជាក្នុងសតវត្សថ្មី គឺវប្បធម៌សន្តិភាព វប្បធម៌អហិង្សា រស់នៅសុខដុមរមនាក្នុងស្មារតីខន្តី ស្មារតីបង្រួបបង្រួមឯកភាពជាតិ ប្រកដោយក្តីស្រឡាញ់រាប់អានគ្នា មានភាពអត់ឱនគ្នា យោគយល់គ្នា សន្តោសប្រណីគ្នា ក្នុងមេត្តាធម៌ យុត្តិធម៌ សច្ចធម៌ ដើម្បី

ឈោងចាប់វឌ្ឍនភាព ភាពថ្កើងថ្កានរុងរឿងឡើងវិញ មានឋានៈស្មើមុខស្មើមាត់នឹងប្រទេសនានា ក្នុងសហគមន៍ប្រជាធិបតេយ្យអន្តរជាតិ ។

បទពិសោធន៍ និងវិចារណញ្ញាណបានបង្ហាញថា យើងនឹងអាចរកផ្លូវសុខសាន្តមួយ ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិរបស់យើងបាន លុះត្រាតែយើងទាំងអស់គ្នាស្រុះចិត្ត មូលគំនិត យកព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ជាវិធីអប់រំកាយចិត្ត ដើម្បីជម្រុះចោលនូវគំនិតគុំគួន បៀតបៀន ច្រណែនឈ្នានីស សងសឹកគ្នា តាមមធ្យោ-បាយហឹង្សា ។

សង្គ្រាមប្រទូសរ៉ាយគ្នាដោយអាវុធជាង ៣ ទសវត្ស ត្រូវបានបញ្ចប់ហើយ, ស្មារតីហឹង្សានិយម វិធីបណ្តុះគំនិតចងកំហឹង គំនុំគុំគួន តាមរយៈពាក្យសំដីដែលនៅមានសេសសល់ក្នុងអារម្មណ៍ទាំងប៉ុន្មាន ត្រូវតែលុបបំបាត់ កុំអោយនៅមានចងកម្ម ចងពៀរនឹងគ្នា តទៅទៀត ព្រោះថា « ពៀរមិនអាចរម្ងាប់ដោយពៀរបានទេ » ។ និយាយរួម, យើងនាំគ្នាឈប់ត្រូវការវប្បធម៌ចងកំហឹង ឬបណ្តុះកំហឹងទៀត, ប៉ុន្តែយើងត្រូវការវប្បធម៌សន្តិភាព វប្បធម៌បណ្តុះចិត្តគំនិតសន្តិភាពក្រោមពន្លឺ និងម្លប់នៃពុទ្ធសាសនា ដើម្បីអោយកូនចៅយើងមានអារម្មណ៍ស្ងប់ស្ងាត់រស់នៅក្នុងសន្តិភាព, ក្នុងបរិយាកាសយោគយល់គ្នា, ចេះអធ្យាស្រ័យដល់គ្នានឹងគ្នា, ហើយរួបរួមគ្នាពង្រឹងសាមគ្គីភាព ឯកភាពជាតិ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា និងកសាងប្រទេសអោយរីកចំរើន នៅក្នុងសតវត្សថ្មីនេះ ។

ជាការពិត, ពុំមានសេចក្តីសុខណាប្រសើរជាងសន្តិភាពឡើយ *( នត្ថិ សន្តិ បរំ សុខំ )* ។ ដើម្បីមានជីវិតសន្តិភាព ព្រះពុទ្ធជាបរមគ្រូរបស់មនុស្ស និងទេព្តាបានទូន្មានសាវ័ក និងពុទ្ធបរិស័ទថា :

*១. សព្វបាបស្ស អករណំ* លះបង់សេចក្តីអាក្រក់ ឬអំពើអកុសលគ្រប់យ៉ាង ។

២. *កុសលស្សូបសម្បទា* បំពេញសេចក្តីល្អ ឬសាងកុសលកម្ម ។

៣. *សចិត្តបរិយោទបនំ* សំអាតចិត្តអោយបរិសុទ្ធ ។

ពាក្យថា « *លះបង់សេចក្តីអាក្រក់ ឬអំពើអកុសលគ្រប់យ៉ាង* » មានន័យថា ឈប់ធ្វើអំពើអាក្រក់ថោកទាបទាំងពួង ដូចជា ការសម្លាប់សត្វមានជីវិត ការលួចប្លន់ កេងប្រវ័ញ្ចទ្រព្យសម្បត្តិគេ ឬទ្រព្យសម្បត្តិជាតិ និងការប្រព្រឹត្តខុសក្នុងកាម គឺទៅលបលួចរួមរក្សស្នេហាជាមួយប្តីប្រពន្ធកូនគេ ជាដើម ដែលជាហេតុនាំអោយគេរងទុក្ខទោស ក្តៅក្រហាយ ពោលគឺ ការបញ្ឈប់អំពើរំលោភឈ្លានពានទៅលើសិទ្ធិសេរីភាពអ្នកដទៃ និងបញ្ឈប់ការបំផ្លិចបំផ្លាញផលប្រយោជន៍ខ្លួនឯង និងអ្នកដទៃឯទៀត ។

ពាក្យថា « *បំពេញសេចក្តីល្អ* » មានន័យថា ការប្រព្រឹត្ត ឬកសាងកុសលកម្ម ពោលគឺ ការធ្វើអំពើល្អគ្រប់បែបយ៉ាង ដូចជា ការធ្វើទាន ការជួយសង្គ្រោះអាយុជីវិតគេ ការជួយឧបត្ថម្ភអ្នកឯទៀត អោយរួចផុតពីភាពអត់ឃ្លាន ពីភាពក្រីក្រ ពីភាពឈឺថ្កាត់ និងពីភាពល្ងង់ខ្លៅ ឬដូចជា ការបំពេញនូវសង្គហធម៌ ជួយសង្គ្រោះគ្នាទៅវិញទៅមក រវាងមាតាបិតា និងបុត្រធីតា រវាងគ្រូបាធ្យាយ និងសិស្សានុសិស្ស រវាងភរិយា និងស្វាមី រវាងអ្នកដឹកនាំគេ និងអ្នកដែលត្រូវគេដឹកនាំ ឬរវាងព្រះសង្ឃ និងគ្រហស្ថ ... ដើម្បីអោយអ្នកដទៃទទួលបាននូវសេចក្តីសុខ សេចក្តីចំរើន ពោលគឺ ការខំប្រឹងប្រែងសាងជីវិតសន្តិភាព និងវឌ្ឍនភាពជូនសង្គមជាតិ និងជូនមនុស្សជាតិ ក្នុងពិភពលោកទាំងមូល ។

ចំណែកពាក្យថា « *សំអាតចិត្តអោយបរិសុទ្ធ* » មានន័យថា ការខំប្រព្រឹត្តប្រតិបត្តិធម៌អាចិ ធ្វើចិត្តរបស់ខ្លួនអោយឃ្លាតចាកកិលេស គឺលោភៈ ទោសៈ មោហៈ ដែលជាឫសគល់នៃអកុសលធម៌ រហូតដល់ធ្វើអោយកិលេសតណ្ហាគ្រប់ជំពូករលត់រលាយពីខ័ន្ធសន្តាន ។

ដូច្នេះ ការឈប់ធ្វើបាប ឬការបញ្ឈប់នូវអំពើរំលោភឈ្លានពានគេ ដែលធ្វើអោយគេរងទុក្ខទោស មានសេចក្តីក្តៅក្រហាយ ឈឺចាប់ មានឈ្មោះថាជាការលះបង់សេចក្តីអាក្រក់ ។ ការធ្វើល្អ សាងសេចក្តីសុខចំរើនជូនសង្គមជាតិ និងមនុស្សជាតិក្នុងសកលលោក មានឈ្មោះថាជាការបំពេញសេចក្តីល្អ ឬការសាងបុណ្យ ។ ឯការធ្វើខ្លួនអោយស្រោលចាកកិលេសតណ្ហា ឬការធ្វើអោយអស់ទៅនូវលោភៈ ទោសៈ មោហៈ ពីខន្ធសន្តាន មានឈ្មោះថា ការសំអាតចិត្តអោយបរិសុទ្ធ ។

វិធី ឬមធ្យោបាយ សំរាប់ប្រតិបត្តិនូវពុទ្ធឱវាទទាំង ៣ ខាងលើនេះអោយបានសំរេចផលល្អ គឺ ពុទ្ធបរិស័ទគ្រប់រូប ត្រូវតែពង្រឹងការប្រតិបត្តិតាមមាគ៌ានៃជីវិត ៨ យ៉ាងគឺ អដ្ឋង្គិកមគ្គ ដែលមាន សីល សមាធិ បញ្ញា ជាគ្រឹះ សំដៅបង្កើតអោយបាននូវសេចក្តីសន្តោស ទស្សនះយោគយល់គ្នា រស់នៅជាមួយគ្នាក្នុងសុខ សន្តិភាព ជានិរន្តរ៍ ! ។ អដ្ឋង្គិកមគ្គនោះគឺ :

១. *សម្មាទិដ្ឋិ* ការយល់ឃើញត្រូវ

២. *សម្មាសង្កប្បៈ* ការត្រិះរិះត្រូវ

៣. *សម្មាវាចា* ការនិយាយត្រូវ

៤. *សម្មាកម្មន្តៈ* ការងារត្រូវ

៥. *សម្មាអាជីវៈ* ការចិញ្ចឹមជីវិតត្រូវ

៦. *សម្មាវាយាមៈ* ការព្យាយាមត្រូវ

៧. *សម្មាសតិ* ការរលឹកត្រូវ

៨. *សម្មាសមាធិ* ការតាំងចិត្ត ឬតម្កល់ចិត្តត្រូវ

មាគ៌ានៃជីវិតដ៏ប្រសើរ ៨ យ៉ាងនេះ លោកចាត់ទុកថាជា « បញ្ញាសិក្ខា » សំរាប់អប់រំខាងបញ្ញា ឬសំរាប់អភិវឌ្ឍន៍បញ្ញាផង ជា « សីលសិក្ខា » សំរាប់អប់រំកាយ វាចា អោយមានវិន័យ អោយមានសណ្តាប់ធ្នាប់ល្អ អោយមានសីលធម៌ រស់

នៅក្នុងសង្គមបានសុខចំរើន ឬសំរាប់អភិវឌ្ឍន៍កាយវាចាផង ជា « សមាធិសិក្ខា » សំរាប់អភិវឌ្ឍន៍ចិត្តផង ។

ការពង្រឹងការប្រតិបត្តិតាមមាគ៌ាទាំង ៨ នេះ ពិតជាមធ្យោបាយជួយជំរុញអោយទទួលបាននូវជីវិតសន្តិភាព សំរាប់ខ្លួនឯង និងសំរាប់មនុស្សលោកទូទៅ ។

• សីលសិក្ខា ការរៀនអប់រំកាយវាចាអោយមានវិន័យ មាន សីលធម៌ខ្ពស់ គឺការអភិវឌ្ឍន៍កាយវាចានោះ ត្រូវអោយអ្នកប្រតិបត្តិប្រកបដោយ ព្រហ្មវិហារធម៌ ៤ យ៉ាងគឺ :

១. *មេត្តា* ការស្រលាញ់រាប់អានគ្នា មិនប្រកាន់រើសអើងគ្នា,

២. *ករុណា* ការអាណិតអាសូរគ្នា ជួយសង្គ្រោះគ្នា ជួយដោះទុក្ខធុរៈគ្នា,

៣. *មុទិតា* ការជួយអបអរសាទរចំពោះអ្នកដទៃ ដែលបានសុខចំរើនហើយ,

៤. *ឧបេក្ខា* ការរៀនដាក់ចិត្ត ឬតាំងចិត្តអោយនៅកណ្តាលស្មើៗ ដោយមិនអោយធ្លាក់ចុះទៅក្នុងអគតិធម៌ទាំង ៤ យ៉ាងគឺ :

- *ឆន្ទាគតិ* ( លំអៀងព្រោះស្រឡាញ់ ឬព្រោះប្រាថ្នាផលប្រយោជន៍ផ្ទាល់ខ្លួន )
- ទោសាគតិ ( លំអៀងព្រោះស្អប់ ឬព្រោះខឹង )
- *មោហាគតិ* ( លំអៀងព្រោះវង្វេង ឬព្រោះល្ងង់ខ្លៅ មិនស្គាល់ការពិត )
- ភយាគតិ ( លំអៀងព្រោះភ័យខ្លាច ) ។

• សមាធិសិក្ខា ការសិក្សាអប់រំបន្ទំចិត្តអោយនឹងធឹង និងអប់រំចិត្តអោយស្ថិតនៅក្នុងអារម្មណ៍តែមួយមានប្រយោជន៍ ធ្វើអោយមនុស្សដែលមានចិត្តអប់រំល្អប្រពៃហើយនោះ មើលឃើញ យល់ដឹង និងស្គាល់អ្វីដែលជាការពិត ឬជាសច្ចធម៌នោះ គឺជាការអភិវឌ្ឍន៍ចិត្ត ។

• ចំណែក បញ្ញាសិក្ខា គឺការសិក្សាបណ្តុះបណ្តាលអោយមានចំណេះដឹងទូទៅ ទាំងផ្លូវលោក ទាំងផ្លូវធម៌ គឺការអភិវឌ្ឍន៍បញ្ញា ។ ការអភិវឌ្ឍន៍បញ្ញា ការអភិ-

វឌ្ឍន៍កាយ វាចា និងការអភិវឌ្ឍន៍ចិត្ត ធ្វើអោយមនុស្សមានវិន័យ មានសីលធម៌ មានព្រហ្មវិហារធម៌ និងប្រកាន់ខ្ជាប់នូវយុត្តិធម៌សង្គម ហើយជំរុញអោយមនុស្សចេះដោះស្រាយបញ្ហាគ្រប់បែបយ៉ាងក្នុងជីវិតដោយសន្តិវិធី ឬដោយវិធីអហឹង្សា ។

សរុបសេចក្តី ព្រះធម៌ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សំដែង បើនិយាយអោយខ្លី គឺសំដែងប្រដៅសង្កត់ទៅលើសច្ចធម៌ ប្រដៅអោយអ្នករៀន អ្នកស្តាប់ ដឹងពិតឃើញពិតតាមសភាវៈ, ប្រដៅមនុស្សអោយស្គាល់ផ្លូវល្អ គួរប្រព្រឹត្ត ជាធម៌អាចនាំយកមកបដិបត្តិបាន ជាធម៌ប្រើក្នុងការបដិរូបសង្គម ឬការងាររបស់មនុស្សគ្រប់ជាន់-ថ្នាក់ គ្រប់វ័យ អោយល្អ ចំរើនល្វតលាស់ និងនាំមកនូវសុខសន្តិភាព ។ ព្រះពុទ្ធជាម្ចាស់ ជាអ្នកសង្គមមួយរូប ទ្រង់ឃើញសេចក្តីសំខាន់នៃសង្គម ទើបទ្រង់ឧទ្ទិសកម្លាំងព្រះកាយ និងព្រះទ័យដើម្បីសង្គម; ព្រះអង្គបានលះសេចក្តីសុខផ្ទាល់ព្រះអង្គធ្វើការអោយជាប្រយោជន៍ដល់សង្គម ទ្រង់យាងទៅតាមជនបទតូច-ធំ ប្រដៅមនុស្សអោយចេះអប់រំខ្លួន ដើម្បីសេចក្តីស្ងប់ស្ងាត់ចាកសភាវៈអាក្រក់ពោលគឺ កិលេស ដរាបទ្រង់ចូលព្រះនិព្វាន ។ កិច្ចការដែលព្រះអង្គទ្រង់ធ្វើនោះមាននៅសល់ដរាបដល់បច្ចុប្បន្ននេះ និងទៅក្នុងអនាគតទៀតជារអង្វែង ។

សេចក្តីដែលពណ៌នាមកប៉ុណ្ណេះ បញ្ជាក់អោយឃើញថា « សន្តិភាពក្រោមពន្លឺ និងម្លប់នៃពុទ្ធសាសនា » មានសារសំខាន់យ៉ាងណាខ្លះ, សូមអ្នកអានពិចារណា និងចូលចិត្ត តាមការគួរ ។

**ឌិម ខែម**

**វិចារណកថា**

# សម្ដេច ជួន ណាត
# ជាអ្នកប្រាជ្ញកើតពីសង្គមខ្មែរដ៏បរិសុទ្ធ

គួរអោយស្ដាយណាស់ ដែលធម្មជាតិមិនអាចមិនប្រែប្រួល ។ ជីវិតដែលកើតឡើងត្រូវតែស្លាប់ ។ ជីវិតសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ក៏មិនអាចមានករណីពិសេសដែលធម្មជាតិលើកលែងបានដែរ ព្រះអង្គបានលាចាកលោកនេះទៅដោយស្ងៀមស្ងាត់ បន្ទាប់ពីបានបំពេញព្រះសកម្មភាពក្នុងព្រះឋានៈជាអ្នកប្រាជ្ញខ្មែរក្នុងវិស័យពហុវិជ្ជា ដើម្បីព្រះពុទ្ធសាសនា វប្បធម៌ និងសន្តិភាព ។ នៅក្នុងចុងឆ្នាំទី ៨៦ នៃព្រះជន្មាយុ ដែលត្រូវនឹងថ្ងៃទី ២៥ កញ្ញា ឆ្នាំ ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ទ្រង់សោយព្រះទិវង្គតក្នុងកណ្ដាលព្រះសកម្មភាពរបស់ព្រះអង្គ ក្រោយពីទ្រង់ប្រឈួនតែ ៣ ថ្ងៃប៉ុណ្ណោះ ដោយបានបូជាព្រះកាយ និងព្រះសតិបញ្ញា ដើម្បីព្រះពុទ្ធសាសនា និងប្រជាជាតិខ្មែរ ដែលទ្រង់ជាមហាបុរសស្នេហាជាតិមាតុភូមិយ៉ាងមាំ ។

ពិធីប្រារព្ធធ្វើបុណ្យខួប ៣០ ឆ្នាំ នៃការសោយព្រះទិវង្គតសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ( ២៥ កញ្ញា ១៩៦៩ - ២៥ កញ្ញា ១៩៩៩ ) បានប្រព្រឹត្តទៅនៅក្នុងបរិវេណនៃពុទ្ធសាសនបណ្ឌិត្យ រយៈពេល ៣ ថ្ងៃ គឺថ្ងៃទី ២៤ - ២៥ - ២៦ ខែកញ្ញា ឆ្នាំ ១៩៩៩ ដើម្បីរំលឹកឧបការគុណដែលព្រះអង្គមានចំពោះប្រទេសជាតិទាំងខាងវិស័យវប្បធម៌ អក្សរសាស្ត្រ អប់រំ សាសនា តាមសកម្មភាពទូន្មានប្រៀនប្រដៅ និងស្នាព្រះហស្តដ៏ច្រើនដែលព្រះអង្គបានរៀបរៀង និងនិពន្ធឡើង ពុំអាចបំភ្លេចបានឡើយ ។

សម្ដេចទ្រង់ប្រសូតនៅថ្ងៃអង្គារ ១១ រោច ខែផល្គុន ព.ស ២៤២៧ ត្រូវនឹងថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៨៨៣ នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ព្រះបិតានាម **ជួន** ព្រះមាតានាម **យក់** ។ គ្រួសារនេះមានបុត្តតែពីរនាក់ គឺ **សម្ដេច** និងឧកញ៉ាសោភ័ណមន្ត្រី **ជួន នុត** ។

កាលនៅជាកុមារ បានសិក្សាអក្សរ និងលេខ ដរាបដល់ជន្មាយុ ១៤ ឆ្នាំ បានបួសជាសាមណេរ នៅវត្តពោធិព្រឹក្ស ( ហៅ វត្តពោល្យំ ) សង្កាត់រលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ ពីរឆ្នាំក្រោយមក, សម្ដេចបានចូលសិក្សាបរិយត្តិធម៌ នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ លុះជន្មាយុគ្រប់ ២១ ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុ នៅវត្តពោធិព្រឹក្ស ដែលជាវត្តដើម ដោយទ្រង់ទទួលនាមបញ្ញត្តិថា **ជោតញ្ញាណោ** រួចនិមន្តត្រឡប់ទៅគង់នៅវត្តឧណ្ណាលោមវិញ ។

សម្ដេចព្រះសង្ឃរាជ **ជួន ណាត** (ជោតញ្ញាណោ) ជាអ្នកប្រាជ្ញជាតិមួយអង្គ ដែលបានទទួលព្រះឋានៈជា *អគ្គមហាបណ្ឌិត* នៃសហភាពភូមា ក្នុងឆ្នាំ ១៩៥៤ និងជា *អភិធជមហារដ្ឋគុរុ* នៃសហភាពភូមា ពីរដ្ឋាភិបាលនៃសហភាពភូមា ក្នុងឆ្នាំ ១៩៥៧ និងបានទទួលព្រះឋានៈជា *បណ្ឌិតអក្សរសាស្ត្រ* ដំបូងបង្អស់ ពីមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ នៃភូមិន្ទសកលវិទ្យាល័យ ភ្នំពេញ ក្នុងឆ្នាំ ១៩៦៧ ដែលសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋ ទ្រង់បានប្រទានថ្វាយផ្ទាល់ ។

សម្ដេច **ជួន ណាត** គឺជាអ្នកប្រាជ្ញដែលកើតពីសង្គមខ្មែរដ៏បរិសុទ្ធ ។ អ្នកប្រាជ្ញនីមួយៗ តែងដុះចំណោះប្រាជ្ញាភ្លឺប្រុះសុសសព្វមុខវិជ្ជាណាមួយរបស់ខ្លួន ។ ការដុះចំណោះប្រាជ្ញានេះ ជួនកើតមកពីសិក្សាសន្សំដោយខ្លួនឯង ជួនចេះដោយការសិក្សាពីគ្រូបាធ្យាយ ។ ក្នុងបណ្ដាអ្នកប្រាជ្ញទាំងពីរសណ្ឋាននេះ សម្ដេច **ជួន ណាត**

ស្ថិតក្នុងអ្នកប្រាជ្ញសណ្ឋានទីមួយ គឺថា លោកបានសន្សំសន្សំចំណេះប្រាជ្ញាដោយខ្លួនឯង តាមរយៈ សុ. ចិ. បុ. លិ. ( ស្តាប់, គិត, សួរ, សរសេរ ឬកត់ត្រា ) ។ ហេតុបានជាយើងហ៊ានពោលដូច្នេះ ព្រោះសម័យដែលលោកមានវ័យនៅក្មេងនោះ ស្រុកយើងពុំទាន់មានសាលារៀនត្រកុំត្រកាល ដូចសព្វថ្ងៃនេះទេ ទោះជាសាលាសិក្សាផ្លូវលោកក្តី ផ្លូវសាសនាក្តី ។ ម្យ៉ាងទៀត សមបើសម្តេចលោកកើតនៅស្រុកស្រែ ( ភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ) ដែលជាស្រុកមួយ នៅក្បែនកោះថែមទៀត នោះក៏រឹងរឹតតែលង់ក្នុងភពជ្រៅណាស់ទៅទៀត ។ បើលោកអ្នកធ្លាប់ទៅលេងដល់ភូមិកំរៀង ស្រុកភូមិកំណើតព្រះអង្គ ក៏រឹតតែកើតអនិច្ចាខ្លាំងណាស់ទៅទៀត រហូតដល់ឈរភាំង រំពឹងគិត ជញ្ជឹងគិតម្នាក់ឯងថា សម្តេចព្រះសង្ឃរាជ លោកកើតក្នុងភូមិនេះសោះ ម្តេចឡើយក៏ទៅជាអ្នកប្រាជ្ញបានហ្នំ ! ។ ទិដ្ឋភាពស្រុកភូមិនេះ នាំឱ្យយើងឃើញច្បាស់ថា ការរៀនសូត្ររបស់សម្តេច ពិតជាផុសចេញពីសង្គមខ្មែរដ៏បរិសុទ្ធ គឺខ្មែរគ្មានលាយវប្បធម៌បរទេសណាទេ បើទោះជាលាយឡំបាលី-សំស្ក្រឹត ក៏ជាបាលី-សំស្ក្រឹតរបៀបខ្មែរ ដែលធ្លាប់រលាយមកក្នុងទំនៀមទម្លាប់ខ្មែរ រាប់ពាន់ឆ្នាំហើយដែរ ហើយចំណេះវិជ្ជាទាំងអស់សោត ក៏សុទ្ធតែកើតឡើងពីការប្រមូលសន្សំ ចេះចាំ កត់ត្រាទុក ពីគ្រប់ទិសទី មជ្ឈដ្ឋានអ្នកស្រែចំការខ្មែរសុទ្ធសាធ ។ លុះលោកមានវ័យចំរើនឡើងហើយ ទើបលោកនិមន្តទៅសិក្សានៅទីក្រុង បានភពប្រសព្វនឹងអរិយធម៌អ្នកក្រុង ស្គាល់ឥទ្ធិពលអរិយធម៌បរទេសខ្លះ ដែលបានមកលបលួចច្របល់ចូលក្នុងអរិយធម៌ខ្មែរ ក្នុងមជ្ឈដ្ឋានអ្នកក្រុងទាំងនេះ ។ បើទោះបីជាលោកបានជួបប្រទះ ដឹង អរិយធម៌ក្លាយទាំងនេះក្តី សម្តេច **ជួន ណាត** ព្រះអង្គទ្រង់ក៏មិនក្រេបជាទម្លាប់ផ្ទាល់ព្រះអង្គដែរ ទ្រង់គ្រាន់តែចេះ ហើយចំណាំទុក ថានេះជាអរិយធម៌គេមួយដែរ តែខ្មែរយើងនៅឯនេះទេ មិនមែនដូចគេទេ ។ ការសិក្សារបស់លោក កាន់តែជ្រៅទៅ ៗ ត្រូវចេះ ត្រូវ

ស្គាល់ អក្សរ-ភាសា-អរិយធមិបរទេសផ្សេងៗ រហូតដល់ត្រូវទៅបន្តវិជ្ជាឯបរទេសទៀត ប៉ុន្តែ ចំណេះដឹងថ្មីៗទាំងប៉ុន្មាន គ្រាន់តែបង្កើនអោយលោកមានការយល់ទូលាយខ្សែនេត្រាវែងឆ្ងាយ ធ្វើការផ្ទុះផ្ទឹមគ្នាបានគ្រប់ទិសតែប៉ុណ្ណោះ ឯមូលដ្ឋានដើមខ្មែរ នៅតែជិតដក់ជាប់ក្នុងព្រះទ័យដដែល ឥតល្អៀង ឥតរង្គើឡើយ ។ ដោយវិរិយភាពមោះមុត និងគុណធមិរបស់ព្រះអង្គ សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានក្លាយជាអ្នកប្រាជ្ញមួយព្រះអង្គក្នុងវិស័យពហុវិជ្ជា និងជាស្ថាបនិកដ៏ឧត្ដមលើវិស័យវប្បធមិសន្តិភាព ដែលមានកិត្តិនាមល្បីល្បាយជាអន្តរជាតិ បីដូចផ្កាឈូកដុះចេញពីភក់ល្បប់ ។

អ្នកផងទទួលស្គាល់ គោរពលោក មិនមែនស្គាល់ និងគោរព ព្រោះតែលោកចេះអរិយធមិបរទេសខ្ពង់ខ្ពស់ ហាពន្យល់ឡើង សូត្រទ្រឹស្ដី សូត្រសុភាសិត សូត្រគម្រោងផែនការ តាមបរទេសណាមួយឡើយ គឺ លោកសូត្រតែសុភាសិតខ្មែរ ទំនៀមខ្មែរសុទ្ធៗ ហើយជាទំនៀម ឬចំណេះដែលខ្មែរកប់ជ្រៅណាស់មកហើយ ហើយខ្មែរធម្មតាយល់មិនដល់ ។ បើមានជនបរទេសណាម្នាក់ ឬយុវជនណាមួយចូលសាកសួរលោកពីរឿងខ្មែរ ទោះជារឿងអ្វីក៏ដោយ អោយតែក្នុងអរិយធមិខ្មែរ លោកមិនដែលថាមិនចេះ មិនដឹងឡើយ ។ មិនតែប៉ុណ្ណោះ លោកណែនាំពន្យល់ទាល់តែអ្នកនោះឯងស្ដាប់បាន ចូលចិត្តបាន អស់មន្ទិលសង្ស័យថែមទៀត ។

ជាការពិតណាស់, វរជន អ្នកប្រាជ្ញក្មេងៗ ក៏ពុំអាចមានថាមភាព និងប្រសិទ្ធភាពស្មើព្រះអង្គបានឡើយ ។ នៅក្នុងពុទ្ធិកវិទ្យាល័យ, ពុទ្ធិកមហាវិទ្យាល័យ, នៅក្នុងពុទ្ធសាសនបណ្ឌិត្យ, នៅក្នុងគណៈកម្មការនានា និងក្នុងអង្គការផ្សេងៗ ខាងអក្សរសាស្ត្រ សម្ដេចព្រះសង្ឃរាជទ្រង់ជាសាស្ដា និងជាអ្នកចាត់ចែងដឹកនាំ ឧបត្ថម្ភជានិច្ច ។ ជាងនេះទៅទៀត ការងារដ៏ធ្ងន់ក្រៃលែងនេះ ពុំមែនតម្កល់ព្រះអង្គត្រឹមតែជាអ្នកនិពន្ធពហុផលប៉ុណ្ណោះទេ ពិសេស ព្រះអង្គជាកវី ដែលក្រៅអំពីស្នាព្រះហស្ត

ទាំងឡាយ គឺមានពាក្យពេចន៍ បទចំរៀង " នគររាជ " ដែលទ្រង់និពន្ធនៅដើមរាជ្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ក្នុងឆ្នាំ ១៩៤៧ ។

ដូច្នេះ ការចេះដឹងធ្លុះធ្លាយទាំងអស់នេះរបស់សម្ដេច កើតពីក្បួនណា ? កើតពីសាស្ត្រាចារ្យណា ? . គ្មានទេ ! គឺកើតពីការសិក្សាស្រាវជ្រាវផ្ទាល់ព្រះអង្គ ។ បើទ្រង់ឃើញអ្វីប្លែក ហើយឆ្ងល់ ក៏ដេញដោលសួររកហេតុផល យកមកពិចារណា ភ្លាម តាំងពីអក្សរ ភាសា ទំនៀមទម្លាប់ សិល្បៈ . ល . ។ នេះយើងមិននិយាយ ពីរឿងធម៌-វិន័យ ដែលលោកចេះចាំម៉ត់ចត់ ចាំរហូតទាំងលេខទំព័រ លេខបន្ទាត់ ទាល់តែទីប្រជុំផ្ទៀងផ្ទាត់ធម៌-វិន័យ ក្នុងឆដ្ឋសង្គាយនា នៅរង្គូន ( ប្រទេសភូមា ) តាំងលោកជាអគ្គមហាបណ្ឌិតនោះផងឡើយ ។

និយាយដោយខ្លី សម្ដេចព្រះសង្ឃរាជ **ជួន ណាត** មួយជីវិតលោក លោកបូជាជីវិតទាំងស្រុងក្នុងពុទ្ធសាសនា ក្នុងអរិយធម៌ខ្មែរ និងវប្បធម៌សន្តិភាព គឺ ថា លោកមិនអោយពេលវេលារបស់លោកក្នុងនាទីណាមួយកន្លងទៅ ដោយមិនគិត ពីអរិយធម៌ខ្មែរនោះទេ ។ ដូច្នេះ ក្នុងព្រះជន្ម ៨៦ ឆ្នាំរបស់សម្ដេច ពិតជា ៨៦ ឆ្នាំ ដែលឋិតក្នុងការសាង ការគិតពីអរិយធម៌ខ្មែរទាំងស្រុង ។ ការដែលលោកបានទទួល សញ្ញាប័ត្រថ្នាក់អគ្គមហាបណ្ឌិត រហូតដល់ថ្នាក់អភិធជមហារដ្ឋគុរុ ពីប្រទេសភូមាក្ដី និងបណ្ឌិតអក្សរសាស្ត្រខ្មែរ ពីភូមិន្ទសកលវិទ្យាល័យភ្នំពេញក្ដី សុទ្ធតែពុំមែនលោក ដាក់ខ្លួនសរសេរវិញ្ញាសាធីប្រឡង ដូចជនធម្មតាឡើយ គឺពិតជាមេប្រយោគទាំងនោះ អត់ទ្រាំមិនបាន ព្រោះឃើញសកម្មភាព ថ្វីព្រះហស្តនោះឆ្អិនឆ្អៅ ជាក់លាក់ រកអ្នក ផ្ទឹមគ្មានពីបែបខ្មែរសុទ្ធនោះ គេក៏នាំគ្នាតែងតាំងឡើងពេញលក្ខណៈ ពេញសមត្ថភាព មិនមែនជាការបញ្ចើចបញ្ចើគ្រាន់ជានាទីកិត្តិយសនោះឡើយ ។ ព្រះកិត្តិស័ព្ទរបស់ សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានល្បីសុសសាយរហូតដល់ក្រៅប្រទេស ដែល ទ្រង់ត្រូវបានប្រទេសអ្នកកាន់ពុទ្ធសាសនាទាំងឡាយ ចាត់ទុកព្រះអង្គថាជាមហាអ្នក

ប្រាជ្ញខាងព្រះពុទ្ធសាសនាមួយអង្គ លើផ្ទៃរាបអន្តរជាតិ ។

ក្រៅពីព្រះសកម្មភាពខាងសាសនា វប្បធម៌ ព្រះអង្គបានបំពេញនូវកិច្ចការស្ថាបនាជាតិ ជាសាធារណប្រយោជន៍ច្រើន មានការសាងថ្នល់ ស្ពាន អគារសិក្សា គិលានដ្ឋាន ជាដើម ។

ហេតុនេះ យើងតែងនាំគ្នាចាំច្បាស់ថា សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ជាអ្នកប្រាជ្ញកើតចេញពីសង្គមខ្មែរដ៏បរិសុទ្ធ គឺពុំមែនពោលតែពីរឿងវង្សត្រកូលទេ គឺនិយាយពីសង្គមចំណេះវិជ្ជារបស់លោកនោះឯង ។ ការសោយព្រះទិវង្គតនៃសម្ដេចព្រះសង្ឃរាជ **ជួន ណាត** គឺជាការបាត់បង់មួយដ៏ធំធេងរបស់ពុទ្ធសាសនា និងរបស់ជាតិយើង ដែលរហូតមកដល់បច្ចុប្បន្ន ចន្លោះប្រហោងនៃការបាត់បង់នេះ ពុំទាន់បានបំពេញនៅឡើយ ។

ព្រះរូបព្រះកាយសម្ដេចព្រះសង្ឃរាជ **ជួន ណាត** រលត់បាត់មែន តែក្នុងដួងចិត្តនៃកុលបុត្តកុលធីតាខ្មែរ សំគាល់ថា សម្ដេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់មានព្រះជន្មនៅឡើយ ពោលគឺ « *វត្តមាន និងនិច្ចភាពនៃសម្ដេច ជួន ណាត* » ឋិតនៅជានិរន្តរ៍ ជាមួយប្រជាជាតិខ្មែរ, ព្រះអង្គទ្រង់ជានិមិត្តរូបនៃសាមគ្គីភាព ឯក-ភាពជាតិ និងភាពបរិសុទ្ធ ។ ព្រះរូបសម្ដេចបាត់មែន តែព្រះកេរ្តិ៍ និងព្រះនាមរបស់ព្រះអង្គ ពិតជាពុំបាត់ទៅផងទេ, ព្រះអង្គបានបន្សល់ទុកជាមរតក នូវស្នាព្រះហស្តជាច្រើន ដែលពោរពេញទៅដោយឱវាទដ៏មានខ្លឹមសារ សំរាប់ការប្រតិបត្តិ និងការចេះដឹងរបស់យើងគ្រប់ពេលវេលា ។

សូមប្រជាពលរដ្ឋខ្មែរ បរិបូរដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួមគ្នាកសាងប្រទេស និងលើស្ទួយព្រះពុទ្ធសាសនារបស់ជាតិ តាមគំរូវិរិយភាព និងព្រះសកម្មភាពសម្ដេច អោយបានរីកចំរើនជាភិយ្យោភាព តរៀងទៅ !

**ឱម ខែម**

# សិលាចារឹកថ្មី ពីរ Ka 77 (*) នៅភូមិណាផាង និង សិលាចារឹកបន្ទាយធំព Ka 67 នៅថ្មពួក

## TWO NEW ANGKOREAN INSCRIPTION Ka 77 AT NAPHANG VILLAGE AND Ka 67 AT BANTEAY TOAP TEMPLE, THMO PUOK DISTRICT

ដោយ **ខង់ សុធារ៉ា**
សាស្ត្រាចារ្យ នៃដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា
សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ

### ១. សិលាចារឹកភូមិណាផាង Ka 77 ខេត្តសាកលនគរ ប្រទេសថៃ
An Inscription Of Naphang Village Ka 77 In Sakalnakorn Province, Thailand

សិលាចារឹកនេះ គេរកឃើញនៅក្នុងរូងភ្នំមួយ នាភូមិណាផាង តំបន់កក់ប្លាសីវ ខេត្តសាកលនគរ ប្រទេសថៃបច្ចុប្បន្ន ។ អត្ថបទ គេចារនៅលើផ្ទាំងថ្មដុលជាអក្សរខ្មែរចំនួន ៦ បន្ទាត់ ដោយមានកាលបរិច្ឆេទឆ្នាំ ៩៨៨ នៃមហាសករាជ ដែលត្រូវនឹងគ្រឹស្តសករាជ ១០៦៦ គឺស្ថិតនៅក្នុងរាជ្យព្រះបាទឧទយាទិត្យវរ្ម័នទី ២ (១០៥០ - ១០៦៦ គ.ស.) ឬព្រះបាទហសិវរ្ម័នទី ៣ (១០៦៦ - ១០៨០ គ.ស. ) ។

(*) លេខក្នុងបញ្ជីសិលាចារឹកទើបរកឃើញថ្មី នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលរៀបចំឡើងដោយបណ្ឌិត មីសែល ត្រាណេ ។ ចំណែកនៅក្នុងបញ្ជីរបស់លោក ក្លូដ ហ្សាក ថា សិលាចារឹកថាមផ្រា K 1153 ។

លោក មីសែល ត្រាណេ ជាអនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអោយផ្ដាំងសិលាចារឹកនេះមកខ្ញុំ ដើម្បីសិក្សាបកប្រែ ហេតុនេះខ្ញុំមិនដឹងថា គេបានសិក្សា និងបោះពុម្ពផ្សាយនៅសៀវភៅណាមួយនោះទេ ។

អត្ថបទចារឹកនេះ បានបញ្ជាក់អំពីការស្ថាបនាព្រះ គួរគំនួរ និងធ្វើពិតាន ( ប្រហែលធ្វើអំពីកំណាត់សំពត់ ) ថ្វាយដល់ព្រះគ្រូនាម *សោមង្គល* នាឆ្នាំ ១០៦៦ គ.ស. ) ខាងចុងអត្ថបទបញ្ជាក់ថា លោកអាចារ្យឈ្មោះ *ធមិប្ញូរ* ជាអ្នកចារសិលាចារឹកនេះ ។ ចំណែកពាក្យ « ព្រះ » ដែលគេប្រើនៅក្នុងអត្ថបទ មិនអាចអោយយើងសន្និដ្ឋានបានថាតើគេប្រើសំដៅលើអាទិទេពនៃព្រហ្មញ្ញសាសនា ឬក៏ ព្រះពុទ្ធ-បដិមាបានឡើយ ។ ក៏ប៉ុន្តែ យើងសង្កេតឃើញថា គេបានថ្វាយគំនួរជាពិសេស « ពិតាន » ដែលយើងសង្កេតឃើញថា មានតែព្រះពុទ្ធបដិមាប៉ុណ្ណោះ ដែលបរិស័ទនិយមធ្វើកំណាត់ សំរាប់ចងជាពិតានប្រក់ពីលើ ។ ពតិមាននេះមានច្រើន នៅសិលាចារឹកនគរវត្ត សម័យក្រោយអង្គរ ។

រីឯនៅសម័យអង្គរជាមួយគ្នានេះ រាល់តង្វាយដល់ទីអាសនៈរបស់ព្រះ ឬអាទិទេពនៃសាសនាព្រាហ្មណ៍ យើងកត់សំគាល់ឃើញថា កម្រមានតង្វាយជា « ពិ-តាន » សំរាប់ប្រក់លើបដិមាព្រះ[*] ណាស់ ។

ខាងក្រោម ជាអត្ថបទសិលាចារឹកទាំងស្រុង ដែលសរសេរជាអក្សរសម័យសព្វថ្ងៃ :

១. ៩៨៨ ឝកតតិទឝមីរោច

២. ជ្យេស្ឋចន្រ្ទវារតិនុស្បុប្រតិ

៣. ម្ពូវ្រះនេះរីវ្រះនេះនុគំនួរ

៤. នេះនុំវិតាននេះក្រាតគ្រុរ

(១) ចង់និយាយសំដៅអាទិទេពទាំងឡាយក្នុងព្រហ្មញ្ញសាសនា ។

៥. សោមង្គល អាចាយ៌ធ

៦. មិបូរតឆ្លោកប្រឝម្ដនេះ

## អត្ថបទជាអក្សរកុំព្យូទ័រ

១ ស៧៧ឝកតគិទឝមីរោច

២ ជ្យេឞ្ឋចន្ទ្រវារគិនុសុប្រតិ

៣ ឞ្ឋវ្រះនេះរិវ្រះនេះនុគំន្វរ

៤ នេះនុវិតាននេះក្រាតគុរុ

៥ សោមង្គល៑អាចាយ៌ធ

៦ រ្មបុរតឆ្លោកប្រឝម្ដនេះ

## អត្ថបទជាអក្សររ៉ូម៉ាំង

1- 988 çaka ta gi daçamī roc

2- jyeṣṭha candravāra gi nu suprati

3- ṣṭha vraḥ neḥ ri vraḥ neḥ nu gaṃnvar

4- neḥ nu vitāna neḥ krā ta guru

5- somaṅgala °ācāryadha

6- rmapura ta chlok praçaṣta neḥ

## អត្ថបទប្រែ

(១) នៅឆ្នាំ ៩៨៨ នៃមហាសករាជ ត្រូវនឹងថ្ងៃ ១០ រោច ( ២ . ៣ ) ខែជេស្ឋ ថ្ងៃច័ន្ទ ព្រះបដិមានេះត្រូវបានស្ថាបនាឡើង រីឯព្រះនេះ និងគំនូរ (៤) នេះ និងពិតាន ( ធ្វើពីកំណាត់ ) នេះក្រា ( ក្រាល ឬថ្វាយ ? ) ដល់លោកគ្រូ ( ៥.៦ ) សោមង្គល ។ អាចារ្យ ធមិបូរ ចារឆ្លាក់ស្លោកចារឹកនេះ ។

## ២. សិលាចារឹកប្រាសាទបន្ទាយទ័ព Ka 67 នៅស្រុកថ្មពួក

An Inscription of Banteay Toap Temple
Ka 67 at Thmo Puok District

បើតាមលោក មីសែល ត្រាណេ សិលាចារឹកនេះត្រូវបានគេរកឃើញនៅប្រាសាទបន្ទាយទ័ព ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីពេលថ្មីៗនេះ ។ ខ្ញុំបានទទួលរូបថតនៃសិលាចារឹកនេះពីគាត់ នាថ្ងៃទី ២០ កញ្ញា ១៩៩៩ ក្នុងពេលជួបគ្នាក្នុងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

សិលាចារឹកនេះមាន ៧ បន្ទាត់ សរសេរជាភាសាសំស្ក្រឹត ១ បន្ទាត់ និងភាសាខ្មែរ ៦ បន្ទាត់ ។ កន្លងមក នៅភូមិថ្មពួក [១] គេបានរកឃើញសិលាចារឹកមួយផ្ទាំងដែរ ជាភាសាសំស្ក្រឹត ចុះកាលបរិច្ឆេទឆ្នាំ ៩៨៩ គ.ស. ។ ចំណែកសិលាចារឹកនេះវិញ ចុះកាលបរិច្ឆេទឆ្នាំ ១០៤៧ គ.ស. គឺស្ថិតនៅក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី ១ (១០០២ - ១០៥០ គ.ស.) ។

ភាសាសំស្ក្រឹតមួយបន្ទាត់ បញ្ជាក់អំពីបទនមស្ការចំពោះព្រះគ្រូទាំងឡាយ ដែលមានព្រះសិវៈដ៏ជាព្រះគ្រូកំពូល រីឯភាសាខ្មែរចំនួន ៦ បន្ទាត់ បញ្ជាក់អំពីអ្នកស្ថាបនាឈ្មោះ « វ្រះកម្រតេងអញ [២] ត្រីភុវនបតិន្ទ្រវម៌្ម » ដែលបានសាងសំរេចនូវប្រាសាទរបស់អាទិទេព « ស្រីព្រៃទ្ធេស្វរៈ » ឬ « កំម្រតេងជគតត្រីវ្ធទ្ធេស្វរ » នៅឯស្រុក « ត្រីភុវនបតិន្ទ្របុរ » គឺតំបន់ថ្មពួក ដែលជាទីតាំងនៃប្រាសាទសព្វថ្ងៃនេះឯង ។

ខាងក្រោម ជាអត្ថបទសិលាចារឹកដើមទាំងស្រុង ដែលយើងលើកយក

(១) ស្រុកស្វាយចេក ខេត្តបាត់ដំបង បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ ។

(២) ប្រហែលជាព្រះអង្គម្ចាស់មួយអង្គ ឈ្មោះនូបតិន្ទ្រវរ្ម័ន ដែលត្រួតត្រានៅតំបន់នោះ ។

មកសរសេរជូន :

១. ឱំនមឝ្ឝិវាទិភ្យោគុ្យភ្យ (ះ)

២. ៹ ៩៦៩ ឯកាទឝិកេតចៃត្រ

៣. នុកំម្រតេងជគតឝ្រីវ្ឫទ្ធេ

៤. ត្វរ (តតា) តវាត្រអាយត្រី

៥. ន្វប តិន្ទ្របុរនេះតិរោះ

៦. ហ កល្យណាវ្រះកម្រតេ

៧. ងអញត្រីន្ទ្វបតិន្ទ្រវមិ

## អក្ខរធាតុអក្សរកំពុងធំ (១)

១ ឱំនមឝ្ឝិវាទិភ្យោគុ្យភ្យះ

២ ៹៩៦៩ឯកាទឝិកេតចៃត្រ

៣ នុកំម្រតេងជគតឝ្រីវ្ឫទ្ធេ

៤ ត្វរតាតវាត្រអាយត្រី

៥ ន្វប តិន្ទ្របុរនេះតិរោះ

៦ ហ កល្យណាវ្រះកម្រតេ

៧ ងអញត្រីន្ទ្វបតិន្ទ្រវមិ

## អក្ខរធាតុអក្សររ៉ូម៉ាំង

1- Oṃ namaç çivā dibhyo gubhya [ḥ]

2 - ° 969 ekādaçi ket caitra

3 - nu kaṃmrateṅ jagat çrīvṛddhe

(១) អក្សរនេះខ្ញុំបានបង្កើតឡើង ដើម្បីកត់ត្រាអក្សរសិលាចារឹកទាំងឡាយ ដែលស្ថិតក្នុងអំឡុងសតវត្សទី ១០-១១ ក្រោមកម្មវិធីអ្នកស្ម័គ្រចិត្តសហប្រជាជាតិនៅកម្ពុជា សហការជាមួយអង្គការយូណេស្កូ ។

4 - çvara [ ta tā ] ta vātra āy çrī
5- nṛpatindrapura neḥ gi roḥ
6- ha kalpanā vraḥ kamrate
7- ṅ añ çri nṛpatindravarma

## អត្ថបទបកប្រែ

១. ឱ ! សូមនមស្ការថ្វាយបង្គំចំពោះព្រះគ្រូទាំងឡាយ ដែលអង្គព្រះសិរវដ៏ជាព្រះគ្រូកំពូល

២. ៩៦៩ (១) មហាសករាជ ១១ កើត (ខែ) ចែត្រ (៣-៤) នូវអាទិទេពស្រី ព្រៃទ្វេស្វរ .... នៅឯស្រុកស្រីនឫបតីន្ទ្របុរនេះ (៥-៧) ដែលព្រះគម្តែងអញស្រីនឫបតិន្ទ្រវ៌្មន បានស្ថាបនាអោយសម្រេចជាស្ថាពរ ។

## វាក្យានុក្រម និងអត្ថន័យ

| | | |
|---|---|---|
| កល្បណា (សំ.) | kalpanā Ka 67,6 | = ស្ថាបនាសម្រេច |
| កេត | Ket Ka 67,2 | = កើត កេ្មីត យប់ខែភ្លឺ |
| កំម្រតេងជគត | Kaṃmrateṅ jagat Ka 67,3 | = បច្ចេកពាក្យសំគាល់ ប្រាសាទ ឬអាទិទេព |
| កំម្រតេងអញ | Kaṃmrateṅ añ Ka 67,6-7 | = ឋានន្តរនាមជាន់ខ្ពស់របស់ ខ្មែរបុរាណ |
| ក្រា | Krā Ka 77,4 | =? ឈ្មោះសត្វល្អិតមួយប្រភេទ ដែលតោងស៊ីស្លឹករុក្ខជាតិ |
| គិ | gi Ka 77,1,2 ; Ka 67,5 | = គឺ នោះឯង នេះឯង ទីនោះ |

(១) ត្រូវនឹង គ.ស. ១០៤៧

| | | |
|---|---|---|
| គុរុ ( សំ. ) | guru Ka 77,4 | = គ្រូ |
| គំនួរ | gaṃnvar Ka 77,3 | = គំនូរ |
| ចន្ទ្រវារ ( សំ. ) | candravāra Ka 77,2 | = ថ្ងៃច័ន្ទ |
| ចៃត្រ ( សំ. ) | caitra Ka 67,2 | = ឈ្មោះខែទី ៥ នៃចន្ទគតិ គឺខែចែត្រ |
| ឆ្លោក | Chlok Ka 77,6 | = ឆ្លាក់អត្ថបទ, សរសេរស្លោក |
| ជ្យេឞ្ឋ ( សំ. ) | jyeṣṭha Ka 77,2 | = ឈ្មោះខែទី ៧ នៃចន្ទគតិ គឺខែជេស្ឋ |
| ត | ta Ka 77,1,4,6; Ka67,4 | = (ឈ្នាប់) ដ៏ នៃ របស់ ដែល |
| ទឝមី ( សំ ) | daçamī Ka 77,1 | = ទី ១០ |
| ធម៌បុរ ( សំ. ) | dharmapura 77,5-6 | = ឈ្មោះមនុស្ស (អាចារ្យម្នាក់) |
| នុ | nu Ka 77,1,3,4; Ka 67,3 | = និង ហើយ នៅ នូវ |
| នេះ | neḥ Ka 77,3,4,6; Ka 67,5 | = នេះ |
| ប្រឝស្ត ( សំ. ) | praçaṣṭa Ka 77,6 | = ប្រសាសន៍ ចារឹក អត្ថបទ |
| រិ | ri Ka 77,3 | = រី រឺង |
| រោច | roc Ka 77,1 | = រោច ឬ រោជ-រនោច យប់ខែងងឹត |
| រោះហ | roḥh Ka 67,5 | =រឿង សារតារ ថ្មីៗ អ្វីដែល កំពុងមើលឃើញ |
| វាត្រ ( សំ. ) | vātra Ka 67,4 | = ? |
| វិតាន ( សំ. ) | vitān Ka 77,4 | = ពិតាន |
| វ្រះ | vraḥ Ka 77,3; Ka 67,6 | = ព្រះ |

សុប្រតិដ្ឋ (សំ.) supratiṣṭha Ka 77,2-3 = ប្រតិស្ឋានយ៉ាងប្រសើរ

សោមង្គល (សំ.) somaṅgala Ka 77,5 = ឈ្មោះមនុស្ស ព្រះគ្រូមួយអង្គ

ឝក ( សំ. ) çaka Ka 77,1 = ឈ្មោះសករាជ ១ ដែលកើត ក្រោយ គ.ស. ៧៨ ឆ្នាំ

ឝ្រីនួបតិន្ទ្របុរ (ស្ថាននាម) çrī nṛpatindrapura Ka 67,5 = ស្រុក នួបតិន្ទ្របុរ

ឝ្រីនួបតិន្ទ្រវម៌(មន្ត្រី) çrī nṛpatindravarma Ka 67,7 = មន្ត្រីឈ្មោះ នួបតិន្ទ្រវ៌ន

ឝ្រីវ្ទ្ធេឝ្វរ ( ព្រះ ) çrī vṛddheçvara Ka 67,3-4 = អាទិទេព ព្រឹទ្ធេស្វរ ( ព្រះឥស្វរ )

អាចាយ៌ ( សំ. ) ācārya Ka 77,5 = អាចារ្យ

អាយ āy Ka 67,4 = ឯ ជិត នៅ នៅជិត

ឯកាទឝិ ( សំ. ) ekādaçi Ka 67,2 = ទី ១១

## ឯកសារពិគ្រោះ

1- Coedès Georges, *Inscritions du Cambodge,* Vol. II-VIII, Paris 1951-66.

2- Claude Jacques, *Inventaire des Nouvelles Inscriptions du Cambodge,* K 1051 à K 1205 ( ébauche )

3- POU, Saveros, *What is Khmerology,* in Kampuja Suriya Review, year 53rd, 1999 № 1-2, pp.27-43 and 36-45, Phnom Penh.

4- POU, Saveros, *An Old Khmer-French-English Dictionary,* CEDORECK, Paris 1992.

# សិលាចារឹកភូមិណាដាង Ka 77
# ខេត្តសាកលនគរ ប្រទេសថៃ



# សិលាចារឹកបន្ទាយធំព Ka 67
# ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ



# ប្រវត្តិនៃការលេងខ្លែងឯក " មេកូន " និងផលប្រយោជន៍

នៅប្រទេសកម្ពុជាយើង ខ្មែរលេងបង្ហើរខ្លែងកំសាន្តសប្បាយ តែងប្រព្រឹត្តទៅក្នុងរដូវលំហើយ ( ត្រូវគ្នានឹងរដូវ អូតូន (Automne) ប្រទេសបារាំងសែស ) ។ បើគិតតាមបែបសុរិយគតិ គឺមួយរដូវមានបីខែ ហើយរដូវលំហើយនេះ ( សរទរដូវ ) ចាប់ផ្តើមរាប់ពីថ្ងៃ ២៣ កញ្ញា ដល់ថ្ងៃ ២១ ធ្នូ មាន ៩០ ថ្ងៃ ។ ពេលខ្លះខ្មែរយើងលេងរហូតរដូវបន្ទាប់ទៀត គឺ សិសិររដូវ ( រដូវរងារខ្លាំង ) ត្រូវនឹងរដូវបារាំង ( អ៊ីវែរ Hiver ) ។ ប៉ុន្តែ បើយើងគិតតាមចន្ទគតិវិញ មានតែបីរដូវទេ ក្នុង ១ រដូវមាន ៤ ខែ ។ ផ្តើមរាប់ពីត្រឹមថ្ងៃ ២២ ធ្នូ ដល់ថ្ងៃ ២០ មីនា មាន ៨៩ ថ្ងៃ ឬជួនកាល មាន ៩០ ថ្ងៃ ។ ចំពោះចន្ទគតិនេះ ខ្មែរយើងលេងបង្ហើរខ្លែង នៅហេមន្តរដូវ ។

ពេលអោយខ្លីមក ខ្មែរយើងបង្ហើរខ្លែងនៅក្នុងខែ កក្តិក មិគសិរ ( ភាគច្រើន ) ។ ចំពោះមនុស្សវ័យចំណាស់ គេចូលចិត្តបង្ហើរខ្លែងឯក " មេកូន" (ខ្លែងធ្នូង) នៅពេលយប់ ក្នុងខែផល្គុន ព្រោះជំនោររាត្រីនាខែនោះស្មើល្អ មិនរលកគួចខ្លាំង ដូចកក្តិក មិគសិរឡើយ, ហើយរាត្រីចាប់ពីខែផល្គុនទៅ ខ្លែងអាចហោះហើរបានទល់ភ្លឺ មិនធ្លាក់ខ្លែងពីអាកាសទេ ។

## ប្រវត្តិខ្មែរបង្ហោះខ្លែងឯក " មេកូន " ( ខ្លែងធ្នូង )

នៅក្នុងពិភពលោកនេះ មានអ្នកនិយមចូលចិត្តលេងខ្លែងមិនតិចទេ នៅប្រទេសជាតិនិមួយៗ ។ ប៉ុន្តែ រូបរាងនៃខ្លែង គេធ្វើទៅតាមការចូលចិត្តរៀងៗខ្លួន

ទៅតាមការច្នៃប្រឌិតតាមបែបជាសត្វស្លាប ឬពោងហោះ ឬក៏ក្លស់ ដែលគេសង្កេតឃើញ ដូចជា ខ្លែងប្រចៀវ ខ្លែងកន្ទោង ខ្លែងកណ្តុង ខ្លែងប្រមង់ ខ្លែងកង្កែប ខ្លែងនាគ ខ្លែងព្រះខែ ខ្លែងកូនមាន់ ។ ល ។

ចំពោះខ្លែងខ្មែរយើង មានភាគច្រើនតាំងពីបុរាណកាលមក គេឃើញតែខ្លែងកណ្តុង និងខ្លែងឯក « មេកូន » ( ខ្លែងផ្នុង ) ដែលគេនិយមបង្ហើរលេងនៅតាមភូមិ ស្រុក ទូទាំងជនបទដែលរស់នៅ ហើយដែលមានប្រវត្តិវា បែបជារឿងនិទានប្រជាប្រិយផង ។

ប្រភពព្រេងនិទានមួយបានលើកឡើងថា កាលនោះមានព្រានប្រមាញ់ម្នាក់ឈ្មោះ លន់ ពណិ មានកូនប្រុសកំលោះពីរនាក់រស់នៅក្នុងបន្ទុក ។ ព្រានប្រមាញ់លន់ ពណិ តែងប្រើកូនកំលោះខ្លួនអោយនាំសត្វដែលបាញ់បានទៅលក់នៅទីផ្សារជារឿយៗ ។ ពេលមួយនោះ បុត្រីពីរអង្គរបស់មហាក្សត្រ បានយាងមកទតតាមទីផ្សារជនបទ ក៏បានប្រទះឃើញកំលោះទាំងពីរ យកសត្វប្រមាញ់ទៅលក់ក្នុងផ្សារដែរ តែពេលនោះកំលោះរូបស្អាតពីរនាក់បងប្អូន មានសត្វខ្លែងពណិមាសម្នាក់មួយ ដែលគេចិញ្ចឹមផ្សាំងតាំងពីតូចមក អោយទំលើស្មាគេម្នាក់មួយទៅជាមួយដែរ ។ ពេលនោះ បុត្រីស្តេចទាំងពីរអង្គបានទតឃើញកំលោះបងប្អូន ក៏ចាប់ព្រះទ័យប្រតិព័ទ្ធហើយទ្រង់សុំទិញសត្វខ្លែងដែលទំលើស្មាកំលោះនោះ ដើម្បីយកទៅបង្ហោះលេង ។ ប៉ុន្តែ កំលោះបងប្អូន ពុំបានព្រមលក់ថ្វាយព្រះរាជបុត្រីទាំងពីរអង្គនោះទេ ព្រោះស្រឡាញ់សត្វនេះតាំងពីតូចមក ព្រមទាំងបានផ្សាំងបង្ហាត់បានល្អផង ។ ក្រោយមកកំលោះកូនព្រានប្រមាញ់ទាំងពីរនាក់ ក៏ព្រមអោយបុត្រីក្សត្រខ្ចីបង្ហើរលេង ដោយចងខ្សែជាប់នឹងជើងខ្លែងពណិមាសនោះ ។

ការបង្ហោះលេងកំសាន្តព្រះទ័យនៃបុត្រីក្សត្រទាំងពីរអង្គនោះ បានធ្វើអោយសត្វអស់កម្លាំង រហូតដល់សត្វទាំងពីរស្លាប់អស់ទៅ ។ ក្រោយមក កំលោះ

ក្រមុំទាំងពីរគូ ក៏បានការស្ម័គ្រចិត្ត ស្មគ្រព្រះទ័យ រៀបចំអភិសេកជាគូស្វាមីភរិយានឹងគ្នាតទៅ ។ ពេលក្រោយមកទៀត គូស្រករទាំងពីរគូ បាននំរលឹកនឹកឃើញពីអនុស្សាវរីយ៍កំណើតស្នេហា គេបានធ្វើជាខ្លែងពាសក្រណាត់សំពត់ ដើម្បីបង្ហោះរំលឹកនារដូវលំហើយ ។ រួមទាំងកំលោះក្រមុំ កូនអ្នកស្រុកណាដែលចង់បានគូស្រករ ក៏ធ្វើខ្លែងបង្ហោះលេងនារដូវលំហើយ ។ ដោយហេតុនេះ ប្រវត្តិខ្លែងឯក « មេកូន » ( ព្នង ) ក៏ចាប់មានតាំងពីពេលនោះមក ។

ចំពោះពាក្យដែលខ្មែរយើងនិយមហៅថាខ្លែងព្នងនៅតាមតំបន់ខ្លះនោះ ក៏គួរយើងនិយមមកហៅថាខ្លែង « មេកូន » វិញទៅ ទើបសមរម្យជាង ។

ពាក្យ : ព្ន < វ្នង => វ្និ ( ង = ំ ) > ភ្នំ, ( អ្នកនគរភ្នំ ) ? ស្ងម្បីតែជនជាតិខ្មែរដើម ដែលកន្លងមក យើងតែងតែហៅថា ព្នងៗ នោះ ក៏រាជរដ្ឋាភិបាលពីសមម័យសង្គមរាស្ត្រនិយមបានហាមប្រាម ដោយចេញប្រកាសផ្សព្វផ្សាយ អោយហៅថា « ខ្មែរលើ » វិញដែរ ។

លោក ហ្ស៊កសឺដេស Gorge Cedès អ្នកសរសេរប្រវត្តិសាស្ត្រ សារ.តាររអំបូរខ្មែរយើងជាភាសាបារាំង, គាត់ក៏ជាអ្នកប្រាជ្ញប្រវត្តិវិទូនៃសាលាបារាំង ចុងបូព៌ាប្រទេស បានរកឃើញសិលាចារឹកមួយផ្ទាំង មានកាលបរិច្ឆេទតាំងពីដើមសត.វត្សទី១០ (972 jr) ដែលអត្ថន័យបានបញ្ជាក់ប្រាប់យើងថា ព្រះរាជា ក៏ធ្វើព្រះរាជពិធីបង្ហោះខ្លែងដែរ ពេលនោះមានតង្វាយជាច្រើនមុខ ច្រើនប្រភេទ : មាស សំរឹទ្ធ ប្រាក់ លង្ហិន ពាន លំពែង និងខ្លែង ៥ ទៀតផង ។

តាមឯកសារខ្លះទៀត ព្រះរាជពិធីបង្ហោះខ្លែងធ្វើឡើងដើម្បីរំលឹកព្រះចូឡាមណីចេតិយ នៅស្ថានត្រ័យត្រឹង្ស ដែលបានប្រារព្ធធ្វើឡើងចាប់ពីថ្ងៃ ១២ កើត រហូតដល់ថ្ងៃ ១៥ កើត ក្នុងខែមិគសិរ ដោយរៀបចំតុបតែងពិធីជា ៥ អន្លើ បាននិមន្តព្រះរាជគណៈ ចំរើនព្រះបរិត្តគ្រប់រោងទាំង ៥ ដែលមានតាំងខ្លែងចំនួន ៥ និងគោម

៥ ផង ។ ពិធីនេះប្រារព្ធធ្វើឡើងក្នុងរាជព្រះស្រីសុរិយោពណ៌ ដែលទ្រង់គង់នៅព្រះបរមរាជវាំងឧដុង្គមានជ័យ ក៏ដូចក្នុងរាជ្យព្រះហរិរក្សរាមាឥស្សរាធិបតី ( ព្រះអង្គខ្វង់ព្រះបិតារបស់ព្រះបាទ នរោត្តម និង ស៊ីសុវត្ថិ ) ក៏បានរៀបចំពិធីនេះដែរ ។

## ផលប្រយោជន៍នៃការលេងខ្លែង

ពិតជាមានផលប្រយោជន៍ច្រើនសំរាប់អ្នកលេងខ្លែង និងមានអាថិកំបាំងមួយផ្នែកធំទៀត ដែលយើងពិចារណាពុំទាន់បានសព្វជ្រុងជ្រោយ ។ ប៉ុន្តែពេលនេះយើងសូមលើកនូវចំណុចខ្លះៗ ដែលយើងបានយល់ដឹងពីល្បែងកំសាន្តនេះ ដូចជា ៖

- យើងបានបន្តវេនពីបុរាណផង ដែលបាក់នឹងបាត់បង់ មិនអាចអោយកូនខ្មែរយើងបានស្គាល់ខ្លែងឯក ឬខ្លែងមេកូន មិនបានអោយកូនខ្មែរយើងឃើញរូបរាង និងស្គាល់ច្បាស់ ព្រមទាំងចេះធ្វើឡើងវិញបន្តទៅទៀត ។

. បានបង្រៀនអប់រំកូនខ្មែរចេះធ្វើខ្លែង ដោយមានវិធីសាស្ត្រខ្លះៗ សំខាន់ដូចជា ៖ ចេះរើសឫស្សីចាស់ សាច់ស្វិតជាប់ល្អ ។ ចេះបិតឆ្អឹងបែបណានោះ ដែលជាសរួចហើយ បង្ហោះទៅនឹងល្អ ឡើងខ្ពស់ មិនចាក់ឆ្វេល គ្រវីក្បាល រាប់ទាំងរបៀបដាសទំហំ កំពស់ខ្លែង ត្រូវប្រើខ្សែបង្ហោះប៉ុនណា កន្ទុយប្រវែងណា ហើយត្រូវធ្វើយ៉ាងណាអោយកន្ទុយទាំងពីរបោះទៅហើយបើកកន្ទែកល្អ ។

ចំពោះ ឯក តើត្រូវចេះបិតដងបែបណា និងបិតអណ្តាតឯកបែបណា ទើបដងឯក និងអណ្តាតឯកឆ្លើយសូរសំឡេងបានច្រើនពាក្យ ហើយសំឡេងមិនស្អក ម្យ៉ាងទៀត វិធីបច្ចេកទេសចងសាយឯក និងបិតក្រមួនបែបណា ទើបឯកលាន់សូរពិរោះ និងត្រូវដឹងទៀតថា ត្រូវប្រើសាយឯកជាសរសៃអ្វី ( ម្នាស់ - សូត្រ ឬខ្សែនីឡុង ដង្ក ) ។

ចំពោះខ្សែទ្រូងខ្លែង ត្រូវចេះចងភ្ជួចប្រវែងណា វាស់ជាមួយខ្លែង ឬស្មាន

ទាញបែបណា ទើបខ្លែងបោះល្អ មិនតឹងខ្សែពេក អាចទប់នឹងខ្យល់ខ្លាំងម្តងម្កាល ។

នេះគឺការគិតរៀនដំបូង ដោយស្មារតីយកចិត្តទុកដាក់ ប្រយ័ត្នប្រយែង ខ្លាចខ្លែងដាច់ខ្សែ ដាច់កន្ទុយ ខ្លែងដាំដូង ចាក់ផ្ទៃល ធ្លាក់លើចុងឈើ ឬលើដំបូលផ្ទះគេ ។ នេះជាការបណ្តុះស្មារតីជំនាញអោយយុវជនចេះសម្រិតសម្រាំងស្នាដៃអ្វីមួយដែលខ្លួនត្រូវធ្វើ ក្នុងនោះបណ្តុះស្មារតីទាំងពីរ សម្រស់ និងសោភណភាព រូបរាងស្អាត ដើម្បីជាទម្លាប់អោយចេះស្រឡាញ់ភាពប្រណីត និងសមរម្យភ្នែកញាតិ ។

បានបន្ថយនូវចិត្តហិង្សាក្នុងខ្លួនអ្នកលេងខ្លែង ដែលកើតមានឡើងពីប្រការផ្សេងៗនៅក្នុងគ្រួសារ ឬនៅទីកន្លែងសាធារណៈនានា ព្រោះពេលឃើញខ្លែងហើរឡើង ហើយបោះល្អ ឯកពិរោះនោះ ចិត្តអារម្មណ៍បង្កើតបានក្តីសប្បាយ ភ្លេចអស់នូវបញ្ហាស្មុគស្មាញពីបញ្ហាផ្សេងៗ ។

- ពេលលេងខ្លែង ក្មេង ឬចាស់ ពិតជា ចៀសវាងបានពីល្បែងស៊ីសង អំពើអបាយមុខផ្សេងៗ ដូចជា ផឹកស៊ី ស្រា កញ្ឆា អំពើពុំគួរគប្បី ព្រោះស្មារតីគេព្យាយាមតែស្តាប់សូរឯក ភ្នែកគេលបឃ្លាំមើលខ្លែងដែលបោះ តើធ្លាក់ ឬដាច់ ឬក៏បែបណាតែរហូត ។

- អ្នកលេងខ្លែង ជាមនុស្សឧស្សាហ៍ព្យាយាមស្វិតស្វាញនឹងកិច្ចការ និងម៉ត់ប្រាយផង ។ បើខ្ជិល ខ្ជីខ្ជា មានស្មារតីធ្វេសប្រហែស គំនិតរាយមាយ ពុំអាចធ្វើខ្លែងបោះបានល្អទេ ។ នេះជាសញ្ញាបញ្ជាក់ថា អ្នកលេងខ្លែងពីបុរាណកាលនៃខ្មែរយើង សុទ្ធតែជាអ្នកសាច់ការ យល់ហេតុផលនីមួយៗ ច្បាស់លាស់ណាស់ ។

- អ្នកលេងខ្លែង ( រត់ខ្លែង ) មានសុខភាពល្អ រឹងប៉ឹង រាងកាយមាំមួន ព្រោះរត់ខ្លែង ស្រាវខ្សែខ្លែង គឺជាកីឡាពិតៗតែម្តង ។

- អ្នកលេងខ្លែង ជាមនុស្សឧតុនិយម : អាចដឹងពីសន្ទុះល្បឿននៃខ្យល់ ដឹងពីធាតុអាកាសប្រួលប្រែ ដែលទាក់ទងទៅនឹងកសិកម្ម ថាតើឆ្នាំក្រោយ ទឹកធំ ទឹក

ជន់ ឬរាំងយ៉ាងណានោះ អ្នកលេងខ្លែងទស្សន៍ទាយតាមចំណាំបាន ពុំដែលខុសទេ ។

- លេងខ្លែង ជាមធ្យោបាយមួយសំខាន់ណាស់ អោយអ្នកលេងពីភូមិមួយទៅភូមិមួយ ស្រុកមួយ រួមសាមគ្គី ភាតរភាព ស្គាល់គ្នា រកបាននូវការសរសើរដំណាលពីប្រជាជន ពីឯកពិរោះ ខ្លែងស្អាត ហោះខ្ពស់ ឈ្មោះល្បី ស្រីល្អចស្រឡាញ់ ដូចនៅក្នុងស្រុកបាទី មានតាញ៉ែម តាសាន្ត នៅឃុំត្រពាំងសាប ( ស្លាប់ ) តាភួង ( នៅសំរោងយ៉ោង ) តាជីម នៅជាប់របងវត្តក្រាំងស្លែង ព្រមទាំង តាខុច តាម៉ាន ទាំងអស់នេះ សុទ្ធតែជាអ្នកជំនាញបំផុតក្នុងការធ្វើខ្លែង និងលេងខ្លែងឯក ឬខ្លែងមេកូន របស់ខ្មែរយើង បន្តពីបុរាណមក ។

ដោយសរុបមក ផលប្រយោជន៍នៃការលេងខ្លែងរបស់ខ្មែរយើង ក៏ដូចជាជាតិនានាដែរ សុទ្ធតែបានផ្តល់ផលប្រយោជន៍ ដ៏ល្អ និងចាំបាច់ដល់អ្នកលេង ។

ដោយឡែក ខ្លែងឯក ឬខ្លែងមេកូន (ខ្លែងធ្នូ) ពិតជាឧបករណ៍តន្ត្រីមួយបែបរបស់ប្រជាជនខ្មែរយើងពីបុរាណកាល ដែលនេះជាការវៃឆ្លាតរបស់សិល្បករខ្មែរ បានរកឃើញ និងចេះធ្វើខ្លែង ធ្វើឯក អោយមានសំនៀងឆ្លើយរណ្តំក្នុងពេលបង្ហោះ ព្រោះឧបករណ៍តន្ត្រីដទៃទៀត ដូចជា ទ្រ ស្គ តាខេ សាយដៀវ ចាប៉ី ខ្លុយ ស្រឡៃ ។ ល ។ ទាល់តែដេញ ដំ ផ្លុំ កូត ទើបឮពិរោះ ។ ចំពោះខ្លែងយើងដេកស្តាប់ មិនបាច់ដេញ ដំ ផ្លុំកូតទេ ។ ពីសម័យដើម យើងគ្មានវិទ្យុ ម៉ាញ៉េទូរទស្សន៍ ឬម៉ាស៊ីនច្រៀងអ្វីទេ ពេលយប់ ចាស់បុរាណខ្មែរយើងស្តាប់តែខ្លែងឯកតែប៉ុណ្ណោះ នៅរដូវលំហើយ ។

ខ្លែងឯក ឬខ្លែងមេកូន អ្នកស្រុកបាទី ដាក់ឈ្មោះថា « បំពេរាត្រី » ។

**អ៊ុក សៅប៊ុល**

កែសម្រួលដោយ **ឱម ខែម**

# អំពីពុទ្ធទំនាយ

នៅក្នុងសង្គមខ្មែរយើង អ្នកណាក៏តែងនិយាយពី « ពុទ្ធទំនាយ » ដែរ ទោះបីជាគេបានដឹងតិចក្តី ច្រើនក្តី ទៅតាមការចាំ ដោយបានឮគេនិយាយប្រាប់ ឬក៏ដោយសារបានអានសៀវភៅពុទ្ធទំនាយនានា ដែលបានធ្លាក់មកដល់ដៃគេនោះតែម្តង ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ គេនៅតែមិនទាន់បានដឹងឱ្យប្រាកដថា តើពុទ្ធទំនាយនោះ គឺជាទំនាយដែលចេញមកពីព្រះសម្មាសម្ពុទ្ធ បានធ្វើការទស្សន៍ទាយនេះនៅក្នុងគម្ពីរព្រះត្រៃបិដក ឬក៏ នៅក្នុងជាតកណាមួយឡើយ ។

យោងទៅតាមសេចក្តីដែលមានចារឹកនៅក្នុង « ពុទ្ធទំនាយ » ទាំងអស់ គេអាចសង្កេតឃើញថា ការទស្សន៍ទាយនោះ មានលក្ខណៈជាទូទៅខ្លះដែរ ប៉ុន្តែមានការកត់សម្គាល់ពិសេសមួយដែលថា ទំនាយទាំងនោះច្រើននិយាយសំដៅទៅលើប្រទេសកម្ពុជាយើងតែម្តង ដោយហៅប្រទេសយើងតាមឈ្មោះពីដើមថា «នគរគោកធ្លក» ជាហេតុញាំងឱ្យអ្នកអានខ្លះយល់ថា ព្រះសម្មាសម្ពុទ្ធទ្រង់ដែលបាននិមន្តមកប្រទេសកម្ពុជា ។ ចំពោះករណីនេះ យើងអាចសន្និដ្ឋានបានថា ជាការមិនពិតទេ ពីព្រោះថា នគរគោកធ្លកយើងនេះ កើតក្រោយពុទ្ធសករាជដល់ទៅជាង ៦០០ ឆ្នាំឯណោះ ។

ព្រមជាមួយនឹងពុទ្ធទំនាយនោះ គេនៅមាននិយាយពី « ឥន្ទទំនាយ » ទៀត ។ នេះក៏ជាករណីមួយដែលកាន់តែឃ្លាតឆ្ងាយពីការពិតថែមទៀត ព្រោះថាពុំមានឯកសារអក្សរសាស្ត្រណាជាភស្តុតាង បញ្ជាក់ថាព្រះឥន្ទធ្លាប់បានយាងមកនគរគោកធ្លកទេ ឬក៏ថា ព្រះអង្គបានទស្សន៍ទាយពីនគរគោកធ្លកដោយផ្ទាល់ព្រះឱស្ឋ ឬតាមរយៈឫសីអង្គណាមួយ ក៏ទេដែរ ។

រួមសេចក្តីទៅ ការដាក់ឈ្មោះថានេះជា « ពុទ្ធទំនាយ » ឬនេះជា « ឥន្ទទំនាយ » គឺគ្រាន់តែជាសិល្បៈនៃការតែងនិពន្ធរបស់លោកអ្នកប្រាជ្ញខ្មែរយើងប៉ុណ្ណោះ ។ ខ្ញុំបានសួរចាស់ៗជាច្រើន មានទាំងព្រះសង្ឃផង ឃើញថាពុំមានអ្នកណាមួយអាចបកស្រាយ ថាពិតជាទំនាយរបស់ព្រះពុទ្ធ ឬរបស់ព្រះឥន្ទបានឡើយ ។ ប៉ុន្តែនៅក្នុងការសួរដេញដោលនោះ មានលោកតាចាស់ៗខ្លះបានបំភ្លឺប្រាប់យ៉ាងសមហេតុផល ដែលគួរអោយយកជាការបានថា កាលនៅក្នុងសម័យអង្គរ ដែលប្រទេសយើងកំពុងស្គាល់ការរីកចម្រើនដល់កំរិតនោះ ខ្មែរយើងសម្បូរអ្នកប្រាជ្ញណាស់ ក្នុងនោះក៏មានហោរាដ៏ពូកែៗផងដែរ ។ ផ្នែកសំណង់, ចម្លាក់, សិល្បៈ, អក្សរសាស្ត្រ, ហោរាសាស្ត្រ សុទ្ធតែបង្ហាញអោយឃើញនូវទេពកោសល្យដ៏អស្ចារ្យ ស្ទើរតែរកជឿផងមិនបាន ថាសមិទ្ធិផលទាំងនោះជាស្នាដៃរបស់មនុស្សធម្មតា ។ លោកបានបញ្ជាក់ថា នៅក្នុងសម័យនោះ មានហោរាខ្មែរពូកែៗពីរនាក់ម្នាក់ឈ្មោះ « ពុត » និងម្នាក់ទៀតឈ្មោះ « អ៊ិន » ។ គឺលោកទាំងពីរនាក់នោះហើយ ដែលបានផ្តល់សេចក្តីនៃទំនាយចំពោះ « នគរគោកធ្លក » ។

ក្នុងនាមលោកជាហោរា ប្រហែលលោកអាចប្រមើលមើលឃើញនូវព្រឹត្តិការណ៍ ដែលនឹងត្រូវកើតមានឡើងដោយចៀសមិនផុតនៅក្នុងលោក ហើយជាពិសេស នៅក្នុងប្រទេសកម្ពុជាយើងនេះតែម្តង ទើបបានជាលោកចងក្រងជាទំនាយទាំងនេះឡើង ដើម្បីទុកជូនជាដំណឹងដល់ជនានុជនជំនាន់ក្រោយ ។

ចំពោះករណីដែលលោកអ្នកប្រាជ្ញទាំងពីរនាក់ មិនព្រមសរសេរដាក់ឈ្មោះរបស់លោកផ្ទាល់នោះ គឺប្រហែលជាដោយមានមូលហេតុ ដូចតទៅនេះ ៖

ទី១. គឺដោយសារទំនាយនោះ មានលក្ខណៈអស្ចារ្យពេក មិនសមថាជាមនុស្សលោកអាចនឹងដឹងបានក្រៅពីអច្ឆរិយបុគ្គល ដូចជាព្រះពុទ្ធជាដើម ឬក្រៅពីទេព្តា ដូចជាព្រះឥន្ទជាដើម ទើបបានជាលោកសរសេរឈ្មោះទាំងពីរនោះ ( ដែល

ក្នុងភាសាខ្មែរ គេអានដូចគ្នា ) តាមអក្ខរាវិរុទ្ធសម្រាប់សម្គាល់ព្រះនាមនៃ « ព្រះ » ទាំងពីរព្រះអង្គនោះទៅ,

ទី២. គឺដោយសារលោកចង់អោយអ្នកកាន់ព្រះពុទ្ធសាសនា ក៏ដូចជាអ្នកកាន់ព្រហ្មញ្ញសាសនា មានជំនឿស៊ប់លើទំនាយដ៏អស្ចារ្យទាំងនោះ,

ទី៣. គឺដើម្បីជាសន្តិសុខសម្រាប់ខ្លួនលោកផ្ទាល់ផង ព្រោះថា ទំនាយទាំងនោះ មិនត្រឹមតែនិយាយពីនគរគោកធ្លកប៉ុណ្ណោះទេ ប៉ុន្តែ ក៏មាននិយាយទៅដល់ព្រះមហាក្សត្រ និងពួកនាហ្មឺនធំៗ ជាខ្ញុំរាជការផងដែរ ។

មូលហេតុចុងក្រោយនេះ អាចចាត់ទុកជាមូលហេតុសំខាន់ជាងនេះ ។ វាមានលក្ខណៈប្រហែលគ្នានឹងករណីរបស់ហោរាបារាំងដ៏ល្បីឈ្មោះម្នាក់ ដែលបានទស្សន៍ទាយពីព្រឹត្តិការណ៍អនាគតនៃសកលលោក ហើយជាពិសេស គឺព្រឹត្តិការណ៍ដែលនឹងត្រូវកើតមានឡើងនៅក្នុងប្រទេសបារាំង ហើយដែលទាក់ទិនទៅនឹងព្រះមហាក្សត្របារាំងផង ។ ហោរាបារាំងនោះគឺលោក មីស្សែល ដឺ ណោត្រឺ ដាម ( Michel de Notre Dame, 1503-1566 ) ដែលឈ្មោះលោកត្រូវគេនិយមហៅជាភាសាឡាតាំងថា ណូស្ត្រាដាមុស Nostradamus ។ លោកមិនបានកត់ត្រាទំនាយរបស់លោកជាភាសាបារាំងដោយត្រង់ៗទេ គឺលោកច្រើនតែធ្វើការប្រៀបធៀប ប្រើពាក្យបញ្ឆិតបញ្ឆៀង ប្រឌិតឈ្មោះថ្មី (New City = New York) តាំងពីទីក្រុងញូវយ៉កមិនទាន់កើតមានមកម្ល៉េះ ដូរឈ្មោះដោយប្រើអក្សរដដែលរបស់ឈ្មោះដើម ឧទាហរណ៍ Paris ទៅជា Ripas ជាដើម ។ ទំនាយរបស់លោកមានលក្ខណៈទូលំទូលាយណាស់ គឺមានទាក់ទិនទៅនឹងព្រឹត្តិការណ៍សកលលោក ជាច្រើន ដូចជាសង្គ្រាមលោកលើកទី១, លើកទី២, ការរញ្ជួយដីនៅក្រុងឡូសអង់ស៊ីឡែស អ្នកនយោបាយធំៗនៅអឺរ៉ុប នៅអាមេរិក នៅមជ្ឈិមបូពា សង្គ្រាមលោកលើកទី៣ ដែលនឹងត្រូវកើតមាន ។ ល ។

ឯរឿងកាន់តែអស្ចារ្យទៀតនោះ គឺទំនាយទាំងឡាយដែលគេចារឹកទុកនៅតាមជញ្ជាំងប្រាសាទពីរ៉ាមីដ នៃប្រទេសអេហ្ស៊ីប តាំងពីជាង ៥.០០០ ឆ្នាំមុន គ.ស. ទស្សន៍ទាយពីព្រឹត្តិការណ៍ដែលនឹងត្រូវកើតមានឡើងនៅលើសកលលោកដែរ គឺមានវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ ។ ល ។ ដែលខ្ញុំគ្រាន់តែលើកយកនិយាយប៉ះពាល់ត្រឹមតែប៉ុណ្ណោះ ដោយមិនអាចអោយបានពិស្តារទេ ព្រោះអត្ថបទទាំងនោះវែងៗពេក ។

ត្រឡប់មកនិយាយពីពុទ្ធទំនាយ ឬឥន្ទទំនាយវិញ កាលខ្ញុំនៅពីក្មេង ខ្ញុំបានឮជីតាខ្ញុំនិយាយប្រាប់ខ្លះ ឮចាស់ៗឯទៀតនិយាយខ្លះ ។ ខ្ញុំក៏ចេះតែចងចាំតាំងពីពេលនោះមក ជិត ៤០ ឆ្នាំហើយក៏មាន ជិត ៣០ ឆ្នាំហើយក៏មាន បើគិតមកដល់ថ្ងៃនេះ។ ខ្ញុំបានបញ្ចូលទំនាយនេះនៅទំព័រខាងចុង គ្រាន់ជាការពិចារណា និងរក្សាឯកសារតិចតួចនេះទុកតទៅមុខទៀត ។ ប៉ុន្តែ អ្វីដែលជាក់ស្តែងបំផុតនោះ គឺសៀវភៅពុទ្ធទំនាយមួយ ដែលខ្ញុំបានអានជាច្រើនលើក ច្រើនសា នៅក្នុងដើមទសវត្សនៃដើមឆ្នាំទី ៦០ រហូតដល់ចាំបានមួយចំណែកយ៉ាងធំ ។ សៀវភៅនោះ មានឈ្មោះថា «*ពុទ្ធទំនាយសោឡសនិម្មិត*» ដែលបរិយាយពីព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិតឃើញហេតុ ១៦ ប្រការ ហើយព្រះអង្គបានយាងទៅរកព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដើម្បីសុំអោយព្រះអង្គកាត់ព្រះសុបិននោះថ្វាយ ។

មានតែពុទ្ធទំនាយនិម្មិត ស្តែងពីមហាសុបិន ១៦ ប្រការនេះទេ ដែលគេបានប្រទះឃើញនៅក្នុងគម្ពីរព្រះត្រៃបិដក គឺនៅក្នុងសុត្តន្តបិដក ខុទ្ទកនិកាយជាតកភាគ ៥៨ ដែលមានចំណងជើងថា « មហាសុបិនជាតក » ប៉ុន្តែ ពុំឃើញមានសេចក្តីបកស្រាយបំភ្លឺន័យទាំង ១៦ នៃមហាសុបិននោះថាយ៉ាងនេះយ៉ាងនោះផងទេ ( សូមមើលសេចក្តីដកស្រង់នៅក្នុងអត្ថបទនេះ ត្រង់ទំព័រទី ៥៧ ) ។

មហាសុបិនទាំង ១៦ នោះគឺ :

១. ឃើញគោឧសភរាជ ( គោឡើងក ) រត់ពីទិសទាំងបួន សំដៅមកព្រះលានក្នុងកិរិយាថានឹងជល់គ្នា ប៉ុន្តែលុះរត់មកដល់ វាបែរជាមិនជល់គ្នាវិញ,

២. ឃើញដើមឈើដុះទើបតែបានកម្ពស់ប្រហែលមួយហត្ថ ក៏ស្រាប់តែមានបែកមែកសាខា មានផ្កា មានផ្លែរណែងរណោង,

៣. ឃើញមានគោបង្កើតកូនមកថ្ងៃហ្នឹង រួចសុំកូនរបស់ខ្លួនបៅដោះវិញ,

៤. ឃើញអ្នកស្រែចម្ការ គេមិនទឹមគោធំៗទេ តែគេបែរជាទឹមកូនគោតូចៗវិញ ដែលអូសនង្គ័ល, រនាស់, រទេះមិនរួចទាល់តែសោះ,

៥. ឃើញសេះមួយមានមាត់ពីរ ហើយមានមនុស្សពីរនាក់បញ្ចុកស្មៅឱ្យស៊ីនៅមាត់ទាំងពីរ ប៉ុន្តែវាស៊ីមិនចេះឆ្អែតសោះ,

៦. ឃើញគេយកភាជន៍មាសមានតម្លៃរាប់សែនតម្លឹង ឱ្យឆ្កែចចកជុះនោមដាក់,

៧. ឃើញឆ្កែចចកស៊ីខ្សែ ដែលបុរសម្នាក់វេញហើយនុំះទាល់តែអស់,

៨. ឃើញក្អមធំមួយមានទឹកពេញ គេដាក់នៅកណ្ដាល ហើយក្អមតូចៗជាច្រើននៅជុំវិញ ឃើញមានមនុស្សនាំគ្នាដងទឹកចាក់ចូលតែនៅក្នុងក្អមធំដែលមានទឹកស្រាប់ ប៉ុន្តែឥតមានអ្នកណាម្នាក់ចាប់ភ្លឹកចាក់ទឹកចូលក្អមតូចៗទទេសោះ,

៩. ឃើញស្រះបោក្ខរណីមួយមានទឹកល្អក់នៅត្រង់កណ្ដាល ឯទឹកនៅតាមច្រាំងជុំវិញ ដែលមនុស្សសត្វផងតែងចុះអាស្រ័យ ទៅជាថ្លាស្អាត,

១០. ឃើញបាយមួយឆ្នាំង មានឆ្អិនផង, ជ្រាយផង, ឆៅផង,

១១. ឃើញគេយកខ្លឹមចន្ទន៍ តម្លៃមួយសែនតម្លឹង ទៅដូរយកទឹកដោះគោជូរ, ផ្អូម ហើយស្អុយទៅវិញ,

១២. ឃើញឃ្លោកលិច អំបែងអណ្ដែត,

១៣. ឃើញដុំថ្មប៉ុនផ្ទះអណ្ដែតទឹក រួចរសាត់តាមខ្យល់បាត់ទៅ,

១៤. ឃើញសត្វកង្កែបតូចៗលោតដេញខាំពស់វែកធំៗ,

១៥. ឃើញរាជហង្សហើរទៅហែហមក្អែក,

១៦. ឃើញពពែដេញខាំខ្លា ។

សូមអានន័យ នៃមហាសុបិននិមិត្តទាំង ១៦ ប្រការ ដែលព្រះពុទ្ធសមណ-គោតមទ្រង់បានកាត់ថ្វាយព្រះបាទបសេនទិកោសល នៅក្នុងទំព័រជាបន្តបន្ទាប់ទៅខាងក្រោមនេះ ។

នៅសៀវភៅនេះ ខ្ញុំមានចុះទំនាយពីរជាកំណាព្យបទពាក្យ ៧ ដែលមានឈ្មោះថា « សាស្ត្រាថ្ងៃសុក្រ » ឬតាមឈ្មោះមួយទៀតថា « សាស្ត្រាពារសុក្រ » និង « សាស្ត្រាថ្ងៃសៅរ៍ » ឬតាមឈ្មោះមួយទៀតថា « សាស្ត្រាពារសៅរ៍ » ។ សាស្ត្រាទាំងពីរនេះ គេពុំបានដឹងពីប្រភពដើមរបស់វាទេ គឺមិនបានដឹងថាតើអ្នកណាជាអ្នកនិពន្ធចងក្រងកំណាព្យទាំងនេះទេ ហើយក៏មិនបានដឹងពីកាលបរិច្ឆេទពិតប្រាកដរបស់វាដែរ ។ ដោយឡែក ចំពោះសាស្ត្រាថ្ងៃសុក្រ គេគ្រាន់តែដឹងថា ថ្ងៃមួយនោះ មានបុរសម្នាក់ដើរទៅវាលស្រែនៅពោធិចិនតុង ស្រាប់តែប្រទះរបស់ទាំងនេះ គឺ ឆ័ត្រ, ឈើច្រត់ និងយាមមួយ ។ លុះគាត់រើសយកមក ក៏ឃើញនៅក្នុងថង់យាមមានអកកំបោរ, ប្រណាក, ស្លា, ម្លូ, ត្បាល់បុក និងប្រស្នានេះនៅជាមួយគ្នា យកមកមើលឃើញដូច្នេះ គាត់នឹករអែងខ្លួននឹងរាជការ ក៏យកវត្ថុទាំងនោះទៅជូនចៅហ្វាយស្រុក ចំពេលដែលលោកស័ក្តិ ៤ អ៊ុំ ទៅលេង ។ លោកចៅហ្វាយស្រុកបានទទួលយកហើយ ក៏និយាយរឿងនេះជម្រាបជូនលោកស័ក្តិ ៤ និងយកប្រស្នានេះជូនលោកមើលផង ។ លោកស័ក្តិ ៤ បានមើលរួចហើយ ក៏ហូតទំនាយនោះទុកជាប់នៅនឹងខ្លួនលោក ដែលក្រោយមក គេក៏សុំចម្លងពីលោក និងចម្លងតៗគ្នា រហូតដល់មានស្ទើរគ្រប់ខេត្ត ។ ទំនាយនេះ បើតាមការប៉ាន់ស្មានមើលទៅ ប្រហែលជាកើតឡើងនៅក្នុង ព.ស. ២៤៥២ ត្រូវនឹង គ.ស. ១៩០៩ ។ លុះដល់ឆ្នាំ ច អដ្ឋស័ក ព.ស. ២៤៨៥

គ.ស. ១៩៤៦ លោកឧកញ៉ាសុន្ទរារាជកិច្ច ខឹម ប៉ែន ជាអ្នកកាន់កាប់ការក្រសួងព្រះបរមរាជវាំង ក៏បានឱ្យចម្លងទុក ដោយឱ្យឈ្មោះថា « សាស្ត្រាថ្ងៃសុក្រ » តាមពាក្យចាប់ផ្ដើមរបស់សាស្ត្រានេះថា « ថ្ងៃសុក្រ ពេញបូរមី ... » ។

ប៉ុន្តែ បើយោងទៅតាមខ្លឹមសារនៃអត្ថបទ សាស្ត្រាថ្ងៃសុក្រនេះ ត្រូវបានលោកអ្នកកវីនិពន្ធយើង លោកចាប់ផ្ដើមចងក្រងឡើង នៅក្នុងថ្ងៃពេញបូរមី ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ( ពុទ្ធសករាជ មិនច្បាស់ ) ដោយលោកគ្រាន់តែចារិកមកថា សាសនា ២៤០០ ប្លាយតែប៉ុណ្ណោះ ។ ឯសាស្ត្រាពារសៅរ៍វិញ ក៏លោកឥតមានបញ្ជាក់កាលបរិច្ឆេទឱ្យបានពេញលេញដែរ លោកដាក់តែត្រឹមថា ថ្ងៃសៅរ៍ ជាថ្ងៃដែលលោកចងក្រងឯកសារនោះ គឺត្រូវនឹងថ្ងៃពេញបូរមី ខែកត្តិក ឆ្នាំខាល ឯកស័ក ( មិនដឹងក្នុងឆ្នាំណានៃពុទ្ធសករាជ ) ។

បើពិនិត្យទៅតាមកាលបរិច្ឆេទខាងលើនេះ គេគ្រាន់តែអាចដឹងបានត្រឹមថា សាស្ត្រាថ្ងៃសុក្រ បានចងក្រងក្នុងឆ្នាំ ឆ្លូវ សាស្ត្រាថ្ងៃសៅរ៍ បានចងក្រងក្នុងឆ្នាំខាល ។ នៅក្នុងសាស្ត្រាពារសៅរ៍ ក៏មានកន្លែងខ្លះប្រហែលគ្នានឹងសាស្ត្រាថ្ងៃសុក្រដែរ ។ នេះជាការបញ្ជាក់ថា អ្នកនិពន្ធសាស្ត្រាពារសៅរ៍នោះ លោកបានអានសាស្ត្រាពារសុក្ររួចហើយ ហើយប្រហែលជាលោកៈឃើញថា នៅមានការខ្វះចន្លោះដែលត្រូវបំពេញ ទើបបានជាលោកលើកជាទំនាយមួយផ្សេងទៀតឡើង ។ ឯកាលបរិច្ឆេទពិតប្រាកដនោះ បើយើងស្រាវជ្រាវដោយផ្អែកលើបម្រាប់ដូចមានខាងលើនេះ ប្រហែលជាយើងអាចកំណត់បានដោយត្រឹមត្រូវ ។ បើយោងទៅតាមឆ្នាំ នៃការតែងនិពន្ធ ( គឺសាស្ត្រាថ្ងៃសុក្រ លោកចងក្រងក្នុងឆ្នាំឆ្លូវ ខែភទ្របទ ហើយសាស្ត្រាថ្ងៃសៅរ៍ លោកចងក្រងក្នុងឆ្នាំខាល ខែកត្តិក ) យើងហាក់ដូចជាយល់ឃើញថា សាស្ត្រាពារសៅរ៍ ត្រូវបានលោកអ្នកប្រាជ្ញយើងចងក្រងឡើង ក្រោយសាស្ត្រាពារសុក្រ ក្នុងរយៈកាល ១៤ ខែ ( ១ ឆ្នាំ ២ ខែ ) ។ ប៉ុន្តែ ការសន្និដ្ឋាននេះ

អាចថាខុសក៏បាន ពីព្រោះ មិនស៊ីគ្នាជាមួយនឹង « ស័ក » ។ សូមទុកឱ្យលោកអ្នកជំនាញខាងវិជ្ជានេះ ស្រាវជ្រាវតទៅទៀតចុះ ។

បើយើងពិនិត្យមើលនូវពាក្យពេចន៍ ដែលលោកអ្នកកវីនិពន្ធប្រើនៅក្នុងអត្ថបទនៃសាស្ត្រាថ្ងៃសុក្រ និងសាស្ត្រាថ្ងៃសៅរ៍នោះ យើងអាចវាយតម្លៃបានថា ការតែងនិពន្ធនេះត្រូវបានលោកធ្វើឡើងនៅក្នុងសម័យទំនើបជាខាងក្រោយនេះមកហើយ ដូចលោកបានចារឹកនៅក្នុងអត្ថបទនោះស្រាប់ ( សាសនា ២៤០០ ឆ្នាយ ) ពោលគឺ អាចនៅចុងសតវត្សទី ១៩ ឬក៏នៅដើមសតវត្សទី ២០ នៃគ្រិស្តសករាជ ជាសម័យដែលប្រទេសកម្ពុជាយើងសម្បូរអ្នកប្រាជ្ញផ្នែកអក្សរសាស្ត្រ និងផ្នែកកវីនិពន្ធ ដូចមានការអះអាងនៅខាងដើមស្រាប់ ( គ.ស. ១៩០៩ ) ។

ទំនាយមួយទៀត ដែលលោកចាត់ទុកថាជាពុទ្ធទំនាយមួយដែរនោះ ត្រូវបានលោក អ៊ឹ កេត ចម្លងចេញពីសាស្ត្រាស្លឹករឹត បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៧០ ។ គឺជាស្នាដៃដែលស្ទើរតែបាត់បង់ទៅហើយ ។ ជាសំណាងល្អ ដែលខ្ញុំជួនជាមានមួយក្បាល ហើយក៏ខ្ញុំគិតថា ត្រូវតែបញ្ចូលជាមួយគ្នា ក្នុងគោលបំណងរក្សាឱ្យនៅគង់វង្សឋិតថេរ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវស្នាដៃផ្នែកអក្សរសាស្ត្រ និងជាទស្សនវិជ្ជានៃពុទ្ធនិយម ។ ឯកសារនេះ និយាយពីវាសនានៃព្រះពុទ្ធសាសនា និងព្រឹត្តិការណ៍ដែលត្រូវកើតមានឡើងនៅក្នុងនគរគោកធ្លក ។ នៅក្នុង « ពុទ្ធទំនាយ » នេះ គេពុំឃើញមានការបញ្ជាក់ពីប្រភពរបស់វា ឈ្មោះអ្នកចងក្រង ឬកាលបរិច្ឆេទនៃការតែងនិពន្ធទេ ។

ទំនាយដែលខ្ញុំបានយកមកចុះនៅក្នុងសៀវភៅនេះ ទោះបីជា ពុទ្ធទំនាយក្តី ជាឥន្ទទំនាយក្តី ក៏វាស្រេចតែនៅលើអស់លោកអ្នកអាន មេត្តាស្វែងយល់ថែមទៀតចុះ ។ ប្រការសំខាន់នៃការបោះពុម្ពស្នាដៃទាំងនេះឡើងវិញនេះ គឺដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់អ្នកអានមួយចំនួន និងសិក្សាស្នាដៃ ដ៏មានតម្លៃទាំងនេះ

ឱ្យមានជីវិតឡើងវិញ ។

នៅក្នុងសៀវភៅនេះ ក្រៅពីពុទ្ធទំនាយសោឡសនិម្មិត ( សៀវភៅដើម បោះពុម្ពក្នុងឆ្នាំ ១៩៥២ ), សាស្ត្រាថ្ងៃសុក្រ និងសាស្ត្រាថ្ងៃសៅរ៍ ខ្ញុំបានបញ្ចូលទំនាយស្ដីពីព្រះបាទធម្មិក និងស្ពានជ្រោយចង្វា ជាបន្ថែមបន្តិច ទៅតាមការសន្សំសន្សំ ដែលខ្ញុំបានពីនេះបន្តិច ពីនោះបន្តិច គ្រាន់នឹងកុំឱ្យបាត់បង់ចោលទទេ ។ ហេតុនេះ ទើបបានជាពុំមានសេចក្ដីក្បោះក្បាយល្អ ដែលខ្ញុំក៏សូមអភ័យទោសពីសំណាក់អស់លោកអ្នកអានផងដែរ ចំពោះការខ្វះខាតនេះ ។ ខ្ញុំកត់ចូលនូវអ្វីដែលខ្ញុំបានឮប៉ុណ្ណោះ ។

ប៉ុន្តែ ជាវាសនាល្អដែលខ្ញុំបានសៀវភៅ « ក្បួនពុទ្ធទំនាយ » របស់លោក អ៊ុំ កេត ដែលនិយាយពីនគរគោកធ្លក និងព្រះបាទធម្មិក ជាសៀវភៅចម្លងចេញពីច្បាប់ដើមជាសាស្ត្រាស្លឹករឹតមក ដែលខ្ញុំចម្លងចូលទាំងស្រុង ដោយរៀបចំសម្រួលជាឃ្លាប្រយោគឱ្យស្រួលមើល និងកែអក្ខរាវិរុទ្ធរបស់ពាក្យតែបន្តិចបន្តួចប៉ុណ្ណោះ ។

ចំពោះទំនាយពីស្ពានជ្រោយចង្វា មានអ្នកនិយាយប្រាប់ខ្ញុំជាច្រើនអ្នកដែរ តែដូចជាមិនមានអ្នកណាចាំឱ្យលើសពីអ្វីដែលជីតាខ្ញុំបាននិទានប្រាប់នោះឡើយ ។ ជាអកុសល ឯកសារដែលជីតាខ្ញុំថាមានជាកំណាព្យនោះ ក៏ខ្ញុំពុំបានជួបប្រទះសោះឡើយ ។

ជាសំណូមពររបស់ខ្ញុំ បើអស់លោកអ្នកណាអាចរកឃើញស្នាដៃអស់ទាំងនេះ សូមមេត្តាជួយបំពេញបន្ថែមតាមការគួរ ។ ខ្ញុំសូមថ្លែងអំណរគុណទុកជាមុន ។

**ឆន់ ហ៊ិន**

# ពុទ្ធទំនាយសោឡសនិមិត្ត

មានរឿងតំណាលមកថា នៅនាវេលានោះឯង ព្រះបាទបសេនទិកោ-សល ទ្រង់យាងចូលព្រះទៃនសយនាក្រឡាព្រះបន្ទំដូចសព្វមួយដង ។ ក្នុងរាត្រីនោះ ព្រះអង្គទ្រង់ផ្ទំលក់យ៉ាងសៃនស្កប់ស្កល់ក្នុងព្រះបន្ទំ តាំងពីវេលារំលងអធ្រាត្រ ទ្រង់យល់ព្រះសុបិននិមិត្តឃើញ ១៦ ប្រការ យ៉ាងច្បាស់ទែង ហាក់បីដូចជាទ្រង់បានទតឃើញនឹងព្រះនេត្រស្រស់ ដូច្នោះដែរ ។ លុះព្រះអង្គតើនដឹងព្រះស្មារតីឡើងនៅនាវេលាទៀបភ្លឺនោះ ព្រះអង្គទ្រង់នៅចាំព្រះសុបិនទាំង ១៦ យ៉ាងច្បាស់ ឥតមានភ្លេចភ្លាំងដោយប្រការណាមួយឡើយ ។ ព្រះអង្គទ្រង់ព្រះចិន្តាថា « ព្រះសុបិននេះ ហាក់បីដូចជាចម្លែកពន់ពេកណាស់ នេះច្បាស់ជាប្រផ្នូលអ្វីខ្លះមិនលែងឡើយ » ។ កាលបើទ្រង់ព្រះតម្រិះដូច្នេះហើយ ព្រះបាទបសេនទិកោសល ក៏ទ្រង់ត្រាស់ហៅពួករាជអាមាត្យឱ្យទៅអញ្ជើញអស់លោកជាព្រាហ្មណ៍បុរោហិត បណ្ឌិតហោរា មកកាន់ព្រះរាជរោងរម្យជាបន្ទាន់ ។ បន្ទាប់ពីទ្រង់ស្រង់ព្រះវារីរួចហើយ ព្រះអង្គទ្រង់ព្រះពស្ត្រតាមទម្លាប់ ប្រញាប់យាងទៅកាន់ព្រះរាជរោងរម្យ ជួបជុំអស់លោកបុរោហិតព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតហោរា ដែលបានអញ្ជើញមកចាំគាល់ត្រៀមត្រារួចជាស្រេច ។ ព្រះបាទសម្តេចបសេនទិកោសល ទ្រង់ត្រាស់ទៅអស់លោកនាហ្មឺនទាំងនោះ ពីព្រះបំណងរបស់ព្រះអង្គក្នុងការបើកអង្គប្រជុំជាវិសាមញ្ញមួយនេះ ។ រួចហើយ ព្រះអង្គក៏រៀបរាប់ជូនអង្គប្រជុំទាំងមូល អំពី «ព្រះមហាសុបិននិមិត្ត ១៦ ប្រការ» នោះ ។ ក្នុងចំណោមព្រះរាជហោរាក្តី ព្រះរាជបុរោហិតក្តី ដែលបានរៀនពីវិជ្ជានេះ ពុំមានអ្នកណាម្នាក់អាចកាត់យល់បាននូវប្រផ្នូល ដែលកើតឡើងពីព្រះមហាសុបិនទាំងនោះទេ ។ ប៉ុន្តែ ដើម្បីកុំឱ្យខូចឈ្មោះរបស់ខ្លួន មានហោរាម្នាក់ ទស្សន៍ទាយទាំងស្មានៗថ្វាយព្រះមហាក្សត្រ ថាព្រះអង្គនឹងត្រូវជួបគ្រោះថ្នាក់ណាមួយ ក្នុងគ្រោះថ្នាក់

បីយ៉ាង ដូចតទៅ :

« ព្រះអង្គអាចខូចរាជសម្បត្តិ, ពុំនោះសោតត្រូវខូចមហេសី, ឬបើមិនដូច្នោះទេ ព្រះអង្គនឹងត្រូវសោយទិវង្គតហើយ » ។

កាលបើទ្រង់សណ្តាប់ឮទំនាយនេះហើយ ព្រះបាទបសេនទិកោសល ក៏ត្រាស់សួរយោបល់បុរោហិត ថាតើត្រូវធ្វើដូម្តេច ដើម្បីរំដោះគ្រោះនេះបាន ។ បុរោហិតថ្វាយយោបល់ថា មានតែត្រូវប្រារព្ធពិធីបូជាយញ្ញប៉ុណ្ណោះ ។ ដោយហេតុថាពិធីបូជាយញ្ញ តម្រូវឱ្យមានការសម្លាប់មនុស្ស និងសត្វជាច្រើន ទើបព្រះនាងមល្លិកាជាព្រះអគ្គមហេសីទ្រង់ថ្វាយយោបល់ជំទាស់ថា « ដែលព្រះអង្គចង់រស់ខ្លួនឯងហើយទៅសម្លាប់គេដើម្បីបូជាយញ្ញនុ៎ះ វាមិនត្រឹមត្រូវទាល់តែសោះ ! » ។ ព្រះអគ្គមហេសី ក៏បានណែនាំព្រះស្វាមីឱ្យទៅទូលសួរព្រះសម្មាសម្ពុទ្ធមើល ដើម្បីចង់ដឹងថាតើន័យនៃមហាសុបិននេះ វាពិតដូចបុរោហិតបានទូលថ្វាយមែន ឬមិនមែន ។

ព្រះបាទបសេនទិកោសល ក៏ទ្រង់ស្តេចយាងទៅកាន់សំណាក់ នៃព្រះបរមសាស្តាសម្មាសម្ពុទ្ធ ដែលកំពុងគង់នៅវត្តជេតពន ។ លុះយាងទៅដល់ហើយ ព្រះបាទបសេនទិកោសល ក៏លើកករប្រណម្យធ្វើអភិវន្ទនកិច្ចចំពោះព្រះបរមសាស្តា ទាំងទូលព្រះបរមសាស្តាពីវត្ថុបំណងនៃការយាងរបស់ព្រះអង្គមកកាន់ទីនេះ ។ ដោយអានុភាពនៃទិព្វញាណរបស់ព្រះអង្គ ព្រះសម្មាសម្ពុទ្ធទ្រង់បានជ្រាបអំពីដំណើររឿងនេះរួចជាស្រេចទៅហើយ ។ ព្រះបាទបសេនទិកោសល ទ្រង់លើកពីព្រះមហាសុបិនរបស់ព្រះអង្គ ម្តងមួយៗ ទូលព្រះបរមសាស្តា ។ ចំណែកឯព្រះបរមសាស្តាវិញ ព្រះអង្គក៏ទ្រង់ថ្វាយសេចក្តីថា « បពិត្រមហារាជ, រឿងយល់សប្តនេះ មិនមានន័យអ្វីទាក់ទងទៅនឹងព្រះអង្គផ្ទាល់ ដូចបុរោហិតទូលថ្វាយទេ ។ រឿងទាំងអស់ វានឹងកើតមានឡើងនៅនាអនាគតឯណោះ សម្រាប់មនុស្សលោកជាទូទៅផង និងសម្រាប់សាសនាតថាគតផង » ។ រួចហើយ ព្រះសម្មាសម្ពុទ្ធទ្រង់កាត់ព្រះមហាសុបិននិម្មិត

ទាំងអស់នោះថ្វាយព្រះបាទបសេនទិកោសល តាមលំដាប់លំដោយ ដូចតទៅនេះ :

*សុបិនជាតម្រប់ ១.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិមិត្ត ឃើញគោឧសុភរាជបោលពីទិសទាំងបួន សំដៅមកព្រះលាន ក្នុងកិរិយាសង្វើញពីចម្ងាយមកថានឹងជល់គ្នា ។ លុះបោលមកដល់ជួបគ្នានៅលើទីព្រះលានខាងមុខព្រះបរមរាជវាំង គោឧសុភរាជទាំងនោះ បែរជាមិនជល់គ្នាវិញ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្ដាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ មេឃ អាកាស នឹងប្រែប្រួលលក្ខណៈខុសពីធម្មតា ។ ដោយសារមនុស្សមិនសូវកាន់ធមិ គឺទាំងព្រះរាជា ទាំងនាម៉ឺន ទាំងប្រជាជន ទាំងសមណព្រាហ្មណ៍ ច្រើនតែខ្វះសីលធមិ នាំឱ្យទេព្ដាពុំសប្បាយព្រះទ័យ ក៏បណ្ដាលឱ្យធាតុអាកាសប្រែប្រួល ភ្លៀងបង្អុរមកពុំបានគ្រប់គ្រាន់ ដំណាំ និងឈើផងទាំងឡាយ ឱ្យផលានុផលមិនបានបរិបូណ៌ ។ ជួនកាលមេឃមីរងងឹតអួរអាប់ ដាបដោយពពកខ្មៅ ដែលតាមចំណាំថាបន្តិចទៀតទៅនឹងមានភ្លៀងបង្អុរធ្លាក់ចុះមក ។ មនុស្សម្នាប្រញាប់នាំគ្នាទៅសាស្រូវ សាសម្លៀកបំពាក់ រីឯអ្នកដំណើរនាំគ្នារត់រកជម្រកតែរៀង១ខ្លួន ។ ស្រាប់តែគេពុំបានឃើញភ្លៀងធ្លាក់ទៅវិញ ។ មានពេលខ្លះ មេឃភ្លឺស្រឡះ ដែលតាមការចំណាំថានឹងគ្មានភ្លៀងធ្លាក់ទេ ។ ប៉ុន្តែ បន្តិចក្រោយមក ក៏ស្រាប់តែមានភ្លៀងបង្អុរចុះមកយ៉ាងជោគជាំ ។

*សុបិនជាតម្រប់ ២.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិមិត្ត ឃើញឈើមួយដើម ទើបនឹងដុះបានកម្ពស់ប្រហែលមួយហត្ថ ក៏ស្រាប់តែបែកមែកត្រសុំត្រសាយសាខា មានផ្កា មានផ្លែរណោងរណោង ។

ព្រះសម្មាសម្ពុទ្ធបរមសាស្ដាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ មនុស្សម្នាចេះស្រឡាញ់គ្នា និងយកគ្នាជាប្ដីប្រពន្ធនៅក្មេង១ណាស់ ព្រោះតែគេមានកិលេសច្រើនពេក គឺអាយុបាន ១៣ ឆ្នាំ, ១៤ ឆ្នាំ, ១៥ ឆ្នាំ គេនឹងរៀបការគ្នា

ជាប្តីប្រពន្ធ មានកូន មានចៅ អាយុក៏កាន់តែខ្លី ឯក្មេងស្រីឆាប់មានរដូវណាស់ ។

*សុបិនជាតម្រប់ ៣.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិត ឃើញមេគោធំៗបង្កើតកូនមកហើយក្នុងថ្ងៃហ្នឹង រួចក៏សុំបៅដោះកូនរបស់ខ្លួន ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ មនុស្សកាន់តែបាត់បង់សិលធម៌ច្រើន មិនសូវចេះគោរពមា.តាបិតា.គ្រូបាអាចារ្យរបស់ខ្លួនទេ ហើយយូរទៅមុខទៀតទៅ មាតាបិតាត្រូវអង្វរករកូន ត្រូវផ្គាប់ចិត្តកូនរបស់ខ្លួន ដើម្បីឱ្យកូនចិញ្ចឹមខ្លួនជាឪពុកម្តាយ ឱ្យបាយទទួលទាន ។

*សុបិនជាតម្រប់ ៤ .* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិត ឃើញគេមិនទឹមគោធំៗទេ តែគេបែរជាទឹមគោតូចៗទៅវិញ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ មនុស្សអ្នកចេះអ្នកដឹង មានការពិសោធន៍ គេមិនឱ្យទទួលធ្វើការងារធំដុំទេ គឺគេយកតែក្មេងៗ ដែលខ្វះការពិសោធន៍ឱ្យធ្វើការវិញ ម្ល៉ោះហើយធ្វើការទៅ មានត្រូវខ្លះខុសខ្លះ ដែលបង្កឱ្យមានការលំបាកជាពន់ពេកហោង ។

*សុបិនជាតម្រប់ ៥.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិត ឃើញមានសេះមួយនោះមានមាត់ពីរ គេឱ្យស្មៅស៊ីប៉ុន្មាន ក៏វាមិនចេះឆ្អែតដែរ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ ក្រឡាផ្ទៃក្រោមធ្វើអំពើអធម្មកម្មពេកណាស់ហោង ។ ពួកតុលាការផង គេកាត់ក្តីពុំប្រកបដោយសេចក្តីសុចរិត យុត្តិធម៌បន្តិចណាសោះឡើយ គឺគេតែងឆ្លៀតយកការកាត់ក្តីធ្វើជាឱកាសសម្រាប់ជីវិតយកមាសប្រាក់ ឬទ្រព្យសម្បត្តិរបស់គូក្តីទាំងសងខាង ដោយឥតមានត្រាប្រណីឡើយ ហើយទោះបីជាគូវិវាទទាំងសងខាងស្ងួកប៉ាន់អស់ប៉ុន្មានៗ ក៏ចៅក្រមមិនចេះឆ្អែតឆ្អន់ដែរ គឺគេនៅតែប្រព្រឹត្តដូច្នេះជារហូត ។ ឯអ្នកកាត់ក្តីនោះទៀតសោត ច្រើនតែជាមនុស្សក្មេងៗ ជាអ្នកមិនសូវមាន

ចំណោះវិជ្ជាអ្វីជ្រៅជ្រះទេ ។

*សុបិនជាគម្រប់ ៦.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិមិត្ត ឃើញគេយកភាជន៍មាស តម្លៃមួយសែនតម្លឹងទៅត្រងទឹកនោមឆ្កែចចក ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ អ្នកដែលធ្លាប់មានត្រកូលខ្ពង់ខ្ពស់នឹងធ្លាក់ខ្លួនទៅជាទ័លក្រ លំបាកតោកយ៉ាកថោកទាប ព្រោះឥតមានយសស័ក្តិនឹងគេ ។ ចំណែកឯអ្នកដែលធ្លាប់នៅក្នុងត្រកូលទាបថោកវិញ គេត្រូវបានឡើងធ្វើជាអ្នកដឹកនាំ មានស័ក្តិយសខ្ពស់ត្រដែតត្រដឹមម្ល៉ោះហើយ ពួកអ្នកត្រកូលខ្ពស់ទាំងនោះ ត្រូវបង្ខំចិត្តលើកកូនស្រីរបស់ខ្លួនឱ្យទៅធ្វើជាភរិយានៃអ្នកត្រកូលថោកទាប ដែលមានស័ក្តិយស មានអំណាច ដើម្បីឱ្យបានងាយស្រួលក្នុងការរស់នៅ ។

*សុបិនជាគម្រប់ ៧.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិមិត្ត ឃើញឆ្កែចចកស៊ីខ្សែ ដែលបុរសវេញហើយនោះទាល់តែអស់ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាព្យាករតាមសុបិននិមិត្តនេះថា អំណើះតទៅមុខ ស្រីៗមានភាគៈ គឺមានតម្រេកយ៉ាងខ្លាំងក្លា ចូលចិត្តផឹកស្រា ស្រឡាញ់តែគ្រឿងអលង្ការ ចូលចិត្តតាក់តែងរាងកាយ សប្បាយតែខាងការត្រាច់ចរតាមច្រកល្ហករកប្រុសសាហាយ ឥតគិតគូររក្សាសីលទានសោះ សូម្បីតែការងារក្នុងផ្ទះសម្បែង ក៏ពុំសូវធ្វើឱ្យបានដិតដល់ដែរ, ឯប្តីលំបាកចិត្តណាស់ ឥតបានសុខសាន្តទេព្រោះហេតុតែទុកប្រាក់កាសមិនចេះគង់ ដោយសារតែប្រពន្ធក្បត់ចិត្ត គិតតែពីចាយវាយខ្ជះខ្ជាយ ។

*សុបិនជាគម្រប់ ៨.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិមិត្ត ឃើញក្អមធំមួយមានទឹកពេញព្រៀប និងក្អមទទេតូចៗជាច្រើន នៅព័ទ្ធជុំវិញ ។ ព្រះអង្គទ្រង់ឃើញមានមនុស្សមកពីទិសទីទៃៗ នាំគ្នាដងទឹកចាក់ចូលទៅតែក្នុងក្អមធំ

មានទឹកពេញស្រាប់ដែលនៅត្រង់កណ្ដាលនោះ ឥតមាននរណាចាប់ភ្លឹកថា នឹងចាក់ទឹកទៅក្នុងក្អមទទេតូចៗទាំងនោះផងឡើយ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្ដាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ *នៅក្រឡាផ្ទៃក្រោមនឹងមានកើតការប្រែប្រួល ដោយអ្នកកម្សត់ទុរគតនាំគ្នា*ជញ្ជូនប្រាក់កាសទៅបំពេញតែទូ និងហិប របស់អ្នកមានធនធានស្រាប់ៗ ផែមទាំងត្រូវកំណែនឱ្យទៅធ្វើស្រែចម្ការច្បារដំណាំឱ្យអ្នកធំ ឱ្យអ្នកមានស្តុកស្តម្ភ ចោលមុខរបររបស់ខ្លួនអស់ ខំបេះយកផលជញ្ជូនដាក់ឃ្លាំងរបស់អ្នកមានសម្បត្តិ ឥតឱកាសនឹងធ្វើការងាររបស់ខ្លួនឡើយ ។

*សុបិនជាគម្រប់ ៩.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិតឃើញស្រះបោក្ខរណីមានទឹកល្អក់ត្រង់កណ្ដាល ដែលពុំមាននរណាទៅប៉ះពាល់សោះនុ៎ះ ឯទឹកតាមឆ្នេរនៅច្រាំងជុំវិញ ដែលមនុស្សសត្វផងតែងតែចុះអាស្រ័យ បែរជាថ្លាស្អាតល្អ ឥតមានកករល្អក់បន្តិចណាសោះឡើយ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្ដាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ ពួកមន្ត្រីអ្នករាជការមានចិត្តមិនបរិសុទ្ធ រមែងប្រកបដោយអគតិទាំង ៤ យ៉ាង គឺ កាត់ក្ដីមិនត្រឹមត្រូវតាមច្បាប់នេះ ១, សម្លឹងចង់បានទ្រព្យសម្បត្តិរបស់គេនេះ ១, គ្មានព្រហ្មវិហារធម៌ចំពោះបណ្ដារាស្ត្រសោះនេះ ១, មានចិត្តកាចឃោរឃៅនេះ ១ គឺគេធ្វើបាបរាស្ត្រខ្លាំងពេក រហូតដល់បណ្ដារាស្ត្ររត់ចោលស្រុកកំណើត រត់ចោលការងារជាមុខរបរ នាំគ្នាទៅនៅតាមដោយចុងកាត់មាត់ញក នាព្រៃភ្នំក្រំថ្ម ឯណោះទៅវិញ ទើបបានសុខស្រួល បានរួចរដោះអស់ពីទុក្ខភ័យ ផុតក្ដីលំបាក ។

*សុបិនជាគម្រប់ ១០.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិតឃើញបាយមួយឆ្នាំង មានឆ្អិនផង, មានឆៅផង, មានជ្រាយផង ។

ព្រះសម្មាសម្ពុទ្ធបរមសាស្ដាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅ

មុខ ស្រុកទេសនឹងមានកើតហេតុភេទ ៣ យ៉ាង ដូចតទៅ :

ទី១. មនុស្សផងទាំងឡាយគឺ ពួកមន្ត្រីរាជការ គហបតី និងសមណៈ ជីព្រាហ្មណ៍ទាំងឡាយ មិនប្រកបដោយសីលធម៌សោះឡើយ ។

ទី២. ពួករុក្ខទេវតា, អារក្ខទេវតា, អាកាសទេវតាទាំងអម្បាលម៉ាន មិនកាន់សីល កាន់ធម៌ឡើយ ។

ទី៣. នៅភូមិភាគខ្លះ មានភ្លៀងធ្លាក់ច្រើនហួសពេក ទាល់តែរលួយសំណាប រលួយសន្ទូងអស់ ដំណាំដាំដុះឱ្យផលមិនបានគ្រប់គ្រាន់ចូនល្មមនឹងសេចក្តីត្រូវការឡើយ ។

*សុបិនជាគម្រប់ ១១.* ព្រះបាទបសេនទិកោសល់ទ្រង់ព្រះសុបិននិម្មិតឃើញគេយកខ្លឹមចន្ទន៍តម្លៃមួយសែនតម្លឹងទៅដូរយកទឹកដោះគោជូរ ផ្អូម ហើយស្អុយទៅវិញ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ ពួកភិក្ខុសង្ឃដែលជាអ្នកបួសក្នុងសាសនាតថាគត គិតតែពីខាងលោភលន់ ចង់បានបច្ច័យ ៤ ហួសហេតុ ព្រមទាំងចង់បានឋានៈខ្ពង់ខ្ពស់ ឥតបើមានអៀនខ្មាសសោះឡើយ ។ ធម៌វិន័យដែលតថាគតទេសនាទូន្មាននោះ គឺមិនឱ្យត្រេកអរនឹងបច្ច័យ ៤ ទេ មិនឱ្យចង់បានឋានៈអ្វីឡើយ ឱ្យខំតែកម្ចាត់បង់នូវលោភៈ ទោសៈ មោហៈ ចេញឱ្យផុតពីសន្តានចិត្ត ឱ្យខំប្រព្រឹត្តតែត្រៃសិក្ខាគឺ សីល, សមាធិ, បញ្ញា ឱ្យបានមុតមាំ មែនទែន ដើម្បីជាផ្លូវទៅកាន់ព្រះនិព្វាន ។ ប៉ុន្តែ លុះដល់តថាគតចូលបរិនិព្វានអស់កាលកន្លងទៅជាយូរអង្វែង ពួកភិក្ខុទាំងឡាយទៅជានាំគ្នាប្រែក្លាយធម៌របស់តថាគត ដោយទេសនាបញ្ចេញបញ្ចូលឱ្យតែខាងបានពិរោះល្បីល្បាញលើសគេ ដើម្បីឱ្យបានលាភសក្ការៈច្រើន មានឋានៈខ្ពង់ខ្ពស់ ឥតខ្លាចបាបសោះ គឺ « ពួកភិក្ខុទាំងនោះហ៊ានយកធម៌សម្រាប់ព្រះនិព្វានទៅដូរយកបច្ច័យ ៤ » ។

*សុបិនជាតម្រប់ ១២.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិត **ឃើញឃ្លោកលិច អំបែងអណ្តែត ។**

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ នឹងមានការប្រែប្រួលនៅក្រឡាផ្ទៃក្រោម ដោយហេតុថា អ្នកល្ងង់ខ្លៅ ត្រូវបានឡើងធ្វើជាអ្នកដឹកនាំ មានស័ក្តិយសខ្ពង់ខ្ពស់ត្រដែតត្រដឹម មានអំណាច រួចហើយគេលើកតំកើងតែមនុស្សល្ងង់ខ្លៅដូចគ្នា ឱ្យស្រដីលើអ្នកប្រាជ្ញបណ្ឌិត តម្រូវឱ្យអ្នកប្រាជ្ញ បណ្ឌិត ស្តាប់បង្គាប់អ្នកល្ងង់ខ្លៅវិញ ។

*សុបិនជាតម្រប់ ១៣.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិតឃើញថ្មមួយដុំធំប៉ុនផ្ទះ អណ្តែតទឹកដូចជាទូក រួចរសាត់បាត់ទៅតាមខ្យល់ទៅ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ យសស័ក្តិខ្ពង់ខ្ពស់នឹងត្រូវបានទៅតែខាងពួកអ្នកឥតត្រកូល ពោលគឺ ពួកអ្នកត្រកូលថោកទាប អវិជ្ជា ត្រូវបានឡើងធ្វើជានាហ្មឺនធំៗ ចំណែកឯពួកមានត្រកូលល្អត្រឹមត្រូវ សុចរិត យុត្តិធម៌ពិតៗ ត្រឡប់ទៅជាធ្លាក់ខ្លួនក្រខ្សត់ អ្នកផងលែងគោរពកោតក្រែង គឺគេនាំគ្នាគោរពកោតខ្លាចតែអ្នកឥតត្រកូលទៅវិញ ។ ម្យ៉ាងវិញទៀតគេនឹងលែងធ្វើគារវកិច្ចចំពោះព្រះសង្ឃដែលមានសីលល្អបរិសុទ្ធ តែគេបែរជាគោរពរាប់អានភិក្ខុអលជ្ជី ដែលទ្រុស្តសីលទៅវិញ ។ ពួកព្រះសង្ឃដែលប្រតិបត្តិត្រឹមត្រូវតាមធម៌-វិន័យ ត្រឡប់ជាខ្ចាត់ព្រាត់ពីទីប្រជុំសង្ឃ ទៅនៅឯក្រៅបាត់ អស់ទៅ ។

*សុបិនជាតម្រប់ ១៤.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិតឃើញសត្វកង្កែបតូចៗ លោតដេញខាំពស់វែកធំៗ ហើយទំពាស៊ីលេបបាត់ទៅ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ លោកនឹងអាប់ឱនទៅ នៅក្នុងគ្រាដែលមនុស្សទាំងឡាយសឹងក្រាស់ទៅដោយកម្លាំងកាមរាគដ៏ខ្លាំងក្លា មានកិលេសតណ្ហាគ្របសង្កត់ជាប់ បណ្តាលឱ្យប្តីសឹសុខចិត្ត

នៅក្រោមអំណាចប្រពន្ធក្មេងៗ ទាំងទ្រព្យសម្បត្តិសព្វសារពើសោត ក៏នៅក្នុងកណ្តាប់ដៃប្រពន្ធក្មេងៗទាំងនោះដែរ ។ កាលបើប្តីសួរនាំពីទ្រព្យសម្បត្តិផ្សេងៗ ប្រពន្ធក្មេងៗ តែងស្តីបន្ទោស ជេរ ប្រមាថ តបតទៅវិញ កំហែងប្តីឱ្យលុះក្នុងអំណាចរបស់ខ្លួននោះ ស្មើខ្ញុំកំដរ ។

*សុបិនជាគម្រប់ ១៥.* ព្រះបាទបសេនទិកោសល ទ្រង់ព្រះសុបិននិម្មិតឃើញរាជហង្សហើរហែហមសត្វក្អែក បើក្អែកនៅទីណា រាជហង្សក៏នៅទីនោះដែរ ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តាទ្រង់ព្យាករតាមសុបិននេះថា អំណើះតទៅមុខ ពួកព្រះរាជាក្នុងខត្តិយត្រកូល និងពួកអ្នកដែលធ្លាប់នៅក្នុងត្រកូលខ្ពង់ខ្ពស់ មានចំណេះវិជ្ជា បែរជាទៅហែហមពួកល្ងង់ខ្លៅនៅក្នុងត្រកូលទាបៗ ដែលមានអំណាចដើម្បីទៅសុំបុណ្យ សុំសក្តិយសពីពួកក្រកូលទាបៗនោះវិញ ។

*សុបិនជាគម្រប់ ១៦.* ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ទូលទៅព្រះបរមសាស្តាថា ៖ « ខ្ញុំម្ចាស់ យល់សប្តឃើញពពែដេញខាំខ្លា ។ បើតាមសុបិននេះតើនឹងមានកើតហេតុភេទទៅជាប្រែប្រួលយ៉ាងណាដែរទៅ ព្រះអង្គ ? ឱ ! ព្រះជាម្ចាស់ខ្ញុំអើយ ! តាំងពីកើតមក ខ្ញុំព្រះអង្គធ្លាប់តែបានដឹង បានឮថា ធម្មជាតិជាសត្វខ្លា វាតែងខាំ តែងតែស៊ីពពែ ។ ប៉ុន្តែ ខ្ញុំព្រះអង្គបែរជាឃើញពពែដេញខាំស៊ីខ្លាវិញ ។ មិនតែប៉ុណ្ណោះ ខ្ញុំព្រះអង្គបានឃើញទៀតថា ហ្វូងខ្លាគ្រាន់តែឃើញពពែលើមៗ ពីចម្ងាយ ក៏នាំគ្នាដាក់មេផាយបោលយ៉ាងលឿនចូលទៅនៅក្នុងព្រៃធំ ខំលាក់ខ្លួន ពួនសំងំ ព្រោះខ្លាចពពែខាំស៊ី » ។

ព្រះសម្មាសម្ពុទ្ធបរមសាស្តា ទ្រង់មានព្រះពុទ្ធដីកាកាត់ព្រះមហាសុបិននេះថ្វាយព្រះបាទបសេនទិកោសលថា ៖ « ថ្វាយព្រះពរ មហារាជ, លុះចំណេរចិរកាលតទៅមុខទៀតទៅ ពួកបណ្តាជនជាអ្នកឥតត្រកូល ហើយអវិជ្ជាត្រូវទទួលបានសេចក្តីប្រោសប្រាណឱ្យឡើងធ្វើជានាហ្មឺនធំ ។ ឯជនដែលមានពូជ មានត្រកូលខ្ពង់ខ្ពស់

បែរទៅជាអ័ព្ភយសសក្តិ ធ្លាក់ខ្លួនទៅជាអ្នកកម្សត់វិញ ។ អ្នកធំគេជឿតាមតែសេចក្តីវិនិច្ឆ័យរបស់មន្ត្រីក្មេងៗ ដែលកេងប្រវ័ញ្ចយកមាស ប្រាក់ យកស្រែចម្ការ ជារបស់បណ្តារាស្ត្រធ្វើជារបស់ខ្លួន ថែមទាំងឱ្យចាប់រាស្ត្រខ្លះធ្វើទារុណកម្ម ទាំងកំហែងថា « ឯងម៉េចបានជាហ៊ានបៀតបៀននឹងនាហ្មឺន ! » ។ ជួនកាល មានដល់ទៅធ្វើទោសពៃរ៍ កាត់ដៃ កាត់ជើង វាយខ្នងផង ម្ល៉ោះហើយ អ្នកមានពូជ មានត្រកូលខ្ពង់ខ្ពស់ចេះតែភិតភ័យ ព្រួយបារម្ភ ខ្លាចគេរកឃើញ គេនឹងចាប់ចងយកខ្លួនទៅធ្វើទោសពៃរ៍ ។ ម្យ៉ាងទៀត ក្នុងសាសនាតថាគត ក៏មានកើតហេតុភេទដូចគ្នាដែរ គឺពួកភិក្ខុទ្រុស្តសីល ចេះតែរករឿងហេតុចាប់ទោស ចាប់កំហុសពួកភិក្ខុជាអ្នកមានសីលល្អបរិសុទ្ធទៅវិញ ។ ដូច្នេះ ពួកភិក្ខុដែលមានសីលស្អាតល្អបរិសុទ្ធទាំងនោះ ក៏នាំគ្នារត់រកទីពឹងនៅតាមដងព្រៃភ្នំក្រំថ្មអស់ទៅ ។

ថ្វាយព្រះពរ មហារាជ, ព្រះសុបិននិមិត្តទាំង ១៦ ប្រការនេះ ឥតមានឱ្យកើតទោសជាទុក្ខ ជាភយន្តរាយអ្វីដល់ព្រះអង្គសោះឡើយ ។ សូមមហារាជ កុំទ្រង់ព្រួយព្រះរាជហឫទ័យ ! » ។

**ចប់ ពុទ្ធធំនាយ សោឡសនិមិត្ត**
**ស្តីពី ព្រះមហាសុបិន ១៦ ប្រការ តែប៉ុណ្ណេះ**

------

***សម្គាល់*** : មានច្បាប់ខ្លះចែងថា ព្រះបាទបសេនទិកោសលទ្រង់ព្រះសុបិនឃើញពស់វែកមួយលូនចេញចាប់កង្កែប ។ លុះពស់ដេញទាន់កង្កែប ស្រាប់តែកង្កែបបែរជាលេបពស់នោះទៅវិញ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករតាមសុបិននិមិត្តនេះថា អំណើះតទៅ នៅក្រឡាផ្ទៃក្រោម ពួកចៅក្រមប្រព្រឹត្តអំពើអយុត្តិធម៌ពេកណាស់ គឺគេពុំកាន់ធម៌សុចរិតបន្តិចណាឡើយ ។ គេកាត់ក្តីឱ្យអ្នកដែលត្រូវឈ្នះទៅជាចាញ់ រីឯអ្នកដែលត្រូវមានទោសទ័ណ្ឌពិតប្រាកដត្រូវចាញ់គេ បែរជាចៅក្រមកាត់ឱ្យឈ្នះក្តី ទៅវិញ ដោយសារតែចៅក្រមនោះទទួលសំណូកគេ ។

សុបិននេះ ជាជំនួសសុបិនឃើញ « គេទឹមគោតូចៗ មិនទឹមគោធំៗ » ។

# មហាសុបិនជាតកំ

(៧៧) ឧសភា រុក្ខា គាវិយោ គវា ច
អស្សោ កំសោ សិគាលី ច កុម្ភោ
បោក្ខរណី ច អបាកចន្ទនំ
លាពូនិ សីទន្តិ សិលា ប្លវន្តិ
មណ្ឌូកិយោ កណ្ហសប្បេ គិលន្តិ
កាកំ សុវណ្ណា បរិវារយន្តិ
តសា វកា ឯឡកានំ ភយា ហិ
វិបរិយាសោ វត្តតិ នយិធមត្ថីតិ ។

មហាសុបិនជាតកំ សត្តមំ ។

## មហាសុបិនជាតក

( ៧៧ ) ( ព្រះរាជាទ្រង់ត្រាស់ថា មហាសុបិន ១៦ គឺ ) *គោឡើងក ទាំងឡាយ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំង ឡាយ ១ សេះ ១ ភាជន៍ (មាស) ១ មេចចក ១ ក្អម ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយ អណ្តែត ១ មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ ១ រាជហង្សមាស ទាំងឡាយចោមរោមក្អែក ១ ខ្លាដំបងទាំងឡាយ ១ (រត់ទៅ) ព្រោះភ្ញាក់ ផ្អើលដោយសេចក្តីខ្លាចអំពីពពែទាំងឡាយ ១ បរិយាយចំឡែកប្រព្រឹត្តទៅ ន័យទាំងឡាយមានក្នុងសុបិនទាំងនេះ ។*

ចប់ មហាសុបិនជាតកទី ៧ ។

# សាស្ត្រាថ្ងៃសុក្រ

ថ្ងៃសុក្រពេញបូរមីខែភទ្របទ នៅក្នុងកំណត់ព្រះវស្សា
ឆ្នាំឆ្លូវត្រីស័ក នក្សត្រា សាសនាពីរពាន់បួនរយថ្លាយ ។
នឹងថ្លែងពីរដ្ឋរាជបុរី ក្នុងផែនដែនដីនគរអោយ
កកើតអស្ចារ្យជនទាំងឡាយ ភ្លែងក្លាយទាំងគ្រប់សព្វសេចក្តី ។
តាំងតែអ្នកឆ្ងាយគេចូលមក នៅក្នុងគោកធ្លករាជបុរី
កកើតជាហេតុភេទផែនដី ទាំងមនុស្សប្រុសស្រីប្រែចិន្តា ។
ប្រែរបែកបោះបង់បែបបុរាណ គ្រប់ប្រាណពុំមានតាមតម្រា
សឹងត្រេកដោយទ្រព្យគ្រប់រូបា ពុំមានអ្នកណាតាមសណ្តាប់ ។
ទាំងនេះហេតុតែភេទសីមា ព្រះពុទ្ធសាសនាប្រែក្រឡាប់
បណ្តាលក្នុងចិត្តងងឹតអ័ត្ថ យកខុសជាគាប់ក្រឡាប់ប្រែ ។
អ្នកប្រាជ្ញប្រាប់ទៅខ្លៅមិនតាម មិនដោយទំនៀមទំនងខ្មែរ
ចចេសចិត្តឯងអាងពូកែ ដ្បិតតែមានគេមកនៅថ្មី ។
ខ្លះអាងខ្លួនឯងមានមាសប្រាក់ មានបុណ្យមានស័ក្តិជាមន្ត្រី
ហើយកើតធំចិត្តធំសម្តី ឥតបីឥតបើនឹងគណនា ។
តម្កើងខ្លួនឯងឱ្យគេខ្លាច ពាក្យប៉ោងកោងកាចទាំងឫកពា
មិនកោតមិនខ្លាចចាស់ព្រឹទ្ធា អាងមានទ្រព្យាជាទីពឹង ។
ខ្លះអាងខ្លួនឯងមានចំណេះ ប្រាជ្ញាវៃចេះជជែករឹង
ជជែកយកឈ្នះឈ្លោះទទឹង មិនមានរំពឹងគិតខុសត្រូវ ។
មានទ្រព្យគាប់ចិត្តស្បិត(*) ធ្វើបុណ្យ ភ្លាំងភ្លើនភ្លេចគុណម៉ែគុណឪ
គិតតែធ្វើស្រែនិងលក់ស្រូវ ឯផ្លូវទៅសួគ៌មិនគិតសោះ ។

(*) ស្បិត = មិន, មិនរវល់, មិនត្រូវការ

នេះហើយជាកម្មអកុសល មកផ្ដល់ឱ្យគ្មានបុណ្យឡើងសោះ
បើខាងស៊ីផឹកនឹកទាំងអស់ នោះទើបស្រួលស្រស់គិតរាល់ថ្ងៃ ។
ខ្លះមានបុណ្យស័ក្តិមាក់ងាយសង្ឃ ព្រោះសាងជាអង្គឯងថ្កើងក្រៃ
សំពះព្រះសង្ឃក្រែងថោកដៃ ឆ្មើងឆ្មៃវិស័យដូចក្រៅសាសន៍ ។
មានបុណ្យប៉ុណ្ណឹងប្រឹងក្រអឺត ចំកោងស្ដួយស្ដើតទើសអាកាស
ចង់ធំតែខ្លួនគ្មានគិតខ្មាស ចោលសង្ឃបង់សាសន៍ថ្លៃឧត្ដម ។
ជួនកាលត្រូវការដើរចូលវត្ត ពាក់មួកជាំងផ័ត្រធ្វើរម្យទម
ចូលក្នុងអារាមគ្មានអារម្មណ៍ អាងខ្លួនជាធំប៉ុណ្ណេះឯង ។
អ្នកអើយនេះហើយហៅលោភោ ទោសោមោហោនាំវង្វេង
បង្វែរនាំចិត្តឥតគិតក្រែង នេះហៅវង្វេងក្នុងសាសនា ។
មនុស្សលោកឥឡូវក្រៅក្រមក្រឹត្យ កើតមានទុស្តចិត្តបីប្រការ
ចិត្តមួយមិនខ្លាចគ្រូអាចារ្យ ចិត្តមួយសោតណាមិនខ្លាចចាស់ ។
ចិត្តមួយមិនខ្លាចម៉ែឪឯង ឥតកោតឥតក្រែងវែងក្រឡាស់
ក្រឡាប់ត្រឡប់គ្រប់សព្វសាសន៍ រាល់រូបរាល់រាស្ត្រសឹងវង្វេង ។
វិលវល់ក្នុងចិត្តគិតវិវរ ព្រោះភេទនគរកើតហេតុព្រេង
ទើបមានអកុសលដូច្នេះឯង ក្លាយក្លែងវង្វេងវរចិន្តា ។
នេះហៅប្រែរាជ្យសករាជ សិស្សសោតមិនខ្លាចគ្រូអាចារ្យ
កូនសោតមិនខ្លាចអ្នកមេបា រីឯភរិយាមិនខ្លាចប្ដី ។
កង្កេបមិនចង់ខ្លាចពស់វែក សត្វក្អែកចង់ជល់នឹងដំរី
ដើមចេកប្រុងជល់នឹងក្របី រីត្រីចង់ជល់នឹងបព្វតា ។
ហេតុភេទទាំងនេះកើតមានមក នាំឱ្យជនយកជាកិរិយា
សឹងចោលសណ្ដាប់ធ្នាប់មាត្រា ទើបលោកឧបមាដូច្នេះនៃ ។

គោស្រុកទៅចូលឯហ្វូងស្វា ឯឆ្មាបង់ផ្ទះទៅពឹងព្រៃ
មច្ឆាចោលបឹងទៅពឹងជ្រៃ ក្របីចោលត្រពាំងស្រឡាញ់ព្រែង ។
យកជាពំនាក់នៃអាត្មា ភ្លើងឆេះកាលណាទើបស្វះស្វែង
ភ្លើងឆេះរោលរាលដល់ខ្លួនឯង ទើបចោលបឹងព្រែងមករកត្រពាំង ។
រាជហង្សហើរបង់ចោលសម្បុក ហើរទៅយកកុកជាសម្លាញ់
ដល់មានព្រានព្រៃមកបរបាញ់ កុកស សស្រោញ់ហើរចោលហង្ស ។
ម្លោះហើយសុមនឹងអសារសូន្យ អន្តរាយខូចខ្លួនវិនាសបង់
ព្រោះព្រើលគំនិតចិត្តគិតចង់ សប្បាយទើបបង់ពីសម្បុក ។
លង់លុះមានភ័យដូច្នេះឯង ទើបបានស្វះស្វែងរកទីសុខ
រកទៅរកមកបានតែទុក្ខ ព្រោះបង់សម្បុកឋានអាត្មា ។
ហៃនៃអស់ជនទាំងឡាយអើយ អ្នកអើយនេះហើយហៅឧបមា
ឧបមេយ្យឱ្យដឹងហេតុគ្រប់គ្នា ការរងវេទនាជាប្រាកដ ។
ព្រោះជនមានចិត្តវិបល្លាស សាងអកុសលក្រាស់ដោយសន្ធត
លោភខឹងវង្វេងជាបែបបទ កំណាត់ឥតក្រែងឋានអវិចី ។
គ្មាននឹករលឹកទៅឋាននាយ គិតតែសប្បាយនៅលោកិយ
ចង់បានចង់មានហួសពេកខ្មី មានអ្វីអួតហ៊ឹងឥតគណនា ។
មានគោអួតគោពូកែតាប់ មានទ្រព្យអួតទ្រព្យប្រសើរជា
ចេះគូរអួតគូរឥតគណនា ចេះបៀអួតបៀឥតបើស្តី ។
មានកូនអួតកូនដោយដំណើរ មានក្តីអួតក្តីដោយមេត្រី
មានសេះអួតសេះឱ្យបានល្បី មានអ្វីអួតហ៊ឹងឱ្យបានខ្ពស់ ។
អ្នកណាដូច្នោះនោះលោកថា វីងស៊ុងមនុស្សាមហាឆោតហួស
សឹងលុះអំណាចខ្លៅជ្រុលជ្រួស ពីព្រោះមិនត្រូវគន្លងឡើយ ។

ហៃអ្នកទាំងឡាយចូរស្អាងចិត្ត ស្អាងកាយប្រព្រឹត្តទៅអ្នកអើយ
ដ្បិតព្រះសាសនាជិតដល់ហើយ កុំធ្វើតោះតើយគួរឱ្យប្រឹង ។
ធ្វើបុណ្យធ្វើទានកុំវៀនខ្លៅ កុំកាចឃោរឃៅឆោតឆាប់ខឹង
ធ្វើចិត្តឱ្យធ្ងន់ទន់ទើបនឹង បានជាពំនឹងទៅថាននាយ ។
សេចក្ដីនេះព្រែងអស់អ្នកផង ពុំដឹងទំនងការសម្ដាយ(*)
នូវអស់កិច្ចការផងទាំងឡាយ នៃនគរអាយកើតកូនខ្ចី ។
កូនមួយជាប្អូន មួយជាបង ដើរត្រាច់ត្រសងសាងបារមី
ឯអស់មហាជនទាំងប្រុសស្រី បានដឹងសេចក្ដីនៃសុខំ ។
ផ្គរលាន់ឯបូពិត្កណ្ដុក អ្នកតាចាស់ស្រុកឱបដៃយំ
កំពិសឡើងពងកំពូលភ្នំ ក្អែក សសំងំក្នុងគុម្ពព្រែង ។
ពោធិ៍ព្រឹក្សរាបគល់ពុំចាក់ឫស ពស់វែកត្រាំពិសផ្កាំកន្លែង
ក្របីលាក់ខ្លួនសម្រួចស្នែង រាជហង្សហើរស្វែងកាច់សម្បុក ។
ពពេចក្រាបពងក្រោមគង្គា ក្អែកពាំផ្លែល្វារាយគ្រប់ស្រុក
អ្នកផងឃើញហើយប្រឹងរើសទុក ចំណោរទៅមុខទើបដឹងខ្លួន ។
ស្វាក្រេះក្រញ៉ឹងប្រឹងហាត់គុន លុះឃើញសេះលុនទើបរត់ពួន
កុក ស កវែង ឯងអួតខ្លួន ថាស្គាល់ចំនួនត្រីក្នុងទឹក ។
កុកសាប់រកស៊ីកណ្ដាលត្រាញ់ សស្រាក់សស្រាញ់ពុំមានភ្លឹក
សីហានាទគគាតជាពន្លឹក ចាប់ត្រីរាល់ព្រឹកគ្មានមេត្តា ។
ខ្លាញីរកស៊ីក្នុងសមសាន្ត លាក់ប្រាណលំអានចាំសាសនា
លុះដល់ផ្គរលាន់បួនទិសា ទើបខ្លាឃ្មាត្រាពីក្នុងព្រៃ ។
ឱ្យអស់មហាជនស្រោយចំណោទ ដែលខ្ញុំចងចោទអាថិសេចក្ដី

(*) សម្ដាយ ( សំ_ម្ដាយ ) រាយរង, បន្ទាប់បន្ទុំ

បើអ្នកឯណាប្រាជ្ញាវៃ    ទើបដឹងសេចក្ដីនៃបញ្ហា ។
រីឯគោស្រុក និងកុក ស    សព្វថ្ងៃអបអរស្រឡាញ់គ្នា
ធ្វើហាក់ដូចមិត្តចិត្តស្នេហា    តែថាគំនិតគិតទីទៃ ។
ឯកុកនិងខ្លានៅដោយខ្លួន    មិនទាន់ជួបជួនគ្នាឡើយនៃ
តែជួបកាលណាអស្ចារ្យក្រៃ    សព្វសាសន៍ទីទៃភ័យមិនខាន ។
ដ្បិតអ្នកទាំងពីរសឹងកាចក្លាត់    អួតអាងអាវុធតែរាល់ប្រាណ
កាន់ឫទ្ធិចេស្ដាពន់ប្រមាណ    សឹងកាចហៅបានឥតឧបមា ។
ឥឡូវខ្ញុំសួរអ្នកទាំងឡាយ    ស្ម័គ្រចិត្តស្ម័គ្រកាយទៅខាងណា
ជាស្ម័គ្រខាងកុកឬខាងខ្លា    អ្នកមានប្រាជ្ញាទើបថាត្រូវ ។
រីមនុស្សរឹងស៊ិងអាវ៉ាសែ    ឃើញតែគេខ្ពស់ដូច្នេះក្ដូវ
ម្ល៉ោះហើយផ្ដេកខ្លួនចូលចិត្តទៅ    ឯបអបនិត្យនៅធ្វើអាត្មា ។
នេះហើយសង្គ្រាមសករាជថ្មី    អ្នកល្បីនិងល្បីល្បែងចេស្ដា
ឯត្រង់ឈ្មោះចាញ់មិនបានថា    តែនឹងឧបមាដូច្នេះនៃ ។
កង្កែបខ្លួនតូចទាបទេតើ    ផ្ទឹមម្ដេចឱ្យស្មើនឹងដំរី
កង្កែបនៅតែដោយរូងដី    ផ្ទឹមម្ដេចរាជសីហ៍មានគុហា ។
អំពិលអំពែកតូចមួយមិញ    ម្ដេចឡើយគិតផ្ដាញ់ព្រះចន្ទ្រា
សត្វចាបខ្លួនតូចឥតគណនា    ម្ដេចឡើយពុះពារជល់នឹងមាន់ ។
រីសោតកុកសាប់អាប់វង្សា    ម្ដេចឡើយប្រាជ្ញាហង្សសោភ័ណ
សំណាស្លួលាយកាឡៃស្មាន់    ផ្ទឹមម្ដេចសុវណ្ណមាសចរណៃ ។
ដូច្នេះអ្នកអើយចូរអ្នកគិត    រំពឹងក្នុងចិត្តកុំសង្ស័យ
ធម្មតាខ្លាផ្លាប់នៅក្នុងព្រៃ    កន្ទុយវែងវៃបំពេនទុក ។
ឥឡូវខ្លាដឹងដំណឹងជាក់    ជាគោមកស្ម័គ្រទាក់ទងកុក

វិស័យឯខ្លាទន្សាយស្រុក ដឹងហើយកើតទុក្ខឥតឧបមា ។
ផ្ទរលាន់ឯជើងភ្លើងឆេះទីក ឆេះដើមពោធិ៍ព្រឹក្សព្រៃបព្វតា
លុះដល់រស្មៀលព្រះសុរិយា ទើបខ្លាយាត្រាលត់ភ្លើងព្រៃ ។
ហែអស់មហាជនទាំងឡាយអើយ អ្នកអើយដឹងហើយគួររំពៃ
រំពឹងរកឋានខ្លួនទីទៃ រវៀសរវៃឱ្យឆាប់រ៉ា ។
សេចក្តីនេះមានមែនពិតហើយ អ្នកអើយកុំតុញទាល់ប្រាជ្ញា
រឿងនេះអ្នកប្រាជ្ញលោកឧបមា ឱ្យអ្នករាល់គ្នាគិតឱ្យយល់ ។
សាសនាពីរពាន់ប្អូនរយប្លាយ តាមដោយទំនាយព្រះទសពល
អ្នកបុណ្យចាប់ផ្តើក្នុងមណ្ឌល កើតកោលាហល់ខ្វល់ជំពាក់ ។
កើតកាប់ លួច ប្លន់ ក្នុងនគរ សង្គ្រាមវឹកវរគ្មានទីភាក់
គ្មានទីអាស្រ័យជាពំនាក់ ពំនឹងពឹងពាក់អាត្មាឡើយ ។
អ្នកអើយឮហើយគួរភាវនា ធ្វើបុណ្យគ្រប់គ្នាកុំកន្តើយ
សីលទានភាវនាធ្វើឱ្យហើយ ទើបអ្នកបានស្បើយពីទុក្ខភ័យ ។
ការនេះអ្នកប្រាជ្ញអាចប្រាយប្រាប់ ឱ្យអ្នកផងស្តាប់ហើយរវៃ
រវៀសសាងមគ្គផលប្រពៃ ដើម្បីឱ្យទាន់ព្រះសិអារ្យ ។
ហែអស់មហាជនផងទាំងឡាយ កុំភ្លើតភ្លើនកាយភ្លេចមាតា
ភ្លេចទាំងគុណគ្រូ គុណអាចារ្យ ទាំងគុណបិតានិងគុណបង ។
តែភ្លេចសឹងភ្លាត់ក្តីប្រាថ្នា ភ្លេចនេះហៅមហាខុសពេកហោង
អ្នកណាធ្វើតាមដោយតន្លង នេះហោងទើបបានដូចប្រាថ្នា ។
ឥឡូវនេះនឹងបង្អង់ស្លេះ បញ្ឈប់ប៉ុណ្ណេះពុំចរចា
សង្ខេបសេចក្តីនៃប្រស្នា សូរេចបការម្លេះឯងហោង ។

ចប់ សាស្ត្រាថ្ងៃសុក្រ

# សាស្ត្រាពារសៅរ៍

ពារសៅពេញបូរមីខែកត្តិក ចេញខ្យល់រអឹកពីឧត្តរា
ត្រជាក់ស្លួងស្លឹមអស់កាយា វាតារំភើយរហើយផាត់ ។
នៅក្នុងហិមន្តរដូវ ឆ្នាំខាលនោះក្ដូវត្រូវឯកស័ក
ព្រះសូរ្យចាំងចែងត្រូវក្តៅក្តាត់ ត្រីចុះច្រវាត់រកទឹកជ្រៅ ។
ចង្វាជ្រួលជ្រើមដណ្តើមច្រក ត្រីកុះករ កក រកលំនៅ
នន្ទៀលរាលរកទីជម្រៅ សំដៅរិះរកព្រៃកទីទៃ ។
សុរិយាទៀបទឹមចង្កេះភ្នំ ព្នមាត់សោកយំរំពងព្រៃ
លលកទំលើចុងឈើលៃ រងាវខ្លាំងក្រៃព្នលន្លោច ។
មើលឋានសន្លឹមត្រឹមលន្លង់ ឈើឈរខ្ពស់ខ្ពង់គួរស្រងោច
ស្រងាត់ក្នុងចិត្តគិតផ្សាខ្លោច កំណ្តុងកណ្តោចកណ្តាលឋាន ។
គន់មើលទៅវាល វាលវិវេក វែងធំក្រៃពេកពន់ប្រមាណ
មើលសត្វវែងថប់អាណិតប្រាណ ព្រោះដោយឃ្លាតឋានទីកន្លែង ។
ពេលព្រឹកមើលមេឃមីរងងឹត ព[illegible]កឈើរជិតរុំជុំផ្សេង
ថ្ងៃត្រង់គ្រលួចព្រះសូរ្យសែង បក្សីហើរស្វែងចុះបឹងជ្រៅ ។
ភិរុណរាំងរីងរែងហែងហួត គោកទឹកភក់ស្ងួតគ្រប់លំនៅ
ស្រវលាស់ដង្ហឹខៀវខ្ចលខ្មៅ ទឹកហូរចុះទៅតាមជ្រលង ។
មើលសត្វច្រវាត់ហើរខ្សៀវខ្សារ ស្វែងរកមច្ឆាឆោឡោកង
ព្នស័ព្ទយំស្រែកស្ងួររំពង ហើយហើរត្រសងដោយហ្វូងវា ។
គន់មើលទៅសត្វវែងសញ្ជប់ សញ្ជឹងគិតគ្រប់មើលមេឃា
ឃើញហើយនឹកដល់ក្តីវេទនា ដោយខ្លួនកំព្រាព្រាត់កន្លែង ។

មើលស្រុកមើលស្រែប្រែទាំងគ្រប់ ក្នុងផែនដែនភពត្រៃនេះឯង
គន់មើលសព្វៗថប់ចំបែង គិតក្រែងក្រៀមក្រំមិនមានស្បើយ ។
ដ្បិតមើលទៅជនផងទាំងឡាយ សឹងតែប្រែក្លាយទៅអស់ហើយ
មិនគង់កំណត់ដូចដើមឡើយ នឹកហើយរែងថប់ពន់ប្រមាណ ។
ហេតុដោយវេរាជសករាជ អ្នកខ្លៅមិនខ្លាចអ្នកប្រាជ្ញប្រាណ
បក្សារែងជាស្អប់សមសាន្ត មនុស្សលោកក្នុងឋានស្អប់ព្រៃព្រឹក្ស ។
រីក្មួនមិនខ្លាចអ្នកមេបា រីមហាក្សត្រាមិនជឿឫក្ស
ហោរាមិនជឿរាជបណ្ឌិត អាចារ្យព្រតព្រឹទ្ធមិនជឿបុណ្យ ។
រីសិស្សមិនជឿគ្រូអាចារ្យ ក្នុងចិត្តគិតថាគ្រូគ្មានគុណ
រីឯពេទ្យហ្មមិនជឿមន្ត មហាជនឥឡូវដូច្នេះឯង ។
នេះហើយហេតុតែព្រះសាសនា ប្រែភេទក្រឡាឱ្យវង្វេង
វិលវល់ក្នុងចិត្តឥតគិតក្រែង បង្វែងឱ្យវរក្នុងចិន្តា ។
យកខុសជាត្រូវ ត្រូវជាខុស សេចក្ដីដូច្នោះហេតុសាសនា
កើតកង្វល់ក្នុងរាជសីមា អស្ចារ្យទាំងគ្រប់សព្វសេចក្ដី ។
អ្នកខ្លះមានទ្រព្យគាប់ចិន្តា ហើយមិនប្រាថ្នាសម្បត្តិបី
នឹករកតែក្នុងនាលោកិយ ទាំងប្រុសទាំងស្រីសឹងដូចគ្នា ។
មានទ្រព្យគាប់ចិត្តស្បិត(*) ធ្វើបុណ្យ មិនមានគិតគន់គ្រប់ប្រការ
តម្កើងចង់ធំតែអាត្មា ក្នុងចិត្តគិតថាអញថ្កើងហើយ ។
ខ្លះអាងយសស័ក្តិមាក់ងាយសង្ឃ ក្នុងចិត្តមិនចង់កោតខ្លាចឡើយ
បើធ្វើការបុណ្យនឹងគេហើយ ព្រងើយកន្តើយមិនឱបាត ។
ប្រើគេប្រើឯងមិនក្រែងចិត្ត ព្រោះដោយគំនិតគិតប្រមាថ
ធ្វើបុណ្យធ្វើទានគ្មានសង្វាត ដោយខ្នាតព្រះពុទ្ធនោះគ្មានសោះ ។

ធ្វើបានតិចតួចចង់ធំមុខ
តែងតួលើកទុកឱ្យថ្កើងខ្ពស់
មិនឱ្យនរណាស្មើខ្លួនសោះ
ស្មើហើយគិតឈ្លោះអាក់ចិន្តា ។
មនុស្សខ្លៅលោកហៅវង្វេងវិណ្ណ
ស្រឡាញ់ទ្រព្យធនស្មើអាត្មា
ស្រឡាញ់នរកលើសសួគ៌ា
ព្រោះដោយកាមានាំងងឹត ។
វេងវោងក្នុងកាយស្ដាយទាំងគ្រប់
វង្វេងវោកងប់មិនមានគិត
ចង់ឱ្យបានថ្កើងខ្ពស់ដូចចិត្ត
ហេតុដោយងងឹតក្នុងអវិជ្ជា ។
មានគោអួតគោពូកែគាប់
មានទ្រព្យអួតទ្រព្យប្រសើរជា
ចេះជាងអួតជាងឥតគណនា
ចេះបៀ អួតបៀឥតបើស្ដី ។
នេះហើយហៅហេតុតែលោភោ
ទោសោមោហោអន្យត្តិរិយ
មកនាំឱ្យភ្លួតក្នុងលោកិយ
ឥតបីឥតបើភ្លេចតិចឡើយ ។
ភ្លេចសីលភ្លេចទានភ្លេចទោសគុណ
ភ្លេចបាបភ្លេចបុណ្យសូន្យអស់ហើយ
បង់ចោលព្រះធម៌ចេញកន្តើយ
អ្នកអើយនេះហើយហៅវង្វេង ។
មនុស្សយើងឥឡូវត្រូវបានគេ
ចូលមកជាមេធំចិញ្ចឹង
ចោលសាសន៍ស្រឡះពីសាសន៍ឯង
អ្វីៗទន្ទេងនាំចូលដែរ ។
កើតហេតុតិចតួចផ្ដួចផ្ដើមឡើង
ចចេសចចើងអួតពូកែ
មិនមានគិតគន់ត្រកូលខ្មែរ
នេះហើយហៅប្រែកោលាហល ។
អនិច្ចារូបអើយរាល់តែកាយ
ដែលកើតដែនអាយអកុសល
រំពឹងគន់គិតសែនថប់សល់
ព្រោះដោយមណ្ឌលមកកើតភេទ ។
ភេទអើយកើតមកពីឯណា
កើតពីអាត្មាឯងមែនពិត
ពឹងគេលលើធ្វើជាមិត្ត
មិនមានហៅគិតឱ្យវែងឆ្ងាយ ។
គន់មើលសាសន៍ឯងវង្វេងអស់
មិនសល់មួយសោះសូន្យសព្វសាយ
ថាបើដូច្នេះអ្នកទាំងឡាយ
ចូរស្ដាប់បរិយាយអ្នកប្រាជ្ញប្រាប់ ។

ឱ្យដឹងពីទីរាជក្រុងក្រៅ
ហៃអ្នកទាំងឡាយចូរចាំស្តាប់
ដំណើរអំពីបុរីរម្យ
រល្បើងល្បើងពីពុទ្ធទំនាយ
ព្រោះដោយនគរកើតមានកម្ម
មកកើតវិវាទគ្រាឥឡូវ
ហៃអ្នកទាំងឡាយចូរផ្តែងស្តាប់
ន័យនេះអ្នកចេះលោកចាត់ចែង
អស់អាថ៌កិច្ចការក្នុងបុរី
ទំនងឱ្យអស់អ្នកផងដឹង
តាមដោយប្រាជ្ញប្រាណបានដឹងន័យ
កើតមានហេតុភេទគ្រប់ប្រការ
ផ្ទះលាន់ឯបូព៌ាអ្នកណ្តុក
កំពិសពងលើកំពូលភ្នំ
ពោធិ៍ព្រឹក្សកំពុងតែចាក់ឫស
ក្របីលាក់ខ្លួនសម្រួចស្នែង
កង្កែបអាចម៍គោលាលោតទំ
ផ្តើងគេវ៉ី ផ្តើងយសសែនត្រសាល
ដីរោងរត់រកទ្រមាក់
ទម្រាំចាំពេលវេលាបាន
ក្អែកហើរមកពីឧត្តរ
បបួលគ្នីគ្នាហោះហើរស្វែង

គោកធ្លាក់វិស័យដោយក្បួនច្បាប់
អ្នកប្រាជ្ញអាចប្រាប់ដោយទំនាយ ។
ខុសក្រៅក្រឹត្យក្រមក្បួននិយាយ
ព្រះឥន្ទលោកទាយក៏មិនត្រូវ ។
ពីនាយមកនាំផ្លូវច្មេះក្លូវ
កម្មរត់ឱ្យត្រូវផ្លូវច្មេះឯង ។
អស់អាថិសាស័ព្ទសេចក្តីថ្លែង
ចំណោទថ្នាថ្លែងឱ្យបានដឹង ។
ទើបចែងសេចក្តីជាដំណឹង
គ្រាហ្នឹងទើបចែងជាប្រស្នា ។
កិច្ចការទីទៃក្នុងសីមា
អ្នកណាកាត់យល់មានព្រេងធំ ។
អ្នកតាចាស់ស្រុកឱបដៃយំ
ក្អែក សសំងំក្នុងគុម្ពព្រៃង ។
ពស់វែកមានពិសដិតន្លែង
លុះទឹកលិចព្រៃងទើបចេញវាល ។
លើកំពូលភ្នំធំត្រកាល
ចំអើតមើលវាលលេងកម្សាន្ត ។
ឃើញម្លប់ត្រជាក់សំណាក់ប្រាណ
ទើបចរចេញឋានម្លប់នោះឯង ។
ជួបនឹងក្អែក ស ក្នុងគុម្ពព្រៃង
រកទឹកន្លែងលេងទីទៃ ។

ពពេចសត្វអើយហើរនាំក្បួន ខ្លាធំលាក់ខ្លួនពួនក្នុងព្រៃ
ពពេចចូលជ្រកក្រោមដើមជ្រៃ សញ្ចប់ចាំថ្ងៃមើលវេលា ។
ត្រីក្រាញ់ក្រញូក្រាបក្រោមបាតភ្នំ ត្រីក្រឹមសំងំក្រោមគុម្ពស្តា
ខ្លាខ្វាក់ងងឹតកុំថាជា ក្រចកជើងវាក្តោបក្តាប់ដី ។
បឹងធំត្រដែតកណ្តាលព្រៃ សព្វសត្វទីទៃសឹងពឹងពាក់
អាស្រ័យសព្វថ្ងៃជាពំនាក់ ព្រោះដោយត្រជាក់សុខសប្បាយ ។
ឥឡូវទឹករីងហែងហួតអស់ ត្រីនឹកស្រណោះអាណិតកាយ
ព្រោះដោយកុកក្រកមកកម្ចាយ កម្ចាត់ចាប់កាយជាចំណី ។
ក្អែកពាំផ្លែល្វារាយគ្រប់ស្រុក អ្នកតាកើតទុក្ខមិនចេញស្តី
ចាំស្តាប់ផ្គរលាន់ទិសប្រាំបី លាន់ឮក្រោមដីធ្ងន់កណ្តុក ។
រាជហង្សហើរបង់ចោលសម្បុក ហើរទៅយកកុកជាសម្លាញ់
លុះមានព្រានព្រៃមកបរបាញ់ កុកសោតចេញហើរចោលហង្ស ។
ម្លោះហើយសមនឹងអសារសូន្យ អន្តរាយខូចខ្លួនវិនាសបង់
ព្រោះដោយគំនិតគិតចើកចង់ ឱ្យបានថ្កើងអង្គក្នុងលោកិយ ។
មុខគួរស្រណោះតែគោកធ្លក ពីដើមវៀងមកគ្មានព្រួយអ្វី
ឥឡូវស្មាពីរលើឃ្មាងបី អ្នកស្រុកប្រុសស្រីស្តីដើមឯង ។
ពានរចាប់កូនជូនឱ្យខ្លា ស៊ីជាអាហារសប្បាយលេង
មិនមានអាណិតគិតកូនព្រេង ហេតុដោយវង្វេងភ្លេចវិញ្ញាណ ។
ឱះឱ ! អាសូររាជសីហ៍សត្វ ម្តេចឡើយជ្រកបាត់ព្រៃហេមពាន្ត
មិនឃើញអ្នកចេញមកទូន្មាន ឬអាក់អន់អៀនដំណើរអ្វី ។
ឬមួយឃើញបឹងរីងហែងហួត ភិរុណរាំងស្ងួតវិនាសត្រី
ឬឃើញស្មាពីរលើឃ្មាងបី បានជាអ្នកថ្លៃមិនចេញមក ។

បាត់សូន្យយ៉ាងហ្នឹងដឹងយ៉ាងណា ឬចាំអាចារ្យទៅតាមរក
ឬមួយគ្មានមួប់នឹងឈប់ជ្រក ទើបកែវពន្លកមិនមកអាយ ។
ម្ដេចអ្នកមិនអាសូរសព្វសត្វ រង់ចាំពេកក្ដាត់លំបាកកាយ
សព្វថ្ងៃគ្មានសោះហៅសប្បាយ ព្រួយណាស់ហើយណាយឥតឧបមា ។
ហៃជនទាំងឡាយចូរស្ដែងស្ដាប់ អស់អាថិសាស័ព្ទគ្រប់ប្រការ
ពីលោកអ្នកប្រាជ្ញថែងចរចា ចោទចង់ប្រស្នាដោយប្រាជ្ញប្រាណ ។
ព្រោះដោយបានដឹងដំណឹងច្បាស់ ប្រាកដជាក់ណាស់ទើបនិទាន
ឱ្យអស់អ្នកផងទើបបានយ៉ាន អ្នកអើយគ្រប់ប្រាណស្ដាប់ប្រស្នា ។
នេះឯងឱ្យដឹងបានច្បាស់ជាក់ បើដឹងហើយអ្នកកុំចរចា
រង់ចាំមើលទៅតាមសាសនា ធម្មតាសាសនាខ្មែរមិនសូន្យ ។
វិស័យស្រមោលមិនចោលប្រាណ ស្រីង្គារក្នុងឋានមិនបង់ខ្លួន
រីឯដង្ហៅមិនចោលក្បូន មាតានិងកូនមិនដែលបង់ ។
អ្នកអើយឮហើយតួររំពឹង ទប់ចិត្តឱ្យនឹងទាត់ទៀងត្រង់
ណាៗអ្នកកុំចោលព្រះសង្ឃ ខ្ទីឃ្មាតតម្រង់កុំតាមគេ ។
ដ្បិតរាជ្យឥឡូវខុសសណ្ដាប់ ក្រពើលង់ស្លាប់ក្នុងទន្លេ
មច្ឆាខ្លាចបឹងអ្នកដឹងទេ កូនខ្លាខ្លាចមេភេខ្លាចត្រី ។
អន្ទង់ខ្លាចភក់កុកព្រើបឹង ស្វាព្រែះក្រញឹងចេះស្រដី
ឈើធំមួយដើមបង្អោងបី ទិវាប្រុសស្រីស្រឡាញ់ប្រេត ។
សម្បកឃ្លោកលិចក្នុងទឹកស្រែ អំបែងបែកបែរជាអណ្ដែត
នេះហើយហៅកើតកាលភេទ ផ្គរលាន់ខែចេត្រភ្លៀងលិចស្រុក ។
លិចស្រែចម្ការច្បារដំណាំ លិចព្រៃកទាំងប្រាំត្រពាំងថ្លុក
ទើបត្រីទាំងឡាយសប្បាយសុខ ស្បើយទុក្ខរីកមុខដោយសារភ្លៀង ។

ភ្លើងភ្លឺប៉ផ្លុងកណ្ដាលព្រៃ រោលរាលដល់ន័យស្រីមានរាង
សំពត់ពេញដីស្រីមិនលាង ព្រោះឃើញទឹកភ្លៀងពីលើភ្នំ ។
សេចក្ដីចំណោទអស់នេះណា ចែងតាមប្រាជ្ញាគិតផ្សៃផ្សំ
លើកតាមហេតុភេទបុរិម្យ កើតខុសក្រឹត្យក្រមទំនៀមខ្មែរ ។
ចំពូកមួយទៀតខ្ញុំគិតថា ចង់ដឹងប្រាជ្ញាអ្នកស្រុកស្រែ
ក្រែងមានលោកណាប្រាជ្ញពូកែ អាចកាត់បកប្រែស្រាយដឹងទៅ ។
សាសន៍ខ្មែរដូចគ្នាខ្ញុំមិនស្អប់ ឃើញហើយខ្ញុំថប់កើតហ្មងសៅ
ទើបបានជាខ្ញុំសុំប្រដៅ រំលឹកឱ្យត្រូវតាមមាត្រា ។
ដ្បិតឃើញចម្លែកក្រែពេកពន់ មានខ្លះធ្វើបុណ្យហើយផឹកស្រា
មិនមានអារម្មណ៍ពិចារណា តាមតែចិន្ដាអាត្មាឯង ។
មានខ្លះនិយាយនឹងព្រះសង្ឃ ពាក្យស្មើពុំចង់គោរពខ្លាចក្រែង
មានកាលកំហល់ស្រែកកំហែង អ៊ី អើ អញ ឯង អាងអំណាច ។
ឃើញលោកអំណត់អត់មិនថា កើតក្នុងចិន្ដាថាលោកខ្លាច
ធ្វើឫកធ្វើពាជាអ្នកកាច មាក់ងាយអ្នកប្រាជ្ញមិនមានខ្មាស ។
ឃើញគេមានឫកគួរសមសួន គ្រាន់បើជាងខ្លួនដោយកិត្តិយស
ឯងច្រណែនក្នាញ់នៅក្នុងពោះ ប្រឹងលើកខ្លួននោះឱ្យដូចគេ ។
ខ្លះឃើញគេមានរបស់ទ្រព្យ អ្នកផងតែងរាប់ទុកជាមេ
ឯងនឹកច្រណែននិន្ទាគេ លបលួចស្ដីជេរដោយសារខឹង ។
នេះឯងមោហោនាំងងឹត វង្វេងក្នុងចិត្តឱ្យដូចហ្នឹង
ដូច្នេះអ្នកអើយបើមិនដឹង ចូរស្ដាប់ដំណើងខ្ញុំនិទាន ។
តែងតាមនិទ្ទេសដោយទំនង ដំណើរដើមទងមនុស្សឈ្លានពាន
ចិត្តកើតបណ្ដាលឱ្យហេតុមាន គ្រប់ប្រុសគ្រប់ប្រាណដែនដីអាយ ។

ដែលកើតលោភានាំងងឹត ភ្លេចសព្វលើសសាយកាយសុចរិត ។
គិតឃើញតែស្តាយគ្រប់ប្រការ នេះហើយហេតុថាកម្មនាំចិត្ត
កង្វល់ខ្វល់ខ្វាយឆ្ងាយមិនគិត ងងល់ងងឹតគ្រប់ប្រការ ។
នេះហើយជាកម្មមកបាំងបិទ ឱ្យខ្វល់ងងឹតដូច្នេះណា
វិលវល់មិនយល់គ្រប់ប្រការ សូន្យសព្វសញ្ញាមហាងងឹត ។
មានខ្លះភ្លេចគុណអ្នកម៉ែឪ ឃើញចាស់សក់ស្កូវរោគរោមរឹត
បោះបង់មិនចង់ឱ្យមកជិត ព្រោះដោយគំនិតគិតខ្លាចខាត ។
មានទ្រព្យច្រើនហើយក្រវើនទុក ធ្វើមានទៅមុខកោលាហល
ធ្វើវត្តប្រតិបត្តិសោតណាសល់ ហើយរក្សាដល់ភ្នក់បីហោង ។
រីអ្នកម៉ែឪត្រូវចាស់ៗ ពិបាកពេកណាស់ពន់កន្លង
ឃើញកូនមានទ្រព្យមកនៅផង ឯកូននោះហោងមេត្តាគ្មាន ។
នៅផ្ទះខ្ជិលណាស់មិនធ្វើការ ដេកឆីដោយសារកម្លាំងប្រាណ
ម្ល៉ោះហើយជិនឆ្អន់ពន់ប្រមាណ ខេខឹងមិនខានមួយវេលា ។
មានកាលបើបានចំណីឆ្ងាញ់ ក្នុងចិត្តនោះមិញខឹងមហិមា
បញ្ឆោះទៅឱ្យទាំងខ្ជិលខ្ជា សម្ដីតរកៀវកែកល់ថា ។
ឃើញចាស់នៅក្អក់ក្អាញ់ក្នុងចិត្ត ធុញថប់គំនិតគ្រប់ប្រការ
ស្តីនាយស្តីឱ្យដោយប្រាជ្ញា ព្រោះដោយចិន្តាចង់បានមាន ។
រីខ្ញុំនិទានតែងសេចក្តី ពុំសូវគប្បីដោយវោហារ
ពីព្រោះគ្រាន់មើលល្បងប្រាជ្ញា ប្រាថ្នាសង្ខេបប៉ុណ្ណេះហោង ។

ចប់ សាស្ត្រាល្បើកថ្ងៃសៅរ៍

# អំពីព្រះបាទធម្មិក

ចំណោរតទៅមុខ នៅក្រឡាផ្ទៃក្រោមនេះ នឹងមានកើតកោលាហលជាអំពល់ទុក្ខសឹងតែរកពេលស្រាកស្រាន្តមិនបានឡើយ ដោយសារស្តេចទាំង ៨ ទិសចេះតែច្បាំងគ្នាមិនមានឈប់ឈរសោះ ។ ព្រះឥន្ទ្រាធិរាជបើកទិព្វចក្ខុសម្លឹងមើលមកឃើញដូច្នោះ ព្រះអង្គនឹកសង្វេគក្នុងព្រះហឫទ័យពន់ពេក ។ កាលបើព្រះឥន្ទ្រទ្រង់ទតឃើញហេតុភេទដែលកំពុងកើតឡើងអស់អាថិសេចក្តីដូច្នោះ ព្រះអង្គក៏ទ្រង់យាងទៅរកទេវបុត្រមួយអង្គ ។ លុះទៅដល់បានជួបជាមួយទេវបុត្រហើយ ព្រះឥន្ទ្រាធិរាជ ក៏ត្រាស់ទៅទេវបុត្រនោះថា ៖ « យើងបានឃើញហេតុការណ៍ដ៏សែនអាក្រក់ក្រៃ កំពុងកើតឡើងនៅឋានមនុស្សលោក គឺមានការកើតប្លន់ កាប់ចាក់សម្លាប់គ្នា ព្រមជាមួយនឹងចម្បាំងរាំងជល់ ។ នេះឯងក៏ព្រោះតែស្តេចទាំង ៨ ទិសចេះតែកើតវិវាទនឹងគ្នាមិនមានឈប់ឈរសោះ ។ អាស្រ័យហេតុនេះ សូមព្រះអង្គយាងទៅយោនយកកំណើតកើតជាមនុស្សលោក នៅនគរគោកធ្លក ដើម្បីឃាត់ស្តេចទាំង ៨ ទិស កុំឱ្យឈ្លោះគ្នាតទៅទៀត » ។

ទេវបុត្របានស្តាប់ឮដូច្នេះហើយ ព្រះអង្គក៏ត្រាស់សួរទៅព្រះឥន្ទ្រាធិរាជវិញថា ៖ «តើខ្លួនខ្ញុំព្រះករុណាមានអំណាចអ្វីទើបបានជាអាចទៅឃាត់ស្តេចទាំង ៨ ទិសនោះឱ្យឈប់ច្បាំងគ្នាបាន ?» ។ ព្រះឥន្ទ្រាធិរាជក៏ឆ្លើយតបវិញថា ៖ «ព្រះអង្គឯងនេះហើយជាព្រះបាទធម្មិក» ។ ទើបទេវបុត្រនោះលាអស់ស្រីស្នំក្រមការ ដោយមានព្រះបន្ទូលប្រាប់ថា «អញទៅតែ ៥ ថ្ងៃទេ អញនឹងត្រឡប់មកវិញហើយ» ។

ព្រះបាទធម្មិកក៏យាងចុះមកចាប់បដិសន្ធិនៅក្នុងផ្ទៃនៃព្រះមាតា ក្នុងខត្តិយត្រកូល ដែលទ្រង់រក្សាខ្លួននៅតែមួយអង្គឯង ហាក់បីដូចជាស្រីក្រមុំ ដិបូងគង់នៅក្នុងព្រះរាជវាំង ដែលនៅចំទន្លេប្រសព្វមុខទាំង ៤ ក្រោយមកក៏លើកព្រះរាជវាំង

ទៅនៅខាងត្បូងនោះបន្តិច រួចក្រោយមកទៀត ទើបលើកមកនៅចំទន្លេប្រសព្វមុខ ៤ វិញ ។ គឺនៅទីនោះហើយ ដែលព្រះបាទធម្មិកទ្រង់ចុះមកចាប់បដិសន្ធិ និងទ្រង់ប្រសូតមកជាបុត្រព្រះមហាក្សត្រនៅក្នុង ព.ស. ២៤៦៤ ត្រូវនឹង គ.ស. ១៩២០ ។ ព្រះអង្គមានសម្បុរដូចចេកទុំ មានរាងតូចទាប ដំណើរល្វាសល្វន់ ហាក់បីដូចជាមនុស្សស្រី មានព្រះទ័យល្អ សុភាពស្លូតត្រង់ ។

តាំងពីកាលដែលព្រះអង្គធម្មិក ទ្រង់បានមកដឹកនាំនគរគោកធ្លកមក នគរនេះ សឹងបានប្រកបដោយសេចក្ដីសុខសប្បាយ ចំរើនរុងរឿងពន់ពេកណាស់ ។ អ្នកណារត់មកសុំជ្រកនៅក្នុងនគរគោធ្លក អ្នកនោះនឹងបានសុខ រួចចាកផុតពីចម្បាំង ។ ប្រជារាស្ត្រនៅក្នុងនគរនេះ មានរូបរាងស្អាតដូចៗគ្នា ទាំងអ្នកនៅទីក្រុង ក៏ដូចជាអ្នកនៅជនបទចុងកាត់មាត់ញក មិនថាស្ដេច ឬរាស្ត្រខ្មែរ ឬចិនទេ ។

អំពីឆ្នាំកំណើតរបស់ព្រះបាទធម្មិកនោះ មានការអះអាងខុសគ្នា ។ តាមតាម្នាក់ឈ្មោះ ឡាង នៅសង្កាត់ចុងជាច, ស្រុកទឹកជ្រៅ ខេត្តកំពង់ចាម គាត់បាននិយាយប្រាប់ខ្ញុំក្នុងខែស្រាពណ៍ ឆ្នាំ ១៩៧៧ ថា ព្រះបាទធម្មិកជាបុត្រព្រះមហាក្សត្រ ថាព្រះអង្គទ្រង់មានទ្រព្យសម្បត្តិជាច្រើន ប៉ុន្តែទ្រង់ធុញថប់នឹងជីវិតជាគ្រហស្ថពេក ព្រះអង្គទ្រង់លះបង់ទ្រព្យសម្បត្តិដើម្បីជាប្រយោជន៍ដល់ប្រទេសជាតិ រួចក៏ទ្រង់ចេញទៅសាងព្រះផ្នួសបាត់ទៅ ។ គឺក្សត្រអង្គនេះហើយដែលជាព្រះបាទធម្មិក ។ លោកតាឡាងបានសូត្រកំណាព្យ ដែលគាត់នៅចាំបានតែបន្តិចបន្តួចនោះថា « កើតក្នុងឆ្នាំកុរ ខែចេត្រពេញបូណ៌ ថ្ងៃសៅរ៍ផងណា អ្នកនោះឯងជា ពូជពង្សវង្សក្សត្រ។ សព្វថ្ងៃកំព្រា លំបាកវេទនា រស់នៅខ្វាត់ព្រាត់ គ្មានទីលំនៅ ដើរត្រាច់រង្គាត់ ហៅសែនកម្សត់ សុំទានគេស៊ី ។ .... លុះបានព្រះជន្ម ៥៥ វស្សា ម្ចាស់យើងនេះណា មានបុណ្យកន្លង .... » ។

តាមការនិទានរបស់ចាស់ៗខ្លះទៀត នៅសង្កាត់ចុងជាចដដែលនោះថា

ព្រះបាទធម្មិកទ្រង់សាងផ្នួសនៅក្នុងព្រៃមួយនៃភ្នំជាយត្បែង ។ នៅពេលដែលព្រះអង្គត្រូវបានទៅជាអ្នកមានបុណ្យបារមីដោយព្រះអង្គមិនដឹងខ្លួន ព្រះអង្គកំពុងគង់នៅលើផ្ទាំងសិលាមួយដុំ គ្រងចីវរចាស់ ហើយមានរបែកដោយអន្លើផង ។ មានចិនម្នាក់បានបើកក្បួនក្នុងគម្ពីរមើលទៅ ឃើញសេចក្តីដូច្នោះហើយ ក៏លិតគម្ពីរនោះដើរស្វែងរកព្រះបាទធម្មិកនៅតាមកន្លែង ដូចមានចែងក្នុងគម្ពីរនោះ ។ លុះទៅជួបព្រះអង្គហើយ ចិននោះក៏សួរព្រះអង្គថា «តើព្រះអង្គនេះហើយឬជាព្រះបាទធម្មិក ?» ។ ព្រះបាទធម្មិកទ្រង់ឆ្លើយប្រកែកថា « ទេ ! អាត្មាមិនមែនជាព្រះបាទធម្មិកទេ » ។ ចិននោះក៏ដើរស្វែងរកតទៅទៀត ។ លុះគាត់បើកក្បួនមើលហើយដើរចុះដើរឡើងតាមក្បួននោះទៅ គាត់ក៏មកដល់ទីកន្លែងដដែល ។ គាត់ក៏សួរទៅព្រះសង្ឃដដែលនោះនូវសំណួរដដែល តែព្រះអង្គប្រកែកដូចមុន ។ ចិននោះក៏ធ្វើដំណើរចេញពីទីនោះ ដើរចុះដើរឡើងទៅតាមក្បួន ក៏មកដល់ទីដដែលនោះវិញ ។ លើកនេះគាត់ប្រាកដក្នុងចិត្តថា គ្មាននរណាក្រៅពីព្រះអង្គនេះទេ ដែលជាព្រះបាទធម្មិកនុ៎ះ ។ គាត់ក៏ទូលទៅព្រះសង្ឃនោះថា « ទេ ! គឺព្រះអង្គនេះហើយ ដែលជាព្រះបាទធម្មិក ពីព្រោះបើតាមគម្ពីរ មានការចែងមកថា ព្រះបាទធម្មិកត្រូវគង់នៅកន្លែងហ្នឹងឯង ។ ដូច្នេះគ្មានអ្នកណាក្រៅពីព្រះអង្គទៀតទេ ដែលជាព្រះបាទធម្មិកនោះ » ។

ព្រះបាទធម្មិកក៏ត្រាស់តបទៅចិននោះថា « បើអាត្មាជាព្រះបាទធម្មិកមែននោះ ព្រះបាទធម្មិកត្រូវមានសម្លៀកបំពាក់សម្រាប់ខ្លួន » ។ ពេលនោះ គ្រឿងអលង្ការសម្រាប់ព្រះបាទធម្មិកក៏ផុសឡើង ។ បន្ទាប់ពីទ្រង់គ្រឿងរួចហើយ ព្រះបាទធម្មិកក៏មានព្រះបន្ទូលថា « ព្រះបាទធម្មិកត្រូវមានដំរីស ភ្លុកខៀវ » ។ ភ្លាមនោះក៏ស្រាប់តែដំរីសភ្លុកខៀវផុសចេញមក ។ ព្រះបាទធម្មិកក៏ឡើងគង់លើជំនិះនោះដែលហោះនាំយកព្រះអង្គទៅ ។

កាលនោះ ស្តេចទាំង ៨ ទិស កំពុងច្បាំងគ្នាយ៉ាងសម្បើម ដណ្តើមយក

ឧត្តមភាពតែរៀងៗខ្លួន នរណាក៏តាំងខ្លួនឯងជាព្រះបាទធម្មិកដែរ ។ ស្ដេចទាំងនោះធ្វើសឹកជាមួយគ្នាយ៉ាងខ្លាំងក្លា រហូតដល់ឈាមហូរដាបពោះដីរ នៅទន្លេបួនមុខនោះ ។ កាលបើព្រះបាទធម្មិកយាងទៅដល់ទីនោះ ហើយទ្រង់ប្រកាសថា ព្រះអង្គនេះឯងដែលជាព្រះបាទធម្មិកដែលត្រូវយាងមកទីនេះ ដើម្បីឃាត់ស្ដេចទាំង ៨ ទិសនោះឱ្យឈប់ច្បាំងគ្នា ស្ដេចទាំង ៨ ទិសនោះ មិនព្រមជឿ មិនព្រមស្ដាប់ព្រះអង្គឡើយ ។ លុះព្រះអង្គយាងចូលទៅកាន់តែជិត ស្ដេចទាំងនោះក៏នាំគ្នាបាញ់សំដៅទៅរកព្រះអង្គ ។ ខណៈនោះ ស្រាប់តែមានកើតហេតុជាអស្ចារ្យ ដោយសារកាំភ្លើងទាំងនោះ ដែលគេបាញ់សម្រុកសំដៅទៅរកព្រះបាទធម្មិកនោះ បែរជាចេញតែទឹកជាជំនួសគ្រាប់កាំភ្លើងទៅវិញ ។ ឃើញដូច្នោះហើយ ទើបស្ដេចទាំង ៨ ទិស ព្រមចុះចាញ់ និងទទួលស្គាល់ព្រះអង្គថាជាតួអង្គព្រះបាទធម្មិកពិតមែន ។

ព្រះបាទធម្មិក ទ្រង់ពុំសោយរាជសម្បត្តិទេ ព្រះអង្គគ្រាន់តែជួយរៀបចំស្រុកទេសឱ្យបានសុខ ឱ្យបានសន្តិភាព មានរបៀបរៀបរយ មានក្បួនច្បាប់ឡើងវិញ រួចហើយព្រះអង្គក៏យាងចេញទៅសាងព្រះផ្នួសបាត់ទៅ ។ ចាប់ពីពេលនោះមកនគរគោកធ្លកយើង ត្រូវដូរឈ្មោះទៅជានគរ « វង្កតបុរិ » ហើយក៏បានស្គាល់នូវសេចក្ដីសុខ សេចក្ដីចំរើនយ៉ាងយូរអង្វែងឆ្នាំ មាននគរ ១២០ ជាចំណុះ ។

ចប់ទំនាយ អំពីព្រះបាទធម្មិក
ដោយសង្ខេប

សូមអានសេចក្ដីពិស្ដារនៅទំព័រជាបន្ទាប់ទៅនេះ ។ ក្បួននិមួយៗ មានការខុសប្លែកគ្នាបន្តិច មិនដឹងជាដោយមូលហេតុអ្វី ។ ពុទ្ធទំនាយសង្ខេបខាងលើនេះខ្ញុំចម្លងចេញតាមការចាំ ដោយខ្លួនខ្ញុំបានអានតាំងពីដើមទសវត្សទី ៦០ នៃ គ.ស.

និងតាមការនិទានប្រាប់នៃតាចាស់ៗខ្លះ ។ ចំពោះសករាជ ហាក់ដូចជាយកជាការមិនបានទេ ប្រហែលជាមានការបកស្រាយខុស ។ គួរស្រង់យកតែខ្លឹមសារ ជាការស្រេច អំពីពាក្យថា « ចិន » មានអ្នកខ្លះយល់ថាជាទេវតាក្លែងខ្លួនធ្វើជាជនជាតិចិន ព្រោះហេតុនោះហើយ ទើបបានជាខ្ញុំរក្សាអក្ខរាវិរុទ្ធទៅតាមន័យនៃពាក្យនោះទៅ ។ ចំណែកឯ « ក្បួនពុទ្ធទំនាយ » ស្ដីពីព្រះបាទធម្មិក ដែលលោក អ៊ុំ កេត ចម្លងចេញពីសាស្ត្រាស្លឹករឹតនោះ លោកបានសរសេរជា « ចិន្ត » វិញ គឺមានជើង « ត » ។ នេះប្រហែលលោករក្សាអក្ខរាវិរុទ្ធតាមច្បាប់ដើម ដូចជាឈ្មោះមនុស្សដែលមានន័យអ្វីពិសេសទៅវិញ ។ ត្រង់នេះ ស្រេចលើលោកអ្នកអានស្វែងយល់ជាបន្ថែមចុះ ។

***

## • ឆ្កួតបីប្រការ

លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង
អំពើពាលា ឆ្កួតនេះហៅមហា ឆ្កួតក្រៃកន្លង ។
ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងឆ្គង លោកពុំឱ្យសេព
ឱ្យវៀរជាម្ដង វាតែងឱ្យហ្មង ភ្លេចភ្លាំងស្មារតី ។
ឱ្យភ្លេចក្ដីគាប់ ភ្លេចទាំងខ្លួនស្លាប់ ភ្លេចសាស្ត្រសូស្ដី ភ្លេចសីលភ្លេចទាន
ភ្លេចញាណវុឌ្ឍិ ភ្លេចច្បាប់ប្រក្រតី ឆ្កួតបីប្រការ ។

ច្បាប់កូនចៅ

# វប្បធមិសន្តិភាព

## ពាក្យ ៤

* អង្គរថ្មីថ្មើង ដោយសារខ្មែរយើង ចេះសាងវប្បធមិ
រួបរួមសាមគ្គី មូលមីអបអរ ព្រលឹងវប្បធមិ
រឹងមាំមួនខ្លាំង ។

* ខ្មែរល្បីពេលនោះ មិនមែនដោយឈ្លោះ មិនមែនដោយច្បាំង
មិនមែនអាងទ័ព គ្រាប់រាប់រយឃ្លាំង ឈ្នះដោយកម្លាំង
ឈ្នះមិនយូរទេ ។

* ច្បាំងតែគ្នាឯង ជាតិគេមិនក្រែង លួចពេបជ្រាយជេរ
ឈាមខ្មែរហៀរហូរ ជោរដូចទន្លេ រីងជាតិគេ
លូតលាស់រាល់ថ្ងៃ ។

* គួរឈប់ឈ្លោះគ្នា ទុកអោយប្រជា បានសុខសេរី
រួបរួមសាមគ្គី កសាងទឹកដី វប្បធមិល្បាញល្បី
ទើបជាតិផុតព្រួយ ។

* ខ្មែរគ្រប់ជាន់ថ្នាក់ ត្រូវឈប់បែកបាក់ អួលអាក់បេះបួយ
ត្រូវប្រើភាសា វប្បធមិតែមួយ ហើយខំប្រឹងជួយ
ស្ទួយព្រលឹងជាតិ ។

* ខ្មែរមានព្រលឹង ពេលណាខ្មែរខឹង ត្រូវដឹងកុំឃ្លាត
ទឹកដល់សញ្ញា ជាប់ក្នុងទង់ជាតិ កុំបីចង្អៀត
ភ្លេចជាតិអោយសោះ ។

* ត្រូវរួមសាមគ្គី ផ្លូងមួយគ្មានពីរ ទើបជាតិបានរស់
តែត្រូវសាមគ្គី ដោយពិតដោយស្មោះ ព្រោះសាមគ្គីនោះ

មានច្រើនប្រាកដ ។

* សាមគ្គីអុកកែវ សាមគ្គីបាញ់ផែវ សាមគ្គីស៊ើយណាត់
ពេលបានផឹកស៊ី សាមគ្គីពេញមាត់ លុះពេលណាអត់
ក្បត់ចិត្តគ្នាភ្លាម ។

* សាមគ្គីព្រោះប្រាក់ សាមគ្គីព្រោះស័ក្តិ សាមគ្គីចុកឈាម
សំណូកសំណែន បត់បែនភ្លាមៗ សាមគ្គីរវាម
តាមតៀមលក់ស្រា ។

* សាមគ្គីពួកបក្ស សាមគ្គីប្រឡាក់ ដោយមហិច្ឆតា
បញ្ជើចបញ្ជោរ អោយបួរដុល្លារ ហើយអួតអាងថា
គ្មានអ្នកណាដល់ ។

* សាមគ្គីច្រើនណាស់ អែបអបបោកប្រាស មានល្បិចមានកល
សាមគ្គីចាក់ខ្សែ ឡប់ឡែវិលវល់ សាមគ្គីដោះទ័ល
ស្គាល់ព្រោះតែប្រាក់ ។

* រីឯសាមគ្គី ដែលស្មោះជីវី ដល់ទីមរណៈ
មានតែសាមគ្គី ប្រជាគ្រប់ថ្នាក់ មួប់ទង់សច្ចៈ
ខឿនវប្បធម៌ជាតិ ។

* សាមគ្គីវប្បធម៌ ស្អិតជាប់ដូចជ័រ បិទផ្លូវប្រាសាទ
ច្រើនសតវត្សហើយ មិនរបេះឃ្លាត សាងសន្តិភាព
ជ្រួតជ្រាបពេញដី ។

* វប្បធម៌សន្តិភាព ព្រលឹងសត្វព្រាប លើមាតុភូមិជ័យ
គោរពលទ្ធិ ប្រជាធិបតេយ្យ សាងសិទ្ធិសេរី
ជូនប្រជាជន ។

គង្គ ប៊ុនឈឿន

# ញញឹមសន្តិភាព

## ពាក្យ ៤



ញញឹមបាយ័ន ញញឹមទន់ភ្លន់ សោភ័ណអង្គរ
ភក្រ្តាចតុស្តម្ភ ស្វាគមន៍ស្មោះសរ ឃាត់អ្នកទេសចរ
អោយឈរសម្លឹង ។

ញញឹមរាក់ទាក់ ញញឹមជឿជាក់ ឆ្លាក់ជាប់ព្រលឹង
ញញឹមខេមរា ក្លាហានរឹងប៉ឹង សម្លក់សម្លឹង

ញញឹមការពារ ទឹកដីកម្ពុជា ស្ថិតស្ថេរខ្ជាប់ខ្ជួន
កេរប្រពៃណី ទ្រឹស្ដីច្បាប់ក្បួន អោយខ្មែរភ្ញាក់ខ្លួន
កុំពួនយកសុខ ។

ញញឹមបាយ័ន ញញឹមសន្សំ ខន្តីប្អូនមុខ
មេត្តាករុណា មុទិតាឈ្នះសុខ ឧបេក្ខាសុខ
គ្មានទុក្ខញាប់ញ័រ ។

ញញឹមឧត្តម សាងសីលមនោគម ព្រហ្មវិហារធម៌
តគ្រប់ជំនាន់ មិនភ័ន្តប្រែពណ៌ ល្បីល្បាញខ្ចរខ្ច័រ
ជ្រោងវប្បធម៌ខ្មែរ ។

ស្នាមញញឹមត្រួត លាក់ទុកអំនួត មិនអួតពូកែ
តែអាចជ្រោងខ្ពស់ កេរ្តិ៍ឈ្មោះអោយខ្មែរ រាប់រយឆ្នាំខែ
ព្រោះតែញញឹម ។

បាយ័នសន្តិភាព ជ្រាលជ្រៅជ្រួតជ្រាប ប្រាប់ក្ដីសង្ឃឹម
អោយខ្មែរគ្រប់គ្នា ចេះប្រើញញឹម តាមក្ដីសង្ឃឹម
ញញឹមបាយ័ន ។

**គង្គ ប៊ុនឈឿន**

# បុណ្យខួប ៣០ ឆ្នាំ នៃការសោយព្រះទិវង្គត សម្តេចព្រះសង្ឃរាជ ជួន ណាត ( ជោតញ្ញាណោ )

២៥ កញ្ញា ១៩៦៩ - ២៥ កញ្ញា ១៩៩៩



សម្តេចព្រះរាម **បុប្ផាទេវី** ក្នុងពិធីប្រកាសបើកពិធីបុណ្យ ( រូបថត ពុទ្ធសាសនបណ្ឌិត្យ )

ថ្ងៃ ២៤ - ២៥ - ២៦ កញ្ញា ១៩៩៩ ពុទ្ធសាសនបណ្ឌិត្យ និងមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ បានសហការប្រារព្ធធ្វើពិធីបុណ្យខួប ៣០ ឆ្នាំ នៃការសោយព្រះទិវង្គតសម្តេចព្រះសង្ឃរាជ **ជួន ណាត** យ៉ាងមហោឡារិក ក្រោមព្រះបរមរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់ នៃព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះរាជអគ្គមហេសី **មុនីនាថ**

**សីហនុ** ជាទីសក្ការៈ ដើម្បីរំលឹកឧបការគុណដែលព្រះអង្គមានចំពោះប្រទេស-ជាតិ ទាំងខាងវិស័យវប្បធម៌ អប់រំ សាសនា និងនយោបាយ ។

នេះជាលើកទី ១ ហើយដែលពិធីបុណ្យរំលឹកខួបនៃការសោយព្រះទិវង្គត សម្តេចព្រះសង្ឃរាជ **ជួន ណាត** អ្នកប្រាជ្ញជាតិមួយអង្គ ក្នុងវិស័យពហុវិជ្ជា ត្រូវបានប្រារព្ធធ្វើឡើង ។ ទិសដៅចម្បងនៃសកម្មភាពនេះ គឺ ពញ្ញាក់ដាស់ស្មារតីកុលបុត្តកុលធីតាខ្មែរអោយស្គាល់ច្បាស់នូវអត្តសញ្ញាណជាតិរបស់ខ្លួន, ស្គាល់អ្នកប្រាជ្ញរបស់ខ្លួន តាមរយៈជីវប្រវត្តិ ស្នាព្រះហស្ត និងសកម្មភាពជាច្រើន ដែលបង្ហាញចេញពីការថ្លែងសុន្ទរកថា សិក្ខាសាលា ការតាំងពិព័រណ៍សិល្បៈ ព្រមទាំងគំនូរផ្សាយផ្សេងៗ ។

ពិធីបុណ្យនេះ បានប្រព្រឹត្តទៅនៅក្នុងបរិវេណនៃវិជ្ជាស្ថានពុទ្ធសាសន-បណ្ឌិត្យ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះរាជបុត្រីព្រះរាម **បុប្ផាទេវី** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា ដោយមានការនិមន្ត-អញ្ជើញចូលរួមច្រើនកុះករនៃមន្ត្រីសង្ឃជាន់ខ្ពស់ ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រ សមាជិករាជរដ្ឋាភិបាល សមណសិស្ស មន្ត្រីរាជការ សាស្ត្រាចារ្យ និស្សិតពុទ្ធបរិស័ទ និងមន្ត្រីអង្គការក្រៅរដ្ឋាភិបាល ។

មានព្រះសុវណ្ណីប្រកាសបើកពិធីបុណ្យ, សម្តេចព្រះរាម **បុប្ផាទេវី** ក្នុងនាមរាជរដ្ឋាភិបាល ទ្រង់សប្បាយព្រះទ័យ និងទ្រង់កោតសរសើរ នូវគំនិតផ្តួចផ្តើម អោយមានការជួបប្រជុំគ្នានិយាយរំលឹកពីព្រះកិត្តិគុណ និងព្រះកិត្តិយស របស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ជាអម្ចាស់ ដែលព្រះអង្គមានព្រះកិត្តិស័ព្ទ និងព្រះនាមដ៏ល្បីល្បាញ គឺសម្តេច ព្រះអង្គមាននាទីផ្តាច់គេក្នុងវិស័យចំណេះវិជ្ជា និងស្នាព្រះហស្ត ។

សម្តេចព្រះរាម ទ្រង់មានព្រះសុវណ្ណបញ្ជាក់ថា គឺដោយសារសម្តេចនេះហើយ ទើបព្រះពុទ្ធសាសនាយើងមានក្បួនខ្នាតសិក្សាត្រឹមត្រូវ ទើបអក្សរសាស្ត្រយើងមានទម្រង់ទាន់សម័យ ។ គឺព្រះអង្គសម្តេចព្រះសង្ឃរាជនេះហើយ ដែលជាឫសគល់នៃវឌ្ឍនភាពរបស់ភាសាខ្មែរ ដែលសំបូរទៅដោយពាក្យពេចន៍ប្រើប្រាស់ទៅតាមការចាំបាច់នៃសម័យថ្មី ។ សម្តេច ព្រះអង្គបានជួយស្រោចស្រង់ភាសាខ្មែរយើង អោយចៀសវាងបាននូវការគាំងដំណើររបស់ភាសាបុរាណជាច្រើន ។ ដូច្នេះសកម្មភាពទាំងឡាយដែលនឹងប្រព្រឹត្តឡើង នៅក្នុងពិធីបុណ្យរំលឹកខួប ៣០ ឆ្នាំ នៃការសោយព្រះទិវង្គតសម្តេចព្រះសង្ឃរាជ **ជួន ណាត** នាឱកាសនេះ គឺជាសក្ខីភាពនៃកតញ្ញូតាធម៌ ចំពោះព្រះអង្គ ។ សូមអោយសកម្មភាពបែបនេះបានបន្តទៅទៀតជារៀងរហូត ។

សកម្មភាពនៃពិធីបុណ្យជាបន្តបន្ទាប់ មាន ៖

- និន្តព្រះសង្ឃ ចំរើនព្រះបរិត្ត ទេសនា និងទទួលចង្ហាន់រាប់បាត្រ ។



ក្នុងពិធីចំរើនព្រះបរិត្ត និងទេសនា (រូបថត ពុទ្ធសាសនបណ្ឌិត្យ)

សម្តេចព្រះរាម ទ្រង់មានព្រះសុវណ្ណិបញ្ជាក់ថា គឺដោយសារសម្តេចនេះហើយ ទើបព្រះពុទ្ធសាសនាយើងមានក្បួនខ្នាតសិក្សាត្រឹមត្រូវ ទើបអក្សរសាស្ត្រយើងមានទម្រង់ទាន់សម័យ ។ គឺព្រះអង្គសម្តេចព្រះសង្ឃរាជនេះហើយ ដែលជាឫសគល់នៃវឌ្ឍនភាពរបស់ភាសាខ្មែរ ដែលសំបូរទៅដោយពាក្យពេចន៍ប្រើប្រាស់ទៅតាមការចាំបាច់នៃសម័យថ្មី ។ សម្តេច ព្រះអង្គបានជួយស្រោចស្រង់ភាសាខ្មែរយើង អោយចៀសវាងបាននូវការគាំងដំណើររបស់ភាសាបុរាណជាច្រើន ។ ដូច្នេះសកម្មភាពទាំងឡាយដែលនឹងប្រព្រឹត្តឡើង នៅក្នុងពិធីបុណ្យរំលឹកខួប ៣០ ឆ្នាំ នៃការសោយព្រះទិវង្គតសម្តេចព្រះសង្ឃរាជ **ជួន ណាត** នាឱកាសនេះ គឺជាសក្ខីភាពនៃកតញ្ញូតាធម៌ ចំពោះព្រះអង្គ ។ សូមអោយសកម្មភាពបែបនេះបានបន្តទៅទៀតជារៀងរហូត ។

សកម្មភាពនៃពិធីបុណ្យជាបន្តបន្ទាប់ មាន :

- និន្តព្រះសង្ឃ ចំរើនព្រះបរិត្ត ទេសនា និងទទួលចង្ហាន់រាប់បាត្រ ។



ក្នុងពិធីចំរើនព្រះបរិត្ត និងទេសនា ( រូបថត ពុទ្ធសាសនបណ្ឌិត្យ )



ក្នុងពិធីប្រគេនចង្ហាន់រាប់បាត្រព្រះសង្ឃ ៨៧ អង្គ (រូបថត ពុទ្ធសាសនបណ្ឌិត្យ)

- ដំណើរការសិក្ខាសាលា ស្ដីពី « សម្ដេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ** ១៨៨៣ - ១៩៦៩ មួយជីវិតដើម្បីព្រះពុទ្ធសាសនា វប្បធម៌ និងសន្តិភាព ( Smdech CHUON NATH 1883 - 1969 : A LIFE FOR BUDDHISM CULTURE AND PEACE ) » ដោយមានវាគ្មិនសំខាន់ៗ ជាព្រះសង្ឃ ជានាយកវិជ្ជាស្ថាន ជាព្រឹទ្ធបុរស ជាសាស្ត្រាចារ្យ ជានាយកអង្គការក្រៅរដ្ឋាភិបាល ឡើងថ្លែងយោបល់រំលឹកពី ព្រះកិត្តិគុណព្រះកិត្តិនាម, ពីគុំរូវិរិយភាព និងពីព្រះសកម្មភាពរបស់ព្រះអង្គ ចំពោះពុទ្ធសាសនា និងប្រទេសជាតិ ។

វាគ្មិនដែលបានបង្ហាញខ្លួន នៅក្នុងសិក្ខាសាលានោះ មាន

• ឯកឧត្តម *នុត ណារ៉ាង* : ថ្លែងចំណាប់អារម្មណ៍ទូទៅចំពោះកិត្តិគុណរបស់សម្ដេចព្រះសង្ឃរាជ *ជួន ណាត* ។




• លោក *ម៉ី យ៉ាំ* ៖ ថ្លែងពីព្រះរាជជីវប្រវត្តិរបស់សម្តេចព្រះសង្ឃរាជ *ជួន ណាត* និងគុំរូវិរិយភាពក្នុងជីវិត និងកង្វល់ចំពោះអនាគត ។

• លោក *យី ធន់* និងលោក *យូ ប៊ូ* ថ្លែងពី ៖

- សម្តេចព្រះសង្ឃរាជ *ជួន ណាត* និងវប្បធមិ អក្សរសាស្ត្រជាតិ
- សម្តេចព្រះសង្ឃរាជ និងសិល្បៈ កំណាព្យ

• លោកលោកស្រី *ជា វណ្ណាត* និងលោកស្រី *ធីតា ឃិះ* ថ្លែងពី ៖

- សម្តេចព្រះសង្ឃរាជ *ជួន ណាត* និងកិច្ចការសង្គម
- សម្តេចព្រះសង្ឃរាជ *ជួន ណាត* និងការអប់រំសីលធមិ

• សម្តេចព្រះមង្គលទេពាចារ្យ *អ៊ុម ស៊ុម* ព្រះពុទ្ធឃោសាចារ្យ *ហេង លាងហោ* និងព្រះភិក្ខុ ខេមចារោ *យស ហ៊ុត* ថ្លែងពី ៖

- សម្តេចព្រះសង្ឃរាជ *ជួន ណាត* និងកិច្ចការពុទ្ធសាសនា
- ក្រុមជំនុំព្រះត្រៃបិដក
- កិច្ចការរៀបចំពុទ្ធសាសនាឱ្យមានក្បួនខ្នាត

- ការរៀបចំពុទ្ធសាសនាឱ្យមានសណ្ដាប់ធ្នាប់ និងសេចក្ដីថ្លៃថ្នូរ
- ការរៀបចំពុទ្ធិកសិក្សា
- ការចាត់ចែងសៀវភៅសិក្សា

• លោកព្រឹទ្ធាចារ្យ *ឆេង ផុន* ថ្លែងពីគុណធម៌របស់សម្ដេច និងរួមយោបល់ពិភាក្សាអំពីគម្រោងបង្កើតមូលនិធិ សម្ដេច *ជួន ណាត* ។



- រាល់យប់ មានសំដែងទស្សនីយភាពល្ខោន យីកេ ដោយមានទស្សនិកជនចូលរួមទស្សនាយ៉ាងច្រើន ។

*

នៅថ្ងៃបិទពិធីបុណ្យ, ឯកឧត្ដម *សុខ អាន* ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី ជាដំណាងដ៏ខ្ពង់ខ្ពស់ នៃសម្ដេចនាយករដ្ឋមន្ត្រី *ហ៊ុន សែន* និងលោកជំទាវ បានមានប្រសាសន៍ថា ៖ សម្ដេចព្រះសង្ឃរាជ *ជួន ណាត* ក្នុងជីវិតរបស់ព្រះអង្គ គឺបានបូជាសំរាប់ព្រះពុទ្ធសាសនា វប្បធម៌ និងសន្តិភាព ។ ព្រះអង្គជា

បុគ្គលម្នាក់ ដែលទប់ទល់គំនិតជ្រុលនិយម ហើយយកព្រះទ័យទុកដាក់ធ្វើកិច្ចសហ-ប្រតិបត្តិការអន្តរជាតិ ទាំងនៅក្នុងស្រុក ទាំងនៅនៅក្រៅស្រុក ។ ព្រះអង្គជាអ្នកប្រាជ្ញកំពូល ដែលបានទទួលជាសាស្ត្រាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ នាឆ្នាំ ១៩១៥ និងជាលេខាធិការនៃក្រុមជំនុំតែងវចនានុក្រមខ្មែរ ។ វចនានុក្រមខ្មែរ ជាស្នាព្រះហស្តផ្ទាល់របស់ព្រះអង្គ ដែលបានបោះពុម្ពផ្សាយតាមរយៈពុទ្ធសាសនបណ្ឌិត្យ តាំងពីឆ្នាំ ១៩២៥ . ១៩៦០ ។

ឯកឧត្តម *សុខ អាន* បានមានប្រសាសន៍បញ្ជាក់ទៀតថា ក្រៅពីអត្ថបទជាច្រើន ដែលព្រះអង្គផ្សាយតាមកម្ពុជសុរិយា ព្រះអង្គជាម្ចាស់សៀវភៅ ចំនួន ២០ ចំណងជើង ទាំងខ្មែរ ទាំងបាលី ដែលភាគច្រើនពាក់ព័ន្ធទៅនឹងព្រះពុទ្ធសាសនា ភាសាខ្មែរ និងប្រវត្តិសាស្ត្រខ្មែរ ។ ព្រះអង្គជាអ្នកតាក់តែងបទភ្លេង និងចម្រៀង « នគររាជ » ភ្លេងជាតិសព្វថ្ងៃ ។



សម្តេច ជួន ណាត មួយជីវិតដើម្បីពុទ្ធសាសនា វប្បធម៌ និងសន្តិភាព ( រូបថត ព.ប. )



ពុទ្ធសាសនបណ្ឌិត្យ ក្នុងការស្តារវិស័យពុទ្ធសាសនា និងសីលធមិសង្គម (រូបថត ព.ប.)



ស្តង់ពិព័រណ៍ស្តីពីសិប្បកម្មផលិតសម្ភារៈ និងវប្បធមិ (រូបថត ពុទ្ធសាសនបណ្ឌិត្យ)